ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជា និង នីតិវិធី

## សម្រាប់

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី ២

[ ថ្ងៃអាទិត្យ ទី១៨ ខែឧសភា ឆ្នាំ២០១៤ ]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ០៥៤/១៤ គ.ជ.ប

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១២/៩៤៥ ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១២ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ៤៣ ស.ស.រ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតលើកទី ២ ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញការអនុម័តរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៤ លើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

## ប្រកាស

**ប្រការ ១ :** ឱ្យប្រើជាផ្លូវការនូវបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី ២ នាថ្ងៃ អាទិត្យ ទី ១៨ ខែ ឧសភា ឆ្នាំ ២០១៤ ដែលមាន ៣ ជំពូក ១៣ ផ្នែក និងឧបសម្ព័ន្ធទាំង ១១ ។

**ប្រការ ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងបទបញ្ជា និងនីតិវិធីនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៤

ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម សូស៊ី

# មាតិកា

ទំព័រ


**ជំពូកទី ១._ បទប្បញ្ញត្តិទូទៅ** .................... ០១

**ជំពូកទី ២._ អំពីការបោះឆ្នោត** .................... ០៣

**ផ្នែកទី ១._ ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា** .................... ០៣

- សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត .................... ០៣
- សមាសភាពនៃ គ.ជ.ប .................... ០៣
- ករណីបាត់បង់មុខតំណែងជាសមាសភាពនៃ គ.ជ.ប .................... ០៣
- លក្ខណវិនិច្ឆ័យនិងការតែងតាំងសមាជិក គ.ជ.ប .................... ០៤
- រចនាសម្ព័ន្ធនៃ គ.ជ.ប .................... ០៤
- សិទ្ធិអំណាចរបស់ គ.ជ.ប .................... ០៥
- ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត .................... ០៨
- រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់ គ.ជ.ប ក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោត .................... ០៨
- រចនាសម្ព័ន្ធនៃ គធ/ខប .................... ០៩
- លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ/ខប .................... ១០
- ភារកិច្ច និងការទទួលខុសត្រូវនៃ គធ/ខប .................... ១១
- សមាសភាពនៃគណៈកម្មការការិយាល័យបោះឆ្នោត (គកប) .................... ១៣
- លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គកប .................... ១៤
- ភារកិច្ច និងការទទួលខុសត្រូវរបស់ គកប .................... ១៦
- នីតិវិធីនៃការជ្រើសរើសសមាជិក មន្ត្រីបុគ្គលិកនៃ គ.ជ.ប .................... ២២
- អាណត្តិរបស់គណៈកម្មាធិការ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ .................... ២៦
- ការតែងតាំងក្នុងរយៈពេលមានកំណត់ .................... ២៦
- ប្រាក់កំរៃរបស់សមាជិក និងបុគ្គលិក .................... ២៦
- ការដាក់ពិន័យ ការព្យួរការងារ ការបណ្តេញចេញពីការងារ ចំពោះបុគ្គលិក ឬសមាជិកគណៈកម្មការ .................... ២៧
- គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខារនៃ គ.ជ.ប .................... ២៧
- ប្រតិទិនការងារបោះឆ្នោត .................... ២៧
- ការងារសន្តិសុខបោះឆ្នោត .................... ២៨

**ផ្នែកទី ២._ ប្រព័ន្ធបោះឆ្នោត និងរូបមន្ត** ........................................ ៣១
- ប្រព័ន្ធបោះឆ្នោត ........................................ ៣១
- រូបមន្តនៃការបែងចែកអាសនៈ ........................................ ៣១
- ករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន...... ៤២
- ករណីលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងគណបក្សនយោបាយ មួយចំនួន ........................................ ៤៧
- ការចាប់ឆ្នោតជាសាធារណៈ ........................................ ៥០
- ការប្រកាសឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងការកំណត់បេក្ខជនជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ........................................ ៥២

**ផ្នែកទី ៣._ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ** .៥៥
- ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ........................................ ៦០
- ការពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត..... ៦០
- ការចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ........ ៦៣

**ផ្នែកទី ៤._ បញ្ជីបោះឆ្នោត** ........................................ ៦៦
- អ្នកបោះឆ្នោត ........................................ ៦៦
- លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ........................................ ៦៧
- សង្ខេបដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ........................................ ៦៧
- រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ........................................ ៦៨
- ការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ........................................ ៦៩
- សម្ភារឯកសារសម្រាប់បម្រើកិច្ចប្រតិបត្តិការចុះឈ្មោះបោះឆ្នោត ........................................ ៧១
- ការចុះឈ្មោះបោះឆ្នោត និងការរៀបចំនិងបញ្ជូនបញ្ជីបោះឆ្នោត មក គ.ជ.ប ......... ៧១
- ការប្រគល់ ទទួលបញ្ជីបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតដំបូងដោយកុំព្យូទ័រនៅ គ.ជ.ប ........................................ ៧៧
- ការបញ្ជូន និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ........................................ ៧៩
- ការដាក់/ទទួល និងដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូង ........................................ ៨១
- ការផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ ........................................ ៨៦
- លក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ........................................ ៩១

**ផ្នែកទី ៥._ ការិយាល័យបោះឆ្នោត** ........ ៩៣
_ ការិយាល័យបោះឆ្នោត........ ៩៣
_ វិធានការសន្តិសុខសម្រាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត........ ៩៤
_ ការផ្សព្វផ្សាយបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យ បោះឆ្នោត និងរាប់សន្លឹកឆ្នោត........ ៩៨
**ផ្នែកទី ៦._ ការឃោសនាបោះឆ្នោត** ........ ១០០
_ បញ្ញត្តិទូទៅ........ ១០០
_ សម្ភារអប់រំអ្នកបោះឆ្នោត........ ១០៩
_ រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ........ ១១២
_ ភារកិច្ច និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន........ ១២០
**ផ្នែកទី ៧._ ការបោះឆ្នោត** ........ ១២១
_ សម្ភារឯកសារបោះឆ្នោតដែល គ.ជ.ប ត្រូវផ្គត់ផ្គង់ និងការត្រួតពិនិត្យរបស់ គកប លើសម្ភារឯកសារបោះឆ្នោតដែលបានទទួល និងទីតាំងការិយាល័យ បោះឆ្នោត........ ១២១
_ ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត........ ១២៨
_ ការប្រព្រឹត្តទៅនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត........ ១២៩
_ ការបិទការបោះឆ្នោត នៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត........ ១៤៩
**ផ្នែកទី ៨._ ការរាប់សន្លឹកឆ្នោត និងលទ្ធផលនៃការបោះឆ្នោត** ........ ១៥៦
_ ការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត........ ១៥៦
_ សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ........ ១៦៦
_ ការរៀបចំ និងការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់ សន្លឹកឆ្នោត និងសម្ភារឯកសារបោះឆ្នោតពាក់ព័ន្ធ........ ១៦៩
_ ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ ទៅ គធ/ខប........ ១៧៤
_ ការរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាននៃ គធ/ខប ឬទីកន្លែងមានសុវត្ថិភាព ដែលកំណត់ដោយ គ.ជ.ប........ ១៧៨
_ ការដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការ រាប់សន្លឹកឆ្នោត និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឬ/និង រាជធានី ខេត្ត ទៅ គធ/ខប........ ១៨១

- កិច្ចប្រតិបត្តិការរបស់ គធ/ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ........ ១៩០
- ការកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ........ ២០២
- ការវេចខ្ចប់ " យពិសេស " កញ្ចប់ " យ " ដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ បញ្ជូនទៅ គ.ជ.ប ........ ២០៧
- ការដាក់ពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់នៅ គ.ជ.ប ពាក់ព័ន្ធនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ........ ២១៦
- ការបង្កើតក្រុមទទួលសម្ភារឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិ បម្រើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា........ ២១៨
- ការប្រគល់ និងការទទួលកញ្ចប់ " យ " និងកញ្ចប់ " យពិសេស " ដាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងសម្ភារឯកសារបោះឆ្នោតពាក់ព័ន្ធទៅទីស្ដីការ គ.ជ.ប ........ ២២៦
- កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមបែងចែកអាសនៈ........ ២៣០
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាដែល គធ/ខប បានសម្រេចព្យួរលទ្ធផលជាបណ្ដោះអាសន្ន........ ២៣៣
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅការិយាល័យបោះឆ្នោតដែលគ្មានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គធ/ខប ឬ/និង គ.ជ.ប ........ ២៣៩
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅការិយាល័យបោះឆ្នោតដែលមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គ.ជ.ប ឬ/និង ត្រូវបានដាក់នៅ គធ/ខប ហើយដែលមានកញ្ចប់សុវត្ថិភាព " **ត** " មួយ ឬច្រើន ត្រូវបានបើកត្រួតពិនិត្យ និងរាប់សន្លឹកឆ្នោតឡើងវិញ ........ ២៤៦

**ផ្នែកទី ៩._ ការបោះឆ្នោតសាជាថ្មី** ..................................... ២៥៣

_ ការបិទការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន ..................... ២៥៣

_ ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីកាលៈទេសៈមានអាសន្ន ឬដែលលទ្ធផលនៃកាបោះឆ្នោត ត្រូវបានបដិសេធដោយ គ.ជ.ប ..................... ២៥៦

**ផ្នែកទី ១០._ ការដាក់ជំនួសក្រុមប្រឹក្សា** ..................................... ២៦០

**ផ្នែកទី ១១._ សមត្ថកិច្ច និងនីតិវិធីដោះស្រាយវិវាទក្នុងការបោះឆ្នោត និងនីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយបណ្តឹងចំពោះគ្រប់អំពើល្មើសបោះឆ្នោតដែលអាចនាំឱ្យមានការផ្តន្ទាទោស** ..................................... ២៦១

_ សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត ..................... ២៦១

_ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សារ ឬ ក្រុមប្រឹក្សាជំនុំជម្រះ ..................... ២៦១

_ ការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ..................... ២៦៣

_ ការដកពាក្យបណ្តឹង ..................... ២៦៤

_ ការរួមបញ្ចូលរឿងក្តី ..................... ២៦៥

_ សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹង ចុងចម្លើយ អ្នកតំណាង ឬមេធាវី ..................... ២៦៥

_ សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ..................... ២៦៧

_ នីតិវិធីប្រជុំផ្សះផ្សា ឬសវនាការ ..................... ២៦៨

_ នីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយបណ្តឹងចំពោះគ្រប់អំពើល្មើសដែលអាចនាំឱ្យមានការផ្តន្ទាទោស ..................... ២៧៦

**ផ្នែកទី ១២._ ការបោះឆ្នោតឡើងវិញ** ..................................... ២៨៦

**ផ្នែកទី ១៣._ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន** ..................... ២៩១

_ តំណាងគណបក្សនយោបាយ ..................... ២៩១

_ អ្នកសង្កេតការណ៍បោះឆ្នោត ..................... ២៩៤

_ អ្នកសង្កេតការណ៍ជាតិ ..................... ២៩៤

_ អ្នកសង្កេតការណ៍អន្តរជាតិ ..................... ២៩៩

_ អ្នកយកព័ត៌មានជាតិ និងអន្តរជាតិ ..................... ៣០០

**ជំពូកទី ៣._ អំពីថវិកា** ..................................... ៣០៤

# ឧបសម្ព័ន្ធ

១_ នីតិវិធីស្តីពីការដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ សម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ........ ៣០៨

២_ ក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ........ ៣១២

៣_ ក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត........ ៣២០

៤_ ក្រមសីលធម៌ សម្រាប់មន្ត្រីបោះឆ្នោត........ ៣២៦

៥_ ក្រមសីលធម៌ សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ........ ៣៣៤

៦_ គោលការណ៍ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន........ ៣៤៨

៧_ សម្ភារ ឯកសារបោះឆ្នោត ដែលត្រូវប្រគល់ជូន គធ/ខប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល........ ៣៥១

៨_ សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឧបករណ៍ និងឯកសារផ្សេងទៀត ដែល គធ/ខប ត្រូវប្រគល់ជូន គកប នីមួយៗ........ ៣៥៣

៩_ បទល្មើស និងទណ្ឌកម្ម ដែលជាកម្មវត្ថុនៃការផ្តន្ទាទោសក្នុងជំពូកទី៤ នៃ ច.ប.ក និងតាមនីតិវិធី ជំពូកទី១១ នៃ ច.ប.ត.រ........ ៣៥៥

១០_ បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយបណ្តឹង........ ៣៥៩

១១_ ខ្លឹមសារនៃសម្បថ........ ៣៦០

# អក្សរកាត់

## (ACRONYM)

| | | |
|---|---|---|
| ១_ | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២_ | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គជ/ខប |
| ៣_ | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ/ស |
| ៤_ | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ/សប |
| ៥_ | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គកប/គករ |
| ៦_ | ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ៧_ | ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ឃ.ស |
| ៨_ | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ប.ន.ត.រ |
| ៩_ | ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | ច.ប.ក |
| ១០_ | ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ច.គ.ខ.ស |
| ១១_ | បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | ប.ន.ក |

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**ប្រការ ១.១** អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ច.ប.ក) និងតាមរយៈក្របខ័ណ្ឌអំណាច ដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានសិទ្ធិ និងភារកិច្ចរៀបចំបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ប.ន.ក) ដែលកំណត់អំពីការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ព្រមទាំងការកំណត់អំពីការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងបញ្ជីបោះឆ្នោត ។ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហៅកាត់ថា " ក្រុមប្រឹក្សា " ។

**ប្រការ ១.២** អនុលោមតាមមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ច.គ.ខ.ស) ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រដូចខាងក្រោម ៖

១.២.១ ក្រុមប្រឹក្សារាជធានីភ្នំពេញមានចំនួនសមាជិកមិនលើសពីម្ភៃមួយ (២១) រូប ។

១.២.២ ក្រុមប្រឹក្សាខេត្តមានចំនួនសមាជិកពីប្រាំបួន (០៩) ដល់ម្ភៃមួយ (២១) រូប ។

១.២.៣ ក្រុមប្រឹក្សាក្រុងមានចំនួនសមាជិកពីប្រាំពីរ (០៧) ដល់ដប់ប្រាំ (១៥) រូប ។

១.២.៤ ក្រុមប្រឹក្សាស្រុក ខណ្ឌមានចំនួនសមាជិកពីប្រាំពីរ (០៧) ដល់ដប់ប្រាំបួន (១៩) រូប ។

**ប្រការ ១.៣** ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០) ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

១.៣.១ ក្នុងករណីគ្មានអនុក្រឹត្យចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

១.៣.២ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី ២ ចំនួនសមាជិកក្រុមប្រឹក្សា ត្រូវកំណត់ក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ (១២០) ថ្ងៃ មុនថ្ងៃបោះឆ្នោត ដោយអនុលោមតាមក្រោមប្រការ ១.២ ខាងលើ ។

**ប្រការ ១.៤** សមាជិកក្រុមប្រឹក្សា ត្រូវជ្រើសរើសឡើងដោយការបោះឆ្នោតអសកល មិនចំពោះ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងមុខតំណែង គឺជាអ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សា ។

**ប្រការ ១.៥** អនុលោមតាមមាត្រា ៤ និងមាត្រា ៥ នៃ ច.គ.ខ.ស រាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម ៖

១.៥.១ ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។ រាជធានីភ្នំពេញ ចែកជាខណ្ឌ ។ ខណ្ឌ ចែកជាសង្កាត់ ។

១.៥.២ ខេត្ត ចែកជាក្រុង និងជាស្រុក ។ ក្រុង ចែកជាសង្កាត់ ។ ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**ប្រការ ១.៦** មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ ត្រូវបានរៀបចំតាម រាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ។ មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗរួមមាន ៖

១.៦.១ រាជធានី ខេត្ត ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

១.៦.២ ក្រុង ស្រុក ខណ្ឌ ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

១.៦.៣ ករណីមានការបង្កើតខេត្ត ក្រុង ស្រុក ខណ្ឌថ្មី ដែលជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ តែពុំទាន់មានការរៀបចំ និងចាត់តាំងក្បាលម៉ាស៊ីនដឹកនាំ និងរចនាសម្ព័ន្ធរដ្ឋបាលនៅឡើយ រដ្ឋបាលដែលធ្លាប់ដឹកនាំ និងចាត់ចែងពីមុនត្រូវបន្តអនុវត្តការងាររដ្ឋបាលនានាពាក់ព័ន្ធនឹងការបោះឆ្នោត រហូតដល់មានការរៀបចំក្បាលម៉ាស៊ីនដឹកនាំ និងរចនាសម្ព័ន្ធរដ្ឋបាល នៅមណ្ឌលបោះឆ្នោតទាំងនោះ ។

**ប្រការ ១.៧** អាណត្តិរបស់ក្រុមប្រឹក្សាមានប្រាំ (០៥) ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

**ប្រការ ១.៨** ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើតែមួយថ្ងៃ នៅថ្ងៃអាទិត្យណាមួយ រៀងរាល់ប្រាំ (៥) ឆ្នាំម្តង។

១.៨.១ កាលបរិច្ឆេទជាក់ស្តែងនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

១.៨.២ កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទីមួយ (០១) ត្រូវធ្វើឡើងក្នុងរយៈពេលដប់ពីរ (១២) ខែយ៉ាងយូរ បន្ទាប់ពី ច.ប.ក ចូលជាធរមាន ។

# ជំពូកទី ២

# អំពីការបោះឆ្នោត

## ផ្នែកទី ១

## ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

**សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត**

**ប្រការ ២.១** អនុលោមតាម មាត្រា ៩ និងមាត្រា ១០ នៃ ច.ប.ក គ.ជ.ប ជាអង្គការឯករាជ និងអព្យាក្រឹតក្នុងការអនុវត្តសមត្ថកិច្ចរបស់ខ្លួន និងមានសមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១.១ គ.ជ.ប ប្រើប្រាស់សិទ្ធិអំណាច ដូចមានចែងក្នុង ច.ប.ត.រ សម្រាប់គ្រប់គ្រងការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១.២ គ.ជ.ប ត្រូវកំណត់បទបញ្ជា និងនីតិវិធីពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា បន្ថែមលើភារកិច្ចបច្ចុប្បន្នរបស់ខ្លួន ។

**សមាសភាពនៃ គ.ជ.ប**

**ប្រការ ២.២** សមាសភាព គ.ជ.ប ដែលត្រូវបានកំណត់ដោយមាត្រា ១៣ថ្មី (ពីរ) នៃ ច.ប.ត.រ មានដូចតទៅ ៖

២.២.១ ឥស្សរជនខ្មែរមួយ (១) រូប ជាប្រធាន

២.២.២ ឥស្សរជនខ្មែរមួយ (១) រូប ជាអនុប្រធាន

២.២.៣ ឥស្សរជនខ្មែរប្រាំពីរ(៧) រូប ជាសមាជិក

**ករណីបាត់បង់មុខតំណែងជាសមាសភាពនៃ គ.ជ.ប**

**ប្រការ ២.៣** ប្រធាន ឬអនុប្រធាន ឬសមាជិកនៃ គ.ជ.ប ត្រូវបាត់បង់មុខតំណែងក្នុងករណីណាមួយដូចខាងក្រោម ៖

២.៣.១ សាមីខ្លួនទទួលមរណភាព ។

២.៣.២ សាមីខ្លួនលាឈប់ជាលាយលក្ខណ៍អក្សរ ។

២.៣.៣ សាមីខ្លួនបានបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។

២.៣.៤ សាមីខ្លួនប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

ការសម្រេចបណ្តេញពីប្រធាន ឬអនុប្រធាន ឬសមាជិក គ.ជ.ប ជាសមត្ថកិច្ចរបស់រដ្ឋសភា ។

**លក្ខណវិនិច្ឆ័យ និងការតែងតាំងសមាជិក គ.ជ.ប**

**ប្រការ ២.៤** លក្ខណវិនិច្ឆ័យដើម្បីជ្រើសរើសសមាជិករបស់ គ.ជ.ប ត្រូវបានកំណត់ដោយមាត្រា ១៣ថ្មី (ពីរ) នៃ ច.ប.ត.រ ។

២.៤.១ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនខ្មែរ ដែលមានសមត្ថភាពខាងនយោបាយ មានពិសោធន៍ក្នុងការងារ និងមានកេរ្តិ៍ឈ្មោះល្អ ។

២.៤.២ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលជាសមាជិកនៃគណបក្សនយោបាយ ឬ/និងជាអ្នកស្ថិតនៅក្នុងជួរអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាគម សហជីព ឬ/និងជាមន្ត្រីរាជការ ក្រោយពីទទួលបានការតែងតាំងក្នុង គ.ជ.ប ត្រូវសុំលាលែងជាស្ថាពរពីគណបក្សនយោបាយ ឬ/និងពីជួរអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សមាគម សហជីព ឬ/និងដាក់ពាក្យសុំទៅបម្រើការងារនៅក្រៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់អាណត្តិ ។

**ប្រការ ២.៥** សេចក្តីព្រាងសមាសភាពនៃ គ.ជ.ប ត្រូវបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងដាក់ជូនគណៈរដ្ឋមន្ត្រី ដើម្បីបន្តលើកសំណើសុំការទុកចិត្តពីរដ្ឋសភា ។

២.៥.១ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់គណៈរដ្ឋមន្ត្រីក្រោយពីបានទទួលការយល់ព្រមពីរដ្ឋសភា តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

២.៥.២ ប្រធាន អនុប្រធាន និងសមាជិកនៃ គ.ជ.ប ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ។

**រចនាសម្ព័ន្ធនៃ គ.ជ.ប**

**ប្រការ ២.៦** រចនាសម្ព័ន្ធរបស់ គ.ជ.ប ត្រូវអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលបានអនុម័តនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។ រចនាសម្ព័ន្ធរបស់ គ.ជ.ប រួមមានសមាជិក គ.ជ.ប និងអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ។

២.៦.១ គ.ជ.ប អាចបង្កើតអនុគណៈកម្មការសម្របសម្រួល និងអនុគណៈកម្មការចំពោះកិច្ច ដើម្បីត្រួតពិនិត្យការងាររបស់អគ្គលេខាធិការដ្ឋាន ហើយត្រូវរាយការណ៍អំពីបញ្ហា ដែលមានជូន គ.ជ.ប ។ អនុគណៈកម្មការនេះត្រូវបង្កើតស្របតាមប្រការ ៨ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.៦.២ គ.ជ.ប ត្រូវមានអគ្គលេខាធិការ ដែលមិនមែនជាសមាជិក គ.ជ.ប ធ្វើជាសេនាធិការ ដើម្បីអនុវត្តការរៀបចំការបោះឆ្នោត ហើយត្រូវទទួលខុសត្រូវចំពោះមុខ គ.ជ.ប ។ អគ្គលេខាធិការ មានអគ្គលេខាធិការរងជាជំនួយ ។

២.៦.៣ គ.ជ.ប ត្រូវបង្កើតនាយកដ្ឋានចំនួនប្រាំ (៥) ដើម្បីអនុវត្តការងារបោះឆ្នោត ។

២.៦.៤ នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធានមួយ (១) រូប និងមានអនុប្រធានយ៉ាងតិចមួយ (១) រូបជាជំនួយ ។

២.៦.៥ ប្រធាននាយកដ្ឋានត្រូវទទួលខុសត្រូវចំពោះមុខអគ្គលេខាធិការ ។

២.៦.៦ អនុប្រធាននាយកដ្ឋានត្រូវទទួលខុសត្រូវចំពោះមុខប្រធាននាយកដ្ឋាន ។

២.៦.៧ នាយកដ្ឋាននីមួយៗត្រូវបែងចែកជាការិយាល័យ ។ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានមួយ (១) រូប និងអនុប្រធានជាជំនួយតាមការកំណត់របស់ គ.ជ.ប ។

**សិទ្ធិអំណាចរបស់ គ.ជ.ប**

**ប្រការ ២.៧** គ.ជ.ប មានសិទ្ធិពេញលេញក្នុងការអនុវត្តការងារទាក់ទងនឹងការបោះឆ្នោត ក្នុងសមត្ថកិច្ចរបស់ខ្លួន ដែលតម្រូវដោយច្បាប់ ។ ផ្អែកលើសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវដែលមានស្រាប់បច្ចុប្បន្ននេះ សិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវទាក់ទងទៅនឹងការកសាងផែនការ ការរៀបចំបែបបទ ការចាត់ចែង និងការត្រួតពិនិត្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមានដូចតទៅ ៖

២.៧.១ ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តាមរយៈការបោះឆ្នោតអសកល មិនចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

២.៧.២ រៀបចំគំរោងផែនការការងារ ថវិកា និងសម្ភារបំរើឱ្យការបោះឆ្នោត ព្រមទាំងផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត ។

២.៧.៣ តែងតាំងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ/ខប) និងគណៈកម្មការការិយាល័យបោះឆ្នោត ( គកប ) ។

២.៧.៤ ធ្វើបទបញ្ជា និងនីតិវិធី និងសេចក្តីណែនាំនានា សម្រាប់ដំណើរការបោះឆ្នោតក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

២.៧.៥ លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

២.៧.៦ ត្រួតពិនិត្យការងាររបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

២.៧.៧ កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

២.៧.៨ ចេញសេចក្តីសម្រេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.៧.៩ ផលិត និងបែងចែកសម្ភារបរិក្ខារបំរើឱ្យការងារបោះឆ្នោត ។

២.៧.១០ លើកសំណើដាក់ជូនក្រសួងមហាផ្ទៃ ដើម្បីធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យជួយបំពេញការងារស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដើម្បីបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោត ស្របតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងច្បាប់ ។

២.៧.១១ រៀបចំបញ្ជីបោះឆ្នោត ។

២.៧.១២ ពិនិត្យ និងផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ ។

២.៧.១៣ ទទួល និងសម្រេចលើពាក្យសុំឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ និងការឈរឈ្មោះជាបេក្ខជនតាមប្រភេទក្រុមប្រឹក្សានីមួយៗរបស់គណបក្សនយោបាយ ។

២.៧.១៤ ត្រួតពិនិត្យ និងសម្របសម្រួលការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោត ។

២.៧.១៥ រៀបចំ និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផល ។

២.៧.១៦ ដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬផ្តល់សិទ្ធិបោះឆ្នោតឡើងវិញ ។ ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។ លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះឡើងវិញ ។

២.៧.១៧ ត្រួតពិនិត្យចំណូល ចំណាយក្នុងពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ ។

២.៧.១៨ ចាត់វិធានការ និងសម្របសម្រួល ដើម្បីឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ តាមគោលការណ៍ស្មើភាព ។

២.៧.១៩ ផ្តល់ព័ត៌មានអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោតដល់គណបក្សនយោបាយ និងបេក្ខជន និងទទួលសំណើនានាទាក់ទងនឹងការងារបោះឆ្នោត ។

២.៧.២០ ធានាឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលជាប្រចាំអំពីកិច្ចការបោះឆ្នោតរវាង គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ជាមួយគណបក្សនយោបាយ បេក្ខជន និងអ្នកដែលពាក់ព័ន្ធនានា ។

២.៧.២១ ផលិតឯកសារផ្សព្វផ្សាយអំពីការងារបោះឆ្នោត ។

២.៧.២២ លើកកំពស់ការយល់ដឹងរបស់អ្នកបោះឆ្នោត និងអ្នកពាក់ព័ន្ធ អំពីការងារបោះឆ្នោតតាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងតាមមធ្យោបាយផ្សេងៗទៀត ។

២.៧.២៣ រៀបចំឯកសារ កម្មវិធី និងបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត ។

២.៧.២៤ ពិនិត្យសម្រេច និងចេញប័ណ្ណសម្គាល់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ។

២.៧.២៥ ត្រួតពិនិត្យភាពត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការអនុវត្តការងារបោះឆ្នោត ។

២.៧.២៦ សម្រេចដោយបើកសវនាការជាសាធារណៈលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត លើកលែងតែបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

២.៧.២៧ បង្ការ និងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត ។

២.៧.២៨ រៀបចំគណៈកម្មការដើម្បីបំផ្លាញសន្លឹកឆ្នោត ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមអាណត្តិនីមួយៗ បន្ទាប់ពីបានរក្សាទុកដោយសុវត្ថិភាពនូវសន្លឹកឆ្នោតទាំងនោះ រយៈពេលបួន (៤) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោតតាមអាណត្តិនីមួយៗ ដោយមានការចូលរួមពីតំណាងគណបក្សនយោបាយ ដែលមានអាសនៈក្នុងក្រុមប្រឹក្សា ។

២.៧.២៩ អនុវត្តការងារដទៃទៀតដែលច្បាប់ និងបទបញ្ជាអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

**ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត**

**ប្រការ ២.៨** យោងតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ច.ប.ក គ.ជ.ប អាចប្រគល់សិទ្ធិទៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឬទៅមន្ត្រីបោះឆ្នោតណាម្នាក់ ដើម្បីអនុវត្តការងារបោះឆ្នោត ។

២.៨.១ គ.ជ.ប អាចប្រគល់សិទ្ធិជូន គធ/ខប ឬមន្ត្រីបោះឆ្នោតណាម្នាក់ ដែលបានតែងតាំងឱ្យបំពេញការងារមួយចំនួន តាមការចាំបាច់ ។

២.៨.២ គ.ជ.ប ត្រូវធ្វើប្រតិភូកម្មអំណាចដល់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាង ឱ្យជួយអនុវត្តការស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដើម្បីរៀបចំបញ្ជីបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៨.៣ ផ្អែកតាមការចាំបាច់ គ.ជ.ប អាចប្រគល់សិទ្ធិទៅ គកប ដែលត្រូវបានតែងតាំងតាមសំណើរបស់ គធ/ខប ។

**រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់ គ.ជ.ប ក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោត**

**ប្រការ ២.៩** គធ/ខប ជាអង្គភាពរដ្ឋបាលថ្នាក់ក្រោមរបស់ គ.ជ.ប នៅក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ ដោយឡែក ក្នុងការចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាង

ដែលត្រូវបានប្រគល់សិទ្ធិ ត្រូវអនុវត្តសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្មឱ្យដោយ គ.ជ.ប និងដែលមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

២.៩.១ គធ/ខប គឺជាផ្នែករដ្ឋបាលថ្នាក់ក្រោមមួយ របស់ គ.ជ.ប ដែលបំពេញការងារតាមការប្រគល់សិទ្ធិ ដោយ គ.ជ.ប ។

២.៩.២ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាង ដែលត្រូវបាន គ.ជ.ប ធ្វើប្រតិភូកម្មអំណាចឱ្យបំពេញតួនាទីជាតំណាងខ្លួន ក្នុងការស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងដើម្បីបោះឆ្នោត ត្រូវទទួលការណែនាំ និងការសម្របសម្រួលអនុវត្តការងារពី គ.ជ.ប តាមរយៈ គធ/ខប ។

**រចនាសម្ព័ន្ធនៃ គធ/ខប**

**ប្រការ** ២.១០ គធ/ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលត្រូវបានបង្កើតដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំការបោះឆ្នោត ។

២.១០.១ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះ គធ/ខប ត្រូវមានសមាសភាពប្រាំ (៥) នាក់ ។

២.១០.២ សមាសភាពនៃ គធ/ខប ត្រូវបានជ្រើសរើស និងតែងតាំងដោយ គ.ជ.ប ដោយអនុលោមតាមនីតិវិធីនៃការជ្រើសរើសមន្ត្រីបុគ្គលិក ដូចមានចែងក្នុងប្រការ ២.១៦ នៃ ប.ន.ក នេះ ។

២.១០.៣ គធ/ខប ត្រូវបង្កើតលេខាធិការដ្ឋានមួយ ដែលមានផ្នែកជំនាញចំនួនប្រាំ (៥) ដូចខាងក្រោម ៖

- ផ្នែកប្រតិបត្តិការ
- ផ្នែករដ្ឋបាល
- ផ្នែកហិរញ្ញវត្ថុ
- ផ្នែកបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ
- ផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម ។

២.១០.៤ ប្រធាន គធ/ខប មានភារៈទទួលខុសត្រូវការងាររួម ។ អនុប្រធាន គធ/ខប ជាជំនួយឱ្យប្រធាន គធ/ខប និងទទួលភារៈជំនួសប្រធាន ពេលប្រធានអវត្តមាន ។

សមាសភាពម្នាក់ៗនៃ គធ/ខប ត្រូវបានបែងចែកឱ្យទទួលបន្ទុកផ្នែកជំនាញមួយ (១) ក្នុងចំណោមផ្នែកជំនាញទាំងប្រាំ (៥) ។ ប្រធាន និងអនុប្រធាន អាចបែងចែកឱ្យទទួលបន្ទុកផ្នែកជំនាញមួយ (១) ក្នុងចំណោមផ្នែកជំនាញពីរ (២) គឺផ្នែកប្រតិបត្តិការ និងផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម ។

**លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ/ខប**

**ប្រការ** ២.១១ លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ/ខប ត្រូវបានកំណត់ ដូចខាងក្រោម ៖

២.១១.១ សមាសភាព គធ/ខប នៅរាជធានី ឬ ខេត្តណា ត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងរាជធានី ឬខេត្តនោះ ។

២.១១.១.១ ដើម្បីគោរពឯករាជភាព និងអព្យាក្រឹតភាពនៃ គ.ជ.ប សមាជិក គធ/ខប ត្រូវតំណាងឱ្យក្រុមទាំងអស់នៃសង្គមកម្ពុជាទាំងមូល ។

២.១១.១.២ ក្រុមទាំងអស់ នៃសង្គមកម្ពុជាទាំងមូល ត្រូវបានកំណត់ជា មន្ត្រីរាជការ បំរើការងារក្នុងរាជរដ្ឋាភិបាល គណបក្សនយោបាយ និងសង្គមស៊ីវិល ។

២.១១.១.៣ សង្គមស៊ីវិលត្រូវបានកំណត់ជាអង្គការនានា មិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីរាជរដ្ឋាភិបាលដូចជា សមាគមគណៈមេធាវី អង្គការមិនមែនរដ្ឋាភិបាល សមាគមផ្នែកអប់រំ វប្បធម៌ និងអង្គការ ឬសមាគមមិនគិតផលចំណេញដទៃទៀត ។

២.១១.១.៤ អ្នកដែលមានសិទ្ធិត្រូវបានជ្រើសរើស គឺប្រជាពលរដ្ឋទូទៅ មន្ត្រីរាជការ និងអ្នកមុខអ្នកការនៅក្នុងរាជធានី ខេត្ត ដែលមានសិទ្ធិបោះឆ្នោត ។

២.១១.១.៥ សមាសភាព គធ/ខប មិនត្រូវបានជ្រើសរើសក្នុងចំណោមកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ ព្រះសង្ឃ ឬបព្វជិតនៃសាសនាណាមួយ ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ បេក្ខជនឈរឈ្មោះបោះឆ្នោតជាសមាជិកក្រុមប្រឹក្សា និងសមាជិកគណៈកម្មាធិការនាយកនៃគណបក្សនយោបាយ ។

២.១១.១.៦ សមាសភាព គធ/ខប ត្រូវមានកិត្តិស័ព្ទស្មោះត្រង់ និងសុចរិតទៀងត្រង់ ហើយត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ ។

២.១១.១.៧ ប្រសិនបើអាចធ្វើបាន យ៉ាងហោចណាស់ត្រូវមានស្ត្រីមួយ (១) នាក់ ជាសមាជិកនៃ គធ/ខប ។ នៅតំបន់ណាដែលមានជនជាតិភាគតិចក្នុងចំនួនសមស្រប ប្រសិនបើអាចធ្វើទៅបាន សមាជិកមួយ( ១ )នាក់ នៃ គធ/ខប ត្រូវជ្រើសរើសចេញពីក្រុមជនជាតិភាគតិច ។

២.១១.១.៨ មន្ត្រីបន្តនិរន្តរភាពការងារនៅលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ/ខប) អាចត្រូវបានផ្តល់អាទិភាព ជាបេក្ខជនសម្រាប់ការជ្រើសរើសនេះ ។

២.១១.២ ប្រសិនបើ ពលរដ្ឋណាម្នាក់មានមូលហេតុដែលអាចជឿបានថា អ្នកដែលត្រូវបានតែងតាំងជាសមាជិក គធ/ខប ពុំមានលក្ខណសម្បត្តិស្របតាមច្បាប់ទេនោះ គាត់អាចប្តឹងជំទាស់នឹងការតែងតាំងនេះទៅ គ.ជ.ប ។

២.១១.២.១ ប្រសិនបើមានការប្តឹងជំទាស់ គ.ជ.ប ត្រូវដោះស្រាយបណ្តឹងនោះដោយអនុលោមទៅតាម ប.ន.ក របស់ គ.ជ.ប ។

២.១១.២.២ សេចក្តីសម្រេចរបស់ គ.ជ.ប គឺជាសេចក្តីសម្រេចចុងក្រោយ ។

**ភារកិច្ច និងការទទួលខុសត្រូវនៃ គធ/ខប**

**ប្រការ** ២.១២ ក្រោមការគ្រប់គ្រង និងការណែនាំនៃ គ.ជ.ប គធ/ខប ត្រូវមានការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅក្រុង ស្រុក ខណ្ឌចំណុះរាជធានី ខេត្តរបស់ខ្លួន ។ ក្នុងការរៀបចំនេះ គធ/ខប ត្រូវ ៖

២.១២.១ ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

២.១២.២ អនុវត្តផែនការមេ គ្រប់គ្រងថវិការបស់ខ្លួន ចុះបញ្ជី និងថែរក្សាបញ្ជីសារពើភ័ណ្ឌនៃសម្ភារបរិក្ខារសម្រាប់ការបោះឆ្នោត និងគោរពតាមប្រតិទិននៃការបោះឆ្នោត ។

២.១២.៣ លើកសំណើសុំតែងតាំងសមាជិក គកប ។

២.១២.៤ គោរព និងអនុវត្ត ច.ប.ក ប.ន.ក និងគោលការណ៍ណែនាំរបស់ គ.ជ.ប ។

២.១២.៥ ចាត់វិធានការពាក់ព័ន្ធទៅនឹងសន្តិសុខ និងសណ្តាប់ធ្នាប់នៅក្នុងការបោះឆ្នោត ។

២.១២.៦ តាមដានការងារគ្រប់គ្រង និងប្រតិបត្តិការរបស់ គកប ។

២.១២.៧ លើកគំរោងជូន គ.ជ.ប អំពីចំនួន និងទីតាំងការិយាល័យបោះឆ្នោត ។

២.១២.៨ បែងចែកសម្ភារបរិក្ខារសម្រាប់ការចុះឈ្មោះបោះឆ្នោត និងសម្ភារបរិក្ខារបោះឆ្នោតទៅក្រុមប្រឹក្សាឃុំ សង្កាត់ និង គកប ។

២.១២.៩ រៀបចំចាត់ចែងប្រមូលលទ្ធផល នៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត ត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត បិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងវេចខ្ចប់បញ្ជូនសម្ភារបោះឆ្នោតមក គ.ជ.ប ។

២.១២.១០ ត្រួតពិនិត្យយុទ្ធនាការឃោសនាបោះឆ្នោតនៅតាមរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ។

២.១២.១១ ចាត់គ្រប់វិធានការដើម្បីធានាឱ្យមានភាពស្មើគ្នាក្នុងការប្រើប្រាស់អាគារសាធារណៈដល់គណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតទាំងអស់ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

២.១២.១២ ចែកចាយរាល់ឯកសារ និងព័ត៌មានដែលពាក់ព័ន្ធទៅនឹងការបោះឆ្នោត ។

២.១២.១៣ លើកគំរោង និងអនុវត្តកម្មវិធីបណ្តុះបណ្តាល ស្តីពីការបោះឆ្នោតក្នុងក្របខ័ណ្ឌរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ដោយយោងតាមការណែនាំរបស់ គ.ជ.ប ។

២.១២.១៤ លើកកំពស់ការយល់ដឹងរបស់សាធារណជនអំពីការបោះឆ្នោត ដោយធ្វើការសហការ និងសម្របសម្រួលការងារអប់រំអ្នកបោះឆ្នោតក្នុងក្របខ័ណ្ឌរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល ។

២.១២.១៥ អនុវត្តកម្មវិធីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត ។

២.១២.១៦ ទទួលពាក្យបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ និងធ្វើការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

២.១២.១៧ ដោះស្រាយរាល់វិវាទកម្មក្រោមសមត្ថកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុង ច.ប.ក និង ប.ន.ក ។

២.១២.១៨ ចាត់គ្រប់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងការរៀបចំការបោះឆ្នោត ។

២.១២.១៩ ដឹកនាំអនុគណៈកម្មការសន្តិសុខនៅក្នុងរាជធានី ខេត្ត របស់ខ្លួន ។

២.១២.២០ រាយការណ៍ជូន គ.ជ.ប អំពីស្ថានភាពទូទៅក្នុងរាជធានី ខេត្ត ដើម្បីចាត់វិធានការធានាឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី និងត្រឹមត្រូវ ។

២.១២.២១ ផ្តល់ប័ណ្ណសម្គាល់ជូនអ្នកសង្កេតការណ៍ជាតិ ។

២.១២.២២ វាយតម្លៃ អំពីប្រសិទ្ធភាពការងាររបស់សមាជិកទាំងឡាយនៃ គកប ។

២.១២.២៣ អនុវត្តការងារដទៃទៀត ដែល ច.ប.ក អនុញ្ញាត ឬតម្រូវឱ្យអនុវត្ត ។

២.១២.២៤ អនុវត្តការងារ ឬសិទ្ធិអំណាចដទៃទៀត ដែលត្រូវបានប្រគល់ឱ្យដោយ គ.ជ.ប ។

**សមាសភាពនៃគណៈកម្មការការិយាល័យបោះឆ្នោត (គកប)**

**ប្រការ** ២.១៣ គកប ជាគណៈកម្មការគ្រប់គ្រង និងទទួលខុសត្រូវការងារបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត ដែលតែងតាំងដោយ គ.ជ.ប តាមសំណើរបស់ គធ/ខប ។

២.១៣.១ គកប ត្រូវមានសមាសភាពប្រាំ (៥) រូប ដែលរួមមានប្រធានមួយ (១) រូប អនុប្រធានមួយ (១) រូប លេខាធិការមួយ (១) រូប ជំនួយការមួយ (១) រូប និងសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់មួយ(១) រូប ។

២.១៣.១.១ ប្រធាន មានភារៈទទួលខុសត្រូវរួមក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.១៣.១.២ អនុប្រធាន មានភារៈជាជំនួយរបស់ប្រធាន និងទទួលខុសត្រូវក្នុង ៖

- ការពិនិត្យការស៊កសន្លឹកឆ្នោត ទៅក្នុងហិបឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

- ការផ្តល់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ជូនអ្នកបោះឆ្នោត នៅពេលបោះឆ្នោត
- ការកត់ត្រាសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

២.១៣.១.៣ លេខាធិការមានភារៈទទួលខុសត្រូវក្នុង ៖

- ការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត
- ការផ្តល់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង
- ការបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទ ទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.១៣.១.៤ ជំនួយការមានភារៈទទួលខុសត្រូវក្នុង ៖

- ការពិនិត្យការស៊កសន្លឹកឆ្នោត ទៅក្នុងហិបឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត
- ការជ្រលក់ម្រាម ដៃអ្នកបោះឆ្នោតក្នុងទឹកខ្មៅលុបលាងមិនជ្រះ
- ការគូសសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

២.១៣.១.៥ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ មានភារៈទទួលខុសត្រូវក្នុង ៖

- ការងារសណ្តាប់ធ្នាប់ របៀបរៀបរយ និង
- ការថែរក្សាសម្ភារ ឯកសារបោះឆ្នោត នៅពេលបោះឆ្នោត និងនៅពេលរាប់សន្លឹកឆ្នោត ។

២.១៣.២ គកប ត្រូវទទួលខុសត្រូវចំពោះមុខ គធ/ខប ។

២.១៣.៣ គកប ទទួលសេចក្តីណែនាំពី គ.ជ.ប តាមរយៈ គធ/ខប ។

**លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គកប**

**ប្រការ** ២.១៤ លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គកប ត្រូវបានកំណត់ដូចខាងក្រោម ៖

២.១៤.១ សមាសភាព គកប ត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋទូទៅដែលមានសិទ្ធិបោះឆ្នោត និងរស់នៅក្នុងក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធ ។

២.១៤.២ ដើម្បីគោរពឯករាជ្យភាព និងអព្យាក្រឹតភាពនៃ គ.ជ.ប សមាសភាព គកប ត្រូវតំណាងឱ្យក្រុមទាំងអស់នៃសង្គមកម្ពុជាទាំងមូល ដែលត្រូវបានកំណត់ជាមន្ត្រីរាជការបំរើការងារក្នុងរាជរដ្ឋាភិបាល គណបក្សនយោបាយ និងសង្គមស៊ីវិល ។

២.១៤.៣ អ្នកដែលមានសិទ្ធិត្រូវបានជ្រើសរើស គឺជាប្រជាពលរដ្ឋ មន្ត្រីរាជការ និងអ្នកមុខអ្នកការដែលមានសិទ្ធិបោះឆ្នោត និងកំពុងរស់នៅក្នុងក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធ ។

២.១៤.៤ សមាសភាព គកប មិនត្រូវបានជ្រើសរើសក្នុងចំណោមកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ ព្រះសង្ឃ បព្វជិតសាសនា មេឃុំ ចៅសង្កាត់ ជំទប់ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ បេក្ខជនឈរឈ្មោះបោះឆ្នោតជាសមាជិកក្រុមប្រឹក្សា និងសមាជិកគណៈកម្មាធិការនាយកនៃគណបក្សនយោបាយ ។

២.១៤.៥ សមាសភាព គកប ត្រូវមានកិត្តិស័ព្ទស្មោះត្រង់ និងសុចរិតទៀងត្រង់ និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយដោយប្រជាពលរដ្ឋ ។

២.១៤.៦ ប្រសិនបើអាចធ្វើបាន ប្រធាន និងអនុប្រធានត្រូវជ្រើសរើសក្នុងចំណោមជនចូលនិវត្តន៍ ដែលមានគតិបណ្ឌិត មានសិទ្ធិបោះឆ្នោត និងកំពុងរស់នៅក្នុងក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធ ។

២.១៤.៧ ប្រសិនបើអាចធ្វើបាន យ៉ាងហោចណាស់ត្រូវមានស្ត្រីមួយ (១) នាក់ ជាសមាជិក គកប ។ នៅតំបន់ណាដែលមានជនជាតិភាគតិចក្នុងចំនួនសមស្រប ប្រសិនបើអាចធ្វើបាន សមាជិកមួយ (១) នាក់នៃ គកប ត្រូវជ្រើសរើសចេញពីក្រុមជនជាតិភាគតិច ។

២.១៤.៨ សមាសភាព គកប ត្រូវតែជ្រើសរើស ដោយផ្អែកតាមនីតិវិធីនៃការជ្រើសរើស ដូចបានកំណត់ក្រោមប្រការ ២.១៦ ។

២.១៤.៩ ប្រសិនបើ ពលរដ្ឋណាម្នាក់មានមូលហេតុដែលអាចជឿបានថា អ្នកដែលត្រូវបានតែងតាំងក្នុងសមាសភាព គកប ពុំមានលក្ខណសម្បត្តិស្របតាមច្បាប់ទេនោះ គាត់អាចប្តឹងជំទាស់នឹងការតែងតាំងនេះទៅ គ.ជ.ប ។

២.១៤.៩.១ ប្រសិនបើមានការប្តឹង គ.ជ.ប ត្រូវដោះស្រាយបណ្តឹងនោះដោយអនុលោមតាម ប.ន.ក របស់ គ.ជ.ប ។

២.១៤.៩.២ សេចក្តីសម្រេចរបស់ គ.ជ.ប គឺជាសេចក្តីសម្រេចចុងក្រោយ ។

**ភារកិច្ច និងការទទួលខុសត្រូវរបស់ គកប**

**ប្រការ ២.១៥** គកប នីមួយៗមានភារកិច្ចចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅក្នុងការិយាល័យបោះឆ្នោត ដែលខ្លួនទទួលខុសត្រូវ ។

២.១៥.១ ប្រធាន គកប មានភារកិច្ចចាត់ចែង និងគ្រប់គ្រងនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅក្នុងការិយាល័យបោះឆ្នោត ដែលខ្លួនទទួលខុសត្រូវ និងត្រូវ ៖

២.១៥.១.១ ចូលរួមវគ្គបណ្ដុះបណ្ដាល និងម្ចាស់ការអនុវត្តរាល់នីតិវិធីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.១៥.១.២ ទទួល និងការពារឱ្យបានហ្មត់ចត់នូវរាល់សម្ភារឯកសារបោះឆ្នោតសម្រាប់បំរើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.១៥.១.៣ ត្រួតពិនិត្យរាល់សម្ភារឯកសារបោះឆ្នោត សម្រាប់បំរើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.១៥.១.៤ បោះទីតាំង បំពាក់គ្រឿងសង្ហារឹម និងរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់កំណត់ដោយ គ.ជ.ប ។

២.១៥.១.៥ ត្រួតពិនិត្យការបំពេញការងាររបស់សមាជិក គកប នៅថ្ងៃបោះឆ្នោត ។

២.១៥.១.៦ ដាក់ជំនួសតំណែងសមាជិក គកប ណាដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា ។

២.១៥.១.៧ ចាត់តាំង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោត ក្នុងការិយាល័យបោះឆ្នោត ។

២.១៥.១.៨ ធានាឱ្យប្រាកដថា គ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ត្រូវបានបំពេញ ចុះហត្ថលេខា និងបោះត្រាត្រឹមត្រូវ ។

២.១៥.១.៩ ត្រួតពិនិត្យលិខិតតែងតាំង និងទទួលស្គាល់តំណាងគណបក្សនយោបាយ និងលិខិតតែងតាំង និងទទួលស្គាល់អ្នកសង្កេតការណ៍ដែលត្រូវចូលរួមសង្កេតការណ៍ក្នុងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥.១.១០ ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗដល់អ្នកដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ។

២.១៥.១.១១ បើក និងបិទកិច្ចប្រតិបត្តិការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ។

២.១៥.១.១២ ធានារបៀបរៀបរយក្នុង និងក្រៅបរិវេណការិយាល័យបោះឆ្នោត ។

២.១៥.១.១៣ ចាក់សោឃ្លុំការពារហិបឆ្នោត ។

២.១៥.១.១៤ ធានាឱ្យប្រាកដថា អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបានណែនាំឱ្យចេះអំពីរបៀបបោះឆ្នោតពីរ (២) សន្លឹក ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១៥.១.១៥ បំពេញក្រដាសព័ត៌មានអំពីអ្នកបោះឆ្នោតណាម្នាក់ ដែលអះអាងថា មិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ។

២.១៥.១.១៦ ធានាឱ្យប្រាកដថា ទឹកខ្មៅលុបលាងមិនជ្រះ ត្រូវតែបានអនុវត្តតាមការណែនាំ ។

២.១៥.១.១៧ ត្រួតពិនិត្យសមាជិក គកប ក្នុងអាណត្តិការងាររបស់ខ្លួន ។

២.១៥.១.១៨ ធានាឱ្យប្រាកដថា ការលើកយោបល់ជំទាស់ និងតវ៉ាក្នុងការិយាល័យបោះឆ្នោត ត្រូវបានដោះស្រាយភ្លាម ដោយអនុវត្តស្របតាម ប.ន.ក និងការណែនាំរបស់ គ.ជ.ប ។

២.១៥.១.១៩ ជួយអ្នកបោះឆ្នោតជាជនពិការ (ប្រសិនបើមាន និងប្រសិនបើគាត់ស្នើសុំឱ្យជួយក្នុងការបោះឆ្នោត) ។

២.១៥.១.២០ ធានាឱ្យប្រាកដថា សន្លឹកឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ សម្រាប់ការិយាល័យបោះឆ្នោតរបស់ខ្លួន ត្រូវបានពិនិត្យផ្ទៀងផ្ទាត់យ៉ាងម៉ត់ចត់ និងត្រឹមត្រូវ ។

២.១៥.១.២១ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន តាមការណែនាំ ។ ត្រួតពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្សនយោបាយ ដែលបានទទួលសំឡេងឆ្នោត ។

២.១៥.១.២២ ធានាឱ្យប្រាកដថា កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៃប្រភេទក្រុមប្រឹក្សានីមួយៗ នៅការិយាល័យបោះឆ្នោតរបស់ខ្លួនមួយ (១) ច្បាប់ ត្រូវបានបិទផ្សាយនៅមុខទីតាំងការិយាល័យបោះឆ្នោត ។

២.១៥.១.២៣ ប្រគល់ជូន គឃ/ខប នូវកំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៃប្រភេទក្រុមប្រឹក្សានីមួយៗ នៅការិយាល័យបោះឆ្នោតរបស់ខ្លួន ហិបឆ្នោត និងរាល់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ។

២.១៥.១.២៤ ប្រគល់ជូន គឃ/ខប នូវហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង និងកំណត់ហេតុនៃការបោះឆ្នោត ព្រមទាំងសម្ភារឯកសារបោះឆ្នោតផ្សេងទៀតក្នុងករណីកាលៈទេសៈមានអាសន្ន ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតបាន ។

២.១៥.១.២៥ បំពេញភារកិច្ចរបស់ខ្លួនក្នុងជំហរអព្យាក្រឹត និងមិនលំអៀង ។

២.១៥.១.២៦ បំពេញភារកិច្ចផ្សេងទៀតដែល គឃ/ខប តម្រូវឱ្យធ្វើ ។

២.១៥.២ អនុប្រធាន គកប ត្រូវជួយប្រធាន និងមានភារកិច្ចដោយឡែក ដូចខាងក្រោម ៖

២.១៥.២.១ ចូលរួមវគ្គបណ្តុះបណ្តាល និងម្ចាស់ការអនុវត្តរាល់នីតិវិធីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.១៥.២.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់កិច្ចការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ក ប.ន.ក និងការណែនាំរបស់ គ.ជ.ប ។

២.១៥.២.៣ ជំនួសតំណែងប្រធាន ក្នុងករណី ប្រធានមិនមកបំពេញការងារ ។

២.១៥.២.៤ រាប់ចំនួនសន្លឹកឆ្នោតសម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ ដែលបានទទួលជាក់ស្តែង សម្រាប់ប្រើក្នុងការិយាល័យបោះឆ្នោត ។

២.១៥.២.៥ ពិនិត្យការស៊កសន្លឹកឆ្នោតទៅក្នុងហិបឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១៥.២.៦ ផ្តល់សន្លឹកឆ្នោតមួយ (១) សន្លឹក ដែលជាប្រភេទសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ជូនអ្នកបោះឆ្នោត ។

២.១៥.២.៧ ផ្តល់ការណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត ។

២.១៥.២.៨ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ នៅពេលបញ្ចប់ការបោះឆ្នោត ។

២.១៥.២.៩ ត្រួតពិនិត្យ និងបែងចែកប្រភេទសន្លឹកឆ្នោតបានការ ឬមិនបានការមុននឹងប្រគល់ជូនប្រធាន ។

២.១៥.២.១០ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗទទួលបាន តាមប្រភេទក្រុមប្រឹក្សានីមួយៗ លើតារាងកត់ត្រាសំឡេងឆ្នោត ។

២.១៥.២.១១ អមដំណើរប្រធាន ក្នុងការបញ្ជូន និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារឯកសារពាក់ព័ន្ធផ្សេងទៀត ជូន គធ/ខប ។

២.១៥.២.១២ បំពេញភារកិច្ចផ្សេងទៀតដែល គធ/ខប និងប្រធាន គកប/គករ តម្រូវឱ្យធ្វើ ។

២.១៥.៣ លេខាធិការនៃ គកប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងជាអ្នកទទួលបន្ទុកពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត ព្រមទាំងបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ហើយត្រូវ ៖

២.១៥.៣.១ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥.៣.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់កិច្ចការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ក ប.ន.ក និងការណែនាំរបស់ គ.ជ.ប ។

២.១៥.៣.៣ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥.៣.៤ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

២.១៥.៣.៥ ត្រួតពិនិត្យរកមើលស្នាមទឹកខ្មៅលុបលាងមិនជ្រះ នៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យប្រាកដថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត នៅមុនពេលពិនិត្យរកមើលឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត ។

២.១៥.៣.៦ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ភាពដូចគ្នា រវាងឈ្មោះ និងទិន្នន័យនៅក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត និងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត រួចគូសសម្គាល់ថាបានមកបោះឆ្នោតត្រង់ឈ្មោះអ្នកបោះឆ្នោតនោះលើបញ្ជីបោះឆ្នោត ។

២.១៥.៣.៧ ផ្តល់សន្លឹកឆ្នោតមួយ (១) សន្លឹក ដែលជាប្រភេទសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជូនអ្នកបោះឆ្នោត ។

២.១៥.៣.៨ ផ្តល់ការណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត ។

២.១៥.៣.៩ រាប់គំនូសសញ្ញានៅលើបញ្ជីបោះឆ្នោត ចំនួនអ្នកបោះឆ្នោតដែលមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងមិនបានបោះឆ្នោត ។

២.១៥.៣.១០ បំពេញកំណត់ហេតុនៃការបោះឆ្នោត និងដាក់ជូនប្រធានចុះហត្ថលេខា បន្ទាប់មកដាក់បង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល ។

២.១៥.៣.១១ កត់ត្រាក្នុងកំណត់ហេតុនូវរាល់ការលើកយោបល់តវ៉ា ឬ/និងជំទាស់ ឬករណីមានការប្តឹងតវ៉ា ឬ/និងជំទាស់ទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥.៣.១២ កត់ត្រាសំឡេងឆ្នោតដែលគណបក្សនយោបាយនីមួយៗ បានទទួលតាមប្រភេទក្រុមប្រឹក្សានីមួយៗ នៅលើតារាងកត់ត្រាសំឡេងឆ្នោត ។

២.១៥.៣.១៣ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងដាក់ជូនប្រធានចុះហត្ថលេខា បន្ទាប់មកដាក់បង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល ។

២.១៥.៣.១៤ បំពេញរាល់ភារកិច្ចផ្សេងទៀតដែល គធ/ខប និងប្រធាន គកប តម្រូវឱ្យធ្វើ ។

២.១៥.៤ ជំនួយការ គកប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ច ដូចខាងក្រោម ៖

២.១៥.៤.១ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥.៤.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារឯកសារបោះឆ្នោត ។

២.១៥.៤.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

២.១៥.៤.៤ ត្រួតពិនិត្យហិបឆ្នោត និងការស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១៥.៤.៥ ឃាត់ និងរាយការណ៍ជូនប្រធាន គកប ក្នុងករណីពិនិត្យឃើញថាអ្នកបោះឆ្នោតណាម្នាក់បម្រុងនឹងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀត ចូលក្នុងហិបឆ្នោត ។

២.១៥.៤.៦ ជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោត ដែលបានបោះឆ្នោតរួចហើយទៅក្នុងទឹកខ្មៅលុបលាងមិនជ្រះ ឱ្យដល់គល់ក្រចក និងណែនាំគាត់ឱ្យរង់ចាំសាមសិប (៣០) វិនាទី មុននឹងចេញពីការិយាល័យបោះឆ្នោត ។

២.១៥.៤.៧ ចោះសន្លឹកឆ្នោតនៃប្រភេទក្រុមប្រឹក្សានីមួយៗ ដែលនៅសល់មិនបានប្រើ ។

២.១៥.៤.៨ រាប់ចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដោយឡែកពីគ្នា ដើម្បីផ្ទៀងផ្ទាត់ទៅនឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងដកយកវត្ថុដែលមិនមែនជាសន្លឹកឆ្នោត ដាក់ក្នុងស្រោមសំបុត្រដែលបានបំរុងទុក ។

២.១៥.៤.៩ លាសន្លឹកឆ្នោតដែលបានរាប់រួច ដូចក្នុងចំណុច ២.១៥.៤.៨ ដើម្បីត្រួតពិនិត្យស្នាមបោះត្រាសម្ងាត់នៅផ្នែកខាងខ្នង និងបែងចែកតាមពំនូកនៃសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់ ។

២.១៥.៤.១០ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនីមួយៗបានទទួល តាមប្រភេទក្រុមប្រឹក្សានីមួយៗ នៅលើផ្ទាំងក្រដាសធំ ឬក្ដារខៀន ។

២.១៥.៤.១១ បំពេញភារកិច្ចផ្សេងទៀតដែល គធ/ខប ឬ/និងប្រធាន គកប តម្រូវឱ្យធ្វើ ។

២.១៥.៥ សមាជិកទទួលបន្ទុកសណ្ដាប់ធ្នាប់នៃ គកប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

២.១៥.៥.១ ចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីការអនុវត្តការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥.៥.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារឯកសារបោះឆ្នោត ។

២.១៥.៥.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

២.១៥.៥.៤ ត្រួតពិនិត្យច្រកផ្លូវចូលនៃការិយាល័យបោះឆ្នោត ណែនាំអ្នកបោះឆ្នោត ឱ្យឈរបន្តកន្ទុយគ្នា តាមលំដាប់មុនក្រោយ និងត្រួតពិនិត្យឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ ។

២.១៥.៥.៥ ផ្ដល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោតមុនគេ ចំពោះអ្នកបោះឆ្នោតជាមនុស្សចាស់ ស្ត្រីមានផ្ទៃពោះ ជនពិការ និងអ្នកមានជំងឺ បន្ទាប់មក ទើបឱ្យអ្នកឈរខាងមុខគេក្នុងជួរ ។

២.១៥.៥.៦ ត្រួតពិនិត្យស្នាមទឹកខ្មៅលុបលាងមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យដឹងថា គាត់បានបោះឆ្នោតរួចហើយ ឬមិនទាន់បានបោះឆ្នោត ។

២.១៥.៥.៧ រាយការណ៍ជូនប្រធាន គកប ក្នុងករណីពិនិត្យឃើញថាអ្នកបោះឆ្នោតណាម្នាក់បាននាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត។

២.១៥.៥.៨ ជួយចាត់ចែង និងថែរក្សារបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការអុកឡុករំខានជូនប្រធាន ។

២.១៥.៥.៩ ការពារសន្តិសុខនៅច្រកផ្លូវចូលការិយាល័យបោះឆ្នោត ថែរក្សាសម្ភារឯកសារបោះឆ្នោត និងចាត់ចែងសណ្ដាប់ធ្នាប់ នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

២.១៥.៥.១០ បំពេញភារកិច្ចផ្សេងទៀត ដែល គធ/ខប ឬ/និងប្រធាន គកប តម្រូវឱ្យធ្វើ ។

**នីតិវិធីនៃការជ្រើសរើសសមាជិក មន្ត្រីបុគ្គលិកនៃ គ.ជ.ប**

**ប្រការ** ២.១៦ ការជ្រើសរើសសមាជិក មន្ត្រីបុគ្គលិកនៃ គ.ជ.ប ត្រូវឈរលើគោលការណ៍មិនរើសអើង ស្មើភាព សមត្ថភាព និងការងារពាក់ព័ន្ធ ដែលមានកំណត់នៅក្នុង ប្រការ ១៩ ដល់ប្រការ ២៤ នៃបទបញ្ជាផ្ទៃក្នុង របស់ គ.ជ.ប ។ គ.ជ.ប លើកទឹកចិត្ត និងផ្តល់អាទិភាពដល់បេក្ខជនជាស្ត្រី បេក្ខជនជាជនជាតិភាគតិច (ចំពោះតំបន់ដែលមានជនជាតិភាគតិចតាមចំនួនសមស្រប) និង បេក្ខជនជាជនពិការ ដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងការងារពាក់ព័ន្ធ ។

២.១៦.១ លក្ខខណ្ឌការងារត្រូវបានកំណត់ក្នុងជំពូកទី៧ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.១៦.២ សេចក្តីពណ៌នាអំពីការទទួលខុសត្រូវភារកិច្ច និងលក្ខណសម្បត្តិតម្រូវសម្រាប់បុគ្គលិកនៃ គ.ជ.ប សមាជិក និងបុគ្គលិកនៃ គធ/ខប និងសមាសភាព គកប ត្រូវបានចែងលំអិតក្នុងជំពូកទី១ ទី៣ និងទី៥ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.១៦.៣ គ្រប់តួនាទីត្រូវតែបានផ្សព្វផ្សាយទូលំទូលាយក្នុងរយៈពេលប្រាំ (៥) ថ្ងៃ តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ឬ/និងឯកជន និងបិទផ្សាយនៅទីសាធារណៈ ឬទីប្រជុំជនរាជធានី ខេត្ត ក្រុង ស្រុក និង ខណ្ឌ ។

២.១៦.៣.១ សេចក្តីជូនដំណឹងស្តីពីការជ្រើសរើសបុគ្គលិក ត្រូវលើកឡើងអំពីតួនាទី សេចក្តីពណ៌នាអំពីភារកិច្ចទទួលខុសត្រូវ លក្ខណសម្បត្តិ និងលក្ខណវិនិច្ឆ័យ ។ សេចក្តីជូនដំណឹងនេះក៏ត្រូវជម្រាបសាធារណជនផងដែរនូវទីកន្លែង និងពេលវេលានៃការចែកពាក្យសុំចូលបម្រើការងារ និងពេលវេលា ទីកន្លែង និងកាលបរិច្ឆេទចុងក្រោយនៃការទទួលពាក្យសុំចូលបម្រើការងារ ។

២.១៦.៣.២ សម្រាប់ការជ្រើសរើសសមាជិក និងបុគ្គលិកនៃ គធ/ខប ពាក្យសុំត្រូវបានរៀបចំ និងផ្តល់ដោយ គ.ជ.ប ។ សម្រាប់ការជ្រើសរើសសមាសភាពនៃ គកប ពាក្យសុំត្រូវផ្តល់ដោយ គធ/ខប ។ ពាក្យសុំចូលបំរើការងារត្រូវផ្តល់ជូនអ្នកសុំ ដោយឥតគិតថ្លៃ ។

២.១៦.៣.៣ នៅពេលឈប់ទទួលពាក្យសុំបំរើការងារ គណៈកម្មការជ្រើសរើសបុគ្គលិក ត្រូវជ្រើសរើសសំរាំងពាក្យសុំចូលបំរើការងារដើម្បីកំណត់ថា តើពាក្យសុំមួយណា ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌបច្ចេកទេស ។

២.១៦.៣.៤ លក្ខខណ្ឌទូទៅសម្រាប់ជ្រើសរើសសមាសភាព គធ/ខប និង គកប រួមមាន ៖

- មានសិទ្ធិបោះឆ្នោត
- មានទីលំនៅក្នុងរាជធានី ខេត្ត ពាក់ព័ន្ធ សម្រាប់សមាជិក គធ/ខប និងក្នុងក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធ សម្រាប់សមាជិក គកប
- មានឆន្ទៈបំរើការងារក្នុងគោលជំហរអព្យាក្រឹត និងមិនលំអៀង
- មានសុឆន្ទៈលាឈប់ ឬមានច្បាប់អនុញ្ញាតឈប់ពីការងារ
- មិនមែនជាសមាជិកកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ ឬនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខ័ណ្ឌការងារ (ចៅក្រម និងព្រះរាជអាជ្ញា)
- មិនមែនជាព្រះសង្ឃ បព្វជិតសាសនា
- មិនមែនជាប្រតិភូរាជរដ្ឋាភិបាល អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ
- មិនមែនជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឬ/និងជាសមាជិកគណៈកម្មាធិការនាយកនៃគណបក្សនយោបាយ
- មកពីជនជាតិភាគតិច ប្រសិនបើមាន
- មានលទ្ធភាពចូលរួម ក្នុងការបណ្តុះបណ្តាល និងការបំពេញការងារពេញម៉ោង និងពេញអាណត្តិការងារ ។
- មានសុខភាពល្អ
- មានកិត្តិស័ព្ទសុចរិតទៀងត្រង់ ។

២.១៦.៣.៥ លក្ខខណ្ឌបច្ចេកទេសដែលទាមទារ ដើម្បីបំពេញការងារជាក់លាក់មួយចំនួនដូចជា ៖

- ត្រូវចេះអាន និងសរសេរអក្សរខ្មែរ
- ប្រសិនបើអាចធ្វើបាន ប្រធាន គធ/ខប ឬប្រធាន គកប ត្រូវជាអ្នកចូលនិវត្តន៍ ដែលមានកិត្តិស័ព្ទសុចរិតទៀងត្រង់
- មានចំណេះដឹង ឬបទពិសោធន៍ប្រហាក់ប្រហែល ដែលទាក់ទងជាមួយនឹងតួនាទី

- សម្រាប់តួនាទីមួយចំនួន ទាមទារឱ្យមានការយល់ដឹង និង ចេះប្រើប្រាស់កុំព្យូទ័រ
- ស្ម័គ្រចិត្តធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងរាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌ ។

២.១៦.៣.៦ ពាក្យសុំណា ដែលឆ្លើយតបនឹងលក្ខខណ្ឌបច្ចេកទេស ត្រូវធ្វើការសំរាំងជាលើកទីពីរ ដើម្បីជ្រើសរើសយកបេក្ខជនល្អ ។

២.១៦.៣.៧ បេក្ខជនល្អចំនួនបី (៣) នាក់សម្រាប់មុខតំណែងនីមួយៗ ត្រូវបានអញ្ជើញមកធ្វើសម្ភាសន៍ ពេលនោះ ចំណេះដឹង លក្ខណសម្បត្តិ និងសមត្ថភាពក្នុងការបំពេញការងាររបស់បេក្ខជន នឹងត្រូវបានសាកល្បង និងត្រួតពិនិត្យ ។

២.១៦.៣.៨ ការធ្វើសម្ភាសន៍ត្រូវពិនិត្យជាបឋមទៅលើកំរិតវប្បធម៌ និងមុខតំណែង សញ្ញាប័ត្រ និងបទពិសោធន៍ការងារពាក់ព័ន្ធ ។

២.១៦.៣.៩ ជាបន្ទាប់កិច្ចសម្ភាសន៍ត្រូវធ្វើដោយផ្ទាល់មាត់ លើរបៀបធ្វើការងារ និងដោយឱ្យធ្វើតេស្តជាក់ស្តែងដូចជា វាយកុំព្យូទ័រ ឬសរសេរលិខិតស្នាម ព្រមទាំងពិនិត្យលើអត្តចរិត និងកាយសម្បទាផង ។

២.១៦.៣.១០ ក្នុងការធ្វើសម្ភាសន៍ សមាជិកគណៈកម្មការជ្រើសរើសម្នាក់ៗ ត្រូវផ្តល់ពិន្ទុដល់បេក្ខជនម្នាក់ៗ ក្នុងតារាងវាយតម្លៃផ្ទាល់ខ្លួនមួយ ដើម្បីធ្វើការបូកសរុបពិន្ទុរួម ។

២.១៦.៣.១១ បន្ទាប់ពីការធ្វើសម្ភាសន៍ និងធ្វើតេស្តចប់ គណៈកម្មការជ្រើសរើសត្រូវធ្វើការបូកសរុបពិន្ទុ ដោយធ្វើចំណាត់ថ្នាក់ដូចខាងក្រោម ៖

**A** : សម្រាប់បេក្ខជនដែលបានពិន្ទុខ្ពស់ជាងគេ

**B** : សម្រាប់បេក្ខជនដែលបានពិន្ទុខ្ពស់ជាងបន្ទាប់

**C** : សម្រាប់បេក្ខជនដែលបានពិន្ទុទាបជាងគេ ។

២.១៦.៣.១២ បន្ទាប់មក គណៈកម្មការជ្រើសរើស ត្រូវធ្វើការប្រជុំដើម្បីកំណត់ចំណាត់ថ្នាក់បេក្ខជនទាំងបី (៣) នាក់ រួចបញ្ជូនឈ្មោះបេក្ខជនទាំងនោះ តាមឋានានុក្រម ដើម្បីធ្វើការសម្រេច ។

២.១៦.៣.១៣ រាល់ឯកសាររបស់អ្នកសុំបម្រើការងារ ត្រូវបានចាត់ទុកជាការសម្ងាត់ ហើយត្រូវតម្កល់ទុកជាឯកសារ ។

២.១៦.៣.១៤ បេក្ខជនដែលត្រូវបានជ្រើសរើស ត្រូវតែទទួលបាននូវការជូនដំណឹង និងការផ្តល់កិច្ចសន្យាការងារ តាមការកំណត់របស់ គ.ជ.ប ។

២.១៦.៣.១៥ សមាសភាព គធ/ខប និង គកប ដែលបានតែងតាំងទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចាប់ផ្តើមបំពេញការងារ ។

២.១៦.៤ គណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដែលមានសមាជិកយ៉ាងតិចបី (៣) នាក់ ត្រូវបានតែងតាំងដោយ គ.ជ.ប ដើម្បីជ្រើសរើសមន្ត្រីបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប និងសមាជិក គធ/ខប ។ គណៈកម្មការ ដែលមានសមាសភាពយ៉ាងតិចបី (៣) នាក់នៅ គធ/ខប ត្រូវបានតែងតាំងដោយ គធ/ខប ដើម្បីជ្រើសរើសបុគ្គលិកនៃ គធ/ខប និង គកប ។

២.១៦.៤.១ គ.ជ.ប ត្រូវតែងតាំងគណៈកម្មការជ្រើសរើសមួយ ដើម្បីជ្រើសរើសមន្ត្រី បុគ្គលិក នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប និងសមាជិកនៃ គធ/ខប ។

២.១៦.៤.២ គណៈកម្មការជ្រើសរើសនេះ មានសមាសភាព ៖ អគ្គលេខាធិការ ឬតំណាង ប្រធាន ឬ អនុប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានការិយាល័យបុគ្គលិក និង ប្រធាន ឬអនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានពាក់ព័ន្ធ ។

២.១៦.៤.៣ ក្នុងករណីចាំបាច់ ប្រធានគណៈកម្មការជ្រើសរើសអាចចាត់តាំងអនុគណៈកម្មការមួយ ក្នុងចំណោមសមាជិកដែលមានឈ្មោះ ក្នុងគណៈកម្មការជ្រើសរើស ដើម្បីពិនិត្យជំរុះលើកទី ១ នូវបេក្ខជនដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌជ្រើសរើស ។

២.១៦.៤.៤ គធ/ខប ត្រូវតែងតាំងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដើម្បីជ្រើសរើសមន្ត្រី បុគ្គលិកបម្រើការងារនៅ គធ/ខប និង សមាជិកនៃ គកប ។

២.១៦.៤.៥ សមាជិកនៃគណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិក ត្រូវបំពេញការងារក្នុងជំហរអព្យាក្រឹត យុត្តិធម៌ និងមិនលំអៀង ។

២.១៦.៥ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា សមាជិកណាម្នាក់នៃគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក បានល្មើសនឹងនីតិវិធីនៃការជ្រើសរើសមន្ត្រី ឬបុគ្គលិករបស់ គ.ជ.ប យោងតាមកំរិតធ្ងន់ ឬស្រាល អ្នកនោះនឹងត្រូវទទួលពិន័យពី គ.ជ.ប ។ រូបភាពពិន័យ រួមមានចាប់ពីការព្រមានរហូតដល់ការបណ្តេញចេញពីការងារ ។

## អាណត្តិរបស់គណៈកម្មាធិការ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់

**ប្រការ ២.១៧** អាណត្តិរបស់គណៈកម្មាធិការ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវបានកំណត់ដូចខាងក្រោម ៖

២.១៧.១ គកប ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់បញ្ចប់ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងបញ្ជូនសម្ភារឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតទៅ គធ/ខប ។

២.១៧.២ គធ/ខប ត្រូវបំពេញភារកិច្ចរបស់ខ្លួនយ៉ាងយូរហុកសិប (៦០) ថ្ងៃក្រោយពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១៧.៣ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវបន្តការងាររបស់ខ្លួនរហូតដល់មានការតែងតាំងថ្មី ។

## ការតែងតាំងក្នុងរយៈពេលមានកំណត់

**ប្រការ ២.១៨** គ.ជ.ប មានសិទ្ធិតែងតាំង គធ/ខប ឬ គកប ក្នុងរយៈពេលកំណត់ណាមួយ បន្ទាប់ពីការបោះឆ្នោតជាទូទៅត្រូវបានបញ្ចប់ ក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតសាជាថ្មីប្រសិនបើមាន ។ ក្នុងការតែងតាំងនេះ នីតិវិធីនៃការជ្រើសរើសរចនាសម្ព័ន្ធ សមាសភាព លក្ខណវិនិច្ឆ័យ សិទ្ធិអំណាច ការទទួលខុសត្រូវ អាណត្តិ និងប្រាក់កំរៃ ត្រូវអនុលោមតាម ប.ន.ក នេះ និងតាមការសម្រេចរបស់ គ.ជ.ប ។

## ប្រាក់កំរៃរបស់សមាជិក និងបុគ្គលិក

**ប្រការ ២.១៩** ប្រាក់កំរៃរបស់សមាជិក និងមន្ត្រីបុគ្គលិក នៃ គ.ជ.ប និងសមាជិក និងមន្ត្រី បុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប ។

២.១៩.១ ប្រាក់កំរៃត្រូវតែបានពិនិត្យជារៀងរាល់ឆ្នាំ ។

២.១៩.២ ប្រាក់កំរៃត្រូវបើកជារៀងរាល់ខែចំពោះសមាជិក មន្ត្រី បុគ្គលិកជាប់កិច្ចសន្យា និងត្រូវបើកផ្តាច់ចំពោះមន្ត្រី បុគ្គលិកម៉ៅការ ក្រោយបញ្ចប់ការងារតាមការកំណត់ ។

២.១៩.៣ ប្រាក់កំរៃត្រូវបើកជូនជាប្រាក់រៀល ទៅតាមលទ្ធភាពបើកប្រាក់របស់រតនាគារជាតិ។

**ការដាក់ពិន័យ ការព្យួរការងារ ការបណ្តេញចេញពីការងារចំពោះបុគ្គលិក ឬសមាជិកគណៈកម្មការ**

**ប្រការ ២.២០** សមាជិក ឬបុគ្គលិកនៃគណៈកម្មការថ្នាក់ណាមួយ ដែលប្រព្រឹត្តល្មើសនឹង ច.ប.ក និង ប.ន.ក នេះ ឬអ្នកដែលបដិសេធការប្រតិបត្តិតាមសេចក្តីណែនាំរបស់ គ.ជ.ប ត្រូវទទួលការដាក់ពិន័យ ដោយអនុលោមតាមទំហំនៃអំពើល្មើស ។ វិធានការដាក់ពិន័យត្រូវចាប់ផ្តើមពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ ។

**គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខារនៃ គ.ជ.ប**

**ប្រការ ២.២១** សម្ភារ និងបរិក្ខារនៃ គ.ជ.ប ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការងាររៀបចំការបោះឆ្នោត លើកលែងតែមានការសម្រេចរបស់ គ.ជ.ប ។

២.២១.១ គ្មានសមាជិក ឬបុគ្គលិកនៃ គ.ជ.ប ឬនៃគណៈកម្មការថ្នាក់ណាមួយអាចប្រើប្រាស់បរិក្ខារ ឬ/និងសម្ភារនៃ គ.ជ.ប ក្រៅពីគោលបំណងបំរើឱ្យការរៀបចំការបោះឆ្នោតឡើយ ។ ត្រូវបានកំណត់ជាបរិក្ខារ សម្ភារមានដូចជា រថយន្ត សម្ភារការិយាល័យ សម្ភារចុះឈ្មោះបោះឆ្នោត សម្ភារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬសម្ភារផ្គត់ផ្គង់ការបោះឆ្នោត និងប្រេងឥន្ធនៈ ។ល។

២.២១.២ ប្រសិនបើសមាជិក ឬបុគ្គលិកនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយល្មើសនឹងចំណុច ២.២១.១ ជននោះនឹងត្រូវទទួលការដាក់ពិន័យ ។ វិធានការដាក់ពិន័យគឺគិតចាប់ពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ ។

២.២១.៣ ប្រសិនបើសមាជិក ឬបុគ្គលិកណាម្នាក់នៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយ ធ្វើឱ្យសម្ភារ បរិក្ខារត្រូវបាត់បង់ ឬខូចខាត ក្នុងពេលប្រើប្រាស់ខុសច្បាប់ សមាជិក ឬបុគ្គលិកនោះត្រូវទូទាត់សងតម្លៃនៃសម្ភារ បរិក្ខារដែលបានបាត់បង់ ឬខូចខាតនោះ ។

២.២១.៤ គ.ជ.ប ត្រូវចេញផ្សាយបទបញ្ជាជាមូលដ្ឋាន សម្រាប់ការប្រើប្រាស់សម្ភារ បរិក្ខាររបស់ គ.ជ.ប ។

**ប្រតិទិនការងារបោះឆ្នោត**

**ប្រការ ២.២២** គ.ជ.ប ត្រូវបោះពុម្ពផ្សាយប្រតិទិនការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.២២.១ បន្ទាប់ពីប្រកាសថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គ.ជ.ប ត្រូវចាត់ចែងធ្វើប្រតិទិនការងារបោះឆ្នោត និងបោះពុម្ពផ្សាយជាបន្ទាន់ ។

២.២២.២ ការបោះពុម្ពផ្សាយប្រតិទិនការងារបោះឆ្នោត ត្រូវធ្វើឡើងឱ្យបានមុនថ្ងៃចាប់ផ្តើមចុះឈ្មោះបោះឆ្នោត ។

២.២២.៣ ប្រតិទិននៃការងារបោះឆ្នោតនេះ ត្រូវកំណត់ ៖
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់នៃការចុះឈ្មោះបោះឆ្នោត
- ថ្ងៃចាប់ផ្តើមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ និងថ្ងៃបញ្ឈប់ទទួលពាក្យ
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត
- ថ្ងៃបោះឆ្នោត និងថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ន និងលទ្ធផលជាផ្លូវការ ។

**ការធានាសន្តិសុខបោះឆ្នោត**

**ប្រការ ២.២៣** ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលទទួលខុសត្រូវការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវផ្តល់កិច្ចសហការដល់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ នៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.២៣.១ ស្ថាប័នទទួលបន្ទុកសន្តិសុខរបស់រាជរដ្ឋាភិបាលត្រូវចេញសេចក្តីណែនាំ និងបទបញ្ជាផ្សេងៗ ទាក់ទងនឹងការងារសន្តិសុខទាំងមូល សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.២៣.២ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ដែលជាជំនួយការផ្នែកការងារសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប មានភារកិច្ចសម្របសម្រួល និងសហការជាមួយស្ថាប័នទទួលបន្ទុកសន្តិសុខរបស់រាជរដ្ឋាភិបាល ដើម្បីការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះ ។

**ប្រការ ២.២៤** យន្តការ និងរចនាសម្ព័ន្ធផ្នែកសន្តិសុខរបស់ គ.ជ.ប និងរាជរដ្ឋាភិបាល ត្រូវរៀបចំឱ្យមានប្រសិទ្ធភាព និងសមស្របនឹងទំហំការងារ ។

២.២៤.១ គ.ជ.ប គធ/ខប ក្រុមប្រឹក្សាឃុំ សង្កាត់ និង គកប ត្រូវសហការតាមឋានានុក្រមផ្នែកសន្តិសុខរបស់រាជរដ្ឋាភិបាល ដើម្បីរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដូចបានកំណត់ក្នុងប្រការ ២.២៤ ខាងលើ ។

២.២៨.២ កងកម្លាំងនគរបាលជាតិ ឬ/និងកងយោធពលខេមរភូមិន្ទ ឬ/និងកងរាជអាវុធហត្ថ ដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវស្ថិតក្នុងឯកសណ្ឋានត្រឹមត្រូវ និងត្រូវគោរពអនុវត្តតាមគោលការណ៍នៃ ច.ប.ក ប.ន.ក របស់ គ.ជ.ប ក្រមសីលធម៌ ព្រមទាំងសេចក្តីណែនាំផ្សេងៗ នៅក្នុងពេលកំពុងបំពេញភារកិច្ចការពារសកម្មភាពឃោសនាបោះឆ្នោត របស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ការដឹកជញ្ជូន ការរក្សាទុកនូវឯកសារ សម្ភារ និងឧបករណ៍ផ្សេងៗ សម្រាប់ការបោះឆ្នោត ។

២.២៨.៣ គធ/ខប ត្រូវចាត់ចែងរៀបចំកិច្ចប្រជុំចម្រុះ ក្នុងគោលបំណងជួបពិភាក្សា និងស្វែងរកដំណោះស្រាយសមស្រប រួមនឹងការចាត់វិធានការផ្សេងៗដើម្បីបង្ការ ទប់ស្កាត់ និងកាត់បន្ថយរាល់បញ្ហាទំនាស់ ឬបាតុភាពនានា ដែលអាចកើតមានឡើងជាយថាហេតុនៅគ្រប់ដំណាក់កាលនៃការរៀបចំការបោះឆ្នោត ។ កិច្ចប្រជុំត្រូវរៀបចំធ្វើឱ្យបានមួយ ឬពីរដងក្នុងមួយសប្តាហ៍ជាកំណត់ តាមស្ថានការណ៍ជាក់ស្តែង និងចាំបាច់ ។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ រួមមាន ៖

- ប្រធាន គធ/ខប ជាប្រធាន
- អភិបាលរាជធានី ខេត្ត ឬតំណាង ១ រូប ជាសមាជិក
- តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជាសមាជិក
- តំណាងការិយាល័យអង្គការសិទ្ធិមនុស្សប្រចាំរាជធានី ខេត្ត ជាសមាជិក
- តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ជាសមាជិក
- ស្នងការនគរបាលរាជធានី ខេត្ត ឬតំណាង ១ រូប ជាសមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង ១ រូប ជាសមាជិក
- មេបញ្ជាការកងយោធពលខេមរភូមិន្ទរាជធានី ខេត្ត ឬតំណាង ១ រូប ជាសមាជិក

២.២៨.៤ នៅពេលឃោសនាបោះឆ្នោត កងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ និងកងរាជអាវុធហត្ថដែលកំពុងបំពេញភារកិច្ច មិនត្រូវ ៖

២.២៨.៤.១ ចូលរួមប្រជុំជាសាធារណៈដើម្បីសម្តែងការគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ ។

២.២៨.៤.២ ឈរកៀកពេក ឬក៏ស្ថិតនៅជិតក្បួនឃោសនា ឬទីកន្លែង ដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោតរបស់បេក្ខជន វាគ្មិន ឬក្រុមឃោសនាបោះឆ្នោត របស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតណាមួយឡើយ ។

**ប្រការ ២.២៥** ដើម្បីការពារកុំឱ្យមានការរំខានអុកឡុក ការបំភិតបំភ័យ និងការគំរាមកំហែង ឬហេតុការណ៍ផ្សេងៗ ដែលនឹងអាចកើតមាន ហាមជនគ្រប់រូបយកអាវុធជាតិផ្ទុះ ឬសារជាតិ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.២៥.១ នៅថ្ងៃបោះឆ្នោតភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួនបី (៣) នាក់ ដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ និងត្រូវពាក់ប្រឡង់ដៃសន្តិសុខ ដែលកំណត់ដោយ គ.ជ.ប ។

២.២៥.១.១ ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួនមួយ (១) នាក់ ត្រូវចល័តការពារជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬក៏ចល័តការពារនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយត្រូវស្ថិតក្នុងចម្ងាយពី ១៥-១០០ ម៉ែត្រ គិតចាប់ពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយគ្មានសិទ្ធិប្រើប្រាស់អាវុធឡើយ ។

២.២៥.១.២ ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួនពីរ (២) នាក់ទៀតត្រូវចល័តការពារជុំវិញបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវស្ថិតនៅក្នុងចម្ងាយពី ១០០-១៥០ ម៉ែត្រ មានសិទ្ធិប្រើប្រាស់អាវុធវែង ០១ដើម បង់០១ ដែលមានគ្រាប់យ៉ាងច្រើន ចំនួន ៣០គ្រាប់ ។

២.២៥.២ ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមបុគ្គលិកពេទ្យ ឬ/និងក្រុមពន្លត់អគ្គិភ័យ អាចចូលធ្វើអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានតែក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គ.ជ.ប ប្រធាន គធ/ខប ឬពីប្រធាន គកប ។

**ប្រការ ២.២៦** នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ត្រូវពិនិត្យរៀបចំគម្រោងផលិត ឯកសារ និងសម្ភារទាក់ទងការងារសន្តិសុខ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

# ផ្នែកទី ២

# ប្រព័ន្ធបោះឆ្នោត និងរូបមន្ត

**ប្រព័ន្ធបោះឆ្នោត**

**ប្រការ២.២៧** យោងតាមមាត្រា ១៣ នៃ ច.ប.ក ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ដោយយករាជធានី ខេត្ត ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងយកក្រុង ស្រុក ខណ្ឌ ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយការបែងចែកអាសនៈ តាមមណ្ឌលនីមួយៗ ត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ។

**ប្រការ២.២៨** អាសនៈក្នុងក្រុមប្រឹក្សារាជធានី ខេត្ត និងអាសនៈក្នុងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវបានបែងចែក ដោយផ្អែកលើចំនួនអាសនៈតាមក្រុមប្រឹក្សា និងលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលបោះឆ្នោតនីមួយៗ ។ គធ/ខប ត្រូវធ្វើការបែងចែកអាសនៈ និងកំណត់ចំនួនអាសនៈដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សា សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតតាមមណ្ឌលបោះឆ្នោតនីមួយៗ ។

**ប្រការ២.២៩** បេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ត្រូវបានស្រង់ចេញ ដោយផ្អែកតាមលំដាប់លេខរៀងនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដែលបានជាប់ឆ្នោតនៅក្នុងមណ្ឌលនៃក្រុមប្រឹក្សានីមួយៗ ។

**រូបមន្តនៃការបែងចែកអាសនៈ**

**ប្រការ ២.៣០** ដើម្បីបែងចែកអាសនៈតាមមណ្ឌលបោះឆ្នោតក្រុមប្រឹក្សានីមួយៗ គធ/ខប ត្រូវអនុវត្តតាមជំហានទាំងឡាយដូចខាងក្រោម ៖

**<u>ជំហានទី១:</u> ការកំណត់កូតា ( Quota )**

២.៣០.១ កូតា គឺជាចំនួនសន្លឹកឆ្នោតបានការនៅក្នុងមណ្ឌលបោះឆ្នោតនីមួយៗ ដែលកំណត់ឡើងសម្រាប់ឱ្យគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅក្នុងមណ្ឌលនោះទទួលបានមួយ (១) អាសនៈ ។

២.៣០.២ ដើម្បីកំណត់កូតា ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធ ចែកនឹងចំនួនអាសនៈសរុប ដែលបានកំណត់សម្រាប់មណ្ឌលបោះឆ្នោតនោះ តាមរូបមន្ត ៖

$$ក_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ ៖

- $ក_{ត}$ តាងឱ្យកូតា ជាផលចែកដែលត្រូវគិតដល់ចំនួនទសភាគ ២ ខ្ទង់ក្រោយក្បៀស ។
- $ស_{ស}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ។
- $អ_{ស}$ តាងឱ្យចំនួនអាសនៈសរុប ។

**<u>ឧទាហរណ៍</u>: ការកំណត់កូតា**

នៅមណ្ឌលបោះឆ្នោតក្រុមប្រឹក្សាខេត្ត **A** មាន ៖

- សន្លឹកឆ្នោតបានការសរុប $ស_{ស}$ = ១.៧៦៥ សន្លឹក
- អាសនៈសរុប $អ_{ស}$ = ៩ អាសនៈ

$$ក_{ត} = \frac{ស_{ស}}{អ_{ស}} = \frac{១.៧៦៥}{៩} = ១៩៦,១១$$

កូតាស្មើនឹង ១៩៦,១១ ($ក_{ត}$ = ១៩៦,១១)

## <u>ជំហានទី២</u>: ការកំណត់ចំនួនអាសនៈបឋម ឬការបែងចែកអាសនៈលើកទី១

២.៣០.៣ ដើម្បីកំណត់ចំនួនអាសនៈបឋមសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវយកចំនួនសន្លឹកឆ្នោតបានការដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន មកចែកនឹងកូតា ដោយមិនគិតសំណល់ចែក តាមរូបមន្តដូចខាងក្រោម ៖

$$អ_{ទ} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ ៖

- $អ_{ទ}$ តាងឱ្យចំនួនអាសនៈ ជាផលចែកមិនគិតសំណល់ចែក ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី ១ តាមរូបមន្តជំហានទី២ ។
- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- $ក_{ត}$ តាងឱ្យកូតា ។

**<u>ឧទាហរណ៍:</u> ការបែងចែកអាសនៈលើកទី១**

នៅមណ្ឌលបោះឆ្នោតក្រុមប្រឹក្សាខេត្ត **A** ដដែល មានបញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៧ ៖

| | | | | | | |
|---|---|---|---|---|---|---|
| គណបក្ស | ក | មានសន្លឹកឆ្នោតបានការ | $ស_{ប}ក$ | = | ១២៣ | សន្លឹក |
| គណបក្ស | ខ | មានសន្លឹកឆ្នោតបានការ | $ស_{ប}ខ$ | = | ៣៣១ | សន្លឹក |
| គណបក្ស | គ | មានសន្លឹកឆ្នោតបានការ | $ស_{ប}គ$ | = | ៩៨ | សន្លឹក |
| គណបក្ស | ឃ | មានសន្លឹកឆ្នោតបានការ | $ស_{ប}ឃ$ | = | ៥១២ | សន្លឹក |
| គណបក្ស | ង | មានសន្លឹកឆ្នោតបានការ | $ស_{ប}ង$ | = | ៣៩៥ | សន្លឹក |
| គណបក្ស | ច | មានសន្លឹកឆ្នោតបានការ | $ស_{ប}ច$ | = | ៥៤ | សន្លឹក |
| គណបក្ស | ឆ | មានសន្លឹកឆ្នោតបានការ | $ស_{ប}ឆ$ | = | ២៥២ | សន្លឹក |

អនុវត្តតាមរូបមន្ត ដូចចែងក្នុងចំណុច ២.៣០.៣ យើងបាន ៖

គណបក្ស ក $អ_{ទ}ក = \frac{១២៣}{១៩៦,១១} = ០,៦២$ ត្រូវជា ០ អាសនៈ

គណបក្ស ខ $អ_{ទ}ខ = \frac{៣៣១}{១៩៦,១១} = ១,៦៨$ ត្រូវជា ១ អាសនៈ

គណបក្ស គ $អ_{ទ}គ = \frac{៩៨}{១៩៦,១១} = ០,៤៩$ ត្រូវជា ០ អាសនៈ

គណបក្ស ឃ $អ_{ទ}ឃ = \frac{៥១២}{១៩៦,១១} = ២,៦១$ ត្រូវជា ២ អាសនៈ

គណបក្ស ង $អ_{ទ}ង = \frac{៣៩៥}{១៩៦,១១} = ២,០១$ ត្រូវជា ២ អាសនៈ

គណបក្ស ច $អ_{ទ}ច = \frac{៥៤}{១៩៦,១១} = ០,២៧$ ត្រូវជា ០ អាសនៈ

គណបក្ស ឆ $អ_{ទ}ឆ = \frac{២៥២}{១៩៦,១១} = ១,២៨$ ត្រូវជា ១ អាសនៈ

២.៣០.៤ បន្ទាប់ពីការគណនាបែងចែកអាសនៈ គ្រប់គណបក្សនយោបាយទាំងអស់ក្នុងជំហានទី២ រួច ប្រសិនបើគ្មានអាសនៈនៅសល់ នោះចំនួនអាសនៈត្រូវកំណត់យកតែម្តង ។

## ជំហានទី៣: ការកំណត់មធ្យមភាគខ្ពស់បំផុត

២.៣០.៥ ក្នុងករណីមានអាសនៈនៅសល់ គជ/ខប ត្រូវបន្តបែងចែក ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមការគណនាដូចខាងក្រោម ៖

២.៣០.៥.១ ត្រូវកំណត់ជាដំបូងនូវមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ចែកនឹងចំនួនអាសនៈបឋម ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល បន្ទាប់ពីការគណនាក្នុងជំហានទី ២ បូកនឹងលេខនិមិត្តចំនួនមួយ (១) តាមរូបមន្តដូចខាងក្រោម ៖

$$ម_{ធ} = \frac{ស_{ប}}{អ_{ទ}+១}$$

ក្នុងនោះ ៖

- $ម_{ធ}$ តាងឱ្យមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- $ស_{ប}$ តាងឱ្យសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗ ។
- $អ_{ទ}$ តាងឱ្យចំនួនអាសនៈបឋម ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបាន បន្ទាប់ពីការបែងចែកលើកទី១ ។
- លេខ ១ ជាលេខនិមិត្ត

២.៣០.៥.២ ក្នុងការគណនារកមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ប្រសិនបើលេខចែកមិនដាច់ ត្រូវបន្តចែកដល់ចំនួនទសភាគពីរ (២) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់រកបញ្ជីបេក្ខជននៃគណបក្សនយោបាយណា ដែលមានមធ្យមភាគខ្ពស់ជាងគេ ។

២.៣០.៥.៣ បន្ទាប់ពីកំណត់បានមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចហើយ ត្រូវធ្វើការប្រៀបធៀបគ្នា ។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណា មានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុតត្រូវទទួលបានអាសនៈមួយ (១) ។

**ឧទាហរណ៍ : ការបែងចែកអាសនៈលើកទី២**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល តាមការបែងចែកអាសនៈលើកទី១ យើងបាន ៖

គណបក្ស ក បានទទួលអាសនៈ ០

គណបក្ស ខ បានទទួលអាសនៈ ១

គណបក្ស គ បានទទួលអាសនៈ ០

គណបក្ស ឃ បានទទួលអាសនៈ ២

គណបក្ស ង បានទទួលអាសនៈ ២

គណបក្ស ច បានទទួលអាសនៈ ០

គណបក្ស ឆ បានទទួលអាសនៈ ១

- អាសនៈដែលបានបែងចែកលើកទី១ មាន ៦ អាសនៈ
- អាសនៈសរុបក្នុងមណ្ឌលខេត្ត A មាន ៩ អាសនៈ
- អាសនៈនៅសល់ដែលត្រូវបន្តធ្វើការបែងចែកមាន ៣ អាសនៈ

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងការបែងចែកអាសនៈលើកទី ២ នេះ យើងបាន ៖

| | | | | | | |
|---|---|---|---|---|---|---|
| គណបក្ស | ក | មធក | = | $\frac{១២៣}{០+១}$ | = | **១២៣,០០** |
| គណបក្ស | ខ | មធខ | = | $\frac{៣៣១}{១+១}$ | = | ១៦៥,៥០ |
| គណបក្ស | គ | មធគ | = | $\frac{៩៨}{០+១}$ | = | ៩៨,០០ |
| គណបក្ស | ឃ | មធឃ | = | $\frac{៥១២}{២+១}$ | = | ១៧០,៦៦ |
| គណបក្ស | ង | មធង | = | $\frac{៣៩៥}{២+១}$ | = | ១៣១,៦៦ |
| គណបក្ស | ច | មធច | = | $\frac{៥៨}{០+១}$ | = | ៥៨,០០ |
| គណបក្ស | ឆ | មធឆ | = | $\frac{២៥២}{១+១}$ | = | ១២៦,០០ |

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងប្រាំពីរ (៧) ខាងលើ បញ្ជីបេក្ខជននៃគណបក្ស ឃ មានមធ្យមភាគខ្ពស់ជាងគេគឺ **១៧០,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត ។ ដូចនេះបញ្ជីបេក្ខជននៃគណបក្ស ឃ ត្រូវទទួលបានអាសនៈមួយ (១) ។

២.៣០.៦ ក្នុងករណីមាននៅសល់អាសនៈ គជ/ខប ត្រូវបន្តបែងចែកទៀតតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដដែល ។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈលើកទី៣**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល

តាមការបែងចែកអាសនៈលើកទី២ យើងបាន ៖

| | | | |
|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស ក | បានទទួលអាសនៈ: | ០ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស ខ | បានទទួលអាសនៈ: | ១ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស គ | បានទទួលអាសនៈ: | ០ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស ឃ | បានទទួលអាសនៈ: | ៣ | (បាន ១ អាសនៈបន្ថែម) |
| បញ្ជីបេក្ខជននៃគណបក្ស ង | បានទទួលអាសនៈ: | ២ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស ច | បានទទួលអាសនៈ: | ០ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស ឆ | បានទទួលអាសនៈ: | ១ | ដដែល |

- សរុបអាសនៈដែលបានបែងចែកលើកទី១ និងលើកទី២មាន ៧ អាសនៈ
- អាសនៈសរុបក្នុងមណ្ឌលបោះឆ្នោតក្រុមប្រឹក្សាខេត្ត A មាន ៩ អាសនៈ

ដូចនេះនៅសល់អាសនៈពីរ (២) ទៀត ដែលត្រូវបន្តបែងចែក ។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងការបែងចែកអាសនៈលើកទី ៣ នេះ យើងបាន ៖

| | | | | | |
|---|---|---|---|---|---|
| គណបក្ស | ក | $ម_{ធ}ក$ | = | $\frac{១២៣}{០+១}$ | = ១២៣,០០ |
| គណបក្ស | ខ | $ម_{ធ}ខ$ | = | $\frac{៣៣១}{១+១}$ | = ១៦៥,៥០ |
| គណបក្ស | គ | $ម_{ធ}គ$ | = | $\frac{៩៨}{០+១}$ | = ៩៨,០០ |
| គណបក្ស | ឃ | $ម_{ធ}ឃ$ | = | $\frac{៥១២}{៣+១}$ | = **១២៨,០០** |
| គណបក្ស | ង | $ម_{ធ}ង$ | = | $\frac{៣៩៥}{២+១}$ | = ១៣១,៦៦ |
| គណបក្ស | ច | $ម_{ធ}ច$ | = | $\frac{៥៤}{០+១}$ | = ៥៤,០០ |
| គណបក្ស | ឆ | $ម_{ធ}ឆ$ | = | $\frac{២៥២}{១+១}$ | = ១២៦,០០ |

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងប្រាំពីរ (៧) ខាងលើ បញ្ជីបេក្ខជននៃគណបក្ស ខ មានមធ្យមភាគធំជាងគេ ១៦៥,៥០ ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ត្រូវបានទទួលអាសនៈមួយ (១) នាំឱ្យ ៖

| | | | | |
|---|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | ក | បានទទួលអាសនៈ | ០ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស | ខ | បានទទួលអាសនៈ | ២ | (ទទួលបន្ថែម១អាសនៈ) |
| បញ្ជីបេក្ខជននៃគណបក្ស | គ | បានទទួលអាសនៈ | ០ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស | ឃ | បានទទួលអាសនៈ | ៣ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស | ង | បានទទួលអាសនៈ | ២ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស | ច | បានទទួលអាសនៈ | ០ | ដដែល |
| បញ្ជីបេក្ខជននៃគណបក្ស | ឆ | បានទទួលអាសនៈ | ១ | ដដែល |

សរុប = ប្រាំពីរ (៨) អាសនៈ

២.៣០.៧ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀត ការគណនាត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ហើយបន្តបែងចែកតាមរបៀបនេះម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈដែលនៅសល់ ។

**ឧទាហរណ៍ : ការបែងចែកអាសនៈបន្ត**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល

បន្ទាប់ពីការបែងចែកអាសនៈលើកទី៣ នៅមានសល់អាសនៈចំនួនមួយ (១) ទៀត ដែលត្រូវបន្តបែងចែក ។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងការបែងចែកលើកទី ៨ នេះ យើងបាន ៖

គណបក្ស ក $មធក = \frac{១២៣}{០+១} = ១២៣,០០$

គណបក្ស ខ $មធខ = \frac{៣៣១}{២+១} = ១១០,៣៣$

គណបក្ស គ $មធគ = \frac{៩៨}{០+១} = ៩៨,០០$

គណបក្ស ឃ $ម_ធឃ = \frac{៥១២}{៣+១}$ = **១២៨,០០**

គណបក្ស ង $ម_ធង = \frac{៣៩៥}{២+១}$ = **១៣១,៦៦**

គណបក្ស ច $ម_ធច = \frac{៥៤}{០+១}$ = ១០៨,០០

គណបក្ស ឆ $ម_ធឆ = \frac{២៥២}{១+១}$ = ១២៦,០០

តាមការប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំងប្រាំពីរ (៧) ខាងលើឃើញថា បញ្ជីបេក្ខជននៃគណបក្ស **ង** មានមធ្យមភាគធំជាងគេ **១៣១,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត ។ ដូចនេះ បញ្ជីបេក្ខជននៃគណបក្ស **ង** ត្រូវបានទទួលអាសនៈមួយ (១) ដែលនៅសល់ចុងក្រោយនេះ ។ ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈនៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A យើងបាន ៖

បញ្ជីបេក្ខជននៃគណបក្ស ខ បានទទួលអាសនៈ ២

បញ្ជីបេក្ខជននៃគណបក្ស ឃ បានទទួលអាសនៈ ៣

បញ្ជីបេក្ខជននៃគណបក្ស ង បានទទួលអាសនៈ ៣

បញ្ជីបេក្ខជននៃគណបក្ស ឆ បានទទួលអាសនៈ ១

បញ្ជីបេក្ខជននៃគណបក្ស ក គ និង ច ពុំបានទទួលអាសនៈ

សរុប = ប្រាំបួន (៩) អាសនៈ

**ប្រការ** ២.៣១ ក្នុងករណី ការបែងចែកអាសនៈលើកទី ១ តាមរូបមន្តជំហានទី ២ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈទេនោះ គធ/ខប ត្រូវបន្តបែងចែក ដោយអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងជំហានទី ៣ ម្តងមួយ (១) អាសនៈៗ រហូតដល់អស់អាសនៈ ។

**<u>ឧទាហរណ៍</u>**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង B មាន ៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយមានចំនួន = ៩
- សន្លឹកឆ្នោតបានការសរុប $ស_ស$ = ៨៤៦ សន្លឹក
- អាសនៈសរុប $អ_ស$ = ៧ អាសនៈ
- កូតា $ក_ត$ = ១២០,៨៥

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងជំហានទី ៣ ទាំងប្រាំពីរ (៧) លើក យើងទទួលបាន

| បញ្ជីបេក្ខជននៃ | $ស_{ស}$ | $អ_{ទ១}$ | $ម_{ធ១}$ | $អ_{ទ២}$ | $ម_{ធ២}$ | $អ_{ទ៣}$ | $ម_{ធ៣}$ | $អ_{ទ៤}$ | $ម_{ធ៤}$ | $អ_{ទ៥}$ | $ម_{ធ៥}$ | $អ_{ទ៦}$ | $ម_{ធ៦}$ | $អ_{ទ៧}$ | $ម_{ធ៧}$ | $អ_{ទ៨}$ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គណបក្ស **ក** | ១១៣ | ០ | $\frac{១១៣}{០+១}$ | ០ | $\frac{១១៣}{០+១}$ | ១ | $\frac{១១៣}{១+១}$ | ០ | $\frac{១១៣}{១+១}$ | ០ | $\frac{១១៣}{១+១}$ | ០ | $\frac{១១៣}{១+១}$ | ០ | $\frac{១១៣}{១+១}$ | ០ |
| គណបក្ស **ខ** | ៩៧ | ០ | $\frac{៩៧}{០+១}$ | ០ | $\frac{៩៧}{០+១}$ | ០ | $\frac{៩៧}{០+១}$ | ០ | $\frac{៩៧}{០+១}$ | ០ | $\frac{៩៧}{០+១}$ | ១ | $\frac{៩៧}{១+១}$ | ០ | $\frac{៩៧}{១+១}$ | ០ |
| គណបក្ស **គ** | ៨៦ | ០ | $\frac{៨៦}{០+១}$ | ០ | $\frac{៨៦}{០+១}$ | ០ | $\frac{៨៦}{០+១}$ | ០ | $\frac{៨៦}{០+១}$ | ០ | $\frac{៨៦}{០+១}$ | ០ | $\frac{៨៦}{០+១}$ | ០ | $\frac{៨៦}{០+១}$ | ១ |
| គណបក្ស **ឃ** | ១១៥ | ០ | $\frac{១១៥}{០+១}$ | ១ | $\frac{១១៥}{១+១}$ | ០ | $\frac{១១៥}{១+១}$ | ០ | $\frac{១១៥}{១+១}$ | ០ | $\frac{១១៥}{១+១}$ | ០ | $\frac{១១៥}{១+១}$ | ០ | $\frac{១១៥}{១+១}$ | ០ |
| គណបក្ស **ង** | ៧៣ | ០ | $\frac{៧៣}{០+១}$ | ០ | $\frac{៧៣}{០+១}$ | ០ | $\frac{៧៣}{០+១}$ | ០ | $\frac{៧៣}{០+១}$ | ០ | $\frac{៧៣}{០+១}$ | ០ | $\frac{៧៣}{០+១}$ | ០ | $\frac{៧៣}{០+១}$ | ០ |
| គណបក្ស **ច** | ១០៦ | ០ | $\frac{១០៦}{០+១}$ | ០ | $\frac{១០៦}{០+១}$ | ០ | $\frac{១០៦}{០+១}$ | ១ | $\frac{១០៦}{១+១}$ | ០ | $\frac{១០៦}{១+១}$ | ០ | $\frac{១០៦}{១+១}$ | ០ | $\frac{១០៦}{១+១}$ | ០ |
| គណបក្ស **ឆ** | ៩២ | ០ | $\frac{៩២}{០+១}$ | ០ | $\frac{៩២}{០+១}$ | ០ | $\frac{៩២}{០+១}$ | ០ | $\frac{៩២}{០+១}$ | ០ | $\frac{៩២}{០+១}$ | ០ | $\frac{៩២}{០+១}$ | ១ | $\frac{៩២}{១+១}$ | ០ |
| គណបក្ស **ជ** | ១០១ | ០ | $\frac{១០១}{០+១}$ | ០ | $\frac{១០១}{០+១}$ | ០ | $\frac{១០១}{០+១}$ | ០ | $\frac{១០១}{០+១}$ | ១ | $\frac{១០១}{១+១}$ | ០ | $\frac{១០១}{១+១}$ | ០ | $\frac{១០១}{១+១}$ | ០ |
| គណបក្ស **ឈ** | ៦៣ | ០ | $\frac{៦៣}{០+១}$ | ០ | $\frac{៦៣}{០+១}$ | ០ | $\frac{៦៣}{០+១}$ | ០ | $\frac{៦៣}{០+១}$ | ០ | $\frac{៦៣}{០+១}$ | ០ | $\frac{៦៣}{០+១}$ | ០ | $\frac{៦៣}{០+១}$ | ០ |

ករណីនេះអាចកើតមានក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណា ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយ មានចំនួនសន្លឹកឆ្នោតបានការប្រហាក់ប្រហែលគ្នា ។

តាមតារាងឧទាហរណ៍ខាងលើ យើងបាន ៖

- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ
- $អ_{ស}១$ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី ១ តាមរូបមន្តជំហានទី ២ ដែលក្នុងនោះពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈ និងត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងជំហានទី ៣ ។
- $ម_{ធ}១$ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ១ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស ឃ មានមធ្យមភាគធំជាងគេ ១១៥,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ស}២$ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី ២ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស ឃ ។
- $ម_{ធ}២$ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ២ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស ក មានមធ្យមភាគធំជាងគេ ១១៣,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ស}៣$ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី ៣ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស ក ។
- $ម_{ធ}៣$ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ៣ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស ច មានមធ្យមភាគធំជាងគេ ១០៦,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ស}៤$ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី ៤ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស ច ។
- $ម_{ធ}៤$ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ៤ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស ជ មានមធ្យមភាគធំជាងគេ ១០១,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ស}៥$ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី ៥ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស ជ ។

- មធ្ម៥ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ៥ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស ខ មានមធ្យមភាគធំជាងគេ ៩៧,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អទូ៦ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី ៦ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស ខ ។
- មធ្ម៦ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ៦ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស ឆ មានមធ្យមភាគធំជាងគេ ៩២,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អទូ៧ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី ៧ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស ឆ ។
- មធ្ម៧ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ៧ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស គ មានមធ្យមភាគធំជាងគេ ៨៦,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អទូ៨ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី ៨ ក្នុងនោះអាសនៈចំនួនមួយ (១) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស គ ។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈ ក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង B យើងបាន ៖

- គណបក្ស ឃ ទទួលបានមួយ (១) អាសនៈ
- គណបក្ស ក ទទួលបានមួយ (១) អាសនៈ
- គណបក្ស ច ទទួលបានមួយ (១) អាសនៈ
- គណបក្ស ជ ទទួលបានមួយ (១) អាសនៈ
- គណបក្ស ខ ទទួលបានមួយ (១) អាសនៈ
- គណបក្ស ឆ ទទួលបានមួយ (១) អាសនៈ
- គណបក្ស គ ទទួលបានមួយ (១) អាសនៈ
- គណបក្ស ង និង ឈ មិនបានទទួលអាសនៈ

សរុប = ប្រាំពីរ (៧) អាសនៈ

**ករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន**

**ប្រការ** ២.៣២ ក្នុងករណី ដែលគណបក្សនយោបាយណាមួយបានទទួលអាសនៈមួយ ឬច្រើនក្នុងក្រុមប្រឹក្សាណាមួយ ប៉ុន្តែស្ថិតក្នុងស្ថានភាពដូចចែងក្នុងកថាខណ្ឌទី ៣ ចំណុច **ឃ** មាត្រា ១៣ នៃ ច.ប.ក ឬបានប្រកាសបោះបង់ចោលអាសនៈដែលខ្លួនបានទទួល ឬត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយ តាមច្បាប់ស្តីពីគណបក្សនយោបាយ គ.ជ.ប ត្រូវបែងចែកអាសនៈដែលបោះបង់ចោល ឬនៅទំនេរនោះទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀត ដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សាពាក់ព័ន្ធ ក្នុងអំឡុងពេលយ៉ាងយូរដប់បួន (១៤) ថ្ងៃ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចថាគណបក្សនយោបាយនោះបានបោះបង់ចោលអាសនៈ ឬទទួលបានលិខិតបោះបង់អាសនៈចោល ឬលិខិតលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយជាផ្លូវការដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយ ដូចខាងក្រោម ៖

**<u>ជំហានទី១:</u> ការកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ**

២.៣២.១ ដើម្បីកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ សម្រាប់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយពាក់ព័ន្ធទទួលបានមួយ (១) អាសនៈ ត្រូវយកសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយទាំងអស់ដែលមានអាសនៈក្នុងក្រុមប្រឹក្សានោះ ដកនឹងចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ រួចយកមកចែកនឹងចំនួនអាសនៈដែលបោះបង់ចោល តាមរូបមន្ត ៖

$$ក់_{ត} = \frac{ស់_{ស}}{អ់_{ប}}$$

ក្នុងនោះ ៖

- $ក់_{ត}$ តាងឱ្យកូតានៃអាសនៈដែលបោះបង់ចោល ឬនៅទំនេរ ដែលជាផលចែកគិតដល់ចំនួនទសភាគពីរ (២) ខ្ទង់ក្រោយក្បៀស ។
- $ស់_{ស}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលមានអាសនៈក្នុងក្រុមប្រឹក្សាពាក់ព័ន្ធ ដកចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ។
- $អ់_{ប}$ តាងឱ្យចំនួនអាសនៈ ដែលបោះបង់ចោលក្នុងក្រុមប្រឹក្សា ។

**ឧទាហរណ៍** : **ការកំណត់កូតា នៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល ៖

បញ្ជីបេក្ខជននៃគណបក្ស ខ បានទទួលអាសនៈ ២

បញ្ជីបេក្ខជននៃគណបក្ស ឃ បានទទួលអាសនៈ ៣

បញ្ជីបេក្ខជននៃគណបក្ស ង បានទទួលអាសនៈ ៣

បញ្ជីបេក្ខជននៃគណបក្ស ឆ បានទទួលអាសនៈ ១

បញ្ជីបេក្ខជននៃគណបក្ស ក គ និង ច ពុំបានទទួលអាសនៈ

- គណបក្សនយោបាយ ខ បានបោះបង់ចោលអាសនៈទាំងពីរ (២) ។
- គណបក្សនយោបាយដែលមានអាសនៈក្នុងក្រុមប្រឹក្សាខេត្ត A មាន ៤ គឺគណបក្សនយោបាយ ខ ឃ ង និង ឆ ។

នៅពេលដែលគណបក្សនយោបាយ ខ បានបោះបង់ចោលអាសនៈរបស់ខ្លួន អាសនៈដែលបោះបង់ចោលនោះត្រូវយកមកបែងចែកឱ្យគណបក្សនយោបាយ ឃ ង និង ឆ ដែលមានអាសនៈក្នុងក្រុមប្រឹក្សាខេត្ត A រីឯគណបក្ស ក គ និង ច ដែលពុំបានទទួលអាសនៈក្នុងក្រុមប្រឹក្សានេះ មិនត្រូវបានរាប់បញ្ចូលក្នុងការបែងចែកអាសនៈ ដែលគណបក្ស ខ បានបោះបង់ចោលឡើយ ។

នៅពេលអនុវត្តតាមរូបមន្តក្នុងចំណុច ២.៣២.១ ខាងលើ យើងបាន ៖

$$សស_{ស} = (៣៣១+៥១២+៣៩៥+២៥២)-៣៣១ = ១.១៥៩ \text{ សន្លឹក}$$

$$អអ_{ប} = ២ \text{ អាសនៈ}$$

$$កក_{ត} = \frac{សស_{ស}}{អអ_{ប}} = \frac{១.១៥៩}{២} = ៥៧៩,៥០$$

កូតាស្មើនឹង ៥៧៩,៥០ ($កក_{ត}$ = ៥៧៩,៥០) ។

**ជំហានទី២: ការបែងចែកអាសនៈ ដែលបោះបង់ចោល ឬនៅទំនេរលើកទី ១**

២.៣២.២ ដើម្បីបែងចែកអាសនៈដែលត្រូវបានបោះបង់ចោល ឬនៅទំនេរលើកទី ១ ឱ្យទៅបញ្ជីបេក្ខជននៃគណបក្ស ឃ ង និង ឆ ត្រូវយកចំនួនសន្លឹកឆ្នោតបានការដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗបានទទួល មកចែកនឹងកូតានៃអាសនៈដែលបោះបង់ចោល ឬនៅទំនេរ តាមរូបមន្តដូចខាងក្រោម ៖

$$អ់_ទ = \frac{ស_ប}{ក់_គ}$$

ក្នុងនោះ ៖

- $អ់_ទ$ តាងឱ្យចំនួនអាសនៈដែលបោះបង់ចោល ឬនៅទំនេរ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗបានទទួលក្នុងការបែងចែកលើកទី ១ តាមរូបមន្តជំហានទី ២ ។
- $ស_ប$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ
- $ក់_គ$ តាងឱ្យកូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ ដែលបានកំណត់ក្នុងជំហានទី ១ ។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោលលើកទី១**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល

បន្ទាប់ពីអនុវត្តការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោល តាមរូបមន្តក្នុងជំហានទី២ យើងបាន ៖

$$\text{គណបក្ស ឃ} \quad អ់_ទឃ = \frac{៥១២}{៥៧៩,៥០} = ០,៨៨$$

$$\text{គណបក្ស ង} \quad អ់_ទង = \frac{៣៩៥}{៥៧៩,៥០} = ០,៦៨$$

$$\text{គណបក្ស ឆ} \quad អ់_ទឆ = \frac{២៥២}{៥៧៩,៥០} = ០,៤៣$$

តាមការគណនាខាងលើ ពុំមានគណបក្សណាមួយទទួលបានអាសនៈ ដែលត្រូវបានបោះបង់ចោល ឬនៅទំនេរនេះទេ ។

២.៣២.៣ ក្នុងករណីគ្មានអាសនៈនៅសល់សម្រាប់បែងចែកបន្ត បន្ទាប់ពីការបែងចែកលើទី១ តាមរូបមន្ត ក្នុងជំហានទី២ ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយបានទទួលក្នុងមណ្ឌលនោះ ត្រូវកំណត់យកតែម្តង ។

**<u>ជំហានទី៣</u>: ការកំណត់មធ្យមភាគខ្ពស់បំផុត**

២.៣២.៤ ក្នុងករណី បន្ទាប់ពីការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោល ឬនៅទំនេរលើកទី១ តាមរូបមន្តជំហានទី២ ពុំមានបញ្ជីបេក្ខជននៃគណបក្សណាមួយទទួលបានអាសនៈ ឬនៅមានសល់អាសនៈ អាសនៈដែលមាន ឬនៅសល់នោះត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី ៣ ខាងក្រោម ។

២.៣២.៥ ដើម្បីគណនារកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ចែកនឹងចំនួន

អាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សទាំងនោះបានទទួល បន្ទាប់ពីការបែងចែកលើកទី១ ក្នុងជំហានទី២ បូកនឹងលេខនិមិត្តចំនួនមួយ (១) តាមរូបមន្តខាងក្រោម ៖

$$ម៉_{ធ} = \frac{ស_{ប}}{អ៉_{ទ}+១}$$

ក្នុងនោះ ៖

- ម៉$_{ធ}$ តាងឱ្យមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- ស$_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- អ៉$_{ទ}$ តាងឱ្យចំនួនអាសនៈ ដែលបោះបង់ចោល ឬនៅទំនេរដែលបញ្ជីបេក្ខជននៃគណបក្ស នីមួយៗទទួលបានក្នុងការបែងចែកលើកទី ១ ។
- ១ ជាលេខនិមិត្ត

២.៣២.៦ បន្ទាប់ពីកំណត់បានមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចហើយ ត្រូវធ្វើការប្រៀបធៀបគ្នា ។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត នឹងត្រូវទទួលបានអាសនៈមួយ (១)។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោលលើកទី ២**

បន្ទាប់ពីការបែងចែកលើកទី ១ តាមរូបមន្តក្នុងជំហានទី ២ ពុំមានបញ្ជីបេក្ខជននៃគណបក្សណាមួយ ទទួលអាសនៈដែលត្រូវបានបោះបង់ចោលទេ ។

បន្ទាប់ពីអនុវត្តតាមរូបមនមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន ៖

| | | | | |
|---|---|---|---|---|
| គណបក្ស | ឃ | ម៉$_{ធ}$ឃ | $= \frac{៥១២}{0+១}$ | = ៥១២,00 |
| គណបក្ស | ង | ម៉$_{ធ}$ង | $= \frac{៣៩៥}{0+១}$ | = ៣៩៥,00 |
| គណបក្ស | ឆ | ម៉$_{ធ}$ឆ | $= \frac{២៥២}{0+១}$ | = ២៥២,00 |

តាមការប្រៀបធៀបមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងបីខាងលើ បញ្ជីបេក្ខជននៃគណបក្ស ឃ មានមធ្យមភាគធំជាងគេគឺ **៥១២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស ឃ ត្រូវទទួលបានអាសនៈដែលត្រូវបានបោះបង់ចោល ឬនៅទំនេរមួយ (១) អាសនៈ ។

២.៣២.៧ ប្រសិនបើនៅមានសល់អាសនៈ បន្ទាប់ពីការបែងចែកលើកទី២ អាសនៈដែលនៅសល់នោះត្រូវបន្តបែងចែកម្តងមួយអាសនៈៗរហូតដល់អស់អាសនៈ តាមរូបមន្តក្នុងជំហានទី ៣ ដដែល ។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោលលើកទី ៣**
បន្ទាប់ពីការបែងចែកលើកទី ២ នៅមានសល់អាសនៈមួយ (១) ទៀត ត្រូវបន្តបែងចែក ។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន ៖

គណបក្ស ឃ $ម៉_ធឃ = \frac{៥១២}{១+១} =$ ២៥៦,០០

គណបក្ស ង $ម៉_ធង = \frac{៣៩៥}{០+១} =$ ៣៩៥,០០

គណបក្ស ឆ $ម៉_ធឆ = \frac{២៥២}{០+១} =$ ២៥២,០០

តាមការប្រៀបធៀបមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងបីខាងលើ បញ្ជីបេក្ខជននៃគណបក្ស ង មានមធ្យមភាគធំជាងគេគឺ **៣៩៥,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស ង ត្រូវទទួលបានអាសនៈមួយ (១) ដែលនៅសល់ចុងក្រោយ ។
ជាលទ្ធផលសម្រេចក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ៖

បញ្ជីបេក្ខជននៃគណបក្ស ឃ បានទទួលអាសនៈ ៤
បញ្ជីបេក្ខជននៃគណបក្ស ង បានទទួលអាសនៈ ៤
បញ្ជីបេក្ខជននៃគណបក្ស ឆ បានទទួលអាសនៈ ១
សរុប = ប្រាំបួន (៩) អាសនៈ

**ករណីលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន**

**ប្រការ** ២.៣៣ ក្នុងករណី ការគណនាតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចចែងក្នុងចំណុច ២.៣០.៥.១ និង ២.៣២.៥ នៃ ប.ន.ក នេះ មានលទ្ធផលមធ្យមភាគស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន នោះការបែងចែកអាសនៈត្រូវកំណត់ដូចខាងក្រោម ៖

២.៣៣.១ ក្នុងករណីអាសនៈនៅសល់ បន្ទាប់ពីការបែងចែកលើកទី ១ មានចំនួនស្មើ ឬលើសពីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា គច/ខប ត្រូវផ្តល់ឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងនោះមួយ (១) អាសនៈ សម្រាប់គណបក្សនីមួយៗ ។ ហើយបើមាននៅសល់អាសនៈទៀត ត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដដែល ។

**<u>ឧទាហរណ៍</u>**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត **C** មាន ៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយមានចំនួន ៥
- សន្លឹកឆ្នោតបានការសរុប $សស_{ស}$ = ១.៣៥១ សន្លឹក
- អាសនៈសរុប $អ_{ស}$ = ១៥ អាសនៈ
- កូតា $ក_{ត}$ = ៩០,០៦

| បញ្ជីបេក្ខជន | $ស_{ប}$ | $អ_{ទ}១$ លើកទី១ | $ម_{ធ}១$ | $អ_{ទ}២$ លើកទី២ |
|---|---|---|---|---|
| គណបក្ស **ក** | ៨០ | ០ | $\frac{៨០}{០+១}$ = ៨០,០០ | ០ |
| គណបក្ស **ខ** | ២៥៩ | ២ | $\frac{២៥៩}{២+១}$ = ៨៦,៣៣ | ១ |
| គណបក្ស **គ** | ៩៣ | ១ | $\frac{៩៣}{១+១}$ = ៤៦,៥០ | ០ |
| គណបក្ស **ឃ** | ១៨២ | ២ | $\frac{១៨២}{២+១}$ = ៦០,៦៦ | ០ |
| គណបក្ស **ង** | ៧៧៧ | ៨ | $\frac{៧៧៧}{៨+១}$ = ៨៦,៣៣ | ១ |

- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។

- អ$_{\text{ទ}}$១ តាងឱ្យចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ ។

- ម$_{\text{ធ}}$១ តាងឱ្យលទ្ធផលនៃការគណនាមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស ខ និង ង មានមធ្យមភាគធំជាងគេ ស្មើគ្នាគឺ **៨៦,៣៣** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះអនុវត្តតាមចំណុច ២.៣៣.១ គជ/ខប ត្រូវបែងចែកអាសនៈដែលនៅសល់ពីរ (២) នោះឱ្យទៅបញ្ជីបេក្ខជននៃគណបក្ស ខ មួយ (១) អាសនៈ និងគណបក្ស ង មួយ (១) អាសនៈ ។

- អ$_{\text{ទ}}$២ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី ២ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ និង ង ត្រូវទទួលបានមួយ (១) អាសនៈបន្ថែម សម្រាប់គណបក្សនីមួយៗ ។

ជាលទ្ធផលសំរេចក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត **C** គឺ ៖

- គណបក្សនយោបាយ ខ ទទួលបានបី (៣) អាសនៈ
- គណបក្សនយោបាយ គ ទទួលបានមួយ (១) អាសនៈ
- គណបក្សនយោបាយ ឃ ទទួលបានពីរ (២) អាសនៈ
- គណបក្សនយោបាយ ង ទទួលបានប្រាំបួន (៩) អាសនៈ
- គណបក្សនយោបាយ ក ពុំបានទទួលអាសនៈ

សរុប = ដប់ប្រាំ (១៥) អាសនៈ ។

២.៣៣.២ ក្នុងករណីអាសនៈនៅសល់ មានចំនួនតិចជាងចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលមានលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា គជ/ខប ត្រូវអនុវត្តវិធីចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈនោះ ។

**<u>ឧទាហរណ៍</u>**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង **D** មាន ៖

- ចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ : ៧
- ចំនួនសន្លឹកឆ្នោតបានការសរុប : ស$_{\text{ស}}$ = ៦៦៣
- ចំនួនអាសនៈសរុប : អ$_{\text{ស}}$ = ១១ អាសនៈ
- កូតា : ក$_{\text{ត}}$ = ៦០,២៧

| បញ្ជីបេក្ខជន | ស$_{ប}$ | អ$_{ទ}$១ | ម$_{ធ}$១ | អ$_{ទ}$២ | ម$_{ធ}$២ | អ$_{ទ}$៣ |
|---|---|---|---|---|---|---|
| គណបក្ស ក | ៥២ | ០ | $\frac{៥២}{០+១}$ = ៥២,០០ | ១ | $\frac{៥២}{១+១}$ = ២៦,០០ | ០ |
| គណបក្ស ខ | ១៥៥ | ២ | $\frac{១៥៥}{២+១}$ = ៥១,៦៦ | ០ | $\frac{១៥៥}{២+១}$ = ៥១,៦៦ | ១ ? |
| គណបក្ស គ | ៦៣ | ១ | $\frac{៦៣}{១+១}$ = ៣១,៥០ | ០ | $\frac{៦៣}{១+១}$ = ៣១,៥០ | ០ |
| គណបក្ស ឃ | ៣១០ | ៥ | $\frac{៣១០}{៥+១}$ = ៥១,៦៦ | ០ | $\frac{៣១០}{៥+១}$ = ៥១,៦៦ | ១ ? |
| គណបក្ស ង | ១៩ | ០ | $\frac{១៩}{០+១}$ = ១៩,០០ | ០ | $\frac{១៩}{០+១}$ = ១៩,០០ | ០ |
| គណបក្ស ច | ៨ | ០ | $\frac{៨}{០+១}$ = ៨,០០ | ០ | $\frac{៨}{០+១}$ = ៨,០០ | ០ |
| គណបក្ស ឆ | ៦១ | ១ | $\frac{៦១}{១+១}$ = ៣០,៥០ | ០ | $\frac{៦១}{១+១}$ = ៣០,៥០ | ០ |

- ស$_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- អ$_{ទ}$១ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី ១ តាមរូបមន្តជំហានទី ២ ក្នុងនោះ ៖
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ទទួលបានពីរ (២) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ គ ទទួលបានមួយ (១) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ ឃ ទទួលបានប្រាំ (៥) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ ឆ ទទួលបានមួយ (១) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ ក ង និង ច ទទួលបានសូន្យ (០) អាសនៈ ។
- ម$_{ធ}$១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ តាមរូបមន្តជំហានទី ៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ក មានមធ្យមភាគធំជាងគេគឺ ៥២,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។

- អ₂២ គាំងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី ២ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ក ត្រូវទទួលបានមួយ (១) អាសនៈ ។
- ម₂២ គាំងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ២ តាមរូបមន្តជំហានទី ៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ និង ឃ មានមធ្យមភាគធំជាងគេស្មើគ្នាគឺ ៥១,៦៦ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ₂៣ គាំងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី ៣ ដែលក្នុងនោះចំនួនអាសនៈនៅសល់មានតែមួយ(១) តិចជាងចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។ អនុវត្តតាមចំណុច ២.៣៣.២ គធ/ខប ត្រូវរៀបចំការចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលត្រូវទទួលបានអាសនៈនៅសល់មួយ (១) ចុងក្រោយនេះ ។

**ការចាប់ឆ្នោតជាសាធារណៈ**

**ប្រការ** ២.៣៤ ក្នុងករណីដូចមានចែងក្នុងចំណុច ២.៣៣.២ គធ/ខប ត្រូវអនុវត្តនូវវិធីចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយណា ដែលត្រូវទទួលបានអាសនៈនៅសល់នេះ ។

២.៣៤.១ ក្នុងករណីបែបនេះ គធ/ខប ត្រូវចាត់ចែងរៀបចំការចាប់ឆ្នោតជាសាធារណៈ ។

២.៣៤.២ ពិធីចាប់ឆ្នោតជាសាធារណៈត្រូវធ្វើនៅទីស្នាក់ការ គធ/ខប ក្រោយពេលបញ្ចប់ការបែងចែកអាសនៈនៅតាមមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក្នុងរាជធានី ខេត្ត ពាក់ព័ន្ធ ។

២.៣៤.២.១ គធ/ខប ត្រូវកំណត់ទីកន្លែង ពេលវេលា និងកម្មវិធីនៃការចាប់ឆ្នោត ហើយត្រូវនិមន្ត ឬអញ្ជើញ ៖

- ព្រះសង្ឃ ឬព្រឹទ្ធាចារ្យដែលត្រូវចាប់ឆ្នោត ។
- តំណាងផ្លូវការនៃគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។
- តំណាងផ្លូវការ នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។
- អ្នកសង្កេតការណ៍ ដើម្បីចូលរួមក្នុងពិធីចាប់ឆ្នោតនេះ ។

២.៣៤.២.២ ពិធីចាប់ឆ្នោតត្រូវអនុវត្តតាមជំហានដូចខាងក្រោម ៖

- មន្ត្រីប្រតិបត្តិការត្រូវសរសេរ ឬបោះពុម្ពនៅលើក្រដាសដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នា នូវឈ្មោះនៃគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាស្មើគ្នា ។ ក្រដាសឆ្នោតមួយសន្លឹកត្រូវសរសេរ ឬបោះពុម្ពឈ្មោះតែមួយគណបក្សនយោបាយប៉ុណ្ណោះ ។ តួអក្សរជាឈ្មោះរបស់គណបក្សនយោបាយត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា។ ក្រដាសសន្លឹកឆ្នោត ដែលសរសេរ ឬបោះពុម្ពឈ្មោះរបស់គណបក្សនយោបាយ ហើយត្រូវលើកបង្ហាញជាសាធារណៈ រួចបត់ជាផ្នត់ដូចគ្នា ដាក់ក្នុងស្រោមសំបុត្រដែលមានប្រភេទ ពណ៌ និងទំហំ ដូចគ្នា រួចបិទភ្ជិត ។
- មន្ត្រីទទួលបន្ទុកប្រតិបត្តិការ ត្រូវបង្ហាញហិបឆ្នោតទទេជាសាធារណៈមុននឹងដាក់សំបុត្រសន្លឹកឆ្នោតចូលទៅក្នុងហិបនោះ និងបិទគម្រប ។
- មន្ត្រីទទួលបន្ទុកប្រតិបត្តិការត្រូវក្រឡុកហិបឆ្នោត រួចលើកហិបឆ្នោត នោះទៅដាក់លើតុខ្ពស់ ។
- ព្រះសង្ឃ ឬព្រឹទ្ធាចារ្យ ត្រូវចាប់យកសំបុត្រសន្លឹកឆ្នោតមួយពីក្នុងហិបនោះ រួចជូនទៅប្រធាន ឬ តំណាង គធ/ខប ដែលត្រូវបានប្រគល់សិទ្ធិ ។
- ប្រធាន ឬតំណាង គធ/ខប ដែលត្រូវបានចាត់តាំង ត្រូវបើកស្រោមសំបុត្រនោះជាសាធារណៈ រួចអានប្រកាសឈ្មោះគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈ និងលើកបង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ដែលចូលរួមបានឃើញ និងប្រាកដថាឈ្មោះគណបក្សដែលបានប្រកាសដូចគ្នានឹងឈ្មោះរបស់គណបក្សដែលបានសរសេរ ឬបោះពុម្ពនៅលើសន្លឹកឆ្នោតនោះមែន ។
- បន្ទាប់មក ត្រូវបើកគ្រប់ស្រោមសំបុត្រសន្លឹកឆ្នោតទាំងអស់ដែលនៅសល់ ដើម្បីបង្ហាញជាសាធារណៈ ។

២.៣៤.២.៣ មន្ត្រីទទួលបន្ទុកប្រតិបត្តិការត្រូវធ្វើកំណត់ហេតុនៃការចាប់ឆ្នោតនេះ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងតំណាងចូលរួម (គធ/ខប តំណាងគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគស្មើគ្នា អ្នកសង្កេតការណ៍.......) ដំណើរការចាប់ឆ្នោត និងលទ្ធផលនៃការចាប់ឆ្នោត ។

២.៣៤.២.៤ កំណត់ហេតុ ត្រូវចុះហត្ថលេខាដោយ ៖

- អ្នកធ្វើកំណត់ហេតុ
- ប្រធាន ឬតំណាង គធ/ខប ដែលត្រូវបានចាត់តាំង
- តំណាងគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។

២.៣៤.២.៥ កំណត់ហេតុត្រូវធ្វើជាច្រើនច្បាប់ តាមតម្រូវការដូចខាងក្រោម ៖

- ផ្ញើជូនទៅ គ.ជ.ប មួយ (១) ច្បាប់ ។
- ផ្ញើជូនទៅគ្រប់គណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។
- រក្សាទុកជាឯកសារ មួយ (១) ច្បាប់ ។

**ការប្រកាសឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ និងការកំណត់បេក្ខជនជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ**

**ប្រការ ២.៣៥** បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ បានទទួលហើយ គធ/ខប ត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ តាមលក្ខខណ្ឌដូចខាងក្រោម ៖

២.៣៥.១ ឈ្មោះអ្នកជាប់ឆ្នោតទាំងអស់ ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលជាប់ឆ្នោតជាសមាជិកតាមប្រភេទក្រុមប្រឹក្សានីមួយៗ ។ ចំនួនឈ្មោះអ្នកជាប់ឆ្នោតដែលត្រូវស្រង់ ត្រូវស្មើគ្នានឹងចំនួនអាសនៈដែលបានកំណត់ ដោយអនុក្រឹត្យ ។

២.៣៥.២ ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវស្រង់តាមលំដាប់អាទិភាពពីខ្ពស់មកទាបនៃបញ្ជីបេក្ខជន នៃគណបក្សនយោបាយជាប់ឆ្នោតនីមួយៗ ។

២.៣៥.៣ ក្នុងករណី នៅមណ្ឌលបោះឆ្នោតរាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌណាមួយមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតែមួយគត់ ដែលត្រូវបានអនុម័តយល់ព្រមឱ្យចុះបញ្ជី ឬមានបញ្ជីបេក្ខជនតែមួយគត់ជាប់ឆ្នោត

ឈ្មោះបេក្ខជនជាប់ឆ្នោតត្រូវស្រង់ចេញពីបញ្ជីបេក្ខជន នៃគណបក្សនយោបាយតែមួយនោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប រហូតដល់គ្រប់អាសនៈក្នុងក្រុមប្រឹក្សារាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌពាក់ព័ន្ធ ។

២.៣៥.៤ ឈ្មោះបេក្ខជនណា ដែលត្រូវបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាតាមប្រភេទនីមួយៗរួចហើយ ឈ្មោះបេក្ខជននោះត្រូវដកចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយនោះ ។

២.៣៥.៥ ប្រសិនបើ ក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៃគណបក្សនយោបាយ មានអ្នកជាប់ឆ្នោតណាម្នាក់ទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពសមាជិកក្រុមប្រឹក្សា បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៃគណបក្សនយោបាយនោះ ត្រូវបានស្រង់ជាអ្នកជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារបស់សាមីគណបក្សនយោបាយ ។

២.៣៥.៦ ក្នុងករណី បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយមានបេក្ខជនមិនគ្រប់គ្រាន់ដោយមូលហេតុ ដូចមានចែងក្នុងចំណុច ២.៣៥.៥ គ.ជ.ប ត្រូវស្នើជាលាយលក្ខអក្សរទៅសាមីគណបក្សនយោបាយនោះ ឱ្យបន្ថែមឈ្មោះបេក្ខជនក្នុងរយៈពេលដប់បួន (១៤) ថ្ងៃក្រោយពីទទួលបានសំណើ ។

២.៣៥.៦.១ បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៥ ដល់មាត្រា ១៨ មាត្រា ២០ មាត្រា ២២ ដល់មាត្រា ២៦ នៃ ច.ប.ក ។

២.៣៥.៦.២ ក្នុងករណី គណបក្សនយោបាយណាមួយមិនបានអនុវត្តតាមពេលវេលាកំណត់ខាងលើ ឬមិនបានកែលំអការខ្វះខាតដែលស្នើឡើងដោយ គ.ជ.ប ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈទំនេរបាននោះ គ.ជ.ប ត្រូវចាត់ទុកថាគណបក្សនយោបាយនោះបានបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។

២.៣៥.៦.៣ ក្នុងករណី គណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន ដូចកំណត់ក្នុងចំណុច ២.៣៥.៦.២ គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈ ដែលបោះបង់ចោលនោះ ក្នុងរយៈពេលយ៉ាងយូរដប់បួន (១៤) ថ្ងៃ បន្ទាប់ពីថ្ងៃបោះបង់ចោលជាផ្លូវការ ដោយអនុវត្តតាមវិធីគណនា ដូចមានចែងក្រោមប្រការ ២.៣២ នៃ ប.ន.ក នេះ ។

២.៣៥.៧ បន្ទាប់ពីបានស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ រួចហើយ គធ/ខប ត្រូវកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោត ដែលទទួលតំណែងជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

២.៣៥.៧.១ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ត្រូវជ្រើសរើសបេក្ខជន ដែលស្ថិតនៅលំដាប់លេខរៀងលើគេ នៃបញ្ជីបេក្ខជន ដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា ។

២.៣៥.៧.២ ក្នុងករណីដែល បញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវបានជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេ នៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

២.៣៥.៧.៣ ក្នុងករណីបញ្ជីបេក្ខជន នៃគណបក្សនយោបាយមានសំឡេងឆ្នោត និងចំនួនអាសនៈស្មើគ្នានោះ គធ/ខប ត្រូវរៀបចំការចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់បញ្ជីបេក្ខជនដែលត្រូវទទួលតំណែងប្រធានក្រុមប្រឹក្សា តាមលំនាំដូចមានចែងក្រោមប្រការ ២.៣៤ នៃ ប.ន.ក នេះ ។

**ប្រការ ២.៣៦** ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្រោមប្រការ ២.៣០ ២.៣១ ២.៣២ ២.៣៣ និង ២.៣៤ គ.ជ.ប អាចធ្វើការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗ ជាបន្តបន្ទាប់ ។

**ប្រការ ២.៣៧** មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គ.ជ.ប ត្រូវធ្វើសេចក្តីរាយការណ៍ជូនគ្រប់គណបក្សនយោបាយដែលបានចូលរួមបោះឆ្នោត នូវចំនួនសន្លឹកឆ្នោតសរុប ដែលបានបោះពុម្ពសម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់ពីការប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗនោះ ។

# ផ្នែកទី ៣

# ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និង បញ្ជីបេក្ខជនឈរឈ្មោះ

**ប្រការ២.៣៨** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញលក្ខខណ្ឌ និងលក្ខណសម្បត្តិដូចខាងក្រោម ៖

២.៣៨.១ មានសញ្ជាតិខ្មែរពីកំណើត ។ មាត្រា ៤ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ១៩៩៦ បានកំណត់ថា មានសញ្ជាតិខ្មែរពីកំណើតក្នុងករណីដូចខាងក្រោម ៖

**ក_ ត្រូវបានសញ្ជាតិខ្មែរទោះបីកើតនៅទីណាក៏ដោយ**

២.៣៨.១.១ កូនមានខាន់ស្លាដែលកើតមកពីឪពុកឬម្តាយមានសញ្ជាតិខ្មែរឬ

២.៣៨.១.២ កូនឥតខាន់ស្លា ដែលកើតមកពីឪពុកឬម្តាយមានសញ្ជាតិខ្មែរទទួលស្គាល់

២.៣៨.១.៣ កូនដែលឪពុក ម្តាយមិនទទួលស្គាល់កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ។

**ខ_ ត្រូវបានសញ្ជាតិខ្មែរដោយកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា**

២.៣៨.១.៤ កូនដែលកើតពីឪពុក និងម្តាយបរទេសដែលកើត និងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២.៣៨.១.៥ កូនដែលកើតពីឪពុកម្តាយមិនស្គាល់ និងកូនដែលទើបនឹងកើតដែលគេរើសបានក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថាកើតនៅព្រះរាជាណាចក្រកម្ពុជាដែរ ។

២.៣៨.២ មានអាយុយ៉ាងតិចម្ភៃប្រាំ (២៥) ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត ។

២.៣៨.៣ មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយ ច.ប.ក ។

**ប្រការ២.៣៩** ជនគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គឺ ៖

២.៣៩.១ សមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាល និងចៅក្រម ។

២.៣៩.២ អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

២.៣៩.៣ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.៣៩.៤ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោត និងមន្ត្រី បុគ្គលិកបម្រើការងាររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

២.៣៩.៥ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ក្នុងមុខតំណែង ។

២.៣៩.៦ មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ ។

២.៣៩.៧ ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ។

២.៣៩.៨ ព្រះសង្ឃ ឬបព្វជិតសាសនា ។

**ប្រការ ២.៤០** មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ នគរបាលជាតិ កងយោធពលខេមរភូមិន្ទ មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ (៧) ថ្ងៃមុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។

២.៤០.១ មន្ត្រីរាជការស៊ីវិល រួមមាន មន្ត្រីរាជការក្នុងក្របខណ្ឌនីតិបញ្ញត្តិ ក្របខណ្ឌនីតិប្រតិបត្តិ ក្របខណ្ឌតុលាការ និងក្របខណ្ឌពិសេសផ្សេងទៀត ។

២.៤០.២ ប្រសិនបើសាមីខ្លួនជាប់ឆ្នោតហើយមានបំណងបម្រើការងារជាសមាជិកក្រុមប្រឹក្សានោះ សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅក្រសួង ឬស្ថាប័នសាមី ដើម្បីទៅបម្រើការងារក្រៅក្របខណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា ។

២.៤០.៣ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខណ្ឌដើម សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬឋានន្តរសក្តិ និងរក្សាអតីតភាពការងារ សម្រាប់ទទួលសោធននិវត្តន៍ ។

២.៤០.៤ នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចសុំត្រឡប់មកបម្រើការងារនៅក្រសួង ឬស្ថាប័នដើមវិញ ប៉ុន្តែមុខងារ និងតំណែងអាស្រ័យដោយក្រសួង ឬស្ថាប័នជាអ្នកសម្រេច ។

**ប្រការ ២.៤១** លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ឬស្ថាប័នដើម អាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។ ក្នុងករណីមិនអាចធ្វើទាន់ ត្រូវធ្វើពាក្យសុំច្បាប់ឈប់ពិសេសជូន គជ/ខប ក្នុងរយៈពេលយ៉ាងតិចប្រាំពីរ (៧) ថ្ងៃ មុនថ្ងៃចាប់ផ្តើម

បើកការឃោសនាបោះឆ្នោត ។ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី ឈ្មោះសាមីជនដែលបានសុំច្បាប់ឈប់ពិសេស មុខតំណែង ក្រសួង ឬស្ថាប័នដែលសាមីជនកំពុងបម្រើការងារ កាលបរិច្ឆេទសុំច្បាប់ឈប់ពិសេស និងមានហត្ថលេខារបស់ថ្នាក់ដឹកនាំរបស់ខ្លួន ពោលគឺនៅថ្នាក់លើមួយថ្នាក់ដែលខ្លួននៅក្រោមឱវាទ ។

**ប្រការ២.៤២** គណបក្សនយោបាយ ដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ គណបក្សនយោបាយដែលមានបំណងចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវចាប់ផ្តើមដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅ គធ/ខប យ៉ាងតិចប៉ែតសិប (៨០) ថ្ងៃមុនកាលបរិច្ឆេទនៃការបោះឆ្នោត ។

២.៤២.១ គណបក្សនយោបាយ ត្រូវដាក់ពាក្យសុំចុះបញ្ជីឈរឈ្មោះបោះឆ្នោតដោយឡែកៗពីគ្នា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រភេទណាមួយ ដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង ។

២.៤២.២ គណបក្សនយោបាយ ដែលមានបំណងចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវរៀបចំបញ្ជីបេក្ខជនរបស់ខ្លួន តាមមណ្ឌលបោះឆ្នោត និងតាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.៤២.៣ ក្នុងការរៀបចំបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត គណបក្សនយោបាយត្រូវបំពេញបែបបទ សេចក្តីប្រកាសបេក្ខភាព ដែលផ្តល់ដោយ គ.ជ.ប តាមរយៈ គធ/ខប ។ បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលបោះឆ្នោត និងតាមប្រភេទក្រុមប្រឹក្សានីមួយៗ ត្រូវ ៖

២.៤២.៣.១ បញ្ជាក់ច្បាស់ពីប្រភេទក្រុមប្រឹក្សា ដែលបញ្ជីបេក្ខជនត្រូវឈរឈ្មោះបោះឆ្នោត ។

២.៤២.៣.២ រៀបចំឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ ។

២.៤២.៣.៣ បញ្ជីបេក្ខជននៃគណបក្សនយោបាយត្រូវមានបេក្ខជនពេញសិទ្ធិ និងបេក្ខជនបម្រុង ដែលមានចំនួនបេក្ខជនយ៉ាងតិចពីរ (២) ដងនៃចំនួនអាសនៈសម្រាប់ក្រុមប្រឹក្សាណាមួយ ដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង ។

២.៤២.៣.៤ បេក្ខជនម្នាក់ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយ និងមានសិទ្ធិឈរឈ្មោះជាបេក្ខជន សម្រាប់ក្រុមប្រឹក្សាតែមួយប៉ុណ្ណោះ ។

២.៤២.៣.៥ បេក្ខជន ដែលមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសពីមួយ ឬឈរឈ្មោះជាបេក្ខជនសម្រាប់ក្រុមប្រឹក្សាលើសពីមួយ ត្រូវបានប្រកាសថា បាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយ គ.ជ.ប ។

២.៤២.៤ បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវបានដាក់ពាក្យសុំចុះបញ្ជីនៅ គធ/ខប រួចហើយ មិនអនុញ្ញាតឱ្យបេក្ខជនលាឈប់ ឬប្តូរបេក្ខជន ឬដកបញ្ជីបេក្ខជនឈរឈ្មោះឡើយ ។ បេក្ខជនអាចលាឈប់ពីបញ្ជីបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយបាន បន្ទាប់ពី គធ/ខប ទទួលស្គាល់ជាផ្លូវការនូវការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។

២.៤២.៥ គណបក្សនយោបាយ ដែលទទួលបានអាសនៈនៅក្នុងក្រុមប្រឹក្សា ហើយបេក្ខជនពេញសិទ្ធិ និងបម្រុងផ្លូវការរបស់ខ្លួនមានចំនួនមិនគ្រប់គ្រាន់ សម្រាប់បំពេញអាសនៈរបស់ខ្លួនដែលនៅទំនេរ ដោយមូលហេតុទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពសមាជិកក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម ដោយអនុវត្តតាមនីតិវិធីស្តីពីការដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (សូមមើលឧបសម្ព័ន្ធទី ១ ទំព័រទី ៣០៨) ។

**ប្រការ ២.៤៣** ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាជាផ្លូវការ គណបក្សនយោបាយត្រូវដាក់ពាក្យសុំតាមបែបបទកំណត់ដោយ គ.ជ.ប ទៅ គធ/ខប ក្នុងរយៈពេលប្រាំ (៥) ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើមចុះបញ្ជី ។

២.៤៣.១ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតគឺ ជាទម្រង់បែបបទ គ.ជ.ប លេខ ១០០៨ ។ ពាក្យសុំចុះបញ្ជីនេះត្រូវបានផ្តល់ដោយឥតគិតថ្លៃ ជូនគណបក្សនយោបាយ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីនេះជាពីរ (២) ច្បាប់ ។

២.៤៣.២ ពាក្យសុំនេះត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ ។ ការផ្ទេរសិទ្ធិនេះ មិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តដោយគ្មានការអនុញ្ញាតពីប្រធានគណបក្សសាមីឡើយ ។

២.៤៣.៣ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវភ្ជាប់មកជាមួយនូវ ៖

២.៤៣.៣.១ សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃមួយ (១) ច្បាប់ ។

២.៤៣.៣.២ ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសំគាល់គណបក្សនយោបាយ ។

២.៤៣.៣.៣ អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ និងអាសយដ្ឋានទីស្នាក់ការរបស់គណបក្សនយោបាយនៅតាមរាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌ ។

២.៤៣.៣.៤ បញ្ជីរាយនាមបេក្ខជនឈរឈ្មោះបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។ បញ្ជីនេះត្រូវមានចំនួនបេក្ខជនពេញសិទ្ធិ និងបម្រុង ដែលមានចំនួនបេក្ខជនយ៉ាងតិចពីរ (២) ដង នៃចំនួនអាសនៈក្រុមប្រឹក្សាណាមួយដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង ។

២.៤៣.៣.៥ សេចក្តីបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់ អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ដែលសាមីបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត ។

២.៤៣.៣.៦ សេចក្តីប្រកាសរបស់គណបក្សនយោបាយថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលបោះឆ្នោត ដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងចូលរួមអនុវត្ត ច.ប.ក ប.ន.ក របស់ គ.ជ.ប ក្រមសីលធម៌ និងច្បាប់ស្តីពីគណបក្សនយោបាយ ។

២.៤៣.៣.៧ សេចក្តីប្រកាសរបស់បេក្ខជន យល់ព្រមឱ្យគណបក្សនយោបាយតែងតាំងខ្លួនជាបេក្ខជនដើម្បីឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត**

**ប្រការ២.៤៤** គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទ នៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៤៤.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈ នូវកាលបរិច្ឆេទ ទីកន្លែង និងរយៈពេល នៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

២.៤៤.២ ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានរយៈពេលប្រាំ (៥) ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ ១១:៣០ នាទី និងពេលរសៀលចាប់ពីម៉ោង ២:០០នាទី ដល់ ៥:៣០នាទី ។

២.៤៤.៣ គធ/ខប ត្រូវចេញបង្កាន់ដៃបញ្ជាក់ការទទួលពាក្យ ជូនគណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងរក្សាគល់បញ្ជីមួយច្បាប់ទុកជាឯកសារ ។

២.៤៤.៤ បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារ ដែលបានទទួលដោយត្រូវចុះកាលបរិច្ឆេទនៃការប្រគល់ ទទួល និងចុះហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ ទទួល ។

២.៤៤.៥ នៅពេលបញ្ចប់ការទទួលពាក្យ គធ/ខប ត្រូវធ្វើកំណត់ហេតុស្ដីពីលទ្ធផលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងរាជធានី ខេត្តរបស់ខ្លួនចំនួនបី (៣) ច្បាប់ ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រា គធ/ខប រួចបិទផ្សាយមួយ (១) ច្បាប់ នៅលេខាធិការដ្ឋាន គធ/ខប ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។ តំណាងគណបក្សនយោបាយ អាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនេះបាន ។

**ការពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត**

**ប្រការ២.៤៥** គធ/ខប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

២.៤៥.១ ក្នុងករណី គធ/ខប យល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គធ/ខប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូនសាមីគណបក្សនយោបាយ ។

២.៤៥.២ ក្នុងករណី គធ/ខប ពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយណាមួយ ពុំបានបំពេញលក្ខខ័ណ្ឌដូចមានចែងក្នុងប្រការ ២.៣៨ ដល់ ២.៤៤ ខាងលើ គធ/ខប ត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយនោះវិញ ដើម្បីបំពេញបន្ថែម ឬកែតម្រូវ ។ សាមីគណបក្សនយោបាយត្រូវបំពេញលក្ខខណ្ឌ ឬកែតម្រូវចំណុចដែលខ្វះខាត យ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងនេះ ។

២.៤៥.៣ ក្នុងករណី គណបក្សនយោបាយណាមួយពុំបានបំពេញលក្ខខណ្ឌ ឬកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលកំណត់ គធ/ខប ត្រូវសម្រេចបដិសេធពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនោះ ដោយត្រូវ ៖

២.៤៥.៣.១ បំពេញ ចុះហត្ថលេខា និងកាលបរិច្ឆេទលើបែបបទនៃសេចក្តីសម្រេចបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជន ចំនួនបី(៣) ច្បាប់ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធរួចផ្ញើជូន៖

- សាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាងមួយ (១) ច្បាប់
- គ.ជ.ប មួយ (១) ច្បាប់
- រក្សាទុកឯកសារមួយ (១) ច្បាប់ ។

២.៤៥.៣.២ ផ្តល់ព័ត៌មានទៅសាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាងថា គាត់អាចប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ ។

២.៤៥.៣.៣ ផ្តល់ទម្រង់បែបបទលេខ ១២០២ ចំនួនបី (៣) ច្បាប់ ជូនសាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាង ដែលត្រូវបានបដិសេធសម្រាប់ប្តឹងតវ៉ាទៅ គ.ជ.ប ។

**ប្រការ ២.៤៦** គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬបេក្ខភាព ឬបញ្ជីបេក្ខជនរបស់គណបក្សនយោបាយណាមួយ ដែលត្រូវបានបដិសេធដោយ គធ/ខប សាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ ។

២.៤៦.១ ក្នុងករណី បន្ទាប់ពីទទួលបានសេចក្តីសម្រេចបដិសេធការសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬបេក្ខភាព ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ

ឈរឈ្មោះបោះឆ្នោត និងទម្រង់បែបបទសម្រាប់ប្តឹងតវ៉ារួចហើយ ប៉ុន្តែសាមីគណបក្ស ឬសាមីខ្លួន ឬតំណាងពុំបានដាក់ពាក្យប្តឹងតវ៉ាទៅតាមពេលវេលាកំណត់ទេនោះ ត្រូវចាត់ទុកថា ករណីនេះពុំមានការប្តឹងតវ៉ា ។

២.៤៦.២ ប្រសិនបើ សាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាងបានដាក់ពាក្យប្តឹងតវ៉ាតាមពេលវេលាកំណត់ គ.ជ.ប ត្រូវពិនិត្យ បើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃបន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

**ប្រការ២.៤៧** ប្រសិនបើសវនាការ គ.ជ.ប សម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា គ.ជ.ប ត្រូវបំពេញទម្រង់បែបបទលេខ១២០៣ (ទម្រង់សម្រង់សេចក្តីសម្រេច) ចំនួនបី (៣) ច្បាប់ និងផ្តល់ជូនសាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាង មួយ (១) ច្បាប់ ជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.៤៧.១ បន្ទាប់ពីបានទទួលសេចក្តីសម្រេចយល់ព្រមពី គ.ជ.ប គធ/ខប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនោះ ឬ/និងទទួលយល់ព្រមបេក្ខភាព រួចហើយត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬ/និងទទួលយល់ព្រមបេក្ខភាព ឬ/និងបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះ ។

២.៤៧.២ គធ/ខប ត្រូវផ្តល់លិខិតបញ្ជាក់នេះជូនសាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាងមួយ (១) ច្បាប់ ជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

**ប្រការ២.៤៨** ក្នុងករណីសវនាការ គ.ជ.ប សម្រេចបដិសេធបណ្តឹងតវ៉ា គ.ជ.ប ត្រូវ ៖

២.៤៨.១ បំពេញទម្រង់បែបបទលេខ ១២០៣ (ទម្រង់សម្រង់សេចក្តីសម្រេច) ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាលើទម្រង់នេះ ចំនួនបី (៣) ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធរួចផ្ញើជូន ៖

- សាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាងមួយ (១) ច្បាប់
- គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់
- រក្សាទុកឯកសារមួយ (១) ច្បាប់ ។

២.៤៨.២ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

**ការចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោត**

**ប្រការ២.៤៩** បន្ទាប់ពីបានបញ្ចប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ឬ/និងក្រោយពេលដែល គ.ជ.ប បានសម្រេចចុងក្រោយលើបណ្តឹងតវ៉ានានាអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គធ/ខប ត្រូវរៀបចំធ្វើការចាប់ឆ្នោតកំណត់យកលេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប ។

២.៤៩.១ ផ្អែកលើបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផ្លូវការ គធ/ខប ត្រូវធ្វើការចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយ ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត ។

២.៤៩.២ ការចាប់ឆ្នោតនេះត្រូវធ្វើឡើងជាសាធារណៈ ។ គធ/ខប ត្រូវបិទផ្សាយជាសាធារណៈអំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាយ៉ាងហោចណាស់ម្ភៃបួន (២៤) ម៉ោងមុនការចាប់ផ្តើមពិធីចាប់ឆ្នោត ។

២.៤៩.៣ លិខិតអញ្ជើញត្រូវប្រគល់ជូនទៅគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតយ៉ាងហោចណាស់ម្ភៃបួន (២៤) ម៉ោងមុនពិធីចាប់ឆ្នោតចាប់ផ្តើម ។ ក្នុងការទទួលលិខិតអញ្ជើញនេះ ត្រូវមានចុះហត្ថលេខារបស់អ្នកទទួល ដើម្បីទុកជាឯកសារ ។

២.៤៩.៤ របៀបវារៈនៃពិធីចាប់ឆ្នោតមានដូចខាងក្រោម ៖

២.៤៩.៤.១ សុន្ទរកថាបើកពិធី ថ្លែងដោយប្រធាន គធ/ខប ។

២.៤៩.៤.២ ការបង្ហាញសន្លឹកឆ្នោត និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតសម្រាប់ចាប់ឆ្នោត ។

២.៤៩.៤.៣ ការចាប់ឆ្នោតត្រូវធ្វើឡើងដោយព្រះសង្ឃ ឬឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលមានជំហរអព្យាក្រឹត និងដែលអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ ។

២.៤៩.៤.៤ ការប្រកាសលទ្ធផលនៃការចាប់ឆ្នោត ។

២.៤៩.៤.៥ ការបិទពិធីចាប់ឆ្នោត ។

២.៤៩.៥ គធ/ខប ត្រូវរៀបចំសន្លឹកឆ្នោត មួយសន្លឹកសម្រាប់គណបក្សនយោបាយនីមួយៗ ។

២.៤៩.៥.១ ក្រដាសសន្លឹកឆ្នោតនេះត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា ។

២.៤៩.៥.២ ឈ្មោះគណបក្សនយោបាយ ត្រូវសរសេរ ឬបោះពុម្ពជាអក្សរដែលមានពណ៌ ប្រភេទ និងទំហំតួអក្សរដូចគ្នានៅលើសន្លឹកឆ្នោតនេះ ។

២.៤៩.៥.៣ សន្លឹកឆ្នោតមួយសន្លឹក ដែលមានសរសេរ ឬបោះពុម្ពឈ្មោះគណបក្សនយោបាយមួយ ត្រូវបត់ដាក់ចូលក្នុងស្រោមសំបុត្រដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នា ។

២.៤៩.៦ មុនចាប់ផ្តើមការចាប់ឆ្នោត គធ/ខប ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយនីមួយៗនៅចំពោះមុខអង្គពិធី មុននឹងបត់ដាក់ចូលក្នុងស្រោមសំបុត្រ រួចបិទភ្ជិត ។

២.៤៩.៦.១ សន្លឹកឆ្នោតនីមួយៗត្រូវបត់ជាពីរផ្នត់ ហើយស៊កបញ្ចូលក្នុងស្រោមសំបុត្រ រួចបិទភ្ជិត ។

២.៤៩.៦.២ ស្រោមសំបុត្រឆ្នោតទាំងអស់ ត្រូវដាក់ច្របល់បញ្ចូលគ្នាក្នុងហិបឆ្នោតតែមួយ ហើយត្រូវក្រឡុកហិបឆ្នោតនោះ ។

២.៤៩.៧ បន្ទាប់មកត្រូវនិមន្តព្រះសង្ឃ ឬអញ្ជើញឥស្សរជនដែលចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលត្រូវបានជ្រើសរើសហើយតាមលក្ខខណ្ឌដូចចំណុច ២.៤៩.៤.៣ ចាប់យកស្រោមសំបុត្រឆ្នោតម្តងមួយៗ ពីក្នុងហិបឆ្នោត ។

២.៤៩.៧.១ ស្រោមសំបុត្រឆ្នោតដែលចាប់បានត្រូវប្រគល់ទៅមន្ត្រីបោះឆ្នោតម្នាក់ក្នុងចំណោមពីរនាក់ ដែលមកពីផ្នែកប្រតិបត្តិការ ។

២.៤៩.៧.២ មន្ត្រីរូបនោះ ត្រូវបើកស្រោមសំបុត្របង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយ នៅចំពោះមុខអង្គពិធី ហើយជូនសន្លឹកឆ្នោតនោះទៅឱ្យមន្ត្រីទីពីរ ។

២.៤៩.៧.៣ មន្ត្រីទីពីរត្រូវអានឈ្មោះគណបក្សនយោបាយ ដែលសរសេរនៅលើសន្លឹកឆ្នោតឱ្យបានឮ និងសរសេរលេខរៀង « ទី១ » នៅលើសន្លឹកឆ្នោតនោះ ។

២.៤៩.៧.៤ លទ្ធផលនៃការចាប់ឆ្នោត ត្រូវសរសេរនៅលើក្តារខៀន ដើម្បីបង្ហាញបន្ថែម នៅចំពោះមុខអង្គពិធី ។

២.៤៩.៧.៥ ការចាប់ឆ្នោត និងចុះលេខរៀង ត្រូវធ្វើបន្តតាមលំដាប់ រហូតដល់សន្លឹកឆ្នោតចុងក្រោយបង្អស់ ។

២.៤៩.៨ គធ/ខប ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូន គ.ជ.ប អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុនៃពិធីចាប់ឆ្នោតជាសាធារណៈ និងសន្លឹកឆ្នោតរបស់គណបក្សដែលបានចុះលេខរៀងហើយ ដូចមានចែងក្នុងចំណុច ២.៤៩.៧.៣ ។ កំណត់ហេតុនៃពិធីចាប់ឆ្នោតជាសាធារណៈត្រូវរក្សាទុកជាឯកសារមួយ (១) ច្បាប់នៅ គធ/ខប និងបិទផ្សាយមួយ (១) ច្បាប់នៅទីស្នាក់ការ គធ/ខប ។

២.៤៩.៩ ផ្អែកតាមរបាយការណ៍ស្តីពី លទ្ធផលនៃការចាប់ឆ្នោតកំណត់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោតរបស់ គធ/ខប គ.ជ.ប ត្រូវធ្វើគំរូ និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់មណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ ។

២.៤៩.៩.១ ការបោះពុម្ពសន្លឹកឆ្នោត ត្រូវផ្អែកលើបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផ្លូវការ តាមមណ្ឌលបោះឆ្នោតនីមួយៗ និងលទ្ធផលនៃការចាប់ឆ្នោតកំណត់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោត នៅ គធ/ខប ។

២.៤៩.៩.២ សន្លឹកឆ្នោត សម្រាប់មណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាប្រើប្រាស់បានតែនៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះប៉ុណ្ណោះ ។

២.៤៩.៩.៣ ឈ្មោះ និងរូបសញ្ញាគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ត្រូវបោះពុម្ពតាមរបៀបតែមួយគត់ ហើយលេខសម្គាល់របស់គណបក្សនយោបាយត្រូវដាក់ជាលេខរៀង តាមលទ្ធផលនៃការចាប់ឆ្នោត ។

២.៤៩.៩.៤ សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី និងខេត្តត្រូវបោះពុម្ពលើក្រដាសពណ៌ស និងខ្ទប់ដោយក្រដាសពណ៌ស។

២.៤៩.៩.៥ សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក និងខណ្ឌ ត្រូវបោះពុម្ពលើក្រដាសពណ៌ និងខ្ទប់ដោយក្រដាសពណ៌ ។

**ប្រការ ២.៥០** គធ/ខប ត្រូវបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលបានចាប់ឆ្នោតកំណត់លេខរៀងនៅលើសន្លឹកឆ្នោតហើយ ក្នុងរយៈពេលយ៉ាងតិចសែសិបប្រាំ (៤៥) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជននៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

**ប្រការ ២.៥១** គណបក្សនយោបាយ និងបេក្ខជននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីជាផ្លូវការត្រូវគោរពតាម ច.ប.ក និង ប.ន.ក ព្រមទាំងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ ដែលកំណត់ដោយ គ.ជ.ប ។

# ផ្នែកទី ៤

# បញ្ជីបោះឆ្នោត

## អ្នកបោះឆ្នោត

**ប្រការ២.៥២** អនុលោមតាមមាត្រា ២៧ នៃ ច.ប.ក សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែង គឺជាអ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សា ។ គ.ជ.ប ត្រូវណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អំពីបែបបទ បទបញ្ជា និងនីតិវិធីទាក់ទងនឹងការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៥២.១ ការចុះឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែង ក្នុងក្រុបខ័ណ្ឌក្រុង ស្រុក ខណ្ឌទៅក្នុងបញ្ជីបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ជាការងារតម្រូវដោយច្បាប់ ។

២.៥២.២ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងម្នាក់ៗ មានសិទ្ធិចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតមួយ ដែលមានទីតាំងនៅទីប្រជុំជនក្រុង ស្រុក ខណ្ឌ ។

២.៥២.៣ ការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវអនុវត្តតាមរបៀបស្រង់ឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោត និងបញ្ជូនតាមលំដាប់ថ្នាក់នុក្រមមក គ.ជ.ប ឱ្យបានតាមកាលបរិច្ឆេទកំណត់ ។

២.៥២.៤ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមេឃុំ ចៅសង្កាត់ត្រូវរៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែង រួចចុះហត្ថលេខាបោះត្រា និងបញ្ជូនមក គ.ជ.ប ឱ្យបានតាមកាលបរិច្ឆេទកំណត់ ដោយមានការបញ្ជាក់ឯកភាពពីអភិបាលក្រុង ស្រុក ខ័ណ្ឌ និងអភិបាលរាជធានី ខេត្តពាក់ព័ន្ធផង ។

២.៥២.៥ ក្នុងករណី ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមេឃុំ ចៅសង្កាត់នៃឃុំ សង្កាត់ណាមួយមិនបានរៀបចំ និងបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែងមក គ.ជ.ប ដូចមានចែងក្នុងចំណុច ២.៥២.៤ ខាងលើ គ.ជ.ប ត្រូវធ្វើប្រតិភូកម្មអំណាចដល់អភិបាលក្រុង ស្រុក ខ័ណ្ឌពាក់ព័ន្ធឱ្យរៀបចំ

បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែងនៃឃុំ សង្កាត់នោះ រួចចុះហត្ថលេខា បោះត្រា និងបញ្ជូនមក គ.ជ.ប ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ដោយមានការបញ្ជាក់ឯកភាពពីអភិបាលរាជធានី និងខេត្តពាក់ព័ន្ធផង ។

**លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត**

**ប្រការ ២.៥៣** អ្នកដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណាមួយ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

២.៥៣.១ ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែងនៃក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

២.៥៣.២ មិនចាំបាច់បង្ហាញខ្លួន ឬអាចទៅបង្ហាញខ្លួនចំពោះមុខប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិ ឬចំពោះមុខអភិបាលក្រុង ស្រុក ខណ្ឌ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិនៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីទទួលព័ត៌មានអំពីការិយាល័យបោះឆ្នោត និងអំពីតម្រូវការឯកសារនៅពេលបោះឆ្នោត ។

**សង្ខេបដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ**

**ប្រការ ២.៥៤** ការចុះឈ្មោះបោះឆ្នោត ការរៀបចំ និងការផ្តល់សុពលភាពបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រួមមានដំណាក់កាលដូចខាងក្រោម ៖

២.៥៤.១ ការចុះឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៥៤.២ ការដាក់ពាក្យបណ្តឹង និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ដែលទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ។

២.៥៤.៣ ការរៀបចំ និងបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងតាមលំដាប់ឋានានុក្រមមក គ.ជ.ប ដើម្បី គ.ជ.ប បញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ និងរៀបចំជាបញ្ជីបោះឆ្នោតដំបូង ។

២.៥៤.៤ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៅលេខាធិការដ្ឋាននៃ គថ/ខប និងនៅទីកន្លែងណាមួយក្នុងទីប្រជុំជនក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

២.៥៤.៥ ការដាក់ពាក្យបណ្តឹង និងការដោះស្រាយរាល់បណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ដែលទាក់ទងនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

២.៥៤.៦ ការកែតម្រូវបញ្ជីបោះឆ្នោតដំបូង ការបោះពុម្ព និងការផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៥៤.៧ ការកែប្រែបញ្ជីបោះឆ្នោតផ្លូវការ ក្នុងករណីមានអ្នកបោះឆ្នោតទទួលមរណភាព ។

**រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោត តាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ**

**ប្រការ ២.៥៥** គ.ជ.ប ត្រូវរៀបចំបញ្ជីបោះឆ្នោត និងផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ យ៉ាងតិចសាមសិបប្រាំ (៣៥) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ដើម្បីធានាឱ្យការចុះឈ្មោះបោះឆ្នោត ការរៀបចំបញ្ជីបោះឆ្នោតដំបូង ការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទាក់ទងនឹងការចុះឈ្មោះ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងការផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការប្រព្រឹត្តទៅយ៉ាងរលូន និងទាន់ពេលវេលាដែលកំណត់ដោយច្បាប់ គ.ជ.ប ត្រូវកំណត់រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោត សម្រាប់ការិយាល័យចុះឈ្មោះនៅតាមឃុំ សង្កាត់នីមួយៗ ។

២.៥៥.១ ការចុះឈ្មោះបោះឆ្នោត រួមនឹងការរៀបចំ និងបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ក្នុងក្របខ័ណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ តាមលំដាប់ថ្នាក់ក្រុម មកដល់ គ.ជ.ប ត្រូវបានកំណត់រយៈពេលសរុបត្រឹមម្ភៃ (២០) ថ្ងៃ ដោយមិនគិតបញ្ចូលថ្ងៃអាទិត្យ និងថ្ងៃបុណ្យជាផ្លូវការ ។

២.៥៥.១.១ រយៈពេលសម្រាប់ការចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវបានកំណត់ស្មើនឹងដប់បី (១៣) ថ្ងៃ ។

២.៥៥.១.២ រយៈពេលសម្រាប់ការបញ្ជាក់ឯកភាព និងការបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ក្នុងក្របខ័ណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ តាមលំដាប់ថ្នាក់ក្រុមមក គ.ជ.ប ត្រូវបានកំណត់រយៈពេលប្រាំពីរ (៧) ថ្ងៃ ។

២.៥៥.១.៣ ក្នុងករណី ការិយាល័យណាមួយបានចុះឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងគ្រប់រូបរួចរាល់ មុនរយៈពេលកំណត់ ការិយាល័យនោះអាចបន្តអនុវត្តជំហានបញ្ជាក់ការឯកភាព តាមការកំណត់ដូចចែងក្នុងចំណុច ២.៥២.៤ និងបញ្ជូនបញ្ជីឈ្មោះបោះឆ្នោតនោះ តាមលំដាប់ថ្នាក់ក្រុមមក គ.ជ.ប បាន ។

២.៥៥.២ ការចុះឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើមធ្វើនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស ក្នុងថ្ងៃតែមួយ ដូចបានកំណត់ក្នុងប្រតិទិនការងាររបស់ គ.ជ.ប ។ ការិយាល័យចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ត្រូវបើកអនុវត្តការចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលម៉ោងធ្វើការ ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ។

២.៥៥.៣ គ.ជ.ប ត្រូវណែនាំ គធ/ខប និងក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេល និងកាលបរិច្ឆេទដូចចែងក្នុងចំណុច ២.៥៥.១ ខាងលើ ព្រមទាំងប្រតិទិនសម្រាប់ការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យនីមួយៗ ក្នុងរយៈពេលយ៉ាងតិចប្រាំពីរ (៧) ថ្ងៃ មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត ។

**ការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**

**ប្រការ ២.៥៦** ដោយហេតុថា អ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែង គ.ជ.ប ត្រូវលើកសំណើសុំទៅក្រសួងមហាផ្ទៃ ដើម្បីធ្វើប្រតិភូកម្មអំណាចដល់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការចុះឈ្មោះបោះឆ្នោត ។ គ.ជ.ប ត្រូវណែនាំជាក់ស្តែង និងផ្តល់គំរូទម្រង់បែបបទដល់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុវត្តការទទួលខុសត្រូវនេះ ។

២.៥៦.១ ដើម្បីធានារ៉ាប់រងការអនុវត្តសិទ្ធិអំណាចដែល គ.ជ.ប បានធ្វើប្រតិភូកម្មអំណាចឱ្យខ្លួន ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

២.៥៦.១.១ អនុវត្តត្រឹមត្រូវតាម ច.ប.ក និង ប.ន.ក នេះ ។ ប្រកាន់ជំហរអព្យាក្រឹត និងមិនលំអៀងក្នុងពេលបំពេញការងារ និងធានាឱ្យការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព ។

២.៥៦.១.២ ចាត់វិធានការសមស្រប ដើម្បីធានាថាដំណើរនៃការចុះឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង ។

២.៥៦.១.៣ ធានាឱ្យអ្នកសង្កេតការណ៍ និងតំណាងគណបក្សនយោបាយ ដែលមានការបញ្ជាក់ទទួលស្គាល់ដោយអាជ្ញាធររៀបចំការបោះឆ្នោត មានលទ្ធភាពសង្កេតមើលដំណើរប្រព្រឹត្តទៅនៃការចុះឈ្មោះបោះឆ្នោតក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។

២.៥៦.១.៤ ស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ក្នុងក្រុងខណ្ឌ ក្រុង ស្រុក ខណ្ឌនីមួយៗ និងត្រូវពិនិត្យផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ប្រសិនបើឃើញថា ពិតជាត្រឹមត្រូវហើយ ត្រូវចុះឈ្មោះរបស់គាត់ បញ្ចូលទៅក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ។

២.៥៦.១.៥ មិនបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ចំពោះអ្នកដែលមិនបានបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ដូចចែងក្រោមប្រការ ២.៥៣ ខាងលើ ។

២.៥៦.១.៦ ជំរាបជូនអ្នក ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ក្នុងករណី គាត់មកបង្ហាញខ្លួន ឱ្យចងចាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងឱ្យគាត់យកទៅជាមួយនូវ ឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។ ប្រសិនបើគាត់គ្មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ត្រូវជំរាបគាត់ឱ្យត្រៀមស្នើសុំជាមុននូវលិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អំពីអត្តសញ្ញាណ មានបិទរូបថតសាមីខ្លួន ចេញដោយមេឃុំ ចៅសង្កាត់ ។

២.៥៦.១.៧ ជូនដំណឹងចំពោះអ្នកដែលត្រូវបានចុះឈ្មោះក្នុងបញ្ជី ប៉ុន្តែមិនបានមកបង្ហាញខ្លួន តាមមធ្យោបាយដែលមាន នូវខ្លឹមសារនិងព័ត៌មាន ដូចចែងក្នុងចំណុច ២.៥៦.១.៦ ខាងលើ ។

២.៥៦.១.៨ ធានាថាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងគ្រប់រូប ក្នុងក្រុងខ័ណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៥៦.១.៩ សម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចេញលិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង មានបិទរូបថតសាមីខ្លួន តាមការស្នើសុំ ។ លិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ត្រូវចេញដោយប្រធាននៃស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។ ដោយឡែក លិខិតបញ្ជាក់អត្តសញ្ញាណ មានបិទរូបថតសាមីខ្លួន ត្រូវចេញដោយមេឃុំ ចៅសង្កាត់របស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ។

២.៥៦.១.១០ រាយការណ៍ជូន គ.ជ.ប តាមលំដាប់ឋានានុក្រម រាល់ហេតុការណ៍ដែលបានកើតមានក្នុងការចុះឈ្មោះបោះឆ្នោត ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហា ។

២.៥៦.១.១១ ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត នៅពេលដែលការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ និងរៀបចំបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង តាមលំដាប់ឋានានុក្រម មក គ.ជ.ប ដើម្បី គ.ជ.ប រៀបចំជាបញ្ជីបោះឆ្នោតដំបូង ។

២.៥៦.១.១២ ចូលរួមបំភ្លឺក្នុងសវនាការរបស់ គឃ/ខប ឬ គ.ជ.ប ដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង ប្រសិនបើមានតម្រូវការជាចាំបាច់ ។

**សម្ភារឯកសារសម្រាប់បំរើកិច្ចប្រតិបត្តិការចុះឈ្មោះបោះឆ្នោត**

**ប្រការ២.៥៧** គ.ជ.ប ត្រូវធានាផ្តត់ផ្គង់សម្ភារឯកសារគ្រប់គ្រាន់ សម្រាប់បំរើកិច្ចប្រតិបត្តិការនៃការចុះឈ្មោះបោះឆ្នោតឱ្យបានទាន់ពេលវេលា ។

២.៥៧.១ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារឯកសារឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ដល់ គឃ/ខប ដើម្បីបន្តណែនាំ សម្របសម្រួលក្នុងការងារចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់នីមួយៗ ចំណុះក្រុង ស្រុក ខណ្ឌ ។

២.៥៧.២ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារឯកសារសម្រាប់បំរើការចុះឈ្មោះបោះឆ្នោត ឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ដល់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលអនុវត្តការចុះឈ្មោះបោះឆ្នោត នៅតាមសាលាឃុំ សង្កាត់ ។

**ការចុះឈ្មោះបោះឆ្នោត និងការរៀបចំនិងបញ្ជូនបញ្ជីបោះឆ្នោត មក គ.ជ.ប**

**ប្រការ២.៥៨** ផ្អែកតាមបទបញ្ជានិងនីតិវិធី និងការណែនាំរបស់ គ.ជ.ប ផ្អែកតាមការកំណត់រយៈពេល និងកាលបរិច្ឆេទសម្រាប់ការចុះឈ្មោះបោះឆ្នោត និងបន្ទាប់ពីបានទទួលសម្ភារឯកសារបំរើ ការចុះឈ្មោះបោះឆ្នោត ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាង ដែលត្រូវបានប្រគល់សិទ្ធិ ត្រូវចាត់ចែងបើកការិយាល័យចុះឈ្មោះបោះឆ្នោត តាមប្រតិទិនកំណត់ និងត្រូវអនុវត្តឱ្យបានរួចរាល់ឆាប់រហ័ស តាមដែលអាចធ្វើបាន ដើម្បីរៀបចំ និងបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង តាមលំដាប់ឋានានុក្រម មក គ.ជ.ប ឱ្យបានទាន់ពេលវេលា ។ ក្នុងនោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិ ត្រូវ ៖

២.៥៨.១ ចាត់ចែងរៀបចំឱ្យមានបន្ទប់មួយ ព្រមទាំងតុ និងកៅអីមួយចំនួនសម្រាប់ប្រើប្រាស់ជាការិយាល័យចុះឈ្មោះបោះឆ្នោត ។ ការិយាល័យចុះឈ្មោះបោះឆ្នោត អាចតាំងនៅក្នុងបន្ទប់ធ្វើការរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិ ។

២.៥៨.២ បិទផ្សាយជាសាធារណៈនូវឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅមុខទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត

យ៉ាងតិចប្រាំពីរ (៧) ថ្ងៃ មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត ។ រក្សាទុកឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមួយ (១) ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងពេលចុះឈ្មោះបោះឆ្នោត ។

២.៥៨.៣ បិទផ្សាយប្រតិទិនសម្រាប់ការចុះឈ្មោះបោះឆ្នោត នៅខាងមុខការិយាល័យចុះឈ្មោះបោះឆ្នោត យ៉ាងតិចប្រាំពីរ (៧) ថ្ងៃ មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត ។ ប្រតិទិននេះត្រូវតែមានបញ្ជាក់រយៈពេល និងកាលបរិច្ឆេទសម្រាប់ដំណាក់កាលនីមួយៗ ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់នៃការចុះឈ្មោះបោះឆ្នោត ព្រមទាំងពេលម៉ោង និងថ្ងៃធ្វើការផង ។

២.៥៨.៤ ចាប់ផ្តើមបើកការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ នៅថ្ងៃតែមួយឯកភាពគ្នាក្នុងទូទាំងប្រទេស តាមកាលបរិច្ឆេទកំណត់ដោយ គ.ជ.ប ។

**ប្រការ២.៥៩** ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិ ត្រូវមានវត្តមាននៅការិយាល័យចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត ដើម្បីទទួលចុះឈ្មោះបោះឆ្នោតជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងទាំងអស់ ទៅក្នុងទម្រង់បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដែលផ្តល់ជូនដោយ គ.ជ.ប និងផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងទាំងនោះ ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាង ត្រូវ ៖

២.៥៩.១ ស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង និងផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ដូចចែងក្រោមប្រការ ២.៥៣ ខាងលើ ។ ក្នុងករណី មានលក្ខណៈត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះរបស់គាត់នៅក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ។

២.៥៩.១.១ ការចុះឈ្មោះ ក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង អាចបំពេញដោយដៃ តាមទម្រង់ដែលផ្តល់ជូនស្រាប់ដោយ គ.ជ.ប ឬអាចរៀបចំក្នុងកុំព្យូទ័រ (ប្រសិនបើមាន) ។

២.៥៩.១.២ នាមត្រកូល និងនាមខ្លួនរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង នៅលើឯកសារបញ្ជាក់អត្តសញ្ញាណដែលត្រូវប្រើប្រាស់នៅថ្ងៃបោះឆ្នោត ត្រូវតែដូចគ្នាជាមួយនឹងនាមត្រកូលនិងនាមខ្លួនរបស់សាមីខ្លួន ដែលចុះក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ។

២.៥៩.២ ជំរាបជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង និងដែលបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត អំពី ៖

២.៥៩.២.១ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅទីប្រជុំជន ក្រុង ស្រុក ខណ្ឌពាក់ព័ន្ធដែល គ.ជ.ប បានកំណត់ និងផ្តល់ជូនស្រាប់ ។

២.៥៩.២.២ តម្រូវការចាំបាច់ នូវឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយរបស់សាមីខ្លួន ដើម្បីប្រើសម្រាប់បោះឆ្នោត នៅថ្ងៃបោះឆ្នោត ។

២.៥៩.២.៣ ការត្រៀមស្នើសុំទុកជាមុន នូវលិខិតសំគាល់ខ្លួន ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ឬលិខិតបញ្ជាក់អត្តសញ្ញាណប្រសិនបើ គាត់គ្មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ។ លិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងមានបិទរូបថតសាមីខ្លួនត្រូវចេញដោយប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។ ចំពោះ លិខិតបញ្ជាក់អត្តសញ្ញាណមានបិទរូបថតសាមីខ្លួន ត្រូវចេញដោយមេឃុំ ចៅសង្កាត់នៃឃុំ សង្កាត់ដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះរស់នៅ ។

២.៥៩.៣ ប្រើប្រាស់មធ្យោបាយដែលមាន ដើម្បីជំរាបជូនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែង ប៉ុន្តែមិនបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត អំពីខ្លឹមសារ និងព័ត៌មានទាំងឡាយ ដូចចែងក្រោមចំណុច ២.៥៩.២ ខាងលើ ។

២.៥៩.៤ នៅពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោត ឬនៅពេលបានចុះឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងទាំងអស់រួចរាល់ហើយ ត្រូវថតចម្លងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ចំនួនប្រាំ (៥) ច្បាប់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ ។ បន្ទាប់មក ត្រូវចាត់ចែងបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ជូន គ.ជ.ប ដោយដាក់ស្នើសុំការបញ្ជាក់ឯកភាព តាមលំដាប់ឋានានុក្រម ពីអភិបាលក្រុង ឬអភិបាលស្រុក ឬអភិបាលខ័ណ្ឌ និងអភិបាលរាជធានី ឬអភិបាលខេត្ត ដែលក្នុងនោះត្រូវ ៖

២.៥៩.៤.១ រក្សាទុកមួយ (១) ច្បាប់ជាឯកសារនៅក្រុមប្រឹក្សាឃុំ សង្កាត់ ។
២.៥៩.៤.២ ផ្ញើបួន (៤) ច្បាប់ ដើម្បីស្នើសុំការបញ្ជាក់ឯកភាព តាមលំដាប់ថ្នាក់ តាមលំដាប់ឋានានុក្រម ពីអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលរាជធានី ខេត្ត ។

២.៥៩.៥ ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោត តាមគំរូទម្រង់ដែល គ.ជ.ប ផ្តល់ជូន ចំនួនបី (៣) ច្បាប់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ហើយចាត់ចែងប្រើប្រាស់ដូចខាងក្រោម ៖
២.៥៩.៥.១ រក្សាទុកមួយ (១) ច្បាប់ជាឯកសារនៅក្រុមប្រឹក្សាឃុំ សង្កាត់ ។
២.៥៩.៥.២ ផ្ញើមួយ (១) ច្បាប់ជូន គឃ/ខប និងមួយ (១) ច្បាប់ជូន គ.ជ.ប តាមរយៈអភិបាលក្រុង ឬស្រុក ឬខណ្ឌ និងអភិបាលរាជធានី ឬខេត្ត ។

២.៥៩.៦ បញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត ដូចចែងក្នុងចំណុច ២.៥៩.៤.២ និង ២.៥៩.៥.២ ខាងលើជូនអភិបាលក្រុង ឬស្រុក ឬខណ្ឌ និងអភិបាលរាជធានី ឬខេត្ត ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ។

**ប្រការ ២.៦០** អភិបាលក្រុង ឬស្រុក ឬខណ្ឌ និងអភិបាលរាជធានី ឬខេត្ត មានភារកិច្ចត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែងនៃឃុំ សង្កាត់ទាំងអស់ ចំណុះក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្តពាក់ព័ន្ធ ក្នុងករណីបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗមានលក្ខណៈត្រឹមត្រូវពិតប្រាកដ ។ គឃ/ខប ត្រូវសម្របសម្រួល និងសហការឱ្យបានជិតស្និទ្ធជាមួយសាលាក្រុង ឬស្រុក ឬខណ្ឌ ក្នុងការចុះទៅទទួលយកដោយផ្ទាល់នៅសាលាក្រុង ឬស្រុក ឬខណ្ឌ ឬក្នុងការចាត់ចែងបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ចំណុះក្រុង ឬស្រុក ឬខណ្ឌ ជូនអភិបាលរាជធានី ឬខេត្ត ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង នៃឃុំ សង្កាត់ទាំងអស់ចំណុះក្រុង ឬស្រុក ឬខណ្ឌនៃរាជធានី ឬខេត្តពាក់ព័ន្ធ សម្រាប់បញ្ជូនទៅ គ.ជ.ប ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបាន ។
២.៦០.១ នៅពេលទទួលបានបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង និងរបាយការណ៍បូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត ពីឃុំ សង្កាត់នានា ចំណុះ

ក្រុង ឬស្រុក ឬខណ្ឌ អភិបាលក្រុង ឬស្រុក ឬខណ្ឌត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗ និង ត្រូវចាត់ចែងជាបន្ទាន់ ដូចខាងក្រោម ៖

២.៦០.១.១ បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងពីឃុំ សង្កាត់នីមួយៗ ក្នុងករណីត្រឹមត្រូវពិតប្រាកដ ។

២.៦០.១.២ សុំឱ្យប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់សិទ្ធិស្រាយបំភ្លឺ ឬ/និងកែតម្រូវ ក្នុងករណីពិនិត្យឃើញថា មិនទាន់ធ្វើបានត្រឹមត្រូវ ។ បន្ទាប់ពីបានកែតម្រូវរួច ត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងនៃឃុំ សង្កាត់នោះ ។

២.៦០.១.៣ រៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយចំនួនបី (៣) ច្បាប់ និងរបាយការណ៍ទាំងពីរ (២) ច្បាប់ ដោយដាក់តាមឃុំ សង្កាត់នីមួយៗ ត្រៀមបញ្ជូនទៅរាជធានី ឬខេត្ត ។ ត្រូវធ្វើដីកាអមបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ចំណុះក្រុង ឬស្រុក ឬខណ្ឌ ជូនអភិបាលរាជធានី ឬខេត្តផង ។

២.៦០.១.៤ រក្សាទុកបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួនមួយ (១) ច្បាប់ ជាឯកសារនៅសាលាក្រុង ឬស្រុក ឬខណ្ឌ ។

២.៦០.២ គធ/ខប ត្រូវទាក់ទងព័ត៌មានជាប្រចាំ ជាមួយសាលាក្រុង ឬស្រុក ឬខណ្ឌ ដើម្បីឱ្យដឹងប្រាកដថា អភិបាលក្រុង ឬស្រុក ឬខណ្ឌបានត្រៀមរៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង និងរបាយការណ៍បូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ចំណុះក្រុង ឬស្រុក ឬខណ្ឌសម្រាប់ការបញ្ជូនទៅរាជធានី ឬខេត្ត រួចរាល់ហើយ ឬនៅ ។ គធ/ខប ត្រូវចាត់ចែងមន្ត្រីឱ្យចុះទៅទទួលយកបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ចំណុះក្រុង ឬស្រុក ឬខណ្ឌ ដោយផ្ទាល់ ដើម្បីដាក់ជូនអភិបាលរាជធានី ឬខេត្ត ឬស្នើសុំឱ្យសាលាក្រុង ឬស្រុក ឬខណ្ឌបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍ទាំងនោះ មករាជធានី ឬខេត្ត ប្រសិនបើមានមន្ត្រីក្រុង ឬស្រុក ឬខណ្ឌ ត្រូវឡើងមកទាក់ទងការងារស្របពេលគ្នានៅរាជធានី ឬខេត្តពាក់ព័ន្ធ ។

២.៦០.៣ នៅពេលទទួលបានបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង និង របាយការណ៍បូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីឃុំ សង្កាត់នានាចំណុះ ក្រុង ឬស្រុក ឬខណ្ឌ អភិបាលរាជធានី ឬខេត្តពាក់ព័ន្ធ ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗ ដែលអភិបាលក្រុង ឬស្រុក ឬខ័ណ្ឌបានបញ្ជាក់ឯកភាពរួចហើយ និងត្រូវចាត់ចែង ជាបន្ទាន់ ដូចខាងក្រោម ៖

២.៦០.៣.១ បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុង តំណែងនៃឃុំ សង្កាត់នីមួយៗ ក្នុងករណីត្រឹមត្រូវពិតប្រាកដ ។

២.៦០.៣.២ សុំឱ្យប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងដែលត្រូវបានប្រគល់ សិទ្ធិ និងអភិបាលក្រុង ស្រុក ខ័ណ្ឌបកស្រាយបំភ្លឺ ឬ/និង កែតម្រូវ ក្នុងករណីពិនិត្យឃើញថា ធ្វើមិនទាន់បានត្រឹមត្រូវ ។ បន្ទាប់ពីបាន កែតម្រូវរួច ត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ក្នុងមុខតំណែងនៃឃុំ សង្កាត់នោះ ។

២.៦០.៣.៣ រៀបចំតាមក្រុង ឬស្រុក ឬខណ្ឌ នូវបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ក្នុងមុខតំណែង ដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួន ពីរ (២) ច្បាប់ និងរបាយការណ៍ទាំងពីរ (២) ច្បាប់ ដោយដាក់ តាមឃុំ សង្កាត់នីមួយៗ ត្រៀមបញ្ជូនទៅ គ.ជ.ប តាមរយៈ គធ/ខប ។

២.៦០.៣.៤ រក្សាទុកបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែង ចំណុះក្រុង ឬស្រុក ឬខណ្ឌ ក្នុងក្របខណ្ឌរាជធានី ឬខេត្តរបស់ខ្លួន ដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួនមួយ (១) ច្បាប់ ជា ឯកសារនៅរាជធានី ឬខេត្ត ។

២.៦០.៤ ប្រធាន គធ/ខប ត្រូវទាក់ទងព័ត៌មានជាប្រចាំ ជាមួយរាជធានី ឬខេត្ត ដើម្បី ទៅទទួលយកបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដែលមាន ការបញ្ជាក់ឯកភាពពីអភិបាលរាជធានី ឬខេត្ត និងរបាយការណ៍បូកសរុបលទ្ធផល នៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់នានា ចំណុះរាជធានី ខេត្តនោះ ។ ប្រធាន គធ/ខប ត្រូវត្រៀមបែងចែក វេចខ្ចប់ និងប្រើប្រាស់បញ្ជីឈ្មោះ និងរបាយការណ៍ ទាំងនេះ ដូចខាងក្រោម ៖

២.៦០.៤.១ បញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង និងរបាយការណ៍បូកសរុបលទ្ធផល នៃការចុះឈ្មោះបោះឆ្នោតតាម ឃុំ សង្កាត់ ចំណុះក្រុង ឬស្រុក ឬខណ្ឌ មួយ (១) ច្បាប់ៗ ជូន គ.ជ.ប ។

២.៦០.៤.២ រក្សាទុកបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង និងរបាយការណ៍បូកសរុបលទ្ធផល នៃការចុះឈ្មោះបោះឆ្នោត តាមឃុំសង្កាត់ ចំណុះក្រុង ឬស្រុក ឬខណ្ឌ មួយ (១) ច្បាប់ៗ ជាឯកសារនៅ គធ/ខប ។

២.៦០.៥ ប្រធាន គធ/ខប ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត នៅគ្រប់ឃុំ សង្កាត់ ចំណុះក្រុង ឬស្រុក ឬខណ្ឌនីមួយៗ ក្នុងក្រុងខណ្ឌរាជធានី ឬខេត្ត ចំនួនពីរ (២) ច្បាប់ ក្នុងនោះត្រូវរក្សាទុកមួយ (១) ច្បាប់ជាឯកសារ និង បញ្ជូនមួយ (១) ច្បាប់ជូន គ.ជ.ប ។

២.៦០.៦ ប្រធាន គធ/ខប ត្រូវបញ្ជូនបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង នៃឃុំ សង្កាត់នីមួយៗ និងរបាយការណ៍បូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត ដូចចែងក្នុងចំណុច ២.៦០.៤.១ ខាងលើ និងរបាយការណ៍បូកសរុបលទ្ធផល នៃការចុះឈ្មោះបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ ចំណុះក្រុង ឬស្រុក ឬខណ្ឌ ក្នុង ក្រុងខណ្ឌរាជធានី ឬខេត្ត របស់ខ្លួន មួយ (១) ច្បាប់ ជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ឱ្យបានតាមការកំណត់ ដូចចែងក្នុងចំណុច ២.៥៥.១ ខាងលើ ឬឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ។

២.៦០.៧ ប្រធាន គធ/ខប ត្រូវត្រៀមជាស្រេច នូវលិខិតបញ្ជាក់ការប្រគល់ទទួលសម្ភារឯកសារ បោះឆ្នោតចំនួនពីរ (២) ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងការប្រគល់ទទួលបញ្ជីឈ្មោះ និងរបាយការណ៍ ដូចចែងក្នុងចំណុច ២.៦០.៦ ខាងលើ ដើម្បីបញ្ជាក់ថា គ.ជ.ប បានទទួលរួចហើយ ។

**ការប្រគល់ ទទួលបញ្ជីបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតដំបូងដោយកុំព្យូទ័រនៅ គ.ជ.ប**

**ប្រការ** ២.៦១ នៅពេលទទួលបញ្ជីបោះឆ្នោតពី គធ/ខប ដូចចែងក្នុងចំណុច ២.៦០.៦ ខាងលើ មន្ត្រីទទួលឯកសារនៃនាយកដ្ឋានប្រតិបត្តិការ ត្រូវចាត់ចែងពិនិត្យសំណុំឯកសារ ដែលបាន ប្រគល់ រួចចុះហត្ថលេខាបញ្ជាក់ការទទួល ប្រសិនបើ ពិនិត្យឃើញថាគ្រប់គ្រាន់ហើយ ។ ប្រធាននាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប ត្រូវចាត់ចែងមន្ត្រីឱ្យផ្ទៀងផ្ទាត់ របាយការណ៍បូក សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ចំណុះក្រុង ឬស្រុក ឬខណ្ឌនីមួយៗ ក្នុងក្រុងខណ្ឌរាជធានី ឬខេត្ត ជាមួយនឹងបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ។ ក្នុងករណី ត្រឹមត្រូវហើយ ត្រូវចាត់ចែងឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត និង បញ្ចូលទិន្នន័យអ្នកបោះឆ្នោតទៅក្នុងកុំព្យូទ័រ ដើម្បីរៀបចំជាបញ្ជីបោះឆ្នោតដំបូង ។ ក្នុងការ រៀបចំបញ្ជីបោះឆ្នោតដំបូង ប្រធាននាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប ត្រូវ ៖

២.៦១.១ ធានាថា នៅរាល់ពេលប្រគល់ទទួលបញ្ជីឈ្មោះបោះឆ្នោត និងរបាយការណ៍បូកសរុបលទ្ធផល នៃការចុះឈ្មោះបោះឆ្នោត មន្ត្រីទទួលឯកសារបានចុះហត្ថលេខាលើដីកាអម ឬលិខិតប្រគល់ទទួលសម្ភារឯកសារបោះឆ្នោតទាំងពីរ (២) ច្បាប់រួចប្រគល់ឱ្យមន្ត្រីនៃ គឃ/ខប ដែលទទួលបន្ទុកបញ្ជូនសំណុំឯកសារវិញចំនួនមួយ (១) ច្បាប់ ដើម្បីបញ្ជាក់ពីការបានទទួលគ្រប់ចំនួន និងត្រូវរក្សាទុកមួយ (១) ច្បាប់ជាឯកសារ ។ ក្នុងករណីសំណុំឯកសារ ដែលបានប្រគល់មានលក្ខណៈមិនទាន់គ្រប់គ្រាន់ មន្ត្រីទទួលឯកសារអាចស្នើសុំ ឱ្យមន្ត្រីទទួលបន្ទុកការបញ្ជូន យកមកបន្ថែមនូវឯកសារដែលខ្វះ ។

២.៦១.២ ធានាថា សំណុំឯកសារនៃការចុះឈ្មោះបោះឆ្នោតដែលបានទទួល ត្រូវបានបំបែករួចផ្ដុំបញ្ចូលគ្នាទៅតាមក្រុង ស្រុក ខណ្ឌ ដោយឡែកពីគ្នា និងរក្សាទុកនៅកន្លែងមានសុវត្ថិភាព ។

២.៦១.៣ ធានាថា តួលេខ និងទិន្នន័យនៃបញ្ជីបោះឆ្នោតនីមួយៗ ត្រូវបានត្រួតពិនិត្យផ្ទៀងផ្ទាត់បន្ថែមឱ្យបានម៉ត់ចត់ និងត្រឹមត្រូវ ដើម្បីត្រៀមសម្រាប់ការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ ។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់បន្ថែមនេះ ត្រូវផ្អែកជាមូលដ្ឋានលើបញ្ជីបេក្ខជនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ផ្លូវការដែលមានរក្សាទុកជាឯកសារនៅ គ.ជ.ប ឬនៅក្រសួងមហាផ្ទៃ ។ ក្នុងករណី មានភាពមិនប្រក្រតី ឬភាពមិនត្រឹមត្រូវពាក់ព័ន្ធនឹងចំនួន និងទិន្នន័យក្នុងបញ្ជីឈ្មោះ ត្រូវរាយការណ៍ជាបន្ទាន់ តាមឋានានុក្រម ទៅ គ.ជ.ប ដើម្បីសុំយោបល់ណែនាំ ។

២.៦១.៤ ចាត់ចែងមន្ត្រីឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត និងបញ្ចូលទិន្នន័យអ្នកបោះឆ្នោតទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមបញ្ជីឈ្មោះ និងរបាយការណ៍ដែលបានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវរួច ។ ក្នុងនោះ ត្រូវធានាថា ៖

២.៦១.៤.១ មន្ត្រីបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រមានការទទួលខុសត្រូវខ្ពស់ ក្នុងការវាយបញ្ចូលឈ្មោះអ្នកបោះឆ្នោត និងទិន្នន័យពាក់ព័ន្ធបានយ៉ាងត្រឹមត្រូវ និងឆាប់រហ័ស ។

២.៦១.៤.២ ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតនីមួយៗក្នុងកុំព្យូទ័រ ត្រូវតែស្មើគ្នានឹងចំនួនដែលមានក្នុងបញ្ជីឈ្មោះដែលបានកំណត់ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ។

២.៦១.៨.៣ បញ្ជីបោះឆ្នោតដំបូងតាមការិយាល័យបោះឆ្នោតនីមួយៗ ក្នុងកុំព្យូទ័រត្រូវតែបានរៀបចំក្នុងទម្រង់ឯកភាពគ្នាតែមួយ ដែលរួមមាន ៖ ឈ្មោះ និងលេខកូដរាជធានី ឬខេត្ត លេខកូដក្រុង ឬស្រុក ឬខណ្ឌ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត កូនប្រអប់សម្រាប់គូសសំគាល់លេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោត នាមត្រកូល និងនាមខ្លួនដែលរៀបចំតាមអក្ខរក្រមខ្មែរ ភេទ ថ្ងៃខែឆ្នាំកំណើត ឋានៈក្នុងមុខតំណែងក្រុមប្រឹក្សាឃុំ សង្កាត់ អាសយដ្ឋាននៃអ្នកបោះឆ្នោត និងខ្ទង់ទំនេរ សម្រាប់ចារសម្គាល់ឯកសារបញ្ជាក់អត្តសញ្ញាណដែលបានប្រើនៅពេលបោះឆ្នោត ។

២.៦១.៨.៤ នៅគ្រប់ទំព័រ នៃបញ្ជីបោះឆ្នោតដំបូង តាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតដំបូងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ហើយនៅទំព័រចុងក្រោយនៃបញ្ជីបោះឆ្នោតដំបូងនេះ ត្រូវរៀបចំឱ្យមានប្រឡោះ សម្រាប់ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ។ នៅគ្រប់ទំព័រ ផ្សេងទៀតនៃបញ្ជីបោះឆ្នោតដំបូង របស់ការិយាល័យបោះឆ្នោត នីមួយៗ ក៏ត្រូវមានបោះត្រា គ.ជ.ប ផងដែរ ។

២.៦១.៨.៥ ឈ្មោះអ្នកបោះឆ្នោត និងរាល់ទិន្នន័យពាក់ព័ន្ធ នៅលើបញ្ជីបោះឆ្នោតដំបូង ត្រូវតែបានត្រួតពិនិត្យ និងកែតម្រូវយ៉ាងម៉ត់ចត់ ត្រឹមត្រូវ មុននឹងបោះពុម្ព និងដាក់ជូន គ.ជ.ប ផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតដំបូងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**ការបញ្ជូន និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង**

**ប្រការ២.៦២** នាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប ត្រូវបោះពុម្ពបញ្ជីបោះឆ្នោតដែលបានរៀបចំរួចស្រេចចំនួនពីរ (២) ច្បាប់ និងដាក់ជូន គ.ជ.ប ផ្តល់សុពលភាពក្នុងជំហានដំបូង ជាបញ្ជីបោះឆ្នោតដំបូងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ បញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានថតចម្លងបន្ថែមក្នុងចំនួនគ្រប់គ្រាន់ សម្រាប់វេចខ្ចប់ និងបញ្ជូនទៅ គធ/ខប ប្រើប្រាស់ក្នុងការបិទផ្សាយ ដើម្បីបំរើគោលដៅនៃការពិនិត្យកែតម្រូវ តាមរយៈការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងនោះ ។

២.៦២.១ នាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប ត្រូវរក្សាទុកច្បាប់ដើមនៃបញ្ជីបោះឆ្នោតដំបូងដែល គ.ជ.ប បានផ្តល់សុពលភាពក្នុងជំហានដំបូង មួយ (១) ច្បាប់ ជាឯកសារ

នៅ គ.ជ.ប និងត្រូវវេចខ្ចប់តាមការិយាល័យបោះឆ្នោតនីមួយៗ ដោយឡែកពីគ្នា នូវបញ្ជីបោះឆ្នោតដំបូងច្បាប់ដើមមួយ (១) ច្បាប់ និងច្បាប់ចម្លងបី (៣) ច្បាប់ រួចបញ្ជូនទៅ គធ/ខប ឱ្យបានទាន់ពេលវេលា មុនការកំណត់ឱ្យបិទផ្សាយ ។

២.៦២.២ ពេលទទួលបានកញ្ចប់បញ្ជីបោះឆ្នោតដំបូង គធ/ខប ត្រូវដកបញ្ជីបោះឆ្នោតដំបូងច្បាប់ដើមមួយ (១) ច្បាប់ ដើម្បីរក្សាទុកជាឯកសារ និងត្រូវចាត់ចែងបិទផ្សាយបញ្ជីបោះឆ្នោតដំបូងច្បាប់ចម្លង យ៉ាងតិចហាសិបបី (៥៣) ថ្ងៃ មុនថ្ងៃបោះឆ្នោត ដោយត្រូវបិទផ្សាយ ដូចខាងក្រោម ៖

២.៦២.២.១ នៅលេខាធិការដ្ឋាននៃ គធ/ខប មួយ (១) ច្បាប់ ។

២.៦២.២.២ នៅតាមការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌមួយ (១) ច្បាប់ ។

២.៦២.២.៣ នៅទីប្រជុំជនរាជធានី ខេត្ត មួយ (១) ច្បាប់ ។

២.៦២.៣ នៅពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនេះ គធ/ខប ត្រូវធ្វើកំណត់ហេតុស្ដីពីការបិទផ្សាយនេះ ដោយមានបញ្ជាក់អំពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែង នៃការបិទផ្សាយ ហើយត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាផង ។ គធ/ខប ត្រូវបិទផ្សាយកំណត់ហេតុនេះមួយ (១) ច្បាប់ អមជាមួយនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង នៅតាមទីតាំងដូចដែលបានបញ្ជាក់ក្រោមចំណុច ២.៦២.២ ខាងលើ រួចផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.៦២.៤ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង គឺដើម្បីបំរើគោលដៅនៃការពិនិត្យកែតម្រូវតាមរយៈការប្ដឹងតវ៉ា ឬ/និង ការប្ដឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងនេះ ។ បញ្ជីបោះឆ្នោតដំបូងត្រូវបានបិទផ្សាយជាសាធារណៈក្នុងរយៈពេលប្រាំ (៥) ថ្ងៃ ដែលក្នុងរយៈពេលកំណត់នេះ ជនណាក៏ដោយ ក៏មានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ទាក់ទងទៅនឹងបញ្ជីបោះឆ្នោតដំបូងនេះបានដែរ ។ ការដាក់ពាក្យបណ្ដឹងត្រូវធ្វើនៅលេខាធិការដ្ឋាននៃ គធ/ខប ។

២.៦២.៥ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងគណបក្សនយោបាយនានា ដែលបានចុះបញ្ជីស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ មានសិទ្ធិស្នើសុំពី គ.ជ.ប នូវបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតមួយ ឬច្រើនចំនួនមួយ (១) ច្បាប់ ដោយបង់ថ្លៃត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។ ការផ្គត់ផ្គង់ចំពោះការស្នើសុំនេះត្រូវផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ រាល់ការស្នើសុំ តម្រូវឱ្យបង់ប្រាក់ជាមុនស្មើនឹងមួយរយ (១០០) ភាគរយនៃតម្លៃផលិតផលស្នើសុំ ។

២.៦២.៦ គឃ/ខប អាចទទួលថតចម្លងបញ្ជីបោះឆ្នោតដំបូងដោយផ្ទាល់ តាមលទ្ធភាពជាក់ស្តែងរបស់ខ្លួន ដើម្បីផ្គត់ផ្គង់តាមសំណើសុំ ដូចចែងក្នុងចំណុច ២.៦២.៥ ហើយមិនត្រូវអនុញ្ញាតឱ្យអ្នកស្នើសុំខ្ចីបញ្ជីបោះឆ្នោតដំបូងច្បាប់ដើម យកទៅថតចម្លង ដោយខ្លួនឯងឡើយ ។

**ការដាក់/ទទួល និងដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូង**

**ប្រការ** ២.៦៣ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរ ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងនេះ ទៅ គឃ/ខប ក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ ។

២.៦៣.១ ពាក្យបណ្តឹងតវ៉ាអាចធ្វើឡើងអំពីការបាត់ឈ្មោះរបស់អ្នកបោះឆ្នោតពីបញ្ជីបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់ទៅតាមករណីដូចខាងក្រោម ៖

២.៦៣.១.១ សាមីអ្នកប្តឹងតវ៉ាជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងពិតប្រាកដ ប៉ុន្តែបែរជាមិនមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ឬបែរជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌផ្សេងទៅវិញ ។

២.៦៣.១.២ សាមីអ្នកប្តឹងតវ៉ាជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យពាក់ព័ន្ធដែលគេបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដំបូង មានភាពមិនច្បាស់លាស់ ឬមិនដូចគ្នានឹងទិន្នន័យក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់សាមីខ្លួន ហើយដែលគាត់ទាមទារសុំឱ្យកែតម្រូវឡើងវិញ ។

២.៦៣.២ ពាក្យបណ្តឹងជំទាស់អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ក្នុងករណីដែល ៖

២.៦៣.២.១ ជំទាស់ទៅនឹងជនណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណាមួយ ប៉ុន្តែជននោះគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោត ដោយមិនបំពេញបានតាមលក្ខខណ្ឌដូចមានចែងក្រោមប្រការ ២.៥៣ ខាងលើ ។

២.៦៣.២.២ ជំទាស់ទៅនឹងជនណាម្នាក់ ដែលទោះបីមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្តី ឬគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោតក្តី ប៉ុន្តែជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌលើសពីមួយ ។

២.៦៣.៣ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកតំណាង
- កម្មវត្ថុនៃបណ្តឹង
- ពេលវេលា និងទីកន្លែងនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង
- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬប្តឹងជំទាស់
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន
- ភស្តុតាងផ្សេងៗទៀត បើមាន ។

## គ. ការដាក់/ទទួល និងដោះស្រាយបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូងនៅ គឃ/ខប

### គ.១. ការដាក់/ទទួលពាក្យបណ្តឹងនៅ គឃ/ខប

២.៦៣.៤ អ្នកប្តឹង ឬអ្នកតំណាងត្រូវបំពេញទម្រង់បែបបទលេខ ១២០២ ចំនួនបី (៣) ច្បាប់ (ចំពោះបណ្តឹងតវ៉ា) និងបួន (៤) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ។

២.៦៣.៥ នៅពេលបានទទួលពាក្យបណ្តឹង គឃ/ខប ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកតំណាង ទី២ កម្មវត្ថុនៃបណ្តឹង និងការគោរពអំឡុងពេលកំណត់ប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

២.៦៣.៦ បន្ទាប់មក សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬអ្នកតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬអ្នកតំណាងនោះផ្តិតមេដៃលើកំណត់ហេតុ ។ ក្នុងករណីអ្នកប្តឹង ឬអ្នកតំណាងមិនព្រមផ្តិតមេដៃ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនេះ ។

២.៦៣.៧ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុហើយ ឃើញថា ៖

២.៦៣.៧.១ ពាក្យបណ្តឹងមិនគោរពអំឡុងពេលកំណត់ប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយ ប្រធាន គឃ/ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គឃ/ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ និងផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ។

២.៦៣.៧.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ ដូចចែងក្នុងចំណុច ២.៦៣.៣ ខាងលើ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវណែនាំអ្នកប្តឹង ឬអ្នកតំណាង ឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសអំឡុងពេលកំណត់នៃ ការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង មិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ/ខប ឬសមាជិក ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ និងផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ។

២.៦៣.៧.៣ ពាក្យបណ្តឹងគោរពអំឡុងពេលកំណត់ប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងមានព័ត៌មានគ្រប់គ្រាន់ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិក ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គធ/ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬអ្នកតំណាងមួយ (១) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់មួយ (១) ច្បាប់ (ចំពោះបណ្តឹងជំទាស់) រក្សាទុកក្នុងពេលសវនាការមួយ (១) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈមួយ (១) ច្បាប់ ។

**ក.២. ការដោះស្រាយពាក្យបណ្តឹងនៅ គធ/ខប**

២.៦៣.៨ ក្នុងករណី ពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងពាក្យបណ្តឹងគោរពអំឡុងពេលកំណត់ គធ/ខប ត្រូវបើកសវនាការ ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលពាក្យបណ្តឹង ។

២.៦៣.៩ គធ/ខប ត្រូវប្រកាន់យកលក្ខខណ្ឌសម្រាប់ការចុះឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងតំណែង ដូចមានចែងក្រោមប្រការ ២.៥៣ ខាងលើ ធ្វើជាមូលដ្ឋានសម្រេចលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ។

២.៦៣.១០ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬអ្នកតំណាងដែលត្រូវបានប្រគល់សិទ្ធិ អាចមានវត្តមាន នៅក្នុងការបើកសវនាការរបស់ គធ/ខប ដើម្បីផ្តល់ព័ត៌មាន ដោយចំពាក់ព័ន្ធនឹងបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ជូន គធ/ខប ។

២.៦៣.១១ ក្នុងករណី គធ/ខប សម្រេចបដិសេធ ឬយល់ព្រមលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប ត្រូវ ៖

២.៦៣.១១.១ ចាត់លេខាធិការសវនាការឱ្យស្រង់សេចក្តីសម្រេច ចូលក្នុងសម្រង់សេចក្តីសម្រេច (ទម្រង់បែបបទលេខ ១២០៣) ចំនួនបី (៣) ច្បាប់ (ចំពោះបណ្តឹងតវ៉ា) ឬចំនួនបួន (៤) ច្បាប់ (ចំពោះបណ្តឹងជំទាស់) និងឱ្យចុះហត្ថលេខាផង ។

២.៦៣.១១.២ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ/ខប លើសម្រង់សេចក្តីសម្រេច (ទម្រង់បែបបទលេខ ១២០៣) រួចប្រគល់ជូនអ្នកប្តឹងតវ៉ា ឬអ្នកតំណាងមួយ (១) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ឬអ្នកតំណាងមួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.៦៣.១១.៣ ជម្រាបអ្នកប្តឹងតវ៉ា ឬអ្នកត្រូវគេប្តឹងជំទាស់ ឬអ្នកតំណាងថា គាត់មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់អំពីករណីនេះទៅ គ.ជ.ប ក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច ។

## ខ. នីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយបណ្តឹងនៅ គ.ជ.ប

### ខ.១. ការដាក់/ទទួលពាក្យបណ្តឹងនៅ គ.ជ.ប

២.៦៣.១២ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ និងអ្នកត្រូវគេប្តឹងជំទាស់ ឬអ្នកតំណាង ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គធ/ខប មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ ទៅ គ.ជ.ប ក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចរបស់ គធ/ខប ។ អ្នកប្តឹង ឬអ្នកតំណាងត្រូវបំពេញទម្រង់បែបបទលេខ ១២០២ ចំនួនបី (៣) ច្បាប់ (ចំពោះបណ្តឹងតវ៉ា) និងបួន (៤) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ។

២.៦៣.១៣ នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់ មួយចំនួន ជាអាទិ៍ ទី១ ឈ្មោះ

និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬអ្នកតំណាង ទី២ កម្មវត្ថុនៃបណ្ដឹង និងការគោរពអំឡុងពេលកំណត់ប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេចរបស់ គធ/ខប (ទ.១២០៣) ។

២.៦៣.១៤ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬអ្នកតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬអ្នកតំណាងផ្ដិតមេដៃលើកំណត់ហេតុនោះ ។ ក្នុងករណីអ្នកប្ដឹង ឬអ្នកតំណាងមិនព្រមផ្ដិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនេះ ។

២.៦៣.១៥ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុហើយ ឃើញថា ៖

២.៦៣.១៥.១ ពាក្យបណ្ដឹងមិនគោរពអំឡុងពេលកំណត់ប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេចរបស់ គធ/ខប (ទ.១២០៣) អគ្គលេខាធិការនៃ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹងមួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.៦៣.១៥.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ ដូចចែងក្នុងចំណុច ២.៦៣.៣ ខាងលើ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬអ្នកតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត អគ្គលេខាធិការនៃ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹងមួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.៦៣.១៥.៣ ពាក្យបណ្តឹងតវ៉ាគោរពអំឡុងពេលកំណត់ប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចរបស់ គធ/ខប (ទ.១២០៣) និងមានព័ត៌មានគ្រប់គ្រាន់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬអ្នកតំណាងមួយ (១) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ឬអ្នកតំណាងមួយ (១) ច្បាប់ (ចំពោះបណ្តឹងជំទាស់) រក្សាទុកក្នុងពេលសវនាការមួយ (១) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈមួយ (១) ច្បាប់ ។

**ខ.២. ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប**

២.៦៣.១៦ គ.ជ.ប ត្រូវសម្រេចលើបណ្តឹងក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

២.៦៣.១៧ ក្នុងករណី គ.ជ.ប សម្រេចបដិសេធ ឬយល់ព្រមលើបណ្តឹងតវ៉ា ឬលើបណ្តឹងជំទាស់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវ ៖

២.៦៣.១៧.១ ចាត់លេខាធិការសវនាការឱ្យស្រង់សេចក្តីសម្រេច ចូលក្នុងសម្រង់សេចក្តីសម្រេច (ទ. ១២០៣) ចំនួនបី (៣) ច្បាប់ (ចំពោះបណ្តឹងតវ៉ា) ឬចំនួនបួន (៤) ច្បាប់ (ចំពោះបណ្តឹងជំទាស់) និងឱ្យចុះហត្ថលេខាផង ។

២.៦៣.១៧.២ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប លើសម្រង់សេចក្តីសម្រេច (ទ. ១២០៣) រួចប្រគល់ជូនអ្នកប្តឹងតវ៉ា ឬអ្នកប្តឹងជំទាស់ ឬអ្នកតំណាងមួយ (១) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ឬអ្នកតំណាងមួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

**ប្រការ ២.៦៤** សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ ។

**ការផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ**

**ប្រការ ២.៦៥** បន្ទាប់ពីការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ត្រូវបានដោះស្រាយ តាមលំដាប់ថ្នាក់រួចរាល់ជាស្ថាពរហើយ គ.ជ.ប ត្រូវណែនាំនាយកដ្ឋានប្រតិបត្តិការ តាមរយៈអគ្គលេខាធិការ គ.ជ.ប ឱ្យកែតម្រូវបញ្ជីបោះឆ្នោតដំបូង ដោយផ្អែកតាមសេចក្តីសម្រេចលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់របស់ គធ/ខប និង គ.ជ.ប ។

ប្រការ ២.៦៦ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវធានាថា នាយកដ្ឋានប្រតិបត្តិការបានរៀបចំ និងបោះពុម្ពបញ្ជីបោះឆ្នោត តាមការិយាល័យបោះឆ្នោតនីមួយៗ រួចដាក់ជូន គ.ជ.ប ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៦៦.១ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវធានាថា រាល់សេចក្ដីសម្រេចរបស់ គធ/ខប និង គ.ជ.ប ដែលបានយល់ព្រមតាមបណ្ដឹងតវ៉ា ឬយល់ព្រមតាមបណ្ដឹងជំទាស់ ឬ ដែលបានបដិសេធលើបណ្ដឹងតវ៉ា ឬបដិសេធលើបណ្ដឹងជំទាស់ ត្រូវបានថតចម្លងចំនួនពីរ (២) ច្បាប់ និងចាត់ចែងឱ្យនាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម អនុវត្តតាមមុខការរៀងខ្លួន ដូចចែងក្នុង ប.ន.ក នេះ ។

២.៦៦.២ នាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប ត្រូវធានាថា រាល់សេចក្ដីសម្រេចរបស់ គធ/ខប និង គ.ជ.ប ដែលបានយល់ព្រមតាមបណ្ដឹងតវ៉ា ឬយល់ព្រមតាមបណ្ដឹងជំទាស់ ឬដែលបានបដិសេធលើបណ្ដឹងតវ៉ា ឬបដិសេធលើបណ្ដឹងជំទាស់ ត្រូវតែបានអនុវត្តយ៉ាងត្រឹមត្រូវ និងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ដើម្បីកែតម្រូវបញ្ជីបោះឆ្នោតដំបូងឱ្យមានលក្ខណៈសុក្រឹត ។ ផ្អែកតាមសេចក្ដីសម្រេចរបស់ គធ/ខប និង គ.ជ.ប ចំពោះករណីនីមួយៗ នាយកដ្ឋានប្រតិបត្តិការ ត្រូវចាត់ចែងមន្ត្រីឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត និងបញ្ចូលទិន្នន័យអ្នកបោះឆ្នោតក្នុងកុំព្យូទ័រ ដូចខាងក្រោម ៖

២.៦៦.២.១ ករណីបដិសេធបណ្ដឹងតវ៉ា ត្រូវរក្សាបញ្ជីបោះឆ្នោតដដែល ។

២.៦៦.២.២ ករណីបដិសេធបណ្ដឹងជំទាស់ ត្រូវរក្សាបញ្ជីបោះឆ្នោតដដែល ។

២.៦៦.២.៣ ករណីយល់ព្រមតាមបណ្ដឹងតវ៉ា ត្រូវធ្វើការកែតម្រូវឈ្មោះ និងទិន្នន័យពាក់ព័ន្ធ ឬចុះបន្ថែមឈ្មោះរបស់សាមីអ្នកប្ដឹងតវ៉ាដែលបានបាត់ឈ្មោះ ឬចុះឈ្មោះអ្នកត្រូវគេប្ដឹងជំទាស់ឡើងវិញ ក្នុងករណីជននោះឈ្នះការប្ដឹងតវ៉ានៅ គ.ជ.ប ទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.៦៦.២.៤ ករណីយល់ព្រមតាមបណ្ដឹងជំទាស់ ត្រូវលុបឈ្មោះអ្នកដែលត្រូវគេប្ដឹងជំទាស់ ឬលុបឈ្មោះដែលស្ទួន ចេញពីបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.៦៦.៣ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវលើកសំណើដោយមានការបញ្ជាក់ឯកភាព តាមលំដាប់ឋានានុក្រមមក គ.ជ.ប ដើម្បីសុំកែតម្រូវបញ្ជីបោះឆ្នោត ក្នុងករណី មានអ្នកបោះឆ្នោតម្នាក់ ឬច្រើននាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងរួចហើយ ប៉ុន្តែបែរជាលែងស្ថិតក្នុងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តទៅទៀត និងដែលមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងថ្មី ចូលជំនួសជាផ្លូវការ ។

២.៦៦.៤ សំណើសុំកែតម្រូវបញ្ជីបោះឆ្នោត ដោយផ្អែកតាមករណី ដូចមានចែងក្នុងចំណុច ២.៦៦.៣ ខាងលើ ប្រសិនបើមាន ត្រូវតែបានបញ្ជូនមកដល់ គ.ជ.ប ក្នុងចន្លោះពេលចាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង រហូតដល់យ៉ាងតិចមួយ (១) ថ្ងៃ មុនថ្ងៃដែល គ.ជ.ប ត្រូវប្រកាសសុពលភាពបញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ សំណើសុំកែតម្រូវនេះ ត្រូវតែមានភ្ជាប់មកជាមួយនូវ ៖

២.៦៦.៤.១ ឯកសារជាភស្តុតាងបញ្ជាក់អំពីករណីពាក់ព័ន្ធនៃអ្នកបោះឆ្នោត ដែលត្រូវស្នើលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដំបូង ។

២.៦៦.៤.២ ឯកសារផ្លូវការតែងតាំងអ្នកថ្មីជំនួស ដែលត្រូវស្នើបញ្ចូលឈ្មោះទៅក្នុងបញ្ជីបោះឆ្នោតដំបូង ។

២.៦៦.៥ គ.ជ.ប ត្រូវពិនិត្យសម្រេចជាបន្ទាន់ លើសំណើសុំកែតម្រូវបញ្ជីបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.៦៦.៤ ខាងលើ ប្រសិនបើមាន និងត្រូវចាត់ចែងឱ្យនាយកដ្ឋានប្រតិបត្តិការកែតម្រូវបញ្ជីបោះឆ្នោតដំបូងជាបន្ទាន់ តាមការសម្រេចរបស់ គ.ជ.ប នៅមុនពេល គ.ជ.ប ប្រកាសសុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ ។

២.៦៦.៦ នាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប ត្រូវធានាថា ផ្អែកតាមការសម្រេចរបស់ គ.ជ.ប លើសំណើសុំកែតម្រូវបញ្ជីបោះឆ្នោត តាមករណីនីមួយៗ មន្ត្រីក្រោមឱវាទបានកែតម្រូវឈ្មោះ និងទិន្នន័យបញ្ជីបោះឆ្នោតដំបូងក្នុងកុំព្យូទ័រ ដោយត្រូវ ៖

២.៦៦.៦.១ លុបចេញពីបញ្ជីបោះឆ្នោតនូវឈ្មោះ និងទិន្នន័យអ្នកដែលត្រូវបាន គ.ជ.ប សម្រេចលុប ដូចចែងក្នុងចំណុច ២.៦៦.៤.១ ។

២.៦៦.៦.២ បញ្ចូលក្នុងបញ្ជីបោះឆ្នោតដំបូងនូវឈ្មោះ និងទិន្នន័យអ្នកបោះឆ្នោតថ្មី ដែលត្រូវបាន គ.ជ.ប សម្រេចឱ្យបញ្ចូលជំនួស ដូចចែងក្នុងចំណុច ២.៦៦.៤.២ ។

២.៦៦.៧ នាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប ត្រូវរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រនូវសេចក្តីព្រាងបញ្ជីបោះឆ្នោតផ្លូវការ តាមការិយាល័យបោះឆ្នោតនីមួយៗ ក្នុងទម្រង់ឯកភាពគ្នាតែមួយ ដែលក្នុងនោះ រួមមាន ៖

២.៦៦.៧.១ លេខកូដមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឈ្មោះរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតនៅក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

២.៦៦.៧.២ ប្រឡោះតូចសម្រាប់គូសសំគាល់ ពេលមកបោះឆ្នោត ។

២.៦៦.៧.៣ លេខរៀងនៃឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ។

២.៦៦.៧.៤ នាមត្រកូល និងនាមខ្លួន (រៀបចំតាមអក្ខរក្រមខ្មែរ) ភេទ ថ្ងៃ ខែ ឆ្នាំកំណើត តំណែងក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ និង អាសយដ្ឋានបច្ចុប្បន្ននៃអ្នកបោះឆ្នោត ។

២.៦៦.៧.៥ ខ្ទង់ទំនេរសម្រាប់ចារសម្គាល់ឯកសារបញ្ជាក់អត្តសញ្ញាណ ដែលបានប្រើនៅពេលបោះឆ្នោត ។

២.៦៦.៧.៦ ការបញ្ជាក់ចំនួនអ្នកបោះឆ្នោតសរុប ក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតនីមួយៗ ។

២.៦៦.៧.៧ ការបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅគ្រប់ទំព័រ ។

២.៦៦.៧.៨ ចន្លោះបំរុងទុកសម្រាប់ការចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប នៅលើទំព័រចុងក្រោយ ។

២.៦៦.៨ គ.ជ.ប ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតទាំងអស់ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងរយៈពេលយ៉ាងតិចសាមសិបប្រាំ (៣៥) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ នាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប ត្រូវធានាថា សេចក្តីព្រាងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតទាំងអស់ ក្នុងទម្រង់ឯកភាពតែមួយ ដែលបានពិនិត្យកែតម្រូវរួចក្នុងកុំព្យូទ័រ ត្រូវតែបានបោះពុម្ពដោយឡែកពីគ្នា តាមការិយាល័យបោះឆ្នោតនីមួយៗ និងដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។

២.៦៦.៨.១ សេចក្តីព្រាងបញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដូចចែងក្នុងចំណុច ២.៦៦.៧ ខាងលើ ត្រូវតែបានដាក់ជូន គ.ជ.ប ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការ នៅលើទំព័រចុងក្រោយ ។ ដោយឡែក នៅគ្រប់ទំព័រផ្សេងទៀតនៃបញ្ជីបោះឆ្នោតផ្លូវការនេះ ក្រៅពីទំព័រចុងក្រោយ ក៏ត្រូវមានបោះត្រារបស់ គ.ជ.ប ផងដែរ ។

២.៦៦.៨.២ ច្បាប់ដើមនៃបញ្ជីបោះឆ្នោតផ្លូវការ តាមការិយាល័យបោះឆ្នោតនីមួយៗ មួយ (១) ច្បាប់ ត្រូវរក្សាទុកជាឯកសារនៅ គ.ជ.ប ។

២.៦៦.៨.៣ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗ ដូចចែងក្នុងចំណុច ២.៦៦.៨.២ ត្រូវតែបានថតចម្លងបន្ថែមចំនួនបី (៣) ច្បាប់ទៀត ដែលត្រូវរៀបចំតាមលំដាប់លេខកូដ នៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ និងវេចខ្ចប់ដោយឡែកពីគ្នាតាមរាជធានី ខេត្តនីមួយៗ ។ បញ្ជីបោះឆ្នោតផ្លូវការចំនួនបី (៣) ច្បាប់ ត្រូវផ្តល់ជូន គធ/ខប ដើម្បីបិទផ្សាយចំនួនពីរ (២) ច្បាប់ និងរក្សាទុកមួយ (១) ច្បាប់ ។

២.៦៦.៨.៤ គធ/ខប ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងរយៈពេលយ៉ាងតិចសាមសិប (៣០) ថ្ងៃ មុនថ្ងៃបោះឆ្នោត នៅការិយាល័យបោះឆ្នោត និងនៅទីកន្លែងសាធារណៈណាមួយក្នុងមណ្ឌលបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សា ។

២.៦៦.៨.៥ រាល់កញ្ចប់បញ្ជីបោះឆ្នោតផ្លូវការ ដែលវេចខ្ចប់និងបញ្ជូនខាងលើនេះ ត្រូវតែមានសរសេរសម្គាល់ លេខកូដមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឈ្មោះរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌទាំងអស់ក្នុងរាជធានី ខេត្ត ព្រមទាំងគោលដៅដែលត្រូវទទួល និងប្រើប្រាស់បញ្ជីបោះឆ្នោតនោះផង ។

២.៦៦.៩ បញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលត្រូវបាន គ.ជ.ប ផ្តល់សុពលភាពរួចហើយ មិនអាចកែប្រែបានឡើយ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។

២.៦៦.១០ ក្នុងករណី មានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យ គ.ជ.ប ដាក់ជំនួសក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។

២.៦៦.១១ គ.ជ.ប ត្រូវធានាថា នាយកដ្ឋានប្រតិបត្តិការនៃ គ.ជ.ប បានចាត់វិធានការម៉ត់ចត់ក្នុងការថែរក្សាសុវត្ថិភាពបញ្ជីបោះឆ្នោតផ្លូវការ ជាឯកសាររបស់ គ.ជ.ប និងរក្សាសុវត្ថិភាពទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការនេះ ក្នុងកុំព្យូទ័របានល្អប្រសើរ ។

២.៦៦.១២ គណបក្សនយោបាយដែលបានអនុញ្ញាតឱ្យចុះបញ្ជី ដើម្បីចូលរួមប្រកួតប្រជែង នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងអង្គការពាក់ព័ន្ធនានា មានសិទ្ធិស្នើសុំពី គ.ជ.ប នូវច្បាប់ចម្លងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតមួយ ឬច្រើន ចំនួនមួយ (១) ច្បាប់ ដោយបង់ថ្លៃត្រឹមតម្លៃផលិត ។ ការផ្តល់ផ្គត់ផ្គង់ចំពោះការស្នើសុំនេះ ត្រូវផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ រាល់ការស្នើសុំ តម្រូវឱ្យបង់ប្រាក់ជាមុនស្មើនឹងមួយរយ (១០០) ភាគរយ នៃតម្លៃផលិតផលស្នើសុំ ។

**ប្រការ២.៦៧** តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងគណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អាចចូលរួមសង្កេតការណ៍ ក្នុងគ្រប់ដំណើរនៃការចុះឈ្មោះបោះឆ្នោត ការរៀបចំបញ្ជីបោះឆ្នោតដំបូង ការបើកសវនាការដោះស្រាយបណ្តឹងនៅគ្រប់លំដាប់ថ្នាក់ និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ។ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិដែលចូលរួមសង្កេតការណ៍ ត្រូវតែមានការអនុញ្ញាតពី គ.ជ.ប ឬអាជ្ញាធររៀបចំការបោះឆ្នោត ដែលត្រូវបានប្រគល់សិទ្ធិ ។

**ប្រការ២.៦៨** ទោះបីជានីតិវិធីនៃការដាក់ពាក្យបណ្តឹង និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ត្រូវបានចែងលំអិតរួចហើយក្នុងផ្នែកទី ៤ ជំពូកទី ២ នៃ ប.ន.ក នេះក្តី ក្នុងការអនុវត្តត្រូវតែគួបផ្សំជាមួយនឹងនីតិវិធីនៃការដាក់ពាក្យបណ្តឹង និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ដូចចែងក្នុងជំពូកទី ៤ នៃ ប.ន.ក នេះដែរ ។ ការរាប់ចំនួនថ្ងៃតវ៉ា និងការសម្រេចលើបណ្តឹងតវ៉ាពុំរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

**លក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**

**ប្រការ២.៦៩** អ្នកមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគឺ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែង ។ គ.ជ.ប ត្រូវណែនាំដល់អ្នកបោះឆ្នោត អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ អំពីសិទ្ធិបោះឆ្នោត និងលក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៦៩.១ ដើម្បីមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែងទាំងពីរភេទត្រូវមានឈ្មោះ នៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងមានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ សម្រាប់ប្រើនៅថ្ងៃបោះឆ្នោត ។

២.៦៩.២ នៅថ្ងៃបោះឆ្នោត សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងណា ដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ទោះបីមានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ឬលិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អត្តសញ្ញាណចេញដោយមេឃុំ ចៅសង្កាត់ ក៏ដោយ ក៏មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដែរ ។

២.៦៩.៣ នៅថ្ងៃបោះឆ្នោត ទោះបីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងណាម្នាក់ ឬច្រើននាក់ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ឬលិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អត្តសញ្ញាណចេញដោយមេឃុំ ចៅសង្កាត់ ក៏មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដែរ ។

២.៦៩.៤ ឈ្មោះអ្នកបោះឆ្នោតនៅក្នុងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយ ឬលិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អត្តសញ្ញាណ ចេញដោយមេឃុំ ចៅសង្កាត់ ត្រូវតែដូចគ្នានឹងឈ្មោះនៃអ្នកបោះឆ្នោតនោះ នៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។

២.៦៩.៥ ឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការ ឬលិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដែលចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬលិខិតបញ្ជាក់អត្តសញ្ញាណចេញដោយមេឃុំ ចៅសង្កាត់ ត្រូវតែមានបិទរូបថតសាមីខ្លួន ។

# ផ្នែកទី ៥
## ការិយាល័យបោះឆ្នោត

**ការិយាល័យបោះឆ្នោត**

**ប្រការ** ២.៧០ គ.ជ.ប ត្រូវកំណត់ក្នុងជំហានដំបូងនូវការិយាល័យបោះឆ្នោតមួយ (១) ឬច្រើនសម្រាប់ក្រុង ស្រុក ខណ្ឌនីមួយៗ ក្នុងរយៈពេលយ៉ាងតិចដប់ប្រាំ (១៥) ថ្ងៃ មុនថ្ងៃចាប់ផ្តើមចុះឈ្មោះបោះឆ្នោត ។ ទីតាំងការិយាល័យបោះឆ្នោតអាចនឹងកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប បន្ទាប់ពីការចុះឈ្មោះបោះឆ្នោតបានបញ្ចប់ និងត្រូវធ្វើឱ្យហើយរួចរាល់នៅរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ មុនថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ ការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត នៅពេលរាប់សន្លឹកឆ្នោត ។ គណៈកម្មការការិយាល័យបោះឆ្នោត " គកប " នឹងក្លាយទៅជាគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត " គករ " នៅពេលរាប់សន្លឹកឆ្នោត ។

២.៧០.១ ក្រុង ស្រុក ខណ្ឌ គឺជាការិយាល័យបោះឆ្នោត ។

២.៧០.២ ក្នុងករណីចាំបាច់ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំនួនមួយ ឬច្រើនអាចតាំងនៅក្នុងបរិវេណអាគារ ឬកន្លែងតែមួយ ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សុចរិតភាព និងប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ ។ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងនោះត្រូវតែរៀបចំខណ្ឌដាច់ពីគ្នា និងគ្រប់គ្រងដោយឡែកពីគ្នា ។

២.៧០.៣ ការកែសម្រួលទីតាំងការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវគោរពតាមលក្ខខណ្ឌជាក់ស្តែង និងសុវត្ថិភាពនៃកិច្ចប្រតិបត្តិការបោះឆ្នោត ។

២.៧០.៤ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបំរើឱ្យតំបន់បោះឆ្នោតមួយដែលបានកំណត់ ។ ការិយាល័យបោះឆ្នោត និងតំបន់បោះឆ្នោតស្ថិតក្នុងដែនសមត្ថកិច្ច ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវតែរួមបញ្ចូលនូវឃុំ សង្កាត់ទាំងអស់ ដែលស្ថិតក្នុងព្រំប្រទល់រដ្ឋបាលក្រុង ឬស្រុក ឬខណ្ឌពាក់ព័ន្ធ ។

២.៧០.៥ គ.ជ.ប ត្រូវចាត់វាល់វិធានការចាំបាច់ ដើម្បីបង្កើតការិយាល័យបោះឆ្នោតមួយ (១) ឬច្រើនសម្រាប់ក្រុង ស្រុក ខណ្ឌនីមួយៗ ដើម្បីឱ្យសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំណុះក្រុង ស្រុក ខណ្ឌនោះ បានចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតទាំងអស់គ្នា ។

២.៧០.៦ ការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌនីមួយៗ អាចរួមបញ្ចូលឃុំ សង្កាត់ច្រើនជាងមួយ ។

២.៧០.៧ ការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវទទួលចុះឈ្មោះអ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងទាំងអស់ ចំណុះក្រុង ស្រុក ខណ្ឌរបស់ខ្លួន ។

២.៧០.៨ ការិយាល័យបោះឆ្នោត ដែលបញ្ជីបោះឆ្នោតនៃការិយាល័យ ត្រូវបានផ្តល់សុពលភាពជាផ្លូវការដោយ គ.ជ.ប នឹងត្រូវប្រើជាការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៧០.៩ ការិយាល័យបោះឆ្នោត គឺជាការិយាល័យនៅមួយកន្លែង ដែល គ.ជ.ប បង្កើតឡើងនៅទីតាំងជាក់លាក់មួយសម្រាប់តំបន់បោះឆ្នោតមួយជាកំណត់ ហើយដែលត្រូវបើកទទួលអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ មកបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

២.៧០.១០ ក្នុងការកំណត់ទីតាំងការិយាល័យបោះឆ្នោត ត្រូវយកចិត្តទុកដាក់ចំពោះទីតាំងសាលារៀន ទីវត្តអារាម និងទីសាធារណៈ ។

២.៧០.១១ ការិយាល័យបោះឆ្នោត មិនត្រូវបានបង្កើត នៅក្នុងបរិវេណទីធ្លា និងអាគាររបស់រាជរដ្ឋាភិបាលដូចជា សាលាខេត្ត ក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ជាដើម ឬនៅបន្ទាយ ឬអាគារនៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ឬ/និងអាគាររបស់គណបក្សនយោបាយ នៅគ្រប់លំដាប់ថ្នាក់ ។

**វិធានការសន្តិសុខសម្រាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ ២.៧១** ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ គឺជាទីតាំងរដ្ឋបាល និងសន្តិសុខ ដែលត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ។

២.៧១.១ បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអាគារដែលការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាំងនៅ ហើយដែលខ័ណ្ឌដោយវណ្ឌមណ្ឌលមួយមានកាំប្រវែងយ៉ាងតិចដប់ប្រាំ (១៥) ម៉ែត្រ ។

២.៧១.២ ការិយាល័យបោះឆ្នោត ត្រូវរៀបចំឱ្យមានច្រកចេញមួយ និងច្រកចូលមួយ ។

២.៧១.៣ បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលខ័ណ្ឌដោយវណ្ឌមណ្ឌល មានកាំប្រវែងមួយរយ (១០០) ម៉ែត្រ ឬមានកាំតូចជាង ដោយតាមស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជារបងនៃវត្តអារាម សាលារៀន សាលមហោស្រព ឬទីធ្លាសាធារណៈ ជាដើម ។

២.៧១.៤ ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ ចរាចរ និងសណ្តាប់ធ្នាប់ នៅទីប្រជុំជនក្រុង ស្រុក ខណ្ឌនីមួយៗ គធ/ខប អាចចាត់ចែងឱ្យមានបរិវេណសន្តិសុខ សម្រាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ ដើម្បីបង្ការកុំឱ្យមានការរំខានដល់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

**ប្រការ២.៧២** ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុង នៃការិយាល័យទាំងនោះ ឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារឧបករណ៍សម្ភារទាំងអស់ក្នុងការិយាល័យទាំងនោះ គ.ជ.ប គធ/ខប និងប្រធាន គកប ត្រូវចាត់វិធានការចាំបាច់នានា ដូចខាងក្រោម ៖

២.៧២.១ ហាមជនគ្រប់រូបយកអាវុធ ឬ/និងជាតិផ្ទុះ ឬ/និងសារជាតិ ឬវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។ ក្នុងករណីដែលមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ប្រធាន គ.ជ.ប គធ/ខប និងប្រធាន គកប មានភារកិច្ចស្នើសុំអន្តរាគមន៍រក្សាសន្តិសុខ ពីអាជ្ញាធរមានសមត្ថកិច្ចនៅគ្រប់លំដាប់ថ្នាក់ ។

២.៧២.១.១ គ.ជ.ប គធ/ខប ត្រូវប្រគល់សិទ្ធិអំណាចពេញលេញដល់ប្រធាន គកប ក្នុងការទំនាក់ទំនងស្នើសុំអន្តរាគមន៍ ពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីដូចចែងក្នុងចំណុច ២.៧២.១ ។

២.៧២.១.២ ក្នុងករណី មានសំណូមពរពីប្រធាន គកប ឱ្យជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យណាមួយនោះ ភ្នាក់ងារសន្តិសុខ ដែលបំពាក់ដោយអាវុធសមស្របអាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធបាន ។

២.៧២.១.៣ ហាមនាយ ឬពលនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ និងកងនគរបាលជាតិណាម្នាក់ចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខឡើយ ។ បំរាមនេះត្រូវបានលើកលែង ក្នុងករណី អ្នកទាំងនោះត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខ ឬភ្នាក់ងារសង្គ្រោះ និងត្រូវបានប្រធាន គកប ស្នើសុំឱ្យធ្វើអន្តរាគមន៍ ដូចចែងក្នុងប្រការ ២.៧២ និងលក្ខខណ្ឌទាំងឡាយក្រោមចំណុច ២.៧២.១ ។

២.៧២.២ ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត មុនពេលការិយាល័យនោះចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម ៖

២.៧២.២.១ សមាសភាព គកប ដែលបានទទួលការតែងតាំងពី គ.ជ.ប ។

២.៧២.២.២ តំណាងគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត និងអ្នកសង្កេតការណ៍ ដែលទទួលបានការអនុញ្ញាតពី គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោត ដែលត្រូវបានប្រគល់សិទ្ធិ ។

២.៧២.២.៣ អ្នកយកព័ត៌មានដែលទទួលបានការអនុញ្ញាតពី គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតដែលត្រូវបានប្រគល់សិទ្ធិ ។

២.៧២.២.៤ អ្នកមានសិទ្ធិបោះឆ្នោត ដែលត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

២.៧២.២.៥ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គកប សំណូមពរ ក្នុងករណីចាំបាច់ ។

២.៧២.៣ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

២.៧២.៣.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

២.៧២.៣.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោតបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។

២.៧២.៣.៣ ការបង្ហាញការគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

២.៧២.៤ ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោតមុនពេល ឬក្រោយពេលរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម ៖

២.៧២.៤.១ សមាសភាព គករ ដែលបានទទួលការតែងតាំងពី គ.ជ.ប និងដែលទទួលខុសត្រូវរាប់សន្លឹកឆ្នោតនៅការិយាល័យនោះ ។

២.៧២.៤.២ តំណាងគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត និងអ្នកសង្កេតការណ៍ ដែលទទួលបានការអនុញ្ញាតពី គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោត ដែលត្រូវបានប្រគល់សិទ្ធិ ។

២.៧២.៤.៣ អ្នកយកព័ត៌មានដែលទទួលបានការអនុញ្ញាតពី គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតដែលត្រូវបានប្រគល់សិទ្ធិ ។

២.៧២.៤.៤ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គករ សំណូមពរ ក្នុងករណីចាំបាច់ ។

២.៧២.៥ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

២.៧២.៥.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

២.៧២.៥.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យសមាសភាព គករ ដែលទទួលខុសត្រូវរាប់សន្លឹកឆ្នោត រាប់គំនូសនៅលើសន្លឹកឆ្នោតគាំទ្រ ឬប្រឆាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

២.៧២.៦ ក្នុងករណីចាំបាច់ គធ/ខប ឬ/និងប្រធាន គកប/គករ អាចអនុវត្តលក្ខខណ្ឌដូចចែងក្នុងចំណុច ២.៧១.៤ ខាងលើ ដើម្បីធានាឱ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ។

២.៧២.៧ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គកប/គករ ដែលត្រូវបានប្រគល់សិទ្ធិពេញលេញដោយ គ.ជ.ប ស្របតាមលក្ខខណ្ឌនៃច្បាប់ ។

**ប្រការ២.៧៣** ចំពោះការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីកាលៈទេសៈមានអាសន្ន ដូចកំណត់ក្រោមប្រការ ១.៩ គ.ជ.ប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ដែលមានសុវត្ថិភាព ។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណៈអំពីសេចក្ដីសម្រេចនេះ ។

**ប្រការ២.៧៤** សំណង់ អាគារ ឬទីធ្លាសាធារណៈ និងទីវត្តអារាមត្រូវបានផ្ដល់ដោយឥតគិតថ្លៃទៅ គ.ជ.ប សម្រាប់រៀបចំជាការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

**ការផ្សព្វផ្សាយបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ២.៧៥** គ.ជ.ប ត្រូវបោះពុម្ពផ្សាយនូវបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។ នាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានបណ្ដុះបណ្ដាល និងព័ត៌មានសាធារណៈនៃ គ.ជ.ប ត្រូវអនុវត្តដោយផ្ទាល់ ឬ/និងសហការជាមួយ គឃ/ខប ក្រុមប្រឹក្សាឃុំ សង្កាត់ និងសង្គមស៊ីវិល ក្នុងការផ្សព្វផ្សាយបញ្ជីទីតាំងការិយាល័យខាងលើ ឱ្យបានយល់ជ្រួតជ្រាបដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងទាំងអស់ ដែលមានសិទ្ធិបោះឆ្នោតសម្រាប់ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។

២.៧៥.១ គ.ជ.ប ត្រូវណែនាំ គឃ/ខប និងក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅ គឃ/ខប និង សាលាឃុំ សង្កាត់ មុនពេលចាប់ផ្ដើមការចុះឈ្មោះបោះឆ្នោត ។

២.៧៥.២ នៅក្រោយបញ្ចប់ការចុះឈ្មោះបោះឆ្នោត និងបន្ទាប់ពីបានកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប នូវចំនួននិងទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត គ.ជ.ប ត្រូវណែនាំ គឃ/ខប ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅតាមសាលាឃុំ សង្កាត់ និងនៅទីកន្លែងសាធារណៈណាមួយនៅក្នុងមណ្ឌលបោះឆ្នោត យ៉ាងតិចសាមសិប (៣០) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.៧៥.៣ គណបក្សនយោបាយ ដែលបានអនុញ្ញាតឱ្យចុះបញ្ជី ដើម្បីចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា មានសិទ្ធិស្នើសុំពី គ.ជ.ប នូវបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតផ្លូវការ ដោយត្រូវបង់ថ្លៃត្រឹមថ្លៃផលិត ។ ការផ្គត់ផ្គង់ចំពោះការស្នើសុំខាងលើនេះ ត្រូវផ្អែកតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ រាល់ការស្នើសុំតម្រូវឱ្យបង់ប្រាក់មុនស្មើនឹងមួយរយ(១០០) ភាគរយនៃតម្លៃផលិតផលស្នើសុំ ។

២.៧៥.៤ គ.ជ.ប ត្រូវផ្ញើច្បាប់ចម្លងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ មួយច្បាប់ ជូនក្រសួងមហាផ្ទៃ ។

# ផ្នែកទី ៦

## ការឃោសនាបោះឆ្នោត

**បញ្ញត្តិទូទៅ**

**ប្រការ ២.៧៦** អនុលោមតាម ច.ប.ក ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។ ការឃោសនាបោះឆ្នោតគឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើឡើងជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ។ សកម្មភាពមួយចំនួនដើម្បីគាំទ្របេក្ខជនឬគណបក្សនយោបាយណាមួយ ឬរិះគន់គោលនយោបាយ ឬកម្មវិធីនយោបាយគណបក្សណាមួយមានដូចជា ៖

២.៧៦.១ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ។

២.៧៦.២ ការជួបជុំ ឬការរៀបចំជាក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ឬការឃោសនាតាមផ្ទះ ។

២.៧៦.៣ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ។

២.៧៦.៤ ការផ្សព្វផ្សាយតាមរលកអាកាស ឬស្រែកជាពាក្យស្លោកខ្លីៗតាមឧបករណ៍បំពងសំឡេង ឬដោយការចាក់ម៉ាញ៉េ ។

២.៧៦.៥ ការផ្សព្វផ្សាយតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌីក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ ។

២.៧៦.៦ សកម្មភាពបិទផ្សាយនូវរូបភាពឃោសនា ។

២.៧៦.៧ សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ។

២.៧៦.៨ សកម្មភាពចែកចាយមួក សំលៀកបំពាក់ ស្លាកសញ្ញាគណបក្សនយោបាយ ឬសម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិត ជូនអ្នកបោះឆ្នោត ។

២.៧៦.៩ សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទប្រកាសផ្សាយ ។

២.៧៦.១០ ការប្រគំតន្ត្រីដោយការដើរជាក្បួន ឬនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ។

២.៧៦.១១ ការរៀបចំកម្មវិធីប្រកួតកីឡា ។

**ប្រការ២.៧៧** ការឃោសនាត្រូវបើករយៈពេលដប់ប្រាំមួយ (១៦) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.៧៧.១ សកម្មភាពឃោសនាបោះឆ្នោតត្រូវធ្វើឡើងក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ជាប់ៗគ្នា ។

២.៧៧.២ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោងប្រាំមួយ (៦) ព្រឹក ដល់ម៉ោងដប់ (១០) យប់ ។

២.៧៧.៣ គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ត្រូវឈប់សម្រាកនៅចន្លោះពីម៉ោងដប់ (១០) យប់ ដល់ម៉ោងប្រាំមួយ (៦) ព្រឹក ។ បន្ថែមលើនេះទៀត សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវហាមឃាត់ចាប់ពីម៉ោងដប់ពីរ (១២) ថ្ងៃត្រង់ ដល់ម៉ោងពីរ (២) រសៀល ។

២.៧៧.៤ ការឃោសនាត្រូវបញ្ចប់ម្ភៃបួន (២៤) ម៉ោងមុនថ្ងៃបោះឆ្នោត ។

២.៧៧.៥ រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិទាក់ទងទៅនឹងការបោះឆ្នោតត្រូវបញ្ឈប់ប្រាំ (៥) ថ្ងៃមុនថ្ងៃបោះឆ្នោត និងហាមធ្វើនៅថ្ងៃបោះឆ្នោត ។ ការស្ទង់មតិ គឺជាការប្រើបញ្ជីសំនួរដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីការបោះឆ្នោត ។ ការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិត្រូវបញ្ជាក់អំពីប្រភពផ្តល់ព័ត៌មាន ពេលវេលា ចំនួនប្រជាពលរដ្ឋដែលត្រូវបានជ្រើសរើសមកស្ទង់មតិ និងកម្រិតលម្អៀងនៃលទ្ធផល ។

២.៧៧.៦ មិនអនុញ្ញាតឱ្យធ្វើសកម្មភាពឃោសនាអ្វីទាំងអស់ក្នុងអំឡុងពេលម្ភៃបួន (២៤) ម៉ោងមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។

២.៧៧.៦.១ ជនណាប្រព្រឹត្តល្មើសនឹងបម្រាមនេះនឹងត្រូវទទួលការពិន័យតាម ច.ប.ក ។

២.៧៧.៦.២ អ្នកបោះឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង អាចស្នាក់នៅជុំគ្នា នៅថ្ងៃមុនថ្ងៃបោះឆ្នោត ក្នុងទីប្រជុំជន ក្រុង ស្រុក ខណ្ឌ ដែលការិយាល័យបោះឆ្នោតរបស់ពួកគាត់តាំងនៅ ។

២.៧៧.៦.៣ ការស្នាក់នៅ ដូចចែងក្នុងចំណុច ២.៧៧.៦.២ មិនចាត់ទុកថាជាសកម្មភាពឃោសនាឡើយ ។

**ប្រការ២.៧៨** គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ស្តីពីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ អាចរៀបចំកិច្ចប្រជុំអំពីកម្មវិធីនយោបាយរបស់ខ្លួននៅទីកន្លែងឯកជនបានគ្រប់ពេល និងមានសិទ្ធិលើកស្លាកគណបក្សគ្រប់ពេលនៅលើទីតាំងឯកជន ឬផ្ទះឯកជន ដោយមានការអនុញ្ញាតពីម្ចាស់ទីកន្លែងនោះ ។

២.៧៨.១ ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ និងសណ្តាប់ធ្នាប់ តាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ។

២.៧៨.២ ស្លាកសញ្ញាគណបក្ស និងសម្ភារឃោសនារបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអាគារ ឬការិយាល័យរបស់រដ្ឋ ។

២.៧៨.៣ ស្លាកសញ្ញា ឬសម្ភារឃោសនារបស់គណបក្សនយោបាយដែលស្ថិតនៅក្នុងរង្វង់ ១០០ ម៉ែត្រពីការិយាល័យបោះឆ្នោតត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

២.៧៨.៤ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយបដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

**ប្រការ២.៧៩** ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះឱ្យអ្នកបោះឆ្នោតជិះ មិនរាប់បញ្ចូលទៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈជាឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នឹងការឃោសនាបោះឆ្នោត ។

២.៧៩.១ ហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

២.៧៩.២ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ត្រូវបានកំណត់ដូចជា ៖ រថយន្តទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬ/និងរដ្ឋ រាជរដ្ឋាភិបាល នគរបាល និង ខេមរភូមិន្ទ ។

២.៧៩.៣ ការដឹកជញ្ជូនមានលក្ខណៈកៀងគរ ឬរៀបចំទុកជាមុន ត្រូវហាមឃាត់ ។

**ប្រការ** ២.៨០ ការស្លៀកពាក់ (សំលៀកបំពាក់ មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា ឬសារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរាប់បញ្ចូលទៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត ។

**ប្រការ** ២.៨១ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវ ៖

- ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ ។
- ប្រើប្រាស់អាគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោត ។
- ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយឡើយ ។

ការចូលរួមសកម្មដែលត្រូវបានហាមឃាត់ ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការដែលកំពុងបំពេញភារកិច្ចត្រូវបានកំណត់ដូចតទៅ ៖

២.៨១.១ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។

២.៨១.២ ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រាដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

២.៨១.៣ ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨១.៤ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨១.៥ ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោត ដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

២.៨១.៦ ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

២.៨១.៧ ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

**ប្រការ២.៨២** បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬស្ថិតក្នុងច្បាប់ឈប់សម្រាក មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន ឬ/និងមិនត្រូវមានអាវុធជាប់នឹងខ្លួនឡើយ ។ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងមន្ត្រីតុលាការ ដែលប្រព្រឹត្តល្មើសនឹងប្រការនេះ និងប្រការ ២.៨១ ត្រូវទទួលទោស ដូចមានចែងក្នុងមាត្រា ៨៧ នៃ ច.ប.ក ។

**ប្រការ ២.៨៣** មុននឹងបើកការឃោសនាបោះឆ្នោត គធ/ខប ត្រូវផ្សព្វផ្សាយដល់មន្ត្រីដែលបានរៀបរាប់ក្នុងប្រការ ២.៨១ និង ២.៨២ ខាងលើ និងប្រការ ២.៨៧ ខាងក្រោម តាមរយៈអាជ្ញាធរដែនដី កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីភារកិច្ច និងអព្យាក្រឹតភាព ក្នុងម៉ោងធ្វើការទាក់ទិនដល់ការឃោសនាបោះឆ្នោត ។

**ប្រការ២.៨៤** គធ/ខប ត្រូវរៀបចំកម្មវិធីប្រជុំប្រចាំសប្តាហ៍ ឬតាមការចាំបាច់ ជាមួយនឹងតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានាដើម្បី ៖

- ជម្រាបឱ្យដឹងពីការប្រព្រឹត្តទៅនៃការបោះឆ្នោត ។
- ជម្រាបជូនជាសង្ខេបពី ប.ន.ក ។
- ស្តាប់មតិយោបល់ សំណូមពរ និងការកត់សំគាល់ផ្សេងៗ របស់អង្គប្រជុំ ។
- ពិភាក្សាលើបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធដល់ការបោះឆ្នោត ។

**ប្រការ២.៨៥** គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវតែគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ដែលអនុម័តដោយ គ.ជ.ប ។

២.៨៥.១ គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវតែគោរព ច.ប.ក ។

២.៨៥.២ គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវតែគោរព ប.ន.ក និងសេចក្តីណែនាំផ្សេងៗ ដែលបានអនុម័តដោយ គ.ជ.ប ។

២.៨៥.៣ គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ ។

២.៨៥.៤ គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវតែអនុវត្តតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដូចមានចែងក្នុងជំពូកទី ៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

២.៨៥.៥ គណបក្សនយោបាយ បេក្ខជន ឬតំណាង មិនត្រូវបង្គាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួន ទៅហែក ឬបំផ្លាញចោលនូវសម្ភារឯកសារផ្សព្វផ្សាយការឃោសនាបោះឆ្នោតរបស់គណបក្ស ឬ/និងបេក្ខជនដទៃឡើយ ។

២.៨៥.៦ គណបក្សនយោបាយ បេក្ខជន ឬតំណាង មិនត្រូវជម្រុញឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបំភិតបំភ័យ ក្នុងអំឡុងពេលធ្វើការឃោសនាបោះឆ្នោតឡើយ ។

២.៨៥.៧ គណបក្សនយោបាយ បេក្ខជន ឬតំណាង ឬជនណាក៏ដោយ មិនត្រូវផ្តល់វិភាគទាន ជូនសគុណចែកអំណោយឬរង្វាន់លើកទឹកចិត្ត ជាប្រាក់កាស សម្ភារទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់បុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោតឡើយ ។

២.៨៥.៨ គណបក្សនយោបាយ បេក្ខជន ឬតំណាង មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យបុគ្គលណាម្នាក់ ឬច្រើននាក់ ឬក្រុមណាមួយ ឬច្រើនក្រុម ទោះបីដោយផ្ទាល់ក្តី

ឬដោយប្រយោលក្តី ដើម្បីឱ្យអ្នកទាំងនោះ ឬក្រុមទាំងនោះ គាំទ្រខ្លួន ឬបំបាក់ទឹកចិត្ត បុគ្គលទាំងនោះ ឬក្រុមទាំងនោះ ឱ្យឈប់គាំទ្រដល់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀយ ។ ការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ៖

២.៨៥.៨.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ។

២.៨៥.៨.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថានឹងធ្វើទារុណកម្ម ។

២.៨៥.៨.៣ ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរ ។

២.៨៥.៨.៤ ការរំលោភដោយពាក្យសំដីថា នឹងធ្វើទុក្ខទោសដល់រាងកាយ ។

២.៨៥.៨.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសញ្ញាវុធដើម្បីបំភិតបំភ័យ ។

២.៨៥.៨.៦ ការលើកឡើងជាពាក្យសំដី ឬជាលាយលក្ខណ៍អក្សរ ដោយយកព្រឹត្តិការណ៍គួរឱ្យតក់ស្លុត ពីអតីតកាលមកដំណាល ដូចជាឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ឬក្រុមណាមួយ ។

២.៨៥.៨.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាល ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលណាម្នាក់ ។

២.៨៥.៨.៨ ការយកសាកសពសត្វធាតុ ឬឧបករណ៍ណាមួយ ឬធ្វើសញ្ញាណាមួយ ទៅដាក់មុខផ្ទះជនណាម្នាក់ ឬក្រុមណាមួយ ដែលអាចធ្វើឱ្យជននោះ ឬក្រុមនោះមានការភ័យខ្លាច ដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូន គ្រួសាររបស់ខ្លួន ។

២.៨៥.៨.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬគ្រួសាររបស់ខ្លួន ។

២.៨៥.៨.១០ ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង ។

២.៨៥.៨.១១ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬការធ្វើឱ្យខូចប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។

២.៨៥.៨.១២ ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំឱ្យធ្វើសម្បថ ឬផ្តិតមេដៃសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។

២.៨៥.៨.១៣ ការប្រមូល ឬការដកហូត ឬបំផ្លាញឯកសារបញ្ជាក់អត្តសញ្ញាណ ដែលត្រូវប្រើសម្រាប់បោះឆ្នោត ។

២.៨៥.៨.១៤ ការដាក់កំហិតសិទ្ធិណាមួយចំពោះអ្នកបោះឆ្នោត ក្នុងការស្វែងរក ឬស្តាប់នូវព័ត៌មានអំពីគណបក្សនយោបាយនានា ។

**ប្រការ ២.៨៦** គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង ដែលប្រព្រឹត្តផ្ទុយនឹងចំណុចទាំងឡាយក្រោមប្រការ ២.៨៥ ខាងលើ នឹងត្រូវទទួលទោសតាមមាត្រា ៨៧ នៃ ច.ប.ក ។

**ប្រការ ២.៨៧** អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហារអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារ ក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចចែងក្នុងចំណុច ២.៨៧.១ ដល់ ២.៨៧.៣ ខាងក្រោម ។

២.៨៧.១ ផ្តួចផ្តើម ឬចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្តួចផ្តើម ឬការចូលរួមឃោសនារួមមាន ៖

២.៨៧.១.១ ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៧.១.២ ការចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៧.១.៣ ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឬបេក្ខជនណាមួយ ។

២.៨៧.១.៤ ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោត នៃគណបក្សនយោបាយណាមួយ ។

២.៨៧.២ ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលំអៀង រួមមាន ៖

២.៨៧.២.១ ការស្ទង់មតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៤៧.២.២ ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៤៧.២.៣ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យបន្តុះបង្អាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៤៧.២.៤ ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តផ្ទាល់ខ្លួន ឬរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៤៧.៣ ផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្តល់ឱ្យដូចចែងក្នុងចំណុចនេះ រួមមាន ៖

២.៤៧.៣.១ ការផ្តល់យានជំនិះគ្រប់ប្រភេទ ជាមធ្យោបាយបម្រើការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៤៧.៣.២ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៤៧.៣.៣ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ការដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៤៧.៤ បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងធ្វើការ ឬស្ថិតក្នុងច្បាប់ឈប់សម្រាក មន្ត្រី បុគ្គលិកជាតិនៃអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់បាន ។

២.៤៧.៥ ហាមជនបរទេស ដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើសកម្មភាពឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ។

**សម្ភារអប់រំអ្នកបោះឆ្នោត**

**ប្រការ ២.៨៨** នាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈនៃ គ.ជ.ប ត្រូវទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការបោះឆ្នោត ។

២.៨៨.១ គ.ជ.ប អំពាវនាវ និងលើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យចូលរួមយ៉ាងសកម្មក្នុងសកម្មភាពផ្សព្វផ្សាយ និងអប់រំ ដើម្បីលើកកំពស់ការយល់ដឹងអំពីការបោះឆ្នោតជូនសាធារណជន ។

២.៨៨.២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃការអប់រំអំពីការបោះឆ្នោត អាចទំនាក់ទំនងជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈនៃ គ.ជ.ប ។

២.៨៨.៣ សម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវមានលក្ខណៈអព្យាក្រឹត និងមិនលម្អៀង ។ សម្ភារទាំងនោះមិនត្រូវរៀបចំឡើងដើម្បីគាំទ្រ ឬបន្ទុះបង្អាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ហើយត្រូវគោរពទៅតាម ច.ប.ក ប.ន.ក និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។

២.៨៨.៤ សម្ភារព័ត៌មានសាធារណៈ និងសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយ គ.ជ.ប និងសម្ភារដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវបានរក្សាសិទ្ធិ ហើយមិនត្រូវបន្ថែម ឬបន្ថយខ្លឹមសារ ដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលបានសហការជាមួយ គ.ជ.ប ក្នុងការផលិតសម្ភារអប់រំអ្នកបោះឆ្នោត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងករណី មានការប្រព្រឹត្តខុសពីកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ ។

២.៨៨.៥ ដើម្បីធានាថា ខ្លឹមសារនៃសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ត្រឹមត្រូវតាមបច្ចេកទេស និងតាម ច.ប.ក និង ប.ន.ក គ.ជ.ប នឹងជួយផ្តល់សេវាកម្មពិនិត្យផ្ទៀងផ្ទាត់/យល់ព្រម និងណែនាំ ដល់អង្គការមិនមែនរដ្ឋាភិបាលអំពីលក្ខណៈបច្ចេកទេស និងបញ្ជាក់ពីភាពស្របច្បាប់នៃសម្ភារអប់រំនេះ ។

២.៤៨.៦ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត ពុំតម្រូវឱ្យមានសេវាកម្មពិនិត្យផ្ទៀងផ្ទាត់ ឬយល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ ។

២.៤៨.៧ ទោះបីជាសម្ភារអប់រំត្រូវបានទទួល ឬមិនត្រូវបានទទួលការយល់ព្រមពី គ.ជ.ប ក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយ ត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយនឹងមិនត្រូវបានដាក់បន្ទុកឱ្យទទួលខុសត្រូវចំពោះមុខច្បាប់បោះឆ្នោតលើខ្លឹមសារ បច្ចេកទេស នៃសម្ភារអប់រំទាំងនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ ។

២.៤៨.៨ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ដូចមានចែងក្នុងចំណុច ២.៤៩.៦ ខាងក្រោម មានភារកិច្ចក្នុងការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់/យល់ព្រម ក្នុងរយៈពេលចិតសិបពីរ (៧២) ម៉ោង បន្ទាប់ពីទទួលបានសំណើសុំឱ្យជួយពិនិត្យផ្ទៀងផ្ទាត់សម្ភារអប់រំនោះ ។ ក្នុងករណី ពិនិត្យឃើញថា សម្ភារ ឬខ្លឹមសារអប់រំត្រូវបានរៀបចំឡើងមិនសមស្របទៅតាម ច.ប.ក និង ប.ន.ក គណៈកម្មការនេះត្រូវបង្ហាញអំពីការខុសឆ្គង ដែលត្រូវកែតម្រូវ និងផ្តល់ព័ត៌មានទៅសាមីអ្នកស្នើសុំជាបន្ទាន់ តាមដែលអាចធ្វើបាន ។ ក្នុងករណី គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ធ្វើការពិនិត្យផ្ទៀងផ្ទាត់ ហួសរយៈពេលចិតសិបពីរ (៧២) ម៉ោង ដោយពុំបានផ្តល់ការឆ្លើយតបទេ ចាត់ទុកថាគណៈកម្មការនេះ បានឯកភាពទាំងស្រុងលើខ្លឹមសារ និងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន ។

២.៤៨.៩ សម្ភារអប់រំអ្នកបោះឆ្នោតដែលអាចត្រូវបានទទួលពិនិត្យ ផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពី គ.ជ.ប មានដូចជា ៖

២.៤៨.៩.១ ស្ប៉ុតវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ ។

២.៤៨.៩.២ កាសែតម៉ាញ៉េ ឬខ្សែអាត់សំឡេង ។

២.៤៨.៩.៣ ខិត្តប័ណ្ណផ្សេងៗ និងបដា ។

២.៤៨.៩.៤ សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត ។

២.៤៨.៩.៥ ការផ្សព្វផ្សាយ និងរូបភាពចុះលើទំព័រសារព័ត៌មាន ។

២.៤៨.៩.៦ រូបភាព ឬពាក្យស្លោកបោះពុម្ពលើសំលៀកបំពាក់ ឬ មួក ។

២.៤៨.១០ សម្ភារដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកនៅ គ.ជ.ប មួយមុខមួយ (១) ច្បាប់សម្រាប់ជាឯកសារ ។

២.៤៨.១១ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យផ្ទៀងផ្ទាត់ ណែនាំ និងយល់ព្រមដែលផ្តល់ឱ្យដោយ គ.ជ.ប ត្រូវទទួលខុសត្រូវលើខ្លឹមសារ បច្ចេកទេសនៃសម្ភារអប់រំរបស់ខ្លួន តាមបញ្ញត្តិនៃ ច.ប.ក ។ ប្រសិនបើព័ត៌មាននៅក្នុងសម្ភារអប់រំដែលខ្លួនបានផលិតនោះ ត្រូវបានរកឃើញថា ពុំត្រឹមត្រូវតាម ច.ប.ក និង ប.ន.ក ឬមានភាពលម្អៀង ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.ក និង ប.ន.ក ដូចចែងក្នុងចំណុច ២.៤៩.៩ ខាងក្រោម គ.ជ.ប ត្រូវឱ្យសាមីអង្គការធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូត សម្ភារនោះទាំងស្រុងតែម្តង ។

២.៤៨.១២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោត ដែលមានកម្មវិធីនយោបាយរបស់គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋាន មុនថ្ងៃចាប់ផ្តើមការឃោសនាបោះឆ្នោត និងអនុញ្ញាតឱ្យចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈបាន តែក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោតប៉ុណ្ណោះ ។

២.៤៨.១៣ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងរៀបចំឱ្យមានកម្មវិធីស្មើភាព សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលឃោសនាបោះឆ្នោត អាចពិគ្រោះកម្មវិធីលំអិត និងធ្វើសហប្រតិបត្តិការជាមួយ គ.ជ.ប ។ សកម្មភាពដែលត្រូវបានកំណត់ថាជាកម្មវិធីស្មើភាព មានដូចខាងក្រោម ៖

២.៤៨.១៣.១ កម្មវិធីមួយ ឬកម្មវិធីជាភាគ ដែលផ្តល់ឱកាសឱ្យគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនីមួយៗ ផ្សព្វផ្សាយកម្មវិធីនយោបាយ ឬទស្សនៈនយោបាយ ក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់ កិច្ចសម្ភាសន៍ ការពិភាក្សាសួរដេញដោល ការពិភាក្សាតុមូល វេទិកា ឬកម្មវិធីជជែកជាសាធារណៈ ដោយឈរលើមូលដ្ឋាននៃការផ្តល់ពេលវេលាស្មើភាពគ្នា ចំពោះអ្នកចូលរួមទាំងអស់ ។

២.៤៨.១៣.២ អនុលោមតាមមាត្រា ៤៦ នៃ ច.ប.ក ដើម្បីសម្របសម្រួល ឱ្យមានការប្រើប្រាស់ប្រព័ន្ធឃោសនា តាមគោលការណ៍ស្មើភាព និងដើម្បីបញ្ចៀសបាតុភាព ដូចចែងក្រោមចំណុច ២.៤៩.៩ ខាងក្រោម ការផ្សព្វផ្សាយកម្មវិធីស្មើភាពនេះ ត្រូវមានលិខិតយល់ព្រមពី គ.ជ.ប ។

២.៤៨.១៤ គ.ជ.ប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬដកហូតទាំងស្រុង នៃសម្ភារអប់រំអ្នកបោះឆ្នោតទាំងឡាយណា ដែលមិនគោរពទៅតាមចំណុច ២.៤៨.៣ ២.៤៨.១២ និងចំណុច ២.៤៩.៩ ។ សាមីអង្គការត្រូវធ្វើការកែតម្រូវតាមការណែនាំរបស់ គ.ជ.ប ជាចាំបាច់ ។ ក្នុងករណី កំហុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ សាមីអង្គការត្រូវទទួលទោសតាមមាត្រា ១២៤ថ្មី នៃ ច.ប.ត.រ ។

២.៤៨.១៥ គ.ជ.ប មានសិទ្ធិបញ្ជាឱ្យផ្អាក ឬបញ្ឈប់ការផ្សព្វផ្សាយទាំងស្រុង ចំពោះកម្មវិធីស្មើភាពទាំងឡាយណាដែលមិនគោរពទៅតាមលក្ខខណ្ឌ ដូចមានចែងក្នុងចំណុច ២.៤៨.៣ ២.៤៨.១២ និងចំណុច ២.៤៩.៩ ។

២.៤៨.១៦ ក្នុងករណី គណបក្សនយោបាយណាមួយបដិសេធការចូលរួមក្នុងកម្មវិធី ដែលរៀបចំឡើងដោយអង្គការ ដូចចែងក្នុងចំណុច ២.៤៨.១៣ ឬមិនបានផ្ញើឯកសារដើម្បីផ្សព្វផ្សាយក្នុងកម្មវិធីនោះ សាមីអង្គការពាក់ព័ន្ធអាចអនុវត្តកម្មវិធីរបស់ខ្លួនបាន ដោយមិនប៉ះពាល់ដល់គោលការណ៍ស្មើភាព ។

**រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ**

**ប្រការ២.៤៩** យោងតាមប្រការ ២.៧៧ នៃ ប.ន.ក នេះ គណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោត និងអ្នកគាំទ្រទាំងឡាយអាចប្រើប្រាស់រូបភាព ឬសម្ភារឃោសនាផ្សព្វផ្សាយ បានដូចជា ៖

២.៤៩.១ ខិត្តប័ណ្ណឃោសនាបោះឆ្នោត ។

២.៤៩.២ សារព័ត៌មាន (ការផ្សព្វផ្សាយ គំនូរជីវចល ការជូនព័ត៌មាន សេចក្តីថ្លែងការណ៍ សារនយោបាយ រូបសញ្ញា) ។

២.៤៩.៣ ការឃោសនាតាមវិទ្យុ ទូរទស្សន៍ ឬតាមឧបករណ៍សនស័ព្ទ ឬឧបករណ៍បញ្ចាំងរូបភាព ដែលរួមមាន ៖

២.៤៩.៣.១ អត្ថបទឃោសនា ។

២.៤៩.៣.២ បទភ្លេង និងចម្រៀងជាពាក្យស្លោកខ្លីៗ ។

២.៤៩.៣.៣ ការសូត្រពាក្យកំណាព្យ ។

២.៤៩.៣.៤ ការប្រគំតន្ត្រី ។

២.៤៩.៣.៥ កិច្ចសម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយការចាក់ផ្សាយ ។

២.៤៩.៣.៦ ការសម្តែងសិល្បៈ ។

២.៤៩.៣.៧ ការចាក់កាសែ្សតវីដេអូជាសាធារណៈ ។

២.៤៩.៤ ក្រៅពីរូបភាព នៃសម្ភារឃោសនាបោះឆ្នោត ដូចបានបញ្ជាក់ខាងលើ ការឃោសនាផ្សព្វផ្សាយអាចប្រើប្រាស់រូបភាពផ្សេងៗទៀតបាន ដូចជា ៖

២.៤៩.៤.១ ការសម្តែងរឿងល្ខោនខ្លីៗ ឬ/និងសិល្បៈ ឬការបញ្ចាំងខ្សែភាពយន្ត ឬ/និងវីដេអូ ។

២.៤៩.៤.២ ការបង្ហោះប៉េងប៉ោង ឬ/និងខ្លែង ។

២.៤៩.៤.៣ ការបោះពុម្ពជារូបភាព សម្រាប់បិទផ្សាយលើសំលៀកបំពាក់ មួក ស្លាកសញ្ញា ពាក្យស្លោក ឬរូបភាពបិទតាមរថយន្ត ស្លាកសញ្ញាលោហៈខ្វាស់ បដា ។ល។

២.៤៩.៤.៤ ការស្រែកឃោសនា តាមទីសាធារណៈ ។

២.៤៩.៥ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

២.៤៩.៥.១ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវបានអនុញ្ញាតឱ្យចំណាយទៅលើការជួលផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ និងការបោះពុម្ពផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយឯកជន នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

២.៤៩.៥.២ ប្រព័ន្ធផ្សព្វផ្សាយឯកជន ដែលមានបំណងទទួលយកការជួលផ្សាយរបស់គណបក្សនយោបាយ ត្រូវវែលែកទុកពេលវេលា និងម៉ោងផ្សាយ ដើម្បីផ្តល់ជូនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំងអស់ជួលផ្សព្វផ្សាយដូចគ្នា ដោយឈរលើមូលដ្ឋានឱកាស និងតម្លៃស្មើភាពគ្នា ។

២.៤៩.៥.៣ ប្រព័ន្ធផ្សព្វផ្សាយឯកជនអាចមិនចុះផ្សាយ ឬមិនផ្សព្វផ្សាយការជួលផ្សព្វផ្សាយរបស់គណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។ ប្រសិនបើប្រព័ន្ធផ្សព្វផ្សាយឯកជនណាមួយ សម្រេចមិនចុះផ្សាយ ឬមិនផ្សព្វផ្សាយការជួលផ្សព្វផ្សាយរបស់គណបក្សណាមួយ ប្រព័ន្ធផ្សព្វផ្សាយនោះត្រូវបដិសេធការជួលផ្សព្វផ្សាយ និងចុះផ្សាយរបស់គណបក្សនយោបាយទាំងអស់ ។

២.៤៩.៦ គ.ជ.ប ត្រូវបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ដើម្បីរៀបចំ និងដឹកនាំកម្មវិធីស្មើភាព ត្រួតពិនិត្យស្ប៉ត និងអត្ថបទឃោសនារបស់គណបក្សនយោបាយដែលបញ្ជូនមក គ.ជ.ប ត្រួតពិនិត្យសម្ភារអប់រំអ្នកបោះឆ្នោតដែលស្នើសុំលិខិតយល់ព្រមពី គ.ជ.ប និងសម្ភារឃោសនារបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានបណ្តឹងពីគណបក្សនយោបាយ បេក្ខជន ឬតំណាង តាមការណែនាំរបស់ គ.ជ.ប ។

២.៤៩.៦.១ សមាសភាពគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព មានដូចខាងក្រោម ៖

១. អគ្គលេខាធិការរង នៃ គ.ជ.ប មួយរូប ជាប្រធាន
២. ជំនួយការ គ.ជ.ប មួយរូប ជាអនុប្រធាន
៣. ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ ជាសមាជិក
៤. ប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ជាសមាជិក
៥. អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ ទទួលបន្ទុកព័ត៌មានសាធារណៈ ជាសមាជិក
៦. ជំនួយការនាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ ជាសមាជិក។

២.៤៩.៦.២ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវរៀបចំចាត់ចែងឱ្យមានកិច្ចប្រជុំជាមួយគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដើម្បីពិភាក្សា កំណត់អំពីការរៀបចំកម្មវិធីស្មើភាព ហើយត្រូវមានបទបញ្ជាមួយដោយឡែកទៀត ដែលអនុម័តដោយ គ.ជ.ប ។

២.៤៩.៦.៣ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវអនុវត្តតាមគោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាពរបស់ គ.ជ.ប ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ។

២.៨៩.៦.៤ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវជួបប្រជុំជាមួយអ្នកគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងរដ្ឋ និងឯកជន ដើម្បីពិភាក្សារករិធានការផ្សេងៗ ក្នុងការអនុវត្តមាត្រា ៨៦ នៃ ច.ប.ក ។

២.៨៩.៦.៥ គណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព ត្រូវជួបប្រជុំពិភាក្សាជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ និងឯកជន ដើម្បីពន្យល់ណែនាំអំពី ប.ន.ក ក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ និងគោលការណ៍ណែនាំផ្សេងៗ របស់ គ.ជ.ប ។

២.៨៩.៦.៦ កម្មវិធីផ្សព្វផ្សាយ ដែលត្រូវអនុវត្តតាមគោលការណ៍ស្មើភាព មានដូចខាងក្រោម ៖

- ការចាក់ផ្សាយស្ប៉តរបស់គណបក្សនយោបាយ តាមរយៈវិទ្យុ និងទូរទស្សន៍របស់រដ្ឋ ។
- ការចាក់ផ្សាយកិច្ចពិភាក្សាតុមូល សម្រាប់គណបក្សនយោបាយ តាមរយៈវិទ្យុ និងទូរទស្សន៍របស់រដ្ឋ ។
- ការចុះផ្សាយអត្ថបទឃោសនា អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមទាំងស្រុងរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត លើព្រឹត្តិប័ត្ររបស់ គ.ជ.ប ។

២.៨៩.៦.៧ សម្ភារផ្សព្វផ្សាយដូចខាងក្រោម នឹងត្រូវបានត្រួតពិនិត្យអំពីភាពត្រឹមត្រូវតាមលក្ខខណ្ឌដូចចែងក្រោមចំណុច ២.៨៩.៩ ដោយគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព មុននឹងធ្វើការផ្សព្វផ្សាយ ៖

- សម្ភារផ្សព្វផ្សាយផលិតដោយ គ.ជ.ប ។
- សម្ភារផ្សព្វផ្សាយផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលសហការជាមួយ គ.ជ.ប ។
- សម្ភារឃោសនារបស់គណបក្សនយោបាយ ក្នុងកម្មវិធីស្មើភាព ។

២.៨៩.៦.៨ សម្ភារឃោសនារបស់គណបក្សនយោបាយដែលមិនពាក់ព័ន្ធនឹងកម្មវិធីស្មើភាព មិនត្រូវបានត្រួតពិនិត្យដោយ គ.ជ.ប ទេ ។ តែសម្ភារឃោសនាទាំងនេះត្រូវគោរពតាមលក្ខខណ្ឌ ដូចកំណត់ក្នុងចំណុច ២.៨៩.៩ ។

២.៨៩.៧ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត គ.ជ.ប ត្រូវស្នើសុំឱ្យនាយកនៃសារព័ត៌មាន វិទ្យុ និងទូរទស្សន៍ ផ្ដល់នូវកម្មវិធីផ្សព្វផ្សាយប្រចាំសប្ដាហ៍ ឬប្រចាំខែ និងតារាងតម្លៃផ្សព្វផ្សាយមក គ.ជ.ប ។

២.៨៩.៨ គ្រប់សម្ភារឯកសារឃោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយ ដោយបេក្ខជន ឬ/និងគណបក្សនយោបាយ ត្រូវតែមានដាក់សញ្ញាសំគាល់ ឈ្មោះ ឬ/និងអាសយដ្ឋានរបស់សាមីគណបក្សនយោបាយនោះ ។

២.៨៩.៩ សម្ភារអប់រំអ្នកបោះឆ្នោត និងសម្ភារឃោសនាដែលត្រូវបានផ្សព្វផ្សាយជាទម្រង់អត្ថបទបោះពុម្ព ឬផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ មិនត្រូវប្រើប្រាស់រូបភាព ឬភាសាណាមួយ ដែលមានន័យ ៖

២.៨៩.៩.១ ញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬធ្វើឱ្យបាត់បង់ជំនឿលើភាពសំងាត់នៃការបោះឆ្នោត ។

២.៨៩.៩.២ មាក់ងាយ បំភិតបំភ័យ ប្រមាថ ឬអសីលធម៌ ។

២.៨៩.៩.៣ សាបព្រោះភាពភ័យខ្លាច ធ្វើឱ្យភាន់ច្រឡំ និងខូចសណ្ដាប់ធ្នាប់សង្គម ។

២.៨៩.៩.៤ ផ្ដល់ព័ត៌មានមិនត្រឹមត្រូវអំពីការបោះឆ្នោត ។

២.៨៩.១០ ការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត និងសម្ភារឃោសនា ដែលត្រូវបានរកឃើញថា រំលោភបញ្ញត្តិខាងលើ គ.ជ.ប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារខុសច្បាប់ទាំងនោះ ។

២.៨៩.១១ គណបក្សនយោបាយត្រូវទទួលខុសត្រូវចំពោះសម្ភារអប់រំ និងសម្ភារឃោសនាដែលខ្លួនផ្សព្វផ្សាយ និងត្រូវទទួលទោសតាមមាត្រា ៨៧ នៃ ច.ប.ក ប្រសិនបើសម្ភារទាំងនោះរំលោភលើលក្ខខណ្ឌ ដូចចែងក្នុងចំណុច ២.៨៩.៩ ខាងលើ ។

២.៨៩.១២ ហាមធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតា និងរូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ ដើម្បីរកសំឡេងឆ្នោត ។

២.៨៩.១៣ ហាមលើកបដាឃោសនា ស្លាកសញ្ញាគណបក្ស និងរូបសញ្ញាណាមួយ ដែលបង្ហាញពីការគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់កាត់ទទឹងផ្លូវសាធារណៈ ។

**ប្រការ២.៩០** អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីសាធារណៈ ឬសាលសាធារណៈ ត្រូវផ្ដល់ទីកន្លែងរបស់ខ្លួនដល់គណបក្សនយោបាយ ឬ/និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់ជាកន្លែងឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ គណបក្សនយោបាយ ឬ/និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលមានបំណងជួលទីតាំង ដូចបញ្ជាក់ក្នុងប្រការនេះ អាចដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ក្នុងរយៈពេលយ៉ាងតិចបី (៣) ថ្ងៃ មុនថ្ងៃប្រជុំឃោសនាបោះឆ្នោតរបស់ខ្លួន ។ អ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ត្រូវឆ្លើយតបទៅនឹងការស្នើសុំរបស់គណបក្សនយោបាយមិនឱ្យលើសពីម្ភៃបួន (២៤) ម៉ោង ក្រោយពីបានទទួលពាក្យស្នើសុំ ។

២.៩០.១ គណបក្សនយោបាយ ឬ/និងបេក្ខជន ត្រូវតែជូនដំណឹង ដោយចម្លងពាក្យសុំមួយច្បាប់ទៅ គឃ/ខប យ៉ាងហោចណាស់បី (៣) ថ្ងៃ មុនថ្ងៃធ្វើសកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន ។ សកម្មភាពឃោសនាបោះឆ្នោត រួមមាន ៖

២.៩០.១.១ ការដង្ហែក្បួនដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ។

២.៩០.១.២ ការជួបប្រជុំជាសាធារណៈ ។

២.៩០.១.៣ ការប្រគុំតន្ត្រី ការលេងភ្លេង ឬការរាំកំសាន្ត ។

២.៩០.១.៤ ការសម្ដែងរឿងល្ខោនខ្មែរ ឬការសម្ដែងសិល្បៈ ឬការបញ្ចាំងខ្សែភាពយន្ត ឬវីដេអូ ។

២.៩០.១.៥ ក្បួនព្យុហយាត្រា ។

២.៩០.១.៦ សកម្មភាពកីឡា ដើម្បីប្រមូលប្រាក់គាំទ្រគណបក្សនយោបាយណាមួយ និង/ឬបេក្ខជនណាម្នាក់ ។

២.៩០.២ បន្ទាប់ពីបានទទួលនូវសេចក្ដីជូនដំណឹង ដូចមានចែងក្នុងចំណុច ២.៩០.១ គឃ/ខប ត្រូវចាត់វិធានការសម្របសម្រួល ដើម្បីរក្សា ការពារសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់ជូនគណបក្សនយោបាយ ឬ/និងបេក្ខជន ដើម្បីធ្វើការឃោសនា ។

២.៩០.៣ គឃ/ខប ត្រូវមានសៀវភៅសម្រាប់ចុះលេខ និងខ្លឹមសារលិខិតស្នើសុំធ្វើការឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន ដើម្បីឱ្យបានដឹងពីលំដាប់លេខរៀងមុន ក្រោយរបស់គណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលត្រូវធ្វើសកម្មភាពឃោសនារបស់ខ្លួន ។

២.៩០.៤ គឆ/ខប ត្រូវធ្វើកាលវិភាគប្រចាំសប្តាហ៍ ស្តីពីកាលកំណត់តាមលំដាប់លេខរៀងមុន ក្រោយនៃការស្នើសុំប្រើប្រាស់ទីសាធារណៈ និងទីកន្លែងឯកជន រួចបិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គឆ/ខប មួយច្បាប់ និងនៅទីកន្លែងដែលត្រូវធ្វើការឃោសនា មួយច្បាប់ ។

២.៩០.៥ គឆ/ខប ត្រូវសម្របសម្រួល និងរៀបចំតាមលំដាប់នៃការជូនដំណឹងស្តីពីការធ្វើការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ និងមានវិធានការទប់ស្កាត់ និងដោះស្រាយចំពោះការឃោសនាទាំងឡាយណា ដែលប្រព្រឹត្តផ្ទុយនឹង ច.ប.ក ប.ន.ក និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ។

**ប្រការ២.៩១** គណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត អាចធ្វើសកម្មភាពឃោសនានៅលើទីកន្លែងឯកជន ឬនៅសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឆ/ខប យ៉ាងតិចបី (៣) ថ្ងៃ មុនថ្ងៃធ្វើសកម្មភាពឃោសនា ។

**ប្រការ២.៩២** គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជន ត្រូវរក្សានូវសណ្តាប់ធ្នាប់ល្អ និងសេចក្តីថ្លៃថ្នូរ ។

**ប្រការ២.៩៣** គណបក្សនយោបាយ ឬ/និងបេក្ខជន ឬ/និងអ្នកគាំទ្រទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរំខាន ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជន ឬ/និងអ្នកគាំទ្រផ្សេងទៀតឡើយ ។ សកម្មភាពដែលមានន័យជ្រៀតជ្រែក ឬ/និងធ្វើឱ្យរំខាន ឬរាំងស្ទះនោះ រួមមាន ៖

២.៩៣.១ ការនិយាយដៀមដាម ប្រមាថមើលងាយ ។

២.៩៣.២ ការធ្វើទុក្ខទោសដល់រាងកាយ ។

២.៩៣.៣ ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់ ។

២.៩៣.៤ ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សកំពុងធ្វើការឃោសនា ឬកន្លែងប្រជុំ ឬបង្ហើរលើក្បាល ឬលើដំបូលផ្ទះ ឬលើយានជំនិះ អ្នកណាម្នាក់ ។

២.៩៣.៥ ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ថយបង្អាក់មិនឱ្យក្បួនដង្ហែការឃោសនាទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនា របស់គណបក្សនយោបាយផ្សេងទៀត ។

២.៩៣.៦ ការប្រើគ្រឿងផ្ទុះ ដើម្បីរំខានដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន ។

២.៩៣.៧ ការប្រើឧបករណ៍បំពងសំឡេងដើម្បីរំខានដល់ទីកន្លែង ដែលគណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការឃោសនា ឬការជួបប្រជុំ ។

២.៩៣.៨ ការទម្លាក់ស្លាក ឬបំផ្លាញបដាគណបក្ស ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជន ។

២.៩៣.៩ ការហាមឃាត់ ឬរារាំងប្រជាពលរដ្ឋចូលរួមក្នុងកិច្ចប្រជុំ ឬក្បួនដង្ហែរបស់គណបក្សនយោបាយណាមួយ ។

**ប្រការ២.៩៤** បេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបានការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

២.៩៤.១ កងយោធពលខេមរភូមិន្ទ នគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវក្នុងការរក្សាបរិយាកាសសុវត្ថិភាពសម្រាប់ការបោះឆ្នោត ។

២.៩៤.២ កងយោធពលខេមរភូមិន្ទ នគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវដោយធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

២.៩៤.៣ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ដែលមានភារកិច្ចការពារ មិនត្រូវឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំពីសាមីបេក្ខជន ឬ/និងគណបក្សនយោបាយ ដែលធ្វើការឃោសនានោះ ។

២.៩៤.៤ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត គធ/ខប ត្រូវតាមដានជាប្រចាំអំពីស្ថានភាពសន្តិសុខ និងសុវត្ថិភាពក្នុងរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងត្រូវជូនព័ត៌មានទៅ គ.ជ.ប ជារៀងរាល់ថ្ងៃ ។

**ប្រការ ២.៩៥** គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនីដើម្បីកត់ត្រាប្រាក់ចំណូល ប្រភពនៃប្រាក់ចំណូល និងចំណាយសម្រាប់ការឃោសនាបោះឆ្នោត ។

២.៩៥.១ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចត្រួតពិនិត្យសៀវភៅគណនីនេះ នៅពេលមានការចាំបាច់ ។

២.៩៥.២ វិភាគទានទាំងអស់ដែលគណបក្សនយោបាយទទួលបាន ត្រូវបញ្ចូលក្នុងគណនីនៃធនាគារ ហើយរាល់ចំណាយទៅលើការឃោសនាត្រូវតែចេញពីគណនីតែមួយនេះ ។

**ភារកិច្ច និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន**

**ប្រការ ២.៩៦** ផ្អែកតាមសារៈសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានជូនដល់អ្នកបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងរដ្ឋ ទាំងឯកជន ត្រូវបំពេញតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

២.៩៦.១ កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយដោយឥតគិតថ្លៃ នូវរាល់ព័ត៌មានពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការអប់រំអ្នកបោះឆ្នោត ដែលស្នើឡើងដោយ គ.ជ.ប ។ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការ និងការគាំទ្រពីក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោត ។

២.៩៦.២ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ត្រូវបានលើកទឹកចិត្តឱ្យផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ។

**ប្រការ២.៩៧** អ្នកបោះឆ្នោតមានសិទ្ធិធ្វើការជ្រើសរើសទៅតាមព័ត៌មានដែលខ្លួនទទួលបាន ។ សិទ្ធិនេះតម្រូវឱ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងរដ្ឋ និងឯកជនមានកាតព្វកិច្ចអនុវត្ត តាមគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដូចមានចែងក្នុងឧបសម្ព័ន្ធ ដើម្បីឱ្យការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

**ប្រការ ២.៩៨** គ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ទាំងរដ្ឋ និងឯកជនត្រូវគោរពក្រមសីលធម៌ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងអំឡុងពេលបោះឆ្នោត ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ស្តីពីគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ។ ប្រព័ន្ធផ្សព្វផ្សាយដែលមិនគោរពតាម ច.ប.ក និង ប.ន.ក ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

**ប្រការ ២.៩៩** រាល់បណ្តឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ត្រូវអនុវត្តតាមជំពូកទី ៤ នៃ ប.ន.ក នេះ ។

## ផ្នែកទី ៧

## ការបោះឆ្នោត

**ប្រការ ២.១០០** អនុវត្តតាមមាត្រា ៣៨ នៃ ច.ប.ក នៅក្រោយបញ្ចប់ការចុះឈ្មោះបោះឆ្នោត និងបន្ទាប់ពីបានកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប នូវចំនួននិងទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត គ.ជ.ប ត្រូវណែនាំ គធ/ខប ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅតាមសាលាឃុំ សង្កាត់ និងនៅទីកន្លែងសាធារណៈណាមួយនៅក្នុងមណ្ឌលបោះឆ្នោត យ៉ាងតិចសាមសិប (៣០) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.១០០.១ នាយកដ្ឋានប្រតិបត្តិការត្រូវបោះពុម្ព និងបញ្ជូនបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំនួនបី (៣) ច្បាប់ ទៅ គធ/ខប សម្រាប់ ៖

២.១០០.១.១ បិទផ្សាយមួយ (១) ច្បាប់ នៅតាមសាលាឃុំ សង្កាត់ ។

២.១០០.១.២ បិទផ្សាយមួយ (១) ច្បាប់ នៅទីកន្លែងសាធារណៈណាមួយនៅក្នុងមណ្ឌលបោះឆ្នោត ។

២.១០០.១.៣ រក្សាមួយ (១) ច្បាប់ នៅលេខាធិការដ្ឋាន គធ/ខប ដើម្បីទុកជាឯកសារ និងបំរើការផ្សព្វផ្សាយជាសាធារណៈ ។

២.១០០.២ នាយកដ្ឋានប្រតិបត្តិការត្រូវផ្តល់បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ជូននាយកដ្ឋានរដ្ឋបាលមួយ (១) ច្បាប់ ដើម្បីរៀបចំបែបបទសម្រាប់ការជ្រើសរើសសមាសភាព គកប ដែលត្រូវបំរើការងារបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

### សម្ភារឯកសារបោះឆ្នោតដែល គ.ជ.ប ត្រូវផ្គត់ផ្គង់ និងការត្រួតពិនិត្យរបស់ គកប លើសម្ភារឯកសារបោះឆ្នោតដែលបានទទួល និងទីតាំងការិយាល័យបោះឆ្នោត

**ប្រការ ២.១០១** គ.ជ.ប ត្រូវទទួលខុសត្រូវក្នុងការផ្គត់ផ្គង់សម្ភារបរិក្ខារ និងឯកសារគ្រប់គ្រាន់ សម្រាប់បំរើការបណ្តុះបណ្តាល និងកិច្ចប្រតិបត្តិការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ។ គ.ជ.ប ត្រូវធានាថា ហិបបរិក្ខារបោះឆ្នោតត្រូវបានបញ្ជូនទៅដល់ គកប ទាន់ពេលវេលា ។ ដើម្បីធានាប្រសិទ្ធភាពការងារ ប្រធាន គកប ត្រូវកោះប្រជុំសមាជិកទាំងអស់នៃ គកប ឱ្យមកជួបជុំគ្នា នៅពេលព្រឹកថ្ងៃសៅរ៍ មួយ (១) ថ្ងៃមុនថ្ងៃបោះឆ្នោត ដើម្បីត្រួតពិនិត្យវត្តមានសមាសភាព គកប ពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារ ឯកសារបោះឆ្នោតដែលបានទទួល ។

២.១០១.១ នាយកដ្ឋានប្រតិបត្តិការត្រូវផ្គត់ផ្គង់ និងបញ្ជូនសម្ភារបរិក្ខារនិងឯកសារ សម្រាប់បំរើការបណ្ដុះបណ្ដាល និងសម្រាប់ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ឱ្យបានគ្រប់គ្រាន់ និងដល់គោលដៅ គធ/ខប និង គកប នីមួយៗ ។

២.១០១.២ នាយកដ្ឋានប្រតិបត្តិការត្រូវទទួលខុសត្រូវក្នុងការបោះពុម្ព វេចខ្ចប់ និងដឹកជញ្ជូនបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗចំនួនបី (៣) ច្បាប់ ដែលត្រូវបែងចែកជូន គធ/ខប និង គកប ពាក់ព័ន្ធទាំងអស់ សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១០១.២.១ បញ្ជីបោះឆ្នោតផ្លូវការ ត្រូវតែបានវេចខ្ចប់ដោយឡែកពីគ្នាតាមមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌនីមួយៗ ដោយរៀបចំតាមលំដាប់លេខកូដ នៃការិយាល័យបោះឆ្នោត ដែលមានទីតាំងនៅទីប្រជុំជនក្រុង ស្រុក ខណ្ឌ និងត្រៀមសម្រាប់បែងចែកជាស្រេចឱ្យដល់ គធ/ខប ចំនួនមួយ (១) ច្បាប់ និង គកប ចំនួនពីរ (២) ច្បាប់ ។

២.១០១.២.២ រាល់កញ្ចប់បញ្ជីបោះឆ្នោតផ្លូវការដែលវេចខ្ចប់ និងបញ្ជូន ខាងលើនេះ ត្រូវតែមានសរសេរសម្គាល់ឈ្មោះរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលេខកូដការិយាល័យបោះឆ្នោត ព្រមទាំងគោលដៅដែលត្រូវទទួល និងប្រើបញ្ជីបោះឆ្នោតទាំងនោះផង ។

២.១០១.២.៣ នាយកដ្ឋានប្រតិបត្តិការ អាចផលិតស៊ីឌីមានផ្ទុកបញ្ជីបោះឆ្នោតផ្លូវការ នៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្ត ដោយឡែកពីគ្នា ជាបន្ថែម សម្រាប់ផ្ដល់ជូន គធ/ខប ពាក់ព័ន្ធ ប្រសិនបើចាំបាច់ ។

២.១០១.៣ គ.ជ.ប ត្រូវធានាថា គធ/ខប បានចាត់ចែង និងណែនាំ គកប ឱ្យប្រើប្រាស់បញ្ជីបោះឆ្នោត ដូចចែងក្រោមចំណុច ២.១០១.២ ខាងលើ ដូចខាងក្រោម ៖

២.១០១.៣.១ រក្សាមួយ (១) ច្បាប់ នៅលេខាធិការដ្ឋាននៃ គធ/ខប ដើម្បីទុកជាឯកសារ និងបម្រើសាធារណជន ។

២.១០១.៣.២ ចាត់ គកប ឱ្យបិទផ្សាយនៅមុខទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗមួយ (១) ច្បាប់ មួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.១០១.៣.៣ ណែនាំ គកប ឱ្យរក្សាទុកមួយ (១) ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត នៅការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត ។

២.១០១.៤ នាយកដ្ឋានប្រតិបត្តិការត្រូវរៀបចំផែនការ និងត្រៀមសម្ភារបរិក្ខារសម្រាប់បំរើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឱ្យបានគ្រប់គ្រាន់ជាមុន ។ សម្ភារបរិក្ខារសម្រាប់បំរើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ត្រូវបានរៀបចំដាក់ក្នុងហិបបរិក្ខារដែលរួមមានបី (៣) ប្រភេទ ។ នៅរាល់ពេលនៃការបញ្ជូន និងប្រគល់ទទួលហិបបរិក្ខារបោះឆ្នោត មន្ត្រីទទួលបន្ទុកការបញ្ជូននៅតាមលំដាប់ថ្នាក់នីមួយៗ ត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) និងត្រូវឱ្យមន្ត្រីទទួលបន្ទុកការទទួល នៅតាមថ្នាក់នីមួយៗ ចុះហត្ថលេខាបញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ ។ ហិបបរិក្ខារទាំងបី (៣) ប្រភេទរួមមាន ៖

២.១០១.៤.១ ហិបបរិក្ខារសម្រាប់បណ្ដុះបណ្ដាល ដែលត្រូវប្រគល់ជូននាយកដ្ឋានបណ្ដុះបណ្ដាល និងព័ត៌មានសាធារណៈ ។

២.១០១.៤.២ ហិបបរិក្ខារ គធ/ខប ដែលត្រូវប្រគល់ជូន គធ/ខប នីមួយៗ ។

២.១០១.៤.៣ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ចំនួនមួយ (១) សម្រាប់ គកប នីមួយៗ ។

២.១០១.៥ ហិបបរិក្ខារ គធ/ខប ដែលត្រូវប្រគល់ជូន គធ/ខប សម្រាប់ប្រើប្រាស់ ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូលរួមមាន សម្ភារ ឯកសារ ដូចកំណត់ក្នុងតារាងឧបសម្ព័ន្ធទី ៧ ។

២.១០១.៦ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឧបករណ៍ និងឯកសារ ផ្សេងទៀត ដូចមានក្នុងឧបសម្ព័ន្ធទី ៨ ដែល គធ/ខប ត្រូវប្រគល់ជូន គកប នីមួយៗ មិនត្រូវឱ្យលើសពីសាមសិបប្រាំមួយ (៣៦) ម៉ោងមុនថ្ងៃបោះឆ្នោត ។

២.១០១.៦.១ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវធានាក្នុងការបញ្ជូន និងប្រគល់ឱ្យបានគ្រប់គ្រាន់ជូន គកប នៅមួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោត នូវសម្ភារ ឯកសារបោះឆ្នោត ដូចចែងក្រោមចំណុច ២.១០១.៦ ។

២.១០១.៦.២ គធ/ខប ត្រូវជូនដំណឹងដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីចូលរួមសង្កេតមើលជាមួយ គកប នៅពេលធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារបោះឆ្នោត ដូចចែងក្នុងចំណុច ២.១០១.៨ ។

២.១០១.៦.៣ ទម្រង់បែបបទ ដែលប្រើសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងដោយក្រដាសពណ៌ ។

២.១០១.៦.៤ ទម្រង់បែបបទ ដែលប្រើសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបានរៀបចំឡើងដោយក្រដាសស ។

២.១០១.៧ សមាជិកគ្រប់រូបនៃ គកប ត្រូវតែមកបង្ហាញខ្លួននៅការិយាល័យបោះឆ្នោតតាមការអញ្ជើញរបស់ប្រធាន គកប និងត្រូវធានាថានឹងមានវត្តមានក្នុងការបំពេញការងារនៅថ្ងៃបោះឆ្នោត ។

២.១០១.៧.១ ប្រសិនបើមានសមាសភាពណាម្នាក់នៃ គកប មិនអាចមកបំពេញការងារបានក្នុងថ្ងៃបោះឆ្នោត ប្រធានត្រូវតែជូនដំណឹងដល់ គធ/ខប ជាបន្ទាន់ ដើម្បីដាក់អ្នកជំនួស ។

២.១០១.៧.២ ប្រសិនបើ គធ/ខប មិនអាចទទួលដំណឹងអំពីការដាក់អ្នកជំនួសបានទាន់ពេលវេលា ដោយសារតែចម្ងាយផ្លូវ ឬដោយសារតែកង្វះខាតមធ្យោបាយធ្វើដំណើរ ប្រធាន គកប ត្រូវធ្វើការជ្រើសរើសមនុស្សម្នាក់ ដែលមានលក្ខណៈវិនិច្ឆ័យស្រមតាមប្រការ ២.១៤ នៃ ប.ន.ក នេះ ឱ្យធ្វើការជំនួសតំណែងសមាសភាព គកប ដែលអវត្តមាន ។

២.១០១.៧.៣ ប្រសិនបើប្រធាន គកប មិនអាចមកបំពេញការងារបាន ដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធានត្រូវចូលកាន់តំណែងប្រធាន ជំនួយការត្រូវចូលកាន់តំណែងអនុប្រធាន ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មី ត្រូវជំនួសតំណែងជំនួយការ ។

២.១០១.៧.៤ ប្រសិនបើ អនុប្រធានមិនអាចមកធ្វើការបាននោះ ប្រធាន គកប ត្រូវតែងតាំងជំនួយការជាអនុប្រធាន ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងត្រូវចូលកាន់តំណែងជំនួយការ ។

២.១០១.៧.៥ ប្រសិនបើ លេខាធិការមិនអាចមកធ្វើការបាននោះ ប្រធាន គកប ត្រូវតែងតាំងជំនួយការ ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងចូលកាន់តំណែងជំនួយការ ។

២.១០១.៧.៦ មុនថ្ងៃបោះឆ្នោតមួយ (១) ថ្ងៃ សមាសភាពទាំងអស់នៃ គកប ត្រូវសិក្សានីតិវិធីឡើងវិញ រួមជាមួយសមាជិកដែលទើបតែជ្រើសរើសថ្មី ដោយផ្អែកលើសៀវភៅណែនាំ គកប ។

២.១០១.៧.៧ សមាជិកតែងតាំងថ្មីទាំងអស់ ត្រូវតែបានទទួលការសិក្សារួមគ្នា ដូចដែលបានចែងក្នុងចំណុច ២.១០១.៧.៦ ។

២.១០១.៧.៨ ប្រធាន គកប ត្រូវជូនដំណឹងជាបន្ទាន់ដល់ គធ/ខប អំពីអ្វីដែលបានអនុវត្ត ពាក់ព័ន្ធនឹងការដាក់ជំនួសតំណែងសមាសភាពណាម្នាក់នៃ គកប ។

២.១០១.៨ បន្ទាប់ពីអនុវត្តចំណុច ២.១០១.៧ រួច គកប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារឯកសារបោះឆ្នោតដែល គធ/ខប បានផ្តល់ជូន ហើយដែលមានរាយមុខក្នុងលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) ។ ក្នុងនោះ គកប ត្រូវ ៖

២.១០១.៨.១ ត្រូវត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោត ដោយផ្អែកលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១១២) ។

២.១០១.៨.២ ប្រសិនបើសម្ភារបោះឆ្នោតដែលបានទទួល ត្រឹមត្រូវគ្រប់ចំនួនហើយ ត្រូវចុះហត្ថលេខាលើតារាងត្រួតពិនិត្យសម្ភារឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១១២) នោះ និងរក្សាទុកឱ្យបានហ្មត់ចត់ ។

២.១០១.៨.៣ ប្រសិនបើសម្ភារ ឯកសារណាមួយ ឬមួយចំនួន ដែលបានទទួល មិនគ្រប់តាមចំនួនកំណត់ លេខាធិការត្រូវបំពេញត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតណាដែលបាត់បង់នៅលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១១២) និងត្រូវធ្វើតារាងត្រួតពិនិត្យនេះមួយ (១) ច្បាប់ ជាបន្ទាន់ទៅ គធ/ខប ។

២.១០១.៨.៤ ប្រសិនបើសម្ភារ ឯកសារដែលបាត់បង់នោះ ជាសម្ភារ ឯកសារ ចាំបាច់មិនអាចខ្វះបាន សម្រាប់ការបោះឆ្នោត ប្រធាន គកប ត្រូវចាត់សមាជិក គកប ចំនួនពីរ (២) រូប ឱ្យធ្វើដំណើរទៅកាន់ទីស្នាក់ការ គឃ/ខប ដើម្បីទទួលសម្ភារ ថ្មី ជំនួសសម្ភារដែលខ្វះ ឬបានបាត់បង់ទៅ ឬក៏ទូរស័ព្ទ បញ្ជូនព័ត៌មានស្នើសុំទៅ គឃ/ខប ដើម្បីដោះស្រាយបញ្ហា ខាងលើ ។

២.១០១.៨.៥ ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោត ខាងលើនេះ គកប ត្រូវយកចិត្តទុកដាក់ចំពោះមុខសម្ភារ ដូចខាងក្រោម ៖

- ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតនោះ និងពិនិត្យផ្ទៀងផ្ទាត់ ចំនួន និងលេខរៀងដែលមានកត់ត្រានៅលើកញ្ចប់សន្លឹក ឆ្នោត ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតឡើយ ។
- ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ ឱ្យប្រាកដថាពិតជា មានត្រាសម្ងាត់ ចំនួនពីរ (២) នៅខាងក្នុង ប៉ុន្តែមិនត្រូវ បើកស្រោមសំបុត្រជាដាច់ខាត។

២.១០១.៩ សម្ភារសំខាន់ៗដែលការិយាល័យបោះឆ្នោតមិនបានទទួល ឬបាត់បង់ ហើយ ដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត រួមមាន ៖

២.១០១.៩.១ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ដូចចែងក្នុងចំណុច ២.៤៩.៩.៤ និងចំណុច ២.៤៩.៩.៥ នៃ ប.ន.ក នេះ ។

២.១០១.៩.២ ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតចំនួនពីរ (២) ។

២.១០១.៩.៣ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

២.១០១.៩.៤ ហិបឆ្នោតទាំងពីរ (២) ដែលហិបឆ្នោតមួយ (១) មានជញ្ជាំង ខាងមុខបិទពាសដោយក្រដាសស ប្រើសម្រាប់បោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងហិបឆ្នោតមួយ (១) ទៀត មានបិទពាសដោយក្រដាសពណ៌ ប្រើសម្រាប់បោះ ឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងសោឃ្លុំ មានលេខ ។

២.១០១.៩.៥ ទឹកខ្មៅលុបលាងមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃ ។

២.១០១.១០ សម្ភារដទៃទៀត ដែលប្រសិនបើមិនបានផ្តល់ដោយ គជ/ខប ឬបាត់បង់ នោះ គកប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង ៖

២.១០១.១០.១ កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើបិទបាំង ជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។

២.១០១.១០.២ ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់បែបបទ សម្រាប់បំពេញកំណត់ហេតុជាគំរូ ។

២.១០១.១០.៣ ប៊ិចសរសេរ បន្ទាត់ ខ្សែចង... ។ល។

២.១០១.១១ នៅពេលពិនិត្យ ផ្ទៀងផ្ទាត់ឃើញថា សម្ភារឯកសារបោះឆ្នោតមានគ្រប់ចំនួន ហើយ ប្រធាន គកប ត្រូវចាត់ជំនួយការ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការមួយ (១) ច្បាប់ នៅមុខទីតាំងការិយាល័យបោះឆ្នោត និងលើកស្លាកការិយាល័យបោះឆ្នោតនៅលើច្រកទ្វារចូលការិយាល័យបោះឆ្នោត ។

២.១០១.១២ បន្ទាប់ពីអនុវត្តចំណុច ២.១០១.១១ រួច គកប ត្រូវរៀបចំការិយាល័យបោះឆ្នោតទៅតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ដោយធានាថា ទីតាំងការិយាល័យបោះឆ្នោតនោះ អាចធ្វើការបោះឆ្នោតបាន និងបានរៀបចំរួចរាល់នៅម៉ោងប្រាំមួយ (៦) ព្រឹក នៃថ្ងៃបោះឆ្នោត ។

២.១០១.១២.១ គកប ត្រូវគូរគំរូប្លង់ការិយាល័យបោះឆ្នោត ឯកភាពគ្នាមួយទៅតាមស្ថានភាពជាក់ស្តែងនៃការិយាល័យ ដោយត្រូវគោរពតាមគោលការណ៍ ដូចបានចែងក្នុងសៀវភៅណែនាំ គកប ។

២.១០១.១២.២ គកប ត្រូវបាំងរាំងនន ឬរបាំងផ្សេងទៀតដែលអាចរកបាន នៅចន្លោះបន្ទប់សម្ងាត់ទាំងពីរ នៅក្នុងការិយាល័យបោះឆ្នោត។ រាំងនន ឬរបាំង ត្រូវមានកម្ពស់មួយជំហរដែលមិនអាចឱ្យអ្នកបោះឆ្នោតមើលគ្នាឃើញ ។

២.១០១.១២.៣ ប្រសិនបើ គ្មានគ្រឿងសង្ហារិមនៅក្នុងការិយាល័យបោះឆ្នោតទេ ប្រធាន គកប ត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់ នូវគ្រឿងសង្ហារិមចាំបាច់មួយចំនួនសម្រាប់បម្រើការបោះឆ្នោត ដូចជា តុ កៅអី និងសម្ភារដទៃទៀត ដែលអាចសម្រួលដល់ការងារបោះឆ្នោត ។

២.១០១.១២.៤ ប្រធាន គកប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខយាមកាមរក្សាសន្តិសុខ ទីតាំងការិយាល័យបោះឆ្នោត ។ ប្រសិនបើអាចធ្វើបាន ប្រធានត្រូវបិទទ្វារចាក់សោទីតាំងការិយាល័យបោះឆ្នោតនោះផង ។

២.១០១.១៣ ប្រធានរួមជាមួយសមាជិក គកប ត្រូវការពារសម្ភារឯកសារបោះឆ្នោត ឱ្យបានហ្មត់ចត់ នៅមុនពេលបោះឆ្នោត ។

២.១០១.១៣.១ សម្ភារ ឯកសារបោះឆ្នោតអាចនឹងត្រូវបានរក្សាទុកនៅផ្ទះរបស់ប្រធាន ឬសមាជិកណាម្នាក់ ឬនៅទីតាំងណាមួយដែល គកប ឯកភាពគ្នាថាមានសុវត្ថិភាព ។

២.១០១.១៣.២ យ៉ាងហោចណាស់ត្រូវមានសមាជិក គកប បី (៣) នាក់ គិតទាំងប្រធានផង សម្រាកនៅផ្ទះ ឬទីតាំងដែលរក្សាសម្ភារ ឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព ។

២.១០១.១៣.៣ ប្រធានត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលរក្សាទុកសម្ភារឯកសារបោះឆ្នោត ។

២.១០១.១៤ ប្រធានត្រូវណាត់ជាមួយសមាជិកដទៃទៀតឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាពដែលរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោងប្រាំសាមសិបនាទី (៥:៣០) ព្រឹកនៃថ្ងៃបោះឆ្នោត ជាកំហិត ដើម្បីដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោត ទៅកាន់ទីតាំងការិយាល័យបោះឆ្នោត ។

២.១០១.១៥ សមាជិកទាំងអស់នៃ គកប ត្រូវត្រៀមអាហារទុកសម្រាប់មួយ (១) ថ្ងៃ ដើម្បីបរិភោគនៅពេលទំនេរ ដែលពុំមានវត្តមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប ។

**ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ ២.១០២** ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ដូចចែងក្នុងផ្នែកទី ៥ ក្រោមប្រការ ២.៧១ នៃ ប.ន.ក នេះ ។ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងយាមកាមយ៉ាងតឹងរ៉ឹងបំផុត ក្នុងគោលបំណងបំរើសុវត្ថិភាពនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.១០២.១ ប្រធាន គកប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ឱ្យចៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារឧបករណ៍សម្ភារ ឯកសារទាំងអស់ក្នុងការិយាល័យទាំងនោះ ។

២.១០២.២ ការិយាល័យបោះឆ្នោតត្រូវបានបង្កើតឡើងដោយ គ.ជ.ប សម្រាប់បំពេញកិច្ចប្រតិបត្តិការនៃការបោះឆ្នោត នៅថ្ងៃបោះឆ្នោត ។

២.១០២.៣ ការិយាល័យបោះឆ្នោត នឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត សម្រាប់បំពេញកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោត បន្ទាប់ពីការិយាល័យនោះបានបញ្ចប់ការបោះឆ្នោត លើកលែងតែ គ.ជ.ប សំរេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ។

**ការប្រព្រឹត្តទៅនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត នៅថ្ងៃបោះឆ្នោត**

**ប្រការ ២.១០៣** សមាសភាពទាំងអស់នៃ គកប ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោត ដោយនាំមកជាមួយនូវសម្ភារឯកសារបោះឆ្នោត ឱ្យបានទាន់ពេលនៅវេលាម៉ោងប្រាំមួយ (៦) ព្រឹក នាថ្ងៃបោះឆ្នោតជាកំហិត ។

២.១០៣.១ បន្ទាប់ពី គកប បានចូលដល់ក្នុងការិយាល័យភ្លាម ប្រធាន គកប ត្រូវប្រកាសឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ ចូលក្នុងការិយាល័យបោះឆ្នោត ដោយធ្វើការត្រួតពិនិត្យស្លាកសម្គាល់ ឬ/និងសេចក្តីសម្រេចតែងតាំង និងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ ។ ប្រធាន គកប ត្រូវអនុញ្ញាតឱ្យអ្នកដែលបានត្រួតពិនិត្យរួចហើយ ចូលក្នុងការិយាល័យបោះឆ្នោត និងប្រាប់ទីកន្លែងដែលបំរុងទុក សម្រាប់ពួកគាត់ ដូចចែងក្នុងចំណុច ២.១០៣.២.៥ ខាងក្រោម ។

២.១០៣.២ ទន្ទឹមពេលអនុវត្តចំណុច ២.១០៣.១ ខាងលើ ប្រធាន គកប ត្រូវចាត់ចែងសមាជិក គកប ដទៃទៀតឱ្យរៀបចំគ្រឿងសង្ហារិមនិងដាក់សម្ភារឯកសារសម្រាប់ការបោះឆ្នោត ដូចបានកំណត់ឯកភាពគ្នាលើគំរូប្លង់ការិយាល័យបោះឆ្នោតដែលបានរៀបចំមុនមួយថ្ងៃ និងដូចបានបញ្ជាក់នៅក្នុងសៀវភៅណែនាំ គកប ។

២.១០៣.២.១ តុមួយដាក់នៅប៉ែកខាងឆ្វេងដៃ បន្ទាប់ពីទ្វារចូល សម្រាប់ប្រធាន គកប ដែលនៅលើនោះ មានទម្រង់បែបបទលេខ ១២០២ ត្រៀមផ្តល់ជូនតាមការស្នើសុំរបស់តំណាងគណបក្សនយោបាយសម្រាប់បំពេញពាក្យបណ្តឹង។

២.១០៣.២.២ តុមួយដាក់នៅប៉ែកខាងស្តាំដៃ បន្ទាប់ពីទ្វារចូល សម្រាប់លេខាធិការ ដែលមានដាក់បញ្ជីបោះឆ្នោត កញ្ចប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ស្រោមសំបុត្រមានដាក់ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ទម្រង់បែបបទ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត ទម្រង់បែបបទផ្សេងទៀត និងតាំប៉ុងពណ៌ក្រហម ។

២.១០៣.២.៣ បន្ទប់សម្ងាត់ទី១ សម្រាប់ការគូសសន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែល មានបិចចង់ខ្សែភ្ជាប់ស្រាប់ ត្រូវដាក់តម្កល់នៅលើតុមួយ (១) ក្បែរជញ្ជាំង ដើម្បីរក្សាការសម្ងាត់នៃការបោះឆ្នោត ប៉ុន្តែមិនត្រូវដាក់នៅក្បែរបង្អួចទេ ។ ផ្ទាំងក្រដាសមួយ (១) សន្លឹក សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់ ។

២.១០៣.២.៤ តុវែងមួយស្ថិតនៅចន្លោះកណ្តាល ប៉ែកខាងមុខរវាងបន្ទប់សម្ងាត់ទី១ និងទី២ សម្រាប់អនុប្រធាន គកប ដែលមានដាក់កញ្ចប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ស្រោមសំបុត្រមានដាក់ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត តាំប៉ុងពណ៌ក្រហម និងហិបឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៣.២.៥ បន្ទប់សម្ងាត់ទី ២ សម្រាប់ការគូសសន្លឹកឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវឃ្លាតឆ្ងាយពីបន្ទប់សម្ងាត់ទី ១ យ៉ាងតិចមួយ (១) ម៉ែត្រ និងត្រូវរៀបចំបំពាក់សម្ភារ ដូចបន្ទប់សម្ងាត់ទី ១ ។

២.១០៣.២.៦ ហិបឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ទឹកខ្មៅលុបលាងមិនជ្រះ និងកំណាត់សម្រាប់ជូតត្រូវដាក់នៅលើតុវែងមួយ ស្ថិតនៅកណ្តាលបន្ទប់ ទល់មុខនឹងតុរបស់ប្រធាន គកប ។

២.១០៣.២.៧ តុ និងកៅអី (ប្រសិនបើមាន) សម្រាប់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវដាក់នៅអែបជញ្ជាំងប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន និងនៅខាងក្រោយតុលេខាធិការ ។

២.១០៣.២.៨ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានសម្ភារ ឯកសារមិនទាន់ប្រើប្រាស់ ត្រូវរក្សាទុកនៅក្បែរតុប្រធាន ។

២.១០៣.៣ នៅពេលអនុវត្តចំណុច ២.១០៣.១ រួចរាល់ ប្រធាន គកប ត្រូវពន្យល់ណែនាំជារួមដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ ដែលពួកគេត្រូវគោរព និងអនុវត្ត ដូចខាងក្រោម ៖

២.១០៣.៣.១ ត្រូវគោរព ច.ប.ក ប.ន.ក ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ក្រមសីលធម៌អ្នកសង្កេតការណ៍ និងក្រមសីលធម៌ សម្រាប់អ្នកយកព័ត៌មាន ដែលកំណត់ដោយ គ.ជ.ប ។

២.១០៣.៣.២ ត្រូវតាមដានជាប្រចាំរាល់កិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្រែងមានភាពមិនប្រក្រតី ។

២.១០៣.៣.៣ ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។

២.១០៣.៣.៤ ត្រូវលើកសំណួរ ឬ/និងសំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ ដោយផ្ទាល់ទៅប្រធាន គកប ។

២.១០៣.៣.៥ មិនត្រូវណែនាំអ្វីដល់ គកប ។

២.១០៣.៣.៦ មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត ។

២.១០៣.៣.៧ មិនត្រូវធ្វើអ្វីឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៣.៤ នៅចន្លោះពីម៉ោងប្រាំមួយ (៦) ដល់ម៉ោងប្រាំមួយកន្លះ (៦:៣០) ព្រឹក នៃថ្ងៃបោះឆ្នោត គកប ត្រូវត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតទាំងពីរ (២) ជូនអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត តាមនីតិវិធីដូចខាងក្រោម ៖

២.១០៣.៤.១ ប្រធាន គកប ត្រូវពិនិត្យហិបឆ្នោតទាំងពីរ (២) ឡើងវិញម្តងមួយៗ ដើម្បីឱ្យប្រាកដថា ត្រូវបានតម្លើងត្រឹមត្រូវហើយ ។

២.១០៣.៤.២ ប្រធាន គកប ត្រូវបើកគំរបក្រៅ និងគំរបក្នុងនៃហិបឆ្នោតនីមួយៗ រួចបង្ហាញហិបឆ្នោតដែលទទេ ចំពោះអ្នកដែលមានវត្តមាន ក្នុងការិយាល័យបោះឆ្នោតទាំងអស់ បន្ទាប់មកត្រូវបិទគំរបក្នុង នៃហិបឆ្នោតទាំងនោះវិញ មួលភ្ជិតគំរបសន្ទះ

បិទប្រឡោះ សម្រាប់បោះឆ្នោត ហើយខ្ទាស់គន្លឹះបិទគំរបក្នុង រួចចាក់សោឃ្លុំ និងបង្គាប់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំដែលចាក់ភ្ជាប់នឹងគន្លឹះហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៅលើកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០១ ស) ដែលមានពណ៌ និងលេខសោឃ្លុំ ដែលចាក់ភ្ជាប់នឹងគន្លឹះហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត នៅលើកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០១ ខ) ។

២.១០៣.៤.៣ ប្រធាន គកប ត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោត និងបោះត្រាលើក្រដាសពណ៌ ចំនួនពីរ (២) សន្លឹក រួចបិទភ្ជាប់នៅលើជញ្ជាំងខាងមុខនៃហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បន្ទាប់មកត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោត និងបោះត្រាលើក្រដាសស ចំនួនពីរ (២) សន្លឹកទៀត ដើម្បីបិទភ្ជាប់នៅលើជញ្ជាំងខាងមុខ នៃហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ។ បន្ទាប់ពីរៀបចំរួចរាល់ហើយ ប្រធាន គកប ត្រូវអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោតទាំងពីរ (២) នៃការិយាល័យបោះឆ្នោតនោះ ។

២.១០៣.៤.៤ លេខាធិការត្រូវកត់ត្រាពេលម៉ោង នៃការពិនិត្យហិបឆ្នោត នៅលើកំណត់ហេតុ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៣.៥ ហិបឆ្នោតដែលបានបិទស្លាកសម្គាល់លេខកូដការិយាល័យ និងចាក់សោឃ្លុំរួចហើយ ដូចចែងក្រោមចំណុច ២.១០៣.៤ ខាងលើ ត្រូវហាមដូចខាងក្រោម ៖

២.១០៣.៥.១ មិនអនុញ្ញាតឱ្យយកចេញពីការិយាល័យបោះឆ្នោត នៅក្នុងអំឡុងពេលទាំងមូលនៃកិច្ចប្រតិបត្តិការបោះឆ្នោតឡើយ ។

២.១០៣.៥.២ មិនអនុញ្ញាតឱ្យបើកចំហជាដាច់ខាត លើកលែងតែតម្រូវឱ្យអនុវត្តតាមបទបញ្ជានិងនីតិវិធីរបស់ គ.ជ.ប ស្តីពីការផ្ទៀងផ្ទាត់សន្លឹកឆ្នោត និងការរាប់សន្លឹកឆ្នោត នៅការិយាល័យរាប់សន្លឹកឆ្នោតពាក់ព័ន្ធ ។

២.១០៣.៦ ប្រសិនបើ សម្ភារឯកសារបោះឆ្នោត សម្រាប់ការិយាល័យបោះឆ្នោត ត្រូវបាន ប្រគល់ទទួលនៅក្រោយម៉ោងប្រាំមួយកន្លះ (៦:៣០) ដោយសារករណីប្រធាន ស័ក្តិ ប៉ុន្តែមិនទាន់ហួសម៉ោងប្រាំពីរ (៧:០០) ព្រឹក នៃថ្ងៃបោះឆ្នោតទេនោះ ប្រធាន គកប ត្រូវព្យួរការអនុវត្តនីតិវិធី ដូចចែងក្រោមចំណុច ២.១០៣.៧ ខាងក្រោម ជាបណ្តោះអាសន្នសិន រហូតទាល់តែនីតិវិធី ដូចចែងក្រោមចំណុច ២.១០៣.៤ ខាងលើ ត្រូវបានបំពេញចប់សព្វគ្រប់ ។ ក្នុងករណីនេះ លេខាធិការ ត្រូវកត់ត្រាអំពីពេលម៉ោងនៃការអនុវត្តនីតិវិធីបោះឆ្នោតនីមួយៗ ទៅក្នុងកំណត់ ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងកំណត់ហេតុ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឱ្យបានច្បាស់លាស់ ។

២.១០៣.៧ ប្រសិនបើគ្មានអ្វីប្រែប្រួលទេ នៅចន្លោះពីម៉ោងប្រាំមួយកន្លះ (៦:៣០) ដល់ម៉ោង ប្រាំពីរ (៧:០០) ព្រឹក នៃថ្ងៃបោះឆ្នោត គកប ត្រូវត្រួតពិនិត្យ និងរាប់ចំនួន សន្លឹកឆ្នោតបានទទួលជាក់ស្តែង ព្រមទាំងត្រួតពិនិត្យ និងបង្ហាញត្រាសម្ងាត់ផ្លូវការ សម្រាប់ការិយាល័យបោះឆ្នោតនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ៖

២.១០៣.៧.១ អនុប្រធានត្រូវបើកកញ្ចប់សន្លឹកឆ្នោតទាំងពីរ (២) ដូចកំណត់ ក្នុងចំណុច ២.១០៣.២.២ និង២.១០៣.២.៤ ម្តងមួយ កញ្ចប់ៗ ដើម្បីត្រួតពិនិត្យមើល និងធានាថា សន្លឹកឆ្នោតទាំងនេះ ជាសន្លឹកឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធប្រើប្រាស់ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ប្រាកដមែន ។ ក្នុងករណី សន្លឹកឆ្នោត ដែលបានទទួលមិនមែនជាសន្លឹកឆ្នោត សម្រាប់ការិយាល័យ បោះឆ្នោតនោះ គកប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈ គឃ/ខប មក គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ ។

២.១០៣.៧.២ បន្ទាប់មក អនុប្រធានត្រូវរាប់សន្លឹកឆ្នោត ដែលប្រើសម្រាប់ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង សន្លឹកឆ្នោត ដែលប្រើសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សារាជធានី ខេត្ត ដែលជាធម្មតាកញ្ចប់នីមួយៗ មានចំនួន សន្លឹកឆ្នោតលើសពីចំនួនអ្នកបោះឆ្នោត ដែលមានក្នុងបញ្ជី បោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះពី ៥០ ដល់ ៩៩ សន្លឹក សម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១០៣.៧.៣ លេខាធិការ ត្រូវកត់ត្រាចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាក់ស្តែង ព្រមទាំងលេខរៀងដើមដំបូងបង្អស់ និងលេខរៀងចុងបញ្ចប់នៃសន្លឹកឆ្នោត ប្រភេទក្រុមប្រឹក្សានីមួយៗ នៅលើកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ខេត្ត ។ ទោះបី សន្លឹកឆ្នោតរាប់ឃើញជាក់ស្តែង មានចំនួនលើស ឬខ្វះ ធៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ទទួលក្តី ក៏លេខាធិការត្រូវកត់ត្រាចំនួនលើស ឬខ្វះនោះ នៅលើកំណត់ហេតុនៃការបោះឆ្នោតដែរ ។

២.១០៣.៧.៤ លេខាធិការត្រូវពិនិត្យចំនួនអ្នកបោះឆ្នោត ដែលមាននៅក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះនៅលើកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៣.៧.៥ ប្រធានត្រូវបើកស្រោមសំបុត្រទាំងពីរ (២) ដែលមានត្រាសម្ងាត់ សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រួចដកយកត្រាទាំងនោះ មកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស និងលើកបង្ហាញឱ្យអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ បានឃើញច្បាស់ និងចំណាំបានរូបសញ្ញាដូចគ្នានៃត្រាសម្ងាត់ទាំងពីរនោះ ។

២.១០៣.៨ ប្រធាន គកប ត្រូវប្រកាសបើកការិយាល័យបោះឆ្នោតនៅម៉ោងប្រាំពីរ (៧:០០) ព្រឹក នៃថ្ងៃបោះឆ្នោត ។ ប្រសិនបើមាន ករណីដូចចែងក្នុងចំណុច ២.១០៣.៦ ខាងលើ ប្រធាន គកប អាចប្រកាសបើកការិយាល័យបោះឆ្នោត នៅក្រោយម៉ោងប្រាំពីរ (៧:០០) ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោងប្រាំបី (៨:០០) ឡើយ ។

២.១០៣.៩ នៅមុនពេល ប្រធាន គកប ប្រកាសបើកការិយាល័យបោះឆ្នោត សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ត្រូវចាត់ចែងសណ្តាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុង ដោយណែនាំអ្នកបោះឆ្នោតឱ្យឈរជាជួរបន្តកន្ទុយគ្នា ។

២.១០៣.១០ បន្ទាប់ពី ប្រធាន គកប ប្រកាសបើកការិយាល័យបោះឆ្នោត សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ដែលប្រចាំការនៅត្រង់មាត់ទ្វារចេញ ចូលការិយាល័យបោះឆ្នោត ត្រូវជម្រាបអ្នកបោះឆ្នោត ដែលកំពុងឈរជាជួរបន្តកន្ទុយគ្នា នៅមុខមាត់ទ្វារចូល

ការិយាល័យបោះឆ្នោត អំពីការផ្តល់អាទិភាពចំពោះអ្នកបោះឆ្នោតដែលជាជនមានវ័យចំណាស់ ស្ត្រីមានផ្ទៃពោះ អ្នកមានជម្ងឺ ជនពិការ និងអ្នកជំនួយជានីតិជនម្នាក់ដែលគាត់ជ្រើសរើសមកជាមួយ ។ អ្នកបោះឆ្នោតដែលត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោតត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

២.១០៣.១០.១ ត្រូវបង្ហាញជូនសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ នូវឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ដែលកំណត់ដោយច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងដែលអ្នកបោះឆ្នោតត្រូវប្រើប្រាស់សម្រាប់បោះឆ្នោត ។ ឯកសារបញ្ជាក់អត្តសញ្ញាណ អាចជាអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬប័ណ្ណសំគាល់គ្រួសារមានបិទរូបថតសាមីខ្លួន ឬសៀវភៅគ្រួសារមានបិទរូបថតសាមីខ្លួន ឬលិខិតសំគាល់ខ្លួនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង មានបិទរូបថតសាមីខ្លួន ឬលិខិតបញ្ជាក់អត្តសញ្ញាណ មានបិទរូបថតសាមីខ្លួន ដែលចេញដោយមេឃុំ ចៅសង្កាត់ ។

២.១០៣.១០.២ យល់ព្រមឱ្យសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ពិនិត្យមើលម្រាមដៃរបស់ខ្លួន ដែលពិតជាពុំមានស្នាមទឹកខ្មៅលុបលាងមិនជ្រះមែន ។

២.១០៣.១១ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ត្រូវជម្រាបអ្នកបោះឆ្នោត ដែលខ្លួនអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោតថា ជាដំបូងត្រូវដើរតម្រង់ទៅរកតុលេខាធិការ ។ អ្នកបោះឆ្នោតត្រូវបង្ហាញលេខាធិការ នូវឯកសារបញ្ជាក់អត្តសញ្ញាណណាមួយដែលខ្លួនមានដូចចែងក្នុងចំណុច ២.១០៣.១០.១ ខាងលើ ។ ពេលនោះលេខាធិការត្រូវ ៖

២.១០៣.១១.១ ត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបលាងមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ ។

២.១០៣.១១.២ រកឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត បន្ទាប់មក ពិនិត្យផ្ទៀងផ្ទាត់ឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ ជាមួយនឹងរូបពិត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធ នៅក្នុងបញ្ជីបោះឆ្នោត ។

២.១០៣.១១.៣ ដាក់បន្ទាត់តម្រង់តាមបណ្ដោយជួរឈ្មោះរបស់គាត់ ផ្ទៀងផ្ទាត់ប្រសិនបើឈ្មោះ និងទិន្នន័យក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតដូចគ្នានឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត និងគូសសញ្ញាមួយបញ្ជាក់ការមកបោះឆ្នោតរបស់អ្នកបោះឆ្នោតក្នុងប្រឡោះទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ ។

២.១០៣.១១.៤ ហែកសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មួយ (១) សន្លឹក ចេញពីគល់បញ្ជីសន្លឹកឆ្នោត រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង បត់ជាបួន (៤) ផ្នត់ តាមការណែនាំ រួចប្រគល់ជូនអ្នកបោះឆ្នោត ដែលមិនស្ថិតក្នុងស្ថានភាពដូចចែងក្នុងចំណុច ២.១០៣.១១.៧ និង ២.១០៣.១៣ រួមជាមួយឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ផង លើកលែងតែលិខិតបញ្ជាក់អត្តសញ្ញាណមានបិទរូបថតសាមីខ្លួន ដែលចេញដោយមេឃុំ ចៅសង្កាត់ ដែលត្រូវរក្សាទុករហូតដល់ក្រោយការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត ។

២.១០៣.១១.៥ ជម្រាបអ្នកបោះឆ្នោតថា នេះគឺជាសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលមានពណ៌ ។ លោក អ្នកត្រូវចូលទៅក្នុងបន្ទប់សម្ងាត់ទី ១ ប្រើប៊ិចដែលមាននៅទីនោះស្រាប់ ឬប៊ិច ឬស្លាបប៉ាកាផ្ទាល់ខ្លួន ។ អ្នកត្រូវគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយណាមួយដែលលោក អ្នកពេញចិត្ត ។ លោក អ្នកមិនអាចប្រើខ្មៅដៃក្នុងការគូសសន្លឹកឆ្នោតបានទេ ។ លោក អ្នកត្រូវគិតពិចារណាឱ្យបានហ្មត់ចត់ មុននឹងគូសសញ្ញាគាំទ្រ ដើម្បីបង្ការការខូចសន្លឹកឆ្នោតដោយសារការផ្លាស់ប្ដូរចិត្ត បន្ទាប់ពីបានគូសរួច ។ លោក អ្នកត្រូវបត់សន្លឹកឆ្នោតនេះ តាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលលោកអ្នកបានគូស ស្ថិតនៅខាងក្នុងផ្នត់ មិនអាចមើលឃើញ និងឱ្យរូបត្រាសម្ងាត់ស្ថិតនៅខាងក្រៅ ។ លោក អ្នកត្រូវយកសន្លឹកឆ្នោតនេះទៅស៊កចូលក្នុងហិបឆ្នោត ដែលស្ថិតនៅលើតុរបស់អនុប្រធាន និងរង់ចាំគាត់ប្រគល់ជូនសន្លឹកឆ្នោតមួយ (១) សន្លឹកទៀត សម្រាប់ការបោះឆ្នោតជ្រើសរើសកុមប្រឹក្សារាជធានី ខេត្ត ។

២.១០៣.១១.៦ លេខាធិការមិនត្រូវប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតបន្ទាប់ទេ ប្រសិនបើអ្នកបោះឆ្នោតមុន មិនទាន់បានចេញផុតពីបន្ទប់សម្ងាត់ទី១ ។

២.១០៣.១១.៧ ប្រសិនបើ មានអ្នកបោះឆ្នោតណាម្នាក់អះអាងថា គាត់នឹងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយទេ ត្រូវអនុវត្តការផ្ទៀងផ្ទាត់ដូចចំណុច ២.១០៣.១១.២ និង ២.១០៣.១១.៣ ហើយត្រូវនាំគាត់ទៅជួបប្រធាន គកប ដើម្បីប្រធានបំពេញព័ត៌មានអំពីបញ្ហានេះទៅក្នុងក្រដាសកត់ត្រាព័ត៌មាន ដែលកំណត់ដោយ គ.ជ.ប ។

២.១០៣.១១.៨ ក្នុងករណីដូចចំណុច ២.១០៣.១១.៧ ប្រសិនបើអ្នកបោះឆ្នោតនោះអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវអនុវត្តបន្តតាមចំណុច ២.១០៣.១១.៤ ។

២.១០៣.១១.៩ ក្នុងករណីដូចចំណុច ២.១០៣.១១.៧ ប្រសិនបើអ្នកបោះឆ្នោតនោះអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវណែនាំគាត់ឱ្យទៅជួបអនុប្រធាន គកប ដើម្បីធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៣.១២ ប្រសិនបើ ក្នុងពេលអនុវត្តចំណុច ២.១០៣.១១.១ លេខាធិការបានរកឃើញថា មានស្នាមប្រឡាក់ទឹកខ្មៅលុបលាងមិនជ្រះ ជាប់នៅនឹងម្រាមដៃអ្នកបោះឆ្នោត ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គកប ដើម្បីរាយការណ៍អំពីករណីនេះ ។

២.១០៣.១២.១ ប្រធានត្រូវអញ្ជើញតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ឱ្យមកធ្វើការកត់សម្គាល់អំពីបញ្ហានេះ ហើយត្រូវឱ្យអ្នកបោះឆ្នោតរូបនេះ ពន្យល់អំពីស្នាមប្រឡាក់ទឹកខ្មៅលុបលាងមិនជ្រះ ដែលជាប់នឹងម្រាមដៃរបស់គាត់ ។

២.១០៣.១២.២ ប្រសិនបើ អ្នកបោះឆ្នោតនោះមិនអាចផ្តល់ការពន្យល់របស់ខ្លួនបានសមហេតុផលអំពីស្នាមទឹកខ្មៅទេ នោះគាត់នឹងត្រូវបានគេសន្និដ្ឋានថា មានបំណងបោះឆ្នោតលើសពីមួយដង និងត្រូវទទួលទោសតាម ច.ប.ក ។

២.១០៣.១២.៣ ប្រធានត្រូវ ដកហូតលិខិតបញ្ជាក់អត្តសញ្ញាណរបស់គាត់ ជាបណ្តោះអាសន្ន ហើយត្រូវបញ្ជូនករណីនេះទៅ គធ/ខប ដើម្បីចាត់វិធានការបន្ត ។

២.១០៣.១២.៤ លេខាធិការត្រូវកត់ត្រាទុកអំពីហេតុការណ៍នេះ នៅក្នុងកំណត់ហេតុនៃការបោះឆ្នោតទាំងពីរ (២) ហើយត្រូវស្រង់ឈ្មោះ និងទិន្នន័យពីលិខិតបញ្ជាក់អត្តសញ្ញាណរបស់ជននោះ សម្រាប់ជាការតាមដានបន្ថែមទៀត ។

២.១០៣.១២.៥ ប្រសិនបើ អ្នកបោះឆ្នោតរូបនោះមិនយល់ព្រមតាមការអនុវត្តនីតិវិធីនេះ ប្រធាន គកប ឬ/និង គជ/ខប ត្រូវស្នើសុំអាជ្ញាធរមានសមត្ថកិច្ច ឱ្យឃាត់ខ្លួនជននោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

២.១០៣.១៣ ប្រសិនបើ ក្នុងពេលអនុវត្តចំណុច ២.១០៣.១១.២ លេខាធិការរកមិនឃើញឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតទេ ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គកប ដើម្បីរាយការណ៍អំពីករណីនេះ ។

២.១០៣.១៣.១ ប្រធានត្រូវប្រាប់អ្នកបោះឆ្នោតនោះថា គាត់មិនអាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះបានទេ ព្រោះគាត់មិនបានបំពេញគ្រប់ល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងប្រការ ២.៦៩ នៃ ប.ន.ក នេះ ។

២.១០៣.១៣.២ ប្រសិនបើជាករណីច្រឡំការិយាល័យបោះឆ្នោត ប្រធាន គកប ត្រូវណែនាំអ្នកបោះឆ្នោតនោះ អំពីទីតាំងការិយាល័យបោះឆ្នោតដែលគាត់ត្រូវទៅបោះឆ្នោត ។

២.១០៣.១៣.៣ ប្រធានត្រូវប្រាប់គាត់ឱ្យចេញពីការិយាល័យបោះឆ្នោត ។

២.១០៣.១៤ នៅពេលទទួលបានសន្លឹកឆ្នោត អ្នកបោះឆ្នោតត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោត ។

២.១០៣.១៤.១ អ្នកបោះឆ្នោតមិនត្រូវសួរនាំ ឬប្រាប់អ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឱ្យដឹងអំពីគណបក្សនយោបាយណាមួយដែលគាត់ពេញចិត្ត ឬមិនពេញចិត្តឡើយ ។

២.១០៣.១៤.២ អ្នកបោះឆ្នោតមិនអាចស្នើសុំជំនួយពីជនណាម្នាក់ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ឱ្យជួយគាត់ក្នុងការបោះឆ្នោតឡើយ ។ ដោយឡែក អ្នកបោះឆ្នោតជាជនពិការដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង (ប្រសិនបើមាន) មានសិទ្ធិជ្រើសរើសអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬស្នើសុំជំនួយពី ប្រធាន គកប ។

២.១០៣.១៤.៣ តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលស្ថិតក្នុងការិយាល័យបោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតទេ ទោះបីអ្នកបោះឆ្នោតស្នើសុំឱ្យជួយក៏ដោយ ។

២.១០៣.១៤.៤ ហាមអ្នកបោះឆ្នោត និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត ប្រើទូរស័ព្ទដៃ ឬ/និងម៉ាស៊ីនថត ឬ/និងឧបករណ៍ផ្សេងទៀត ដែលអាចថតរូបបាន ឬ/និងធ្វើសកម្មភាពទាំងឡាយណាដែលរំលោភលើការសម្ងាត់នៃការបោះឆ្នោត ក្នុងការិយាល័យបោះឆ្នោត ។ អ្នកសារព័ត៌មានដែលទទួលស្គាល់ដោយ គ.ជ.ប និង បានទទួលការអនុញ្ញាតពីប្រធាន គកប អាចថតរូបបាន ។

២.១០៣.១៥ បន្ទាប់ពីអ្នកបោះឆ្នោតបានទទួលសន្លឹកឆ្នោត និងបានអនុវត្តតាមការណែនាំរបស់លេខាធិការ ដូចចែងក្នុងចំណុច ២.១០៣.១១.៥ រួចហើយ អ្នកបោះឆ្នោតត្រូវចេញពីបន្ទប់សម្ងាត់ទី ១ ហើយដើរតម្រង់ទៅតុដាក់ហិបឆ្នោត ដែលស្ថិតនៅលើតុរបស់អនុប្រធាន ។

២.១០៣.១៥.១ អ្នកបោះឆ្នោតត្រូវកាន់សន្លឹកឆ្នោតរបស់ខ្លួន ដែលបានបត់រួចដោយដាក់បង្ហាញផ្នែកដែលមានបោះត្រាសម្ងាត់ បែរទៅរកអនុប្រធាន គកប ហើយស៊កសន្លឹកឆ្នោតនោះ ដោយខ្លួនឯង ។ ក្នុងករណី អ្នកបោះឆ្នោតជាជនពិការ ដែលមានអ្នកជំនួយជានីតិជន ឬបានស្នើសុំជំនួយពីប្រធាន គកប នោះ អ្នកជំនួយជានីតិជន ឬ ប្រធាន គកប ជាអ្នកជួយស៊កសន្លឹកឆ្នោតជំនួសគាត់ ។

២.១០៣.១៥.២ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោត ដែលបត់រួច បម្រុងនឹងស៊កទៅក្នុងហិបឆ្នោត អនុប្រធាន គកប ត្រូវពិនិត្យឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតផ្លូវការពណ៌ ដែលមានបោះត្រាសម្ងាត់សម្រាប់ការិយាល័យនោះតែមួយ (១) សន្លឹកត្រូវបានស៊កចូលទៅក្នុងហិបឆ្នោត ដែលស្ថិតនៅលើតុរបស់គាត់ ។

២.១០៣.១៥.៣ ប្រសិនបើ ពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បាន ឬបម្រុងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀត ចូលទៅ

ក្នុងហិបឆ្នោត អនុប្រធាន គកប ត្រូវឃាត់ទុក និងរាយការណ៍ជាបន្ទាន់ ទៅប្រធាន គកប ។ ក្នុងករណីនេះ ប្រធាន គកប ត្រូវប្រកាសប្រាប់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការឆែកឆេររកសន្លឹកឆ្នោតផ្លូវការ ។

២.១០៣.១៥.៤ ប្រធាន គកប ត្រូវឃាត់អ្នកបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ២.១០៣.១៥.៣ មិនឱ្យបោះឆ្នោត រួចដកហូតសន្លឹកឆ្នោតក្លែងក្លាយនោះ និងឆែកឆេររកសន្លឹកឆ្នោតផ្លូវការ (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រ ដែលមានកាខ្នងថា " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " បន្ទាប់មកត្រូវដកហូតឯកសារបញ្ជាក់អត្តសញ្ញាណរបស់ជននោះ ជាបណ្តោះអាសន្ន ព្រមទាំងចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្តឹងចោទប្រកាន់ជនល្មើស ទៅ គធ/ខប ។

២.១០៣.១៥.៥ ប្រសិនបើ មានអ្នកបោះឆ្នោតណាម្នាក់ ត្រូវបានចាប់ភស្តុតាងបានថា មានបំណងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពីមួយសន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវតែមានទោស ដោយផ្អែកតាម ច.ប.ក ។

២.១០៣.១៦ បន្ទាប់ពីអ្នកបោះឆ្នោតបានស៊កសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទៅក្នុងហិបឆ្នោតដែលស្ថិតនៅលើតុរបស់អនុប្រធាន គកប រួច ឬប្រសិនបើ អ្នកបោះឆ្នោតអះអាងថា គាត់មិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដូចចំណុច ២.១០៣.១១.៩ និងបន្ទាប់ពីប្រធាន គកប បានបំពេញក្រដាសព័ត៌មាន ដូចចែងក្នុងចំណុច ២.១០៣.១១.៧ រួចរាល់ អនុប្រធាន គកប ត្រូវហែកសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត មួយ (១) សន្លឹក ចេញពីគល់បញ្ជីសន្លឹកឆ្នោត រួចបោះត្រាសម្ងាត់ នៅលើផ្នែកខាងខ្នង បត់ជាបួន (៤) ផ្គត់តាមការកំណត់របស់ គ.ជ.ប និងប្រគល់ទៅឱ្យអ្នកបោះឆ្នោតនោះ ។ អនុប្រធាន គកប មិនត្រូវហែកសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ជូនអ្នកបោះឆ្នោតទេ ប្រសិនបើ គាត់អះអាងថាមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

រាជធានី ខេត្ត ដូចចំណុច ២.១០៣.១១.៤ ដែលត្រូវបានប្រធាន គកប កត់ត្រាព័ត៌មាននេះរួចរាល់ ។ អនុប្រធាន គកប មិនត្រូវប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតបន្ទាប់ទេ ប្រសិនបើ អ្នកបោះឆ្នោតមុន មិនទាន់បានចេញផុតពីបន្ទប់សម្ងាត់ ទី២ ។ នៅពេលប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតហើយ អនុប្រធានត្រូវណែនាំជាសង្ខេប ចំពោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត តាមលំនាំចំណុច ២.១០៣.១១.៥ ។

២.១០៣.១៧ អ្នកបោះឆ្នោតត្រូវគោរពតាមគោលការណ៍សម្ងាត់ ដូចចែងក្រោមចំណុច ២.១០៣.១៤ ។ បន្ទាប់ពីបានទទួលសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងបន្ទាប់ពីអនុវត្តតាមការណែនាំរបស់អនុប្រធាន ដូចចែងក្នុងចំណុច ២.១០៣.១៦ រួចហើយ អ្នកបោះឆ្នោត ត្រូវចេញពីបន្ទប់សម្ងាត់ ទី ២ ហើយដើរតម្រង់ទៅតុដាក់ហិបឆ្នោតទី២ ។

២.១០៣.១៧.១ អ្នកបោះឆ្នោតត្រូវកាន់សន្លឹកឆ្នោតរបស់ខ្លួន ដែលបានបត់រួច ដោយដាក់បង្ហាញផ្នែកដែលមានបោះត្រាសម្ងាត់ បែរទៅរកជំនួយការ ហើយស៊កសន្លឹកឆ្នោតនោះចូលទៅក្នុងហិបឆ្នោត ដោយខ្លួនឯង ។ ក្នុងករណី អ្នកបោះឆ្នោតជាជនពិការ ដែលមានអ្នកជំនួយជានីតិជន ឬបានស្នើសុំជំនួយពីប្រធាន គកប នោះ អ្នកជំនួយជានីតិជន ឬ ប្រធាន គកប ជាអ្នកជួយស៊កសន្លឹកឆ្នោតជំនួសគាត់ ។

២.១០៣.១៧.២ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោត ដែលបត់រួច បម្រុងនឹងស៊កទៅក្នុងហិបឆ្នោត ជំនួយការត្រូវពិនិត្យឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតផ្លូវការ ដែលមានបោះត្រាសម្ងាត់សម្រាប់ការិយាល័យនោះ តែមួយ (១) សន្លឹក ត្រូវបានស៊កចូលទៅក្នុងហិបឆ្នោត ។

២.១០៣.១៧.៣ ប្រសិនបើ ពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បាន ឬបម្រុងស៊ក សន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀត ចូលទៅក្នុងហិបឆ្នោត ជំនួយការត្រូវឃាត់ទុក និងរាយការណ៍ ជាបន្ទាន់ទៅប្រធាន គកប ។ ក្នុងករណីនេះ ប្រធាន គកប ត្រូវប្រកាសប្រាប់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការដែកឆេររកសន្លឹកឆ្នោតផ្លូវការ ។

២.១០៣.១៧.៤ បន្ទាប់មក អ្នកបោះឆ្នោតត្រូវយល់ព្រមឱ្យជំនួយការ ជ្រលក់ម្រាមចង្អុលដៃស្ដាំ ឬម្រាមផ្សេងទៀត (ប្រសិនបើម្រាមចង្អុលដៃស្ដាំពិការ) ចូលទៅក្នុងដបទឹកខ្មៅលុបលាងមិនជ្រះ ដូចចែងក្រោមចំណុច ២.១០៣.១៨ ខាងក្រោម ឱ្យលិចដល់គល់ក្រចក ។

២.១០៣.១៧.៥ ប្រធាន គកប ត្រូវឃាត់អ្នកបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ២.១០៣.១៧.៣ មិនឱ្យបោះឆ្នោត រួចដកហូតសន្លឹកឆ្នោតក្លែងក្លាយនោះ និងឆែកឆេររកសន្លឹកឆ្នោតផ្លូវការ (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រ ដែលមានកាខ្វងថា " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " បន្ទាប់មកត្រូវដកហូតឯកសារបញ្ជាក់អត្តសញ្ញាណរបស់ជននោះ ជាបណ្ដោះអាសន្ន ព្រមទាំងចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្ដឹងចោទប្រកាន់ជនល្មើស ទៅ គធ/ខប ។

២.១០៣.១៧.៦ ប្រសិនបើ មានអ្នកបោះឆ្នោតណាម្នាក់ ត្រូវបានចាប់ភស្តុតាងបានថា មានបំណងសៀកសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពីមួយសន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវតែមានទោស ដោយផ្អែកតាម ច.ប.ក ។

២.១០៣.១៧.៧ ទោះបីអ្នកបោះឆ្នោតបានអះអាងថា នឹងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ដូចចែងក្នុងចំណុច ២.១០៣.១១.៧ ក៏ដោយ គាត់ត្រូវតែយល់ព្រមឱ្យជំនួយការជ្រលក់ម្រាមដៃរបស់គាត់ចូលទៅក្នុងដបទឹកខ្មៅលុបលាងមិនជ្រះ ដូចចែងក្នុងចំណុច ២.១០៣.១៧.៤ ។

២.១០៣.១៨ ទឹកខ្មៅលុបលាងមិនជ្រះដែលអាចមើលឃើញច្បាស់ ត្រូវបានដាក់បញ្ញត្តិឱ្យប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សម្រាប់បង្ការមិនឱ្យមានការបោះឆ្នោតលើសពីមួយដង ។

២.១០៣.១៨.១ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានផ្គត់ផ្គង់ទឹកខ្មៅលុបលាងមិនជ្រះ ចំនួនពីរ (២) ដប ។

២.១០៣.១៨.២ ទឹកខ្មៅលុបលាងមិនជ្រះមួយ (១) ដបត្រូវបានក្រឡុកឱ្យសព្វ រួចបើកគម្របប្រើ នៅពេលចាប់ផ្តើមការបោះឆ្នោត និងបម្រុងទុកមួយ (១) ដបសម្រាប់ប្រើនៅពេលអស់ទឹកខ្មៅដបទីមួយ ។

២.១០៣.១៨.៣ បន្ទាប់ពីអ្នកបោះឆ្នោតបានស៊កសន្លឹកឆ្នោតរបស់ខ្លួន ទៅក្នុងហិបឆ្នោត និងនៅមុនពេលគាត់ដើរចេញពីការិយាល័យបោះឆ្នោត គាត់ត្រូវយល់ព្រមឱ្យជំនួយការ ជ្រលក់ម្រាមចង្អុលដៃស្តាំរបស់គាត់ទៅក្នុងដបទឹកខ្មៅលុបលាងមិនជ្រះ ឱ្យលិចដល់គល់ក្រចក និងរង់ចាំរហូតដល់ស្ងួតស្រួលបួល ក្នុងរយៈពេលសាមសិប (៣០) វិនាទី ទើបចេញពីការិយាល័យបោះឆ្នោត ។

២.១០៣.១៨.៤ ក្នុងករណី ម្រាមចង្អុលដៃស្តាំពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់លំដោយដូចតទៅ ៖ ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ។ ប្រសិនបើ គាត់មិនអាចធ្វើបានតាមការកំណត់ខាងលើ រាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវៈយវៈរបស់គាត់ ត្រូវទទួលយកជាបានការ ។

២.១០៣.១៨.៥ រៀងរាល់សាមសិប (៣០) នាទីម្តង ដបទឹកខ្មៅលុបលាងមិនជ្រះ ត្រូវតែបានបិទគម្របយ៉ាងជិត ហើយក្រឡុក ។

២.១០៣.១៨.៦ ប្រសិនបើគ្មានវត្តមានអ្នកបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតមួយរយៈពេលយូរបន្តិច ជំនួយការត្រូវបិទគម្របដបទឹកខ្មៅលុបលាងមិនជ្រះ ដើម្បីការពារកុំឱ្យហួត ។

២.១០៣.១៩ គ្មានជនណាម្នាក់នៅក្នុងការិយាល័យបោះឆ្នោត អាចជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានឡើយ លើកលែងតែ អ្នកបោះឆ្នោតនោះជាជនពិការ ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ហើយបានស្នើសុំឱ្យអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬស្នើសុំជំនួយពីប្រធាន គកប ត្រូវអនុវត្តតាម នីតិវិធីដូចខាងក្រោម ៖

២.១០៣.១៩.១ បន្ទាប់ពី បានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោតអ្នកបោះឆ្នោតពិការដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយជានីតិជនម្នាក់ ដែលអមដំណើរជាមួយដើម្បីជួយគាត់ក្នុងការបោះឆ្នោត ត្រូវអនុវត្តជាបន្តបន្ទាប់ តាមនីតិវិធីដូចចែងក្រោមចំណុច ២.១០៣.១១ ២.១០៣.១៤ ២.១០៣.១៥ ២.១០៣.១៦ និង ២.១០៣.១៧ ខាងលើ ។

២.១០៣.១៩.២ បន្ទាប់ពីបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនពិការ ដែលមានបំណងស្នើសុំជំនួយពីប្រធាន គកប ត្រូវទៅជួបប្រធាន ដោយផ្ទាល់ ។ បន្ទាប់មក ប្រធាន ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនពិការនោះ និងអនុវត្តជាបន្តបន្ទាប់តាមនីតិវិធីដូចចែងក្រោមចំណុច ២.១០៣.១១ ២.១០៣.១៤ ២.១០៣.១៥ ២.១០៣.១៦ និង ២.១០៣.១៧ ។ ក្នុងករណីនេះ ប្រធានអាចចាត់សមាជិក គកប ណាម្នាក់ឱ្យជួយក៏បាន ប៉ុន្តែត្រូវមានការយល់ព្រមពីសាមីខ្លួន ។

២.១០៣.១៩.៣ អ្នកបោះឆ្នោតជាជនពិការ ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ត្រូវសួរនាំ ឬ/និងប្រាប់អំពីគណបក្សនយោបាយដែលខ្លួនពេញចិត្តទៅប្រធាន ឬសមាជិក គកប ឬអ្នកជំនួយដែលខ្លួនជ្រើសរើស តែនៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតប៉ុណ្ណោះ ។

២.១០៣.១៩.៤ នៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ប្រធាន ឬសមាជិក គកប ឬអ្នកជំនួយ ត្រូវសួរអ្នកបោះឆ្នោតជាជនពិការនោះតិចៗ ដើម្បីកុំឱ្យមនុស្សផ្សេងទៀតនៅក្នុងការិយាល័យបោះឆ្នោត ដឹងថាគាត់បោះឆ្នោតឱ្យគណបក្សនយោបាយមួយណា ។ បន្ទាប់មក ប្រធាន ឬសមាជិក គកប ឬអ្នកជំនួយត្រូវគូសនៅលើសន្លឹកឆ្នោតនូវសញ្ញាមួយ ក្នុងប្រឡោះរាងបួនជ្រុងទ្រវែងនៃគណបក្សនយោបាយ ដែលអ្នកបោះឆ្នោតពិការជ្រើសរើស បន្ទាប់មក ត្រូវអនុវត្តតាមនីតិវិធីដូចចែងក្រោមចំណុច ២.១០៣.១៥ និង ២.១០៣.១៧ រួចត្រូវនាំអ្នកបោះឆ្នោតពិការ ទៅកាន់ហិបឆ្នោត និងជួយស៊កសន្លឹកឆ្នោតរបស់គាត់តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។

២.១០៣.១៩.៥ ប្រធាន ឬសមាជិក គកប ឬអ្នកជំនួយ ដែលបានជួយអ្នកបោះឆ្នោតជាជនពិការនោះ ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់ ។

២.១០៣.២០ ក្នុងអំឡុងពេលនៃការបោះឆ្នោត ប្រសិនបើ ក្នុងការិយាល័យបោះឆ្នោត គ្មានអ្នកបោះឆ្នោតទេនោះ ជំនួយការ និងអនុប្រធាន គកប ត្រូវមួលភ្ជិតសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោត ជាបណ្ដោះអាសន្ន ហើយត្រូវបើកឡើងវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត ។

២.១០៣.២១ គ្មានជនណាម្នាក់ អាចមើលការគូសសញ្ញាគាំទ្រលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតបានឡើយ លើកលែងតែអ្នកដែលត្រូវបានស្នើសុំឱ្យជួយអ្នកបោះឆ្នោតជាជនពិការ ដូចចែងក្រោមចំណុច ២.១០៣.១៩ ខាងលើ ។

២.១០៣.២១.១ ជនណាក៏ដោយ ដែលប៉ុនប៉ងចង់ឃើញការគូសសញ្ញានៅលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត ជននោះនឹងត្រូវទទួលការព្រមានពីប្រធាន គកប ។ ការប៉ុនប៉ងជាលើកទីពីរ ដើម្បីធ្វើឱ្យបែកខ្ញូវខ្ញាយនូវគោលការណ៍សម្ងាត់នៃការបោះឆ្នោត នឹងត្រូវចាត់ទុកថា ជាការរំលោភទៅលើ ច.ប.ក ហើយជនល្មើសពាក់ព័ន្ធ ត្រូវតែបានបណ្តេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ក ។

២.១០៣.២១.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត ។

២.១០៣.២២ អ្នកបោះឆ្នោតណាម្នាក់ដែលបានធ្វើឱ្យខូច ឬរហែកសន្លឹកឆ្នោតដោយអចេតនា ឬដែលបានគូសសញ្ញានៅលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ គាត់អាចសុំសន្លឹកឆ្នោតមួយ (១) សន្លឹកទៀត ពីប្រធាន គកប ។

២.១០៣.២២.១ អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោតមួយ (១) សន្លឹកទៀត ត្រូវបត់សន្លឹកឆ្នោតដែលខូច ឬរហែក ឬគូសខុសនោះ តាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់ រួចប្រគល់ជូន ប្រធាន គកប ។

២.១០៣.២២.២ ប្រធានត្រូវស៊កសន្លឹកឆ្នោតដែលខូច ឬរហែក ឬគូសខុសនោះទៅក្នុងស្រោមសំបុត្រមួយដែលមានកាខ្លងថា « សន្លឹកឆ្នោតខូច » ។

២.១០៣.២២.៣ លេខាធិការដែលបានគូសសញ្ញាសម្គាល់ម្តងហើយ ក្នុងប្រឡោះទំនេរ នៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត តាមការណែនាំដូចចែងក្នុងចំណុច ២.១០៣.១១.៣ ខាងលើ មិនចាំបាច់គូសសញ្ញាសម្គាល់ជាលើកទីពីរឡើយ ប៉ុន្តែត្រូវកត់ចំណាំទុក សម្រាប់សរសេរចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

២.១០៣.២២.៤ ប្រធានត្រូវ បង្គាប់លេខាធិការ ឬអនុប្រធានឱ្យផ្តល់សន្លឹកឆ្នោតមួយ (១) សន្លឹកទៀត (តាមប្រភេទសន្លឹកឆ្នោត)

ជូនអ្នកបោះឆ្នោត និងត្រូវធានា ឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់ សម្រាប់អ្នកបោះឆ្នោតទាំងអស់ បានបោះឆ្នោតគ្រប់ៗគ្នា នៅថ្ងៃបោះឆ្នោត ។

២.១០៣.២២.៥ ក្នុងករណី មានអ្នកបោះឆ្នោតមួយចំនួន សុំសន្លឹកឆ្នោតមួយ (១) សន្លឹកទៀតជាបន្តបន្ទាប់គ្នា ដោយយោងតាមចំណុច ២.១០៣.២២ ដែលករណីនេះអាចចាត់ទុកថា ជាភាពមិនប្រក្រតីមួយនោះ ប្រធាន គកប អាចសម្រេចមិនផ្តល់សន្លឹកឆ្នោតមួយ (១) សន្លឹកទៀត តាមការស្នើសុំ និងត្រូវរំលឹកលេខាធិការ ឬអនុប្រធាន ឱ្យណែនាំអ្នកបោះឆ្នោត តាមខ្លឹមសារនៃចំណុច ២.១០៣.១១.៥ និង ២.១០៣.១៦ ខាងលើ ។

២.១០៣.២៣ ប្រសិនបើ តំណាងគណបក្សនយោបាយណាម្នាក់ជំទាស់នឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងសេចក្តីសម្រេចណាមួយរបស់ គកប តំណាងនោះត្រូវលើកការជំទាស់នោះដោយផ្ទាល់ទៅប្រធាន គកប ដោយបង្ហាញអំពីមូលហេតុ ឬ/និងភស្តុតាង ដែលធ្វើឱ្យយល់ថា មានភាពមិនប្រក្រតី ឬការរំលោភច្បាប់ ឬ/និងការរំលោភ ប.ន.ក ក្នុងការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

២.១០៣.២៣.១ ប្រសិនបើ យល់ឃើញថា ការជំទាស់មានលក្ខណៈសមហេតុសមផល ប្រធានត្រូវផ្អាកជាបណ្តោះអាសន្ន នូវកិច្ចប្រតិបត្តិការបោះឆ្នោត ដើម្បីស្តាប់ការជំទាស់របស់តំណាងគណបក្សនយោបាយនោះ និងពិភាក្សាបញ្ហានេះជាមួយនឹងសមាជិក គកប ដទៃទៀត ។

២.១០៣.២៣.២ បន្ទាប់ពីបានពិនិត្យឡើងវិញនូវករណី ដែលបានលើកជំទាស់ហើយ ប្រធាន គកប យល់ព្រមតាមការជំទាស់ ប្រធានត្រូវណែនាំ និងរំលឹកដល់សមាជិក គកប និងអ្នកមានវត្តមានផ្សេងទៀត ក្នុងការិយាល័យបោះឆ្នោត អំពីខ្លឹមសារពាក់ព័ន្ធដែលចែងក្នុង ច.ប.ក ប.ន.ក ហើយត្រូវរិះរកវិធីណាមួយដើម្បីដោះស្រាយភាពមិនប្រក្រតីនោះ ។

២.១០៣.២៣.៣ ប្រសិនបើ ប្រធាន គកប បដិសេធការជំទាស់ គាត់ត្រូវផ្តល់ហេតុផលសមស្រប ពាក់ព័ន្ធនឹងការបដិសេធនោះ ហើយតំណាងគណបក្សនយោបាយ មានសិទ្ធិសុំឱ្យកត់ត្រាករណីនៃការជំទាស់នេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត ប្រសិនបើតំណាងនោះយល់ព្រមផ្តិតមេដៃ លើកំណត់ហេតុនោះ ។

២.១០៣.២៣.៤ ប្រសិនបើតំណាងនោះមិនយល់ព្រមផ្ដិតមេដៃទេ ករណីជំទាស់នេះ មិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោតឡើយ។

២.១០៣.២៣.៥ សេចក្ដីសម្រេចរបស់ប្រធាន គកប ត្រូវតែមានប្រសិទ្ធភាព ហើយ ប្រធានត្រូវប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត ។

២.១០៣.២៣.៦ ចំណុច ២.១០៣.២៣.៥ ខាងលើ មិនបានច្រានចោលការប្ដឹងជំទាស់ទៅ គធ/ខប អំពីករណីដែលតំណាងគណបក្សបានលើកជំទាស់ ក្នុងការិយាល័យបោះឆ្នោតនោះទេ ប៉ុន្តែក្នុងស្ថានភាពនេះ គាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គកប ដោយមិនត្រូវជ្រៀតជ្រែកកិច្ចប្រតិបត្តិការបោះឆ្នោតឡើយ ។

២.១០៣.២៣.៧ ប្រធានត្រូវផ្ដល់ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្ដឹង ប្រសិនបើ តំណាងគណបក្សនយោបាយស្នើសុំសម្រាប់ប្ដឹងបន្តទៅ គធ/ខប ។

២.១០៣.២៤ ប្រសិនបើ អ្នកបោះឆ្នោតណាម្នាក់រំខាន ឬធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់កំពុងស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬកំពុងឈរតម្រង់ជួរនៅក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោតក្ដី ប្រធានត្រូវបញ្ជាទៅអ្នកបោះឆ្នោតរូបនោះឱ្យចេញពីការិយាល័យបោះឆ្នោត ឬចេញផុតពីបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ។ ប្រសិនបើ អ្នកបោះឆ្នោតនោះមិនគោរពតាមបញ្ជា ប្រធាន គកប ត្រូវស្នើកម្លាំងសន្តិសុខឱ្យបណ្ដេញបុគ្គលនោះចេញ ឬឃាត់ខ្លួនបុគ្គលនោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

២.១០៣.២៥ ប្រធាន គកប អាចស្នើសុំឱ្យកងកម្លាំងសន្តិសុខរៀបចំសាឡើងវិញនូវរបៀបរៀបរយខាងក្នុង និងខាងក្រៅការិយាល័យបោះឆ្នោត ប្រសិនបើ កិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កម្រិត ដែលធ្វើឱ្យអ្នកបោះឆ្នោតមិនអាចបោះឆ្នោតបន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី ។ ការរំខានដល់អ្នកបោះឆ្នោត ឬដល់ការប្រព្រឹត្តទៅនៃការបោះឆ្នោត គឺជាសកម្មភាពទាំងឡាយណានៅខាងក្នុង ឬបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ដូចខាងក្រោមនេះ ៖

២.១០៣.២៥.១ ការបញ្ចេញពាក្យសំដីគំរាមកំហែង ឬជេរប្រមាថ មាក់ងាយ។

២.១០៣.២៥.២ ការបញ្ចេញសម្រែកខ្លាំងៗ ។

២.១០៣.២៥.៣ ការរុញច្រានដោយប្រើកម្លាំងធ្ងន់ ។

២.១០៣.២៥.៤ ការគប់វត្ថុផ្សេងៗសំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត ។

២.១០៣.២៥.៥ ការអុកឡុកដោយបុគ្គលណាម្នាក់ ឬច្រើននាក់ ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត ។

២.១០៣.២៥.៦ ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ ។

២.១០៣.២៥.៧ ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗប្រកបដោយគ្រោះថ្នាក់ ។

២.១០៣.២៦ ប្រសិនបើ ការបោះឆ្នោតឈានដល់ម៉ោង ១៥:០០ រសៀល នៃថ្ងៃបោះឆ្នោត ដែលជាពេលវេលាកំណត់ សម្រាប់បញ្ចប់ការបោះឆ្នោត ហើយនៅតែមានអ្នកបោះឆ្នោតកំពុងស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុង នៃការិយាល័យបោះឆ្នោតទៀត អ្នកបោះឆ្នោតទាំងអស់នោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត ។

២.១០៣.២៦.១ ក្នុងករណីនេះ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ត្រូវដើរប្រមូលយកឯកសារបញ្ជាក់អត្តសញ្ញាណ ពីអ្នកបោះឆ្នោតដែលកំពុងឈរក្នុងជួរ ដោយចាប់ផ្តើមពីអ្នកបោះឆ្នោតដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់។

២.១០៣.២៦.២ សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ត្រូវហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្តងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោត តាមលំដាប់លេខរៀង និងតាមនីតិវិធី ។

២.១០៣.២៦.៣ ជនណាក៏ដោយ ដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងជួរអ្នកបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅនាទីចុងក្រោយនាម៉ោងដប់ប្រាំ (១៥:០០) រសៀល នៃថ្ងៃបោះឆ្នោតទេ អ្នកបោះឆ្នោតទាំងនោះពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។

២.១០៣.២៧ ប្រសិនបើ អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មិនទាន់បានមកបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្តី ប្រធាន គកប មិនអាចបិទការបោះឆ្នោតនៅការិយាល័យរបស់ខ្លួននៅមុនម៉ោងដប់ប្រាំ (១៥:០០) រសៀល នៃថ្ងៃបោះឆ្នោតបានឡើយ ។

២.១០៣.២៨ ប្រសិនបើ អ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះឆ្នោតគ្រប់គ្នាហើយ ប្រធាន គកប អាចប្រកាសបញ្ចប់ការបោះឆ្នោតនៅការិយាល័យរបស់ខ្លួន នៅមុនម៉ោងដប់ប្រាំ (១៥:០០) រសៀល ។

២.១០៣.២៩ ក្នុងករណី ដូចចែងក្នុងចំណុច ២.១០៣.១១.៧ ខាងលើ ប្រធាន គកប ត្រូវបំពេញព័ត៌មានអំពីការអះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយរបស់អ្នកបោះឆ្នោត នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ទៅក្នុងក្រដាសព័ត៌មានតាមប្រភេទក្រុមប្រឹក្សា ដែលកំណត់ដោយ គ.ជ.ប ។

**ការបិទការបោះឆ្នោត នៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត**

**ប្រការ ២.១០៤** នៅពេលដែលអ្នកបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យ ប្រធានត្រូវចាត់ឱ្យសមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ចាត់វិធានការចាំបាច់ ដើម្បីការពារច្រកចូលការិយាល័យបោះឆ្នោត កុំឱ្យអ្នកគ្មានភារកិច្ចចេញចូល ។ ប្រធាន គកប ត្រូវប្រកាសបិទការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនោះ បន្ទាប់មកត្រូវចាត់ចែងការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត និងចំនួនសន្លឹកឆ្នោត និងការបំពេញកំណត់ហេតុនៃការបោះឆ្នោត ។

២.១០៤.១ បន្ទាប់ពីបានប្រកាសបិទការបោះឆ្នោត ប្រធាន គកប ត្រូវចាត់ការតាមនីតិវិធីដើម្បីធានាសុវត្ថិភាពហិបឆ្នោតនីមួយៗ ដែលក្នុងនោះ ៖

២.១០៤.១.១ ប្រធានត្រូវមូលភ្ជិតសន្ទះបិទប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនៃហិបឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងហិបឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ព្រមទាំងបិទពាសក្រដាសស្តើងមួយសន្លឹក ដែលមានចុះហត្ថលេខារបស់ប្រធាន គកប និងតំណាងគណបក្សនយោបាយ (ប្រសិនបើគាត់យល់ព្រម) ពីលើសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរ នៃហិបឆ្នោត នីមួយៗនោះផង ។

២.១០៤.១.២ ប្រធានត្រូវបិទគម្របខាងក្រៅនៃហិបឆ្នោតនីមួយៗ និងចាក់សោឃ្លុំមានលេខ នៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរនៃហិបឆ្នោតទាំងនោះ រួចត្រូវអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើលហិបឆ្នោត និងសោឃ្លុំ មានលេខទាំងនោះ ។

២.១០៤.១.៣ លេខាធិការត្រូវកត់ត្រាបន្ថែមនូវលេខសោឃ្លុំដែលចាក់ភ្ជាប់នឹងក្រវិលហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០១ស) និងលេខសោឃ្លុំដែលចាក់ភ្ជាប់នឹងក្រវិលហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០១ខ) និងពេលវេលានៃការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

២.១០៤.១.៤ ប្រធានត្រូវចាត់វិធានការ ការពារយ៉ាងហ្មត់ចត់នូវហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង សម្រាប់ការរាប់សន្លឹកឆ្នោតនៅនឹងកន្លែងការិយាល័យបោះឆ្នោត ឬសម្រាប់ការបញ្ជូនទៅរាប់នៅកន្លែងផ្សេង ប្រសិនបើមានការសម្រេចឱ្យធ្វើដូច្នេះដោយ គ.ជ.ប ។

២.១០៤.២ បន្ទាប់មក ស្ថិតនៅចំពោះមុខវត្តមាន តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គកប ត្រូវចាត់ចែងឱ្យសមាជិក គកប ធ្វើការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ និងសន្លឹកឆ្នោតខូច ដែលក្នុងនោះ ៖

២.១០៤.២.១ លេខាធិការត្រូវរាប់ចំនួនគំនូសក្នុងបញ្ជីបោះឆ្នោត ដែលតម្រូវឱ្យគូសក្នុងប្រឡោះ ផ្នែកខាងដើមនៃឈ្មោះអ្នកបោះឆ្នោត ដូចចែងក្នុងចំណុច ២.១០៣.១១.៣ ខាងលើ និងចំនួនអ្នកអះអាងមិនបោះឆ្នោតក្នុងក្រដាសព័ត៌មាន ដូចចែងក្នុងចំណុច ២.១០៣.២៩ បន្ទាប់មកត្រូវរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងចំនួនអ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ។

២.១០៤.២.២ អនុប្រធានត្រូវបំបែកគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ចេញពីគល់បញ្ជីសន្លឹកឆ្នោតដែលមិនបានប្រើ ម្តងមួយៗ តាមប្រភេទក្រុមប្រឹក្សា រួចរាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងសន្លឹកឆ្នោតខូច ដោយឡែកពីគ្នា ។ ប្រសិនបើ ចំនួន

សន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដូចបញ្ជាក់ក្នុងចំណុច ២.១០៣.៧.៣ ខាងលើ ដកចំនួនសន្លឹកឆ្នោតខូច រួមនឹងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ២.១០៤.២.១ ខាងលើ ឬស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ២.១០៤.២.១ ដកនឹងចំនួនអ្នកបោះឆ្នោត ដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនស្មើគ្នានេះក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬ/និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០១ស ឬ/និង ១១០១ខ) ។

២.១០៤.២.៣ ប្រសិនបើ ក្នុងការផ្ទៀងផ្ទាត់នេះបង្ហាញថា មានភាពខុសគ្នារវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត លេខាធិការត្រូវផ្ទៀងផ្ទាត់ជាលើកទីពីរនូវចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត និងចំនួនអ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ហើយអនុប្រធានក៏ត្រូវផ្ទៀងផ្ទាត់ឡើងវិញដែរ នូវចំនួនគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើសន្លឹកឆ្នោតខូច និងសន្លឹកឆ្នោតមិនបានប្រើ ។ ប្រសិនបើ ភាពខុសគ្នានៅតែមាន លេខាធិការត្រូវកត់ត្រា នូវតួលេខនៃចំនួនដែលខុសគ្នានោះ ក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬ/និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០១ស ឬ/និង ១១០១ខ) ហើយ ប្រធាន គកប ត្រូវបន្តចាត់ចែងអនុវត្តតាមនីតិវិធីជាបន្ត ។

២.១០៤.២.៤ លេខាធិការត្រូវកត់ត្រា នូវចំនួនអ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១១០១ស ឬ ១១០១ខ) ដោយស្រង់ចេញពីក្រដាសព័ត៌មាន ដូចចែងក្នុងចំណុច ២.១០៣.២៩ ។

២.១០៩.២.៥ ជំនួយការ ត្រូវចោះរន្ធសន្លឹកឆ្នោត ដែលមិនបានប្រើទាំងអស់ ដោយប្រដាប់ចោះ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ ។

២.១០៩.២.៦ អនុប្រធានត្រូវដាក់សន្លឹកឆ្នោត ដែលមិនបានប្រើ និងត្រូវបានចោះរន្ធរួច និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ទៅក្នុងស្បោងជ័រផ្លាស្ទិកតែមួយដាច់ដោយឡែកពីគ្នា រួចបិទឱ្យជិត ។

២.១០៩.៣ ប្រធាន គកប ត្រូវធានាថា លេខាធិការបានកត់ត្រាជាមុននូវ លេខសោឃ្លុំ ដែលនឹងត្រូវប្រើសម្រាប់ចាក់ឃ្លុំមាត់កញ្ចប់ " ខ " ដូចចែងក្នុងចំណុច ២.១០៩.៧ ខាងក្រោម ក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០១ស និង ១១០១ខ) និងត្រូវបោះត្រាសម្ងាត់ នៅជ្រុងខាងស្តាំ ប៉ែកខាងលើនៃកំណត់ហេតុទាំងនេះ ។ កំណត់ហេតុនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត (ទម្រង់បែបបទលេខ ១១០១ស និង ១១០១ខ) ចំនួនបី (៣) ច្បាប់ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលលេខាធិការបានបំពេញរួច ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងប្រធានផ្ទាល់ ព្រមទាំងមានបោះត្រាការិយាល័យផង ។

២.១០៩.៣.១ ប្រធានត្រូវដាក់បង្ហាញកំណត់ហេតុ ដូចចែងក្នុងចំណុច ២.១០៩.៣ ខាងលើឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ។

២.១០៩.៣.២ តំណាងគណបក្សនយោបាយ អាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃ ជាសាក្សីលើកំណត់ហេតុនេះបាន ។

២.១០៩.៣.៣ ការមិនចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើកំណត់ហេតុនៃការបោះឆ្នោត ពីតំណាងគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានទេ ។

២.១០៩.៤ ប្រធាន គកប ត្រូវរៀបចំទុកដាក់កំណត់ហេតុនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោត (ទម្រង់បែបបទលេខ ១១០១ស និង ១១០១ខ) ដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដូចចែងក្រោមចំណុច ២.១០៩.៣ ខាងលើ តាមការកំណត់ដូចខាងក្រោម ៖

២.១០៩.៩.១ ដាក់កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មួយ (១) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ទង់ថា " កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០១ស) ផ្ញើជូន គ.ជ.ប" ។

២.១០៩.៩.២ កំណត់ហេតុ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត មួយ (១) ច្បាប់ ក្នុងស្រោមសំបុត្រ បោះពុម្ព ដែល មានកាខ្ទង់ថា " កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០១ខ) ផ្ញើជូន គ.ជ.ប " ។

២.១០៩.៩.៣ ដាក់កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មួយ (១) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ទង់ថា " កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០១ស) ផ្ញើជូន គធ/ខប" ។

២.១០៩.៩.៤ កំណត់ហេតុ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត មួយ (១) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ព ដែល មានកាខ្ទង់ថា " កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០១ខ) ផ្ញើជូន គធ/ខប " ។

២.១០៩.៥ បន្ទាប់មក ប្រធាន គកប ត្រូវរៀបចំដាក់សម្ភារឯកសារបោះឆ្នោតពាក់ព័ន្ធ ទៅក្នុងស្បោងផ្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់បញ្ចូលទៅក្នុង កញ្ចប់សុវត្ថិភាព " ក$_{ស}$ " ឬ " ក$_{ខ}$ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែល មានបោះពុម្ពសម្គាល់ថា " កំណត់ហេតុនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅការិយាល័យ បោះឆ្នោតលេខ..." ។

២.១០៩.៦ សម្ភារឯកសារបោះឆ្នោត ដែលត្រូវបញ្ចូលទៅក្នុងកញ្ចប់សុវត្ថិភាព " ក$_{ស}$" រួមមាន ៖

២.១០៩.៦.១ ស្រោមសំបុត្រមានដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចចែង ក្នុងចំណុច ២.១០៩.៩.១ ។

២.១០៩.៦.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោត ដែលបានប្រើក្នុងពេលបោះ ឆ្នោត និងក្រដាសព័ត៌មាន ដូចចែងក្នុងចំណុច ២.១០៣.២៩ ។

២.១០៥.៦.៣ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច "នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៥.៦.៤ ស្បោងជ័រផ្លាស្ទិកដាក់" សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៥.៦.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៥.៦.៦ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវ ដែលបានដកហូត" (ប្រសិនបើមាន) ។

២.១០៥.៦.៧ ស្រោមសំបុត្រដាក់ឯកសារភស្តុតាង ដែលបានដកហូត (ប្រសិនបើមាន) ។

២.១០៥.៧ សម្ភារឯកសារបោះឆ្នោត ដែលត្រូវដាក់បញ្ចូលទៅក្នុងកញ្ចប់សុវត្ថិភាព " ក₂ " រួមមាន ៖

២.១០៥.៧.១ ស្រោមសំបុត្រមានដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចចែងក្នុងចំណុច ២.១០៥.៥.២ ។

២.១០៥.៧.២ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច" នៃក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៥.៧.៣ ស្បោងជ័រផ្លាស្ទិកដាក់" សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៥.៧.៤ ស្រោមសំបុត្រដាក់ត្រាសម្ងាត់ សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៥.៨ ប្រធាន គកប ត្រូវធានាថា ក្នុងកញ្ចប់សុវត្ថិភាព " ក " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ត្រូវបានដាក់រាល់ស្រោមសំបុត្រ និងស្បោងផ្លាស្ទិកដាក់សម្ភារ ឯកសារ ដូចចែងក្រោមចំណុច ២.១០៥.៦ និង ២.១០៥.៧ ខាងលើ និងធានាថា កញ្ចប់សុវត្ថិភាព " ក" នីមួយៗ មិនទាន់ត្រូវបានបិទភ្ជិតនៅពេលនេះនៅឡើយ ហើយនឹងត្រូវបានបិទភ្ជិតដោយការសុវត្ថិភាពបំរុងស្រាប់ លុះណាតែ គករ បានបញ្ចប់ការរាប់សន្លឹកឆ្នោត និងបានដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធ រួចរាល់សិន ។

២.១០៤.៩ ប្រធាន គកប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ក " នីមួយៗ ដែលដាក់ស្រោមសំបុត្រ និងស្បោងផ្លាស្ទិកដាក់សម្ភារ ឯកសារ ដូចចែងក្រោមចំណុច ២.១០៤.៨ ខាងលើ ត្រូវបានបំពេញលេខកូដការិយាល័យយ៉ាងត្រឹមត្រូវ ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ ព្រមទាំងត្រូវរក្សាទុកឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ក្នុងពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតកំពុងដំណើរការ ។

២.១០៤.១០ ប្រធាន គកប ត្រូវចាត់ចែងសមាជិក ឱ្យរៀបចំទុកដាក់សម្ភារឯកសារដែលនៅសល់បញ្ចូលទៅក្នុងកេសស័ង្កសី និងវេចខ្ចប់ដបទឹកខ្មៅលុបលាងមិនជ្រះដោយឡែកពីគេ ។ ទន្ទឹមនឹងនេះត្រូវរុះរើបន្ទប់សម្ងាត់ទាំងពីរ (២) រួចច្រកចូលទៅក្នុងការុងនីឡុង តាមលំនាំដូចពេលបានទទួល ។

**ប្រការ ២.១០៥** មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួនស្ថិតក្នុងករណីកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ឬ/និង ក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត គ.ជ.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះបាន ។ នីតិវិធីចាប់ពីប្រការ ២.១២២ ដល់ប្រការ ២.១២៦ ខាងក្រោម នៃ ប.ន.ក នេះ ត្រូវតែបានអនុវត្តចំពោះការបិទការិយាល័យ និងការសម្រេចមិនបើកការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន ។

# ផ្នែកទី ៨

# ការរាប់សន្លឹកឆ្នោត និងលទ្ធផលនៃការបោះឆ្នោត

## ការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត

**ប្រការ ២.១០៦** ច.ប.ក បានបញ្ញត្តឱ្យអនុវត្តបែបបទ និងនីតិវិធីក្នុងការរាប់សន្លឹកឆ្នោត ដោយអនុលោមតាម ច.ប.ត.រ ។ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ការរាប់សន្លឹកឆ្នោតត្រូវធ្វើដោយផ្ទាល់នៅការិយាល័យបោះឆ្នោតនីមួយៗ ដែលមានទីតាំងនៅទីប្រជុំជនក្រុង ស្រុក ខណ្ឌ នៅពេលបន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច លើកលែងតែការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារកាលៈទេសៈមានអាសន្ន ហើយដែល គ.ជ.ប បានសម្រេចឱ្យ គធ/ខប ចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យនោះនៅលេខាធិការដ្ឋាននៃ គធ/ខប ឬនៅកន្លែងណាមួយដែលមានសុវត្ថិភាព ។

២.១០៦.១ ក្នុងករណី ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោត ការិយាល័យបោះឆ្នោតនោះនឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត ហើយ គកប ក្លាយជា គករ ។ ក្នុងករណីនេះ ប្រធាន គកប ដែលក្លាយជាប្រធាន គករ ត្រូវចាត់វិធានការ ដោយអនុវត្តតាមប្រការ ២.១០២ និងចំណុច ២.១០២.១ ខាងលើ និងត្រូវចាត់ចែង ប្រមូលទុកដាក់សម្ភារ ឯកសារ ដែលបានប្រើនៅពេលបោះឆ្នោតឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព ។ បន្ទាប់មក ប្រធាន គករ ត្រូវចាត់ចែងឱ្យរៀបចំបន្ទប់ សម្រាប់រាប់សន្លឹកឆ្នោតតាមគំរូប្លង់កំណត់ដោយ គ.ជ.ប ដែលក្នុងនោះត្រូវ ៖

២.១០៦.១.១ រៀបចំតុធំមួយ ឬតុតូចច្រើនផ្គុំគ្នា និងកៅអីបួនសម្រាប់សមាជិក គករ ដោយដាក់នៅចំកណ្តាលបន្ទប់ ដើម្បីអាចឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដើរចុះឡើងជុំវិញតុ ក្នុងការសង្កេតតាមដានកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោត ។

២.១០៦.១.២ លើកហិបឆ្នោតទាំងពីរ (២) ដូចចែងក្នុងចំណុច ២.១០១.៩.៤ ដាក់នៅចំកណ្តាលតុ ព្រមទាំងយកកញ្ចប់សុវត្ថិភាព " ក " ដូចបានបញ្ជាក់ក្នុងចំណុច ២.១០៤.៥ និងរាល់សម្ភារ

ឯកសារ និងទម្រង់បែបបទចាំបាច់ត្រៀមសម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដាក់នៅលើតុ ត្រង់កន្លែងប្រធានអង្គុយ ។

២.១០៦.១.៣ ចាត់សមាជិកទទួលបន្ទុកសណ្តាប់ធ្នាប់ ឱ្យការពារមាត់ទ្វារ បង្អួចដែលបើកចំហ កុំឱ្យមានអ្នកចេញចូល មើលថែរក្សាសុវត្ថិភាពសម្ភារ ឯកសារបោះឆ្នោត ដែលមិនត្រូវប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

២.១០៦.២ ប្រធាន គកក ត្រូវចាត់ចែងអនុវត្តការរាប់សន្លឹកឆ្នោតដោយឡែកពីគ្នាតាមប្រភេទក្រុមប្រឹក្សានីមួយៗ ដោយចាប់ផ្តើមពីការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាមុន បន្ទាប់មកទើបអនុវត្តការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ជាក្រោយ ។ កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ត្រូវធ្វើនៅតែមួយកន្លែង សម្រាប់ការិយាល័យរាប់សន្លឹកឆ្នោតមួយ ហើយប្រសិនបើចាប់ផ្តើមហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយពុំត្រូវឈប់សម្រាកឡើយ ។ ប្រធាន គកក ត្រូវចាត់ចែងត្រៀមឱ្យមានភ្លើងបំភ្លឺនៅការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីបង្ការករណីការរាប់សន្លឹកឆ្នោត ត្រូវអូសបន្លាយដល់ពេលយប់ ។

២.១០៦.២.១ ក្នុងដំណើរការនៃការរាប់សន្លឹកឆ្នោត តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មម ដែលអាចសង្កេតមើលឃើញសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត ។

២.១០៦.២.២ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ មានសិទ្ធិចូលរួមសង្កេតមើលដំណើរការនៃការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ និងត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមាន (ទម្រង់បែបបទលេខ ១១១៥) នៅមុនពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត ។

២.១០៦.២.៣ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចផ្លាស់ប្តូរតំណាងបម្រុងរបស់ខ្លួន (ប្រសិនបើមាន) ឱ្យជំនួសដើម្បីបន្តសង្កេតមើលដំណើរការនេះ រហូតដល់ពេលបញ្ចប់ ។

២.១០៦.៣ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ប្រធាន គករ ត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខខ្លួន ហើយឱ្យអនុប្រធាន និងជំនួយការ អង្គុយនៅអមសងខាងតុ ទល់មុខគ្នា ។

២.១០៦.៤ ស្ថិតនៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងបន្ទប់រាប់សន្លឹកឆ្នោត ប្រធាន គករ ត្រូវប្រកាសចាប់ផ្ដើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដោយចាប់ផ្ដើមពីការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយត្រូវ ៖

២.១០៦.៤.១ បម្រុងទុកនៅក្បែរខ្លួននូវ ៖

- កញ្ចប់សុវត្ថិភាព" កស" ដែលមានស្បោងផ្លាស្ទិក ឬ/និង ស្រោមសំបុត្រដាក់កំណត់ហេតុ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ។
- ទម្រង់បែបបទលេខ ១២០២ សម្រាប់ផ្ដល់ជូនតំណាងគណបក្សនយោបាយបំពេញពាក្យបណ្ដឹង (ប្រសិនបើគាត់ស្នើសុំ) ។
- ស្បោងផ្លាស្ទិកថ្លាសម្រាប់ដាក់សន្លឹកឆ្នោតបានការ និង ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ។
- កៅស៊ូកង ។

២.១០៦.៤.២ ប្រគល់ឱ្យអនុប្រធាន គករ នូវតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស) មួយ (១) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៦.៤.៣ ប្រគល់ទៅលេខាធិការនូវទម្រង់បែបបទលេខ ១១០២ស សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស) មួយ (១) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព " កស " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៦.៤.៤ ប្រគល់ទៅជំនួយការ នូវប៊ិចហ្វឺតធំមួយ (១) ដើម និងផ្ទាំងក្រដាសធំមួយ (១) ផ្ទាំង សំរាប់កត់ត្រាសំឡេងឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៦.៤.៥ ចាត់លេខាធិការ ឱ្យចាប់ផ្តើមបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០២ស) ដោយចម្លងនូវតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួល សន្លឹកឆ្នោតដែលមិនបានប្រើ សន្លឹកឆ្នោតខូច និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដែលតួលេខទាំងនេះត្រូវបានពិនិត្យ ផ្ទៀងផ្ទាត់រួចហើយ ដូចចែងក្រោមចំណុច ២.១០៤.២ ខាងលើ និងដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០១ស) ។

២.១០៦.៥ ស្ថិតនៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ ប្រធាន គករ ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ឱ្យច្បាស់ថា សោឃ្លុំមានលេខដែលចាក់ជាប់នឹងគម្របខាងក្រៅនៃហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ស្ថិតក្នុងស្ថានភាពដើម រួចកាត់ផ្តាច់សោឃ្លុំទាំងនេះ ដោយកន្ត្រៃ ឬកាំបិត តាមដែលអាចរកបាន រួចបើកគម្របខាងក្រៅចេញ ។ បន្ទាប់មក ប្រធាន គករ ត្រូវបន្តត្រួតពិនិត្យផ្ទៀងផ្ទាត់លេខសោឃ្លុំ ដែលចាក់ជាប់នឹងគន្លឹះខ្ទាស់គម្របខាងក្នុងនៃហិបឆ្នោត និងក្រដាសស្តើង ដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រឡោះ សម្រាប់ស៊កសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថា គ្មានការរុះរើ រួចកាត់ផ្តាច់សោឃ្លុំ និងហែកក្រដាសនេះចោល ។ ចុងក្រោយ ប្រធានត្រូវបើកគម្របខាងក្នុងនៃហិបឆ្នោតពាក់ព័ន្ធ និងចាក់សន្លឹកឆ្នោតឱ្យអស់ពីហិបឆ្នោត ដាក់នៅលើតុ ត្រង់ចន្លោះអនុប្រធាន និងជំនួយការ ហើយដាក់ហិបឆ្នោតទទេនៅក្បែរគាត់ ។

២.១០៦.៥.១ ជំនួយការ ត្រូវរើសយកវត្ថុមិនមែនជាសន្លឹកឆ្នោត ដែលមិនស្ថិតនៅជាប់ជាមួយសន្លឹកឆ្នោត ប្រសិនបើមាន ចេញពីគំនរសន្លឹកឆ្នោត រួចដាក់ទៅក្នុងស្រោមសំបុត្របម្រុងមួយ ។

២.១០៦.៥.២ លេខាធិការត្រូវកត់ត្រាករណីដូចចែងក្នុងចំណុច ២.១០៦.៥.១ ខាងលើ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០២ស) ។

២.១០៦.៦ ប្រធាន គកក ត្រូវបង្គាប់ឱ្យអនុប្រធាន និងជំនួយការ លាសន្លឹកឆ្នោត ដែលចាក់ចេញពីហិបឆ្នោត តំរៀបផ្កាប់ចុះក្រោម និងដាក់ជាបាច់នូវសន្លឹកឆ្នោត ណាមានបោះត្រាសម្គាល់ផ្លូវការខាងខ្នង ដោយក្នុងមួយ (១) បាច់មានម្ភៃប្រាំ (២៥) សន្លឹក នៅពំនូកទី១ និងដាក់សន្លឹកឆ្នោតណាគ្មានបោះត្រាសម្គាល់ផ្លូវការ នៅខាងខ្នង (ប្រសិនបើមាន) នៅពំនូកទី២ ។ បន្ទាប់មក អនុប្រធាន និង ជំនួយការ ត្រូវរាប់សន្លឹកឆ្នោតទាំងពីរពំនូកនេះ រួចរាយការណ៍ជូនប្រធាន អំពីចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ ។ ប្រធាន គកក ត្រូវធានាថា នីតិវិធីមួយចំនួន ដូចខាងក្រោមត្រូវតែបានអនុវត្ត ។

២.១០៦.៦.១ ក្នុងករណី ចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើ មានចំនួន សរុប ស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬ ស្មើនឹងចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដកនឹងផល បូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិន បានប្រើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននេះក្នុងកំណត់ ហេតុនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០២ស) ។

២.១០៦.៦.២ ប្រសិនបើ ចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើមានចំនួន តិចជាង ឬច្រើនជាងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬមានចំនួនតិចជាង ឬច្រើនជាងផលដករវាងចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្តែង ដកនឹងផលបូកនៃចំនួនសន្លឹក ឆ្នោតខូច និងចំនួនសន្លឹកឆ្នោតមិនបានប្រើនោះ ប្រធាន គកក ត្រូវរាប់សន្លឹកឆ្នោតដូចបញ្ជាក់ក្នុងចំណុច ២.១០៦.៦ ខាងលើ ជាលើកទីពីរ ។

២.១០៦.៦.៣ ប្រសិនបើ ប្រធាន គកក បានរាប់លើកទី២ហើយ ប៉ុន្តែតួ លេខនៃចំនួនសន្លឹកឆ្នោតនៅតែមានភាពខុសគ្នាដដែល ដូច បញ្ជាក់ក្នុងចំណុច ២.១០៦.៦.២ ខាងលើ លេខាធិការ ត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នានេះ ក្នុងកំណត់ហេតុនៃការ រាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០២ស) ។

២.១០៦.៦.៤ ប្រធាន គកក ត្រូវប្រកាសប្រាប់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោត

ដូចបញ្ជាក់ក្នុងចំណុច ២.១០៦.៦.១ ឬ ២.១០៦.៦.២ ឬ/និង ២.១០៦.៦.៣ ខាងលើ ដើម្បីឱ្យអ្នកទាំងនោះបានដឹង និងងាយស្រួលក្នុងការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផល ។

២.១០៦.៦.៥ អនុប្រធានត្រូវប្រគល់សន្លឹកឆ្នោតពាំនូកទី ២ ដែលគ្មានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង (ប្រសិនបើមាន) ជូនប្រធាន គកប ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងស្តាំដៃខ្លួន ។

២.១០៦.៦.៦ អនុប្រធានត្រូវប្រគល់សន្លឹកឆ្នោតពាំនូកទី ១ ដែលមានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង ជូនប្រធាន គកប ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងឆ្វេងដៃខ្លួន ។

២.១០៦.៧ បន្ទាប់ពីបញ្ចប់ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត ប្រធាន គកប ត្រូវចាប់ផ្តើមរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ដែលជាដំបូងត្រូវពិនិត្យផ្ទៀងផ្ទាត់សុពលភាពនៃសន្លឹកឆ្នោត រួចកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ។ ប្រធាន គកប ត្រូវធានាថា កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ត្រូវបានអនុវត្តតាមលំដាប់លំដោយ ដូចខាងក្រោម ៖

២.១០៦.៧.១ ផ្អែកតាមការកំណត់ ដូចចែងក្រោមប្រការ ២.១០៧ ខាងក្រោម ប្រធាន គកប ត្រូវយកសន្លឹកឆ្នោតម្តងមួយ (១) សន្លឹកៗ ពីពាំនូក ទី ១ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬមិនបានការ ព្រមទាំងត្រូវលើកបង្ហាញសន្លឹកឆ្នោត ដែលបានកំណត់ហើយនោះ ដើម្បីឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បានមើលឃើញច្បាស់ ។

២.១០៦.៧.២ ប្រសិនបើ ប្រធាន គកប កំណត់សន្លឹកឆ្នោតណាមួយ ជាសន្លឹកឆ្នោតមិនបានការ គាត់ត្រូវប្រកាសថា " សន្លឹកឆ្នោតមិនបានការ " រួចដាក់សន្លឹកឆ្នោតនោះ ទៅក្នុងពាំនូកសន្លឹកឆ្នោតមិនបានការ ដែលស្ថិតនៅខាងស្តាំដៃគាត់ ។

២.១០៦.៧.៣ ប្រសិនបើ ប្រធាន គកប កំណត់សន្លឹកឆ្នោតណាមួយ ជាសន្លឹកឆ្នោតបានការ គាត់ត្រូវប្រកាសឱ្យឮៗ នូវឈ្មោះគណបក្សនយោបាយដែលសន្លឹកឆ្នោតនោះ ត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ ហើយត្រូវដាក់សន្លឹកឆ្នោតនោះទៅតាមពាំនូកដោយឡែកសម្រាប់គណបក្សនយោបាយពាក់ព័ន្ធនីមួយៗ។

២.១០៦.៧.៤ ផ្អែកតាមការប្រកាសរបស់ប្រធាន គកស អនុប្រធាន និង លេខាធិការ ត្រូវគូសពិន្ទុមួយ (១) សម្រាប់សន្លឹកឆ្នោតមួយ (១) សន្លឹក ដែលគណបក្សនយោបាយណាមួយត្រូវបាន ទទួល តាមការណែនាំរបស់ គ.ជ.ប នៅលើតារាងកត់ត្រា សំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស) ។ ទន្ទឹម នឹងនេះជំនួយការ ត្រូវប្រើប៊ិចហ្វឺតគូសពិន្ទុមួយ (១) នៅលើ ផ្ទាំងក្រដាសធំ ដែលអាចថ្ពៃប្រឌិតបិទភ្ជាប់នឹងជញ្ជាំង ឬ នៅលើក្ដារខៀន ។

២.១០៦.៧.៥ ក្នុងករណី មានការជំទាស់ចំពោះសន្លឹកឆ្នោត ដែលបាន កំណត់ ដូចចែងក្នុងចំណុច ២.១០៦.៧.៣ ខាងលើ ប្រធាន ត្រូវដាក់សន្លឹកឆ្នោតដែលមានការជំទាស់នោះ ទៅក្នុងពំនូក សន្លឹកឆ្នោតមិនបានការ ដូចចែងក្នុងចំណុច ២.១០៦.៧.២ ខាងលើ ។ សន្លឹកឆ្នោតទាំងនេះនឹងត្រូវ យកមកពិនិត្យផ្ទៀង ផ្ទាត់ និងកំណត់ឡើងវិញម្ដងទៀត ជាចុងក្រោយ ដូចចែង ក្នុងចំណុច ២.១០៦.៧.៦ ខាងក្រោម ។

២.១០៦.៧.៦ នៅពេលផ្ទៀងផ្ទាត់សុពលភាព និងរាប់អស់សន្លឹកឆ្នោតនៅ ក្នុងពំនូកទី ១ រួចហើយ ប្រធាន ត្រូវបន្តយកសន្លឹកឆ្នោត ម្ដងមួយ (១) សន្លឹកៗ ពីពំនូកសន្លឹកឆ្នោតមិនបានការ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ម្ដងទៀតជាចុង ក្រោយ ដើម្បីឱ្យប្រាកដថា ជាសន្លឹកឆ្នោតបានការ ឬមិន បានការ ។

២.១០៦.៧.៧ ប្រសិនបើ ប្រធាន គកស សម្រេចថា ជាសន្លឹកឆ្នោតបានការ វិញ ត្រូវអនុវត្តចំណុច ២.១០៦.៧.៣ និង ២.១០៦.៧.៤ ខាងលើ ។

២.១០៦.៧.៨ ប្រសិនបើ ប្រធាន គកស សម្រេចថា ជាសន្លឹកឆ្នោតមិនបាន ការ គាត់ត្រូវដាក់សន្លឹកឆ្នោតនោះទៅក្នុងពំនូកសន្លឹកឆ្នោតមិន បានការដដែល ។

២.១០៦.៨ ក្នុងអំឡុងពេលនៃការពិនិត្យផ្ទៀងផ្ទាត់ និងកំណត់សន្លឹកឆ្នោត ដូចចែងក្នុង ចំណុច ២.១០៦.៧.១ និង ២.១០៦.៧.៦ ខាងលើ ប្រសិនបើ ប្រធាន គកស

កត់សម្គាល់ឃើញថា សន្លឹកឆ្នោតណាមួយជាសន្លឹកឆ្នោតមិនបានការ ដូចបានកំណត់ក្រោម ប្រការ ២.១០៧ ខាងក្រោម គាត់ត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គកេ ដើម្បីកំណត់ថា សន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតបានការ ឬមិនបានការ ។

២.១០៦.៨.១ ទោះបីប្រធាន គកេ កំណត់ថា ជាសន្លឹកឆ្នោតបានការក្តី ឬមិនបានការក្តី គាត់ត្រូវប្រកាសឱ្យឮៗ អំពីហេតុផលនៃការកំណត់បែបនោះ និងត្រូវអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើល និងចោទសួរអំពីហេតុផលនៃការកំណត់ថា ជាសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការ ។ ក្នុងករណីនេះ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ មិនត្រូវបានអនុញ្ញាតឱ្យកាន់សន្លឹកឆ្នោតនោះឡើយ ។

២.១០៦.៨.២ ប្រសិនបើ តំណាងគណបក្សនយោបាយណាម្នាក់ មិនឯកភាពចំពោះសេចក្តីសម្រេចរបស់ប្រធាន ក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬមិនបានការខាងលើ តំណាងនោះមានសិទ្ធិជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់ រួចត្រូវយល់ព្រមផ្តិតមេដៃក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។ ខ្លឹមសារ និងហេតុផលនៃការជំទាស់នេះ មិនត្រូវបានកត់ត្រាឡើយ ក្នុងករណីអ្នកតំណាងគណបក្សនោះមិនយល់ព្រមផ្តិតមេដៃលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

២.១០៦.៨.៣ សេចក្តីសម្រេចរបស់ប្រធាន គកេ ត្រូវតែមានប្រសិទ្ធភាពក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ។

២.១០៦.៨.៤ ការកំណត់ដូចចែងក្នុងចំណុច ២.១០៦.៨.៣ ខាងលើ មិនបិទផ្លូវប្តឹងជំទាស់ទៅ គធ/ខប ចំពោះការបដិសេធរបស់ប្រធាន គកេ លើការជំទាស់ដូចចែងក្នុងចំណុច ២.១០៦.៨.២ ខាងលើនោះទេ ប៉ុន្តែចំពោះមុខ តំណាងគណបក្សនយោបាយនោះ ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គកេ និងមិនត្រូវជ្រៀតជ្រែកកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតឡើយ ។

២.១០៦.៨.៥ ប្រធានត្រូវផ្តល់ទម្រង់បែបបទលេខ ១២០២ ចំនួនបី (៣) ច្បាប់ ជូនតំណាងគណបក្សនយោបាយ ប្រសិនបើគាត់ស្នើសុំ សម្រាប់បំពេញពាក្យបណ្តឹងទៅ គធ/ខប ។

២.១០៦.៩ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់រួចហើយ ប្រធាន គកស ត្រូវចាត់អនុប្រធាន និងលេខាធិការឱ្យបូកសរុប និងកត់ត្រាចំនួនសន្លឹកឆ្នោតមិនបានការសរុប ចំនួនសន្លឹកឆ្នោតបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស) ព្រមទាំងបង្គាប់ជំនួយការ ឱ្យធ្វើកិច្ចការដូចគ្នានេះ នៅលើផ្ទាំងក្រដាសធំ ដែលបានប្រើសម្រាប់គូសសំឡេងឆ្នោត ។ ទន្ទឹមនេះ នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យរាប់សន្លឹកឆ្នោត ប្រធាន គកស ត្រូវរាប់ចំនួនសន្លឹកឆ្នោតបានការ តាមពំនូកផ្សេងគ្នារបស់គណបក្សនយោបាយនីមួយៗ និងពំនូកសន្លឹកឆ្នោតមិនបានការ ហើយត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញ ជាមួយនឹងតួលេខចំនួនសន្លឹកឆ្នោត ដែលអនុប្រធាន លេខាធិការ និងជំនួយការបានបូកសរុបឃើញខាងលើ ។ ប្រធាន គកស ត្រូវធានាថាតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស) ទាំងពីរ (២) ច្បាប់ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតមួយ (១) ផ្ទាំង ត្រូវបានចុះហត្ថលេខាដោយខ្លួនគាត់ផ្ទាល់ និងលេខាធិការ ។ តំណាងគណបក្សនយោបាយដែលមានវត្តមាន អាចចូលរួមចុះហត្ថលេខាលើទម្រង់បែបបទលេខ ១១០៨ស នេះ ។

២.១០៦.១០ ប្រធាន គកស ត្រូវប្រកាសជាសាធារណៈនូវលទ្ធផលនៃការបូកសរុប និងរាប់ចំនួនសន្លឹកឆ្នោត ដូចចែងក្នុងចំណុច ២.១០៦.៩ ខាងលើ និងត្រូវពិនិត្យផ្ទៀងផ្ទាត់បន្ថែមទៀត ដោយការបូកបញ្ចូលគ្នានូវចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ ជាមួយនឹងចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់ ។

២.១០៦.១០.១ ប្រសិនបើ ផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះស្មើគ្នាទៅនឹងចំនួនសន្លឹកឆ្នោត ដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចចែងក្នុងចំណុច ២.១០៦.៦ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនសន្លឹកឆ្នោត ដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការទៅក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០២ស)។

២.១០៦.១០.២ ប្រសិនបើ ផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះមានចំនួនតិចជាង ឬច្រើនជាងចំនួនសន្លឹកឆ្នោត ដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ ដូចចែងក្នុងចំណុច ២.១០៦.៦ ខាងលើ ប្រធាន ត្រូវរាប់សន្លឹកឆ្នោត ដែលដាក់តាមពំនូកផ្សេងគ្នា សម្រាប់គណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការឡើងវិញម្តងទៀត ។

២.១០៦.១០.៣ ប្រសិនបើ គ្មានព្រឹត្តិការណ៍ណាមួយរំខានដល់ការរាប់សន្លឹកឆ្នោត ឬ/និងគ្មានសន្លឹកឆ្នោតណាមួយ ឬច្រើន ត្រូវបានគេរកឃើញនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដោយសារការធ្លាក់ជ្រុះទេនោះ បន្ទាប់ពី ប្រធាន គករ បានរាប់សន្លឹកឆ្នោតឡើងវិញ ដូចចែងក្នុងចំណុច ២.១០៦.១០.២ ខាងលើរួចហើយ ប៉ុន្តែផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ នៅតែមានភាពខុសគ្នាដដែល ត្រូវសន្មតថា ភាពខុសគ្នានេះបានកើតឡើងមុនជាយថាហេតុ ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នាទាំងនោះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១០២ស) ។

២.១០៦.១១ ប្រធាន គករ ត្រូវធានាថា សន្លឹកឆ្នោតបានការដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ត្រូវបានចងនឹងកៅស៊ូកងឱ្យជាប់ និងដាក់ដោយឡែកពីគ្នា ។

២.១០៦.១២ ប្រធាន គករ ត្រូវធានាថា សន្លឹកឆ្នោតមិនបានការទាំងអស់ត្រូវបានចងនឹងកៅស៊ូកង និងដាក់បញ្ចូលទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្ទង់ថា" សន្លឹកឆ្នោតមិនបានការ " ។

២.១០៦.១៣ ប្រធាន គករ ត្រូវធានាថាសន្លឹកឆ្នោតបានការ ដែលបានចងនឹងកៅស៊ូកង ដូចចែងក្នុងចំណុច ២.១០៦.១១ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ដូចចែងក្នុងចំណុច ២.១០៦.១២ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត ដូចចែងក្នុងចំណុច ២.១០៦.៩ និងស្រោមសំបុត្រដាក់វត្ថុមិនមែនជា

សន្លឹកឆ្នោត (ប្រសិនបើមាន) ដូចចែងក្នុងចំណុច ២.១០៦.៥.១ ខាងលើ ត្រូវបានដាក់រួមគ្នាក្នុងស្បោងផ្លាស្ទិកតែមួយ ដែលមានបោះពុម្ពសម្គាល់ពីខាងក្រៅថា" សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការនៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ការិយាល័យបោះឆ្នោតលេខ... " បន្ទាប់មកត្រូវបិទភ្ជិតមាត់ស្បោងផ្លាស្ទិកនេះ និងត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយប្រើប៊ិចហ្វឺតធំលុបមិនជ្រះនៅលើផ្នែកខាងក្រៅនៃស្បោងផ្លាស្ទិក ដើម្បីត្រៀមបញ្ជូន និងប្រគល់ជូន គធ/ខប ។

២.១០៦.១៤ នៅពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវបានបំពេញរួចរាល់ ប្រធាន គករ ត្រូវចាត់ចែងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ជាបន្តទៀត ដោយអនុវត្តតាមលំនាំនីតិវិធីដូចចែងចាប់ពីចំណុច ២.១០៦.១ ដល់ ២.១០៦.១៣ ខាងលើ និងប្រើទម្រង់បែបបទពណ៌ស ក្នុងនោះមាន ៖

២.១០៦.១៤.១ កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០១ខ) ។

២.១០៦.១៤.២ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០២ខ) ។

២.១០៦.១៤.៣ តារាងកត់ត្រាសំឡេងឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១០៨ខ) ។

**សន្លឹកឆ្នោតបានការ និង សន្លឹកឆ្នោតមិនបានការ**

**ប្រការ** ២.១០៧ ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គករ ជាពិសេសប្រធាន និងអនុប្រធាន គករ ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

២.១០៧.១ សន្លឹកឆ្នោតបានការគឺជាសន្លឹកឆ្នោតផ្លូវការដែលបានផ្ដល់ជូនដោយ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅតាមការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌនីមួយៗ ដែលសន្លឹកឆ្នោតពណ៌ស ជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងសន្លឹកឆ្នោតប្រភេទពណ៌ជាសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ

នៅផ្នែកខាងក្នុង ហើយដែលនៅលើសន្លឹកឆ្នោតនោះ អ្នកបោះឆ្នោតបានបញ្ជាក់យ៉ាងច្បាស់ពីឆន្ទៈរបស់ខ្លួន ដោយមានគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយដែលគាត់ពេញចិត្ត ។

២.១០៧.២ សន្លឹកឆ្នោតមិនបានការ គឺជាសន្លឹកឆ្នោតដែលត្រូវចាត់ទុកជាមោឃៈ ដែលក្នុងនោះរួមមានសន្លឹកឆ្នោតដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ ដូចចែងក្នុងចំណុច ២.១០៧.១ ឬគ្មានគំនូស ឬមានគំនូស ប៉ុន្តែ គករ ពុំអាចសន្និដ្ឋានថា បោះឱ្យគណបក្សនយោបាយណាមួយ ឬមានសញ្ញាដែលនាំឱ្យគេស្គាល់ពីអត្តសញ្ញាណអ្នកបោះឆ្នោត ឬរហែក ឬខូច ឬគ្មានបោះត្រាសម្ងាត់ជាផ្លូវការ ។ សន្លឹកឆ្នោតមិនបានការ រួមមាន ប្រាំ (៥) ប្រភេទ ដូចខាងក្រោម ៖

**១_ សន្លឹកឆ្នោតក្លែងបន្លំ ដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ**

២.១០៧.២.១ សន្លឹកឆ្នោតមានខ្នាតតូចជាង ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។

២.១០៧.២.២ សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាសជាង ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។

២.១០៧.២.៣ សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។

២.១០៧.២.៤ សន្លឹកឆ្នោត ដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើន ដែលបានឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ នៅតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ។

២.១០៧.២.៥ សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយ លើសពីចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សតាមប្រភេទនីមួយៗ នៅតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ។

២.១០៧.២.៦ សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ សម្រាប់មណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ។

២.១០៧.២.៧ សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយ ដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេង មិនដូចសន្លឹកឆ្នោត ដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យ គកប ពាក់ព័ន្ធ ។

**២_ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូស ដែល គកប ពុំអាចសន្និដ្ឋានថា បោះគាំទ្រឱ្យគណបក្សនយោបាយណាមួយ**

២.១០៧.២.៨ សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ) ។

២.១០៧.២.៩ សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយលើសពីមួយគណបក្ស ។

២.១០៧.២.១០ សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើន នៅក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយក៏ដោយ ។

**៣_ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ នាំឱ្យគេស្គាល់អ្នកបោះឆ្នោត**

២.១០៧.២.១១ សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្ទៃកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។

២.១០៧.២.១២ សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះនៅក្នុង ឬក្រៅប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្ទៃកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។

២.១០៧.២.១៣ សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ ភ្ជាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬនៅលើផ្ទៃកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។

២.១០៧.២.១៤ សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្វាស់ជាប់ជាមួយ ។

២.១០៧.២.១៥ សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត ។

**៤_ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច**

២.១០៧.២.១៦ សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បួនជ្រុង ទ្រវែងនៃគណបក្សនយោបាយណាមួយ ។

២.១០៧.២.១៧ សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង ។

២.១០៧.២.១៨ សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅផ្នែកខាងមុខ ឬ/និង ផ្នែកខាងខ្នង ដែលមិនអាចមើលឃើញនូវរូបសញ្ញា និង អក្សរ ដែលត្រូវបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និង គំនូសសញ្ញា ដែលបោះគាំទ្រគណបក្សនយោបាយណា មួយ ។

**៥_ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការ នៃការិយាល័យបោះឆ្នោត ពាក់ព័ន្ធ**

២.១០៧.២.១៩ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការ នៃការិយាល័យ បោះឆ្នោតពាក់ព័ន្ធ ។

២.១០៧.២.២០ សន្លឹកឆ្នោតមានបោះត្រា ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការ នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

**ការរៀបចំ និងការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារឯកសារ បោះឆ្នោតពាក់ព័ន្ធ**

**ប្រការ ២.១០៨** នៅពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដូចចែងក្រោមប្រការ ២.១០៦ ខាងលើ ត្រូវបានបំពេញរួចរាល់ ប្រធាន គករ ត្រូវធានាថា តារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស) ចំនួនពីរ (២) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ស) ចំនួនបួន (៤) ច្បាប់ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ខ) ចំនួនពីរ (២) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ខ) ចំនួនបួន (៤) ច្បាប់ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ដែលបានបំពេញត្រឹមត្រូវ រួចហើយ ត្រូវបានចុះហត្ថលេខា ដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់ ព្រមទាំងបោះត្រា ។ ប្រធាន គករ ត្រូវចាត់ចែងវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន ព្រមទាំងរាល់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ដើម្បីបញ្ជូនទៅ គធ/ខប ។

២.១០៨.១ ប្រធាន គករ ត្រូវបង្ហាញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ដូចបានចែង

ក្នុងប្រការ ២.១០៨ ខាងលើ ឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បានឃើញ និងបានដឹង ព្រមទាំងអញ្ជើញតំណាងគណបក្សនយោបាយឱ្យចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី ។

២.១០៨.១.១ តំណាងគណបក្សនយោបាយអាចចុះហត្ថលេខា ឬផ្តិតមេដៃ ជាសាក្សីលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតខាងលើ ។

២.១០៨.១.២ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី លើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតពីតំណាងគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានឡើយ ។

២.១០៨.២ ប្រធាន គករ ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ស ឬ ១១០២ខ) និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស ឬ ១១០៨ខ) ដូចចែងក្នុងប្រការ ២.១០៨ ដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្ទង់ថា " ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតារាងកត់ត្រាសំឡេងឆ្នោត ផ្ញើជូន គ.ជ.ប " ឬស្រោមសំបុត្រដែលមានកាខ្ទង់ថា " ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងតារាងកត់ត្រាសំឡេងឆ្នោត ផ្ញើជូន គ.ជ.ប " បន្ទាប់មក ត្រូវរៀបចំវេចខ្ចប់រាល់ស្រោមសំបុត្រ ឬស្បោងផ្លាស្ទិកដាក់សម្ភារឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដូចក្នុងចំណុច ២.១០៨.៦ និង ២.១០៨.៧ ដែលកញ្ចប់សុវត្ថិភាព " ក$_{ស}$ " សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រីឯកញ្ចប់សុវត្ថិភាព " ក$_{ខ}$ " សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយត្រូវបិទភ្ជិតដោយការសុវត្ថិភាពដែលបម្រុងស្រាប់ និងបំពេញលេខកូដការិយាល័យនោះឱ្យបានត្រឹមត្រូវ ។

២.១០៨.៣ ប្រធាន គករ ត្រូវធានាថានៅក្នុងកញ្ចប់សុវត្ថិភាព " ក$_{ស}$" មានសម្ភារ ឯកសារដូចខាងក្រោម ៖

២.១០៨.៣.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គ.ជ.ប ។

២.១០៨.៣.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោត ដែលបានប្រើក្នុងការបោះឆ្នោត និងក្រដាសព័ត៌មាន ដូចចែងក្នុងចំណុច ២.១០៣.២៩ ។

២.១០៨.៣.៣ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។

២.១០៨.៣.៤ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៨.៣.៥ ស្បោងផ្លាស្ទិក ឬស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៨.៣.៦ ស្រោមសំបុត្រដាក់ឯកសារភស្តុតាង ដែលបានដកហូត (ប្រសិនបើមាន) ។

២.១០៨.៣.៧ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវ ដែលបានដកហូត (ប្រសិនបើមាន) ។

២.១០៨.៣.៨ ស្បោងផ្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ។

២.១០៨.៤ ប្រធាន គកប ត្រូវធានាថា នៅក្នុងកញ្ចប់សុវត្ថិភាព " ក₂ " មានសម្ភារឯកសារដូចខាងក្រោម ៖

២.១០៨.៤.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គ.ជ.ប ។

២.១០៨.៤.២ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។

២.១០៨.៤.៣ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " នៃក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៨.៤.៤ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវ ដែលបានដកហូត (ប្រសិនបើមាន) ។

២.១០៨.៤.៥ ស្បោងផ្លាស្ទិក ឬស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " នៃក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៨.៤.៦ ស្បោងផ្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត នៃក្រុមប្រឹក្សារាជធានី ខេត្ត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ។

២.១០៨.៥ ប្រធាន គកខ ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ស ឬ ១១០២ខ) និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស ឬ ១១០៨ខ) មួយ (១) ច្បាប់ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលមានកាខ្ទង់ថា " កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ផ្ញើជូន គធ/ខប " ឬ " កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ផ្ញើជូន គធ/ខប " ដូចចែងក្នុងចំណុច ២.១០៨.៤.៣ និង ២.១០៨.៤.៤ ។

២.១០៨.៦ ប្រធាន គកខ ត្រូវចាត់ចែងសមាជិក គកខ ឱ្យបំពេញក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ (ទម្រង់បែបបទលេខ ១១០៩ស ឬ ១១០៩ខ) ដោយស្រង់តួលេខលទ្ធផលចេញពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ស ឬ ១១០២ខ) រួចចុះហត្ថលេខា និងបោះត្រា សម្រាប់ចែកជូនតំណាងគណបក្សនយោបាយ ។ ក្នុងការបំពេញក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ (ទម្រង់បែបបទលេខ ១១០៩ស ឬ ១១០៩ខ) ប្រធាន គកខ ត្រូវណែនាំសមាជិក គកខ ឱ្យហែកទម្រង់នេះម្ដងចំនួនបី (៣) ច្បាប់ ចេញពីដុំធំរួចសិន មុននឹងសរសេរបំពេញ ដើម្បីជៀសវាងការមានស្នាមជាមក្នុងសន្លឹកបន្ទាប់ទៀតដែលមិនទាន់ត្រូវបានសរសេរ ។

២.១០៨.៧ ប្រធាន គកក ត្រូវចាត់ជំនួយការ ឱ្យបិទផ្សាយជាសាធារណៈ នូវកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ស និង ១១០២ខ) មួយ (១) ច្បាប់ៗ តាមប្រភេទក្រុមប្រឹក្សានីមួយៗ នៅការិយាល័យបោះឆ្នោត ។

២.១០៨.៨ ប្រធាន គកក ត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ (ទម្រង់បែបបទលេខ ១១០៧) ចំនួនបី (៣) ច្បាប់ ត្រូវបានបំពេញលំអិតមុខសម្ភារឯកសារបោះឆ្នោត ដោយលេខាធិការ និងចុះហត្ថលេខាដោយប្រធានផ្ទាល់ សម្រាប់ប្រើក្នុងការបញ្ជូន និងប្រគល់ទទួលកញ្ចប់ " ខ" នៅ គឃ/ខប ដែលកញ្ចប់ " ខស " សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រីឯកញ្ចប់សុវត្ថិភាព " ខខ " សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត និងត្រូវ ៖

២.១០៨.៨.១ ដាក់មួយ (១) ច្បាប់ក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុងកញ្ចប់ " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១០៨.៨.២ ដាក់មួយ (១) ច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១០៨.៨.៣ រក្សាទុកមួយ (១) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ទទួលកញ្ចប់ " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ នៅ គឃ/ខប។

២.១០៨.៩ ប្រធាន គកក ត្រូវធានាថា សម្ភារឯកសារបោះឆ្នោតដូចខាងក្រោម ត្រូវបានវេចខ្ចប់ដាក់ក្នុងកញ្ចប់ " ខស " ឬ កញ្ចប់ " ខខ " ដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដើម្បីបញ្ជូនទៅ គឃ/ខប ៖

២.១០៨.៩.១ កញ្ចប់សុវត្ថិភាព " កស " ឬ " កខ " ដាក់សម្ភារឯកសារ ដូចចែងក្រោមចំណុច ២.១០៨.៣ និង ២.១០៨.៤ ។

២.១០៨.៩.២ ស្រោមសំបុត្រដាក់កំណត់ហេតុ នៃការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ។

២.១០៨.៩.៣ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ផ្ញើជូន គឃ/ខប ដូចចែងក្នុងចំណុច ២.១០៨.៥ ។

២.១០៨.៩.៤ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) មួយ (១) ច្បាប់ ដូចចែងក្នុងចំណុច ២.១០៨.៨.១ ។

២.១០៨.៩.៥ ស្រោមសំបុត្រតូចដាក់ត្រាការិយាល័យបោះឆ្នោត (ដាក់ក្រោយពេលបានបោះត្រាលើទម្រង់បែបបទលេខ ១១០៧ រួចរាល់ហើយ) ដែលត្រូវដាក់ក្នុងកញ្ចប់ " ខ$_{ស}$ " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៨.១០ ប្រធាន គករ ត្រូវធានាថា កញ្ចប់ " ខ" នៃប្រភេទក្រុមប្រឹក្សានីមួយៗ ដែលផ្ទុកសម្ភារ ឯកសារបោះឆ្នោត ដូចមានចែងក្រោមចំណុច ២.១០៨.៩ ខាងលើត្រូវបានចងភ្ជិត ចាក់សោឃ្លុំមានលេខ និងសរសេរលេខកូដការិយាល័យបោះឆ្នោតឱ្យបានត្រឹមត្រូវ ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ ។

២.១០៨.១១ ប្រធាន គករ ត្រូវអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានសង្កេតមើលការរៀបចំ និងវេចខ្ចប់សម្ភារឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ គធ/ខប និងបានកត់ត្រាលេខសោឃ្លុំ ដែលបានចាក់ភ្ជិតមាត់កញ្ចប់" ខ" ដូចចែងក្នុងចំណុច ២.១០៨.១០ ខាងលើ ។

២.១០៨.១២ ប្រធាន គករ ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់សម្ភារឯកសារបោះឆ្នោតនៅសល់ដែលតម្រូវឱ្យផ្ញើជូន គ.ជ.ប វិញ ដូចជា ហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី ទឹកខ្មៅលុបលាងមិនជ្រះ (ដែលត្រូវវេចខ្ចប់ដោយឡែក) ស្លាកសញ្ញាការិយាល័យបោះឆ្នោត ជាដើម និងត្រូវបញ្ជូន និងប្រគល់សម្ភារ ឯកសារបោះឆ្នោតទាំងនោះជូន គធ/ខប ទន្ទឹមគ្នានឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។ ប្រធានគករត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារ (ទម្រង់បែបបទលេខ ១១០៧) ចំនួនពីរ (២) ច្បាប់ ត្រូវបានបំពេញលំអិតមុខសម្ភារ ឯកសារនៅសល់ទាំងនោះ សម្រាប់ប្រើក្នុងពេលប្រគល់ទទួលនៅ គធ/ខប ។

**ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារឯកសារបោះឆ្នោតនៅសល់ទៅ គធ/ខប**

**ប្រការ** ២.១០៩ បន្ទាប់ពីបានធ្វើការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត រួចសព្វគ្រប់

ហើយ ប្រធាន គកក ត្រូវចាត់វិធានការចាំបាច់ទាំងឡាយ ក្នុងការបញ្ជូនជាបន្ទាន់នូវកញ្ចប់ " ខ " ដូចចែងក្នុងចំណុច ២.១០៨.១០ និងសម្ភារឯកសារបោះឆ្នោតនៅសល់ ដូចចែងក្នុងចំណុច ២.១០៨.១២ ខាងលើ ឱ្យបានទៅដល់ គឃ/ខប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត ។

២.១០៩.១ ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលា និងសភាពការណ៍សន្តិសុខ ប្រសិនបើ ប្រធាន គកក យល់ថាអាចនឹងបញ្ជូនកញ្ចប់ " ខ " និង សម្ភារឯកសារ ដូចចែងក្នុងប្រការ ២.១០៩ ខាងលើ ទៅ គឃ/ខប បានតាមពេលវេលាកំណត់ និងធានាបាននូវសុវត្ថិភាពនោះ គាត់ត្រូវអញ្ជើញតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានាឱ្យចូលរួមក្នុងការបញ្ជូនខាងលើ និងត្រូវជូនដំណឹងអំពីពេលវេលានៃការចេញដំណើរ ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ ទទួលកញ្ចប់ " ខ " និងសម្ភារឯកសារបោះឆ្នោតទាំងនោះនៅ គឃ/ខប ។

២.១០៩.២ ប្រធាន គកក ដែលអមដំណើរដោយអនុប្រធាន ត្រូវទទួលខុសត្រូវក្នុងការដឹកជញ្ជូនដោយផ្ទាល់នូវកញ្ចប់ " ខ " និងសម្ភារឯកសារ ដូចចែងក្នុងប្រការ ២.១០៩ ទៅ គឃ/ខប ។ ប្រធាន ត្រូវចាត់សមាជិក គកក តាមការចាំបាច់ ដើម្បីជួយដឹកជញ្ជូនឱ្យអស់សម្ភារឯកសារនៅសល់ផ្សេងទៀត ។

២.១០៩.៣ ប្រសិនបើចាំបាច់ប្រធាន គកក ត្រូវស្នើសុំកម្លាំងសន្តិសុខពីរ (២) រូប ដើម្បីអមដំណើរការដឹកជញ្ជូនកញ្ចប់ " ខ " និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គឃ/ខប ។

២.១០៩.៤ នៅពេល ទទួលកញ្ចប់ " ខ " និងសម្ភារ ឯកសារ ដូចចែងក្នុងប្រការ ២.១០៩ ខាងលើ គឃ/ខប ត្រូវធានាថា បានត្រួតពិនិត្យរាល់សម្ភារ ឯកសារទាំងអស់ និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) បញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ ។ ដោយឡែកក្នុងការប្រគល់ ទទួលកញ្ចប់ " ខ" គឃ/ខប ត្រូវ ៖

២.១០៩.៤.១ បើកកញ្ចប់ " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដើម្បីត្រួតពិនិត្យសម្ភារឯកសារបោះឆ្នោតខាងក្នុង ដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ ទទួល (ទម្រង់បែបបទលេខ ១១០៧) ទាំងបី (៣) ច្បាប់ ប៉ុន្តែមិនត្រូវរុះរើកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធឡើយ ។

២.១០៩.៤.២ ចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលទាំងបី (៣) ច្បាប់ បន្ទាប់ពីបានត្រួតពិនិត្យត្រឹមត្រូវហើយ ។

២.១០៩.៤.៣ អញ្ជើញតំណាងគណបក្សនយោបាយ ចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើលិខិតបញ្ជូន និងប្រគល់ទទួលនេះ ។ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃរបស់តំណាងគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវលិខិតបញ្ជូន និងប្រគល់ ទទួលនេះបានទេ ។

២.១០៩.៤.៤ ប្រគល់លិខិតបញ្ជូន និងប្រគល់ទទួល ដែលចុះហត្ថលេខារួច មួយ (១) ច្បាប់ ជូនប្រធាន គកស ពាក់ព័ន្ធ ដាក់មួយ (១) ច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ខ" វិញ និងរក្សាទុកមួយ (១) ច្បាប់ ជាឯកសារ ។

២.១០៩.៥ រាល់កញ្ចប់ " ខ " ដែល គឃ/ខប បានទទួលខាងលើ ត្រូវតែបានកត់ចំណាំ និងរក្សាទុកនៅកន្លែងមានសុវត្ថិភាព ដោយដាក់តាមលំដាប់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងតាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១០៩.៦ គឃ/ខប ត្រូវចាត់វិធានការយ៉ាងម៉ត់ចត់ ក្នុងការការពារសន្តិសុខ និងសុវត្ថិភាពនៃបន្ទប់រក្សាទុកកញ្ចប់ " ខ" ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារឯកសារបោះឆ្នោតផ្សេងទៀត និងត្រូវចាត់ចែងឱ្យមានកំលាំងសន្តិសុខយាមការពារបរិវេណលេខាធិការដ្ឋាននៃ គឃ/ខប ឬអាគារដែលត្រូវរក្សាទុកកញ្ចប់ " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារឯកសារបោះឆ្នោតទាំងនោះផង ។

២.១០៩.៦.១ ទំនាក់ទំនងស្នើសុំកម្លាំងសន្តិសុខ ដើម្បីយាមការពារបរិវេណលេខាធិការដ្ឋាន គឃ/ខប ឬអាគារដែលត្រូវរក្សាទុកកញ្ចប់ " ខ " និងសម្ភារឯកសារបោះឆ្នោត ។

២.១០៩.៦.២ ចាត់ចែងឱ្យមានភ្លើងបំភ្លឺ នៅលេខាធិការដ្ឋាន គឃ/ខប ឬអាគារដែលត្រូវរក្សាទុកកញ្ចប់" ខ" និងសម្ភារ ឯកសារបោះឆ្នោត ។

២.១០៩.៧ ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលា និង សភាពការណ៍សន្តិសុខ ប្រសិនបើ ប្រធាន គកស យល់ថា មិនអាចបញ្ជូន កញ្ចប់ " ខ " និងសម្ភារឯកសារ ដូចចែងក្នុងប្រការ ២.១០៩ ខាងលើ ទៅ គធ/ខប នៅវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត បានទេនោះ គាត់ត្រូវចាត់វិធានការថែរក្សាការពារកញ្ចប់ " ខ " និងសម្ភារឯកសារបោះឆ្នោតទាំងនោះ នៅទីតាំងសុវត្ថិភាពណាមួយ ដោយត្រូវផ្តល់ព័ត៌មានអំពីបញ្ហានេះ ដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធ ។

២.១០៩.៧.១ ប្រធាន គកស ត្រូវថែរក្សាការពារកញ្ចប់ " ខ " និង សម្ភារ ឯកសារបោះឆ្នោតខាងលើ នៅផ្ទះរបស់គាត់ ឬ ផ្ទះរបស់សមាជិកណាម្នាក់នៃ គកស ឬនៅទីតាំងសុវត្ថិភាព ណាមួយដែលបានកំណត់ ។

២.១០៩.៧.២ ប្រធាន គកស ត្រូវប្រាប់ដល់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ឱ្យបានដឹងអំពីផ្ទះ ឬទីតាំងសុវត្ថិភាព ដែលនឹងត្រូវរក្សាទុកកញ្ចប់ " ខ " និងសម្ភារ ឯកសារ បោះឆ្នោតខាងលើ ហើយត្រូវអញ្ជើញតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យចូលរួមថែរក្សាការពារ ។ ទន្ទឹមនឹងនេះ ត្រូវជូនដំណឹងអំពីពេលវេលានៃការ ចេញដំណើរទៅលេខាធិការដ្ឋាន គធ/ខប នៅព្រឹកស្អែក ដើម្បីប្រគល់ ទទួលកញ្ចប់ " ខ " និងសម្ភារ ឯកសារ បោះឆ្នោតទាំងនោះ ។

២.១០៩.៧.៣ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា អាចស្នាក់នៅពេលយប់ នៅផ្ទះ ឬទីតាំងសុវត្ថិភាព ដែល ទទួលរក្សាការពារកញ្ចប់ " ខ " និងសម្ភារឯកសារ បោះឆ្នោត ។

២.១០៩.៧.៤ ប្រធាន ត្រូវចាត់សមាជិក គកស យ៉ាងហោចណាស់បី (៣) នាក់ គិតទាំងរូបគាត់ផង ឱ្យចូលរួមក្នុងការរក្សាការពារកញ្ចប់ " ខ " និងសម្ភារឯកសារបោះឆ្នោតទាំងនោះ ។

២.១០៩.៧.៥ ប្រធាន គកស មិនត្រូវទុកកញ្ចប់ " ខ " និងសម្ភារ ឯកសារបោះឆ្នោតចោល ដោយគ្មានការឃាមកាមទេ ។

២.១០៩.៧.៦ ប្រសិនបើចាំបាច់ ប្រធាន គកស ត្រូវស្នើសុំកម្លាំងសន្តិសុខ

ពីរ (២) នាក់ ដើម្បីយាមការពារបរិវេណផ្ទះ ឬទីតាំង ដែលរក្សាទុកកញ្ចប់ " ខ " និងសម្ភារ ឯកសារបោះឆ្នោត នៅពេលយប់ ។

២.១០៩.៧.៧ នៅព្រឹកថ្ងៃបន្ទាប់ ប្រធាន គករ ត្រូវទទួលបន្ទុកក្នុងការបញ្ជូនកញ្ចប់ " ខ " និងសម្ភារ ឯកសារបោះឆ្នោត នៅសល់ផ្សេងទៀត តាមពេលវេលាកំណត់ទៅ គឃ/ខប ។ ក្នុងករណីនេះ ប.ន.ក ចាប់ពីចំណុច ២.១០៩.២ ដល់ ២.១០៩.៥ ខាងលើ ត្រូវតែបានអនុវត្ត ។

**ការរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាននៃ គឃ/ខប ឬទីកន្លែងមានសុវត្ថិភាពដែលកំណត់ដោយ គ.ជ.ប**

**ប្រការ** ២.១១០ ចំពោះការិយាល័យបោះឆ្នោតនៃក្រុង ស្រុក ខណ្ឌណាមួយ ស្ថិតក្នុងស្ថានភាព ដូចចែងក្នុងប្រការ ២.១០៥ ខាងលើ គ.ជ.ប ត្រូវណែនាំដល់ គឃ/ខប ពាក់ព័ន្ធឱ្យចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ នៅលេខាធិការដ្ឋាន គឃ/ខប ឬនៅទីតាំងសុវត្ថិភាពណាមួយ ។

២.១១០.១ ករណីកាលៈទេសៈមានអាសន្ន ត្រូវបានកំណត់ ដូចចែងក្រោមចំណុច ២.១២២.១ នៃ ប.ន.ក នេះ ។

២.១១០.២ ក្នុងការរៀបចំវេចខ្ចប់សម្ភារឯកសារបោះឆ្នោត នីតិវិធីដូចចែងក្រោមប្រការ ២.១០៤ នៃ ប.ន.ក នេះ ត្រូវតែបានអនុវត្ត ។

២.១១០.៣ ប្រធាន គកប ត្រូវចាត់ចែងបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) ចំនួនពីរ (២) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ទទួលនៅ គឃ/ខប ។

២.១១០.៤ ប្រធាន ដែលអមដំណើរដោយអនុប្រធាន និងសមាជិក គកប មួយចំនួនទៀត ត្រូវទទួលបន្ទុកក្នុងការបញ្ជូន និងប្រគល់ទទួលនេះដោយផ្ទាល់ ព្រមទាំងត្រូវអញ្ជើញតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលរួម ហើយក្នុងការដឹកជញ្ជូននេះ ត្រូវស្នើសុំកម្លាំងសន្តិសុខពីរ (២) នាក់ឱ្យជួយការពារផង ។

២.១១០.៥ នៅពេលទទួលហិបឆ្នោត ដែលមានសន្លឹកឆ្នោតនៅខាងក្នុង កញ្ចប់ " ខ " និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើ ប្រធាន គឃ/ខប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលទាំងពីរ (២) ច្បាប់ រួចប្រគល់ជូនប្រធាន គកប វិញមួយ (១) ច្បាប់ ។

២.១១០.៥.១ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតខាងលើ ។

២.១១០.៥.២ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃពីតំណាងគណបក្សនយោបាយ មិនអាចធ្វើមោឃភាពលិខិតបញ្ជូន និងប្រគល់ទទួលនេះបានទេ ។

២.១១០.៦ បន្ទាប់ពីបានទទួលហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងកញ្ចប់" ខ" នៃការិយាល័យបោះឆ្នោត ដែលមិនអាចរាប់សន្លឹកឆ្នោតនៅនឹងកន្លែងបាន ដោយករណីកាលៈទេសៈមានអាសន្ន ភ្លាម គធ/ខប ពាក់ព័ន្ធ ត្រូវរក្សាទុកនៅកន្លែងមានសុវត្ថិភាព និងត្រូវជូនដំណឹងដល់សមាសភាព គកប នោះដែលនឹងក្លាយជា គករ នៅពេលរាប់សន្លឹកឆ្នោត ឱ្យមកកាន់លេខាធិការដ្ឋាន គធ/ខប នៅវេលាម៉ោងប្រាំពីរ (៧:០០) ព្រឹក នៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដើម្បីរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតរបស់ខ្លួន ។

២.១១០.៦.១ គធ/ខប អាចចាត់ចែងសមាសភាព គករ ផ្សេង ឬសមាជិក គធ/ខប ឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ប្រសិនបើ សមាសភាព គករ នោះ អវត្តមាន ។

២.១១០.៦.២ សមាសភាព គករ ដែលត្រូវបំពេញភារកិច្ចរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាន គធ/ខប ត្រូវតែបានទទួលប្រាក់ឧបត្ថម្ភ សម្រាប់ការធ្វើដំណើរ និងអាហារក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនោះ ។

២.១១០.៧ តាមពេលវេលាដូចចែងក្នុងចំណុច ២.១១០.៦ ខាងលើ គធ/ខប ត្រូវចាត់ចែងការរាប់សន្លឹកឆ្នោត នៃការិយាល័យបោះឆ្នោត ដែលជួបករណីកាលៈទេសៈមានអាសន្ន ដូចបញ្ជាក់ក្នុងចំណុច ២.១១០.១ ។

២.១១០.៨ នៅពេលសមាសភាព គករ ឬមន្ត្រីបោះឆ្នោត ដែលទទួលភារកិច្ចរាប់សន្លឹកឆ្នោត មានវត្តមាននៅបន្ទប់រាប់សន្លឹកឆ្នោតហើយ ប្រធាន គធ/ខប ត្រូវប្រគល់ហិបឆ្នោត សម្រាប់ការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងកញ្ចប់ " ខ "

តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលមានកញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុនៃការបោះឆ្នោតពាក់ព័ន្ធ ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀតឱ្យទៅ ប្រធាន គកស ដើម្បីអនុវត្តការរាប់សន្លឹកឆ្នោត ។ ប្រធាន គកស ត្រូវ ៖

២.១១០.៨.១ ចាត់ចែងអនុវត្តការរាប់សន្លឹកឆ្នោត ដោយឡែកពីគ្នាតាមប្រភេទក្រុមប្រឹក្សានីមួយៗ ដោយចាប់ផ្ដើមពីការរាប់សន្លឹកឆ្នោត ដែលបានបោះសម្រាប់ការជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាមុន បន្ទាប់មកទើបអនុវត្តការរាប់សន្លឹកឆ្នោត ដែលបានបោះសម្រាប់ការជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ជាក្រោយ ។

២.១១០.៨.២ ពិនិត្យដើម្បីឱ្យប្រាកដថា ហិបឆ្នោតមានសន្លឹកឆ្នោតនៅខាងក្នុង និងកញ្ចប់ " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលបានទទួល ពុំត្រូវបានគេរុះរើឡើយ ។

២.១១០.៨.៣ កាត់ផ្ដាច់សោឃ្លុំកញ្ចប់ " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតខាងក្នុង ដោយផ្ទៀងផ្ទាត់ទៅនឹងលិខិតបញ្ជូន និងប្រគល់ទទួល (ទម្រង់បែបបទលេខ ១១០៧) ។

២.១១០.៩ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតខាងលើ ទាំងការរាប់សន្លឹកឆ្នោត ដែលបានបោះសម្រាប់ការជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទាំងការរាប់សន្លឹកឆ្នោត ដែលបានបោះសម្រាប់ការជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវអនុវត្តតាមនីតិវិធីដូចបានចែងក្រោមប្រការ ២.១០៦ ២.១០៧ ២.១០៨ និង ២.១០៩ នៃ ប.ន.ក នេះ ។ ដោយសារការរាប់សន្លឹកឆ្នោតនេះ ត្រូវបានធ្វើនៅលេខាធិការដ្ឋាន គធ/ខប ឬនៅទីតាំងដែលមានសុវត្ថិភាព នីតិវិធីពាក់ព័ន្ធមួយចំនួនដូចខាងក្រោមត្រូវបានកំណត់ឱ្យអនុវត្តដោយឡែក ដែលក្នុងនោះ ប្រធាន គកស ត្រូវ ៖

២.១១០.៩.១ ទទួលខុសត្រូវនាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ស និង ១១០២ខ) មួយ (១) ច្បាប់ៗ ទៅបិទផ្សាយជាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.១១០.៩.២ ធានាថា បន្ទាប់ពីការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ រាល់សម្ភារ ឯកសារបោះឆ្នោតត្រូវបានវេចខ្ចប់ក្នុងស្បោងផ្លាស្ទិក ឬ/និងស្រោមសំបុត្រ នឹងដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព "កស" ឬ "ក១" តាមប្រភេទក្រុមប្រឹក្សានីមួយៗ រួចបិទភ្ជិតដោយការសុវត្ថិភាពបម្រុងស្រាប់ ។ បន្ទាប់មក ខ្ចប់កញ្ចប់ "ខ" ទាំងនោះត្រូវបានវេចជាថ្មី ដោយដាក់សម្ភារ ឯកសារតាម លំនាំដូចចែងក្នុងចំណុច ២.១០៨.៩ ខាងលើ ហើយ ត្រូវប្រគល់ជូន គធ/ខប ដោយផ្ទាល់ នៅបន្ទប់រាប់សន្លឹកឆ្នោតនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

២.១១០.៩.៣ ប្រគល់ហិបឆ្នោតទទេជូន គធ/ខប ។

២.១១០.៩.៤ ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារ (ទម្រង់បែបបទលេខ ១១០៧) ត្រូវបានបំពេញ និងប្រើប្រាស់ក្នុងការប្រគល់ ទទួលស្របតាមការកំណត់របស់ គ.ជ.ប ។

**ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬ/និង រាជធានី ខេត្ត ទៅ គធ/ខប**

**ប្រការ ២.១១១** ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬតំណាងគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ដែលមិនសុខចិត្តនឹងការសម្រេចរបស់ប្រធាន គកប ពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ដូចចែងក្រោមចំណុច ២.១០៣.២៣ និងរាប់សន្លឹកឆ្នោត ដូចចែងក្រោមចំណុច ២.១០៦.៨ និងចំណុច ២.១១០.៩ ខាងលើ ឬជំទាស់នឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬ/និងរាជធានី ខេត្ត អាចបំពេញទម្រង់បែបបទសម្រាប់ប្តឹងទៅ គធ/ខប ។ ការដាក់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលពីរ (២) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចរបស់ គកប ឬថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។ គធ/ខប ត្រូវដោះស្រាយបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ទាំងនោះ ក្នុងរយៈពេលបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលបណ្តឹង ។ ប្រសិនបើ នៅក្នុងរយៈពេលដែលបានកំណត់ខាងលើនេះ គធ/ខប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ណាមួយទេ ចាត់ទុកថា គ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់ ពាក់ព័ន្ធនឹងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ឬលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ។

២.១១១.១ តំណាងគណបក្សនយោបាយដែលមានបំណងប្តឹង ត្រូវបំពេញ និងផ្តិតមេដៃលើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ (ទម្រង់បែបបទលេខ ១២០២) ចំនួន បី (៣) ច្បាប់ ដែលក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចខាងក្រោម ៖

២.១១១.១.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកតំណាង ។

២.១១១.១.២ កម្មវត្ថុនៃបណ្តឹង ។

២.១១១.១.៣ ប្រភេទនៃអំពើល្មើស ។

២.១១១.១.៤ ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង ។

២.១១១.១.៥ បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោត ដែលត្រូវបានរំលោភ ។

២.១១១.១.៦ អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ។

២.១១១.១.៧ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន ។

២.១១១.១.៨ ភ័ស្តុតាងផ្សេងៗទៀត បើមាន ។

២.១១១.២ ចំពោះពាក្យបណ្តឹង ដែលបានទទួលក្រោយរយៈពេលកំណត់ ដូចចែងក្នុងប្រការ ២.១១១ ខាងលើ ប្រធាន គធ/ខប ឬតំណាងទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ចុះពេលវេលា និងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ ចុះហត្ថលេខា និងបោះត្រាលើពាក្យបណ្តឹង ហើយប្រគល់ឱ្យអ្នកប្តឹងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ។

២.១១១.៣ ចំពោះពាក្យបណ្តឹង មិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិកដែលទទួលសិទ្ធិ ត្រូវណែនាំអ្នកប្តឹង ឬអ្នកតំណាង ឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹងមិនបានបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ/ខប ឬសមាជិកដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹងមួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១១១.៤ ចំពោះពាក្យបណ្ដឹង ដែលបានទទួលក្នុងរយៈពេលកំណត់ និងមានព័ត៌មានបញ្ជាក់គ្រប់គ្រាន់ ដូចចែងក្នុងប្រការ ២.១១១ ខាងលើ មន្ត្រីទទួលពាក្យបណ្ដឹងនៃ គធ/ខប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្ដឹង និងបំពេញពេលវេលា កាលបរិច្ឆេទ និងទីកន្លែងដែល គធ/ខប នឹងត្រូវដោះស្រាយពាក្យបណ្ដឹង រួចប្រគល់ជូនអ្នកប្ដឹងវិញមួយ (១) ច្បាប់ បិទផ្សាយជាសាធារណៈនៅ គធ/ខប មួយ (១) ច្បាប់ និងទុកមួយ (១) ច្បាប់ សម្រាប់ គធ/ខប ប្រើក្នុងពេលដោះស្រាយបណ្ដឹង ។ ក្នុងករណីពាក្យបណ្ដឹងគ្មានភស្ដុតាងបញ្ជាក់អំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយទេ គធ/ខប ត្រូវបដិសេធពាក្យបណ្ដឹងនោះ និងត្រូវចាត់ចែងបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្ត ជាធម្មតាតាមការណែនាំ របស់ គ.ជ.ប ។ បន្ទាប់មក ប្រធាន គធ/ខប ត្រូវ ៖

២.១១១.៤.១ បង្គាប់មន្ត្រីសេវាកម្មច្បាប់ ឱ្យបំពេញសម្រង់សេចក្ដីសម្រេចបដិសេធលើបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ (ទម្រង់បែបបទលេខ ១២០៣) ជាបី (៣) ច្បាប់ ដោយមានបញ្ជាក់ពីមូលហេតុនៃការបដិសេធនោះផង ។

២.១១១.៤.២ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសម្រង់សេចក្ដីសម្រេចដែលមន្ត្រីសេវាកម្មច្បាប់បានបំពេញ រួចប្រគល់ជូនអ្នកប្ដឹងមួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ បន្ទាប់មកជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ/ខប ទៅ គ.ជ.ប ក្នុងរយៈពេលបី (៣) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃសម្រេចបដិសេធ ។

២.១១១.៤.៣ ប្រគល់ជូនតំណាងគណបក្សនយោបាយ ដែលប្ដឹងតវ៉ា ប្រសិនបើ គាត់ស្នើសុំនូវទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្ដឹង ចំនួន បី (៣) ច្បាប់ ។

២.១១១.៥ ក្នុងករណី ពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់មានពាក់ព័ន្ធនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលអាចប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គធ/ខប ត្រូវអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញដោយផ្ទាល់ ។

២.១១១.៥.១ គធ/ខប ត្រូវបើកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " ឬ " ក$_{១}$ " ពាក់ព័ន្ធ នៃការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹងនោះ ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ ដោយត្រូវអនុវត្តតាមការកំណត់ និងនីតិវិធីដែលមានចែងក្នុង ប.ន.ក នេះ ។

២.១១១.៥.២ ការត្រួតពិនិត្យ និងការរាប់សន្លឹកឆ្នោតខាងលើនេះ ត្រូវធ្វើនៅចំពោះមុខដើមបណ្តឹង ព្រមទាំងតំណាងនៃគណបក្សនយោបាយ ដែលឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬ/និង ក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។

២.១១១.៦ ក្នុងករណី មានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ដែលតម្រូវឱ្យ គធ/ខប បើកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " ឬ/និង " ក$_{១}$ " ណាមួយ ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ ដូចចែងក្នុងចំណុច ២.១១១.៥.១ ខាងលើ ប្រធាន គធ/ខប ត្រូវ ៖

២.១១១.៦.១ ដកយកកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធ និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គធ/ខប ពីក្នុងកញ្ចប់ " ខ " ពាក់ព័ន្ធ មកដាក់នៅលើតុ ក្បែរខ្លួនគាត់ ។

២.១១១.៦.២ បើកកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធ រួចដកយករាល់ស្រោមសំបុត្រ ឬ/និងស្បោងផ្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោត ដូចចែងចាប់ពីចំណុច ២.១០៨.៣.១ ដល់ ២.១០៨.៣.៨ ឬ/និង ២.១០៨.៤.១ ដល់ ២.១០៨.៤.៥ ខាងលើ មកដាក់ដោយឡែកពីគ្នា នៅលើតុខាងមុខគាត់ ។

២.១១១.៧ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធាន គធ/ខប ត្រូវចាត់ចែងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យនោះឡើងវិញ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធ ទៅនឹងកម្មវត្ថុនៃបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ និងបញ្ហាជារួម ដូចខាងក្រោម ៖

២.១១១.៧.១ ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត ។

២.១១១.៧.២ ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

២.១១១.៧.៣ ពិនិត្យផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដែលបានមកបោះឆ្នោត (ប្រសិនបើ បណ្ដឹងពាក់ព័ន្ធនឹងការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត បញ្ជីបោះឆ្នោតត្រូវដកចេញពីកញ្ចប់សុវត្ថិភាព " ក$_{ស}$ " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ) ។

២.១១១.៧.៤ ពិនិត្យផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ នៅក្នុងក្រដាសព័ត៌មាន (ប្រសិនបើមាន) ។

២.១១១.៧.៥ ពិនិត្យផ្ទៀងផ្ទាត់លេខរៀងគល់បញ្ជីសន្លឹកឆ្នោត ដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោត ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតពាក់ព័ន្ធ ដែលទទួលពីការិយាល័យបោះឆ្នោតនោះវិញ ។ ក្នុងនោះត្រូវ ពិនិត្យសន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ។

២.១១១.៧.៦ រាប់សន្លឹកឆ្នោតពាក់ព័ន្ធ ដែលខូច (ប្រសិនបើមាន) ។

២.១១១.៧.៧ ពិនិត្យសន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន) ។

២.១១១.៧.៨ អនុវត្តការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្ដឹងនោះឡើងវិញ ដោយអនុវត្តតាមលំនាំនីតិវិធី និងការកំណត់ ដូចចែងក្រោមប្រការ ២.១០៦ និង ២.១០៧ ខាងលើ ។

២.១១១.៨ បន្ទាប់ពីអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ដូចចែងក្រោមចំណុច ២.១១១.៧ ខាងលើ រួចរាល់ហើយ គធ/ខប ត្រូវធ្វើការប្រៀបធៀបលទ្ធផល ដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់ឃើញ និងបានរាប់ឃើញ ជាមួយនឹងទិន្នន័យ និងតួលេខ ដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតហើយត្រូវ ៖

២.១១១.៨.១ ធ្វើកំណត់ហេតុស្ដីពីលទ្ធផល នៃការបើកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " ឬ " ក$_{ខ}$ " ពាក់ព័ន្ធដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ និង

រាប់សន្លឹកឆ្នោតឡើងវិញខាងលើ ព្រមទាំងកំណត់សម្រេច យល់ព្រមទទួលយក ឬប្ដឹងជំទាស់ជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។ កំណត់ហេតុនេះត្រូវធ្វើជាពីរ (២) ច្បាប់ និងចុះហត្ថលេខាដោយសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងប្រធាន គឃ/ខប ។

២.១១១.៨.២ ប្រគល់កំណត់ហេតុនេះមួយ (១) ច្បាប់ ស្របពេលនឹងការបញ្ជូនកំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ជូន គ.ជ.ប (នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម) ។

២.១១១.៨.៣ រក្សាមួយ (១) ច្បាប់ ទុកជាឯកសាររបស់ គឃ/ខប ប្រើប្រាស់ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១១១.៨.៤ ដាក់ទៅក្នុងស្បោងផ្លាស្ទិក ឬស្រោមសំបុត្រដដែលវិញនូវកំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត ជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ ឬសម្ភារឯកសារបោះឆ្នោត ដូចចែងក្នុងចំណុច ២.១១១.៦.២ ខាងលើ តាមលំនាំដើមវិញ ។

២.១១១.៨.៥ ដាក់ស្បោងផ្លាស្ទិក និងស្រោមសំបុត្រនានាខាងលើ ទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធឡើងវិញ តាមលំនាំដើម ដូចចែងក្រោមចំណុច ២.១០៨.៣ ឬ/និង ២.១០៨.៤ ខាងលើ ។

២.១១១.៨.៦ ដាក់កញ្ចប់សុវត្ថិភាព " ក " និងរាល់ស្រោមសំបុត្រ ទៅក្នុងកញ្ចប់ " ខ " ពាក់ព័ន្ធឡើងវិញ តាមលំនាំដើម ដូចចែងក្នុងចំណុច ២.១០៨.៩ ខាងលើ រួចនាំយកទៅរក្សាទុកនៅកន្លែងដើម ដើម្បីប្រើប្រាស់ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងត្រៀមវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប ។

២.១១១.៩ ប្រសិនបើ ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ និងការរាប់សន្លឹកឆ្នោត ដូចចែង ក្រោមចំណុច ២.១១១.៧ និង ២.១១១.៨ ខាងលើ គធ/ខប ពិនិត្យមិនឃើញមានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ក្នុងប្រតិបត្តិការនៃការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គធ/ខប ត្រូវបើកសវនាការដោះស្រាយលើពាក្យបណ្តឹងពាក់ព័ន្ធ ដោយសម្រេចទទួលយកលទ្ធផលបោះឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ។ នៅក្នុងសវនាការរបស់ គធ/ខប ប្រធានក្រុមប្រឹក្សាជំនុំជំរះត្រូវ ៖

២.១១១.៩.១ ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឱ្យបំពេញសម្រង់សេចក្តីសម្រេចបដិសេធលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ (ទម្រង់បែបបទលេខ ១២០៣) ចំនួនបី (៣) ច្បាប់ ដោយមានបញ្ជាក់ពីមូលហេតុនៃការបដិសេធនោះផង ។

២.១១១.៩.២ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសម្រង់សេចក្តីសម្រេច ដែលសមាជិកទទួលបន្ទុកសេវាកម្មច្បាប់បានបំពេញ រួចប្រគល់ជូនអ្នកប្តឹងមួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១១១.៩.៣ ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ/ខប ទៅ គ.ជ.ប ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចដិសេធលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ។

២.១១១.៩.៤ ប្រគល់ជូនអ្នកប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ នូវទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹង ចំនួនបី (៣) ច្បាប់ ប្រសិនបើគាត់ស្នើសុំ ។

២.១១១.១០ ប្រសិនបើ ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ និងការរាប់សន្លឹកឆ្នោត ដូចចែងក្រោមចំណុច ២.១១១.៧ និង ២.១១១.៨ ខាងលើ គធ/ខប ពិនិត្យឃើញមានភស្តុតាងបញ្ជាក់ថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ក្នុងប្រតិបត្តិការនៃការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ គធ/ខប ត្រូវបើកសវនាការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធ ដោយសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលបោះឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ។ នៅក្នុងសវនាការ គធ/ខប ប្រធានក្រុមប្រឹក្សាជំនុំជំរះត្រូវ ៖

២.១១១.១០.១ ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឱ្យបំពេញសម្រង់សេចក្តីសម្រេចយល់ព្រមលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ (ទម្រង់បែបបទលេខ ១២០៣) ចំនួនបី (៣) ច្បាប់ ដែលត្រូវព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.១១១.១០.២ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសម្រង់សេចក្តីសម្រេចដែលទើបបានបំពេញ រួចប្រគល់ជូនអ្នកប្តឹងមួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារ មួយ (១) ច្បាប់ ។

២.១១១.១០.៣ ប្រកាសថា សេចក្តីសម្រេចរបស់ គធ/ខប ស្ថិតក្រោមការត្រួតពិនិត្យសម្រេចឡើងវិញដោយ គ.ជ.ប ។

២.១១១.១០.៤ ជម្រាបអ្នកប្តឹងថា គធ/ខប នឹងលើកសំណើពាក់ព័ន្ធនឹងករណីនេះ ព្រមទាំងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ដោយឡែក និងបញ្ជូនទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរម្ភៃបួន (២៤) ម៉ោង បន្ទាប់ពី គធ/ខប សំរេចព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីឱ្យ គ.ជ.ប ពិនិត្យសម្រេចឡើងវិញ ។

២.១១១.១១ ការដាក់ពាក្យប្តឹង និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលបានកើតមានឡើង នៅក្នុងតំបន់បោះឆ្នោតពាក់ព័ន្ធ ក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវអនុវត្តតាមលក្ខខណ្ឌ និងនីតិវិធី ដូចចែងក្នុងផ្នែកទី ១១ ជំពូកទី ២ នៃ ប.ន.ក នេះ ។

២.១១១.១២ អំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ ដូចបញ្ជាក់ក្នុងចំណុច ២.១១១.១១ ខាងលើ ត្រូវបានកំណត់ជាក់ស្តែង តាមរយៈកិច្ចសង្កេតការណ៍ ឬការរាយការណ៍ ឬការចោទប្រកាន់ ដោយមានភស្តុតាងគ្រប់គ្រាន់ ដែលរួមមានប្រភេទបទរំលោភមួយចំនួន ដូចខាងក្រោម ៖

២.១១១.១២.១ ការប្រើកម្លាំងដកហូតឯកសារបញ្ជាក់អត្តសញ្ញាណ ពីអ្នកបោះឆ្នោត ។

២.១១១.១២.២ ការរាំងបេក្ខជន នៃគណបក្សនយោបាយណាមួយ និងអ្នកគាំទ្រ មិនឱ្យឃោសនាតាមការកំណត់ ។

២.១១១.១២.៣ ការប្រើកម្លាំង ឬអំពើហិង្សា ដើម្បីរាំងអ្នកបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ។

២.១១១.១២.៤ ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំអ្នកបោះឆ្នោតឱ្យស្បថថា នឹងបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ។

២.១១១.១២.៥ ការធ្វើឱ្យខូចរបៀបរៀបរយ ឬការអុកឡុករំខានកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត មិនឱ្យដំណើរការបាន ។

២.១១១.១២.៦ ការញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោត ឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង ឬអំពើហិង្សាទៅលើបេក្ខជននៃគណបក្សនយោបាយណាមួយ ។

២.១១១.១២.៧ ការប្រើកម្លាំង ឬអំពើហិង្សា ឬការបំភិតបំភ័យ ដែលបង្កឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ភាពច្របូកច្របល់ និងបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

២.១១១.១២.៨ ការបោកបញ្ឆោត ឬការលួងលោមទិញសន្លឹកឆ្នោត ដោយសម្ភារ ឬប្រាក់កាស ។

២.១១១.១៣ រូបភាពនៃការបំភិតបំភ័យ ការគាបសង្កត់ ការគំរាមកំហែង ការប្រើកម្លាំង ឬអំពើហិង្សា ការរំលោភបំពាន ឬការគំរាមកំហែងដោយហិង្សា ត្រូវបានកំណត់តាមរយៈការស្តែងឡើង ដោយពាក្យសំដី ជាលាយលក្ខណ៍អក្សរ ឬដោយកាយវិការ ដូចខាងក្រោម ៖

២.១១១.១៣.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬដោយការសរសេរជាលាយលក្ខណ៍អក្សរ ដែលពោរពេញទៅដោយការគំរាមកំហែងដល់អាយុជីវិត ការគំរាមធ្វើទុក្ខទោសដល់រាងកាយ ឬការគំរាមបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិ ។

២.១១១.១៣.២ ការចោលសំដីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឬការសរសេរជាលាយលក្ខណ៍អក្សរក្តី ក្នុងន័យថានឹងធ្វើទារុណកម្ម ។

២.១១១.១៣.៣ ការវាយតប់បន្តិចបន្តួច ឬធ្វន់ធ្ងរលើ អ្នកបោះឆ្នោត ឬ បេក្ខជនណាម្នាក់ ។

២.១១១.១៣.៤ ការបង្ហាញ ឬការប្រើប្រាស់គ្រឿងសព្វាវុធ ដើម្បីធ្វើការបំភិតបំភ័យ ។

២.១១១.១៣.៥ ការលើកឡើងដោយផ្ទាល់មាត់ ឬការសរសេរជាលាយលក្ខណ៍អក្សរដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល ដែលជនណាម្នាក់ ត្រូវបានគេប្រហារជីវិត ឬត្រូវគេវាយដំ ឬត្រូវគេរំលោភ ឬទ្រព្យសម្បត្តិរបស់គាត់ត្រូវបានគេបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាត ។

២.១១១.១៣.៦ ការបាញ់ដោយកាំភ្លើងបង្អើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានយន្ត ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

២.១១១.១៣.៧ យកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណា ទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់គេ ដល់អាយុជីវិតបងប្អូនគ្រួសាររបស់គេ ឬបង្កឱ្យគេភ័យខ្លាច ។

២.១១១.១៣.៨ ការបណ្ដើរអ្នកគាំទ្រ ឬអ្នកបោះឆ្នោតណាម្នាក់ ដោយបង្ខំដែលធ្វើឱ្យអារម្មណ៍របស់គេមានការភ័យខ្លាច ឬធ្វើឱ្យគេខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់គេ ។

២.១១១.១៣.៩ ការប្រើភាសា កម្លាំងបាយ ដើម្បីបង្ហាញពីការគំរាមកំហែង ។

**កិច្ចប្រតិបត្តិការរបស់ គធ/ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ**

**ប្រការ ២.១១២** បន្ទាប់ពីបានទទួលកញ្ចប់ " ខ" ដូចចែងក្នុងចំណុច ២.១០៩.៤ និង ២.១១០.៦ ដែលដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត រួចហើយ គធ/ខប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទាំងអស់ចំណោះរាជធានី ខេត្តនីមួយៗ បញ្ចូលគ្នាឱ្យរួចរាល់ ក្នុងរយៈពេល

យ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។ គធ/ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផល កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផល និងក្រដាសលទ្ធផល តាមប្រភេទក្រុមប្រឹក្សានីមួយៗ ត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ ចុះហត្ថលេខា និងបោះត្រាជាផ្លូវការ ។ កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានបិទផ្សាយជាសាធារណៈនៅ គធ/ខប ។ ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្តរបស់ខ្លួន គធ/ខប ត្រូវចាប់ផ្ដើមពីការត្រួតពិនិត្យបញ្ជាក់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាមុន បន្ទាប់មកទើបអនុវត្តការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ជាក្រោយ ។

២.១១២.១ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធ ត្រូវបានអនុញ្ញាត ឱ្យចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ គធ/ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក្នុងរាជធានី ខេត្ត ពាក់ព័ន្ធ ។

២.១១២.១.១ តំណាងគណបក្សនយោបាយនីមួយៗ ឬអ្នកសង្កេតការណ៍នៃអង្គការនីមួយៗ ប្រចាំការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត ត្រូវជ្រើសតាំងឱ្យមានតំណាងរបស់ខ្លួនម្នាក់ និងតំណាងបម្រុងមួយ (១) នាក់ សម្រាប់ចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ គធ/ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ក្នុងការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្តរបស់ខ្លួន ។

២.១១២.១.២ តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលដំណើរនៃការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅរាជធានី ខេត្ត អាចផ្លាស់ប្ដូរតំណាងបំរុងឱ្យបំពេញភារកិច្ចជំនួសខ្លួន ។

២.១១២.១.៣ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មម ដែលអាចសង្កេតមើលឃើញនូវសកម្មភាពនៃការអនុវត្តខាងលើ ។

២.១១២.២ កិច្ចប្រតិបត្តិការរបស់ គធ/ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ពីគ្រប់ការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត ប្រសិនបើចាប់ផ្ដើមហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ។

២.១១២.៣ គធ/ខប ត្រូវត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ពីគ្រប់ការិយាល័យបោះឆ្នោត ដែលក្នុងនោះរួមទាំងលទ្ធផលបោះឆ្នោតនៃការិយាល័យ ដែលមានបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ដែលត្រូវបាន គធ/ខប បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចចែងក្នុងចំណុច ២.១១១.៦ និងត្រូវបាន គធ/ខប សម្រេចព្យួរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ដូចចែងក្នុង ២.១១១.១០ ផង ។

២.១១២.៤ គធ/ខប ត្រូវបើកកិច្ចប្រតិបត្តិការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ពីគ្រប់ការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត នៅលេខាធិការដ្ឋានរបស់ខ្លួន ដែលតម្រូវឱ្យមានបរិវេណសន្តិសុខ មានសុវត្ថិភាពល្អ និងត្រូវរៀបចំបន្ទប់ តាមលំនាំគំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោត ។

២.១១២.៥ ក្នុងករណី គ្មានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតណាមួយ ត្រូវបានដាក់ប្ដឹងនៅ គធ/ខប ឬមានបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ដែរ ប៉ុន្តែគ្មានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះទេ គធ/ខប ត្រូវចាត់ចែងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ននៃការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត របស់ខ្លួន ដោយមិនចាំបាច់បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់ សន្លឹកឆ្នោតឡើងវិញទេ ។ ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលខាងលើនេះ គធ/ខប គ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ និងគណនាដោយផ្អែកលើកំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធប៉ុណ្ណោះ ។

២.១១២.៦ ក្នុងការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ប្រធាន គធ/ខប ត្រូវ ៖

២.១១២.៦.១ ត្រៀមនៅលើតុខាងមុខគាត់នូវ ។

- ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្ដឹង ដែលត្រូវប្រគល់ជូនតំណាងគណបក្សនយោបាយ ប្រសិនបើគាត់ស្នើសុំ ។
- សម្ភារឯកសារចាំបាច់ផ្សេងទៀត ។

២.១១២.៦.២ ប្រគល់ឱ្យអនុប្រធាន និងសមាជិកទទួលបន្ទុកបណ្ដុះបណ្ដាល នូវទម្រង់បែបបទលេខ ១១១៦តពស សម្រាប់បំពេញតារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ តាមការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត របស់ខ្លួន ។

២.១១២.៦.៣ ប្រគល់ឱ្យសមាជិកទទួលបន្ទុករដ្ឋបាល នូវទម្រង់បែបបទលេខ ១១១១ស ចំនួនបី (៣) ច្បាប់ សម្រាប់បំពេញកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ តាមការិយាល័យបោះឆ្នោត ចំណុះរាជធានី ខេត្ត របស់ខ្លួន ។

២.១១២.៦.៤ ប្រគល់ជូនសមាជិកទទួលបន្ទុកហិរញ្ញវត្ថុ នូវម៉ាស៊ីនគិតលេខមួយ (១) គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យបញ្ជាក់នេះ ។

២.១១២.៦.៥ បង្គាប់មន្ត្រីទទួលបន្ទុកឯកសារ ឱ្យនាំយកកញ្ចប់ " ខ$_{ស}$" នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ម្ដងមួយៗ ពីកន្លែងរក្សាទុកមកដាក់នៅលើតុ ចំពីមុខគាត់ ។

២.១១២.៦.៦ បើកកញ្ចប់ " ខ$_{ស}$" រួចដកយកស្រោមសំបុត្រ ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០១ស និង ១១០២ស) និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស) ដែលផ្ញើជូន គធ/ខប មកដាក់នៅលើតុ ។

២.១១២.៦.៧ ដកយកស្រោមសំបុត្រដាក់កំណត់ហេតុ នៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ផ្ញើជូន

គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ពីក្នុងកញ្ចប់ " ខ$_{ស}$ " ដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " ឃ$_{ស}$ ពិសេស " ដែលត្រៀមបម្រុងជាស្រេច បន្ទាប់មករក្សាកញ្ចប់ " ខ$_{ស}$ " ដែលមានកញ្ចប់សុវត្ថិភាព " ក$_{ស}$ " និងសម្ភារ ឯកសារនៅសល់ខាងក្នុង នៅក្បែរខ្លួនគាត់ ។

២.១១២.៦.៨ ត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបតួលេខ ដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទម្រង់បែបបទលេខ ១១០១ស) និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស) រួចធ្វើការប្រៀបធៀបលទ្ធផលជាមួយនឹងតួលេខពាក់ព័ន្ធ ដែលមានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ស) ដើម្បីឱ្យដឹងប្រាកដថា លទ្ធផលដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ពិតជាត្រឹមត្រូវមែន ឬមានកំហុសក្នុងការគណនាលេខណាមួយ ។

២.១១២.៦.៩ សម្រេចកែតម្រូវតួលេខ លទ្ធផលបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ នោះ នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាន ប្រសិនបើបានរកឃើញថា គករ មានកំហុសក្នុងការគណនាលេខ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធាន គធ/ខប ត្រូវគូសឆូតលើតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធាន គធ/ខប ផង ។ តំណាងគណបក្សនយោបាយមានសិទ្ធិដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ ក្នុងករណីមិនពេញចិត្តនឹងការកែតម្រូវរបស់ គធ/ខប ។

២.១១២.៦.១០ ស្រង់ និងហៅតួលេខសន្លឹកឆ្នោតបានការ ដែលគាំទ្រគណបក្សនយោបាយនីមួយៗ និងសន្លឹកឆ្នោតមិនបានការ ដែលបានពិនិត្យត្រឹមត្រូវហើយ ពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២ស) នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងណែនាំអនុប្រធាន និងសមាជិកទទួលបន្ទុកបណ្ដុះបណ្ដាល ឱ្យកត់ត្រាតួលេខទាំងនេះ ទៅក្នុងតារាងត្រួត

ពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៦តពស) ។

២.១១២.៦.១១ ណែនាំសមាជិកទទួលបន្ទុករដ្ឋបាលឱ្យស្រង់ និងកត់ត្រាទិន្នន័យ និងតួលេខពីកំណត់ហេតុនៃការបោះឆ្នោត (ទម្រង់បែបបទលេខ ១១០១ស) និងពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (១១០២ស) នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធបញ្ចូលទៅក្នុងកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រួចត្រូវចម្លងបន្ថែមពីរ (២) ច្បាប់ទៀត គម្រប់បី (៣) ច្បាប់ ។ កំណត់ហេតុនេះ ត្រូវតែបានចុះហត្ថលេខាដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គធ/ខប និងត្រូវដាក់បង្ហាញតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ។ តំណាងគណបក្សនយោបាយ អាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើកំណត់ហេតុត្រួតពិនិត្យបញ្ជាក់នេះ ។ ការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ ពីតំណាងគណបក្សនយោបាយមិនអាចចាត់ទុកជាមោឃៈ នូវកំណត់ហេតុនេះបានទេ ។

២.១១២.៦.១២ ធានាថា តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៦តពស) នេះត្រូវបានចុះហត្ថលេខាដោយ ប្រធាន អនុប្រធាន និងសមាជិកទទួលបន្ទុកបណ្ដុះបណ្ដាល ។

២.១១២.៦.១៣ ធានាថារាល់កំណត់ហេតុនៃការបោះឆ្នោត (ទម្រង់បែបបទលេខ ១១០១ស) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ស) និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស) នៃការិយាល័យបោះឆ្នោតនីមួយៗ ដែលបានប្រើប្រាស់ក្នុងការត្រួតពិនិត្យបញ្ជាក់លទ្ធផលខាងលើនេះរួច ត្រូវតែបានដាក់ទៅក្នុងស្រោមសំបុត្រដដែលវិញ និងរក្សាទុកជាឯកសាររបស់ គធ/ខប ។

២.១១២.៦.១៤ ចាត់ចែងសមាជិក គធ/ខប ឱ្យវេចខ្ចប់កញ្ចប់ " ខស " ឡើងវិញ ដែលមានតែកញ្ចប់សុវត្ថិភាព " កស " និង ស្រោមសំបុត្រដាក់ត្រា គកប បន្ទាប់មក ឱ្យនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និង បញ្ជូនទៅ គ.ជ.ប ។

២.១១២.៧ ប្រធាន គធ/ខប ត្រូវធានាថា នីតិវិធីទាំងឡាយដូចចែងក្រោមចំណុច ២.១១២.៦ ខាងលើ ត្រូវតែបានអនុវត្តដូចគ្នា សម្រាប់កញ្ចប់ " ខស " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្តរបស់ខ្លួន ។

២.១១២.៨ ប្រធាន គធ/ខប ត្រូវធានាថា ស្រោមសំបុត្រដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ត្រូវបានប្រមូលផ្តុំដាក់ទៅក្នុងកញ្ចប់" ឃសពិសេស" ដែលត្រៀមបំរុងជាស្រេច ដូចចែងក្រោមប្រការ ២.១១៤ ខាងក្រោម ។

២.១១២.៩ ប្រធាន គធ/ខប ត្រូវរៀបចំបែងចែក និងប្រើប្រាស់កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១១ស) ចំនួន បី (៣) ច្បាប់ និង តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៦តពស) ចំនួនពី (២) ច្បាប់ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដូចខាងក្រោម ៖

២.១១២.៩.១ បិទផ្សាយកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១១ស) មួយ (១) ច្បាប់ៗ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ នៅលេខាធិការដ្ឋាន គធ/ខប ។

២.១១២.៩.២ ធ្វើកំណត់ហេតុត្រួតពិនិត្យ បញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

(ទម្រង់បែបបទលេខ ១១១១ស) ជូន គ.ជ.ប មួយ (១) ច្បាប់ៗ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដោយត្រូវដាក់រួមជាមួយតារាងត្រួតពិនិត្យ បញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៦តពស) មួយ (១) ច្បាប់ៗ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ទៅក្នុងស្រោមសំបុត្រដែលមានកាខ្ទង់ថា " កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ផ្ញើជូន គ.ជ.ប" ។

២.១១២.៩.៣ រក្សាទុកមួយ (១) ច្បាប់ៗ ជាឯកសាររបស់ គធ/ខប ប្រើសម្រាប់កំណត់ចំនួនអាសនៈ ដែលត្រូវបន្តអនុវត្តតាមនីតិវិធី ដូចចែងក្រោមប្រការ ២.១១៣ នៃជំពូកនេះ ។

២.១១២.៩.៤ ថតចម្លង កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១១ស) និងចែកជូនតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងមណ្ឌលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ (១) ច្បាប់ៗ តាមសំណើសុំ ។

២.១១២.១០ ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ប្រធាន គធ/ខប ត្រូវ ៖

២.១១២.១០.១ ប្រគល់ជូនអនុប្រធាន និងសមាជិកទទួលបន្ទុកបណ្ដុះបណ្ដាលនូវទម្រង់បែបបទលេខ ១១១០ខ មួយ (១) ច្បាប់ម្នាក់ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងទម្រង់បែបបទលេខ ១១១៦តព២ មួយ (១) ច្បាប់ម្នាក់ សម្រាប់បំពេញតារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១១២.១០.២ ប្រគល់ជូនសមាជិកទទួលបន្ទុករដ្ឋបាល នូវទម្រង់បែប

បទលេខ ១១១១ខ ចំនួនបី (៣) ច្បាប់ សម្រាប់បំពេញកំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងទម្រង់បែបបទចាំបាច់ផ្សេងទៀត សម្រាប់ប្រើក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននេះ ។

២.១១២.១០.៣ ប្រគល់ជូនសមាជិកទទួលបន្ទុកហិរញ្ញវត្ថុ នូវម៉ាស៊ីនគិតលេខមួយ (១) គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនេះ ។

២.១១២.១០.៤ បង្គាប់មន្ត្រីទទួលបន្ទុកឯកសារ ឱ្យនាំយកកញ្ចប់ " ខ₂ " នៃក្រុមប្រឹក្សារាជធានី ខេត្ត ពីកន្លែងរក្សាទុកម្តងមួយកញ្ចប់ៗ មកដាក់នៅលើតុចំមុខប្រធាន គធ/ខប ។

២.១១២.១០.៥ បើកកញ្ចប់ " ខ₂ " រួចដកយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទម្រង់បែបបទលេខ ១១០១ខ) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ខ) និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ខ) ផ្ញើជូន គធ/ខប មកដាក់នៅលើតុ ។

២.១១២.១០.៦ ដកស្រោមសំបុត្រដាក់កំណត់ហេតុ នៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ពីក្នុងកញ្ចប់ " ខ₂ " ដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " ឃ₂ពិសេស " ដែលត្រៀមបំរុងជាស្រេច បន្ទាប់មករក្សាកញ្ចប់ " ខ₂ " ដែលមានកញ្ចប់សុវត្ថិភាព " ក₂ " និងសម្ភារ ឯកសារនៅសល់ខាងក្នុងនៅក្បែរខ្លួនគាត់ ។

២.១១២.១០.៧ ត្រួតពិនិត្យបញ្ជាក់ និងបូកសរុបតួលេខ ដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទម្រង់បែបបទលេខ ១១០១ខ) និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ខ) នៃការិយាល័យបោះឆ្នោតនីមួយៗ រួចធ្វើការប្រៀបធៀបលទ្ធផល ជាមួយនឹងតួលេខពាក់ព័ន្ធដែលមានកត់ត្រាក្នុងកំណត់ហេតុនៃ ការរាប់សន្លឹកឆ្នោត

(ទម្រង់បែបបទលេខ ១១០២ខ) នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីឱ្យដឹងប្រាកដថា លទ្ធផលដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ពិតជាត្រឹមត្រូវមែន ឬមានកំហុសក្នុងការគណនាលេខណាមួយ ។

២.១១២.១០.៨ សម្រេចកែតម្រូវតួលេខ លទ្ធផលនៃការបោះឆ្នោតរាជធានី ខេត្តនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ប្រសិនបើរកឃើញថា គករ មានកំហុសក្នុងការគណនាលេខ ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធាន គធ/ខប ត្រូវគូសឆូតលើតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ ប្រធាន គធ/ខប ផង ។ តំណាងគណបក្សនយោបាយ មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ក្នុងករណី មិនពេញចិត្តនឹងការកែតម្រូវរបស់ គធ/ខប ។

២.១១២.១០.៩ ស្រង់ និងហៅតួលេខសន្លឹកឆ្នោតបានការ ដែលគាំទ្រគណបក្សនយោបាយនីមួយៗ និងសន្លឹកឆ្នោតមិនបានការដែលបានពិនិត្យត្រឹមត្រូវហើយ ពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ខ) នៃការិយាល័យបោះឆ្នោតម្តងមួយៗ រហូតដល់អស់ និងណែនាំអនុប្រធាន និងសមាជិកទទួលបន្ទុកបណ្តុះបណ្តាល ឱ្យកត់ត្រាតួលេខទាំងនេះ ទៅក្នុងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) ។

២.១១២.១០.១០ ណែនាំអនុប្រធាន និងសមាជិកទទួលបន្ទុកបណ្តុះបណ្តាល ឱ្យគណនាសរុបតួលេខលទ្ធផលនៃការបោះឆ្នោត ដែលបានស្រង់ និងកត់ត្រាលើតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) ដោយធ្វើប្រមាណវិធីដោយដៃផង និងប្រើម៉ាស៊ីនគិតលេខផង បន្ទាប់មកត្រូវផ្ទៀងផ្ទាត់លទ្ធផលគ្នា និងកត់ត្រាទិន្នន័យ និងតួលេខទាំងនេះ ទៅក្នុងតារាងត្រួត

ពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១៦តព២) ។

២.១១២.១០.១១ ណែនាំសមាជិកទទួលបន្ទុករដ្ឋបាលឱ្យស្រង់ និងបូកសរុបរួចកត់ត្រាតួលេខ និងទិន្នន័យពាក់ព័ន្ធ ដែលក្នុងនោះរួមមានទាំងចំនួនសរុប នៃសន្លឹកឆ្នោតបានការដែលគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការ ដែលបានគណនា និងពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ពីតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) និងតារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១៦តព២) បញ្ចូលទៅក្នុងកំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១១ខ) ចំនួនបី (៣) ច្បាប់ ។

២.១១២.១០.១២ ធានាថារាល់កំណត់ហេតុនៃការបោះឆ្នោត (ទម្រង់បែបបទលេខ ១១០១ខ) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទម្រង់បែបបទលេខ ១១០២ខ) និងតារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ខ) នៃការិយាល័យបោះឆ្នោតនីមួយៗ ដែលបានប្រើប្រាស់ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលខាងលើនេះរួច ត្រូវតែបានដាក់ទៅក្នុងស្រោមសំបុត្រដដែលវិញ និងចងក្រងទុកជាឯកសាររបស់ គធ/ខប ។

២.១១២.១០.១៣ ចាត់ចែងសមាជិក គធ/ខប ឱ្យវេចខ្ចប់កញ្ចប់ " ខ₂ " ពាក់ព័ន្ធឡើងវិញ ដែលមានតែកញ្ចប់សុវត្ថិភាព " ក₂ " បន្ទាប់មក ឱ្យនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប ។

២.១១២.១១ ប្រធាន គធ/ខប ត្រូវធានាថា កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១១ខ) ចំនួនបី (៣) ច្បាប់ ដែលសមាជិកទទួលបន្ទុករដ្ឋបាលបានបំពេញ និងគណនាសរុបរួចហើយ ដូចចែងក្នុងចំណុច ២.១១២.១០.១១ ខាងលើ ត្រូវតែបានផ្ទៀងផ្ទាត់ឡើងវិញជាមួយនឹងតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ដូចចែងក្នុងចំណុច ២.១១២.១០.១០ និងត្រូវបានចុះហត្ថលេខាដោយសមាជិកទទួលបន្ទុករដ្ឋបាល និងខ្លួនគាត់ផ្ទាល់ ព្រមទាំងមានបោះត្រាផង ។

២.១១២.១១.១ ប្រធាន គធ/ខប ត្រូវដាក់បង្ហាញកំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននេះ ជូនតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ព្រមទាំងអញ្ជើញតំណាងគណបក្សនយោបាយឱ្យចូលរួមចុះហត្ថលេខា ឬផ្ដិតមេដៃជាសាក្សី ។

២.១១២.១១.២ ការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ លើកំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១១ខ) ពីតំណាងគណបក្សនយោបាយ មិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ ។

២.១១២.១២ ប្រធាន គធ/ខប ត្រូវចាត់ចែង និងប្រើប្រាស់កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១១ខ) ដូចខាងក្រោម ៖

២.១១២.១២.១ បិទផ្សាយមួយ (១) ច្បាប់ នៅលេខាធិការដ្ឋាននៃ គធ/ខប ។

២.១១២.១២.២ ផ្ញើមួយ (១) ច្បាប់ជូន គ.ជ.ប ។

២.១១២.១២.៣ រក្សាទុកមួយ (១) ច្បាប់ និងកំណត់ហេតុស្ដីពីការបិទផ្សាយមួយ (១) ច្បាប់ ជាឯកសារ និងសម្រាប់ប្រើក្នុងការបែងចែកអាសនៈក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១១២.១២.៤ ថតចម្លង និងចែកជូនតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ (១) ច្បាប់ៗ តាមសំណើសុំ ។

២.១១២.១៣ ប្រធាន គធ/ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១៦តពខ) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១១ខ) ត្រូវបានដាក់ក្នុងស្រោមសំបុត្រធំតែមួយ ត្រៀមសម្រាប់ផ្ញើជូន គ.ជ.ប ។

២.១១២.១៤ ទោះបី គធ/ខប បានសំរេចឲ្យរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ និងបានលើកសំណើសុំ គ.ជ.ប ត្រួតពិនិត្យសំរេចឡើងវិញនូវលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយនោះ ដូចចែងក្រោមចំណុច ២.១១១.១០ ខាងលើ ក៏ដោយ ក៏ គធ/ខប ត្រូវត្រួតពិនិត្យបញ្ជាក់ និងបូកសរុបបញ្ចូលលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងអស់ ទៅក្នុងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាចំណុះរាជធានី ខេត្ត របស់ខ្លួនដែរ ។

## ការកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

**ប្រការ ២.១១៣** បន្ទាប់ពីបានត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ បានធ្វើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក" ណាមួយ និងការរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើមាន) និងបានដោះស្រាយបណ្ដឹងនៅថ្នាក់របស់ខ្លួនចប់សព្វគ្រប់ ប្រធាន គធ/ខប ត្រូវកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្ត របស់ខ្លួន និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា តាមប្រភេទនីមួយៗ ស្របតាមបញ្ញត្តិនៃ ច.ប.ក និង ច.គ.ខ.ស ។ ក្នុងការអនុវត្តភារកិច្ចនេះ គធ/ខប ត្រូវកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្ត ឱ្យហើយរួចរាល់ មុននឹងអនុវត្តការកំណត់ចំនួនអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ។

២.១១៣.១ ប្រធាន គធ/ខប ត្រូវធានាឱ្យមានកុំព្យូទ័រមួយសម្រាប់ ដែលមានម៉ាស៊ីនស្កែន ម៉ាស៊ីនបោះពុម្ព ប្រព័ន្ធអ៊ីមែល និងដែលបំពាក់ដោយកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ ផ្អែកតាមរូបមន្ត និងនីតិវិធីដូចចែងក្នុងជំពូកទី ២ ផ្នែកទី ២ នៃ ប.ន.ក នេះ ។ ប្រធាន គធ/ខប ត្រូវ ៖

២.១១៣.១.១ ធានាថា គ្រឿងបរិក្ខារកុំព្យូទ័រដែលបានតម្លើង ដើរបានល្អត្រឹមត្រូវ និងមានផ្ទុកទិន្នន័យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀត ។

២.១១៣.១.២ ធានាឱ្យមាន បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ទាំងអស់ចំណុះរាជធានី ខេត្ត (បញ្ជីផ្លូវការ) មួយ (១) ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងការពិនិត្យផ្ទៀងផ្ទាត់ ។

២.១១៣.១.៣ ថែរក្សាថាសទន់ ដែលផ្ទុកកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ និងទិន្នន័យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្ត ពាក់ព័ន្ធឱ្យបានល្អ និងគត់មត់ ។

២.១១៣.១.៤ ត្រូវរាយការណ៍ និងស្នើសុំជំនួយអន្តរាគមន៍ ជាបន្ទាន់ពី គ.ជ.ប ក្នុងករណីថាសទន់ ដែលផ្ទុកកម្មវិធីប្រតិបត្តិការបែងចែកអាសនៈត្រូវខូច ឬមិនអាចប្រើប្រាស់បាន ។

២.១១៣.២ ប្រធាន គធ/ខប ត្រូវធានាថា រាល់តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ (ទម្រង់បែបបទ ១១១៦តពស) និងរបាយការណ៍ ដូចបញ្ជាក់ក្នុងប្រការ ១២.១១៣ ខាងលើ ត្រូវបានរៀបចំដោយខ្សែក និងតាមលំដាប់លេខកូដរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ។

២.១១៣.៣ នៅក្នុងការគណនា និងកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធណាមួយ ប្រធាន គធ/ខប ត្រូវ ៖

២.១១៣.៣.១ ចាត់អនុប្រធាន គធ/ខប និងសមាជិកទទួលបន្ទុករដ្ឋបាល ឱ្យសហការគ្នាបញ្ចូលយ៉ាងត្រឹមត្រូវ នូវទិន្នន័យនៃចំនួនសំឡេងឆ្នោតគាំទ្រគណបក្សនយោបាយ ដែលឈរឈ្មោះ

បោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌនីមួយៗ ទៅក្នុងកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ដោយផ្អែកតាមតួលេខលទ្ធផលនៅក្នុងកំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទម្រង់បែបបទលេខ ១១១១ស ឬ ១១១១ខ) ពាក់ព័ន្ធ ។

២.១១៣.៣.២ ធានាថា បន្ទាប់ពីបានបញ្ចូលទិន្នន័យត្រឹមត្រូវ និងបានបញ្ជាកម្មវិធីប្រតិបត្តិការកំណត់ចំនួនអាសនៈ ក្នុងកុំព្យូទ័រ ឱ្យគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធរួច លទ្ធផលនៃការបែងចែកត្រូវបានបោះពុម្ពមួយ (១) ច្បាប់ ។

២.១១៣.៣.៣ ចាត់សមាជិកទទួលបន្ទុកបណ្ដុះបណ្ដាល ឱ្យអនុវត្តប្រមាណវិធីដោយដៃ ឬ/និងម៉ាស៊ីនគិតលេខ ដោយផ្អែកតាមរូបមន្តនៃការបែងចែកអាសនៈដូចចែងក្នុងជំពូកទី២ ផ្នែកទី២ នៃ ប.ន.ក នេះ ដើម្បីគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

២.១១៣.៣.៤ ចាត់ចែងមន្ត្រី គធ/ខប ផ្សេងទៀត ឱ្យសហការគ្នាផ្ទៀងផ្ទាត់ និងគណនាឡើងវិញ ដោយផ្អែកតាមរូបមន្តបែងចែកអាសនៈ ដូចចែងក្នុងជំពូកទី២ ផ្នែក ទី២ នៃ ប.ន.ក នេះ ប្រសិនបើលទ្ធផលនៃការគណនាតាមរូបភាពទាំងពីរខាងលើមានភាពខុសគ្នា ។

២.១១៣.៣.៥ ធានាថា ក្រដាសលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈ តាមរបៀបទាំងពីរ ដែលបានផ្ទៀងផ្ទាត់ត្រឹមត្រូវដូចគ្នាហើយ ត្រូវបានចុះហត្ថលេខាដោយប្រធាន គធ/ខប និងសមាជិកទទួលបន្ទុករដ្ឋបាល ។

២.១១៣.៤ បន្ទាប់ពីបានអនុវត្តរាល់នីតិវិធីដូចចែងក្រោមចំណុច ២.១១៣.៣ និងផ្អែកលើលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈ ដូចចែងក្នុងចំណុច ២.១១៣.៣.៥ ប្រធាន គធ/ខប ត្រូវ ៖

២.១១៣.៩.១ ចាត់ចែងសមាជិកទទួលបន្ទុករដ្ឋបាល ឱ្យបំពេញលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១១១៩ស ឬ១១១៩ខ ) ចំនួនបី (៣) ច្បាប់ នូវ ៖

- ឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ ចំនួនសំឡេងឆ្នោតគាំទ្រសរុប និងចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗទទួលបាន ដោយគិតតាមលំដាប់ពីខ្ពស់ មកទាប ។
- ឈ្មោះបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ក្នុងនោះត្រូវបញ្ជាក់ចំពោះបេក្ខជនដែលត្រូវជាប់ជាប្រធានក្រុមប្រឹក្សាតាមប្រភេទនីមួយៗផង ។

២.១១៣.៩.២ ធានាថា ការស្រង់ឈ្មោះបេក្ខជននៃគណបក្សនយោបាយដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា តាមប្រភេទនីមួយៗត្រូវតែផ្អែកលើបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយដែលបានទទួលអាសនៈ ដោយគិតតាមលំដាប់ពីខ្ពស់ មកទាប ។

២.១១៣.៩.៣ ធានាថា លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ (ទម្រង់បែបបទលេខ ១១១៩ស ឬ ១១១៩ខ) ទាំងបី (៣) ច្បាប់ ត្រូវតែបានចុះហត្ថលេខាកាត់ ដោយសមាជិកទាំងអស់នៃ គធ/ខប និងចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គធ/ខប ។

២.១១៣.៥ លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៩ស ឬ ១១១៩ខ) ចំនួនបី (៣) ច្បាប់ ដូចបញ្ជាក់ក្នុងចំណុច ២.១១៣.៩.៣ ត្រូវដាក់បង្ហាញឱ្យតំណាងគណបក្ស នយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានពិនិត្យមើល ។ ប្រធាន គធ/ខប ត្រូវចាត់ចែង និងប្រើប្រាស់ទម្រង់បែបបទខាងលើនេះ ដូចខាងក្រោម ៖

២.១១៣.៥.១ ផ្ញើជូន គ.ជ.ប ពី (២) ច្បាប់ ដែលត្រូវដាក់ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្លងថា " លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ លេខកូដ..... (បំពេញលេខកូដរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ) ផ្ញើជូន គ.ជ.ប " ។

២.១១៣.៥.២ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១១៣.៦ ក្នុងករណីដែល បញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន មានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវបានជ្រើសរើសយកបេក្ខជនដែលមានលេខរៀងលើគេ នៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

២.១១៣.៧ ប្រសិនបើ ការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ ណាមួយ ក្នុងការគណនារូបមន្តបែងចែកអាសនៈមានលទ្ធផលស្មើគ្នា រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ដែលនឹងត្រូវបានទទួលអាសនៈក្នុងក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌណាមួយនោះ ប្រធាន គធ/ខប ត្រូវចាត់ចែងអនុវត្តការចាប់ឆ្នោត ដោយផ្អែកតាមលក្ខខណ្ឌ និង នីតិវិធីស្តីពីការចាប់ឆ្នោតដូចចែងក្នុងជំពូកទី ២ ផ្នែកទី ២ នៃ ប.ន.ក នេះ ។ ប្រធាន គធ/ខប ត្រូវធានាថា កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោតដូចបញ្ជាក់ក្នុងចំណុចនេះ ត្រូវបានធ្វើជាពីរ (២) ច្បាប់ ដែលមួយ (១) ច្បាប់ ត្រូវរក្សាទុកជាឯកសាររបស់ គធ/ខប និង មួយ (១) ច្បាប់ទៀត ត្រូវដាក់ក្នុងកញ្ចប់ " យ៥ ពិសេស " ឬ " យ៦ ពិសេស " ផ្ញើជូន គ.ជ.ប ។

២.១១៣.៨ ប្រសិនបើ ការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌណាមួយមានលទ្ធផលសំឡេងឆ្នោតស្មើគ្នា និងចំនួនអាសនៈស្មើគ្នា រវាងបញ្ជីបេក្ខជន នៃគណបក្សនយោបាយពីរ ឬច្រើន ប្រធាន គធ/ខប ត្រូវចាត់ចែងអនុវត្តការចាប់ឆ្នោត ដើម្បីកំណត់បញ្ជីបេក្ខជន នៃគណបក្សនយោបាយ ដែលត្រូវទទួលបានជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង

ស្រុក ខណ្ឌ ដោយផ្អែកតាមនីតិវិធីដូចចែងក្នុងជំពូកទី ២ ផ្នែកទី ២ នៃ ប.ន.ក នេះ ។ ប្រធាន គធ/ខប ត្រូវធានាថា កំណត់ហេតុស្ដីពីលទ្ធផលនៃការចាប់ឆ្នោត ដូចបញ្ជាក់ក្នុងចំណុចនេះ ត្រូវបានធ្វើជាពីរ (២) ច្បាប់ ដែលមួយ (១) ច្បាប់ ត្រូវរក្សាទុកជាឯកសារ របស់ គធ/ខប និងមួយ (១) ច្បាប់ ទៀតត្រូវដាក់ក្នុងកញ្ចប់ " យ$_{ស}$ ពិសេស " ឬ " យ$_{ខ}$ ពិសេស " ផ្ញើជូន គ.ជ.ប ។

២.១១៣.៩ បន្ទាប់ពីបានត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា កំណត់ចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា តាមប្រភេទនីមួយៗ និងកំណត់ឈ្មោះបេក្ខជនដែលត្រូវជាប់ជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ រួចរាល់ហើយ ប្រធាន គធ/ខប ត្រូវធានាថា លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ (ទម្រង់បែបបទលេខ ១១១៤ស ឬ ១១១៤ខ) ត្រូវតែបានបំពេញ ចុះហត្ថលេខា និងកាលបរិច្ឆេទ រួចបញ្ជូនដោយវេចខ្ចប់ អមទៅជាមួយនូវសម្ភារ ឯកសារបោះឆ្នោត ពាក់ព័ន្ធទៅ គ.ជ.ប ដើម្បីពិនិត្យ សម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ ។

**ការវេចខ្ចប់កញ្ចប់ " យពិសេស " ដាក់កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា កញ្ចប់ " យ " និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ បញ្ជូនទៅ គ.ជ.ប**

**ប្រការ ២.១១៤** បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចចែងចាប់ពីប្រការ ២.១១០ ដល់ ២.១១៣ ប្រធាន គធ/ខប ត្រូវវេចខ្ចប់កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រភេទនីមួយៗ ដាក់ក្នុងកញ្ចប់ " យ$_{ស}$ពិសេស " ឬ កញ្ចប់ " យ$_{ខ}$ ពិសេស " ដោយឡែកពីគ្នា ។ ក្នុងការវេចខ្ចប់នេះ ប្រធាន គធ/ខប ត្រូវធានាថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៦តពស) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១១ស) លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៤ស) និងឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវតែបានវេចខ្ចប់ទៅក្នុងកញ្ចប់ " យ$_{ស}$ពិសេស"

ហើយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់ បែបបទលេខ ១១១៦ត៣ខ) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១១ខ) លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១៩ខ) និងឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវតែបានវេចខ្ចប់ទៅក្នុងកញ្ចប់ " ឃ$_ខ$ពិសេស" រីឯរាល់កញ្ចប់ " ខ$_ស$" ដាក់សម្ភារ ឯកសារបោះឆ្នោត ដូចក្នុងចំណុច ២.១១២.៦.១៤ ត្រូវតែបានវេចខ្ចប់ ទៅក្នុងកញ្ចប់ " ឃ$_ស$ " ហើយរាល់កញ្ចប់ " ខ$_ខ$" ដាក់សម្ភារឯកសារបោះឆ្នោត ដូចក្នុង ចំណុច ២.១១២.១០.១៣ ត្រូវតែបានវេចខ្ចប់ទៅក្នុងកញ្ចប់ " ឃ$_ខ$ " និងត្រូវប្រគល់ជូន គ.ជ.ប បានយ៉ាងត្រឹមត្រូវ ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពី គកប ។

២.១១៩.១ ប្រធាន គឃ/ខប ត្រូវចាត់ចែងវេចខ្ចប់ដាក់ក្នុងកញ្ចប់ " ឃ$_ស$ពិសេស " មួយ នូវរាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតសំខាន់ៗ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្នុងកញ្ចប់ " ឃ$_ខ$ពិសេស " មួយទៀត នូវរាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតសំខាន់ៗ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ចំណោះរាជធានី ខេត្ត របស់ខ្លួនសម្រាប់ផ្ញើជូន គ.ជ.ប ។ ប្រធាន គឃ/ខប ត្រូវត្រួតពិនិត្យឡើងវិញ និងរៀបចំចងជាបាច់ ទៅតាមប្រភេទស្រោមសំបុត្រដាក់ឯកសារ ដែលត្រូវដាក់ក្នុងកញ្ចប់សុវត្ថិភាព " ឃពិសេស " ទាំងនោះ ។

២.១១៩.២ ប្រធាន គឃ/ខប ត្រូវធានាថា កញ្ចប់" ឃ$_ស$ ពិសេស" នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលត្រូវផ្ញើជូន គ.ជ.ប ត្រូវមានរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោត ដូចខាងក្រោម ៖

២.១១៩.២.១ ស្រោមសំបុត្រតែមួយសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមួយ ដាក់តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

(ទម្រង់បែបបទលេខ ១១១៦គពស) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១១ស) លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៨ស) ។

២.១១៩.២.២ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ដូចក្នុងចំណុច ២.១១២.៦.៧ ខាងលើ ។

២.១១៩.២.៣ ស្រោមសំបុត្រដាក់កំណត់ហេតុ ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព" ក<sub></sub>" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ និងសេចក្ដីសម្រេចរបស់ គធ/ខប យល់ ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ប្រសិនបើមាន) ដូចចែងក្រោមចំណុច ២.១១១.៨ ខាងលើ ។

២.១១៩.២.៤ ស្រោមសំបុត្រតែមួយ ដាក់រាល់សម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលបានបដិសេធលើបណ្ដឹងតវ៉ា ឬ/និង បណ្ដឹងជំទាស់ (ទម្រង់បែបបទលេខ ១២០៣) ផ្ញើជូន គ.ជ.ប (នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម) ដូចចែងក្នុងចំណុច ២.១១១.៩ ខាងលើ ។

២.១១៩.២.៥ កំណត់ហេតុស្ដីពីលទ្ធផលនៃការចាប់ឆ្នោត ដូចចែងក្នុងចំណុច ២.១១៣.៧ និង ២.១១៣.៨ ។

២.១១៩.២.៦ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) មួយ (១) ច្បាប់ ដូចចែងក្នុងចំណុច ២.១១៩.៤ ខាងក្រោម ។

២.១១៩.៣ ក្នុងការវេចខ្ចប់កញ្ចប់" ឃ₂ ពិសេស" នៃក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីផ្ញើជូន គ.ជ.ប ប្រធាន គធ/ខប ត្រូវត្រូវដាក់រាល់ស្រោមសំបុត្រមានផ្ទុកសម្ភារ ឯកសារបោះឆ្នោត ដូចខាងក្រោម ៖

២.១១៩.៣.១ ស្រោមសំបុត្រតែមួយសម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ដាក់តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១៦តពខ) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១១ខ) លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១៩ខ) ។

២.១១៩.៣.២ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ដូចចែងចំណុច ២.១១២.១០.៦ ខាងលើ ។

២.១១៩.៣.៣ ស្រោមសំបុត្រដាក់កំណត់ហេតុ ស្ដីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព" ក₂" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ និងសេចក្ដីសម្រេចរបស់ គធ/ខប យល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ប្រសិនបើមាន) ដូចចែងក្រោមចំណុច ២.១១១.៨ ខាងលើ ។

២.១១៩.៣.៤ ស្រោមសំបុត្រតែមួយ ដាក់រាល់សម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលបានបដិសេធលើបណ្ដឹងតវ៉ា ឬ/និង បណ្ដឹងជំទាស់ (ទម្រង់បែបបទលេខ ១២០៣) ផ្ញើជូន គ.ជ.ប (នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម) ដូចចែងក្នុង ចំណុច ២.១១១.៩ ខាងលើ ។

២.១១៩.៣.៥ កំណត់ហេតុស្ដីពីលទ្ធផលនៃការចាប់ឆ្នោត ដូចចែងក្នុងចំណុច ២.១១៣.៧ និង ២.១១៣.៨ ។

២.១១៩.៣.៦ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) មួយ (១) ច្បាប់ ដូចចែងក្នុងចំណុច ២.១១៩.៤ ខាងក្រោម ។

២.១១៨.៤ ប្រធាន គធ/ខប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) ចំនួនបី (៣) ច្បាប់ សម្រាប់កញ្ចប់ " ឃពិសេស " នីមួយៗ ដោយមានរាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងកញ្ចប់ " ឃ$_{ស}$ពិសេស" ឬ កញ្ចប់ " ឃ$_{ខ}$ ពិសេស" ខាងលើ ហើយត្រូវដាក់មួយ (១) ច្បាប់ក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុង កញ្ចប់ "ឃពិសេស" នីមួយៗ ហើយដាក់មួយ (១) ច្បាប់ទៀត ទៅក្នុង ហោប៉ៅខាងក្រៅនៃកញ្ចប់" ឃពិសេស " នីមួយៗនោះ និងត្រៀមទុកមួយ (១) ច្បាប់ៗ សម្រាប់ប្រើក្នុងការប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត នៅ គ.ជ.ប ។

២.១១៨.៥ ប្រធាន គធ/ខប ត្រូវធានាថា រាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោត ដូចចែងក្រោមចំណុច ២.១១៨.២ និង២.១១៨.៣ ខាងលើ ត្រូវបាន រៀបចំដាក់ក្នុងកញ្ចប់" ឃ$_{ស}$ពិសេស" និង កញ្ចប់" ឃ$_{ខ}$ពិសេស" ឱ្យបាន គ្រប់គ្រាន់ និងត្រឹមត្រូវ នៅមុនពេលត្រូវបិទភ្ជិតដោយការសុវត្ថិភាព ។ សម្រាប់កញ្ចប់" ឃ$_{ស}$ពិសេស" ប្រធាន គធ/ខប ត្រូវសរសេរសម្គាល់ឈ្មោះ និងលេខកូដរាជធានី ឬខេត្ត និងក្រុង ឬស្រុក ឬខណ្ឌ សម្រាប់កញ្ចប់ " ឃ$_{ខ}$ពិសេស" ត្រូវសរសេរតែឈ្មោះ និងលេខកូដរាជធានី ឬខេត្ត ប៉ុណ្ណោះ ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ ។

២.១១៨.៦ ក្នុងករណី គធ/ខប បានសម្រេចព្យួរលទ្ធផលនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ខេត្ត ឬ/និង ក្រុង ស្រុក ខណ្ឌ ដូចចែងក្នុង និង ក្រោមចំណុច ២.១១១.១០ ប្រធាន គធ/ខប ត្រូវធានាថា សេចក្តីសម្រេច ព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ទម្រង់បែបបទត្រួតពិនិត្យបញ្ជាក់ និងបូកសរុប លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សម្ភារ និង ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ត្រូវតែ បានវេចខ្ចប់ដោយឡែក តាមការិយាល័យបោះឆ្នោត និងប្រភេទក្រុមប្រឹក្សា នីមួយៗ និងបញ្ជូនទៅ គ.ជ.ប ។ ក្នុងនេះ ប្រធាន គធ/ខប ត្រូវ ៖

២.១១៨.៦.១ រៀបចំដាក់ក្នុងស្រោមសំបុត្រធំមួយ នូវឯកសារបោះឆ្នោត ដូចខាង ក្រោម ៖

- កំណាត់ហេតុ ស្តីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " ឬ " ក$_{ខ}$ " ពាក់ព័ន្ធ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចចែងក្នុងចំណុច ២.១១១.៨.១ ។
- សេចក្តីសំរេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដែលត្រូវព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ដូចចែងក្នុងចំណុច ២.១១១.១០.២ ។
- ស្រោមសំបុត្រតែមួយ ដាក់តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១១១៦តពស ឬ ១១១៦តពខ) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១១១១ស ឬ ១១១១ខ) លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១១១៩ស ឬ ១១១៩ខ) តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) (សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត) ។
- កំណាត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត ដូចចែងក្នុងចំណុច ២.១១៣.៧ និង ២.១១៣.៨ (ប្រសិនបើមាន) ។
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួល សម្ភារឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) មួយ (១) ច្បាប់ ដូចចែងក្នុងចំណុច ២.១១៩.៦.៣ ខាងក្រោម ។

២.១១៩.៦.២ ចាត់ចែងដាក់ទៅក្នុងកញ្ចប់ " ឃ$_{ស}$" ឬ" ឃ$_{ខ}$" មួយដោយឡែក នូវកញ្ចប់ " ខ$_{ស}$" ផ្ទុកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " ឬ កញ្ចប់ " ខ$_{ខ}$" ផ្ទុកកញ្ចប់សុវត្ថិភាព " ក$_{ខ}$"និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោត ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យនោះ ត្រូវបានព្យួរជាបណ្តោះអាសន្នដោយ គធ/ខប ។

២.១១៨.៦.៣ ចងភ្ជិតកញ្ចប់ " ឃ " ពាក់ព័ន្ធ រួចចាក់សោឃ្លុំ និងសរសេរសម្គាល់ខាងក្រៅកញ្ចប់ " ឃ " នោះ ដោយប្រើប៊ិចហ្វឹតលុបមិនជ្រះ នូវលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ឈ្មោះរាជធានី ខេត្ត និងលេខកូដមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ/និងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ និងពាក្យ " ព្យួរលទ្ធផល " ។

២.១១៨.៦.៤ ចាត់ចែងបំពេញ និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួល សម្ភារ ឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) ចំនួនបី (៣) ច្បាប់ៗ សម្រាប់ស្រោមសំបុត្រធំមួយ និងកញ្ចប់ " ឃ " ពាក់ព័ន្ធដែលត្រូវដាក់មួយ (១) ច្បាប់ ក្នុងស្រោមសំបុត្រធំបន្ទាប់មក កិបមួយ (១) ច្បាប់ជាប់នឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំនោះ និងត្រៀម មួយ (១) ច្បាប់ៗសម្រាប់ប្រើនៅពេលប្រគល់ ទទួល សម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។

២.១១៨.៦.៥ បញ្ជូនស្រោមសំបុត្រធំ និងកញ្ចប់ " ឃ " ដូចចែងក្នុងចំណុច២.១១៨.៦.១ និង ២.១១៨.៦.៣ ខាងលើដើម្បីប្រគល់ជូន គ.ជ.ប យ៉ាងយូរត្រឹមម្ភៃបួន (២៤) ម៉ោង គិតចាប់ពីពេលដែល គធ/ខប បានចេញសេចក្តីសំរេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលត្រូវព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

២.១១៨.៧ ចំពោះការិយាល័យបោះឆ្នោតផ្សេងទៀតក្នុងក្រុង ស្រុក ខណ្ឌចំណុះរាជធានី ខេត្ត ដែលទោះបីមាន ឬគ្មានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ក៏ដោយ ក៏ប៉ុន្តែត្រូវបាន គធ/ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅការិយាល័យនោះ ឬទាំងនោះ ប្រធាន គធ/ខប ត្រូវចាត់ចែងវេចខ្ចប់រាល់កញ្ចប់ " ខស " ផ្ទុកកញ្ចប់សុវត្ថិភាព " កស " និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យ

បោះឆ្នោតពាក់ព័ន្ធ ទៅក្នុងកញ្ចប់ " ឃ$_{ស}$ " និង រាល់កញ្ចប់ " ខ$_{ខ}$ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក$_{ខ}$ " និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោត ទៅក្នុងកញ្ចប់ " ឃ$_{ខ}$ " ពាក់ព័ន្ធតាមប្រភេទក្រុមប្រឹក្សា ត្រៀមសម្រាប់ការបញ្ជូន និងប្រគល់ជូន គ.ជ.ប ។ ក្នុងនោះ ប្រធាន គធ/ខប ត្រូវ ៖

២.១១៤.៧.១ ចាត់ចែងវេចខ្ចប់រាល់កញ្ចប់ " ខ$_{ស}$" ផ្ទុកកញ្ចប់សុវត្ថិភាព" ក$_{ស}$" និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ដែល គធ/ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទៅក្នុងកញ្ចប់ " ឃ$_{ស}$ " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងរាល់កញ្ចប់ " ខ$_{ខ}$ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក$_{ខ}$ " និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ដែល គធ/ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ទៅក្នុងកញ្ចប់ " ឃ$_{ខ}$ " នៃក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១១៤.៧.២ ចាត់ចែងបំពេញ និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួល សម្ភារឯកសារបោះឆ្នោត (ទម្រង់បែបបទលេខ ១១០៧) ចំនួនបី (៣) ច្បាប់ សម្រាប់កញ្ចប់ "ឃ" នីមួយៗ ដែលត្រូវដាក់មួយ (១) ច្បាប់ ក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុងកញ្ចប់ " ឃ " នីមួយៗនោះ បន្ទាប់មកដាក់មួយ (១) ច្បាប់ទៀត ក្នុងហោប៉ៅកញ្ចប់ " ឃ " ពាក់ព័ន្ធ និងត្រៀមមួយ (១) ច្បាប់ៗ សម្រាប់ប្រើនៅពេលប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត នៅ គ.ជ.ប ។

២.១១៤.៧.៣ ចងភ្ជិតកញ្ចប់ " ឃ " រួចចាក់សោឃ្លុំ និងសរសេរសម្គាល់ខាងក្រៅកញ្ចប់ " ឃ " ទាំងនោះ ដោយប្រើប៊ិចហ្វឺតលុបមិនជ្រះ នូវលេខកូដការិយាល័យបោះឆ្នោតពីលេខ ... ដល់លេខ ... ឈ្មោះ និងលេខកូដ រាជធានី ខេត្ត ឬ/និងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ និងពាក្យ " យល់ព្រម" ។

២.១១៩.៨ ប្រធាន គធ/ខប ត្រូវអនុញ្ញាតឱ្យតំណាងគណបក្ស និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ បានសង្កេតពិនិត្យមើលក្នុងរាល់ដំណើរការនៃការរៀបចំ និង វេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ គ.ជ.ប និងត្រូវ អនុញ្ញាតឱ្យកត់ត្រាលេខសោឃ្លុំ ដែលបានចាក់នៅត្រង់មាត់កញ្ចប់ " ឃ " ដូចចែងក្នុងចំណុច ២.១១៩.៦.៤ និង ២.១១៩.៧.៣ ខាងលើ ។

២.១១៩.៩ ប្រសិនបើ កញ្ចប់ " ឃ " ដូចចែងក្រោមចំណុច ២.១១៩.៦ ឬ ២.១១៩.៧ ខាងលើ មានចំនួនច្រើនលើសពីមួយ ប្រធាន គធ/ខប ត្រូវចាត់ចែងឱ្យសរសេរ សម្គាល់លេខរៀង នៅខាងក្រៅកញ្ចប់ " ឃ " ទាំងនោះផង ។ ឧទាហរណ៍ ប្រសិនបើមានកញ្ចប់ " ឃ$_{ស}$ " ចំនួនបី (៣) ត្រូវសរសេរលើកញ្ចប់ " ឃ$_{ស}$ " ទីមួយថា ឃ$_{ស}$១/៣ លើកញ្ចប់ " ឃ$_{ស}$ " ទីពីរថា ឃ$_{ស}$២/៣ និងលើកញ្ចប់ " ឃ$_{ស}$ " ទីបីថា ឃ$_{ស}$៣/៣ ។

២.១១៩.១០ ប្រធាន គធ/ខប ត្រូវធានាថា រាល់កញ្ចប់សន្លឹកឆ្នោតត្រៀមបំរុងសម្រាប់ការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៃការិយាល័យបោះឆ្នោតនីមួយៗ ចំណុះ រាជធានី ខេត្ត របស់ខ្លួន (ប្រសិនបើមាន) ដែលមិនត្រូវបានប្រើប្រាស់ ត្រូវតែបានវេចខ្ចប់ដោយឡែក និងមិនត្រូវដាក់ក្នុងកញ្ចប់ " ឃ " ណាមួយ ឡើយ ហើយត្រូវបញ្ជូន និងប្រគល់ជូន គ.ជ.ប ស្របពេលជាមួយ នឹងការបញ្ជូនកញ្ចប់ " ឃពិសេស " និងកញ្ចប់ " ឃ " ។ ក្នុងការវេចខ្ចប់ បញ្ជូន និងប្រគល់ ទទួលសន្លឹកឆ្នោតត្រៀមបំរុងនេះ ប្រធាន គធ/ខប ត្រូវធានាថា ទម្រង់បែបបទលេខ ១១០៧ ត្រូវតែបានបំពេញ និងប្រើប្រាស់ តាមការកំណត់ក្នុងការបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ។

២.១១៩.១១ ប្រធាន គធ/ខប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ផ្សេងទៀត ដែលបានទទួលពី គកប ចំណុះរាជធានី ខេត្ត ត្រូវតែបាន វេចខ្ចប់ ដោយដាក់ក្នុងកេស ឬបាវ ឬកញ្ចប់ ទៅតាមសភាពជាក់ស្តែង និងបញ្ជូនទៅ គ.ជ.ប ស្របពេលជាមួយនឹងការបញ្ជូនកញ្ចប់ " ឃពិសេស" និងកញ្ចប់ " ឃ " ។ ក្នុងការវេចខ្ចប់ បញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ប្រធាន គធ/ខប ត្រូវធានាថា ទម្រង់ បែបបទលេខ ១១០៧ ត្រូវតែបានបំពេញ និងប្រើប្រាស់តាមការកំណត់ ក្នុងការបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ។

២.១១៤.១២ ប្រធាន គធ/ខប ត្រូវធានាថា កញ្ចប់ " ឃពិសេស " ដូចចែងក្នុងចំណុច ២.១១៤.២ និង ២.១១៤.៣ រាល់កញ្ចប់ " ឃ " ដូចចែងក្នុងចំណុច ២.១១៤.៦.៤ និង ២.១១៤.៧.៣ កញ្ចប់សន្លឹកឆ្នោតបំរុង ដូចចែងក្នុង ចំណុច ២.១១៤.១០ និងរាល់សម្ភារឯកសារបោះឆ្នោតនៅសល់ ដូចចែង ក្នុងចំណុច ២.១១៤.១១ ខាងលើ ត្រូវតែបានបញ្ជូនទៅ គ.ជ.ប យ៉ាងយូរ នៅថ្ងៃទីប្រាំមួយ (៦) បន្ទាប់ពីថ្ងៃបោះឆ្នោត ។

**ការដាក់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅ គ.ជ.ប ពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**

**ប្រការ ២.១១៥** ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬតំណាងគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ គធ/ខប លើពាក្យបណ្តឹងរបស់ខ្លួន ពាក់ព័ន្ធនឹងការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត និងដែលត្រូវបានបដិសេធពាក្យបណ្តឹងក្នុងការអនុវត្តករណី ដូចចែងក្នុងចំណុច ២.១១១.៤ និង ២.១១១.៩ ខាងលើ ឬជំទាស់នឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬ/និងរាជធានី ខេត្ត មានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចបដិសេធលើពាក្យបណ្តឹង ឬថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១១៥.១ រាល់ពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដូចបញ្ជាក់ក្នុងប្រការ ២.១១៥ ខាងលើ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងដាក់នៅទីស្តីការ គ.ជ.ប ហើយ គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងទាំងនេះ ក្នុងរយៈពេល យ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

២.១១៥.២ ប្រសិនបើ នៅក្នុងរយៈពេលកំណត់ខាងលើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថា គ្មានការប្តឹងទៅនឹងសេចក្តីសម្រេចបដិសេធរបស់ គធ/ខប ឬទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយឡើយ ។

២.១១៥.៣ អ្នកប្តឹងជំទាស់ឬតំណាងដែលមានបំណងប្តឹងតវ៉ា ឬប្តឹងជំទាស់ ដូចបញ្ជាក់ក្នុងប្រការ ២.១១៥ ខាងលើ ត្រូវបំពេញ និងចុះហត្ថលេខាលើពាក្យបណ្តឹងដែលក្នុងនោះត្រូវផ្តល់ព័ត៌មានច្បាស់លាស់មួយចំនួន ដូចចែងចាប់ពីចំណុច ២.១១១.១.១ ដល់ ២.១១១.១.៧ ខាងលើ ។

២.១១៥.៤ ចំពោះពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដែលត្រូវបានដាក់ក្រោយពេលវេលាដូចចែងក្នុងប្រការ ២.១១៥ ខាងលើ អគ្គលេខាធិការ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ ចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្តឹងនោះ ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១១៥.៥ ចំពោះពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ណាមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ដូចមានចែងក្នុងចំណុច ២.១៣៣.៥ ខាងក្រោម មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្តឹង ឬអ្នកតំណាង ឱ្យបំពេញបន្ថែមចំណុចខ្វះខាតមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹងមិនបានបំពេញបន្ថែមចំណុចខ្វះខាត អគ្គលេខាធិការ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ រួចចុះហត្ថលេខា និងបោះត្រា គ.ជ.ប ហើយ ប្រគល់ជូន អ្នកប្តឹងមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១១៥.៦ ចំពោះពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ណាមួយ ដែលមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ និងត្រូវបានដាក់ក្នុងរយៈពេលដូចចែងក្នុងប្រការ ២.១១៥ ខាងលើ មន្ត្រីជំនាញ នៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះពេលវេលា និងកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬអ្នកតំណាងមួយ (១) ច្បាប់ រក្សាទុកប្រើពេលសវនាការមួយ (១) ច្បាប់ និងបិទផ្សាយជាសាធារណៈមួយច្បាប់ (១) រួចជម្រាបអ្នកប្តឹង ឬអ្នកតំណាងថា គ.ជ.ប នឹងសម្រេចលើពាក្យបណ្តឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ ។

២.១១៥.៧ មន្ត្រីទទួលពាក្យបណ្តឹងត្រូវរាយការណ៍អំពីករណីបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដោយភ្ជាប់ពាក្យបណ្តឹងដែលបានទទួល ជូន គ.ជ.ប ជាបន្ទាន់ តាមរយៈ

អគ្គលេខាធិការ ដើម្បី គ.ជ.ប សម្រេចកំណត់អំពីករណី នៃការត្រួតពិនិត្យ និងបញ្ជាក់លទ្ធផល និងអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីរាប់សន្លឹកឆ្នោតឡើងវិញ ។ ផ្អែកតាមការសម្រេចរបស់ គ.ជ.ប អគ្គលេខាធិការ ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ និងបញ្ជាក់លទ្ធផល ឱ្យធ្វើការត្រួតពិនិត្យ និងបញ្ជាក់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ នឹងពាក្យបណ្តឹងនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ។

**ការបង្កើតក្រុមទទួលសម្ភារឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិបំរើការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**

**ប្រការ ២.១១៦** ក្នុងគោលបំណងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គ.ជ.ប ត្រូវបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតមួយ (១) ក្រុមត្រួតពិនិត្យលទ្ធផលមួយចំនួនតាមការចាំបាច់ និងក្រុមកំណត់បែងចែកអាសនៈមួយ (១) ព្រមទាំងត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីបំរើឱ្យការងារត្រួតពិនិត្យលទ្ធផលនេះ ។

២.១១៦.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតមួយត្រូវបានបង្កើតឡើងនៅ គ.ជ.ប ដើម្បីធានាការទទួលកញ្ចប់" ឃពិសេស" ដាក់សំណុំឯកសារលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងកញ្ចប់ " ឃ" ដាក់សម្ភារឯកសារបោះឆ្នោតពាក់ព័ន្ធ និងសម្ភារឯកសារផ្សេងទៀត ដូចចែងក្នុងចំណុច ២.១១៤.១២ ដែល គធ/ខប បានបញ្ជូន និងប្រគល់ជូន គ.ជ.ប ព្រមទាំងធានាការបែងចែក និងរក្សាទុកសម្ភារឯកសារទាំងនោះ នៅបន្ទប់ស្តុកតាមរាជធានី ខេត្តនីមួយៗ ។

២.១១៦.១.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតត្រូវដឹកនាំដោយប្រធាននាយកដ្ឋានរដ្ឋបាល និងរួមមានមន្ត្រីនាយកដ្ឋានប្រតិបត្តិការពីរ (២) រូប មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មមួយ (១) រូប និងមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុមួយ (១) រូប ជាសមាជិក ។

២.១១៦.១.២ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ។

២.១១៦.២ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប មួយចំនួនត្រូវបានបង្កើតឡើង តាមការចាំបាច់នៅ គ.ជ.ប ដើម្បីអនុវត្តការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោត

ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ។ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ រួមមានសមាសភាពដែលត្រូវបានតែងតាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋាននានា ចំណុះអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប និងត្រូវបានបែងចែក ឱ្យទទួលបន្ទុកត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក្នុងរាជធានី ខេត្តមួយ ឬច្រើន ។

២.១១៦.២.១ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ត្រូវមានសមាសភាពបួន (៤) រូប ដែលដឹកនាំដោយប្រធានមួយ (១) រូប អនុប្រធានមួយ (១) រូប លេខាធិការ មួយ (១) រូប និងជំនួយការមួយ (១) រូប ។

២.១១៦.២.២ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ។

២.១១៦.៣ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗរបស់ គ.ជ.ប មានភារកិច្ចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ ដោយឡែកពីគ្នា រួចត្រូវបំពេញតួលេខលទ្ធផល នៃការត្រួតពិនិត្យនេះ នៅលើតារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧គពស) សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧គព២) សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។ ក្នុងករណី ការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណាមួយ មានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ទៅនឹងភាពមិនប្រក្រតី នៃការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬមានការប្ដឹងតវ៉ា ឬ/និងជំទាស់ទៅនឹងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវបានដាក់នៅ គ.ជ.ប ឬលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ត្រូវបានព្យួរជាបណ្ដោះអាសន្នដោយ គធ/ខប ក្រុមត្រួតពិនិត្យលទ្ធផល ត្រូវអនុវត្តការងារបន្ថែម ដោយធ្វើរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ ។ ប្រធានក្រុមត្រូវធានាថា តារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧គពស ឬ១១១៧គព២) និងរបាយការណ៍ខាងលើត្រូវបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃ ក្រុមពាក់ព័ន្ធ និងត្រូវដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យ សម្រេច ។

២.១១៦.៣.១ ដើម្បីត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ប្រធានក្រុមត្រូវផ្អែកលើតារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៦តពស) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១១ស) និងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៨ស) ។

២.១១៦.៣.២ ដើម្បីត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ប្រធានក្រុមត្រូវផ្អែកលើតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១៦តពខ) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១១ខ) និងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១៨ខ) ។

២.១១៦.៣.៣ របាយការណ៍របស់ គធ/ខប ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " ឬ " ក$_{ខ}$ " និងការរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើមាន) ។

២.១១៦.៣.៤ សេចក្ដីសម្រេចរបស់ គធ/ខប លើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ និងរាល់ឯកសារពាក់ព័ន្ធនឹងពាក្យបណ្ដឹង (ប្រសិនបើមាន) ។

២.១១៦.៣.៥ កំណត់ហេតុស្ដីពីលទ្ធផលនៃការចាប់ឆ្នោត ដូចចែងក្នុងចំណុច ២.១១៣.៧ និង ២.១១៣.៨ ខាងលើ (ប្រសិនបើមាន ) ។

២.១១៦.៣.៦ ពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ដែលបានដាក់នៅ គ.ជ.ប ដូចចែងក្រោមប្រការ ២.១១៥ ខាងលើ (ប្រសិនបើមាន) ។

២.១១៦.៣.៧ លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " ឬ " ក$_{ខ}$ " និងការរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើ គ.ជ.ប សម្រេចឱ្យធ្វើដូច្នេះ) ។

២.១១៦.៤ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប មួយក្រុមត្រូវបានបង្កើតឡើងនៅ គ.ជ.ប ដើម្បីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងអស់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអនុវត្តការបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងកុំព្យូទ័រ និងការអនុវត្តកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ។

២.១១៦.៤.១ ក្រុមកំណត់បែងចែកអាសនៈ ត្រូវមានសមាសភាពមួយចំនួនតាមការចាំបាច់ ដែលត្រូវបានតែងតាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងខុទ្ទកាល័យអគ្គលេខាធិការ ។

២.១១៦.៤.២ ក្រុមនេះត្រូវដឹកនាំដោយប្រធានមួយ (១) រូប ដែលជាប្រធាននាយកដ្ឋានប្រតិបត្តិការ អនុប្រធាន (១) រូប ដែលជាប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម អនុប្រធានមួយ (១) រូបទៀត ដែលជាអនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវចាត់តាំងឱ្យមានលេខាធិការមួយ (១) រូប ជាជំនួយការ ។

២.១១៦.៤.៣ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ។

២.១១៦.៥ ក្រុមកំណត់បែងចែកអាសនៈ នៃ គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួននៅនាយកដ្ឋានប្រតិបត្តិការ និងត្រូវមានភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ៖

២.១១៦.៥.១ បញ្ចូលជាបណ្ដើរៗ នូវទិន្នន័យលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ

ចំណុះរាជធានី ខេត្ត នីមួយៗ ទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមតារាងត្រួតពិនិត្យ និងបញ្ជាក់លទ្ធផល របស់ក្រុមត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧តពស ឬ ១១១៧តព២) ដែល គ.ជ.ប បានពិនិត្យសម្រេចរួចហើយ ។

២.១១៦.៥.២ បោះពុម្ពសេចក្ដីព្រាងតារាងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យបញ្ជាក់ និងផ្សព្វផ្សាយជាសាធារណៈ ។

២.១១៦.៥.៣ កែតម្រូវតួលេខលទ្ធផល យោងតាមសេចក្ដីសម្រេចរបស់ គ.ជ.ប លើពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ (ប្រសិនបើមាន) និងរៀបចំបោះពុម្ពសេចក្ដីព្រាងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទូទាំងប្រទេស និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យបញ្ជាក់ជាផ្លូវការ និងផ្សព្វផ្សាយសាធារណៈ ។

២.១១៦.៥.៤ ត្រួតពិនិត្យ និងកំណត់បែងចែកអាសនៈ យោងតាមតារាងលទ្ធផលផ្លូវការ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ ដោយគណនាតាមការធ្វើប្រមាណវិធីដោយដៃ និងដោយប្រើកម្មវិធីបែងចែកអាសនៈក្នុងកុំព្យូទ័រ តាមរូបមន្តដែលកំណត់ដោយច្បាប់ និងដូចចែងក្នុងជំពូកទី ២ ផ្នែកទី ២ នៃ ប.ន.ក នេះ ។

២.១១៦.៥.៥ បោះពុម្ពតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈក្រុមប្រឹក្សា ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវទទួលបាន តាមប្រភេទនីមួយៗ រួចផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលនៃការបែងចែកអាសនៈដែលគណនាដោយដៃ បន្ទាប់មកត្រួតពិនិត្យ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ តាមចំនួនអាសនៈ និងលំដាប់លេខរៀងពីក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលទទួលបានអាសនៈ បំពេញទៅក្នុងសេចក្ដីព្រាងសេចក្ដីប្រកាសលទ្ធផល

នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ដោយមានបញ្ជាក់បេក្ខជនជាប់ឆ្នោតជាប្រធាន និងជាសមាជិកក្រុមប្រឹក្សាផង ។

២.១១៦.៥.៦ ផ្ទៀងផ្ទាត់បន្ថែមទៀតនូវតួលេខ និងទិន្នន័យក្នុងសេចក្ដីព្រាងសេចក្ដីប្រកាសលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ ជាមួយនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទម្រង់បែបបទលេខ ១១១៨ស ឬ ១១១៨ខ) ។

២.១១៦.៥.៧ រៀបចំតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈ ដែលបានគណនាឃើញ តាមវិធីទាំងពីរ មួយមុខមួយ (១) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយលេខាធិការ អនុប្រធានក្រុម និងប្រធានក្រុម និងសេចក្ដីព្រាងសេចក្ដីប្រកាស លទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទម្រង់បែបបទលេខ ១១១៨ស ឬ ១១១៨ខ) ចំនួនប្រាំ (៥) ច្បាប់ តាមប្រភេទក្រុមប្រឹក្សានីមួយៗ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចជាផ្លូវការ ។

២.១១៦.៦ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវណែនាំ និងចាត់ចែងក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប នៅក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងកិច្ចប្រតិបត្តិការកំណត់បែងចែកអាសនៈក្រុមប្រឹក្សា តាមប្រភេទនីមួយៗ ។ អគ្គលេខាធិការត្រូវពិនិត្យរាល់សំណុំឯកសាររបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។

២.១១៦.៧ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវត្រៀមបន្ទប់មួយចំនួននៅទីស្ដីការ គ.ជ.ប សម្រាប់ធ្វើជាឃ្លាំងស្ដុកកញ្ចប់ " ឃពិសេស " ដាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងកញ្ចប់ " ឃ " ដាក់សម្ភារឯកសារបោះឆ្នោតពាក់ព័ន្ធ ក្នុងនោះត្រូវ ៖

២.១១៦.៧.១ ត្រៀមបន្ទប់មួយដោយឡែកនៅជាន់ផ្ទាល់ដី សម្រាប់រក្សាទុករាល់ស្រោមសំបុត្រធំ ដាក់សេចក្ដីសម្រេចញ្ញើរជា

បណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតរបស់ គធ/ខប និងរាល់កញ្ចប់ " ឃ " ដាក់កញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធនឹងការបដិសេធនោះ ។

២.១១៦.៧.២ ត្រៀមបន្ទប់មួយដោយឡែកនៅជាន់ទី ១ សម្រាប់ដាក់រាល់កញ្ចប់ "ឃពិសេស" នៃ គធ/ខប ទាំងអស់ ។

២.១១៦.៧.៣ ត្រៀមបន្ទប់មួយចំនួននៅជាន់ផ្ទាល់ដី សម្រាប់ស្តុកកញ្ចប់ " ឃ " ដែលមានដាក់កញ្ចប់ " ខ " ហើយដែលត្រូវដាក់ដោយឡែកពីគ្នា ទៅតាមរាជធានី ខេត្តនីមួយៗ ។

២.១១៦.៨ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវត្រៀមបន្ទប់ធំទូលាយមួយចំនួន ឬបន្ទប់តូចៗច្រើន ដែលអាចឱ្យក្រុមត្រួតពិនិត្យលទ្ធផលបំពេញការងាររបស់ខ្លួនបានល្អ ។

២.១១៦.៨.១ ក្រុមត្រួតពិនិត្យលទ្ធផលពីរ ឬច្រើនក្រុម អាចបំពេញការងាររបស់ខ្លួនរួមគ្នាក្នុងបន្ទប់តែមួយ ឬនៅបន្ទប់ដោយឡែកពីគ្នា ដោយផ្អែកតាមលទ្ធភាពជាក់ស្តែង ។

២.១១៦.៨.២ សេចក្តីជូនដំណឹងស្តីពី ពេលវេលា កាលបរិច្ឆេទ ទីកន្លែង ឈ្មោះ និងលេខកូដការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ដែលត្រូវធ្វើការត្រួតពិនិត្យលទ្ធផលឡើងវិញ ព្រមទាំងលេខក្រុម និងឈ្មោះប្រធានក្រុមត្រួតពិនិត្យលទ្ធផល ដែលទទួលបន្ទុក ត្រូវតែបានបិទផ្សាយជាសាធារណៈនៅមុខទីស្តីការ គ.ជ.ប ដើម្បីជាដំណឹងដល់តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាងដែលទទួលបានការអនុញ្ញាតឱ្យចូលរួមក្នុងការត្រួតពិនិត្យលទ្ធផលនោះ ។

២.១១៦.៩ ក្នុងអំឡុងពេលនៃការត្រួតពិនិត្យលទ្ធផលនៅ គ.ជ.ប នេះ លក្ខខណ្ឌសន្តិសុខនៅជុំវិញបរិវេណ និងក្នុងទីស្តីការ គ.ជ.ប ព្រមទាំងសណ្តាប់ធ្នាប់ និងរបៀបរៀបរយត្រូវតែបានពង្រឹងតាមវិធានការរដ្ឋបាល ដែលគ្រប់គ្រង និងចាត់ចែងដោយអគ្គលេខាធិការ ។

២.១១៦.៩.១ តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាង ដែលទទួលបានការអនុញ្ញាតឱ្យ

ចូលរួមសង្កេតមើលការត្រួតពិនិត្យលទ្ធផល នៅទីស្តីការ គ.ជ.ប ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់អគ្គលេខាធិការនៃ គ.ជ.ប ឬមន្ត្រីដែលត្រូវបានប្រគល់សិទ្ធិ ។

២.១១៦.៩.២ តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាង ដែលទទួលបានការអនុញ្ញាតឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យលទ្ធផល នៅទីស្តីការ គ.ជ.ប ត្រូវគោរពក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត និង ប.ន.ក នេះ ហើយមិនត្រូវធ្វើសកម្មភាព ឬអំពើអ្វីមួយដែលរំខាន អុកឡុក ឬរារាំងការត្រួតពិនិត្យលទ្ធផលនេះ ឬបំពានលើសិទ្ធិអំណាច និងឯករាជភាពរបស់ គ.ជ.ប ឡើយ ។

២.១១៦.១០ ហាមជនគ្រប់រូបចូលក្នុងបន្ទប់ ដែលក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប កំពុងធ្វើការងារ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី គ.ជ.ប ឡើយ ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់ខាងលើនេះ នូវជនទាំងឡាយដូចខាងក្រោម ៖

២.១១៦.១០.១ មន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ ដែលបានទទួលការតែងតាំងពី គ.ជ.ប ។

២.១១៦.១០.២ តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អ្នកប្តឹងពាក់ព័ន្ធ ឬតំណាង ដែលទទួលបានការអនុញ្ញាត ព្រមទាំងអ្នកសង្កេតការណ៍ និងអ្នកយកពត៌មាន ដែលមានប័ណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។

២.១១៦.១០.៣ ប្រធាន អនុប្រធាន សមាជិកនៃ គ.ជ.ប និងអគ្គលេខាធិការនៃ គ.ជ.ប ឬមន្ត្រីដែលបានប្រគល់សិទ្ធិ ដែលមានបំណងត្រួតពិនិត្យ តាមដាន និងណែនាំក្នុងការត្រួតពិនិត្យលទ្ធផលរបស់ក្រុមនីមួយៗ ។

**ការប្រគល់ និងការទទួលកញ្ចប់ " ឃ " និងកញ្ចប់ " ឃពិសេស " ដាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្ដីការ គ.ជ.ប**

**ប្រការ ២.១១៧** មន្ត្រីនៃក្រុមទទួលសម្ភារឯកសារបោះឆ្នោតនៃ គ.ជ.ប ដែលបានតែងតាំងក្រោមចំណុច ២.១១៦.១ ខាងលើត្រូវមានវត្តមានជាប្រចាំនៅទីស្ដីការ គ.ជ.ប ចាប់ពីថ្ងៃដែល គធ/ខប ធ្វើការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ដើម្បីរង់ចាំទទួលសម្ភារ ឯកសារបោះឆ្នោត ដែល គធ/ខប ត្រូវបញ្ជូន និងប្រគល់ជូន គ.ជ.ប ។

២.១១៧.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីទទួលសម្ភារ ឯកសារបោះឆ្នោត ដោយផ្អែកតាមករណីដោយឡែកនៃរាជធានី ខេត្តនីមួយៗ ដែល គធ/ខប ពាក់ព័ន្ធ អាចវេចខ្ចប់ និងបញ្ជូនសម្ភារ ឯកសារបោះឆ្នោតជូន គ.ជ.ប ជាបី (៣) ផ្នែក ដូចខាងក្រោម ៖

២.១១៧.១.១ រាល់សេចក្ដីសម្រេចបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណាមួយ និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោត ដែលលទ្ធផលនៃការបោះឆ្នោតត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្ដោះអាសន្ន ដូចបញ្ជាក់ក្នុងចំណុច ២.១១៤.៦ ខាងលើ ។

២.១១៧.១.២ រាល់កញ្ចប់ " ឃ " និង កញ្ចប់ " ឃពិសេស " ដាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងរាជធានី ខេត្ត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ទាំងនោះត្រូវបាន គធ/ខប សម្រេចយល់ព្រម ដូចបញ្ជាក់ក្នុងចំណុច ២.១១៤.២ ២.១១៤.៣ និង ២.១១៤.៧ ខាងលើ ។

២.១១៧.១.៣ រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ដែលត្រូវបានវេចខ្ចប់ និងបញ្ជូនដោយឡែកមក គ.ជ.ប ដូចចែងក្នុងចំណុច ២.១១៤.១១ ខាងលើ ។

២.១១៧.២ ក្នុងករណី មន្ត្រីនៃ គធ/ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ២.១១៧.១.១ ខាងលើមកដល់ទីស្ដីការ គ.ជ.ប

ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតដែលមាននៅក្នុងស្រោមសំបុត្រធំ និងរាល់កញ្ចប់ " ឃ " ដាក់កញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យនោះ ត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្តោះអាសន្ន ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារ (ទម្រង់បែបបទលេខ ១១០៧) ទាំងបី (៣) ច្បាប់ ដែលមួយ (១) ច្បាប់នៅក្នុងស្រោមសំបុត្រធំ មួយ (១) ច្បាប់ កិបជាប់នឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំ និងមួយ (១) ច្បាប់ នៅនឹងមន្ត្រី គធ/ខប ដែលបញ្ជូនសម្ភារ ឯកសារមក ។

២.១១៧.២.១ មន្ត្រីក្នុងក្រុមទទួលសម្ភារឯកសារ ត្រូវកត់ត្រាមុខសម្ភារ ឯកសារ ដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ដែលប្រសិនបើ គ្រប់គ្រាន់ហើយ ត្រូវចារសម្គាល់ថា " គ្រប់ចំនួន " ។

២.១១៧.២.២ ប្រធានក្រុមទទួលសម្ភារ ឯកសារត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារ ដូចបញ្ជាក់ក្នុងចំណុច ២.១១៧.២ ខាងលើ រួចប្រគល់មួយ (១) ច្បាប់ជូនមន្ត្រី គធ/ខប ទទួលបន្ទុកការបញ្ជូន រក្សាមួយ (១) ច្បាប់ភ្ជាប់ទៅនឹងស្រោមសំបុត្រធំ និងដកមួយ (១) ច្បាប់ចងក្រងទុកជាឯកសារ ។

២.១១៧.២.៣ មន្ត្រីក្នុងក្រុមទទួលសម្ភារ ឯកសារ ត្រូវនាំយកស្រោមសំបុត្រធំ និងកញ្ចប់ " ឃ " ដាក់រាល់កញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោត ដែលលទ្ធផលនៃការបោះឆ្នោតត្រូវព្យួរជាបណ្តោះអាសន្ននោះ ទៅស្តុកទុកនៅក្នុងបន្ទប់ដែលបានត្រៀមបំរុងទុក ដូចចែងក្នុងចំណុច ២.១១៦.៧.១ ខាងលើ និងត្រូវសរសេរសម្គាល់លេខកូដការិយាល័យបោះឆ្នោត និងរាជធានី ខេត្ត ពាក់ព័ន្ធផង ។

២.១១៧.២.៤ ប្រធានក្រុមទទួលសម្ភារ ឯកសារត្រូវរាយការណ៍ជាបន្ទាន់ ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ នូវឈ្មោះ និងលេខកូដការិយាល័យបោះឆ្នោត ដែលត្រូវបាន គធ/ខប សម្រេចព្យួរលទ្ធផលជាបណ្តោះអាសន្ននោះ ដោយដាក់អមទៅជាមួយនូវស្រោមសំបុត្រធំពាក់ព័ន្ធផង ។

២.១១៧.៣ ក្នុងករណី មន្ត្រីនៃ គធ/ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោត ដូច បញ្ជាក់ក្នុងចំណុច ២.១១៧.១.២ ខាងលើមកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងត្រួតពិនិត្យ មើលរាល់សម្ភារ ឯកសារបោះឆ្នោត ដែលមាននៅក្នុងកញ្ចប់ " ឃពិសេស" និងរាល់កញ្ចប់ " ឃ " ដាក់ កញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោត ពាក់ព័ន្ធទាំងអស់ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យទាំងនោះ ត្រូវបាន គធ/ខប សម្រេចយល់ព្រម ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃ ក្រុមទទួលសម្ភារ ឯកសារត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារ (ទម្រង់បែបបទលេខ ១១០៧) ទាំងបី (៣) ច្បាប់ ដោយឡែកពីគ្នា ដែលមួយ (១) ច្បាប់ នៅក្នុងកញ្ចប់ " ឃ " ឬ កញ្ចប់ " ឃពិសេស " មួយ (១) ច្បាប់ នៅក្នុងហោប៉ៅនៃកញ្ចប់ " ឃ " ឬកញ្ចប់ " ឃពិសេស " និងមួយ (១) ច្បាប់នៅនឹងមន្ត្រី គធ/ខប ដែលបញ្ជូនសម្ភារ ឯកសារមក ។

២.១១៧.៣.១ មន្ត្រីក្នុងក្រុមទទួលសម្ភារ ឯកសារ ត្រូវកត់ត្រាមុខសម្ភារ ឯកសារដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ដែលប្រសិនបើ គ្រប់គ្រាន់ហើយ ត្រូវចារសម្គាល់ថា "គ្រប់ចំនួន " ។

២.១១៧.៣.២ ប្រធានក្រុមទទួលសម្ភារ ឯកសារ ត្រូវចុះហត្ថលេខាលើ លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារ ដូចបញ្ជាក់ ក្នុងចំណុច ២.១១៧.៣ ខាងលើ រួចប្រគល់មួយ (១) ច្បាប់ ជូនមន្ត្រី គធ/ខប ទទួលបន្ទុកការបញ្ជូន ដាក់មួយ (១) ច្បាប់ ក្នុងហោប៉ៅកញ្ចប់ " ឃ " ឬ កញ្ចប់ " ឃពិសេស " វិញ និងដកមួយ (១) ច្បាប់ ចងក្រង ទុកជាឯកសារ ។

២.១១៧.៣.៣ មន្ត្រីទទួលសម្ភារឯកសារត្រូវនាំយកកញ្ចប់ " ឃពិសេស " នៃរាជធានី ខេត្តពាក់ព័ន្ធ ទៅស្តុកទុកនៅក្នុងបន្ទប់ ដែល បានត្រៀមបំរុងទុក ដូចចែងក្នុងចំណុច ២.១១៦.៧.២ ខាងលើ ដោយ ត្រូវដាក់តាមលំដាប់លេខកូដរាជធានី ខេត្ត នីមួយៗ ។

២.១១៧.៣.៤ មន្ត្រីក្នុងក្រុមទទួលសម្ភារ ឯកសារ ត្រូវនាំយករាល់កញ្ចប់ " ឃ" ដាក់កញ្ចប់ " ខ" នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យទាំងនោះ ត្រូវបាន គធ/ខប សម្រេចយល់ព្រម ទៅស្តុកទុកនៅក្នុងបន្ទប់ដែលបានត្រៀមបំរុងទុក ដូចចែងក្នុងចំណុច ២.១១៦.៧.៣ ខាងលើ និងត្រូវសរសេរសម្គាល់លេខកូដរាជធានី ខេត្តពាក់ព័ន្ធផង ។

២.១១៧.៣.៥ ប្រធានក្រុមទទួលសម្ភារ ឯកសារត្រូវរាយការណ៍ជាបន្ទាន់ ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការនូវរាជធានី ខេត្ត ដែលបានប្រគល់កញ្ចប់ " ឃពិសេស " និងរាល់កញ្ចប់ " ឃ" ដាក់កញ្ចប់ " ខ" នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតទាំងនោះ ត្រូវបាន គធ/ខប សម្រេចយល់ព្រម ។ ប្រសិនបើ ក្នុងរាជធានី ខេត្តពាក់ព័ន្ធមានការិយាល័យបោះឆ្នោតណាមួយមានបណ្តឹង ត្រូវបានដាក់នៅ គធ/ខប និងដែលមានកញ្ចប់សុវត្ថិភាព " ក" មួយ ឬច្រើន ត្រូវបានបើក និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រធានក្រុមត្រូវបញ្ជាក់បន្ថែមក្នុងរបាយការណ៍ ខាងលើផងដែរនូវឈ្មោះ និងលេខកូដការិយាល័យបោះឆ្នោតដែលមានបណ្តឹងទាំងនោះ និងត្រូវដកយករាល់ស្រោមសំបុត្រ ដាក់សម្រង់សេចក្តីសម្រេចពាក់ព័ន្ធរបស់ គធ/ខប ពីក្នុងកញ្ចប់ " ឃពិសេស " ដាក់អមទៅជាមួយផង ។

២.១១៧.៤ ក្នុងករណី មន្ត្រីនៃ គធ/ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោតនៅសល់ដូចបញ្ជាក់ក្នុងចំណុច ២.១១៧.១.៣ ខាងលើ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើកកញ្ចប់ និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ដែលបានប្រគល់ជូន គ.ជ.ប ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារ (ទម្រង់បែបបទលេខ ១១០៧) ដែលប្រសិនបើ ត្រឹមត្រូវគ្រប់ចំនួនហើយ ប្រធាន

ក្រុមត្រូវចុះហត្ថលេខា លើលិខិតបញ្ជូន និងប្រគល់ទទួលនោះ រួចប្រគល់ជូនមន្ត្រី គធ/ខប ទទួលបន្ទុកការបញ្ជូនវិញមួយ (១) ច្បាប់ ។ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទេររាល់សម្ភារ ឯកសារនៅសល់ដែលបានទទួល ខាងលើ ដោយភ្ជាប់ជាមួយលិខិតបញ្ជូន និងប្រគល់ទទួលមួយ (១) ច្បាប់ ទៅឱ្យនាយកដ្ឋានប្រតិបត្តិការទទួលគ្រប់គ្រង និងរក្សាទុកនៅឃ្លាំង គ.ជ.ប ឬបន្ទប់ស្តុកដែលបានកំណត់ ។

**កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ**

**ប្រការ ២.១១៨** ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប មានភារកិច្ចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្ត ទូទាំងប្រទេស ក្នុងគោលបំណង បញ្ជាក់ជាចុងក្រោយអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ ការកំណត់ចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទទួលបាន ការស្រង់ឈ្មោះបេក្ខជនដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា និងការបញ្ជាក់ឈ្មោះបេក្ខជនជាប់ឆ្នោតដែលត្រូវទទួលតំណែងជាប្រធាន និងសមាជិកក្រុមប្រឹក្សា ដែល គធ/ខប បានធ្វើការត្រួតពិនិត្យម្តងរួចហើយ ។ ប្រសិនបើក្នុងការត្រួតពិនិត្យនេះ ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប យល់ព្រមតាមលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយនោះ ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈត្រូវបំពេញតារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧តពស ឬ ១១១៧តពខ) តារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈ និងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច និងប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬ/និង ក្រុង ស្រុក ខណ្ឌនោះ ជាផ្លូវការ និងជាសាធារណៈ ។

២.១១៨.១ នៅពេលដែល គ.ជ.ប បានទទួលរបាយការណ៍ពីក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត តាមរយៈអគ្គលេខាធិការ ដូចបញ្ជាក់ក្នុងចំណុច ២.១១៧.២.៤ និងពីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដូចបញ្ជាក់ក្នុងចំណុច ២.១១៥.៧ ខាងលើ គ.ជ.ប ត្រូវសម្រេចកំណត់ករណីនៃការិយាល័យបោះឆ្នោតនីមួយៗ ក្នុងរាជធានី ខេត្ត ដែលនឹងត្រូវធ្វើការត្រួតពិនិត្យលទ្ធផល និងត្រូវសម្រេចអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីរាប់សន្លឹកឆ្នោតឡើងវិញ ប្រសិនបើលក្ខខណ្ឌតម្រូវឱ្យធ្វើដូច្នេះ ។

២.១១៨.២ ផ្អែកតាមការកំណត់សម្រេចរបស់ គ.ជ.ប អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ ឱ្យអនុវត្តការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌចំណុះរាជធានី ខេត្ត ដែលក្រុមនីមួយៗ ទទួលបន្ទុក ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចាំបាច់ និងតាមករណី ដូចខាងក្រោម ៖

២.១១៨.២.១ ករណី ការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ណាដែលលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្ដោះអាសន្ន ។

២.១១៨.២.២ ករណី ការិយាល័យបោះឆ្នោតណា គ្មានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គធ/ខប ឬ/និង គ.ជ.ប ហើយដែលគ្មានកញ្ចប់សុវត្ថិភាព " ក " ណាមួយត្រូវបានបើក និងរាប់សន្លឹកឆ្នោតឡើងវិញ ។

២.១១៨.២.៣ ករណី ការិយាល័យបោះឆ្នោតណា ដែលមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ទៅនឹងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ណាមួយត្រូវបានដាក់នៅ គ.ជ.ប ដូចចែងក្នុងលក្ខខណ្ឌក្រោមប្រការ ២.១១៥ ខាងលើ និងត្រូវបានដាក់នៅ គធ/ខប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតនោះ ត្រូវបាន គធ/ខប បើក និងរាប់សន្លឹកឆ្នោតឡើងវិញ ប៉ុន្តែ គធ/ខប បានសម្រេចយល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅការិយាល័យបោះឆ្នោតនោះ ។

២.១១៨.៣ តំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មានដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប មានសិទ្ធិចូលរួមសង្កេតមើលក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅទីស្ដីការ គ.ជ.ប ។ ប្រសិនបើ បន្ទប់ចង្អៀត ការចូលរួមសង្កេតមើលរបស់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍... ដែលចែងក្នុងចំណុចនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ប្រធានក្រុមត្រួតពិនិត្យលទ្ធផល ឬក្រុមកំណត់បែងចែកអាសនៈ តាមរបៀបផ្លាស់ប្ដូរវេនគ្នា ។

២.១១៨.៤ អ្នកប្ដឹងពាក់ព័ន្ធ ឬតំណាងដែលពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់របស់គាត់ត្រូវបាន គធ/ខប សម្រេចយល់ព្រម ឬបដិសេធ ដូចចែងក្នុងចំណុច ២.១១១.៩ និង ២.១១១.១០ ខាងលើ នៃ ប.ន.ក នេះ និងអ្នកប្ដឹងពាក់ព័ន្ធ ឬតំណាងដែលបានដាក់ពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់នៅ គ.ជ.ប យោងតាមលក្ខខណ្ឌដូចចែងក្រោមប្រការ ២.១១៥ ខាងលើ ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលក្នុងការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធនៅទីស្ដីការ គ.ជ.ប ។ ប្រសិនបើ បន្ទប់ចង្អៀត ការចូលរួមសង្កេត មើលរបស់អ្នកប្ដឹងពាក់ព័ន្ធ ដែលចែងក្នុងចំណុចនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ប្រធានក្រុមត្រួតពិនិត្យលទ្ធផល ឬក្រុមកំណត់បែងចែកអាសនៈតាមរបៀបផ្លាស់ប្ដូរវេនគ្នា ។

២.១១៨.៥ កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល ក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅមណ្ឌលបោះឆ្នោតណាមួយ ប្រសិនបើចាប់ផ្ដើមហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ។

២.១១៨.៦ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវបើកកិច្ចប្រតិបត្តិការ ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដែលខ្លួនទទួលបន្ទុកម្ដងមួយមណ្ឌល នៅបន្ទប់ធំទូលាយណាមួយ ឬបន្ទប់តូចៗដោយឡែកពីគ្នា ដែលបានត្រៀមបំរុង ដូចចែងក្រោមចំណុច ២.១១៦.៨ ។ ក្នុងការត្រួតពិនិត្យលទ្ធផលខាងលើនេះ ប្រធានក្រុមត្រូវធានាឱ្យមានម៉ាស៊ីនគិតលេខមួយ (១) គ្រឿង និង ទម្រង់បែបបទសម្រាប់បំពេញតារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧តពស ឬ ១១១៧តព២) ព្រមទាំងរាល់សំណុំឯកសារយោង ដូចចែងចាប់ពីចំណុច ២.១១៦.៣.១ ដល់ ២.១១៦.៣.៧ ខាងលើ ។

២.១១៨.៧ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបើកកិច្ចប្រតិបត្តិការដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ម្ដងមួយមណ្ឌល បន្ទាប់ពីបានទទួលតារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧តពស ឬ ១១១៧តព២) ដែល គ.ជ.ប បានពិនិត្យ សម្រេចរួច ។

**ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាដែល គធ/ខប បានសម្រេចព្យួរលទ្ធផលជាបណ្ដោះអាសន្ន**

**ប្រការ** ២.១១៩ យោងតាមការកំណត់របស់ គ.ជ.ប ដូចចែងក្នុងចំណុច ២.១១៨.១ ខាងលើ ប្រសិនបើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ស្ថិតក្នុងករណី ដែលលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ ត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្ដោះអាសន្ន អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលដែលទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈឱ្យធ្វើការត្រួតពិនិត្យលទ្ធផលតាមនីតិវិធីដូចខាងក្រោម ៖

២.១១៩.១ ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ ត្រូវធានាថា ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្ដោះអាសន្ន ត្រូវបានអនុវត្តយ៉ាងរួសរាន់ និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចក្នុងរយៈពេលយ៉ាងយូរបួន (៤) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសេចក្ដីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ឬនៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណាមួយ ។

២.១១៩.២ ក្នុងករណី គ.ជ.ប សម្រេចមិនឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធដើម្បីរាប់សន្លឹកឆ្នោតឡើងវិញទេ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវធ្វើការត្រួតពិនិត្យលទ្ធផល ដោយគ្រាន់តែផ្អែកលើរាល់សំណុំឯកសារ ដែលមានក្នុងស្រោមសំបុត្រធំដាក់សេចក្ដីសម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ ដូចចែងក្នុងចំណុច ២.១១៤.៦.១ ប៉ុណ្ណោះ ។

២.១១៩.៣ ក្នុងករណី គ.ជ.ប សម្រេចតម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីរាប់សន្លឹកឆ្នោតឡើងវិញនោះ ក្រុមត្រួតពិនិត្យលទ្ធផល ត្រូវធ្វើការត្រួតពិនិត្យ ដោយផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំ ដាក់សេចក្ដីសម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ ដូចចែងក្នុងចំណុច ២.១១៤.៦.១ ផង និងត្រូវអនុវត្តបន្ថែមការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ តាមលំនាំនីតិវិធីទាំងឡាយ ដូចចែងចាប់ពីចំណុច ២.១១១.៧.១ ដល់ចំណុច ២.១១១.៧.៤ ខាងលើ សម្រាប់កញ្ចប់សុវត្ថិភាព " ក " នីមួយៗ (ប្រសិនបើមានកញ្ចប់សុវត្ថិភាព " ក " លើសពីមួយ (១) ត្រូវបើក) ។

២.១១៩.៤ បន្ទាប់ពីបានបញ្ចប់ការត្រួតពិនិត្យលទ្ធផល ដូចចែងក្នុងចំណុច២.១១៩.២ ឬ ដូចចែងក្នុងចំណុច ២.១១៩.៣ ខាងលើ ប្រធានក្រុមត្រួតពិនិត្យលទ្ធផល ត្រូវធានាថា តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ (ទម្រង់បែបបទលេខ ១១០៧តពស ឬ ១១០៧តពខ) ចំនួនមួយ (១) ច្បាប់ និងរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតចំនួន មួយ (១) ច្បាប់ ត្រូវតែបានធ្វើ និងចុះហត្ថលេខា ដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យ សម្រេច ។

២.១១៩.៥ អគ្គលេខាធិការត្រូវចារយោបល់លើតារាងត្រួតពិនិត្យលទ្ធផល និងរបាយការណ៍ដែលបានដាក់ជូនពិនិត្យដូចចែងក្នុងចំណុច ២.១១៩.៤ ខាងលើ រួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ដើម្បីពិនិត្យសម្រេច ។ អគ្គលេខាធិការត្រូវ ៖

២.១១៩.៥.១ ចារលើកយោបល់ស្នើសុំការយល់ព្រមតាមសេចក្តីសម្រេចព្យួរលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារបស់ គធ/ខប ប្រសិនបើមានភាពមិនប្រក្រតីធ្ងន់ធ្ងរ នាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ ។

២.១១៩.៥.២ ចារលើកយោបល់ស្នើសុំការបដិសេធសេចក្តីសម្រេចព្យួរលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារបស់ គធ/ខប និងយោបល់ស្នើសុំការយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ ប្រសិនបើ គ្មានភាពមិនប្រក្រតីនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះទេ ។

២.១១៩.៦ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្តីសម្រេចព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ របស់ គធ/ខប ប្រធាន គ.ជ.ប ត្រូវ ៖

២.១១៩.៦.១ ចារយល់ព្រមលើសេចក្តីសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារបស់ គធ/ខប រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

២.១១៩.៦.២ ចារយល់ព្រមលើរបាយការណ៍លើកស្នើយោបល់ ដូចចែង ក្នុងចំណុច ២.១១៩.៥.១ និងចារបដិសេធលើតារាង ត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧គពស ឬ ១១១៧គព២) ដូចចែងក្នុងចំណុច ២.១១៩.៤ ខាង លើ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

២.១១៩.៦.៣ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេច បដិសេធលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១២០៣) ដោយបញ្ជាក់ ច្បាស់ពីមូលហេតុនៃការបដិសេធផង ហើយដែលត្រូវចុះ ហត្ថលេខា និងកាលបរិច្ឆេទ ដោយប្រធាន គ.ជ.ប ។

២.១១៩.៦.៤ ធានាថា សម្រង់សេចក្តីសម្រេចបដិសេធខាងលើ ត្រូវបាន ត្រៀមក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនម្ចាស់ដើម បណ្តឹងមួយ (១) ច្បាប់ ជូនគ្រប់តំណាងគណបក្ស នយោបាយឈរឈ្មោះបោះឆ្នោត ក្នុងមណ្ឌលបោះឆ្នោត ពាក់ព័ន្ធ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១១៩.៦.៥ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបាន បដិសេធលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើស រើសក្រុមប្រឹក្សានេះជាសេចក្តីសម្រេចចុងក្រោយ បិទផ្លូវ តវ៉ា ហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោត សាជាថ្មី នៅការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នោះ នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ មិនឱ្យលើសពី ប្រាំបី (៨) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចបដិសេធ ។

២.១១៩.៦.៦ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យ លទ្ធផល សេចក្តីសម្រេចរបស់ គធ/ខប ដែលមានចំណារ ប្រធាន គ.ជ.ប និងសេចក្តីសម្រេចរបស់ គ.ជ.ប បដិសេធ លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមួយ (១) ច្បាប់ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមត្រួតពិនិត្យ លទ្ធផលទទួលបន្ទុក ដាក់ក្នុងស្រោមសំបុត្រធំ រួចដាក់ទៅ ក្នុងកញ្ចប់ " យពិសេស " នៃរាជធានី ខេត្តពាក់ព័ន្ធ ។

២.១១៩.៦.៧ ធានាថា ក្រុមត្រួតពិនិត្យលទ្ធផលបានវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ដាក់ក្នុងកញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារ ឯកសារដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

២.១១៩.៧ យោងសម្រង់សេចក្តីសម្រេចបដិសេធរបស់ គ.ជ.ប ដូចចែងក្នុងចំណុច ២.១១៩.៦.៣ ខាងលើ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវបានបដិសេធ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចចែងក្នុងផ្នែកទី ៩ ជំពូកទី ២ នៃ ប.ន.ក នេះ ។

២.១១៩.៨ ប្រសិនបើ គ.ជ.ប សម្រេចមិនយល់ព្រមតាមសេចក្តីសម្រេចព្យួរជាបណ្តោះអាសន្ន នូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ របស់ គធ/ខប ដោយបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធនោះ ប្រធាន គ.ជ.ប ត្រូវ ៖

២.១១៩.៨.១ ចារបដិសេធលើ សម្រង់សេចក្តីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ របស់ គធ/ខប រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

២.១១៩.៨.២ ចារបដិសេធលើរបាយការណ៍លើកស្នើយោបល់ ដូចចែងក្នុងចំណុច ២.១១៩.៥.១ ឬចារយល់ព្រមលើរបាយការណ៍លើកស្នើយោបល់ ដូចចែងក្នុងចំណុច ២.១១៩.៥.២ និងចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧គពស ឬ ១១១៧គពខ) ដូចចែងក្នុងចំណុច ២.១១៩.៤ ខាងលើ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

២.១១៩.៨.៣ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១២០៣) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធរបស់ គ.ជ.ប លើសម្រង់សេចក្តីសម្រេចបដិសេធលទ្ធផល នៃការបោះ

ឆ្នោតជ្រើសរើសក្រុមប្រឹក្សា របស់ គធ/ខប និងមូលហេតុ នៃការទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាពាក់ព័ន្ធផង ហើយត្រូវចុះហត្ថលេខា និងកាល បរិច្ឆេទ ដោយប្រធាន គ.ជ.ប ។

២.១១៩.៨.៤ ធានាថា សម្រង់សេចក្តីសម្រេចខាងលើ ត្រូវបានត្រៀម ក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនម្ចាស់ដើមបណ្តឹង មួយ (១) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយ ឈរឈ្មោះ ក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធមួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុក ជាឯកសារមួយ (១) ច្បាប់ ។

២.១១៩.៨.៥ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបាន យល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សានោះ ជាសេចក្តីសម្រេចចុងក្រោយ ។

២.១១៩.៨.៦ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យ លទ្ធផល សម្រង់សេចក្តីសម្រេចរបស់ គធ/ខប ដែលមាន ចំណាររបស់ប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេច របស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះ ឆ្នោតជ្រើសរើសក្រុមប្រឹក្សាមួយមុខមួយ (១) ច្បាប់ ព្រម ទាំងឯកសារក្នុងស្រោមសំបុត្រធំ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់បែងចែកអាសនៈ ដើម្បីមុខការ ។

២.១១៩.៨.៧ ធានាថា ក្រុមត្រួតពិនិត្យលទ្ធផលបានវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ដាក់ក្នុងកញ្ចប់ " ខ " ពាក់ព័ន្ធ រួចនាំយកទៅ ប្រគល់ឱ្យក្រុមទទួលសម្ភារឯកសារ ដើម្បីរក្សាទុកនៅ កន្លែងដើមវិញ ។

២.១១៩.៩ នៅពេលទទួលបានសំណុំឯកសារដូចក្នុងចំណុច ២.១១៩.៨.៦ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈ ត្រូវចាត់ចែង ៖

២.១១៩.៩.១ បញ្ចូលទិន្នន័យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សានោះ ទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមតារាងត្រួត ពិនិត្យលទ្ធផលពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១១១៧តពស

ឬ ១១១៧តព៦) ដែលមានចំណាររបស់ប្រធាន គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ ។

២.១១៩.៩.២ ត្រួតពិនិត្យ និងកំណត់បែងចែកអាសនៈ ដោយផ្អែកតាមលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ ដោយប្រើកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ ក្នុងកុំព្យូទ័រ និងដោយគណនា តាមការធ្វើប្រមាណវិធីតាមរូបមន្ត ដូចចែងក្នុងផ្នែកទី ២ ជំពូកទី ២ នៃ ប.ន.ក នេះ ។

២.១១៩.៩.៣ បោះពុម្ពតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈ សម្រាប់ក្រុមប្រឹក្សានោះ ដែលគណបក្សនយោបាយនីមួយៗត្រូវទទួលបាន រួចផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលនៃការបែងចែកអាសនៈ ដែលគណនាតាមការធ្វើប្រមាណវិធី បន្ទាប់មកត្រួតពិនិត្យ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា តាមចំនួនអាសនៈ និងលំដាប់លេខរៀង ពីក្នុងបញ្ជីបេក្ខជន នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលត្រូវទទួលបានអាសនៈ បំពេញទៅក្នុងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ (ទម្រង់បែបបទលេខ ១១១៨ស ឬ ១១១៨ខ) និងដោយមានបញ្ជាក់បេក្ខជនជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាផង ។

២.១១៩.៩.៤ រៀបចំតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈ ដែលបានគណនាឃើញ តាមវិធីទាំងពីរមួយមុខមួយ (១) ច្បាប់ ដែលត្រូវចុះហត្ថលេខា ដោយលេខាធិការ អនុប្រធានក្រុម និងប្រធានក្រុម និងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ (ទម្រង់បែបបទលេខ ១១១៨ស ឬ១១១៨ខ) ចំនួនប្រាំ (៥) ច្បាប់ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចជាផ្លូវការ ។

២.១១៩.១០ ក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលត្រូវបាន គធ/ខប សម្រេចព្យួរជាបណ្តោះអាសន្ន ប៉ុន្តែត្រូវបាន គ.ជ.បសម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ

ប្រសិនបើ មានករណីសំឡេងឆ្នោត ឬ/និងមធ្យមភាគ ស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ដែលនឹងត្រូវទទួលបានអាសនៈ ឬ/និង ដែលមានបេក្ខជនជាប់ឆ្នោត ដែលនឹងត្រូវទទួលតំណែងជាប្រធានក្រុមប្រឹក្សា គ.ជ.ប ត្រូវប្រគល់សិទ្ធិអំណាចជូនអគ្គលេខាធិការ ដើម្បីអនុវត្តការចាប់ឆ្នោត ដោយត្រូវផ្អែកតាមលំនាំនីតិវិធីស្តីពីការចាប់ឆ្នោតនៅ គឃ/ខប ដូចចែងក្នុងផ្នែកទី ២ ជំពូកទី ២ នៃ ប.ន.ក នេះ ។

**ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅការិយាល័យបោះឆ្នោត ដែលគ្មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ/ខប ឬ/និង គ.ជ.ប**

**ប្រការ ២.១២០** យោងតាមការកំណត់របស់ គ.ជ.ប ដូចចែងក្នុងចំណុច ២.១១៨.១ ខាងលើ ប្រសិនបើការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ដែលនឹងត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ស្ថិតក្នុងករណីការិយាល័យបោះឆ្នោត ដែលគ្មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ/ខប ឬ/និង គ.ជ.ប ហើយដែលគ្មានកញ្ចប់សុវត្ថិភាព " ក" ណាមួយត្រូវបានបើក និងរាប់សន្លឹកឆ្នោតឡើងវិញទេ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈ ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលតាមនីតិវិធីដូចខាងក្រោម ៖

២.១២០.១ ក្នុងករណីខាងលើនេះ ជាដំបូងផ្អែកតាមការណែនាំរបស់អគ្គលេខាធិការ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្ត ដែលក្រុមទទួលបន្ទុកដោយឡែកពីគ្នា ម្តងមួយមណ្ឌលបោះឆ្នោតៗ ដោយចាប់ផ្តើមពីមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ បន្ទាប់មកទើបអនុវត្តការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត នៅមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ជាក្រោយ ដោយផ្អែកលើរាល់ឯកសារពាក់ព័ន្ធ ដែលមាននៅក្នុងកញ្ចប់ " ឃពិសេស " ពាក់ព័ន្ធតាមប្រភេទក្រុមប្រឹក្សាប៉ុណ្ណោះ និងមិនត្រូវបើកកញ្ចប់សុវត្ថិភាព " ក" ណាមួយ ដើម្បីរាប់សន្លឹកឆ្នោតឡើងវិញទេ ។

២.១២០.២ ក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្តណាមួយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវ ៖

២.១២០.២.១ ចាត់សមាជិកក្រុមពីររូប ឱ្យទៅយកកញ្ចប់ " ឃពិសេស" នៃក្រុមប្រឹក្សាពាក់ព័ន្ធ ចំណុះរាជធានី ខេត្ត ដែលក្រុមទទួលបន្ទុក ម្តងមួយៗ ពីកន្លែងរក្សាស្តុក មកដាក់នៅលើតុចំពីមុខប្រធាន ។

២.១២០.២.២ បើកកញ្ចប់ " ឃពិសេស " នោះ រួចដកយករាល់ស្រោមសំបុត្រដាក់សំណុំឯកសារលទ្ធផលនៃការបោះឆ្នោត មកដាក់នៅលើតុ ដែលរួមមាន ៖

- លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១១១៨ស) ។
- តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១៦តពស) ។
- កំណត់ហេតុត្រួតពិនិត្យ បញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ (ទម្រង់បែបបទលេខ ១១១១ស) ។
- តារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) ចំពោះកញ្ចប់ " ឃពិសេស " ក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១២០.២.៣ រក្សាទុកកញ្ចប់ " ឃពិសេស " នៅក្បែរខ្លួនគាត់ដែលនៅក្នុងនោះមាន ៖

- របាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " និងការរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើមាន) ។
- កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទម្រង់បែបបទលេខ ១១០១ស និង ១១០២ស) ។
- តារាងកត់ត្រាសំឡេងឆ្នោត (ទម្រង់បែបបទលេខ ១១០៨ស ) ។

២.១២០.២.៤ ចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌនីមួយៗ ដោយផ្អែកលើសំណុំឯកសារលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដូចចែងក្នុងចំណុច ២.១២០.២.២

ខាងលើ ហើយប្រសិនបើ មានភាពមិនច្បាស់លាស់ ត្រូវឱ្យពិនិត្យបន្ថែមនូវឯកសារផ្សេងទៀត ដូចបញ្ជាក់ក្នុងចំណុច ២.១២០.២.៣ ខាងលើ ។

២.១២០.២.៥ ធានាថា របាយការណ៍សរសេរដៃស្តីពីលទ្ធផលនៃការត្រួតពិនិត្យខាងលើ ចំនួនមួយ (១) ច្បាប់ សម្រាប់មណ្ឌលបោះឆ្នោតនីមួយៗ ត្រូវបានធ្វើ និងចុះហត្ថលេខា ដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល ដោយត្រូវបញ្ជាក់ច្បាស់នូវខ្លឹមសារ ដូចខាងក្រោម ប្រសិនបើបានរកឃើញថា ៖

- តួលេខនៃលទ្ធផលដែលបានត្រួតពិនិត្យ មានភាពត្រឹមត្រូវ ។
- គធ/ខប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅមណ្ឌលបោះឆ្នោតណាមួយ ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវគូសឆូតលើតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង ។
- ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលមានមធ្យមភាគ ឬ/និងសំឡេងឆ្នោតគាំទ្រស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើនដែលត្រូវទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ឬ/និងដែលមានបេក្ខជនជាប់ឆ្នោតនឹងត្រូវបានទទួលតំណែងជាប្រធានក្រុមប្រឹក្សា ។

២.១២០.២.៦ ធានាថា តារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧តពស ឬ ១១១៧តពខ) ចំនួនមួយ (១) ច្បាប់ត្រូវបានបំពេញដោយមានបញ្ជាក់ច្បាស់នូវឈ្មោះ និងលេខកូដការិយាល័យបោះឆ្នោត លេខកូដក្រុង ស្រុក ខណ្ឌ ឬ/និងរាជធានី ខេត្តពាក់ព័ន្ធ និងត្រូវចុះហត្ថលេខា ដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល ។

២.១២០.២.៧ ធានាថារបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ដូច បញ្ជាក់ក្នុងចំណុច ២.១២០.២.៥ និង ២.១២០.២.៦ ខាងលើ ដែលអមដោយលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោត (ទម្រង់បែបបទលេខ ១១១៤ស ឬ ១១១៤ខ) តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត (ទម្រង់បែបបទលេខ ១១១៦តពស ឬ ១១១៦តពខ) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទម្រង់បែបបទលេខ ១១១១ស ឬ ១១១១ខ) តាមប្រភេទក្រុមប្រឹក្សានីមួយៗ ព្រមទាំងកំណត់ហេតុរបស់ គធ/ខប ស្តីពីលទ្ធផលនៃការចាប់ឆ្នោត (ប្រសិនបើមាន) ត្រូវបានដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យ សម្រេច ។

២.១២០.២.៨ ធានាថា រាល់របាយការណ៍ និងទម្រង់បែបបទ ដូចបានបញ្ជាក់ក្នុងចំណុច ២.១២០.២.៣ ខាងលើដែលបានប្រើក្នុងការត្រួតពិនិត្យលទ្ធផលនេះ ត្រូវតែបានច្រកក្នុងស្រោមសំបុត្រដូចដើម និងដាក់ទៅក្នុងកញ្ចប់ " យពិសេស " នៃក្រុមប្រឹក្សាពាក់ព័ន្ធវិញ ។

២.១២០.៣ ក្រុមត្រួតពិនិត្យលទ្ធផល ត្រូវធ្វើការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ទាំងអស់ចំណុះរាជធានី ខេត្ត ដែលគ្មានបណ្តឹង ម្តងមួយមណ្ឌលបោះឆ្នោតៗ រហូតដល់អស់ និងត្រូវអនុវត្តតាមនីតិវិធីដូចចែងចាប់ពីចំណុច ២.១២០.២.២ ដល់ ២.១២០.២.៨ ខាងលើ ។ នៅពេលបញ្ចប់ការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមមណ្ឌលបោះឆ្នោត ដែលគ្មានបណ្តឹងទាំងអស់ ក្នុងរាជធានី ខេត្តនីមួយៗ និងក្នុងពេលអនុវត្តចំណុច ២.១២០.២.៧ ខាងលើ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមត្រួតពិនិត្យលទ្ធផលត្រូវដាក់ភ្ជាប់អមទៅជាមួយនូវ តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទម្រង់បែបបទលេខ ១១១០ខ) ផង ។

២.១២០.៤ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ តារាងត្រួតពិនិត្យលទ្ធផល របស់ក្រុមត្រួតពិនិត្យ រួមជាមួយសំណុំឯកសារភ្ជាប់ជាមួយ ដែលបានដាក់ជូន ដូចចែងក្នុងចំណុច ២.១២០.២.៧ និង ២.១២០.៣ ខាងលើ ។ ប្រសិនបើ ពិនិត្យឃើញថាត្រឹមត្រូវហើយ អគ្គលេខាធិការត្រូវចារលើកយោបល់ស្នើសុំការ យល់ព្រមពី គ.ជ.ប រួចចុះហត្ថលេខា និង កាលបរិច្ឆេទលើរបាយការណ៍ សរសេរដោយដៃ ស្តីពីលទ្ធផលនៃការត្រួតពិនិត្យលទ្ធផល និងលើតារាងត្រួត ពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧តពស ឬ ១១១៧តព២) និង ដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច ។

២.១២០.៥ ប្រសិនបើ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាណាមួយ ប្រធាន គ.ជ.ប ត្រូវចារយល់ព្រមលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ដូចចែងក្នុងចំណុច ២.១២០.៤ ខាងលើ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ បន្ទាប់មកប្រគល់របាយការណ៍ និងតារាង ត្រួតពិនិត្យលទ្ធផល ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយ តាមរយៈអគ្គលេខា ធិការ ទៅឱ្យក្រុមកំណត់បែងចែកអាសនៈ ដើម្បីមុខការ ។

២.១២០.៦ នៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផលពីអគ្គលេខាធិការ ដូច បញ្ជាក់ក្នុងចំណុច ២.១២០.៥ ខាងលើ ក្រុមកំណត់បែងចែកអាសនៈ ត្រូវចាត់ចែងអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដូចចែងក្រោម ចំណុច ២.១១៦.៥ ខាងលើ និង ២.១២០.៧ ខាងក្រោម ដើម្បីផ្ទៀងផ្ទាត់ បញ្ជាក់អំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ នូវលទ្ធផលនៃការបោះឆ្នោតជ្រើស រើសក្រុមប្រឹក្សា ដែល គធ/ខប បានត្រួតពិនិត្យបញ្ជាក់ម្តងរួចហើយ ។

២.១២០.៧ ក្នុងការផ្ទៀងផ្ទាត់បញ្ជាក់អំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ ដូចចែងក្នុងចំណុច ២.១២០.៦ ប្រធានក្រុមកំណត់បែងចែកអាសនៈ ត្រូវចាត់ចែងធ្វើកុំព្យូទ័រកម្ម លទ្ធផលនៃការបោះឆ្នោត និងធ្វើប្រមាណវិធីនានា ដើម្បីគណនា ឬ/និង ផ្ទៀងផ្ទាត់ចំនួនអាសនៈ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ទទួលបាន ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា និងឈ្មោះបេក្ខជន ជាប់ឆ្នោតដែលត្រូវទទួលតំណែងជាប្រធានក្រុមប្រឹក្សា ។ ប្រធានក្រុមកំណត់ បែងចែកអាសនៈ ត្រូវចាត់ចែងសមាជិកក្រុមឱ្យបំពេញកិច្ចការ ដូចខាងក្រោម ៖

២.១២០.៧.១ បញ្ចូលយ៉ាងត្រឹមត្រូវនូវទិន្នន័យ នៃចំនួនសំឡេងឆ្នោតគាំទ្របញ្ជីបេក្ខជន នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនីមួយៗ ក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមតារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១០៧តពស ឬ ១១០៧តពខ) និងសំណុំឯកសារនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធនីមួយៗ ដែលប្រធាន គ.ជ.ប បានចារយល់ព្រមរួចហើយ ។

២.១២០.៧.២ បញ្ចូលទិន្នន័យ ដូចបញ្ជាក់ក្នុងចំណុច ២.១២០.៧.១ ខាងលើ ឱ្យបានត្រឹមត្រូវ ទៅក្នុងកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ រួចបញ្ជាកម្មវិធីនេះឱ្យគណនារកលទ្ធផល នៃការកំណត់ចំនួនអាសនៈ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធ ។ ទន្ទឹមនឹងនេះ ត្រូវផ្អែកលើទិន្នន័យដដែល គណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈ ដោយការអនុវត្តប្រមាណវិធី តាមរូបមន្តដែលកំណត់ដោយច្បាប់ និងដូចចែងក្នុងជំពូកទី ២ ផ្នែកទី ២ នៃ ប.ន.ក នេះ ។ ត្រូវធានាថា លទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈ តាមរបៀបទាំងពីរ មានលក្ខណៈត្រឹមត្រូវដូចគ្នា ។

២.១២០.៧.៣ ស្រង់ឈ្មោះបេក្ខជន ដែលត្រូវជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា និងឈ្មោះបេក្ខជន ដែលត្រូវទទួលតំណែងជាប្រធានក្រុមប្រឹក្សា ពីបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលទទួលបានអាសនៈ បញ្ចូលទៅក្នុងសេចក្តីព្រាងសេចក្តីប្រកាសលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទម្រង់បែបបទលេខ ១១០៨ស ឬ ១១០៨ខ) ។

២.១២០.៧.៤ ពិនិត្យផ្ទៀងផ្ទាត់បន្ថែមលើកំណត់ហេតុពាក់ព័ន្ធ ស្តីពីលទ្ធផលនៃការចាប់ឆ្នោតដែល គធ/ខប បានអនុវត្ត ប្រសិនបើក្នុងការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតពាក់ព័ន្ធ មានករណីមធ្យមភាគ ឬ/និងសំឡេងឆ្នោតគាំទ្រស្មើគ្នា រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើនដែលនឹងត្រូវទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ឬ/និងដែលមានបេក្ខជនជាប់ឆ្នោតនឹងត្រូវទទួលតំណែងជាប្រធានក្រុមប្រឹក្សានោះ ។

២.១២០.៧.៥ បោះពុម្ព ឬរៀបចំឯកសារលទ្ធផល នៃការអនុវត្តចំណុច ២.១២០.៧.២ និង ២.១២០.៧.៣ ខាងលើ មួយមុខមួយ (១) ច្បាប់ ដើម្បីពិនិត្យផ្ទៀងផ្ទាត់បន្ថែមជាមួយនឹងបញ្ជីបេក្ខជនផ្លូវការ និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទម្រង់បែបបទលេខ ១១១៨ស ឬ ១១១៨ខ) ពាក់ព័ន្ធ ។

២.១២០.៧.៦ អនុវត្តនីតិវិធីដូចចែងចាប់ពីចំណុច ២.១២០.៧.២ ដល់ ២.១២០.៧.៥ ខាងលើឡើងវិញម្ដងទៀត ប្រសិនបើលទ្ធផលនៃការផ្ទៀងផ្ទាត់ ដូចចែងក្នុងចំណុច ២.១២០.៧.៥ ខាងលើ មានភាពខុសគ្នាពីលទ្ធផលដែល គឃ/ខប បានត្រួតពិនិត្យម្ដងហើយ ។ ក្នុងករណី លទ្ធផលនៃការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនេះ នៅតែមានភាពខុសគ្នា ត្រូវយកតាមលទ្ធផលដែលក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានគណនា និងផ្ទៀងផ្ទាត់ ។

២.១២០.៧.៧ បន្ទាប់ពីការផ្ទៀងផ្ទាត់ឃើញលទ្ធផលត្រឹមត្រូវហើយ ប្រធានក្រុមត្រូវធានាថា តារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈដោយកុំព្យូទ័រមួយ (១) ច្បាប់ និងតារាងផ្ទៀងផ្ទាត់ការបែងចែកអាសនៈតាមការធ្វើប្រមាណវិធីដោយដៃមួយ (១) ច្បាប់ ត្រូវបានចុះហត្ថលេខា ដោយលេខាធិការ អនុប្រធានក្រុម និងប្រធានក្រុម ហើយសេចក្ដីព្រាងសេចក្ដីប្រកាសលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទម្រង់បែបបទលេខ១១១៨ស ឬ ១១១៨ខ) ចំនួនប្រាំ (៥) ច្បាប់ ដែលភ្ជាប់ជាមួយនូវសំណុំឯកសារពាក់ព័ន្ធ ដែលក្រុមផ្ទៀងផ្ទាត់បានទទួល ដូចចែងក្នុងចំណុច ២.១២០.៤ ខាងលើត្រូវបានដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។

**ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅការិយាល័យបោះឆ្នោត ដែលមានបណ្ដឹងតវ៉ា ឬ បណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គ.ជ.ប ឬ/និង ត្រូវបានដាក់នៅ គធ/ខប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ត្រូវបានបើកត្រួតពិនិត្យ និងរាប់សន្លឹកឆ្នោតឡើងវិញ**

**ប្រការ ២.១២១** យោងតាមការកំណត់របស់ គ.ជ.ប ដូចចែងក្នុងចំណុច ២.១១៨.១ ខាងលើ ប្រសិនបើក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត មានការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណាមួយ ស្ថិតក្នុងករណីមានការប្ដឹងតវ៉ា ឬប្ដឹងជំទាស់នឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបានដាក់នៅ គ.ជ.ប ឬ/និងនៅ គធ/ខប ហើយដែលមានកញ្ចប់សុវត្ថិភាព " ក" ណាមួយត្រូវបានបើក និងរាប់សន្លឹកឆ្នោតឡើងវិញ ប៉ុន្តែ គធ/ខប បានសម្រេចយល់ព្រមទទួលយកលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យដែលទទួលបន្ទុក និងក្រុមកំណត់បែងចែកអាសនៈ ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលតាមនីតិវិធី ដូចខាងក្រោម ៖

២.១២១.១ ប្រសិនបើ ផ្អែកតាមកម្រិតនៃភាពមិនប្រក្រតីពាក់ព័ន្ធនឹងពាក្យបណ្ដឹង ដែលមិននាំឱ្យផ្លាស់ប្ដូរលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធទេនោះ គ.ជ.ប ត្រូវសម្រេច មិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ ។ ករណីនេះ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលដែលទទួលបន្ទុក ត្រូវពិនិត្យជាមុននូវសេចក្ដីសម្រេចរបស់ គធ/ខប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ និងត្រូវធានាថាផ្អែកលើរាល់ឯកសារ ដែលមាននៅក្នុងកញ្ចប់ " យពិសេស" ដូចបញ្ជាក់ក្នុងចំណុច ២.១១៥.២ ខាងលើ នីតិវិធីចាប់ពីចំណុច ២.១២០.២.២ ដល់ ២.១២០.២.៨ ត្រូវតែបានអនុវត្ត ។

២.១២១.២ បន្ទាប់ពីបានអនុវត្តរាល់នីតិវិធីដូចបញ្ជាក់ក្នុងចំណុច ២.១២១.១ រួច អគ្គលេខាធិការនៃ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ តារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារភ្ជាប់ជាមួយ ដែលក្រុមត្រួតពិនិត្យបានដាក់ជូន ដូចចែងក្នុងចំណុច ២.១២០.២.៧ ខាងលើ ។ ប្រសិនបើ ពិនិត្យឃើញថាត្រឹមត្រូវហើយ អគ្គលេខាធិការត្រូវចារលើកយោបល់ស្នើសុំការយល់ព្រមពី គ.ជ.ប រួចចុះហត្ថលេខា និងកាលបរិច្ឆេទលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧គពស ឬ ១១១៧គពខ) ហើយដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច ។

២.១២១.៣ ផ្អែកលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយ ដូចក្នុងចំណុច ២.១២១.២ ខាងលើ ក្នុងករណីគ្មានបណ្ដឹងដាក់នៅ គ.ជ.ប ទេ ទោះបីមានបណ្ដឹងដាក់នៅ គឃ/ខប ក្ដី គ.ជ.ប ត្រូវសម្រេចដោយមិនចាំបាច់បើកសវនាការទេ ។ ក្នុងករណី មានបណ្ដឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវបើកសវនាការសម្រេច លើបណ្ដឹងពាក់ព័ន្ធ ។ អ្នកប្ដឹងតវ៉ា ឬ/និងគណបក្សនយោបាយ និងសមាជិក គឃ/ខប ដែលពាក់ព័ន្ធ ត្រូវមានវត្តមាននៅក្នុងសវនាការនេះ ។ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ ៖

២.១២១.៣.១ ចារយល់ព្រមលើសម្រង់សេចក្ដីសម្រេចរបស់ គឃ/ខប ដែលបានយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសនោះ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

២.១២១.៣.២ ចារយល់ព្រមលើរបាយការណ៍សរសេរ ដោយដៃស្ដីពីលទ្ធផលនៃការត្រួតពិនិត្យ និងតារាងត្រួតពិនិត្យលទ្ធផល (ទម្រង់បែបបទលេខ ១១១៧តពស ១១១៧តពខ) រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

២.១២១.៣.៣ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្ដីសម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ (ទម្រង់បែបបទលេខ ១២០៣) ហើយដែលត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទដោយប្រធាន គ.ជ.ប ។

២.១២១.៣.៤ ធានាថា សម្រង់សេចក្ដីសម្រេចយល់ព្រមខាងលើត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនម្ចាស់ដើមបណ្ដឹងមួយ (១) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ មួយ (១) ច្បាប់ ផ្ញើជូន គឃ/ខប ពាក់ព័ន្ធ មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១២១.៣.៥ ប្រកាសថា សេចក្ដីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

២.១២១.៣.៦ ប្រគល់របាយការណ៍ តារាងត្រួតពិនិត្យលទ្ធផល និងសម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលមានចំណាររបស់ប្រធាន គ.ជ.ប និងសម្រង់សេចក្ដីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមួយមុខមួយ (១) ច្បាប់ ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់បែងចែកអាសនៈដើម្បីមុខការ ។

២.១២១.៤ នៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផល ដែលមានចំណាររបស់ប្រធាន គ.ជ.ប ដូចចែងក្នុងចំណុច ២.១២១.៣.៦ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដូចចែងក្រោមចំណុច ២.១១៦.៥ ខាងលើ ហើយត្រូវធានាថា រាល់នីតិវិធីដូចចែងក្រោមចំណុច ២.១២០.៧ ខាងលើ ត្រូវតែបានអនុវត្ត ។

២.១២១.៥ ដោយឡែក ប្រសិនបើ ផ្អែកតាមកម្រិតនៃភាពមិនប្រក្រតីពាក់ព័ន្ធនឹងពាក្យបណ្ដឹង ដែលអាចធ្វើឱ្យផ្លាស់ប្ដូរលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ គ.ជ.ប បានសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុក ត្រូវពិនិត្យជាមុននូវពាក្យបណ្ដឹងពាក់ព័ន្ធដែលបានដាក់នៅ គ.ជ.ប និងសេចក្ដីសម្រេចរបស់ គធ/ខប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ ហើយផ្អែកលើរាល់ឯកសារដែលមាននៅក្នុងកញ្ចប់ " ឃពិសេស " និង " ឃ " ពាក់ព័ន្ធដូចបានបញ្ជាក់ក្នុងចំណុច ២.១១៤.២ ឬ ២.១១៤.៣ និង ២.១១៤.៧ ខាងលើ ត្រូវគួបផ្សំ និងអនុវត្តឱ្យបានត្រឹមត្រូវតាមលំនាំនីតិវិធី ដូចចែងចាប់ពីចំណុច ២.១១៩.៣ ដល់ ២.១១៩.៥ និងពីចំណុច ២.១២០.២.១ ដល់ ២.១២០.២.៤ ខាងលើ ។

២.១២១.៦ បន្ទាប់ពីបញ្ចប់ការអនុវត្តចំណុច ២.១២១.៥ ខាងលើ អគ្គលេខាធិការត្រូវពិនិត្យ និងលើកយោបល់លើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ដូចចែងក្នុងចំណុច ២.១២០.២.៧ ខាងលើ និងរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ត្រួតពិនិត្យ និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចចែងក្នុងចំណុច ២.១១៩.៥ ខាងលើ ដែលក្រុមត្រួតពិនិត្យលទ្ធផលបានដាក់ជូនរួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។ អគ្គលេខាធិការត្រូវ ៖

២.១២១.៦.១ ចារលើកយោបល់ស្នើសុំបដិសេធសេចក្ដីសម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារបស់ គធ/ខប ដោយស្នើសុំបដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ពន្ធ និងយល់ព្រមតាមពាក្យបណ្ដឹង ដែលដាក់នៅ គ.ជ.ប ប្រសិនបើ រកឃើញថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលធ្វើឱ្យផ្លាស់ប្ដូរលទ្ធផលនៃការបោះឆ្នោតពាក់ព័ន្ធ ។

២.១២១.៦.២ ចារលើកយោបល់ស្នើសុំយល់ព្រម តាមសេចក្ដីសម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារបស់ គធ/ខប និងស្នើសុំបដិសេធពាក្យបណ្ដឹងដែលដាក់នៅ គ.ជ.ប ប្រសិនបើ រកឃើញថា ពុំមានភាពមិនប្រក្រតី ឬភាពមិនប្រក្រតីដែលកើតមានឡើង មិនធ្វើឱ្យផ្លាស់ប្ដូរលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១២១.៧ ទោះបីមានបណ្ដឹងដាក់នៅ គធ/ខប ក៏ដោយ ប្រសិនបើ គ្មានបណ្ដឹងដាក់នៅ គ.ជ.ប ទេ ផ្អែកតាមចំណារលើកយោបល់ ដូចចែងក្រោមចំណុច ២.១២១.៦ ខាងលើ គ.ជ.ប ត្រូវសម្រេចដោយមិនចាំបាច់បើកសវនាការទេ ។ ក្នុងករណី មានបណ្ដឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវបើកសវនាការសម្រេចលើបណ្ដឹងពាក់ព័ន្ធ ។ អ្នកប្ដឹងតវ៉ា ឬ/និងគណបក្សនយោបាយ និងសមាជិក គធ/ខប ដែលពាក់ព័ន្ធត្រូវមានវត្តមាននៅក្នុងសវនាការនេះ ។ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសំណើរបស់អគ្គលេខាធិការ ដូចចែងក្នុង ចំណុច ២.១២១.៦.១ ប្រធាន គ.ជ.ប ត្រូវ ៖

២.១២១.៧.១ ចារបដិសេធលើ សម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

២.១២១.៧.២ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្ដីសម្រេចបដិសេធលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទម្រង់បែបបទលេខ ១២០៣) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធផង រួចហើយត្រូវចុះហត្ថលេខានិងកាលបរិច្ឆេទ ដោយប្រធាន គ.ជ.ប ។

២.១២១.៧.៣ ធានាថា សម្រង់សេចក្ដីសម្រេចបដិសេធខាងលើត្រូវបាន ត្រៀមក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនម្ចាស់ដើមបណ្ដឹងមួយ (១) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធមួយ (១) ច្បាប់ ផ្ញើជូន គធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១២១.៧.៤ ប្រកាសថា សេចក្ដីសម្រេចរបស់ គ.ជ.ប ដែលបានបដិសេធលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ ជាសេចក្ដីសម្រេចចុងក្រោយ ហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌនោះ មិនឱ្យលើសពីប្រាំបី (៨) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចបដិសេធ ។

២.១២១.៧.៥ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យលទ្ធផល និងសម្រង់សេចក្ដីសម្រេចរបស់ គធ/ខប ដែលមានចំណារប្រធាន គ.ជ.ប និងសម្រង់សេចក្ដីសម្រេចរបស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ មួយមុខមួយ (១) ច្បាប់ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផល ទទួលបន្ទុកដែលត្រូវដាក់ទៅក្នុងកញ្ចប់ " យពិសេស " នៃរាជធានីខេត្តពាក់ព័ន្ធវិញ ។

២.១២១.៧.៦ ធានាថា ក្រុមត្រួតពិនិត្យលទ្ធផល បានវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធដាក់ក្នុងកញ្ចប់ " ខ " នៃការិយាល័យបោះឆ្នោតនោះ រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារឯកសារ ដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

២.១២១.៨ យោងសម្រង់សេចក្ដីសម្រេចបដិសេធរបស់ គ.ជ.ប ដូចចែងក្នុងចំណុច ២.១២១.៧.៣ ខាងលើ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅការិយាល័យនោះ ត្រូវបានបដិសេធ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចចែងក្នុងផ្នែកទី ៩ ជំពូកទី ២ នៃ ប.ន.ក នេះ ។

២.១២១.៩ ផ្អែកតាមចំណារលើកយោបល់ ដូចចែងក្រោមចំណុច ២.១២១.៦ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្តីសម្រេចទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារបស់ គធ/ខប ប្រធាន គ.ជ.ប ត្រូវធានាថា បញ្ញត្តិ និងនីតិវិធីដូចចែងក្រោមចំណុច ២.១២១.៣ ខាងលើ ត្រូវតែបានអនុវត្ត ។

២.១២១.១០ ក្នុងការអនុវត្តចំណុច ២.១២១.៩ ខាងលើ និងនៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផលដែលមានចំណារប្រធាន គ.ជ.ប ដូចចែងក្នុងចំណុច ២.១២១.៣.៦ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈត្រូវចាត់ចែងអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដូចចែងក្រោមចំណុច ២.១១៦.៥ ខាងលើ និងត្រូវធានាថា រាល់នីតិវិធី ដូចចែងក្រោមចំណុច ២.១២០.៧ ខាងលើ ត្រូវតែបានអនុវត្ត ។

២.១២១.១១ នៅពេលដែលក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈបានបញ្ចប់ការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ដែលមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គធ/ខប ឬ/និង គ.ជ.ប ហើយដែលត្រូវបាន គ.ជ.ប សម្រេចបដិសេធ ឬយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅការិយាល័យនោះរួចមក អគ្គលេខាធិការត្រូវធានាថា ក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុក តាមរាជធានី ខេត្តនីមួយៗ និងក្រុមកំណត់បែងចែកអាសនៈ បានរៀបចំទុកដាក់រាល់របាយការណ៍ ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធ ដែលបានប្រើក្នុងការត្រួតពិនិត្យខាងលើ ដោយត្រូវច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ " ឃពិសេស " ឬ/និង ក្នុងកញ្ចប់សុវត្ថិភាព " ក " កញ្ចប់ " ខ " និងកញ្ចប់ " ឃ " តាមលំនាំដូចដើម និងនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារ ឯកសារដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

២.១២១.១២ បន្ទាប់ពីបានដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់រួចរាល់ហើយ និងបន្ទាប់ពីបានត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតទាំងអស់ រួមទាំងលទ្ធផលនៃការបោះឆ្នោតសាជាថ្មី គ.ជ.ប ត្រូវផ្សព្វផ្សាយលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

២.១២១.១៣ លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដូចមានចែងក្នុងចំណុច ២.១២១.១២ គ.ជ.ប ត្រូវបែងចែកដូចខាងក្រោម ។

២.១២១.១៣.១ ផ្ញើជូនរាជរដ្ឋាភិបាលមួយ (១) ច្បាប់ ។

២.១២១.១៣.២ ផ្ញើជូនក្រសួងមហាផ្ទៃមួយ (១) ច្បាប់ ។

២.១២១.១៣.៣ ផ្ញើជូនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមួយ (១) ច្បាប់ ។

២.១២១.១៣.៤ ផ្ញើជូន គធ/ខប មួយ (១) ច្បាប់ ។

២.១២១.១៣.៥ ផ្ញើជូនបណ្ណសារដ្ឋានជាតិមួយ (១) ច្បាប់ ។

២.១២១.១៣.៦ រក្សាទុកជាឯកសាររបស់ គ.ជ.ប មួយ (១) ច្បាប់ ។

# ផ្នែកទី ៩

# ការបោះឆ្នោតសាជាថ្មី

**ការបិទការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន**

**ប្រការ ២.១២២** មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួនស្ថិតក្នុងកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត គ.ជ.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះបាន ។

២.១២២.១ ការសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតបាន លុះត្រាតែការិយាល័យបោះឆ្នោតនោះ ឬទាំងនោះស្ថិតក្នុងកាលៈទេសៈមានអាសន្ន ។ កាលៈទេសៈមានអាសន្ន ត្រូវបានកំណត់ដូចខាងក្រោម ៖

២.១២២.១.១ អសន្តិសុខសាធារណៈ ។

២.១២២.១.២ ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយផែនដី ឬគ្រោះធម្មជាតិផ្សេងទៀត ។

២.១២២.១.៣ ការដួលរលំអាគារ សម្រាប់បម្រើការបោះឆ្នោត ដោយយកថាហេតុណាមួយ អគ្គីភ័យ ឬ ការខូចខាតប្រហាក់ប្រហែលគ្នា ដែលនាំឱ្យមានគ្រោះថ្នាក់ ។ ។

២.១២២.១.៤ ការរាំងស្ទះផ្នែករដ្ឋបាល ដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន ។

២.១២២.២ រាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌណាដែលមិនអាចរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបានដោយសារកាលៈទេសៈមានអាសន្ន ដូចមានចែងក្រោមចំណុច ២.១២២.១ គ.ជ.ប ត្រូវរាយការណ៍ជាបន្ទាន់ជូននាយករដ្ឋមន្ត្រី ។

២.១២២.២.១ គ.ជ.ប ត្រូវរាយការណ៍ជាបន្ទាន់ជូននាយករដ្ឋមន្ត្រី អំពីការិយាល័យបោះឆ្នោតនៅរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ ណាដែលមិនអាចរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបាន ដោយសារកាលៈទេសៈមានអាសន្ន ។

២.១២២.២.២ គ.ជ.ប មានសិទ្ធិសម្រេចមិនបើកការិយាល័យបោះឆ្នោត និងមានសិទ្ធិបិទការិយាល័យបោះឆ្នោតមួយ ឬច្រើននៅ

រាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ ដោយសារកាលៈទេសៈមានអាសន្នដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោត ។

២.១២២.២.៣ ប្រធាន គកប ត្រូវរាយការណ៍ជាបន្ទាន់ពីស្ថានភាពជាក់ស្តែងទៅ គធ/ខប ប្រសិនបើ កើតមានករណីណាមួយនៃកាលៈទេសៈមានអាសន្ន ។

២.១២២.២.៤ គធ/ខប ត្រូវពិនិត្យ និងវាយតម្លៃសភាពការណ៍ច្បាស់លាស់ ដោយផ្តល់យោបល់ និងរាយការណ៍បន្ទាន់ជូន គ.ជ.ប ដើម្បី គ.ជ.ប សម្រេចអំពីការបើក ឬមិនបើកការិយាល័យបោះឆ្នោត ។

២.១២២.២.៥ ក្រោយការសម្រេចបើក ឬមិនបើកការិយាល័យបោះឆ្នោត គ.ជ.ប ត្រូវជូនដំណឹងបន្ទាន់ទៅ គធ/ខប ដើម្បី គធ/ខប ចាត់ចែងបន្ត ។

២.១២២.២.៦ ការរាយការណ៍បន្ទាន់ និងការជូនដំណឹងបន្ទាន់ខាងលើ ត្រូវធ្វើតាមទូរស័ព្ទ ឬវិទ្យុទាក់ទង ។

២.១២២.៣ នៅក្នុងថ្ងៃបោះឆ្នោត នៅមុនពេល ឬក្នុងពេលដំណើរការបោះឆ្នោត ប្រសិនបើកើតមានករណីណាមួយនៃកាលៈទេសៈមានអាសន្ន ដូចមានចែងក្រោមចំណុច ២.១២២.១ ប្រធាន គកប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោត ។ ប្រធាន គកប ត្រូវរាយការណ៍ជាបន្ទាន់អំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតជូន គធ/ខប និងដើម្បី គធ/ខប រាយការណ៍បន្ទាន់ជូន គ.ជ.ប ។

២.១២២.៤ ការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬដែលត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារកាលៈទេសៈមានអាសន្ន ត្រូវតែបិទរហូតពេញមួយថ្ងៃ រហូតដល់មានការសម្រេចជាថ្មី ។

**ប្រការ** ២.១២៣ គ.ជ.ប ត្រូវរាយការណ៍ភ្លាមជូននាយករដ្ឋមន្ត្រីអំពីការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណា ដែលមិនត្រូវបានបើក ឬត្រូវបានបិទដោយសារកាលៈទេសៈមានអាសន្ននៅមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត ។

**ប្រការ** ២.១២៨ ក្នុងករណីមានការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទ ដោយមាន គកប ជាជំនួយ គធ/ខប ពាក់ព័ន្ធត្រូវ ៖

២.១២៨.១ ជូនដំណឹងដល់អ្នកបោះឆ្នោតពាក់ព័ន្ធ អំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះដោយបញ្ជាក់ ពីមូលហេតុច្បាស់លាស់ ។

២.១២៨.២ ប្រមូលសម្ភារឯកសារពាក់ព័ន្ធផ្សេងទៀតសម្រាប់បំរើការបោះឆ្នោតមករក្សាទុកនៅ គធ/ខប ។

២.១២៨.៣ ប្រមូលសន្លឹកឆ្នោតដែលបោះរួចហើយ នៅការិយាល័យបោះឆ្នោតដែលត្រូវបានបិទក្នុងអំឡុងពេលបោះឆ្នោត រាប់ចំនួន និងកត់ត្រាទុកក្នុងកំណត់ហេតុ រួចដាក់ក្នុងស្បោងមួយដោយឡែក ។ សន្លឹកឆ្នោតទាំងនេះត្រូវទុកជាមោឃៈ គឺមិនត្រូវរាប់បញ្ចូលក្នុងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធឡើយ ។

២.១២៨.៤ ធ្វើកំណត់ហេតុស្ដីពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតនោះ និងរាយការណ៍ជូន គ.ជ.ប ។

២.១២៨.៥ ក្នុងករណីកាលៈទេសៈមានអាសន្នកើតមានឡើងនៅការិយាល័យបោះឆ្នោតក្រោយពេលបិទការបោះឆ្នោត និងបានធ្វើកំណត់ហេតុនៃការបោះឆ្នោតរួចហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុងកំណត់ហេតុនៃការបោះឆ្នោត និងឯកសារបោះឆ្នោត នៅរក្សាបានល្អ គកប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះបញ្ជូនទៅ គធ/ខប ដើម្បីចាត់ចែងរាប់សន្លឹកឆ្នោតតាមការកំណត់នៃ ប.ន.ក នេះ ។

២.១២៨.៦ ក្នុងករណីកាលៈទេសៈមានអាសន្នកើតមានឡើងនៅការិយាល័យបោះឆ្នោតក្រោយពេលបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច ប៉ុន្តែហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង កំណត់ហេតុនៃការបោះឆ្នោត និងឯកសារបោះឆ្នោតត្រូវខូចខាត គកប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះ បញ្ជូនទៅ គធ/ខប ដើម្បីបន្តរាយការណ៍ជូន គ.ជ.ប សុំឱ្យមានការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

**ប្រការ ២.១២៥** សមាសភាព គកប នៃការិយាល័យបោះឆ្នោត ដែលមិនត្រូវបានបើក ឬត្រូវបានបិទ ត្រូវរំសាយ និងទទួលបានប្រាក់កម្រៃស្របតាមកិច្ចសន្យា ។

**ប្រការ ២.១២៦** ចំពោះការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌផ្សេង ដែលមិនត្រូវបានបិទ គកប ទាំងនោះ ត្រូវអនុវត្តការបោះឆ្នោត ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូល ការប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោតធម្មតា តាម ប.ន.ក នេះ ។

២.១២៦.១ គធ/ខប ត្រូវរក្សាទុក និងការពារឱ្យបានគត់មត់នូវសន្លឹកឆ្នោតដែលបានប្រើប្រាស់ហើយ និងដែលមិនទាន់បានប្រើប្រាស់ លទ្ធផលនៃការរាប់សន្លឹកឆ្នោត និងឯកសារបោះឆ្នោតពាក់ព័ន្ធនៃការិយាល័យដែលមិនត្រូវបានបិទ ឬត្រូវបានបិទ នៅលេខាធិការដ្ឋាន គធ/ខប ឬនៅកន្លែងធានាសុវត្ថិភាពណាមួយ ដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប រហូតដល់ពេលបញ្ចប់ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះ ។

២.១២៦.២ សម្ភារឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទ អាចត្រូវប្រមូល ប្រគល់ទៅឱ្យ គធ/ខប ទៅតាមសភាពជាក់ស្តែង ដែលសម្រេចដោយ គធ/ខប ។

២.១២៦.៣ គធ/ខប ត្រូវរក្សាទុកសម្ភារឯកសារសម្រាប់បំរើការបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលត្រូវធ្វើការបោះឆ្នោតសាជាថ្មី ។

**ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីកាលៈទេសៈមានអាសន្ន ឬដែលលទ្ធផលនៃការបោះឆ្នោត ត្រូវបានបដិសេធដោយ គ.ជ.ប**

**ប្រការ ២.១២៧** ការិយាល័យបោះឆ្នោត ដែលមិនត្រូវបានបើក ឬត្រូវបានបិទក្នុងករណី ដូចចែងក្រោមចំណុច ២.១២២.១ ខាងលើ ឬដែលលទ្ធផលនៃការបោះឆ្នោតត្រូវបានបដិសេធដោយ គ.ជ.ប ដូចចែងក្នុងចំណុច ២.១១៩.៧ និង ២.១២១.៤ ខាងលើ គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតសាជាថ្មី តាមកាលវេលាសមស្រប នៅពេលដែលការិយាល័យបោះឆ្នោតពាក់ព័ន្ធ វិលមករកស្ថានភាពដើមវិញ បន្ទាប់ពីបានកើតមានកាលៈទេសៈមានអាសន្ន ឬក្នុងរយៈពេលយ៉ាងយូរប្រាំបី (៨) ថ្ងៃ បន្ទាប់ពីថ្ងៃដែល គ.ជ.ប ប្រកាសបដិសេធលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅការិយាល័យបោះឆ្នោតដែលពាក់ព័ន្ធ ។ គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតសាជាថ្មីនៅទីតាំងការិយាល័យបោះឆ្នោតដដែល ឬនៅទីតាំងណាមួយក្នុងទីប្រជុំជនរាជធានី ខេត្ត ដែល គ.ជ.ប យល់ថាមានសន្តិសុខ និងសុវត្ថិភាពល្អ ។

២.១២៧.១ គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទ និងទីតាំងនៃការិយាល័យបោះឆ្នោតដែលត្រូវបោះឆ្នោតសាជាថ្មី និងណែនាំ គធ/ខប ឱ្យផ្សព្វផ្សាយ និងបិទផ្សាយនៅលេខាធិការដ្ឋាននៃ គធ/ខប និងនៅទីតាំងការិយាល័យដែលត្រូវបោះឆ្នោតសាជាថ្មីយ៉ាងតិច បី (៣) ថ្ងៃ មុនថ្ងៃបោះឆ្នោតសាជាថ្មី ។

២.១២៧.២ ដើម្បីគ្រប់គ្រង និងចាត់ចែងការរៀបចំការបោះឆ្នោតសាជាថ្មី គ.ជ.ប ត្រូវ ៖

២.១២៧.២.១ រក្សាសមាសភាព គធ/ខប និងមន្ត្រីបំរើការងារនៅ គធ/ខប មួយចំនួន តាមតំរូវការនៃការងារ ។

២.១២៧.២.២ ណែនាំការជ្រើសរើស គកប សម្រាប់ការបោះឆ្នោតសាជាថ្មី តាមប្រព័ន្ធជ្រើសរើសដូចមានចែងក្នុង ប.ន.ក នេះ ។ ប្រសិនបើ អាចធ្វើបានគួរជ្រើសរើសសមាសភាព គកប ដែលបំរើការងារនៅការិយាល័យបោះឆ្នោត ដែលត្រូវបានបិទនោះ ឬមន្ត្រីដែលធ្លាប់បំរើការងារនៅការិយាល័យបោះឆ្នោតផ្សេងទៀត ដើម្បីងាយស្រួល ដោយពុំចាំបាច់ធ្វើការបណ្តុះបណ្តាលជាថ្មី ។

២.១២៧.៣ អាណត្តិរបស់ គធ/ខប និង គកប សម្រាប់ការបោះឆ្នោតសាជាថ្មី ត្រូវបញ្ចប់តាមការកំណត់របស់ គ.ជ.ប ។

២.១២៧.៤ សិទ្ធិអំណាច និងភារកិច្ចរបស់ គធ/ខប និង គកប ត្រូវអនុលោមតាម ច.ប.ក និង ប.ន.ក នេះ និងទៅតាមតម្រូវការជាក់ស្តែងនៃការបោះឆ្នោតសាជាថ្មី ដែលកំណត់ដោយ គ.ជ.ប ។

២.១២៧.៥ អ្នកបោះឆ្នោតទាំងអស់ដែលមានសិទ្ធិបោះឆ្នោតនៅការិយាល័យក្រុង ស្រុក ខណ្ឌ ដែលត្រូវបោះឆ្នោតសាជាថ្មី គឺអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ទោះបីជាបានបោះឆ្នោតហើយក្តី ឬមិនទាន់បានបោះឆ្នោតក្តី ។

២.១២៧.៦ ដើម្បីមានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតសាជាថ្មី អ្នកបោះឆ្នោត ត្រូវ ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ នៃការិយាល័យនោះ ។
- មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយរបស់ខ្លួន សម្រាប់ប្រើនៅពេលបោះឆ្នោត ។

២.១២៧.៧ មេឃុំ ចៅសង្កាត់ ត្រូវចេញលិខិតធានាអះអាងអំពីអត្តសញ្ញាណ មានបិទរូបថត ជូនអ្នកបោះឆ្នោតដែលត្រូវបោះឆ្នោតសាជាថ្មី តាមសំណើសុំរបស់សាមីខ្លួនរហូតដល់ថ្ងៃបោះឆ្នោត ក្នុងករណីដែលឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ ត្រូវបាត់ ឬខូច ។

២.១២៧.៨ បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យពាក់ព័ន្ធ ដែលប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបានប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាសាជាថ្មី ។ បញ្ជីឈ្មោះនេះត្រូវបិទផ្សាយនៅ គធ/ខប និងនៅការិយាល័យបោះឆ្នោត ដែលត្រូវបោះឆ្នោតសាជាថ្មី មួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.១២៧.៩ បញ្ជីបេក្ខជន នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការ និងលំដាប់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត ដែលត្រូវបានសម្រេច សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធ ត្រូវរក្សាទុកដដែលសម្រាប់ការបោះឆ្នោតសាជាថ្មី ។ បញ្ជីទាំងនេះ ត្រូវបិទផ្សាយជាសាធារណៈនៅ គធ/ខប និងនៅការិយាល័យបោះឆ្នោត ដែលត្រូវបោះឆ្នោតសាជាថ្មី ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ មុនថ្ងៃបោះឆ្នោតសាជាថ្មី ។

២.១២៧.១០ សមាសភាពតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលត្រូវសង្កេតមើលការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ត្រូវរក្សាទុកដដែលសម្រាប់ការបោះឆ្នោតសាជាថ្មី ។

២.១២៧.១១ គ.ជ.ប ត្រូវបោះពុម្ពសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតសាជាថ្មីតាមគំរូសន្លឹកឆ្នោតដែលបានប្រើសម្រាប់ការបោះឆ្នោតលើកមុន នៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតលើកមុន និងត្រូវឱ្យមានចំនួនគ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់ ។

២.១២៧.១២ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារបរិក្ខារ និងឯកសារបម្រើការបោះឆ្នោតសាជាថ្មីឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ដល់ការិយាល័យបោះឆ្នោតពាក់ព័ន្ធតាមរយៈ គធ/ខប ។

២.១២៧.១៣ ក្នុងការបោះឆ្នោតសាជាថ្មី ការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ/និងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ត្រូវហាមឃាត់ ។

២.១២៧.១៤ នីតិវិធីនៃការបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តតាមនីតិវិធីនៃការបោះឆ្នោត ដូចបាន ចែងក្នុង ប.ន.ក នេះ ។ ដោយឡែក ការជ្រលក់ទឹកខ្មៅលុបលាងមិនជ្រះ ត្រូវធ្វើលើម្រាមដៃឆ្វេង ។

២.១២៧.១៥ នៅពេលបញ្ចប់ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតរបស់ខ្លួន គកប ត្រូវអនុវត្តការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការវេចខ្ចប់ និង ការបញ្ជូនសម្ភារ ឯកសារបោះឆ្នោតទៅ គធ/ខប តាមនីតិវិធី ដូចដែល បានចែងក្នុង ប.ន.ក នេះ ។

២.១២៧.១៦ ក្នុងការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៅការិយាល័យដែលត្រូវបោះឆ្នោតសាជាថ្មី គធ/ខប ត្រូវធានាថា នីតិវិធីដូចចែងចាប់ពីចំណុច ២.១១២.៦ ដល់ ២.១១២.៩ ត្រូវតែបានអនុវត្ត ហើយក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុប លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត នៅការិយាល័យដែលត្រូវបោះឆ្នោតសាជាថ្មីនោះ នីតិវិធីដូចចែងក្នុងចំណុច ២.១១២.១០ ២.១១២.១២ ២.១១២.១៣ និង ២.១១២.១៤ ត្រូវ តែបានអនុវត្ត និងបញ្ចូលទៅក្នុងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោត នៅការិយាល័យ ដែលបានបើកបោះឆ្នោតជាធម្មតា រួចបិទផ្សាយលទ្ធផល នេះ ស្របតាម ប.ន.ក របស់ គ.ជ.ប ។

២.១២៧.១៧ គធ/ខប ត្រូវវេចខ្ចប់ និងបញ្ជូនកំណត់ហេតុ និងសម្ភារឯកសារនៃការិយា ល័យបោះឆ្នោតចំណុះរាជធានី ខេត្ត ដែលបានបោះឆ្នោតសាជាថ្មីទៅ គ.ជ.ប ដោយភ្ជាប់ជាមួយនូវសន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោត មិនទាន់ប្រើប្រាស់ និងសម្ភារឯកសារបោះឆ្នោតផ្សេងទៀត ។ ការវេចខ្ចប់ និងបញ្ជូនកំណត់ហេតុ និងសម្ភារឯកសារនៃការិយាល័យដែលបានបោះឆ្នោត សាជាថ្មី ត្រូវអនុវត្តតាមលំនាំការកំណត់ និងនីតិវិធី ដូចដែលត្រូវអនុវត្តសម្រាប់ ការវេចខ្ចប់ និងបញ្ជូនកំណត់ហេតុ និងសម្ភារឯកសារនៃការិយាល័យ ដែល លទ្ធផលនៃការបោះឆ្នោតត្រូវបាន គធ/ខប សំរេចព្យួរជាបណ្ដោះអាសន្ន ។

២.១២៧.១៨ ក្នុងចន្លោះពេលពីដំណើរការនៃការបោះឆ្នោតសាជាថ្មី រហូតដល់ការប្រកាស លទ្ធផលផ្លូវការ ការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់ និងសវនាការដោះស្រាយ បណ្ដឹងទាក់ទងនឹងការបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តដូចគ្នានឹងការកំណត់ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលមានចែងក្នុង ប.ន.ក នេះ ។

# ផ្នែកទី ១០
## ការជំនួសក្រុមប្រឹក្សា

**ប្រការ ២.១២៨** អនុលោមតាមមាត្រា ២៣ នៃ ច.គ.ខ.ស នៅពេលដែលសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ដូចករណីមានចែងក្នុងប្រការ ២.១២៩ ខាងក្រោម ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយ មកជំនួសក្នុងរយៈពេលយ៉ាងយូរដប់បួន (១៤) ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមិនចាំបាច់ធ្វើការបោះឆ្នោតឡើងវិញឡើយ ។

**ប្រការ ២.១២៩** អនុលោមតាមមាត្រា ២២ នៃ ច.គ.ខ.ស សមាជិកក្រុមប្រឹក្សាម្នាក់ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម ៖

២.១២៩.១ សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១២៩.២ សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរ ទៅប្រធានក្រុមប្រឹក្សា ។

២.១២៩.៣ សាមីខ្លួនទទួលមរណភាព ។

២.១២៩.៤ សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នាចាប់ពី ពីរ (២) ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត ។

២.១២៩.៥ សាមីខ្លួនត្រូវបានបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា ដោយអនុលោមតាមច្បាប់ នីតិវិធី ឬបទបញ្ជាផ្ទៃក្នុង ឬក្រមសីលធម៌របស់ក្រុមប្រឹក្សា ។

២.១២៩.៦ សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ។

២.១២៩.៧ សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

**ប្រការ ២.១៣០** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណី ដូចមានចែងក្រោមប្រការ ២.១២៩ ខាងលើ ។

# ផ្នែកទី ១១

# សមត្ថកិច្ច និងនីតិវិធីដោះស្រាយវិវាទក្នុងការបោះឆ្នោត និងនីតិវិធីដាក់,ទទួលពាក្យបណ្តឹង និងដោះស្រាយបណ្តឹងចំពោះគ្រប់អំពើល្មើសបោះឆ្នោតដែលអាចនាំឱ្យមានការផ្តន្ទាទោស

## សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត

**ប្រការ ២.១៣១** គធ/ខប និង គ.ជ.ប មានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើវិវាទដែលពាក់ព័ន្ធទៅនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ គធ/ខប បើកការប្រជុំផ្សះផ្សា ឬបើកសវនាការលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ និង គ.ជ.ប ប្រជុំសម្រេច ឬបើកសវនាការលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត លើកលែងតែបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

២.១៣១.១ នីតិវិធីប្រជុំផ្សះផ្សា និងសវនាការដោះស្រាយបណ្តឹងដូចបានចែងក្នុងផ្នែកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលរួមមាន ដំណាក់កាលចុះឈ្មោះបោះឆ្នោត ដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដំណាក់កាលឃោសនាបោះឆ្នោត ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ។

២.១៣១.២ ការរាប់ចំនួនថ្ងៃតវ៉ា និងការសម្រេចលើបណ្តឹងតវ៉ា ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

២.១៣១.៣ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ ។

## សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ

**ប្រការ ២.១៣២** ការប្រជុំផ្សះផ្សា ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ គធ/ខប ឬ គ.ជ.ប ។ ចំនួន និងសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវធ្វើឡើងតាមចំនួនសេស ជាអាទិ៍ បី (៣) ឬប្រាំ (៥) ឬប្រាំពីរ (៧) ឬប្រាំបួន (៩) ហើយអាចផ្លាស់ប្តូរតាមការចាំបាច់ដែលសម្រេចដោយ គធ/ខប ឬ គ.ជ.ប ។

**ក. សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប**

២.១៣២.១ ប្រធាន អនុប្រធាន និងសមាជិក គធ/ខប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សា ហៅថា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយបណ្ដឹង ហៅថាក្រុមប្រឹក្សាជំនុំជម្រះ ។

២.១៣២.២ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប រួមមាន ៖

២.១៣២.២.១ ប្រធាន គធ/ខប ឬអ្នកតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

២.១៣២.២.២ អនុប្រធាន និងសមាជិក គធ/ខប ជាសមាជិក

២.១៣២.២.៣ មន្ត្រីសេវាកម្មច្បាប់ និងវិវាទកម្ម ជាលេខាធិការ ។

២.១៣២.៣ លក្ខខណ្ឌសុពលភាពនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាត ។

២.១៣២.៤ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប មិនត្រូវមានសំឡេងអនុបវាទឡើយ ។

២.១៣២.៥ ក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ/ខប មានសិទ្ធិអំណាចកោះហៅភាគីទំនាស់ឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ។ ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប មានសិទ្ធិអំណាចកោះហៅភាគីទំនាស់ និងសាក្សី ឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ ។

**ខ. សមាសភាពក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប**

២.១៣២.៦ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយបណ្ដឹងហៅថា ក្រុមប្រឹក្សាជំនុំជម្រះ ។

២.១៣២.៧ សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន ៖

២.១៣២.៧.១ ប្រធាន គ.ជ.ប ឬអ្នកតំណាង ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

២.១៣២.៧.២ អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក ។

២.១៣២.៧.៣ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដែលត្រូវបានចាត់តាំងជាលេខាធិការ ។

២.១៣២.៨ លក្ខខណ្ឌសុពលភាពនៃសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា ១៧ថ្មី នៃ ច.ប.ត.រ និង ប.ន.ក ព្រមទាំងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.១៣២.៩ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ មិនត្រូវមានសំឡេងអនុបវាទឡើយ ។

២.១៣២.១០ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅភាគី និង សាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ ។

២.១៣២.១១ គ.ជ.ប មានសិទ្ធិធ្វើការស៊ើបអង្កេតលើករណីមាន ឬគ្មានបណ្ដឹង ក្នុង គោលបំណងឱ្យមានការគោរព ច.ប.ក និង ប.ន.ក នេះ និងដើម្បី ឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងត្រឹមត្រូវ ។

## ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់

**ប្រការ ២.១៣៣** ជនណាក៏ដោយ ឬអ្នកតំណាងមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់តាមឋានានុក្រមទៅគណៈកម្មការរៀបចំការបោះឆ្នោតតាមលំដាប់ថ្នាក់ ឬ គ.ជ.ប អំពីបញ្ហាទាំងឡាយ ដែលទាក់ទងនឹងការបោះឆ្នោត ប្រសិនបើមានភ័ស្ដុតាងបញ្ជាក់ថា មានភាពមិនត្រឹមត្រូវតាម ច.ប.ក ឬ/និង ប.ន.ក ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប លើកលែងតែការប្ដឹងតវ៉ា និងការប្ដឹងជំទាស់ទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដែលត្រូវប្ដឹងដោយសាមីខ្លួន ឬសាមីគណបក្សនយោបាយ ហើយការប្ដឹងទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ដែលត្រូវប្ដឹងដោយជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬតំណាងគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ។

២.១៣៣.១ ពាក្យបណ្ដឹងអនាមិក ពុំត្រូវបានចាត់ទុកជាពាក្យបណ្ដឹងស្របច្បាប់ និង មិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មាន សម្រាប់ការពិចារណា ។

២.១៣៣.២ ពាក្យបណ្ដឹងប្ដឹងពីអញ្ញាតជន ត្រូវបានចាត់ទុកជាពាក្យបណ្ដឹងស្របច្បាប់ និង ត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែង រកអត្តសញ្ញាណរបស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម ។ ក្នុងករណីស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវជូនដំណឹងទៅអ្នកប្ដឹងវិញ អំពីករណី នេះក្នុងរយៈពេលសមស្រប ។

២.១៣៣.៣ ពាក្យបណ្ដឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ចំនួនបី (៣) ច្បាប់ (ចំពោះបណ្ដឹងតវ៉ា) ឬចំនួនបួន (៤) ច្បាប់ (ចំពោះបណ្ដឹងជំទាស់) ។ អ្នកប្ដឹងអាចថតចម្លងទម្រង់បែបបទដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លង ទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យអ្នកតំណាងដាក់ពាក្យបណ្ដឹង ឬតវ៉ា ជំនួសខ្លួនបាន ។

២.១៣៣.៤ មន្ត្រីនៃគណៈកម្មការរៀបចំការបោះឆ្នោតត្រូវប្រគល់ ទ.១២០២ ដល់អ្នកប្ដឹងដើម្បីប្ដឹង ឬប្ដឹងបន្ត ប្រសិនបើមានការស្នើសុំ ។

២.១៣៣.៥ ពាក្យបណ្ដឹងត្រូវបញ្ជាក់នូវព័តមានចាំបាច់មួយចំនួន ដូចខាងក្រោម ។

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬអ្នកតំណាង
- កម្មវត្ថុនៃបណ្ដឹង
- ប្រភេទនៃអំពើល្មើស
- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង
- បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោត ដែលត្រូវបានរំលោភ
- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន
- ភស្តុតាងផ្សេងៗទៀត បើមាន ។

២.១៣៣.៦ ពាក្យបណ្ដឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ និងជាបន្ទាន់ ។

## ការដកពាក្យបណ្ដឹង

**ប្រការ ២.១៣៤** ដើមបណ្ដឹងអាចដកពាក្យបណ្ដឹងទាំងមូល ឬមួយផ្នែកបាន រហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គឃ/ខប បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គឃ/ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា ។

២.១៣៤.១ ការដកពាក្យបណ្ដឹង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ គឃ/ខប ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា ឬកំពុងសវនាការ ការដកពាក្យបណ្ដឹងនោះអាចធ្វើឡើងដោយផ្ទាល់មាត់បាន ។

២.១៣៤.២ ប្រសិនបើការដកពាក្យបណ្តឹង ធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ឬសវនាការ គធ/ខប ឬ គ.ជ.ប ត្រូវសម្រេច លើកបណ្តឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ ។

២.១៣៤.៣ ប្រសិនបើការដកពាក្យបណ្តឹង ធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្តឹងដកពាក្យបណ្តឹង ហើយពាក្យបណ្តឹងនោះ ត្រូវបានលើកចោលតាមការស្នើសុំ ។

២.១៣៤.៤ ប្រសិនបើការដកពាក្យបណ្តឹង ធ្វើឡើងនៅពេលកំពុងសវនាការ ក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេច លើកពាក្យបណ្តឹងចោលដោយចេញសម្រង់សេចក្តីសម្រេច ។

## ការរួមបញ្ចូលរឿងក្តី

**ប្រការ ២.១៣៥** គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប អាចបញ្ចូលរឿងក្តី ក្នុងករណីដែលមានបណ្តឹងច្រើន ប៉ុន្តែកម្មវត្ថុនៃបណ្តឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្តឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលមានតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ ។ ក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្តីសម្រេចជាស្ថាពរ ប៉ុន្តែអ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅតែបន្តប្រព្រឹត្តល្មើសទៀត ហើយបើមានបណ្តឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវលើកយកមកដោះស្រាយ ដោយចាត់ទុកជាករណីថ្មីទៀត ។

## សិទ្ធិ និងភារកិច្ចរបស់ដើមបណ្តឹង ចុងចម្លើយ អ្នកតំណាង ឬមេធាវី

**ប្រការ ២.១៣៦** ក្នុងករណីគូភាគីមានអ្នកតំណាង ឬមេធាវីដើម្បី ធ្វើជាអ្នកតំណាង ឬអ្នកការពារក្តី ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងការប្តឹងឱ្យចូលរួមបំភ្លឺក្នុងសវនាការ ប៉ុន្តែត្រូវសុំការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ មុនពេលបើកសវនាការ ។ ចំពោះការប្រជុំផ្សះផ្សា គូភាគីអាចមកចូលរួមដោយផ្ទាល់ ឬចាត់អ្នកតំណាងដែលត្រូវបានប្រគល់សិទ្ធិ តែមិនតម្រូវឱ្យមានសាក្សីទេ ។

២.១៣៦.១ គូភាគីត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬអ្នកតំណាងដោយមានចុះហត្ថលេខា ឬផ្តិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងប្រថាប់ត្រាពីមេធាវី ឬស្នាមមេដៃនៃអ្នកតំណាងនោះ (អ្នកតំណាងត្រូវតែជានីតិជន) ។

២.១៣៦.២ លិខិតប្រគល់សិទ្ធិត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ តាមរយៈលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការយ៉ាងតិចពីរ (២) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា ឬបើកសវនាការ ។

២.១៣៦.៣ សិទ្ធិរបស់មេធាវី ឬអ្នកតំណាង ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរ ។

២.១៣៦.៤ មេធាវី ឬអ្នកតំណាងមិនអាចធ្វើការប្រគល់សិទ្ធិបន្តទៅមេធាវី ឬអ្នកតំណាងដទៃទៀត ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ ។

២.១៣៦.៥ ដើមបណ្តឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬអ្នកតំណាងដែលបានទទួលសិទ្ធិផងដែរ ។

២.១៣៦.៦ ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហានានាដែលទាក់ទងនឹងបណ្តឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬអ្នកតំណាងដែលបានទទួលសិទ្ធិផងដែរ ។

២.១៣៦.៧ ដើមបណ្តឹង ឬ/និងជនរងគ្រោះ មានវិសមិតភាពរវាងឋានៈជាដើមបណ្តឹង ឬជនរងគ្រោះ និងឋានៈជាសាក្សី ។ ដើមបណ្តឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្តល់ចម្លើយក្នុងឋានៈជាសាក្សីបានទេ ។

២.១៣៦.៨ ដើមបណ្តឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារ ភ័ស្តុតាង ឬសាក្សី ដើម្បីជាសំអាងក្នុងរឿងក្តីរបស់ខ្លួន ។

២.១៣៦.៩ ចុងចម្លើយត្រូវបង្ហាញឯកសារ ភ័ស្តុតាង ឬសាក្សីដើម្បីជាសំអាងការពាររឿងក្តីរបស់ខ្លួន ។

២.១៣៦.១០ នៅក្នុងនីតិវិធីសវនាការប្រតិបក្ស ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ចុងចម្លើយអាចចោទសំណួរទៅ ដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹងអំពីភ័ស្តុតាងដែលគេមាន ។ ដើមបណ្តឹងក៏អាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយពីភ័ស្តុតាងដែលមានដែរ ។

២.១៣៦.១១ ចុងចម្លើយអាចបង្ហាញភ័ស្តុតាង ជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវី ឬអ្នកតំណាង ដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង ។

២.១៣៦.១២ មធ្យោបាយបង្ហាញភ័ស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជំនុំជម្រះក្តី ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា ឬសវនាការ ។ ភ័ស្តុតាងអាចបង្ហាញបានតាមគ្រប់ មធ្យោបាយ និងត្រូវគោរពតាម ច.ប.ក និង ប.ន.ក នេះ ។

២.១៣៦.១៣ ជនណាបានប្រព្រឹត្តការក្លែងលិខិត ឬឯកសារ ដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវលិខិត ឬឯកសារនោះ ជននោះនឹងត្រូវមានទោសតាមច្បាប់ជាធរមាន ។

២.១៣៦.១៤ ដើមបណ្តឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ ។

២.១៣៦.១៥ ដើមបណ្តឹង ឬចុងចម្លើយ ឬមេធាវី ឬអ្នកតំណាងរបស់ភាគីអាចស្នើសុំឱ្យ គធ/ខប ឬ គ.ជ.ប ថតចម្លងសំណុំរឿងពាក់ព័ន្ធ ឱ្យខ្លួនដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ ។ ការថតចម្លងត្រូវធ្វើ ដោយមន្ត្រី គធ/ខប ឬមន្ត្រីនៅទីស្តីការ គ.ជ.ប ដែលបានចាត់តាំង ។

២.១៣៦.១៦ មុនពេលក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សា ពិចារណា ភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថា មានប្រយោជន៍ដល់ខ្លួនជូនទៅក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា ។

២.១៣៦.១៧ គូភាគីមានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចរបស់ គធ/ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប តាមការកំណត់ក្នុង ច.ប.ក និង ប.ន.ក នេះ ។

## សិទ្ធិ និងភារកិច្ចរបស់សាក្សី

**ប្រការ ២.១៣៧** សាក្សីត្រូវធ្វើសម្បថជាមុន ហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាជំនុំជម្រះនៅចំពោះមុខ ក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវនៅចំពោះមុខច្បាប់ អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មភូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត (ខ្លឹមសារសម្បថមានក្នុងឧបសម្ព័ន្ធទី ១១) ។

២.១៣៧.១ សាក្សីមានសិទ្ធិឆ្លើយបំភ្លឺ នូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំ ដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ ។

២.១៣៧.២ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយ ត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នា រង់ចាំការអញ្ជើញឱ្យមកបំភ្លឺដោយក្រុមប្រឹក្សាជំនុំជម្រះ ។

២.១៣៧.៣ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយ មិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នា ទោះតាមមធ្យោបាយណាក៏ដោយក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមសវនាការ ។

២.១៣៧.៤ សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុង បន្ទប់ជំនុំជម្រះឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

**នីតិវិធីប្រជុំផ្សះផ្សា នីតិវិធីសវនាការ**

**ប្រការ ២.១៣៨** ដំណើរការប្រជុំផ្សះផ្សា ឬសវនាការ ត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការចំពោះជនណា ឬជនទាំងឡាយណា ដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយបណ្តឹង (មានចែងក្នុងឧបសម្ព័ន្ធទី ១០ ស្តីពីបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា សវនាការដោះស្រាយបណ្តឹង) ។

**ក. ប្រភេទសវនាការ**

២.១៣៨.១ ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការតាមសវនាការសង្ខេប ឬសវនាការប្រតិបក្ស ឬសវនាការសួរដេញដោល សេចក្តីអត្ថាធិប្បាយសង្ខេបស្តីពីប្រភេទសវនាការ នីមួយៗមានដូចខាងក្រោមនេះ ។

២.១៣៨.១.១ សវនាការសង្ខេប ជាសវនាការដែលគ្មានទម្រង់ការច្រើន ។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថា មានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ ។

២.១៣៨.១.២ សវនាការប្រតិបក្ស ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងវិវាទ ។ ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាងដើម្បីដាក់ជូនសវនាការ ។

២.១៣៨.១.៣ សវនាការសួរដេញដោល ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី ។ ក្នុងសវនាការប្រភេទនេះ ទាំងក្រុមប្រឹក្សាជំនុំជម្រះទាំងគូក្តី ជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលអង្គហេតុផ្សេងៗ ដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ ជាអ្នកតាំងសំណួរដល់សាក្សី ឯចំណែកគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ ។ ការចោទសួរដេញដោលនេះអាចធ្វើទៅបាន ដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

**ខ. ភាសាដែលត្រូវប្រើក្នុងការប្រជុំផ្សះផ្សា ឬសវនាការ**

២.១៣៨.២ ភាសាដែលត្រូវប្រើក្នុងការប្រជុំផ្សះផ្សា ឬសវនាការ គឺភាសាខ្មែរ ។

២.១៣៨.៣ ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង ។

**គ. ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ក្រុមប្រឹក្សាជំនុំជម្រះ**

២.១៣៨.៤ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែងដែលបានរៀបចំទុក ។ ប្រធានអង្គុយនៅកណ្តាល សមាជិកអង្គុយអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការត្រូវអង្គុយនៅតុ ដែលនៅខាងឆ្វេងដៃ ឬស្តាំដៃនៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ។

២.១៣៨.៥ ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវ ៖

២.១៣៨.៥.១ ទី១ ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ទី២ ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ឬសវនាការ ។

២.១៣៨.៥.២ បង្គាប់ឱ្យលេខាធិការសវនាការ រាយការណ៍អំពីវត្តមានដើមបណ្ដឹង ចុងចម្លើយ និងសាក្សី (ករណីសវនាការ) ។

២.១៣៨.៦ មុននឹងចាប់ផ្ដើមផ្សះផ្សា ឬសួរដេញដោល ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរទៅដើមបណ្ដឹងថា តើលោក ឬលោកស្រី នៅតែបន្តប្ដឹងដូចមានចែងក្នុងកម្មវត្ថុនៃបណ្ដឹង ឬមានការកែប្រែឬទេ?

២.១៣៨.៦.១ ប្រសិនបើដើមបណ្ដឹងឆ្លើយថា ខ្លួនដកពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបង្គាប់ឱ្យលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ កត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការ ហើយឱ្យដើមបណ្ដឹងផ្ដិតមេដៃលើកំណត់ហេតុនោះ ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សា អាចផ្សះផ្សារឿងក្ដីផ្សេងទៀត (ប្រសិនបើមាន) ឬក្រុមប្រឹក្សាជំនុំជម្រះអាចថយទៅពិភាក្សាពិចារណា ឬបន្តសវនាការរឿងក្ដីផ្សេងទៀត (ប្រសិនបើមាន) ។

២.១៣៨.៦.២ ប្រសិនបើដើមបណ្ដឹងនៅតែបន្តប្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាប់ផ្ដើមដំណើរការប្រជុំផ្សះផ្សា ឬសវនាការ ។

២.១៣៨.៦.៣ ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ឬសវនាការ ប្រសិនបើដើមបណ្ដឹងសុំដកពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបញ្ចប់ការផ្សះផ្សា ឬការសួរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងចំណុច ២.១៣៨.៣ ឬចំណុច ២.១៣៨.៤ ។

២.១៣៨.៧ ជាដំបូង ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរដេញដោលទៅដើមបណ្ដឹងមុន រួចត្រូវសួរទៅចុងចម្លើយ ។ បន្ទាប់មកប្រធានត្រូវសួរសាក្សីដើមបណ្ដឹង សាក្សីចុងចម្លើយ និងអ្នកពាក់ព័ន្ធ ។

២.១៣៨.៨ ប្រសិនបើមានមេធាវីការពារក្ដី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្ដល់ពេលវេលា ឱ្យមេធាវីនិយាយការពារកូនក្ដីសួរភាគី និងធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយមុន ក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សា ពិចារណា ។

២.១៣៨.៩ ក្រោយពីបានដំណើរសវនាការតាមលំដាប់លំដោយរួចហើយ ក្រុមប្រឹក្សាជំនុំជម្រះត្រូវទៅពិភាក្សា ពិចារណានៅក្នុងបន្ទប់សម្ងាត់ ។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់ ។

**ឃ. ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ**

២.១៣៨.១០ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ មានភារកិច្ចដូចខាងក្រោម ។

២.១៣៨.១០.១ បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប ។

២.១៣៨.១០.២ នាំសាក្សីទៅធ្វើសម្បថ (ករណីសវនាការ)។

២.១៣៨.១០.៣ ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរនៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ អញ្ជើញមកដល់ ។

២.១៣៨.១០.៤ ពិនិត្យ និងស្រង់វត្តមាន អវត្តមានភាគីពាក់ព័ន្ធ ដែលត្រូវចូលរួមប្រជុំផ្សះផ្សា ឬសវនាការ ។

២.១៣៨.១០.៥ រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ។

២.១៣៨.១០.៦ ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការដោយដៃ ឬដោយកុំព្យូទ័រ ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការមិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ ។ ពាក្យឆូតលុបចោល និងពាក្យសរសេរយោង ត្រូវមានសេចក្តីបញ្ជាក់ និងមានហត្ថលេខាលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ និងភាគី ឬសាក្សី ។

២.១៣៨.១០.៧ អានឯកសារផ្សេងៗ ដែលពាក់ព័ន្ធតាមការបង្គាប់ពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ។

២.១៣៨.១០.៨ រៀបចំសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចចុះហត្ថលេខា រួចដាក់ជូនប្រធានក្រុមប្រឹក្សាជំនុំជម្រះ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ ។

២.១៣៨.១០.៩ អញ្ជើញភាគីផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការ ក្នុងករណីភាគីណាមួយមិនព្រមផ្តិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ ។

ខ. ពេលវេលាដោះស្រាយបណ្តឹង

២.១៣៨.១១ ការប្រជុំផ្សះផ្សា ឬសវនាការ អាចធ្វើជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៨:០០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទីថ្ងៃត្រង់ និងរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:៣០ នាទី ។ ក្នុងករណីចាំបាច់ការប្រជុំផ្សះផ្សា ឬសវនាការ អាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្តែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ ។

២.១៣៨.១២ ក្នុងកម្មវិធីមួយពេលនៃការបើកប្រជុំផ្សះផ្សា ឬសវនាការ លើពាក្យបណ្តឹង អាចកំណត់ធ្វើការផ្សះផ្សា ឬសវនាការច្រើនករណីនៃបណ្តឹងបាន ។

ច. ការជូនដំណឹងអំពីការប្រជុំផ្សះផ្សា ឬសវនាការ

២.១៣៨.១៣ គឃ/ខប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំផ្សះផ្សា ឬ/និងបើកសវនាការនៅថ្នាក់របស់ខ្លួន ទៅតាមករណីនៃបណ្តឹងក្នុងដំណាក់កាលនីមួយៗនៃការបោះឆ្នោត និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ក និង ប.ន.ក និងត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការប្រជុំផ្សះផ្សា ឬសវនាការ ដល់ភាគីពាក់ព័ន្ធបានទាន់ពេលវេលាយ៉ាងតិចម្ភៃបួន (២៤) ម៉ោង មុនពេលប្រជុំផ្សះផ្សា ឬសវនាការ ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សា (ករណីផ្សះផ្សាមិនសះជា) ទៅភាគីពាក់ព័ន្ធឱ្យដឹងពីកាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្តង ។

២.១៣៨.១៤ គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃបណ្តឹង ក្នុងដំណាក់កាលនីមួយៗនៃការបោះឆ្នោត និងទៅតាមរយៈពេលកំណត់ ដូចមានចែងនៅក្នុង ច.ប.ក និង ប.ន.ក នេះ ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការ ដល់ភាគីពាក់ព័ន្ធឱ្យបានទាន់ពេលវេលាយ៉ាងតិចម្ភៃបួន (២៤) ម៉ោង មុនពេលបើកសវនាការ ។

២.១៣៨.១៥ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប និងមន្ត្រីទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មនៃ គធ/ខប មានភារកិច្ចស៊ើបអង្កេត និងរៀបចំសំណុំរឿងទាំងឡាយសម្រាប់ប្រជុំផ្សះផ្សា ឬសវនាការ នៅតាមថ្នាក់របស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយ ទាំងអង្គហេតុ អង្គច្បាប់ និងឯកសារផ្សេងៗដែលពាក់ព័ន្ធ នឹងបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ និងផ្តល់ប្រឹក្សាផ្នែកច្បាប់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ នៅតាមថ្នាក់របស់ខ្លួន ។

២.១៣៨.១៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ត្រូវមានវិធានការបណ្តុះបណ្តាល ណែនាំសមាជិក ឬមន្ត្រីទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មនៃ គធ/ខប ដើម្បីបំពេញការងារជាសេនាធិការផ្នែកនេះឱ្យបានល្អនៅថ្នាក់របស់ខ្លួន ។

**ឆ. ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬសវនាការ**

២.១៣៨.១៧ ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាទេនោះ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ត្រូវសម្រេចលើកបណ្តឹងចោល ដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្តឹង។

២.១៣៨.១៨ ប្រសិនបើភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការទេ នោះក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំបាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខ ដោយបញ្ជាក់ពីមូលហេតុលើសម្រង់សេចក្តីសម្រេច ។

២.១៣៨.១៩ ប្រសិនបើដើមបណ្តឹងមិនបានបង្ហាញខ្លួននាថ្ងៃសវនាការ ក្រុមប្រឹក្សាជំនុំជម្រះត្រូវចាត់លេខាធិការសវនាការបញ្ជូនសម្រង់សេចក្តីសម្រេចទៅជូនដើមបណ្តឹងនៅអាសយដ្ឋានរបស់ដើមបណ្តឹង ឬទីស្នាក់ការគណបក្សរបស់ដើមបណ្តឹងនោះ ។ ប្រសិនបើដើមបណ្តឹងបដិសេធមិនទទួលយកសម្រង់សេចក្តីសម្រេចនោះ លេខាធិការសវនាការ ត្រូវចារលើសម្រង់សេចក្តីសម្រេចនោះ ដោយបញ្ជាក់អំពីការបដិសេធមិនទទួលយក រួចរក្សាទុកជាឯកសារ និងបិទផ្សាយជាសាធារណៈនៅលេខាធិការដ្ឋាន គធ/ខប ឬ នៅទីស្តីការ គ.ជ.ប ហើយចាត់ទុកថា ដើមបណ្តឹងបានទទួលសម្រង់សេចក្តីសម្រេចនេះ ។

២.១៣៨.២០ ប្រសិនបើភាគីដើមបណ្តឹងស្លាប់ នោះក្រុមប្រឹក្សាជំនុំជម្រះ នៅតែបន្តនីតិវិធីរបស់ខ្លួនដដែល ។

២.១៣៨.២១ ប្រសិនបើភាគីចុងចម្លើយស្លាប់ មុនពេលបើកប្រជុំផ្សះផ្សា ឬសវនាការក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវលុបបណ្តឹងចេញពីបញ្ជី ហើយត្រូវជូនដំណឹងទៅភាគីដើមបណ្តឹងឱ្យបានជ្រាប ។

២.១៣៨.២២ ប្រសិនបើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ នៅតែបន្តនីតិវិធីរបស់ខ្លួនដដែល ។

២.១៣៨.២៣ ប្រសិនបើចុងចម្លើយមិនបានបង្ហាញខ្លួននៅថ្ងៃសវនាការ ក្រុមប្រឹក្សាជំនុំជម្រះត្រូវចាត់លេខាធិការសវនាការបញ្ជូនសម្រង់សេចក្តីសម្រេចទៅជូនចុងចម្លើយនៅអាសយដ្ឋានរបស់ចុងចម្លើយ ឬទីស្នាក់ការគណបក្សរបស់ចុងចម្លើយនោះ ។ ប្រសិនបើចុងចម្លើយបដិសេធមិនទទួលយកសម្រង់សេចក្តីសម្រេច លេខាធិការសវនាការត្រូវចារលើសម្រង់សេចក្តីសម្រេចនោះ ដោយបញ្ជាក់អំពីការបដិសេធមិនទទួលយក រួចរក្សាទុកជាឯកសារ និងបិទផ្សាយជាសាធារណៈនៅលេខាធិការដ្ឋាន គជ/ខប ឬនៅទីស្តីការ គ.ជ.ប ហើយចាត់ទុកថា ចុងចម្លើយបានទទួលសម្រង់សេចក្តីសម្រេចនេះ ។

## ៩. ការប្រកាសសេចក្តីសម្រេច

២.១៣៨.២៤ ក្រុមប្រឹក្សាជំនុំជម្រះ ត្រូវប្រកាសសេចក្តីសម្រេចភ្លាមបន្ទាប់ពីពិភាក្សាគ្នារួចរាល់ ។ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះរឿងវិវាទដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយបណ្តឹងឡើយ ។

២.១៣៨.២៥ ការប្រកាសសេចក្តីសម្រេច ត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្តីសម្រេច ។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចចាត់តាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន ។

**ឈ. ការបំពេញ និងប្រើប្រាស់សម្រង់សេចក្តីសម្រេច (ទ. ១២០៣)**

២.១៣៨.២៦ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។ សេចក្តីសម្រេចនេះត្រូវស្រង់ដាក់ក្នុងសម្រង់សេចក្តីសម្រេច (ទ.១២០៣) ហើយត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដោយត្រូវធ្វើឡើងតាមចំនួន និងកម្មវត្ថុនៃបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់ ។

២.១៣៨.២៧ ការបំពេញ ទ.១២០៣ នៅថ្នាក់ គធ/ខប ត្រូវធ្វើជាបី (៣) ច្បាប់ សម្រាប់ការប្តឹងតវ៉ា ឬបួន (៤) ច្បាប់ សម្រាប់ការប្តឹងជំទាស់ ដើម្បី៖

២.១៣៨.២៧.១ ជូន ឬផ្ញើជូនសាមីអ្នកប្តឹង ឬអ្នកតំណាងមួយ (១) ច្បាប់ ជាបន្ទាន់ ។

២.១៣៨.២៧.២ ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងទាស់ ឬអ្នកតំណាងមួយ (១) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់ ។

២.១៣៨.២៧.៣ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ។

២.១៣៨.២៧.៤ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១៣៨.២៨ ការបំពេញ ទ.១២០៣ នៅ គ.ជ.ប ត្រូវធ្វើជាបី (៣) ច្បាប់ សម្រាប់ការប្តឹងតវ៉ា ឬបួន (៤) ច្បាប់ សម្រាប់ការប្តឹងជំទាស់ ដើម្បី ៖

២.១៣៨.២៨.១ ជូន ឬផ្ញើជូនសាមីអ្នកប្តឹង ឬអ្នកតំណាងមួយ (១) ច្បាប់ ជាបន្ទាន់ ។

២.១៣៨.២៨.២ ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងទាស់ ឬអ្នកតំណាងមួយ (១) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់ ។

២.១៣៨.២៨.៣ ផ្ញើជូន គធ/ខប មួយ (១) ច្បាប់ ។

២.១៣៨.២៨.៤ រក្សាទុកជាឯកសារ មួយ (១) ច្បាប់ ។

**ញ. ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា និងសវនាការ**

២.១៣៨.២៩ ទម្រង់បែបបទផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្សះផ្សា ឬសវនាការដែលបំពេញដោយ គធ/ខប ឬ គ.ជ.ប មានជាអាទិ៍ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬសវនាការ និងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការ ។

២.១៣៨.៣០ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬសវនាការ ត្រូវបំពេញតាមចំនួនជាក់ស្តែងនៃអ្នកពាក់ព័ន្ធ ដែលត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬសវនាការ រួចប្រគល់ជូនភាគីពាក់ព័ន្ធមួយ (១) ច្បាប់ៗ និងទុកជាឯកសារមួយ (១) ច្បាប់ ។

២.១៣៨.៣១ កំណត់ហេតុប្រជុំផ្សះផ្សា ត្រូវបំពេញដោយលេខាធិការប្រជុំផ្សះផ្សាចំនួនមួយ (១) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសាររបស់ភាគីពាក់ព័ន្ធនឹងបណ្តឹង និងលទ្ធផលនៃការផ្សះផ្សា ។

២.១៣៨.៣២ កំណត់ហេតុសវនាការ ត្រូវបំពេញដោយលេខាធិការសវនាការចំនួនមួយ (១) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសាររបស់ភាគីពាក់ព័ន្ធនឹងបណ្តឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ ។

២.១៣៨.៣៣ សេចក្តីសម្រេចរបស់ គធ/ខប និង គ.ជ.ប ត្រូវសរសេរនូវចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជាពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្តឹង លិខិតប្រគល់សិទ្ធិ ឬ/និងកំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ ។ សេចក្តីសម្រេចនេះ អាចផ្តល់ជូនគូភាគីបាន ប្រសិនបើមានការស្នើសុំ ។

## នីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយបណ្តឹងចំពោះគ្រប់អំពើល្មើសដែលអាចនាំឱ្យមានការផ្តន្ទាទោស

**ប្រការ ២.១៣៩** បទប្បញ្ញត្តិក្រោមប្រការនេះ កំណត់អំពីនីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយបណ្តឹងចំពោះគ្រប់អំពើល្មើសនឹងការបោះឆ្នោតដែលអាចនាំឱ្យមានការផ្តន្ទាទោសពិន័យជាប្រាក់ ឬ/និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងព្រមាន ឬ/និងបញ្ឈប់ពីការងារបោះឆ្នោត ដែលប្រព្រឹត្តដោយជនមិនមែនជាមន្ត្រីបោះឆ្នោត គណបក្សនយោបាយ និងជនដែលជាមន្ត្រីបោះឆ្នោត ហើយដែលអាចកើតឡើងជាយថាហេតុ នៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**ក. បណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ**

២.១៣៩.១ ជនណាក៏ដោយ ឬអ្នកតំណាងមានសិទ្ធិដាក់ពាក្យបណ្តឹង ចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ទៅ គធ/ខប ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ឬទៅ គ.ជ.ប ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចរបស់ គធ/ខប លើកលែងតែមានកាលបរិច្ឆេទផ្សេងពីនេះ ។

២.១៣៩.២ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចចែងក្នុងចំណុច ២.១៣៣.៥ នៃ ប.ន.ក នេះ ។

**ក.១. នីតិវិធីដាក់/ទទួលពាក្យបណ្តឹង និងដោះស្រាយបណ្តឹងនៅ គធ/ខប**

**ក.១.១ ការដាក់/ទទួលពាក្យបណ្តឹងនៅ គធ/ខប**

២.១៣៩.៣ អ្នកប្តឹង ត្រូវបំពេញ ទ.១២០២ ចំនួនបួន (៤) ច្បាប់ ។

២.១៣៩.៤ នៅពេលបានទទួលពាក្យបណ្តឹង គធ/ខប ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬអ្នកតំណាង ទី២ កម្មវត្ថុនៃបណ្តឹង និងការគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ។

២.១៣៩.៥ បន្ទាប់មក ជំនួយការសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬអ្នកតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬអ្នកតំណាងនោះផ្តិតមេដៃលើកំណត់ហេតុ ។ ក្នុងករណីអ្នកប្តឹង ឬអ្នកតំណាងមិនព្រមផ្តិមមេដៃ ជំនួការសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនេះ ។

២.១៣៩.៦ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុហើយ ឃើញថា ៖

២.១៣៩.៦.១ ពាក្យបណ្តឹងមិនគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ ប្រធាន គធ/ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យ

បណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ និងផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ ។

២.១៣៩.៦.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មាន គ្រប់គ្រាន់ដូចចែងក្នុងចំណុច ២.១៣៣.៥ ខាងលើ ជំនួយការសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬអ្នកតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ/ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹងមួយ (១) ច្បាប់ ផ្ញើជូន គ.ជ.ប មួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១៣៩.៦.៣ ពាក្យបណ្ដឹងគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ និងមានព័ត៌មានគ្រប់គ្រាន់ ជំនួយការសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវ ចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គធ/ខប លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ ជូនអ្នកប្ដឹង ឬអ្នកតំណាងមួយ (១) ច្បាប់ ផ្ញើជូនចុងចម្លើយមួយ (១) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សាមួយ (១) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈមួយ (១) ច្បាប់ ។

### ក.១.២ ការដោះស្រាយពាក្យបណ្ដឹងនៅ គធ/ខប

២.១៣៩.៧ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងជាផ្លូវការហើយ គធ/ខប ត្រូវប្រជុំពិភាក្សា ដើម្បីពិនិត្យសម្រេចជាបន្ទាន់លើបណ្ដឹង ។ ក្នុងករណី គធ/ខប ពិនិត្យ និងយល់ឃើញថា ៖

២.១៣៩.៧.១ ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការល្មើសលើ ច.ប.ក ឬ ប.ន.ក គធ/ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ ។

២.១៣៩.៧.២ កម្មវត្ថុ និងមូលហេតុនៃបណ្ដឹង មានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងបទល្មើសបោះឆ្នោត គធ/ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ ។

២.១៣៩.៧.៣ ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានគ្រប់គ្រាន់ គធ/ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវដែលអាចមានសមាសភាពដូចខាងក្រោម ៖

- ប្រធាន គធ/ខប ឬអ្នកតំណាង ជាប្រធានក្រុម
- សមាជិក គធ/ខប មួយ (១) នាក់ ជាសមាជិក
- មន្ត្រីសេវាកម្មច្បាប់ និងវិវាទកម្ម មួយ (១) នាក់ ជាលេខាធិការ ។

២.១៣៩.៨ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានាដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភ័ស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងបណ្ដឹង ។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្ដឹងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្ដឹង ។

២.១៣៩.៩ បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់ ហើយលទ្ធផលបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់នោះ មិនបានប្រព្រឹត្តល្មើសពាក់ព័ន្ធទៅនឹងការល្មើសលើ ច.ប.ក និង ប.ន.ក នេះ គធ/ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ចុះហត្ថលេខា បោះត្រា គធ/ខប និងចុះកាលបរិច្ឆេទ ។

២.១៣៩.១០ ក្នុងករណី លទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្ដឹងចោទប្រកាន់បានប្រព្រឹត្តល្មើសនឹង ច.ប.ក និង ប.ន.ក គធ/ខប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់ មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គធ/ខប ។

២.១៣៩.១១ គធ/ខប ត្រូវធ្វើកំណត់ហេតុនៃការផ្សះផ្សា ដោយឱ្យគូភាគី ផ្ដិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ ។

២.១៣៩.១១.១ ប្រសិនបើការផ្សះផ្សា ឈានទៅដល់ការព្រមព្រៀងគ្នារវាងភាគីមានទំនាស់ គធ/ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយ ឱ្យភាគីទំនាស់ផ្ដិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ បន្ទាប់ មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប ។

២.១៣៩.១១.២ ប្រសិនបើការផ្សះផ្សា មិនអាចឈានទៅដល់ការព្រមព្រៀងគ្នារវាងភាគីមានទំនាស់ទេ គធ/ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ ។ គធ/ខប ត្រូវកំណត់កាលបរិច្ឆេទបើកសវនាការជាសាធារណៈមួយ (១) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា និងត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សា ទៅភាគីពាក់ព័ន្ធឱ្យដឹងពីកាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្ដង ។

២.១៣៩.១២ ក្នុងសវនាការ គធ/ខប ត្រូវសម្រេចយល់ព្រម ឬបដិសេធលើបណ្ដឹងដោយមានកំណត់ហេតុសវនាការ សេចក្ដីសម្រេច និងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួនបួន (៤) ច្បាប់ ។

២.១៣៩.១៣ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ/ខប ត្រូវអនុវត្តតាមចំណុច ក. ក្រោមប្រការ ២.១៣២ នៃ ប.ន.ក នេះ ។

## គ.២. នីតិវិធីដាក់/ទទួលពាក្យបណ្ដឹង និងដោះស្រាយបណ្ដឹងនៅ គ.ជ.ប

### គ.២.១ ការដាក់/ទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

២.១៣៩.១៤ ភាគីវិវាទ ឬអ្នកតំណាង ដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គឃ/ខប អាចប្ដឹងបន្តទៅ គ.ជ.ប ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គឃ/ខប ។ អ្នកប្ដឹង ឬអ្នកតំណាងត្រូវបំពេញ ទ.១២០២ ចំនួនបួន (៤) ច្បាប់ ។

២.១៣៩.១៥ នៅពេលបានទទួលពាក្យបណ្ដឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬអ្នកតំណាង ទី២ កម្មវត្ថុនៃបណ្ដឹង និងការគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេចរបស់ គឃ/ខប (ទ.១២០៣) ។

២.១៣៩.១៦ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬអ្នកតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬអ្នកតំណាងផ្ដិតមេដៃ លើកំណត់ហេតុនោះ ។ ក្នុងករណីអ្នកប្ដឹង ឬអ្នកតំណាងមិនព្រមផ្ដិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនេះ ។

២.១៣៩.១៧ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុហើយ ឃើញថា ៖

២.១៣៩.១៧.១ ពាក្យបណ្ដឹងមិនគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គឃ/ខប អគ្គលេខាធិការនៃ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះ កាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹងមួយ (១) ច្បាប់ រក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១៣៩.១៧.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ដូចចែងក្នុងចំណុច ២.១៣៣.៥ ខាងលើ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់

និងវិវាទកម្មត្រូវណែនាំអ្នកប្ដឹង ឬអ្នកតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត អគ្គលេខាធិការនៃ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹងមួយ (១) ច្បាប់ និងរក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១៣៩.១៧.៣ ពាក្យបណ្ដឹងគោរពអំឡុងពេលកំណត់បី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គឃ/ខប និងមានព័ត៌មានគ្រប់គ្រាន់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្ដឹង ឬអ្នកតំណាងមួយ (១) ច្បាប់ ផ្ញើជូនចុងចម្លើយមួយ (១) ច្បាប់ រក្សាទុកក្នុងពេលដោះស្រាយបណ្ដឹងមួយ (១) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈមួយ (១) ច្បាប់ ។

**ក.២.២ ការដោះស្រាយបណ្ដឹងនៅ គ.ជ.ប**

២.១៣៩.១៨ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងជាផ្លូវការហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើបណ្ដឹង ។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថា ៖

២.១៣៩.១៨.១ ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការល្មើសលើ ច.ប.ក ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ ។

២.១៣៩.១៨.២ កម្មវត្ថុ និងមូលហេតុនៃបណ្ដឹង មានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធមិនពាក់ព័ន្ធទៅនឹងបទល្មើសបោះឆ្នោត គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ ។

២.១៣៩.១៨.៣ ពាក្យបណ្ដឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នារួច ហើយនៅថ្នាក់ គធ/ខប គ.ជ.ប ត្រូវពិនិត្យសម្រេចថា ត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ ។ ក្នុងករណីបដិសេធ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ ។

២.១៣៩.១៨.៤ ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានគ្រប់គ្រាន់ដូចក្នុងចំណុច ២.១៣៣.៥ គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ ។

២.១៣៩.១៩ គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ ។

២.១៣៩.២០ បន្ទាប់ពីបានស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកបណ្ដឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថា ពាក្យបណ្ដឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្ដឹងដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងស្រពេចស្រពិល មិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថា ផ្ទុយពីការអះអាងក្នុងពាក្យបណ្ដឹង ។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលក្នុងរយៈពេលសមស្របមួយទៅដើមបណ្ដឹង ដើម្បីជូនជ្រាបថា បណ្ដឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយទេ ។

២.១៣៩.២១ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្ដឹង គ.ជ.ប ត្រូវដោះស្រាយបណ្ដឹងតាមពេលវេលាសមស្របជាបន្ទាន់ ដោយត្រូវចាត់ចែងជូនដំណឹងទៅភាគីពាក់ព័ន្ធឱ្យដឹងពីកាលបរិច្ឆេទ និងទីកន្លែងបើកសវនាការ ។

២.១៣៩.២២ ក្នុងសវនាការ គ.ជ.ប ត្រូវសម្រេចយល់ព្រម ឬបដិសេធលើបណ្ដឹងដោយមានកំណត់ហេតុ សេចក្ដីសម្រេច និងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ចំនួន បួន (៤) ច្បាប់ ។

២.១៣៩.២៣ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៅ គ.ជ.ប ត្រូវអនុវត្តតាមចំណុច ខ ក្រោមប្រការ ២.១៣២ នៃ ប.ន.ក នេះ ។

## ខ. បណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

២.១៣៩.២៤ គ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើល្មើសលើ ច.ប.ក និង ប.ន.ក នេះ ដែលប្តឹងមន្ត្រី ឬសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬមន្ត្រីនៅទីស្តីការ គ.ជ.ប ត្រូវដាក់ទៅគណៈកម្មការថ្នាក់លើមួយថ្នាក់ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ លើកលែងតែមានកាលបរិច្ឆេទកំណត់ផ្សេងពីនេះក្នុង ច.ប.ក និង ប.ន.ក នេះ ។

២.១៣៩.២៥ បណ្តឹងពាក់ព័ន្ធនឹងសមាជិក គកប/គករ ដំបូងត្រូវប្តឹងទៅ គឃ/ខប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ២.១៣៩.១ រហូតដល់ចំណុច ២.១៣៩.២៣។

២.១៣៩.២៦ បណ្តឹងពាក់ព័ន្ធនឹងប្រធាន ឬសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដំបូងត្រូវប្តឹងទៅ គឃ/ខប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ២.១៣៩.១ រហូតដល់ចំណុច ២.១៣៩.២៣ ។

២.១៣៩.២៧ បណ្តឹងពាក់ព័ន្ធនឹងមន្ត្រីនៅ គឃ/ខប ត្រូវប្តឹងទៅប្រធាន គឃ/ខប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ២.១៣៩.១ រហូតដល់ចំណុច ២.១៣៩.២៣។

២.១៣៩.២៨ បណ្តឹងពាក់ព័ន្ធនឹងសមាជិក គឃ/ខប ត្រូវប្តឹងទៅ គ.ជ.ប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ២.១៣៩.១៥ រហូតដល់ចំណុច ២.១៣៩.២៣។

២.១៣៩.២៩ បណ្តឹងពាក់ព័ន្ធនឹងមន្ត្រីនៅទីស្តីការ គ.ជ.ប ត្រូវប្តឹងទៅប្រធាន គ.ជ.ប ដូចបានកំណត់ក្នុងចំណុច ២.១៣៩.១៥ រហូតដល់ចំណុច ២.១៣៩.២៣។

២.១៣៩.៣០ បណ្តឹងពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្តឹងទៅរដ្ឋសភា ដោយអនុលោមតាម ច.ប.គ.រ ។

២.១៣៩.៣១ បណ្តឹងចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្តឹង ដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ និងមិនព្រមដោះស្រាយបណ្តឹង ដែល មន្ត្រីនោះបានទទួលពាក្យបណ្តឹងរួចហើយ ត្រូវដាក់ទៅគណៈកម្មការ ថ្នាក់លើមួយថ្នាក់ក្នុងរយៈពេលបី (៣) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។ ក្នុងករណី ៖

២.១៣៩.៣១.១ រកឃើញថា សមាជិក ឬមន្ត្រីនោះ ពិតជាបានប្រព្រឹត្ត ផ្ទុយនឹង ច.ប.ក និង ប.ន.ក ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មស្របតាម ច.ប.ក ។

២.១៣៩.៣១.២ រកឃើញថា សមាជិក ឬមន្ត្រីនោះ បានគោរពតាម ច.ប.ក និង ប.ន.ក ត្រឹមត្រូវហើយ ត្រូវបដិសេធ ពាក្យបណ្តឹងនោះ ហើយពាក្យបណ្តឹងដែលត្រូវបាន បដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធ ផងដែរ ។

# ផ្នែកទី ១២
## ការបោះឆ្នោតឡើងវិញ

**ប្រការ ២.១៤០** អនុលោមតាមមាត្រា ៧៨ និង ៨០ នៃ ច.ប.ក និងមាត្រា ២៥ នៃ ច.គ.ខ.ស ការរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើឡើងក្នុងករណីណាមួយដូចខាងក្រោម ៖

២.១៤០.១ ខេត្ត ក្រុង ស្រុក ខណ្ឌដែលបង្កើតថ្មី ដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃ ច.គ.ខ.ស ។ ក្នុងករណីនេះ ការបោះឆ្នោតឡើងវិញត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរពីររយសែសិប (២៤០) ថ្ងៃបន្ទាប់ពីថ្ងៃបង្កើតខេត្ត ក្រុង ស្រុក ខណ្ឌនោះ ។

២.១៤០.២ ក្រុមប្រឹក្សាដែលត្រូវរំសាយតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ២៤ ច.គ.ខ.ស ។ ក្នុងករណីនេះ ការបោះឆ្នោតឡើងវិញ ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ (១២០) ថ្ងៃបន្ទាប់ពីថ្ងៃត្រូវបានរំសាយ ។

២.១៤០.៣ កាលបរិច្ឆេទសម្រាប់ការបោះឆ្នោតឡើងវិញ ត្រូវកំណត់ដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

២.១៤០.៤ ក្រុមប្រឹក្សា ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

**ប្រការ ២.១៤១** អនុលោមតាមមាត្រា ៨១ នៃ ច.ប.ក និងមាត្រា ២៦ នៃ ច.គ.ខ.ស ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប (១៨០) ថ្ងៃ ។ ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចាត់វិធានការ ដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។

**ប្រការ ២.១៤២** អនុលោមតាម ច.ប.ក និង ច.គ.ខ.ស ការបោះឆ្នោតឡើងវិញត្រូវប្រព្រឹត្តទៅក្រោមការគ្រប់គ្រង និងចាត់ចែងដោយ គ.ជ.ប ។

ប្រការ២.១៤៣ គ.ជ.ប ត្រូវចាត់ចែងគ្រប់គ្រងការបោះឆ្នោតឡើងវិញ ដោយអនុលោមតាម ច.ប.ក និង ប.ន.ក របស់ គ.ជ.ប និងពេលវេលាដែលបានកំណត់ដោយច្បាប់ ។

២.១៤៣.១ សិទ្ធិអំណាច និងភារកិច្ចរបស់ គ.ជ.ប គធ/ខប និង គកប ត្រូវអនុលោមតាម ច.ប.ក និង ប.ន.ក នេះ ។

២.១៤៣.២ គ.ជ.ប ត្រូវចាត់ចែងការផ្សព្វផ្សាយដំណឹង អំពីការបោះឆ្នោតឡើងវិញជាសាធារណៈ ដោយឡែក នៅក្នុងមណ្ឌលបោះឆ្នោតដែលត្រូវធ្វើការបោះឆ្នោតឡើងវិញ ។

២.១៤៣.៣ គ.ជ.ប ត្រូវចាត់ចែងការជ្រើសរើស និងតែងតាំង ៖

១_ មន្ត្រីមួយចំនួននៅ គ.ជ.ប តាមតម្រូវការនៃការងារ ។

២_ គធ/ខប ពាក់ព័ន្ធ និងមន្ត្រីមួយចំនួននៃ គធ/ខប នោះតាមតម្រូវការនៃការងារ ។

៣_ គកប នៃការិយាល័យក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

២.១៤៣.៣.១ ការជ្រើសរើស និងតែងតាំង ត្រូវអនុលោមតាមប្រព័ន្ធជ្រើសរើស ដូចមានចែងក្នុង ប.ន.ក នេះ ។ ប្រសិនបើអាចធ្វើបាន គួរជ្រើសរើសមន្ត្រី ដែលធ្លាប់បំរើការងារបោះឆ្នោតកន្លងមក ។

២.១៤៣.៣.២ រយៈពេលនៃការជ្រើសរើស និងតែងតាំង និងរយៈពេលនៃការបណ្តុះបណ្តាលមន្ត្រីដែលជ្រើសរើសថ្មី ដូចចែងក្នុងចំណុច ១៤.៦.៣ ខាងលើ ត្រូវកាត់បន្ថយឱ្យបានសមស្រប តាមទំហំការងារ ។

២.១៤៣.៣.៣ ពេលវេលានៃការជ្រើសរើស និងតែងតាំង និងអាណត្តិរបស់គណៈកម្មការគ្រប់លំដាប់ថ្នាក់ និងមន្ត្រីដែលជ្រើសរើសថ្មីត្រូវកំណត់ដោយ គ.ជ.ប ។

២.១៤៣.៤ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលត្រូវបោះឆ្នោតឡើងវិញ មានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះតំណាងពេញសិទ្ធិ (១) នាក់ និងតំណាងបំរុងមួយ (១) នាក់ នៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗទៅ គធ/ខប ក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីថ្ងៃដែល គធ/ខប ត្រូវបានបង្កើតឡើង ។

២.១៨៣.៥ គណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោត ដែលត្រូវបោះឆ្នោតឡើងវិញ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ ទៅ គ.ជ.ប នៅក្រោយពេលដែល គ.ជ.ប ប្រកាសអំពីការបោះឆ្នោតឡើងវិញ ។

២.១៨៣.៦ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានអនុញ្ញាតឱ្យសង្កេតការណ៍ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលមានបំណងសង្កេតមើលដំណើរការរៀបចំការបោះឆ្នោតឡើងវិញ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ទៅ គ.ជ.ប នៅក្រោយពេលដែល គ.ជ.ប ប្រកាសអំពីការបោះឆ្នោតឡើងវិញ ។

២.១៨៣.៧ ក្នុងករណី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបង្កើតថ្មី ដូចមានចែងក្នុងចំណុច ២.១៨០.១ ឬក្រុមប្រឹក្សាដែលត្រូវរំសាយ ដូចមានចែងក្នុងចំណុច ២.១៨០.២ ខាងលើ លធ/ខប ពាក់ព័ន្ធត្រូវពិនិត្យ និងលើកសំណើសុំកំណត់ ឬកែសម្រួល ទីតាំងការិយាល័យបោះឆ្នោត ដោយត្រូវផ្អែកលើការិយាល័យបោះឆ្នោតចាស់ ការប្រែប្រួលភូមិសាស្ត្រ និងព្រំប្រទល់រដ្ឋបាលថ្មី ។

២.១៨៣.៨ គ.ជ.ប ត្រូវកំណត់ ឬកែសំរួលទីតាំងការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដោយផ្អែកតាមសំណើរបស់ លធ/ខប ។ បញ្ជីឈ្មោះទីតាំងផ្លូវការនៃការិយាល័យដែលត្រូវបោះឆ្នោតឡើងវិញ ត្រូវបិទផ្សាយជាសាធារណៈនៅគធ/ខប និងនៅតាមការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ យ៉ាងតិចមួយ (១) ថ្ងៃ មុនកាលបរិច្ឆេទនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះបោះឆ្នោត ។

២.១៨៣.៩ គ.ជ.ប ត្រូវធានាក្នុងការរៀបចំឱ្យមានបញ្ជីឈ្មោះអ្នកបោះឆ្នោត សម្រាប់ការបោះឆ្នោតឡើងវិញ ។

២.១៨៣.៩.១ ក្នុងករណី ការបោះឆ្នោតឡើងវិញត្រូវធ្វើឡើងចំពោះ ក្រុមប្រឹក្សាត្រូវបង្កើតថ្មី ដូចចែងក្នុងចំណុច ២.១៨០.១ គ.ជ.ប ត្រូវរៀបចំបញ្ជីបោះឆ្នោត ដោយអនុវត្តតាមលំនាំនីតិវិធី ដូចចែងក្នុងផ្នែកទី ៤ ជំពូកទី ២ នៃ ប.ន.ក នេះ ។

២.១៤៣.៩.២ ក្នុងករណី ការបោះឆ្នោតឡើងវិញត្រូវធ្វើឡើងចំពោះ ក្រុមប្រឹក្សាត្រូវរំសាយ ដូចចែងក្នុងចំណុច ២.១៤០.២ គ.ជ.ប ត្រូវត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ដោយផ្អែកលើបញ្ជីបោះឆ្នោត ដែលបានប្រើសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាចុងក្រោយ ។

២.១៤៣.៩.៣ គ.ជ.ប ត្រូវផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ដូចចែងក្នុងចំណុច ២.១៤៣.៩.១ និង ២.១៤៣.៩.២ ខាងលើ ។ បញ្ជីបោះឆ្នោតផ្លូវការនេះ ត្រូវបិទផ្សាយនៅ គឃ/ខប និងនៅការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ដែលត្រូវបោះឆ្នោតឡើងវិញ នៅថ្ងៃជាមួយគ្នានឹងថ្ងៃបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងត្រូវបិទផ្សាយម្តងទៀត នៅទីកន្លែងដដែលមួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.១៤៣.១០ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងការចាប់ឆ្នោតកំណត់លេខរៀងគណបក្សនយោបាយលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតឡើងវិញ ត្រូវអនុវត្តតាមផ្នែកទី ៣ ជំពូកទី ២ នៃ ប.ន.ក នេះ ។

២.១៤៣.១១ គ.ជ.ប ត្រូវធ្វើគំរូសន្លឹកឆ្នោត និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតឡើងវិញ នៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតដែលប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាលើកមុន ។

២.១៤៣.១២ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារឯកសារបោះឆ្នោតជូន គឃ/ខប និង គកប សម្រាប់ការរៀបចំបោះឆ្នោតឡើងវិញឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។

២.១៤៣.១៣ ការឃោសនាបោះឆ្នោតមានរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ជាប់ៗគ្នា ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ម្ភៃបួន (២៤) ម៉ោង មុនថ្ងៃបោះឆ្នោត ។ ការឃោសនាបោះឆ្នោត ត្រូវធ្វើតែក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលត្រូវធ្វើការបោះឆ្នោតឡើងវិញ និងត្រូវគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងផ្នែកទី ៦ ជំពូកទី ២ នៃ ប.ន.ក នេះ ។

**ប្រការ ២.១៨៤** នីតិវិធីនៃការបោះឆ្នោតឡើងវិញ ត្រូវអនុវត្តដូចនីតិវិធីនៃការបោះឆ្នោត ដែលមានចែងក្នុងផ្នែកទី ៧ និងទី ៨ ជំពូកទី ២ នៃ ប.ន.ក នេះ ។

២.១៨៤.១ ការបោះឆ្នោតឡើងវិញ ត្រូវអនុវត្តតែមួយថ្ងៃចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ១៥:០០នាទី ។

២.១៨៤.២ នៅពេលបញ្ចប់ការបោះឆ្នោតឡើងវិញ គកប ត្រូវអនុវត្តការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រមូល ប្រគល់ និងទទួលសម្ភារឯកសារបោះឆ្នោត ដូចការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលមានចែងក្នុង ប.ន.ក នេះ ។

២.១៨៤.៣ គធ/ខប ត្រូវត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ និងធ្វើការគណនាបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតតាមនីតិវិធី ដូចមានចែងក្នុងផ្នែកទី ២ និងចំណុច ២.១១៦.៥ នៃ ប.ន.ក នេះហើយធ្វើរបាយការណ៍ជូន គ.ជ.ប ដើម្បីត្រួតពិនិត្យ និងប្រកាសលទ្ធផលផ្លូវការ ។

**ប្រការ ២.១៨៥** ក្នុងការរៀបចំការបោះឆ្នោតឡើងវិញ ចាប់តាំងពីការផ្ដើមដំបូងរហូតដល់ការប្រកាសលទ្ធផលផ្លូវការ ការប្ដឹងតវ៉ា ឬ/និង ការប្ដឹងជំទាស់ ការប្រជុំសម្រេច ឬ/និង សវនាការដោះស្រាយបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីដូចគ្នានឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលមានចែងក្នុង ប.ន.ក នេះ ។

# ផ្នែកទី ១៣

# តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន

## តំណាងគណបក្សនយោបាយ

**ប្រការ ២.១៨៦** នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម គឺជាសេនាធិការរបស់ គ.ជ.ប ក្នុងការងារទាក់ទងទៅនឹងគណបក្សនយោបាយ ។

២.១៨៦.១ អនុលោមតាម ច.ប.ក តំណាងគណបក្សនយោបាយ គឺជាអ្នកដែលត្រូវបានតែងតាំងដោយគណបក្សនយោបាយ និងត្រូវបានអនុញ្ញាតដោយ គធ/ខប ដើម្បីសង្កេតមើលការរៀបចំការបោះឆ្នោត ។ តំណាងគណបក្សនយោបាយ គឺជាអ្នកសង្កេតការណ៍ដែលមានសិទ្ធិប្តឹងតវ៉ា ឬជំទាស់ ។

២.១៨៦.២ គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិចាត់តាំងតំណាងពេញសិទ្ធិរបស់ខ្លួនមួយ (១) នាក់ និងតំណាងបម្រុងមួយ (១) នាក់ ដើម្បីសង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ ។

គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ មានសិទ្ធិចាត់តាំងតំណាងពេញសិទ្ធិរបស់ខ្លួនមួយ (១) នាក់ និងតំណាងបម្រុងមួយ (១) នាក់ ដើម្បីសង្កេតមើលការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅតាមការិយាល័យនីមួយៗ ដែលកំណត់ដោយ គ.ជ.ប ។

២.១៨៦.៣ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ ជំនួយការភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាតំណាងគណបក្សនយោបាយ ដើម្បីពិនិត្យមើលការបោះឆ្នោតឡើយ ។

២.១៨៦.៤ តំណាងគណបក្សនយោបាយនីមួយៗ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត និងការិយាល័យ

រាប់សន្លឹកឆ្នោតតែម្នាក់ប៉ុណ្ណោះ ។ តំណាងបម្រុងនៃគណបក្សនយោបាយ ត្រូវបានអនុញ្ញាតឱ្យចាំនៅក្រៅ ការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីជំនួសតំណាងពេញសិទ្ធិ ក្នុងករណីមានការផ្លាស់ប្តូរ ។

២.១៩៦.៥ គណបក្សនយោបាយ ដែលមានបំណងដាក់តំណាងរបស់ខ្លួន ដើម្បីសង្កេតមើលការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យចុះឈ្មោះតំណាងរបស់ខ្លួនទៅ គធ/ខប ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃមុនថ្ងៃចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រហូតដល់ថ្ងៃបញ្ចប់ដំណើរការចុះឈ្មោះបោះឆ្នោត ។

សម្រាប់ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះតំណាងរបស់ខ្លួនទៅ គធ/ខប បន្ទាប់ពី គធ/ខប ទទួលស្គាល់ជាផ្លូវការនូវការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ រហូតដល់ប្រាំពីរ (៧) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

២.១៩៦.៥.១ ពាក្យសុំចុះឈ្មោះជាតំណាងគណបក្សនយោបាយត្រូវធ្វើជាបី (៣) ច្បាប់តាមទម្រង់បែបបទលេខ ១០០៧ ដោយភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ថតចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយ (១) ច្បាប់
- បញ្ជីឈ្មោះតំណាងពេញសិទ្ធិ និងតំណាងបម្រុងនៃគណបក្សនយោបាយ ដែលក្នុងនេះត្រូវបញ្ជាក់អំពីនាមត្រកូល នាមខ្លួន អាសយដ្ឋាន និងលេខការិយាល័យបោះឆ្នោត ដែលតំណាងទាំងនោះត្រូវបំពេញការងារ ។
- លិខិតធានាអះអាងរបស់គណបក្សនយោបាយសាមីថាតំណាងគណបក្សរបស់ខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

២.១៩៦.៥.២ តំណាងគណបក្សនយោបាយត្រូវជាអ្នក ៖

- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- មានសមត្ថភាពអាចបំពេញការងារបាន
- បានទទួលការហ្វឹកហ្វឺនជាតំណាងគណបក្សនយោបាយដោយគណបក្សនយោបាយសាមី ។

២.១៨៦.៥.៣ ពាក្យសុំចុះឈ្មោះជាតំណាងគណបក្សនយោបាយ ត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងនៃគណបក្សនយោបាយ ដែលទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត ដោយគ្មានការអនុញ្ញាតពីប្រធានគណបក្សនយោបាយឡើយ ។

២.១៨៦.៥.៤ គធ/ខប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះជាតំណាងគណបក្សនយោបាយ និងចេញសេចក្តីសម្រេចអនុញ្ញាត ឬបដិសេធលើឈ្មោះនៃតំណាងគណបក្សនយោបាយ ដែលមានក្នុងបញ្ជីឈ្មោះស្នើសុំមកក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យសុំ ។

២.១៨៦.៥.៥ បន្ទាប់ពី គធ/ខប ពិនិត្យ និងសម្រេចលើបញ្ជីឈ្មោះតំណាងគណបក្សនយោបាយរួចហើយ គធ/ខប ត្រូវចុះហត្ថលេខា និងបោះត្រាលើគ្រប់ទំព័រទាំងបី (៣) ច្បាប់ដើម្បី ៖

- ផ្ញើទៅសាមីគណបក្សនយោបាយ មួយ (១) ច្បាប់
- ផ្ញើទៅ គ.ជ.ប មួយ (១) ច្បាប់
- រក្សាទុកជាឯកសារមួយ (១) ច្បាប់ ។

២.១៨៦.៥.៦ ប្រសិនបើ គធ/ខប ពិនិត្យលើពាក្យស្នើសុំឃើញថា តំណាងគណបក្សនយោបាយណាម្នាក់ ពុំមានលក្ខណៈត្រឹមត្រូវ តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ២.១៨៦.៥.២ គធ/ខប ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅតំណាងសាមីគណបក្សនយោបាយ ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ ក្រោយពីបានទទួលពាក្យស្នើសុំ ។ គណបក្សនយោបាយ មានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះតំណាងពេញសិទ្ធិ និងបម្រុងរបស់ខ្លួនជាថ្មីមួយលើកទៀត ជំនួសឈ្មោះតំណាងពេញសិទ្ធិ និងបម្រុង ដែលបានបដិសេធមក គធ/ខប ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងអំពីការបដិសេធនេះ ។ ក្នុងរយៈពេលនេះ ប្រសិនបើតំណាងគណបក្សនៅតែពុំព្រមកែតម្រូវតាមលក្ខខណ្ឌ ដូចបានកំណត់ទេនោះ គធ/ខប ត្រូវសម្រេចទទួលស្គាល់តែឈ្មោះតំណាងណា ដែលបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌតែប៉ុណ្ណោះ ។

២.១៩៦.៥.៧ បន្ទាប់ពី គធ/ខប សម្រេចអនុញ្ញាតលើពាក្យសុំចុះឈ្មោះរបស់តំណាងគណបក្សនយោបាយរួចហើយ គធ/ខប ត្រូវផ្តល់ប័ណ្ណសម្គាល់ ជូនតំណាងគណបក្សនយោបាយ ដើម្បីឱ្យបំពេញ និង បិទរូបថត ។ គធ/ខប ត្រូវចុះហត្ថលេខា និង ចុះកាលបរិច្ឆេទលើប័ណ្ណសម្គាល់តំណាងគណបក្សនយោបាយ ព្រមទាំងបោះត្រានៅលើជ្រុងខាងស្តាំនៃរូបថត និងផ្តល់ជូនតំណាងនោះ ដើម្បីពាក់ក្នុងពេលបំពេញការងារ ។

២.១៩៦.៥.៨ ប័ណ្ណសម្គាល់នេះ មានសុពលភាពប្រើប្រាស់តែក្នុងការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតែប៉ុណ្ណោះ ។

២.១៩៦.៥.៩ សម្រាប់ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត គណបក្សនយោបាយនីមួយៗ មានសិទ្ធិផ្លាស់ប្តូរតំណាងរបស់ខ្លួនរហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ និងសាមសិបនាទី) នៃថ្ងៃសៅរ៍ មុនថ្ងៃបោះឆ្នោតមួយ (១) ថ្ងៃ ។

២.១៩៦.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំគំរូ និងខ្លឹមសារនៃពាក្យស្នើសុំចុះឈ្មោះតំណាងគណបក្សនយោបាយ និងប័ណ្ណសម្គាល់ ។ គធ/ខប ត្រូវផ្តល់ប័ណ្ណសម្គាល់ជូនតំណាងគណបក្សនយោបាយដោយឥតគិតថ្លៃ ដើម្បីបំពេញ និងបិទរូបថត សម្រាប់សង្កេតមើលការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោតនីមួយៗ ។ តំណាងគណបក្សនយោបាយសង្កេតមើលការចុះឈ្មោះបោះឆ្នោត ត្រូវពាក់ប័ណ្ណសម្គាល់ដែលចេញដោយគណបក្សនយោបាយសាមី និងត្រូវបង្ហាញលិខិតអនុញ្ញាតដែលចេញដោយ គធ/ខប (ទ.១០០៧ និងបញ្ជីឈ្មោះភ្ជាប់ជាមួយ ទ.១០០៧) ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

២.១៩៦.៧ តំណាងគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ច ដូចមានចែងក្នុងក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ ។

២.១៩៦.៨ តំណាងគណបក្សនយោបាយ ដែលរំលោភលើ ប.ន.ក និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយនឹងត្រូវទទួលទោស និងពិន័យទៅតាម ច.ប.ក ។

២.១៤៦.៩ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរៀបចំក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ។

២.១៤៦.១០ គកប ឬ គឃ/ខប ត្រូវរាយការណ៍ទៅថ្នាក់លើមួយថ្នាក់របស់ខ្លួនអំពី វត្តមាន និងសកម្មភាពនានារបស់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

**អ្នកសង្កេតការណ៍បោះឆ្នោត**

**ប្រការ ២.១៤៧** អ្នកសង្កេតការណ៍បោះឆ្នោតរួមមានអ្នកសង្កេតការណ៍ជាតិ និងអ្នកសង្កេតការណ៍អន្តរជាតិ ៖

- អ្នកសង្កេតការណ៍ជាតិ គឺជាជនជាតិខ្មែរ ឬជនបរទេសដែលជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬជនបរទេសដែលត្រូវបានអញ្ជើញដោយសមាគម ឬអង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានទទួលស្គាល់ និងអនុញ្ញាតដោយ គ.ជ.ប ។
- អ្នកសង្កេតការណ៍អន្តរជាតិ គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលបរទេស អង្គការអន្តរជាតិ និងប្រទេសនានា ដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប ។
- រាល់ការចំណាយទាំងឡាយរបស់អ្នកសង្កេតការណ៍បោះឆ្នោត ជាបន្ទុករបស់ស្ថាប័ន អង្គការ ឬសាមីខ្លួន ។

**អ្នកសង្កេតការណ៍ជាតិ**

**ប្រការ ២.១៤៨** គ.ជ.ប ត្រូវធ្វើសេចក្តីជូនដំណឹងជាមុន អំពីប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិត្រូវធ្វើនៅ គ.ជ.ប ។ ការទទួលពាក្យ ចាប់ផ្តើមពីថ្ងៃជូនដំណឹងអំពីប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រហូតដល់ដប់ (១០) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.១៤៨.១ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១- មានលិខិតបញ្ជាក់ការចុះបញ្ជីជាផ្លូវការ នៅក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា យ៉ាងហោចណាស់ប្រាំពីរ (៧) ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២- មានលក្ខន្តិកៈ ឬឯកសារប្រហាក់ប្រហែលគ្នា ដែលបញ្ជាក់ពីគោលបំណង ឬទិសដៅក្នុងការលើកកម្ពស់ការការពារ អភិបាលកិច្ចល្អ ប្រជាធិបតេយ្យ ឬការបោះឆ្នោត ឬសិទ្ធិមនុស្ស ឬច្បាប់ ឬយុត្តិធម៌សង្គម។

៣_ មានកម្មវិធីបណ្តុះបណ្តាលអប់រំស្តីពីការបោះឆ្នោត ជូនសមាជិកជាអ្នកសង្កេតការណ៍របស់ខ្លួន ។
៤_ មានផែនការការងារ និងស្ថានភាពថវិការបស់ខ្លួន ។

២.១៨៤.២ ដើម្បីចូលរួមសង្កេតការណ៍បោះឆ្នោត អ្នកសង្កេតការណ៍ជាតិ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានលក្ខណសម្បត្តិដូចចំណុច ២.១៨៤.១ ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួននៅ គ.ជ.ប ។

២.១៨៤.៣ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប ត្រូវផ្តល់គំរូនៃពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតដោយឥតគិតថ្លៃ ។ ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតត្រូវធ្វើជាបី (៣) ច្បាប់ ដោយភ្ជាប់មកជាមួយនូវ ៖
១_ លក្ខខណ្ឌ ដូចចែងក្នុងចំណុច ២.១៨៤.១ ។
២_ បញ្ជីឈ្មោះអ្នកសង្កេតការណ៍តាមរាជធានី ខេត្តដែលត្រូវធ្វើការសង្កេតការណ៍ ។
៣_ សេចក្តីប្រកាសគោរព ច.ប.ក ប.ន.ក និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។

២.១៨៤.៤ អ្នកសង្កេតការណ៍បោះឆ្នោតត្រូវជាអ្នក ៖
- មានសិទ្ធិបោះឆ្នោត
- បានទទួលការហ្វឹកហ្វឺនអំពី ច.ប.ក ប.ន.ក និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ ។

២.១៨៤.៥ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងរយៈពេលប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យសុំចុះឈ្មោះ ។

២.១៨៤.៥.១ ក្នុងករណីពិនិត្យបញ្ជីឈ្មោះ ដែលដាក់ស្នើសុំមកឃើញថាអ្នកសង្កេតការណ៍ណាម្នាក់ពុំមានលក្ខណៈគ្រប់គ្រាន់ គ.ជ.ប ត្រូវបដិសេធឈ្មោះរបស់ជននោះ ដោយត្រូវ ៖
- រក្សាទុកឈ្មោះអ្នកសង្កេតការណ៍ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ។

- គូសបន្ទាត់លុបលើឈ្មោះ ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់ និងចារ « បដិសេធ » នៅខាងចុងឈ្មោះត្រង់ខ្ទង់ផ្សេងៗ ។

២.១៤៨.៥.២ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍របស់ខ្លួនជាថ្មី មួយលើកទៀតជំនួសឈ្មោះអ្នកសង្កេតការណ៍ ដែលបានបដិសេធ ក្នុងរយៈពេលយ៉ាងយូរបី (៣) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងបដិសេធ ។

២.១៤៨.៥.៣ ក្នុងរយៈពេលកំណត់ខាងលើ ប្រសិនបើសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល មិនបានកែតម្រូវឈ្មោះអ្នកសង្កេតការណ៍ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់នោះទេ គ.ជ.ប ត្រូវចេញសេចក្ដីសម្រេចអនុញ្ញាតជាលាយលក្ខណ៍អក្សរ ចំពោះតែអ្នកសង្កេតការណ៍ណា ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងចេញសេចក្ដីសម្រេចបដិសេធឈ្មោះអ្នកសង្កេតការណ៍ណា ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់នោះចោល ។

២.១៤៨.៥.៤ សេចក្ដីសម្រេចអនុញ្ញាត លើឈ្មោះអ្នកសង្កេតការណ៍ជាតិ ត្រូវធ្វើ ជាបួន (៤) ច្បាប់ ដើម្បី ៖

- រក្សាទុកនៅ គ.ជ.ប មួយ (១) ច្បាប់
- ផ្ញើទៅ គធ/ខប មួយ (១) ច្បាប់
- ជូនសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលពីរ (២) ច្បាប់ ។

២.១៤៨.៥.៥ បញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលត្រូវបានសម្រេច ត្រូវបោះត្រាលើគ្រប់ទំព័ររួចផ្ញើបញ្ជីឈ្មោះនោះទៅ គធ/ខប ។

២.១៤៨.៦ គធ/ខប ត្រូវផ្ដល់ប័ណ្ណសម្គាល់ សម្រាប់អ្នកសង្កេតការណ៍ជាតិពាក់បំពេញការងារសង្កេតការណ៍បោះឆ្នោតនៅរាជធានី ខេត្ត របស់ខ្លួន ។ គធ/ខប ត្រូវផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលតំណាងរបស់សមាគម ឬសាមីអង្គការមិនមែនរដ្ឋាភិបាលបង្ហាញជូន ជាមួយនឹងបញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលផ្ញើជូនជាផ្លូវការដោយ គ.ជ.ប ។

២.១៤៨.៦.១ ក្រោយពីបានពិនិត្យឃើញថា ត្រឹមត្រូវហើយ គធ/ខប ត្រូវ ៖

- ប្រគល់ប័ណ្ណគ្រប់ចំនួនតាមឈ្មោះនៃអ្នកសង្កេតការណ៍ ដែលមាននៅក្នុងបញ្ជីឈ្មោះ ដើម្បីឱ្យតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល បំពេញ និងបិទរូបថត។

- ប្រាប់ទៅតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលបានទទួលប័ណ្ណសម្គាល់អ្នកសង្កេតការណ៍ថា ឱ្យប្រញាប់បំពេញ និងបិទរូបថត ដើម្បីទទួលបានសុពលភាពជាផ្លូវការ ។

២.១៥៨.៦.២ ប័ណ្ណសម្គាល់អ្នកសង្កេតការណ៍ ដែលអាចយកជាផ្លូវការបាន ក្នុងដំណើរការសង្កេតការណ៍បោះឆ្នោត លុះត្រាតែ ៖
- ប័ណ្ណសម្គាល់ចេញដោយ គ.ជ.ប តាមរយៈ គឃ/ខប
- ប័ណ្ណមានបិទរូបថត និងបំពេញត្រឹមត្រូវតាមខ្លឹមសារក្នុងប័ណ្ណសម្គាល់
- ត្រូវបាន គឃ/ខប បោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោមនៃរូបថត ។

២.១៥៨.៧ ប្រធាន ឬតំណាងរបស់សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវចុះហត្ថលេខាធានា និងទទួលខុសត្រូវលើបញ្ជីឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួន ពិសេស គឺទទួលខុសត្រូវចំពោះមុខច្បាប់ អំពីអត្តសញ្ញាណរបស់អ្នកសង្កេតការណ៍ម្នាក់ៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។

២.១៥៨.៨ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល អាចស្នើសុំដាក់អ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេសសម្រាប់ថ្នាក់ដឹកនាំរបស់ខ្លួនបានយ៉ាងច្រើនដប់ (១០) នាក់ ក្នុងករណី សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ ដាក់អ្នកសង្កេតការណ៍របស់ខ្លួនចាប់ពីប្រាំ (៥) រាជធានី ខេត្តឡើងទៅ ។ ប័ណ្ណចល័តទូទាំងប្រទេសមានគំរូ និងពណ៌ផ្សេងគ្នាពីប័ណ្ណអ្នកសង្កេតការណ៍ជាតិ ។ ការដាក់ពាក្យសុំអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេស មាននីតិវិធីដូចគ្នានឹងការដាក់ពាក្យសុំអ្នកសង្កេតការណ៍ជាតិដែរ ។ អ្នកសង្កេតការណ៍ចល័តទូទាំងប្រទេសមានសិទ្ធិ និងភារកិច្ចដូចមាន ចែងក្នុងក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។

២.១៥៨.៩ អង្គការដែលបង្កើតដោយរាជរដ្ឋាភិបាល មិនអនុញ្ញាតឱ្យសង្កេតការណ៍បោះឆ្នោតឡើយ ។ សមាសភាពដូចមានចែងក្នុងចំណុច ២.១៥៦.៣ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍ជាតិ ដើម្បីសង្កេតមើលការបោះឆ្នោតឡើយ ។

២.១៥៨.១០ គឃ/ខប ត្រូវធ្វើរបាយការណ៍បូកសរុបចំនួនអ្នកសង្កេតការណ៍ជាតិ តាមដំណាក់កាលនីមួយៗ រួចផ្ញើមក គ.ជ.ប ។

**អ្នកសង្កេតការណ៍អន្តរជាតិ**

**ប្រការ ២.១៤៩** នៅពេលអញ្ជើញចូលមកដល់ព្រះរាជាណាចក្រកម្ពុជា អ្នកសង្កេតការណ៍អន្តរជាតិអាចទៅទំនាក់ទំនងនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬ គ.ជ.ប ដើម្បីទទួលព័ត៌មានផ្សេងៗ ។

២.១៤៩.១ អ្នកសង្កេតការណ៍អន្តរជាតិដូចមានចែងក្នុងប្រការ ២.១៤៩ ត្រូវដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍អន្តរជាតិនៅ គ.ជ.ប ក្នុងរយៈពេលចាប់តាំងពីថ្ងៃប្រកាសផ្សាយប្រតិទិនបោះឆ្នោត រហូតដល់បី (៣)ថ្ងៃមុន ថ្ងៃបោះឆ្នោត ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវផ្តល់ជូននូវគំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ និងប័ណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិ ដោយឥតគិតថ្លៃ ដើម្បីបំពេញ និងបិទរូបថត ។

២.១៤៩.២ គ.ជ.ប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះ និងប័ណ្ណសម្គាល់ ដែលបានបំពេញហើយ និងចេញសេចក្តីសម្រេចអនុញ្ញាតយល់ព្រមឱ្យអ្នកសង្កេតការណ៍អន្តរជាតិក្នុងរយៈពេលយ៉ាងយូរពីរ (២) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យសុំ ។

២.១៤៩.៣ ក្រោយពីពិនិត្យឃើញថា ពាក្យសុំចុះឈ្មោះរៀបចំពុំទាន់បានត្រឹមត្រូវ គ.ជ.ប ត្រូវណែនាំអ្នកសង្កេតការណ៍អន្តរជាតិនោះ ឱ្យបំពេញ ឬកែតម្រូវឡើងវិញភ្លាមៗ ដើម្បី គ.ជ.ប ចេញសេចក្តីសម្រេចអនុញ្ញាត ។

២.១៤៩.៤ ក្នុងករណីពិនិត្យឃើញថា ពាក្យសុំចុះឈ្មោះមានលក្ខណៈគ្រប់គ្រាន់ហើយ គ.ជ.ប ត្រូវជូនប័ណ្ណអ្នកសង្កេតការណ៍អន្តរជាតិឱ្យសាមីខ្លួន ឬតំណាង ដើម្បីសរសេរបំពេញ បិទរូបថត និងចុះហត្ថលេខាសាមីខ្លួន រួចហើយត្រូវជូនប័ណ្ណនោះមក គ.ជ.ប វិញ ។

២.១៤៩.៥ បន្ទាប់ពីទទួលប័ណ្ណដែលបានបំពេញត្រឹមត្រូវហើយ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាត ចុះហត្ថលេខា និងបោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោមនៃរូបថត ភ្ជាប់ទៅនឹងប័ណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិ រួចប្រគល់ជូនទៅអ្នកសង្កេតការណ៍នោះវិញ ដើម្បីពាក់ក្នុងពេលបំពេញការងារ ។

២.១៤៩.៦ អ្នកសង្កេតការណ៍អន្តរជាតិ ដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប មានសិទ្ធិសង្កេតមើលការបោះឆ្នោតទាំងមូល ឬតាមដំណាក់កាល និងគ្រប់ទីកន្លែងទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២.១៤៩.៧ អ្នកបកប្រែភាសារបស់អ្នកសង្កេតការណ៍អន្តរជាតិ ត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយនឹងពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ ដោយបញ្ជាក់ពីមុខងាររបស់ខ្លួនផង ។ អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសង្កេតការណ៍អន្តរជាតិឡើយ ។

**អ្នកយកព័ត៌មានជាតិ និងអន្តរជាតិ**

**ប្រការ** ២.១៥០ សមាគមវិជ្ជាជីវសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកយកព័ត៌មានឯករាជ ដែលមានបំណងចូលរួមយកព័ត៌មាន ក្នុងការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះដោយផ្ទាល់ទៅ គ.ជ.ប ។ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ មិនត្រូវបានផ្តល់បណ្ណអ្នកយកព័ត៌មាន ដែលចេញដោយ គ.ជ.ប និងមិនអនុញ្ញាតឱ្យចូលយកព័ត៌មានក្នុងការបោះឆ្នោតឡើយ ។

២.១៥០.១ ផ្នែកព័ត៌មានសាធារណៈនៃនាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈ គឺជាសេនាធិការរបស់ គ.ជ.ប ក្នុងការងារគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកយកព័ត៌មានជាតិ អន្តរជាតិ និងអ្នកយកព័ត៌មានឯករាជ ដែលចូលរួមក្នុងការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១៥០.២ គ.ជ.ប ត្រូវផ្តល់ពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មាន ដល់សមាគមវិជ្ជាជីវសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកយកព័ត៌មានឯករាជតាមការស្នើសុំ ដោយឥតគិតថ្លៃ ។

- រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មានជាតិ គឺចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិននៃការបោះឆ្នោតរហូតដល់ ដប់ (១០) ថ្ងៃមុនថ្ងៃបោះឆ្នោត ។
- រយៈពេលនៃការដាក់ពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មានអន្តរជាតិ គឺចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិននៃការបោះឆ្នោតរហូតដល់ បី (៣) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

២.១៥០.៣ ពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មានជាតិ និងអន្តរជាតិត្រូវភ្ជាប់ជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម ៖

២.១៥០.៣.១ សម្រាប់អ្នកយកព័ត៌មានជាតិ ត្រូវភ្ជាប់មកជាមួយនូវ ៖

- លិខិតអនុញ្ញាតចេញដោយក្រសួងព័ត៌មាន ។
- លិខិតបញ្ជាក់ ឬលិខិតស្នើសុំធ្វើប័ណ្ណព័ត៌មាន គ.ជ.ប ពីសាមីអង្គភាព ។
- ច្បាប់ចម្លង នៃប័ណ្ណព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមវិជ្ជាជីវៈ ឬប័ណ្ណសំគាល់ខ្លួនជាអ្នកយកព័ត៌មានរបស់សាមីអង្គភាព ។
- ប្រវត្តិរូបសង្ខេប ។

២.១៥០.៣.២ សម្រាប់អ្នកយកព័ត៌មានអន្តរជាតិ ដែលមានការិយាល័យអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់មកជាមួយនូវ ៖

- លិខិតអនុញ្ញាតចេញដោយក្រសួងព័ត៌មាន ។
- លិខិតបញ្ជាក់ ឬលិខិតស្នើសុំធ្វើប័ណ្ណព័ត៌មាន គ.ជ.ប ពីសាមីអង្គភាព ។
- ច្បាប់ចម្លង នៃប័ណ្ណព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមវិជ្ជាជីវៈ ឬប័ណ្ណសំគាល់ខ្លួនជាអ្នកយកព័ត៌មានរបស់សាមីអង្គភាព ។
- ប្រវត្តិរូបសង្ខេប ។
- ច្បាប់ចម្លងនៃលិខិតឆ្លងដែន (សំរាប់ជនបរទេស) ។

២.១៥០.៣.៣ សម្រាប់អ្នកយកព័ត៌មានអន្តរជាតិ ដែលពុំមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់ជាមួយនូវ ៖

- ច្បាប់ចម្លង នៃលិខិតឆ្លងដែន ។
- ប័ណ្ណសំគាល់ខ្លួនជាអ្នកយកព័ត៌មានរបស់សាមីអង្គភាព ។
- ប្រវត្តិរូបសង្ខេប ។

២.១៥០.៣.៤ សម្រាប់អ្នកយកព័ត៌មានឯករាជ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងនៃប័ណ្ណព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមវិជ្ជាជីវសារព័ត៌មាន ។
- ប្រវត្តិរូបសង្ខេប ។
- អត្ថបទចុងក្រោយ ដែលខ្លួនបានសរសេរចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់ក្នុងអំឡុងឆ្នាំចុងក្រោយចំនួន បី (៣) អត្ថបទ ។

២.១៥០.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះជាអ្នកយកព័ត៌មានក្នុងរយៈពេលប្រាំ (៥) ថ្ងៃយ៉ាងយូរ សម្រាប់អ្នកយកព័ត៌មានជាតិ ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកយកព័ត៌មានជាតិ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកយកព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀតក្នុងរយៈពេលបី (៣) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតបដិសេធ ។

២.១៥០.៥ គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះឈ្មោះអ្នកយកព័ត៌មានអន្តរជាតិក្នុងរយៈពេលពីរ (២) ថ្ងៃ យ៉ាងយូរ ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកយកព័ត៌មានអន្តរជាតិ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកយកព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀត ក្នុងរយៈពេលពីរ (២) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

២.១៥០.៦ គ.ជ.ប ត្រូវបោះពុម្ពប័ណ្ណសំគាល់អ្នកយកព័ត៌មានជាតិ និងប័ណ្ណសំគាល់អ្នកយកព័ត៌មានអន្តរជាតិ ដើម្បីផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នកយកព័ត៌មានដែលត្រូវបានអនុញ្ញាតឱ្យយកព័ត៌មានដោយ គ.ជ.ប ដើម្បីពាក់ក្នុងពេលបំពេញការងារ ។

២.១៥០.៧ អ្នកយកព័ត៌មានត្រូវគោរពច្បាប់ស្តីពីរបបសារព័ត៌មាន ច.ប.ក ប.ន.ក ក្រមសីលធម៌ និងវិជ្ជាជីវៈអ្នកសារព័ត៌មាន ។

២.១៥០.៨ អ្នកយកព័ត៌មានជាតិ និងអន្តរជាតិ ដែលបានទទួលការអនុញ្ញាតដោយ គ.ជ.ប អាចយកព័ត៌មានក្នុងដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់កាលនៃការបោះឆ្នោត ដោយត្រូវគោរព ច.ប.ក ប.ន.ក និងក្រមសីលធម៌ សម្រាប់អ្នកយកព័ត៌មាន ។

២.១៥០.៨.១ អ្នកយកព័ត៌មានជាតិ និងអន្តរជាតិ មានសិទ្ធិថត និងយកព័ត៌មានអំពី ៖

- សកម្មភាពនៃការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។
- ការប្រព្រឹត្ត និងសកម្មភាពរបស់មន្ត្រីបោះឆ្នោត ក្នុងដំណាក់កាលចុះឈ្មោះបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១៥០.៨.២ អ្នកយកព័ត៌មានជាតិ និងអន្តរជាតិមិនត្រូវ ៖

- ជ្រៀតជ្រែក ឬ រំខានដល់ការងារចុះឈ្មោះបោះឆ្នោត ឬ/និង ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- ធ្វើសម្ភាសន៍នៅក្នុងការិយាល័យបោះឆ្នោត ឬការិយាល័យ រាប់សន្លឹកឆ្នោត ។
- ធ្វើសម្ភាសន៍ជាមួយអ្នកបោះឆ្នោត ដែលកំពុងឋិតនៅក្នុងជួរ ចូលទៅក្នុងការិយាល័យបោះឆ្នោត ។
- ធ្វើឱ្យរំខានដល់ការងារក្នុងការិយាល័យ ធ្វើឱ្យប៉ះពាល់ដល់ការសម្ងាត់នៃការបោះឆ្នោត និងប៉ះពាល់ដល់សិទ្ធិបុគ្គល ។

២.១៥០.៨.៣ ការយកព័ត៌មាន ដោយរូបភាពក្នុងការិយាល័យបោះឆ្នោត ឬ រាប់សន្លឹកឆ្នោត ត្រូវសុំការអនុញ្ញាតពីប្រធានការិយាល័យនោះ ។ ការថតរូបភាពនេះ មិនត្រូវឱ្យប៉ះពាល់ដល់ការសម្ងាត់នៃការបោះឆ្នោតឡើយ ។

២.១៥០.៨.៤ អ្នកយកព័ត៌មាន មិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើសមាជិក គធ/ខប ឬសមាជិក គកប ឬអ្នកសង្កេតការណ៍ ឬបេក្ខជន ឬតំណាងគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោតឡើយ ។

# ជំពូកទី ៣
## អំពីថវិកា

**ប្រការ ៣.១** ថវិកានៃគណនីពិសេសនៅរតនាគារ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាដែលប្រើប្រាស់ដោយ គ.ជ.ប ត្រូវបើកនៅរតនាគារជាតិ ។

៣.១.១ តាមច្បាប់ស្តីពីគណនីពិសេសនៃ គ.ជ.ប រាជរដ្ឋាភិបាលត្រូវដាក់ថវិការួមចំណែករបស់ខ្លួនក្នុងគណនីពិសេសនេះ ។

៣.១.២ ថវិកានៃគណនីពិសេសនឹងបានមកពីមូលនិធិទាយជ្ជទានដែលបានមកពីវិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល ជំនួយរបស់រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការមិនមែនរដ្ឋាភិបាល និងចំណូលស្របច្បាប់ផ្សេងៗទៀត ។

**ប្រការ ៣.២** គ.ជ.ប ត្រូវបើកគណនីនៅធនាគារមួយ ឬច្រើនតាមតម្រូវការជាក់ស្តែង ឬរតនាគារខេត្ត ក្រុង និងផ្ទេរប្រាក់ចូលក្នុងគណនីនេះតាមចំនួនថវិកា ដែលត្រូវការចាំបាច់សម្រាប់ចំណាយលើការងារបោះឆ្នោត ។

**ប្រការ ៣.៣** គ.ជ.ប ត្រូវកំណត់បរិបថក្នុងការចំណាយថវិកា ដូចបានបញ្ជាក់ក្នុងប្រការ ៣.១ មានដូចខាងក្រោម ៖

៣.៣.១ ការប្រើប្រាស់មូលប្បទានប័ត្រសម្រាប់ការចំណាយរបស់ខ្លួន ៖

៣.៣.១.១ នៅលើមូលប្បទានប័ត្រត្រូវមានហត្ថលេខាចំនួនពីរដែលក្នុងនោះត្រូវតែមានហត្ថលេខាមួយរបស់ប្រធាន គ.ជ.ប ។

៣.៣.១.២ ក្នុងករណីប្រធាន គ.ជ.ប អវត្តមាន អនុប្រធានអាចចុះហត្ថលេខាជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន គ.ជ.ប ។

៣.៣.១.៣ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុត្រូវបានផ្តល់សិទ្ធិអំណាច ក្នុងការចុះហត្ថលេខាលើមូលប្បទានប័ត្ររបស់ គ.ជ.ប ។

៣.៣.១.៤ ក្នុងករណីដែលប្រធាននាយកដ្ឋានហិរញ្ញវត្ថុមិនអាចបំពេញការងារបាន អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុអាចចុះហត្ថលេខាជំនួស ប្រសិនបើគាត់ត្រូវបានប្រគល់សិទ្ធិអំណាចឱ្យដោយ គ.ជ.ប ។

៣.៣.២ រាល់ការចំណាយ ត្រូវតែមានការយល់ព្រមពីនាយកដ្ឋានហិរញ្ញវត្ថុមុនពេលដំណើរការទូទាត់ ។

៣.៣.២.១ រាល់សក្ខីប័ត្រចំណាយទាំងអស់ ត្រូវតែបានផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ។

៣.៣.២.២ សក្ខីប័ត្រត្រឹមត្រូវរួមមាន ៖ គំរោងសំណើសុំ ឯកសារបញ្ជាទិញ ឯកសារស្ទាបស្ទង់តម្លៃ លិខិតប្រគល់ ទទួល និងវិក័យប័ត្រ ។

៣.៣.២.៣ លិខិតបញ្ជាបេសកកម្មត្រូវមានចុះទិដ្ឋាការច្បាស់លាស់ ហើយមានវិក័យប័ត្រលើមធ្យោបាយធ្វើដំណើរ ស្នាក់នៅ ។

៣.៣.២.៤ ការទូទាត់ប្រាក់កំរៃដែល គ.ជ.ប ជាអ្នកកំណត់ ត្រូវមានពាក្យសុំចូលបំរើការងារ កិច្ចសន្យា សេចក្តីសម្រេចកំណត់ប្រាក់កំរៃ តារាងប្រាក់កំរៃ តារាងប្រៀបធៀប ប្រាក់កំរៃដែលមានចុះហត្ថលេខាដោយ គ.ជ.ប និងមានចុះហត្ថលេខានៃអ្នកដែលត្រូវបានទទួលប្រាក់កំរៃ ។

៣.៣.៣ រាល់ការចំណាយដោយផ្ទាល់ ត្រូវមាន ៖

- សំណើសុំទូទាត់
- កំណត់ហេតុប្រគល់ ទទួល
- កំណត់ហេតុដេញថ្លៃ ឬពិគ្រោះថ្លៃ
- ប័ណ្ណបញ្ចេញ និងប័ណ្ណបញ្ចូលទំនិញ សម្ភារ
- កិច្ចសន្យា
- ប័ណ្ណប៉ាតង់
- ដីកាអមលិខិតយុត្តិការ
- ដីកាអមបញ្ចេញអាណត្តិបើកប្រាក់
- សលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ
- អាណត្តិបើកប្រាក់ ។

៣.៣.៤ រាល់ការចំណាយដែលផ្ទុយពីចំណុច ៣.៣.១ ៣.៣.២ និង ៣.៣.៣ ត្រូវតែមានឯកសារដទៃទៀត ដូចជាលិខិតអនុញ្ញាតឱ្យចំណាយពី គ.ជ.ប សំណៅមូលប្បទានប័ត្រ ឯកសារមួយចំនួន ដែលតម្រូវឱ្យធ្វើការទូទាត់តាមការកំណត់ដោយនីតិវិធីហិរញ្ញវត្ថុ ឬអនុក្រឹត្យ ។

**ប្រការ ៣.៤** គ.ជ.ប ត្រូវកំណត់យកប្រព័ន្ធគណនេយ្យមួយសមស្របសម្រាប់ធ្វើការណែនាំដល់គណៈកម្មការរាជធានី និងខេត្តរៀបចំការបោះឆ្នោត ឱ្យអនុវត្តការងារចុះបញ្ជីការគណនេយ្យមានការឯកភាពគ្នា និងងាយស្រួលក្នុងការទូទាត់ ។ គំរូលិខិតស្នាម ឯកសារ បទដ្ឋាននានា ត្រូវកំណត់ឱ្យបានច្បាស់លាស់ មានការឯកភាពគ្នាតាមការកំណត់ពី គ.ជ.ប និងការណែនាំពីនាយកដ្ឋានហិរញ្ញវត្ថុ ដោយអនុលោមតាមច្បាប់ និងនីតិវិធីហិរញ្ញវត្ថុ ឬអនុក្រឹត្យ ។

**ប្រការ ៣.៥** គ.ជ.ប ត្រូវកំណត់បរិបថការងារក្នុងការទិញ ការផ្គត់ផ្គង់ ការបែងចែកសម្ភារ ទំនិញ និងសេវាកម្មផ្សេងៗ ។

៣.៥.១ ក្នុងការត្រួតពិនិត្យការទិញ ការផ្គត់ផ្គង់ ការបែងចែកសម្ភារ ទំនិញ និងសេវាកម្មផ្សេងៗ ត្រូវធ្វើឡើងដោយសេវាកម្មពីរ (២) ដាច់ពីគ្នា ។

៣.៥.២ សម្រាប់គោលបំណងនៃចំណុច ៣.៥.១ គណៈកម្មការត្រួតពិនិត្យការទិញសម្ភារបរិក្ខាររួមមាន ៖

១. នាយកដ្ឋាន ហិរញ្ញវត្ថុ

២. នាយកដ្ឋាន រដ្ឋបាល

៣. នាយកដ្ឋាន ពាក់ព័ន្ធ

នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវក្នុងការរៀបចំដាក់ឱ្យដេញថ្លៃ ឬពិគ្រោះថ្លៃសមស្របតាមនីតិវិធីហិរញ្ញវត្ថុ ឯនាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធទទួលខុសត្រូវក្នុងការត្រួតពិនិត្យ អំពីបរិមាណ និងគុណភាពទំនិញ សម្ភារបរិក្ខារ និងសេវាកម្មផ្សេងៗ រួចហើយធ្វើការកត់ត្រាបញ្ចូលឃ្លាំង និងធ្វើការបែងចែក ។

៣.៥.៣ ទំនិញ សម្ភារបរិក្ខារមួយចំនួន ជាចលនវត្ថុ និងអចលនវត្ថុ ទាំងនៅក្នុង ឬក្រៅសន្និធិត្រូវកត់ត្រាឱ្យបានច្បាស់លាស់ បញ្ចូលក្នុងបញ្ជីសារពើភ័ណ្ឌ ដែលជាការទទួលខុសត្រូវរបស់នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានពាក់ព័ន្ធ ។

**ប្រការ ៣.៦** នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវធានាថា របាយការណ៍ហិរញ្ញវត្ថុប្រចាំខែត្រូវបានបំពេញមិនឱ្យយឺតជាងសប្តាហ៍ទីបី (៣) នៃខែបន្ទាប់ ។

**ប្រការ ៣.៧** ឆ្នាំសារពើពន្ធនៃ គ.ជ.ប ត្រូវគិតចាប់ពីថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ ។

**ប្រការ ៣.៨** នៅដំណាច់ឆ្នាំសារពើពន្ធ នាយកដ្ឋានហិរញ្ញវត្ថុត្រូវធានារៀបចំ និងត្រួតពិនិត្យឱ្យបាននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានអនុវត្តមិនយឺតជាងបី (៣) ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ ។

៣.៨.១ គ.ជ.ប ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមួយច្បាប់ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣.៨.២ គ.ជ.ប ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីចំណូល និងកម្មវិធីចំណាយ មួយ (១) ច្បាប់ជូនរដ្ឋសភា មួយ (១) ច្បាប់ជូនព្រឹទ្ធសភា និងមួយ (១) ច្បាប់ទៀតជូនទៅរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនឱ្យហួសពីបី (៣) ខែ បន្ទាប់ពីប្រតិបត្តិការបោះឆ្នោតត្រូវបានបញ្ចប់ជាស្ថាពរ ។

# ឧបសម្ព័ន្ធទី ១

## នីតិវិធី

## ស្តីពី

## ការដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

**ប្រការ ១ :** គណបក្សនយោបាយដែលទទួលបានអាសនៈក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហើយបេក្ខជនពេញសិទ្ធិ និងបម្រុងផ្លូវការរបស់ខ្លួនមានចំនួនមិនគ្រប់គ្រាន់សម្រាប់បំពេញអាសនៈរបស់ខ្លួន ដែលនៅទំនេរ ដោយមូលហេតុទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពសមាជិកក្រុមប្រឹក្សា ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួងមហាផ្ទៃជាបន្ទាន់ ដើម្បីក្រសួងមហាផ្ទៃជូនដំណឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីចាត់ចែងតាមច្បាប់ បទបញ្ជា និងនីតិវិធី ។

**ប្រការ ២ :** នៅពេលដែលបានទទួលសេចក្តីជូនដំណឹងពីក្រសួងមហាផ្ទៃ គ.ជ.ប ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនយោបាយនោះ ឱ្យមកដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយនៅ គ.ជ.ប ក្នុងរយៈពេលដប់បួន (១៤) ថ្ងៃ ក្រោយពីបានទទួលសំណើ ។ ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាកំណត់នេះទេ ឬមិនបានកែលម្អការខ្វះខាត ដែលធ្វើឱ្យគណបក្សនយោបាយនោះ មិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះ បោះបង់ចោលអាសនៈឱ្យនៅទំនេរ ហើយ គ.ជ.ប នឹងចាត់ចែងអនុវត្តតាមមាត្រា ១៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

**ប្រការ ៣ :** ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយសម្រាប់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ទម្រង់បែបបទលេខ ១០០៤ប) ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ ។ ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម ត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ (ត្រូវភ្ជាប់លិខិតផ្ទេរសិទ្ធិនេះមកជាមួយ) ។

គណបក្សនយោបាយ ត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមចំនួនពីរ (២) ច្បាប់ តាមប្រភេទក្រុមប្រឹក្សានីមួយៗ តាមបែបបទកំណត់ដោយ គ.ជ.ប ដោយភ្ជាប់ជាមួយនូវ ៖

- បញ្ជីរាយនាមបេក្ខជន ចំនួនបួន (៤) ច្បាប់ ដែលមានចំនួនបេក្ខជនបម្រុងបន្ថែម យ៉ាងតិចស្មើនឹងមួយដងនៃចំនួនសមាជិកក្រុមប្រឹក្សារាជធានី ឬក្រុមប្រឹក្សាខេត្ត ឬក្រុមប្រឹក្សាក្រុង ឬក្រុមប្រឹក្សាស្រុក ឬក្រុមប្រឹក្សាខណ្ឌ (ដោយរាប់បញ្ចូលទាំងចំនួនបេក្ខជនដែលនៅសល់) ។
- សេចក្តីបញ្ជាក់អំពីការចុះឈ្មោះបោះឆ្នោតដោយអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត ចំនួនមួយ (១) ច្បាប់ សម្រាប់បេក្ខជនបម្រុងបន្ថែមម្នាក់ៗ ។
- សេចក្តីប្រកាសរបស់បេក្ខជនយល់ព្រមតាមការតែងតាំងជាបេក្ខជនរបស់គណបក្សចំនួនមួយ (១) ច្បាប់ សម្រាប់បេក្ខជនបម្រុងបន្ថែមម្នាក់ៗ ។

**ប្រការ ៤ :** ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុយ៉ាងតិចម្ភៃប្រាំ (២៥) ឆ្នាំ គិតមកទល់ថ្ងៃដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម
- មានសិទ្ធិបោះឆ្នោត និងលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយ ច.ប.ក ។

**ប្រការ ៥ :** ជនគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ ៖

- សមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាល និងចៅក្រម
- អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោត និងមន្ត្រី បុគ្គលិកបម្រើការងាររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិក្នុងមុខតំណែង
- មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់
- ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត
- ព្រះសង្ឃ ឬបព្វជិតសាសនា ។

**ប្រការ ៦ :** គ.ជ.ប ត្រូវពិនិត្យ និងសម្រេចពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ ។

ក. ក្នុងករណីគណបក្សនយោបាយ បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចចែងក្នុងប្រការ ២ ប្រការ ៣ និងប្រការ ៤ ខាងលើ គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនបម្រុងបន្ថែមជូនសាមីគណបក្សនយោបាយ ដោយភ្ជាប់មកជាមួយនូវបញ្ជីបេក្ខជនបម្រុងបន្ថែមផ្លូវការមួយ (១) ច្បាប់ ។ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជនបម្រុងបន្ថែមនៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

ខ. ក្នុងករណីគណបក្សនយោបាយ ពុំបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ ដូចចែងក្នុងប្រការ ២ ប្រការ ៣ និងប្រការ ៤ ខាងលើ គ.ជ.ប ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងណែនាំដល់គណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនោះ ឱ្យធ្វើការកែតម្រូវចំណុចដែលខ្វះខាតឱ្យបានត្រឹមត្រូវ ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ។

- ក្នុងករណីគណបក្សនយោបាយបានកែតម្រូវចំណុចខ្វះខាតបានត្រឹមត្រូវ និងទាន់ពេលវេលាហើយ គ.ជ.ប ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម ដូចចែងក្នុងចំណុច ក ប្រការ ៦ ក្នុងរយៈពេលមួយ (១) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ ។
- ក្នុងករណីគណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជនបម្រុងបន្ថែមមិនបានកែតម្រូវចំណុចខ្វះខាតតាមលក្ខខណ្ឌ និងពេលវេលាដូចចែងក្នុងចំណុច ខ ប្រការ ៦ គ.ជ.ប ត្រូវបដិសេធបេក្ខភាពបម្រុងបន្ថែមណាដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់នោះតែប៉ុណ្ណោះ ។ សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយ ។

**ប្រការ ៧ :** គ.ជ.ប ត្រូវរៀបចំបញ្ជីរាយនាមបេក្ខជនបម្រុងបន្ថែមចំនួនបួន (៤) ច្បាប់ ដើម្បីប្រើប្រាស់មួយ (១) ច្បាប់ ជូនសាមីគណបក្សនយោបាយមួយ (១) ច្បាប់ ផ្ញើជូន លធ/ខប ពាក់ព័ន្ធមួយ (១) ច្បាប់ ផ្ញើជូនក្រសួងមហាផ្ទៃ និងមួយ (១) ច្បាប់ រក្សាទុកជាឯកសារនៅ គ.ជ.ប ។

**ប្រការ ៨ :** គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់ជាមួយនូវសេចក្ដីសម្រេចរបស់ គ.ជ.ប ដើម្បីក្រសួងមហាផ្ទៃបន្តចាត់ចែងតាមនីតិវិធី ។

**ប្រការ ៩ :** គណបក្សនយោបាយ ដែលទទួលបានអាសនៈក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហើយបេក្ខជនពេញសិទ្ធិ និងបម្រុងផ្លូវការរបស់ខ្លួន ត្រូវបានរំកិលលេខរៀងអស់ ឬនៅសល់បេក្ខជនបម្រុងពីរ (២) ឬបី (៣) នាក់ ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួងមហាផ្ទៃជាបន្ទាន់ ដើម្បីក្រសួងមហាផ្ទៃជូនដំណឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដើម្បីចាត់ចែងតាមច្បាប់ បទបញ្ជា និងនីតិវិធី ។

**ប្រការ ១០ :** នៅពេលដែលបានទទួលសំណើពីក្រសួងមហាផ្ទៃ គ.ជ.ប ត្រូវជូនដំណឹងដល់គណបក្សនយោបាយសាមីឱ្យមកដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ ។ នីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម នៃគណបក្សនយោបាយសម្រាប់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្នុងប្រការ ៩ ត្រូវអនុវត្តតាមប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ៦ ប្រការ ៧ និង ប្រការ ៨ ខាងលើ ។

# ឧបសម្ព័ន្ធទី ២

# ក្រមសីលធម៌

## សម្រាប់គណបក្សនយោបាយ បេក្ខជន និង តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ

## I. សេចក្តីផ្តើម

ប្រទេសដែលមាននិន្នាការប្រកាន់លទ្ធិប្រជាធិបតេយ្យបច្ចុប្បន្ន តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតទាំងឡាយ ប្រព្រឹត្តទៅដោយ សេរី ត្រឹមត្រូវ យុត្តិធម៌ និងស្របទៅតាមលទ្ធិប្រជាធិតេយ្យពិតប្រាកដ ។ ដើម្បីសម្រេចនូវគោលដៅដ៏ធំធេងនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ អាជ្ញាធរបោះឆ្នោតគ្រប់ថ្នាក់ អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ អ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអន្តរជាតិ ត្រូវតែរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីបោះឆ្នោត លិខិតបទដ្ឋានពាក់ព័ន្ធនានា និងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន ។

ក្រមសីលធម៌នេះ រៀបចំតាក់តែងឡើងស្របទៅនឹងច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានពាក់ព័ន្ធនានា ។ ការប្រតិបត្តិតាមក្រមសីលធម៌ ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោតតាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលស្ថាពរមានដំណើរប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព ។ ការប្រតិបត្តិក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់អាជ្ញាធរបោះឆ្នោតគ្រប់ថ្នាក់ អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងគណបក្សនយោបាយ ជាដៃគូប្រកួតប្រជែង មានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នាក្នុងការសហការបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន ។ ការគោរពក្រមសីលធម៌បោះឆ្នោតបានល្អ ជាកត្តាកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែកចំពោះអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម ។ ការគោរពក្រមសីលធម៌បានល្អ ជាកត្តាលើកស្ទួយកិត្យានុភាពជាតិ លើឆាកអន្តរជាតិខាងវិស័យបោះឆ្នោត ដើម្បីបង្ហាញឱ្យគេមើលឃើញពីការគោរពច្បាប់ឯកភាពជាតិ ការទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងស្ថាប័នទាំងអស់ក្នុងសង្គម ។

## II. គោលបំណងនៃក្រមសីលធម៌

គោលបំណងនៃក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ គឺដើម្បីឱ្យ ៖

- ការបោះឆ្នោតប្រព្រឹត្តទៅស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងបទប្បញ្ញត្តិផ្សេងៗ ។
- ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ។

## III. សិទ្ធិ និងភារកិច្ចរបស់គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ

គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិពេញលេញ និងស្មើភាពចូលរួមក្នុងការបោះឆ្នោតដូចជា សិទ្ធិចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត សិទ្ធិឃោសនាបោះឆ្នោត សិទ្ធិសង្កេតមើលដំណើរការបោះឆ្នោត សិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់ និងសិទ្ធិទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ។

បេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មេភូមិ អនុប្រធានភូមិ ជំនួយការភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយសង្កេតការណ៍បោះឆ្នោតឡើយ ។

### ក. សិទ្ធិ និងភារកិច្ចរបស់គណបក្សនយោបាយ និងបេក្ខជន

គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត មានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ៖

១. គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ មានសិទ្ធិស្នើសុំចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ។

២. គណបក្សនយោបាយមានសិទ្ធិ ៖

- ប្ដឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ពីការសម្រេចបដិសេធមិនយល់ព្រមចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជ្រើសតាំងសមាជិកព្រឹទ្ធសភា ។
- ប្ដឹងតវ៉ាទៅ គ.ជ.ប ពីការសម្រេចមិនយល់ព្រមចុះបញ្ជីគណបក្សនយោបាយបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ប្ដឹងតវ៉ាទៅ គ.ជ.ប ពីការសម្រេចមិនយល់ព្រមចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់ គធ/ខប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

៣. គណបក្សនយោបាយ បេក្ខជន មានសិទ្ធិសុំជួលមណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ទៅអ្នកគ្រប់គ្រង ដើម្បីប្រើប្រាស់សម្រាប់បម្រើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយ ។

៤. គណបក្សនយោបាយ បេក្ខជន មានសិទ្ធិធ្វើសកម្មភាពឃោសនានៅលើទីធ្លាឯកជន ឬសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងទៅអាជ្ញាធររៀបចំការបោះឆ្នោតពាក់ព័ន្ធ ។

៥. ការឃោសនាបោះឆ្នោត មានទិសដៅឱ្យគណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយនូវកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោតតែប៉ុណ្ណោះ ។
៦. ក្នុងការឃោសនា ការរិះគន់គណបក្សនយោបាយដទៃ ត្រូវផ្តោតបញ្ជាំងតែទៅលើគោលនយោបាយ កម្មវិធីនយោបាយ និងបទពិសោធន៍ការងារ ។ ត្រូវចៀសវាងដាច់ខាតចំពោះការរិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ ។
៧. រាល់សេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តប័ណ្ណ រូបភាពបិទផ្សាយទាំងឡាយ និងសម្ភារៈឃោសនាផ្សេងទៀត ត្រូវចៀសវាងដាច់ខាតការប្រើភាសា ឬរូបភាពរំលោភ បំពានខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សា ។ល។
៨. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវទទួលខុសត្រូវផ្ទាល់លើខ្លឹមសារ និងសកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន ។
៩. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរដែនដី អ្នកសង្កេត ការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ។
១០. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវយកចិត្តទុកដាក់គោរពឱ្យបានល្អនូវរាល់កម្មវិធីឃោសនាទាំងអស់ ដែលសម្របសម្រួលដោយអាជ្ញាធរដែនដី ។
១១. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ មានសិទ្ធិធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយសេរី ក្នុងទីស្នាក់ការគណបក្សនយោបាយរបស់ខ្លួនទូទាំងប្រទេស ។
១២. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅតាមបទបញ្ញា និងនីតិវិធី គ.ជ.ប ប្រសិនបើពិនិត្យឃើញ និងមានភ័ស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ញា និងនីតិវិធី គ.ជ.ប ក្នុងដំណើរការរៀបចំការបោះឆ្នោត ។
១៣. គណបក្សនយោបាយ និងបេក្ខជនទាំងអស់ មានសិទ្ធិស្មើភាពគ្នាក្នុងការការពារសន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានា ក្នុងដំណើរការបោះឆ្នោតទាំងមូល ។

### ខ. សិទ្ធិ និងភារកិច្ចរបស់តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ

ក្នុងការសង្កេតមើលដំណើរការនៃការបោះឆ្នោត តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ៖

១. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិមានវត្តមាន នៅតាមទីកន្លែងចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលខ្លួនបានទទួលការអនុញ្ញាតតាមទីកន្លែង និងពេលវេលា ដែលបានកំណត់ដោយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានតែម្នាក់ប៉ុណ្ណោះ ។ តំណាង ឬ/និងភ្នាក់ងារបម្រុង នៃគណបក្សនយោបាយត្រូវរង់ចាំនៅក្រៅការិយាល័យ ដើម្បីជំនួសតំណាង ឬ/និងភ្នាក់ងារពេញសិទ្ធិក្នុងករណីមានការផ្លាស់ប្តូរ ។

៣. គណបក្សនយោបាយមានសិទ្ធិសុំផ្លាស់ប្តូរតំណាង ឬ/និងភ្នាក់ងារពេញសិទ្ធិ និងតំណាង ឬ/និងភ្នាក់ងារបម្រុង របស់ខ្លួនទៅតាមមូលហេតុសមស្រប និងទៅតាមកាលកំណត់ចុងក្រោយរបស់ គ.ជ.ប ។

៤. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិជំទាស់រាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធី ដែលខ្លួនបានឃើញផ្ទាល់ ។ ការជំទាស់ត្រូវធ្វើឡើងទៅប្រធាន គកប។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់អាចលើកឡើងដោយផ្ទាល់មាត់ ឬ/និងទៅតាមទម្រង់បែបបទរបស់ គ.ជ.ប ។

៥. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗដែលកំណត់ដោយ គ.ជ.ប ។

៦. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ ដែលចូលរួមសង្កេតការណ៍បោះឆ្នោតអាចចុះហត្ថលេខា ឬផ្តិតមេដៃ នៅលើកំណត់ហេតុបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ថ្នាក់ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ។

៨. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅតាមបទបញ្ជា និងនីតិវិធី របស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញថា មានភ័ស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការរៀបចំការបោះឆ្នោត ។

៩. តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើភាពគ្នា ក្នុងការទទួលបានការការពារ សន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានា ក្នុងដំណើរការបោះឆ្នោតទាំងមូល ។

### IV. បម្រាមចំពោះគណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ

ក្នុងពេលបំពេញការងារ គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវអនុវត្តដូចខាងក្រោម ៖

១. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវប្រើកម្លាំង អំពើហិង្សា ឬបំភិតបំភ័យដល់អ្នកបោះឆ្នោត ។

២. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវញុះញង់ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។

៣. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំគេឱ្យធ្វើសម្បថបោះឆ្នោតឱ្យគណបក្សនយោបាយខ្លួនឡើយ ។

៤. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវប្រើកម្លាំង ឬអំពើហិង្សាណាមួយ ដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។

៥. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវរារាំងបេក្ខជន និង អ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប ។

៦. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវប្រើកម្លាំង អំពើហិង្សា បំភិតបំភ័យ ឬប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាចការភាន់ច្រឡំធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

៧. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវបង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន ។

៨. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវបង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត ។

៩. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។

១០. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវទិញសន្លឹកឆ្នោត ដោយសម្ភារៈ ឬដោយប្រាក់កាស ។

១១. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវបង្ខាច់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។

១២. បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវធ្វើឱ្យបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាព ហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

១៣. គណបក្សនយោបាយ និងបេក្ខជន ត្រូវគោរពគោលការណ៍ឃោសនាបោះឆ្នោត ដែលមានរយៈពេលដូចមានចែងក្នុងច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី គ.ជ.ប ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោត ត្រូវបញ្ឈប់ម្ភៃបួន (២៤)ម៉ោងមុនថ្ងៃបោះឆ្នោត ។ គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយ និងបេក្ខជន ត្រូវឈប់សម្រាកចន្លោះពីម៉ោងដប់ (១០)យប់ ដល់ម៉ោងប្រាំមួយ (៦)ព្រឹក ។ សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវហាមឃាត់ចាប់ពីម៉ោងដប់ពីរ (១២)ថ្ងៃត្រង់ ដល់ម៉ោងពីរ (២)រសៀល ។

១៤. ក្នុងពេលឃោសនាបោះឆ្នោតគ្រប់គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ សមាជិក និងអ្នកគាំទ្រទាំងអស់ ត្រូវគោរពបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី គ.ជ.ប ក្រមសីលធម៌គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

១៥. ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គ្រប់គណបក្សនយោបាយ បេក្ខជន មិនត្រូវប្រើអំពើហិង្សា អំពើរំលោភ ប្រើពាក្យសម្តីប្រមាថមើលងាយ មិនត្រូវធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់ បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

១៦. គណបក្សនយោបាយ និងបេក្ខជន មិនត្រូវទាមទារ ឬចូលទៅក្នុងការិយាល័យ ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតបន្ថែមលើតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ ដែលបានអនុញ្ញាតជាផ្លូវការរួចហើយនោះទេ ។

១៧. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីចុះឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោតឡើយ ។

១៨. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវជ្រៀតជ្រែកដល់ដំណើរការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោតឡើយ ។

១៩. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយទាំងអស់មិនត្រូវរិះគន់ ឬរើសអើងប្រកាន់បក្សពួក ជាតិសាសន៍ ភេទ ឋានៈក្នុងសង្គម សាសនា និងតាម គ្រប់រូបភាពទាំងអស់ ។

២០. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវ ៖

- រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាជនមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្ស ឬបេក្ខជនដទៃទៀតឡើយ ។
- ប្រើប្រាស់នូវភាសា ពាក្យសំដីដែលស្តែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ បំភិតបំភ័យណាមួយឡើយ ។
- យល់ព្រមឱ្យដាក់តាំង ឬបង្ហាញ ឬចែកចាយការពិពណ៌នាអំពីការវាយប្រហារ ឬអាវុធនោះឡើយ ។

២១. គណបក្សនយោបាយ បេក្ខជន មិនត្រូវចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសំឡេងតាមផ្លូវសាធារណៈណាមួយ ដែលមានសំឡេងខ្លាំងៗ លុបលើសំឡេងឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀតឡើយ ។

២២. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកគាំទ្រ មិនត្រូវប្រើប្រាស់ព្រះឆាយាល័ក្ខណ៍ ឬព្រះនាមព្រះមហាក្សត្រ ឬព្រះនាមព្រះមហាវីរក្សត្រ ឬស្លាកសញ្ញា គ.ជ.ប ដើម្បីឃោសនារកសំឡេងឆ្នោតឡើយ ។

២៣. គណបក្សនយោបាយ បេក្ខជន មិនត្រូវចម្លងយកសញ្ញាសម្គាល់ របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន ។

២៤. គណបក្សនយោបាយ បេក្ខជន មិនត្រូវបិទប័ណ្ណ ខិត្តប័ណ្ណ រូបភាពឃោសនា សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសារឃោសនាដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃឡើយ ។

២៥. គណបក្សនយោបាយ បេក្ខជន តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកគាំទ្រទាំងអស់មិនត្រូវបក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវប័ណ្ណបិទផ្សាយ ខិត្តប័ណ្ណ សេចក្តីប្រកាសនយោបាយ ឬឯកសារឃោសនា ឬសេចក្តីណែនាំផ្សេងៗ របស់គណបក្សនយោបាយដទៃ ស្ថាប័ននានា ឬអាជ្ញាធរដែនដីឡើយ ។

២៦. គណបក្សនយោបាយ បេក្ខជន មិនត្រូវបិទប័ណ្ណផ្សព្វផ្សាយរូបភាពឃោសនា សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសារឃោសនាដទៃទៀត ក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោតក្នុងចម្ងាយតិចជាង ១០០ម៉ែត្រ និងមិនត្រូវចងបដា ឬរូបសញ្ញាឃោសនាណាមួយឆ្លងកាត់ផ្លូវសាធារណៈឡើយ ។

២៧. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬរដ្ឋ ន.ប ខ.ម និងរាជរដ្ឋាភិបាល ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។ ការប្រើប្រាស់យានយន្តក្នុងពេលឃោសនាបោះឆ្នោត ត្រូវយកចិត្តទុកដាក់គោរពតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

២៨. គណបក្សនយោបាយ បេក្ខជន មិនត្រូវទិញសន្លឹកឆ្នោត ផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារៈ ដើម្បីទទួលបានសំឡេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយក្នុងអំឡុងពេលឃោសនាបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត ។

២៩. គណបក្សនយោបាយ បេក្ខជន តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកគាំទ្រទាំងអស់មិនត្រូវប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទម្លាប់ ដើម្បីបង្ខំ ឬគំរាមកំហែង ក្នុងគោលបំណងទទួលបានការគាំទ្រ ។

៣០. គណបក្សនយោបាយ បេក្ខជន តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកគាំទ្រទាំងអស់ មិនត្រូវក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោតឡើយ ។
៣១. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរស័ព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។
៣២. គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវនៅក្បែរបន្ទប់សម្ងាត់ សម្រាប់គូសសន្លឹកឆ្នោត ។

## V. ទោសប្បញ្ញត្តិសម្រាប់តំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ

ដោយពុំទាន់គិតដល់ទោសប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់បោះឆ្នោត ប្រធានការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតមានសិទ្ធិបណ្តេញចេញពីការិយាល័យចំពោះតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយណាដែលមានចេតនារារាំង ឬបង្កឧបសគ្គដល់ការបំពេញភារកិច្ចរៀបចំការបោះឆ្នោត ។

កប/ឃស ឬ លធ/ខប ឬ គធ/ខប ឬ គឃ/សប និង គកប/គករ មានសិទ្ធិបដិសេធលើលិខិតអនុញ្ញាតចំពោះតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយណាម្នាក់ ឬច្រើននាក់ ក្នុងករណីដែលតំណាងនោះ ៖

- មិនគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។
- បង្កឱ្យមានឧបសគ្គ ឬរំខានដល់ដំណើរការរៀបចំការបោះឆ្នោត ឬមន្ត្រីបោះឆ្នោតក្នុងការបំពេញការងារ ។
- មិនអនុវត្ត ឬរំលោភក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយ ។

# ឧបសម្ព័ន្ធទី ៣
# ក្រមសីលធម៌
## សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត

## I. សេចក្តីផ្តើម

ក្នុងគោលបំណងធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព និងត្រូវបានគ្រប់មជ្ឈដ្ឋានទាំងអស់ទទួលស្គាល់ អ្នកសង្កេតការណ៍ត្រូវមានជំហរអព្យាក្រឹត មិនលំអៀង មិនប្រកាន់បក្សពួក និងមិនជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានអនុម័តក្រមសីលធម៌នេះសម្រាប់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដើម្បីអនុវត្តក្នុងការសង្កេតមើលដំណើរការបោះឆ្នោតក្នុងព្រះរាជាណាចក្រកម្ពុជា ។

## II. ការបកស្រាយ

១. ពាក្យ " **ការបោះឆ្នោត** " និង " **ដំណើរការបោះឆ្នោត** " មានន័យរួមបញ្ចូលទាំងការចុះឈ្មោះបោះឆ្នោត កុំព្យូទ័រកម្មបញ្ជីបោះឆ្នោត ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ការចុះបញ្ជីបេក្ខជន ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលបណ្តោះអាសន្ន និងបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ឬ/និងបណ្តឹងទាក់ទងនឹងករណីខាងលើ ។ ប៉ុន្តែពាក្យនេះ ក៏មានន័យ រួមបញ្ចូលផងដែរនូវសកម្មភាពនានា មុន និងក្រោយថ្ងៃបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងគណបក្សនយោបាយ ។

២. ពាក្យ " **អ្នកសង្កេតការណ៍** " ក្នុងក្រមសីលធម៌នេះ គឺសំដៅតែលើអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិប៉ុណ្ណោះ មិនបានគិតបញ្ចូលអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ និងតំណាង ឬ/និងភ្នាក់ងារនៃគណបក្សនយោបាយទេ ។

## III. គោលដៅ នៃក្រមសីលធម៌

គោលដៅនៃក្រមសីលធម៌នេះ គឺដើម្បីធានាឱ្យ ៖

១. កិច្ចសង្កេតការណ៍ការបោះឆ្នោត ត្រូវធ្វើឡើងដោយសុចរិត និង តម្លាភាព ។

២. អ្នកសង្កេតការណ៍បំពេញការងារដោយពុំមានការជ្រៀតជ្រែក ។

## IV. តួនាទីនៃអ្នកសង្កេតការណ៍

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចបញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមជាអ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោតទាំងមូល ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានាឱ្យចូលរួមសង្កេតការណ៍ការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ។

បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានទទួលស្គាល់ជាផ្លូវការហើយ អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍ដោយឯករាជ្យពីរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងទទួលនូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីអាជ្ញាធរដែនដី គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៀតផង ។

អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិសង្កេតមើលគ្រប់សកម្មភាព ដែលទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត ។ ប៉ុន្តែអ្នកសង្កេតការណ៍មិនត្រូវជ្រៀតជ្រែក ឬប៉ុនប៉ងប្រើឥទ្ធិពលរបស់ខ្លួន ក្នុងគោលបំណងរំខាន ឬរារាំងដំណើរការនៃការបោះឆ្នោតឡើយ ។

## V. សិទ្ធិ ភារកិច្ច និងបម្រាមសម្រាប់អ្នកសង្កេតការណ៍

### ក. សិទ្ធិ និងភារកិច្ចរបស់អ្នកសង្កេតការណ៍

នៅពេលបានទទួលស្គាល់ជាផ្លូវការ និងបានទទួលប័ណ្ណសម្គាល់អ្នកសង្កេតការណ៍រួចហើយ អ្នកសង្កេត ការណ៍ទាំងឡាយនឹងមានឯករាជភាព ព្រមទាំងមានសិទ្ធិ និងភារកិច្ច ដូចខាងក្រោម ៖

១. អ្នកសង្កេតការណ៍អន្តរជាតិ : អាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុ ច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ ។

២. អ្នកសង្កេតការណ៍ជាតិ : អាចធ្វើដំណើរសង្កេតការណ៍ក្នុងរង្វង់រាជធានី ខេត្ត ដែលខ្លួនបានស្នើសុំប៉ុណ្ណោះ ។

៣. ក្នុងករណីអ្នកសង្កេតការណ៍មានជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោតពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីជួយដោះស្រាយទាន់ពេលវេលា ។

៤. អាចអមដំណើរគណៈប្រតិភូនៃ គកប/គករ គឃ/សប គធ/ខប គ.ជ.ប នៅរាល់ពេលដឹកជញ្ជូនហិបឆ្នោត និងសម្ភារៈបោះឆ្នោតទាំងទៅ និងមក ។

៥. សង្កេតការណ៍នូវរាល់សកម្មភាពនានារបស់ កបឃ/ស ស្មៀនឃុំ សង្កាត់ ឬ គកប/គករ ឬ គឃ/សប ឬ លធ/ខប ឬ គធ/ខប និង គ.ជ.ប ទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលបោះឆ្នោត ។

៦. ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលផ្លូវការជាមួយនឹងលទ្ធផលបណ្តោះអាសន្នដែលបានកត់ត្រាក្នុងអំឡុងពេលនៃការរាប់សន្លឹកឆ្នោតនៅថ្ងៃរាប់សន្លឹកឆ្នោត ។

៧. ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធីដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ។ អាចធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដែលពាក់ព័ន្ធ និងត្រូវជូនរបាយការណ៍នេះមួយ(១)ច្បាប់ទៅ គ.ជ.ប ផង ។

៨. រក្សាការសម្ងាត់នៃការបោះឆ្នោត ។

៩. មានសេរីភាពធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន ឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន ។

១០. មានសេរីភាពក្នុងការជួប ឬនិយាយ ឬលើកសំណួរជាមួយគ្រប់បេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោត ប្រសិនបើកម្មវត្ថុនៃការជជែកនោះ មិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

១១. ត្រូវគោរពច្បាប់ដែលមានជាធរមាននៅកម្ពុជា និងត្រូវទទួលស្គាល់អធិបតេយ្យភាព នៃព្រះរាជាណាចក្រកម្ពុជា ។

១២. ត្រូវតែយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ។ ក្នុងករណីមានការរំលោភត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងភស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន ។

១៣. មានសិទ្ធិចេញចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១៤. ចំនួនអ្នកសង្កេតការណ៍ ដែលចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងពេលតែមួយ ត្រូវបានកំណត់ត្រឹមបួន (៤)នាក់ យ៉ាងច្រើន ។ ក្នុងករណីមានអ្នកសង្កេតការណ៍ច្រើនលើសពីបួន (៤)នាក់ អ្នកសង្កេតការណ៍ទាំងនោះ ត្រូវធ្វើការផ្លាស់ប្តូរតាមការកំណត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

១៥. ត្រូវមានឥរិយាបថអព្យាក្រឹត និងមិនត្រូវប្រកាន់បក្សពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋានពណ៌ ឬវត្ថុដទៃទៀតដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

១៦. ត្រូវបង្ហាញភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ច ដែលបានសាកសួរដល់ខ្លួន ហើយត្រូវពាក់ប័ណ្ណសម្គាល់ខ្លួនដែលត្រូវបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

១៧. ពុំមានសិទ្ធិចូលរួមជជែកវែកញែក ក្នុងដំណើរការដោះស្រាយបណ្ដឹងណាមួយក្នុងអំឡុងពេលបោះឆ្នោតឡើយ ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយបណ្ដឹងនេះបាន ។

១៨. ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត រាប់សន្លឹកឆ្នោតណាមួយ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និង នីតិវិធី ដែលបានកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរនៃការបោះឆ្នោតឡើយ ។

១៩. ត្រូវទទួលខុសត្រូវទូទាត់ផ្ទាល់ដោយខ្លួនឯង ឬ និងដោយអង្គការរបស់ខ្លួនលើរាល់តម្លៃ និងការចំណាយផ្សេងៗទៀតនៅក្នុងអំឡុងពេលនៃបេសកកម្មសង្កេតការណ៍របស់ខ្លួន ។

### ខ. បម្រាមសម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត

ក្នុងការសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានា នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោត អ្នកសង្កេតការណ៍ត្រូវជៀសវាង ៖

១. ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា ។

២. ការជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោត ។

៣. ការរំខាន ឬការជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ នៅពេលដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ ។

៤. ការយកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន ។

៥. ការប៉ះពាល់ឯកសារ ឬសម្ភារៈ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង ។

៦. ការប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរស័ព្ទថតរូបនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧. ការនៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។

៨. ការផ្ដល់ដំបូន្មាន ឬការស្ដីបន្ទោសឱ្យកែតម្រូវកំហុសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោតដែលខ្លួនបានរកឃើញ និងការបង្អាក់ដំណើរការបោះឆ្នោត ។

## VI. ទោសប្បញ្ញត្តិ

ដោយមិនទាន់គិតពីទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់បោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានអំណាចឆន្ទានុសិទ្ធិ ក្នុងការបដិសេធលែងទទួលស្គាល់អង្គការសង្កេតការណ៍ ឬអ្នកសង្កេតការណ៍ណាមួយ នៅពេលដែល គ.ជ.ប យល់ឃើញថា អង្គការ ឬអ្នកសង្កេតការណ៍នោះ ៖

ក. មិនគោរពតាមសេចក្តីណែនាំ និងសេចក្តីបង្គាប់បញ្ជារបស់មន្ត្រីបោះឆ្នោតមានសមត្ថកិច្ច នៅថ្នាក់ណាមួយ ។
ខ. បង្ហាញជាសាធារណៈថា បានលំអៀងទៅលើបេក្ខជន ឬគណបក្សនយោបាយណាមួយ ។
គ. បង្អាក់ ឬធ្វើឱ្យរាំងស្ទះក្នុងការបំពេញការងារនៃមន្ត្រីបោះឆ្នោត ។
ឃ. រំលោភបំពានលើក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រគល់សិទ្ធិជូនគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឱ្យបណ្តេញចេញពីទីស្នាក់ការ ឬការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នូវអ្នកសង្កេតការណ៍ទាំងឡាយណា ដែលពុំបានគោរពតាមក្រមសីលធម៌នេះ ។ ដើម្បីអនុវត្តសិទ្ធិអំណាចខាងលើ គណៈកម្ម ការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ត្រូវរាយការណ៍ពីព្រឹត្តិការណ៍នេះ តាមឋានានុក្រមមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## VII. នីតិវិធីទទួលស្គាល់អ្នកសង្កេតការណ៍

### ក. អ្នកសង្កេតការណ៍ជាតិ

១. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យពាក្យសុំ និងសម្រេចទទួលស្គាល់អ្នកសង្កេតការណ៍ជាតិ ។
២. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រគល់សិទ្ធិអំណាចឱ្យមន្ត្រី លធ.ខប គធ.ខប ពាក់ព័ន្ធ ចេញប័ណ្ណសម្គាល់ខ្លួនឱ្យអ្នកសង្កេតការណ៍ជាតិ និងប័ណ្ណសម្គាល់ខ្លួនអ្នកសង្កេតការណ៍គណបក្សនយោបាយ ដែលមិនមានបេក្ខជនឈរឈ្មោះបោះឆ្នោត ។ ប័ណ្ណសម្គាល់ខ្លួននេះ អនុញ្ញាតឱ្យអ្នកសង្កេតការណ៍ជាតិមានសិទ្ធិ និងបំពេញភារកិច្ចរបស់ខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ចំណុះរាជធានី.ខេត្ត ។ ប័ណ្ណសម្គាល់ខ្លួននេះ ត្រូវតែជាប័ណ្ណ ដែលផលិតដោយ គ.ជ.ប ។
៣. បណ្ណសម្គាល់ខ្លួននេះ ក៏អាចប្រើប្រាស់បាននៅក្នុងការបោះឆ្នោតសាជាថ្មីណាមួយ ដែលអាចធ្វើឡើង បន្ទាប់ពីមានការបដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយនោះ ។

### ខ. អ្នកសង្កេតការណ៍អន្តរជាតិ

១. អ្នកសង្កេតការណ៍អន្តរជាតិ អង្គការអន្តរជាតិណាមួយដែលចង់ចូលរួមសង្កេតមើលការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា អាចទាក់ទងជាមួយស្ថានឯកអគ្គរាជទូតកម្ពុជា ដែលប្រចាំនៅសាមីប្រទេស ។

២. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យ សម្រេច និងចេញប័ណ្ណសម្គាល់ខ្លួនឱ្យអ្នកសង្កេតការណ៍អន្តរជាតិ ។ អ្នកសង្កេតការណ៍អន្តរជាតិត្រូវបានអនុញ្ញាតឱ្យសង្កេតការណ៍នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## VIII. សំណូមពរ

បន្ទាប់ពីដំណើរការបោះឆ្នោតបានចប់សព្វគ្រប់ហើយ សាមីអង្គការសង្កេតការណ៍ទាំងឡាយត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងដំណើរការនៃការបោះឆ្នោត ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានមូលដ្ឋានគ្រឹះសម្រាប់ធ្វើការវាយតម្លៃជាចុងក្រោយ ។

# ឧបសម្ព័ន្ធទី ៤

## ក្រមសីលធម៌

## សម្រាប់មន្ត្រីបោះឆ្នោត

### គោលបំណង និងការប្រតិបត្តិតាមក្រមសីលធម៌

**ក. គោលបំណងនៃក្រមសីលធម៌**

គោលបំណងនៃក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត គឺដើម្បីផ្តល់លទ្ធភាពឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) និងមន្ត្រីបោះឆ្នោតទាំងអស់សម្រេចបាននូវ ៖

- ការបោះឆ្នោតដែលធ្វើឡើងទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- ការបោះឆ្នោតដែលមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ដែលទទួលយកបានដោយប្រជាពលរដ្ឋ កម្ពុជា ដោយគណបក្សនយោបាយចូលរួមបោះឆ្នោត និងដោយសហគមន៍អន្តរជាតិ
- ការបោះឆ្នោតដែលប្រព្រឹត្តទៅដោយគ្មានការគំរាមកំហែង គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ឬការផ្ទាញ់ផ្ទាល ។

**ខ. ការប្រតិបត្តិតាមក្រមសីលធម៌**

សមាជិកគ្រប់រូបរបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងមន្ត្រីដែលត្រូវបានធ្វើប្រតិភូកម្មអំណាចឱ្យដោយ គ.ជ.ប គឺជាមន្ត្រីបោះឆ្នោត ។ មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិតាមក្រមសីលធម៌នេះ នៅពេលដែលមន្ត្រីបុគ្គលិកទាំងនោះកំពុងស្ថិតនៅទីកន្លែងបំពេញការងាររបស់ខ្លួន ឬកំពុងបំពេញភារកិច្ចរបស់ខ្លួន ។

**គ. ការអនុវត្តរបស់មន្ត្រីបោះឆ្នោត**

**១. ការអនុវត្តច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាម និងគាំទ្រច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

**២. ល័ក្ខខ័ណ្ឌការងារ**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាមអាណត្តិ និងល័ក្ខខ័ណ្ឌការងាររបស់ខ្លួន ។ ល័ក្ខខ័ណ្ឌការងារនេះរាប់បញ្ចូលទាំងក្រមសីលធម៌នេះផងដែរ ។

៣. **ការអនុវត្តក្រមសីលធម៌**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាម គាំទ្រ និងអនុវត្តក្រមសីលធម៌ ។

៤. **ការគាំទ្រ និងការផ្សព្វផ្សាយ**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តផ្តល់ការគាំទ្រ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌នេះ ។

## ការប្រព្រឹត្តជាទូទៅ

**ការផ្តន្ទាទោសចំពោះអំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យ**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តគ្រប់ពេលវេលាទាំងអស់ ដើម្បីអនុវត្តទៅតាមសិទ្ធិអំណាចរបស់ខ្លួន ក្នុងការផ្តន្ទាទោស និងរារាំងចំពោះអំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យណាមួយទាក់ទិនដល់ការបោះឆ្នោត ។

**ភាពមិនលំអៀងរវាងគណបក្សនយោបាយ**

២.១ មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវលំអៀងជាដាច់ខាត និងមិនត្រូវធ្វើសកម្មភាពសំដែងឥរិយាបថ ឬថ្លែងសុន្ទរកថា ឬថ្លែងការណ៍អ្វីមួយដែលបង្ហាញឱ្យឃើញនូវភាពលំអៀង ឬការចូលចិត្តទៅលើគណបក្សនយោបាយ បេក្ខជន តំណាងគណបក្សនយោបាយណាមួយក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ។

២.២ មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវធ្វើអ្វីមួយដែលជះឥទ្ធិពលទៅលើអ្នកបោះឆ្នោត អាចធ្វើឱ្យមានការបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

២.៣ មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវពាក់ ឬបង្ហាញនូវស្លាកសញ្ញាណាមួយ និមិត្តសញ្ញា ឬពាក្យស្លោកជាប់នឹងសម្លៀកបំពាក់ដែលមានការពាក់ព័ន្ធទៅនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយទេឡើយ ។

**បរិយាកាសការងារ**

ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវបង្ក និងរក្សាភាពមិនលំអៀង ភាពបោះឆ្នោតជាសម្ងាត់ និងសេចក្តីថ្លៃថ្នូរ ។

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវត្រៀមលក្ខណៈចាត់វិធានការសមស្រប ទៅតាមព្រឹត្តិការណ៍ពិសេស ឬចៃដន្យដែលកើតមានឡើងក្នុងដំណើរការរៀបចំការបោះឆ្នោត ។

មន្ត្រីបោះឆ្នោតត្រូវ ៖

- អនុវត្តភារកិច្ចរបស់ខ្លួនក្នុងកាលៈទេសៈលំបាក

- អនុវត្តកិច្ចការថ្មី ឬកិច្ចការបន្ថែមទៀតដែលសមស្របតាមសមត្ថភាពរបស់ខ្លួន ប៉ុន្តែកិច្ចការនោះស្ថិតនៅក្រៅពីទីកន្លែងដែលខ្លួនកំពុងបំពេញការងារ ។

ក្នុងករណីមានការជ្រៀតជ្រែក ឬការរំខាន មន្ត្រីបោះឆ្នោតត្រូវ ៖

- បន្តអនុវត្តភារកិច្ចរបស់ខ្លួនដោយប្រុងប្រយ័ត្ន និងខ្ជាប់ខ្ជួន
- រក្សាសុវត្ថិភាពចំពោះសម្ភារបរិក្ខារបោះឆ្នោតទាំងអស់ដែលខ្លួនទទួលខុសត្រូវ ។ សម្ភារៈបោះឆ្នោតរាប់បញ្ចូលទាំងទម្រង់បែបបទផ្សេងៗ លិខិតបញ្ជាក់ សន្លឹកឆ្នោត សេចក្តីជូន ដំណឹង សោឃ្លុំ និងស្រោមសំបុត្រ ឬប្រដាប់ដាក់សម្ភារៈបោះឆ្នោត
- ធ្វើសកម្មភាពជាបន្ទាន់ទៅតាមសេចក្តីណែនាំផ្សេងៗពីមន្ត្រីថ្នាក់លើរបស់ខ្លួន ។

**ជំនួយពិសេស**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវផ្តល់ជំនួយពិសេសក្នុងសមត្ថកិច្ចរបស់ខ្លួនតាមសំណូមពរដល់បុគ្គលដែល ៖

- ពិការ
- មិនដឹងថាខ្លួនត្រូវធ្វើអ្វី ឬមិនប្រាកដអំពីអ្វីដែលខ្លួនត្រូវធ្វើ ដើម្បីចុះឈ្មោះបោះឆ្នោត ឬមិនដឹងពីរបៀបដាក់ពាក្យប្តឹងតវ៉ា ឬប្តឹងជំទាស់
- មិនមានឯកសារតាមល័ក្ខខ័ណ្ឌតម្រូវឱ្យ ឬឈ្មោះរបស់គាត់បានបាត់ចេញពីបញ្ជីបោះឆ្នោត ឬសិទ្ធិចុះឈ្មោះ ឬសិទ្ធិបោះឆ្នោតរបស់គាត់ត្រូវបានបដិសេធ ។

**ការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះ**

មន្ត្រីបោះឆ្នោតម្នាក់ៗ ត្រូវជៀសវាងសកម្មភាពពាក់ព័ន្ធទៅនឹង ៖

- ការគំរាមកំហែង
- អំពើហិង្សា ការបង្ខិតបង្ខំ ឬការបំភិតបំភ័យដល់បុគ្គលណាម្នាក់ ឬប្រឆាំងទៅនឹងបុគ្គលណាម្នាក់
- ការធ្វើឱ្យខូចខាតដល់បរិវេណការិយាល័យបោះឆ្នោតណាមួយ
- ការធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញ ឬលាក់ទុកសម្ភារបរិក្ខារ ឬទ្រព្យសម្បត្តិបោះឆ្នោតណាមួយ
- ការបង្អាក់ ឬរាំងអ្នកមានសិទ្ធិណាម្នាក់មិនឱ្យទៅការិយាល័យចុះឈ្មោះ ការិយាល័យបោះ ឆ្នោត និងរាប់សន្លឹកឆ្នោត ។

មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវមានវិធានការទប់ស្កាត់ និងដោះស្រាយឱ្យបានសមស្របតាមសមត្ថកិច្ចរបស់ខ្លួនទៅនឹងការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះដូចខាងលើ ។

**ការជក់បារី និងការបង្ការភ្លើង**

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវ ៖

- ជក់បារីនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។
- គូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយគ្មានភារកិច្ចបញ្ជាក់ឱ្យធ្វើ ។

**ការហូបចុក**

មន្ត្រីបោះឆ្នោតម្នាក់ៗមិនត្រូវបរិភោគនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ លើកលែងតែមានការបញ្ជាក់អនុញ្ញាតពីមន្ត្រីថ្នាក់លើរបស់ខ្លួន ។

**គ្រឿងស្រវឹង និងគ្រឿងញៀន**

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវមានភេសជ្ជៈដែលមានផ្ទុកជាតិស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនណាមួយនៅក្នុងការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនេះឡើយ ។

**ល្បែង**

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកម្សាន្តនៅក្នុងកន្លែង និងក្នុងពេលម៉ោងធ្វើការឡើយ ។

## លក្ខខណ្ឌចាំបាច់សម្រាប់ការិយាល័យចុះឈ្មោះ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

### ក. លក្ខខណ្ឌចាំបាច់សម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោត ៖

**ភារកិច្ចទូទៅ**

មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួនដើម្បីធានាបានថា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែងគ្រប់រូប អាចអនុវត្តសិទ្ធិរបស់ខ្លួនដោយសេចក្ដីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្របក្នុងការសុំចុះឈ្មោះបោះឆ្នោត ។

**ជំនួយសម្រាប់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដែលមានពិការភាព**

២.១ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងមុខតំណែង ដែលមិនមាំមួន មានពិការភាពណាមួយ មានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយ ឬកម្រិតណាមួយដែលខ្លួនត្រូវការជាជំនួយក្នុងការចុះឈ្មោះបោះឆ្នោត ។

២.២ មន្ត្រីបោះឆ្នោតដែលត្រូវបានចាត់ឱ្យជួយអ្នកចុះឈ្មោះដែលមិនមាំមួន មានពិការភាពនោះ ត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំដោយអ្នកពិការរូបនោះតែប៉ុណ្ណោះ ។

## ខ. លក្ខខណ្ឌចាំបាច់ទូទៅសម្រាប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

### ១. ការិយាល័យបោះឆ្នោត

មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីធានាថាអ្នកដែលបានចុះឈ្មោះបោះឆ្នោតទាំងអស់អាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតដោយសម្ងាត់ ដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្រប និងធានាថាសម្ភារបរិក្ខារបោះឆ្នោតទាំងអស់ ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និងគ្រប់ចំនួន ។

### ២. ការិយាល័យរាប់សន្លឹកឆ្នោត

មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការិយាល័យរាប់សន្លឹកឆ្នោតត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីធានាថាសន្លឹកឆ្នោតទាំងអស់ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និងគ្រប់ចំនួន ។

### ៣. ការប៉ះពាល់សម្ភារៈបោះឆ្នោត

៣.១ មន្ត្រីបោះឆ្នោតដែលកំពុងបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មិនត្រូវប៉ះពាល់សៀវភៅសន្លឹកឆ្នោត សន្លឹកឆ្នោត បញ្ជីបោះឆ្នោត សោឃ្លុំ ត្រាសម្ងាត់ ត្រាផ្លូវការ ទម្រង់បែបបទ ឬសម្ភារៈបោះឆ្នោតផ្សេងទៀត ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ ទោះបីជាភារកិច្ចរបស់ខ្លួនក៏ដោយ ។

៣.២ ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមិនត្រូវ ៖

- ស្រាយចំណង ឬបើកសោឃ្លុំ សៀវភៅសន្លឹកឆ្នោត ហិបឆ្នោត កញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសម្ភារៈបោះឆ្នោត ។
- យកចេញនូវសៀវភៅសន្លឹកឆ្នោត ហិបឆ្នោត ឬកញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសម្ភារៈបោះឆ្នោតនៅខាងក្នុង ។
- យកសម្ភារៈបោះឆ្នោតណាមួយចេញពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬជួយឱ្យអ្នកណាម្នាក់ផ្សេងទៀតឱ្យធ្វើដូច្នេះ ។
- គូសសំគាល់ ឬសរសេរលើសម្ភារៈបោះឆ្នោតណាមួយ ឬលុបគំនូស ឬលុបសំណេរណាមួយចេញពីសម្ភារៈបោះឆ្នោតណាមួយ ។

### ៤. សន្លឹកឆ្នោត និង ហិបឆ្នោត

ប្រសិនបើមន្ត្រីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយមិនមានការបញ្ជាក់អនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតរូបនោះមិនត្រូវ ៖

- ផ្តល់សន្លឹកឆ្នោតទៅជនណាម្នាក់
- បោះត្រាសម្ងាត់ជាផ្លូវការនៅលើសន្លឹកឆ្នោតណាមួយ
- ផ្លាស់ប្តូរ ឬបំផ្លាញត្រាសម្ងាត់ជាផ្លូវការនៅលើសន្លឹកឆ្នោត
- ផ្លាស់ប្តូរ ឬបំផ្លាញសន្លឹកឆ្នោត
- គូសនៅលើសន្លឹកឆ្នោត
- ចាប់យក ឬប៉ះពាល់ហិបឆ្នោត
- ដាក់សន្លឹកឆ្នោត ឬរបស់ផ្សេងទៅក្នុងហិបឆ្នោត
- យកសន្លឹកឆ្នោតចេញពីហិបឆ្នោតឡើយ ។

## គ. ល័ក្ខខ័ណ្ឌចាំបាច់ពិសេសសម្រាប់ការិយាល័យបោះឆ្នោត

### ១. ការិយាល័យបោះឆ្នោត

១.១ មន្ត្រីបោះឆ្នោតដែលកំពុងបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត មិនត្រូវព្យាយាម ៖

- ចង់ដឹងពីបំណងដែលអ្នកបោះឆ្នោតចង់បោះឆ្នោត ឬបានបោះឆ្នោត
- ធ្វើឱ្យអ្នកបោះឆ្នោតបង្ហាញ ឬប្រាប់ឱ្យដឹងអំពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោត
- គូសសញ្ញាសំគាល់ណាមួយនៅលើសន្លឹកឆ្នោតដែលអាចធ្វើឱ្យគេស្គាល់ដល់អត្តសញ្ញាណនៃអ្នកបោះឆ្នោត
- ប្រើឥទ្ធិពលទៅលើ ឬជួយអ្នកណាម្នាក់ដើម្បីបានបោះឆ្នោតដោយដឹងថាអ្នកនោះមិនមានសិទ្ធិបោះឆ្នោត
- ដើរទៅជិតធ្វើជាសញ្ញា ឬនិយាយទៅកាន់អ្នកបោះឆ្នោតណាម្នាក់ដោយគ្មានភារកិច្ចអនុញ្ញាតចាប់ពីពេលដែលអ្នកបោះឆ្នោតដើរចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោតរហូតដល់អ្នកបោះឆ្នោតចាកចេញពីបរិវេណខាងក្នុងការិយាល័យបោះឆ្នោត
- ដើរចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយគ្មានភារកិច្ច ។

១.២ មន្ត្រីបោះឆ្នោតត្រូវរាយការណ៍ជាបន្ទាន់ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច នូវសកម្មភាពរបស់បុគ្គលណាម្នាក់ទាក់ទិនដល់ការសុំឱ្យបង្ហាញ ឬការចង់ដឹងអំពីរបៀបដែលអ្នកបោះឆ្នោតណាម្នាក់បានបោះឆ្នោត ។

### ២. ជំនួយសម្រាប់អ្នកបោះឆ្នោតដែលពិការដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន

២.១ អ្នកបោះឆ្នោតដែលពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយកម្រិតណាមួយដែលខ្លួនត្រូវការជាជំនួយក្នុងការបោះឆ្នោត ។

២.២ មន្ត្រីបោះឆ្នោតត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំដោយអ្នកបោះឆ្នោតរូបនោះតែប៉ុណ្ណោះ និងទៅតាមការកំណត់នៃបទបញ្ជា និងនីតិវិធី របស់ គ.ជ.ប ។ កិច្ចការនេះតម្រូវឱ្យមន្ត្រីបោះឆ្នោត ដែលត្រូវបានតែងតាំងនោះសួរទៅអ្នកបោះឆ្នោតអំពីគណបក្សនយោបាយណាមួយដែលគាត់ចង់បោះឆ្នោតឱ្យ និងត្រូវគូសលើសន្លឹកឆ្នោតក្នុងនាមអ្នកបោះឆ្នោតរូបនោះ ។ មន្ត្រីបោះឆ្នោត ដែលត្រូវបានចាត់ឱ្យជួយអ្នកពិការត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតនេះ ។

**ឃ. លក្ខខណ្ឌចាំបាច់ពិសេសសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោត**

មន្ត្រីបោះឆ្នោតម្នាក់ៗនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោតដែលគ្មានភារកិច្ចអនុញ្ញាតឱ្យធ្វើ មិនត្រូវព្យាយាមលាតត្រដាង ៖

- សន្លឹកឆ្នោតណាមួយដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ
- លទ្ធផលនៃការត្រួតពិនិត្យ និងការគណនាណាមួយធ្វើឡើងដោយមន្ត្រីបោះឆ្នោត
- ចំនួនសន្លឹកឆ្នោតមិនបានការដែលកំពុងមានវិវាទ
- ចំនួនសំទេឡងឆ្នោតដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ ។

## <u>ទំនាក់ទំនងជាមួយគណបក្សនយោបាយ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍</u>

**១. ទំនាក់ទំនង**

១.១ មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវរាក់ទាក់ មិនលំអៀង និងត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយបេក្ខជន តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ និងគ្រប់ពេលវេលា ទាំងអស់ ។

១.២ មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវទទួលស្គាល់តួនាទីត្រឹមត្រូវតាមច្បាប់របស់តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែល ៖

- មានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនេះ ដើម្បីសង្កេតការណ៍មើលដំណើរការបោះឆ្នោត
- ធ្វើការតវ៉ា ឬជំទាស់ ឬធ្វើពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់អំពីភាពមិនប្រក្រតីនៃការអនុវត្តបទបញ្ជា និងនីតិវិធី ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច )សម្រាប់តំណាងគណបក្សនយោបាយតែប៉ុណ្ណោះ ) ។

១.៣ មន្ត្រីបោះឆ្នោតដែលមានភារកិច្ចទទួលដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ត្រូវទទួលយកគ្រប់ពាក្យបណ្ដឹង ទោះជាពាក្យបណ្ដឹងនោះហួសអាជ្ញាយុកាល ឬមិនមានលក្ខណៈគ្រប់គ្រាន់ក៏ដោយ ។ ក្នុងករណីទាំង២ចុងក្រោយនេះ មន្ត្រីនោះត្រូវចារបដិសេធលើពាក្យបណ្ដឹងដោយបញ្ជាក់មូលហេតុសមស្រប ។

## ២. ភាពគ្មានសិទ្ធិអំណាច

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវដឹងថា ៖

- គណបក្សនយោបាយ បេក្ខជន តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ មិនមានសិទ្ធិធ្វើសេចក្តីណែនាំណាមួយដល់មន្ត្រីបោះឆ្នោតណាម្នាក់ឡើយ ។
- មិនត្រូវប្រតិបត្តិតាមសេចក្តីណែនាំណាមួយរបស់គណបក្សនយោបាយ បេក្ខជន តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់ឡើយ ។

## ៣. ការជូនរង្វាន់ និងការសន្យា

៣.១ មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវទទួលយកទោះដោយផ្ទាល់ ឬដោយប្រយោលក្តីនូវចំនួនទឹកប្រាក់ រង្វាន់ ឬការសន្យាណាមួយពីគណបក្សនយោបាយ បេក្ខជន តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ណាម្នាក់ឡើយ ។

៣.២ រង្វាន់មានរាប់បញ្ចូលទាំងស្បៀងអាហារ ឬភេសជ្ជៈ ឬសេវាកម្មផ្ទាល់ខ្លួនផ្សេងទៀតដែលផ្តត់ផ្គង់ដល់មន្ត្រីបោះឆ្នោតណាម្នាក់ដោយគណបក្សនយោបាយណាមួយ បេក្ខជន តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយគ្មានការយល់ព្រមដោយចំហាពីតំណាងគណបក្សនយោបាយ ទាំងអស់ដែលមានវត្តមាននៅក្នុងការិយាល័យនោះ ។

## ៤. សកម្មភាពដែលត្រូវហាមឃាត់

មន្ត្រីបោះឆ្នោតម្នាក់ៗ នៅក្នុងអំឡុងពេលបោះឆ្នោត មិនត្រូវ ៖

- មានឈ្មោះជាបេក្ខជននៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ
- ធ្វើការងារឱ្យ ឬទទួលថ្លៃឈ្នួលពីគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់
- ជាអ្នកកាន់មុខតំណែងណាមួយ នៅក្នុងការិយាល័យគណបក្សនយោបាយ ។

## <u>ការបណ្តុះបណ្តាល</u>

មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវចូលរួមរៀនសូត្រគ្រប់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាទាំងអស់ដែលខ្លួនត្រូវទទួល ។

## <u>ទោសប្បញ្ញត្តិ</u>

មន្ត្រីបោះឆ្នោតគ្រប់រូបដែលអនុវត្តផ្ទុយពី ប.ច.ក និង ប.ន.ក និងក្រមសីលធម៌នេះនឹងត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងជំពូកទី ៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

# ឧបសម្ព័ន្ធទី ៥

# ក្រមសីលធម៌សម្រាប់

# សមាជិកនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ

## ផ្នែកទី ១

## I. សេចក្តីផ្តើម

ការបោះឆ្នោតនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលបានឆ្លុះបង្ហាញឱ្យឃើញកាន់តែច្បាស់ពីការខិតខំពង្រឹង និងការវិវត្តរីកចំរើននៃលទ្ធិប្រជាធិបតេយ្យ នៅព្រះរាជាណាចក្រកម្ពុជា។

ដូចនេះ ដើម្បីឱ្យដំណើរការនៃការបោះឆ្នោតមួយលើកៗតាមនីតិកាល ឬអាណត្តិ ប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សុវត្ថិភាព សេរី ត្រឹមត្រូវ យុត្តិធម៌ និងដើម្បីពង្រឹងបរិយាកាសសង្គមឱ្យបានល្អសម្រាប់ការរៀបចំការបោះឆ្នោតដែលមានការយោគយល់គ្នា មានការគោរពច្បាប់ មិនមានការបំពុលបរិយាកាសសង្គមនាំឱ្យមានការភ័យខ្លាច ការច្របូកច្របល់ ការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សាផ្សេងៗ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុម័តក្រមសីលធម៌ សម្រាប់សមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ដែលមានខ្លឹមសារលំអិតដូចខាងក្រោម ៖

## II. គោលបំណង

គោលបំណង នៃក្រមសីលធម៌គឺ ៖

- ដើម្បីឱ្យដំណើរការនៃការរៀបចំការបោះឆ្នោតទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ប្រព្រឹត្តទៅបានជោគជ័យ គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ និងគ្មានអំពើហិង្សាផ្សេងៗ ។
- ដើម្បីការពារសន្តិសុខ និងសុវត្ថិភាពជូនបេក្ខជន វាគ្មិន ឬឃោសនិក ភ្នាក់ងារ និងតំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត មន្ត្រីរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកបោះឆ្នោត និងរក្សាស្ថិរភាពសម្រាប់សង្គមជាតិទាំងមូល ។
- ដើម្បីចាត់វិធានការបង្ការរារាំង ទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើស អំពើវិទ្ធង្សនា និងអំពើភេរវកម្មផ្សេងៗ ដែលអាចបង្កឱ្យមានការរាំងស្ទះដល់ដំណើរការបោះឆ្នោត ។

## III. សំណូមពរ

- សមាជិក នៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិទាំងមូល ជាពិសេស កងកម្លាំងដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខ សម្រាប់ការបោះឆ្នោត ហៅកាត់ "ភ្នាក់ងារសន្តិសុខបោះឆ្នោត" ត្រូវប្រមូលផ្តុំកម្លាំងសហការឱ្យបានល្អ និងប្រើប្រាស់តាមគ្រប់វិធានការជំនាញគ្រប់មធ្យោបាយនិងសម្ភារៈ លើកកំពស់ស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ក្នុងកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោត ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវផ្អែកលើច្បាប់ពិសេស ច.ប.ត.រ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប សម្រាប់ការបោះឆ្នោត យកមកធ្វើជាមូលដ្ឋានសំខាន់ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវចូលរួមការពារសុវត្ថិភាព ក្នុងដំណើរការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការការពារសុវត្ថិភាពសម្ភារៈ ឧបករណ៍ គ្រឿងសង្ហារឹមផ្សេងៗ សម្រាប់ដំណើរការបោះឆ្នោតទាំងមូល ។

## IV. សិទ្ធិទទួលការការពារសន្តិសុខ

ក្នុងដំណើរការបោះឆ្នោតនៅថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិនីមួយៗ សមាជិកនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវប្រកាន់ជំហរអព្យាក្រឹត មិនលំអៀង និងមិនត្រូវបង្ហាញការគាំទ្រ ឬប្រឆាំងដល់គណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ឡើយ ។ សមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវចងចាំថា ៖

- អ្នកបោះឆ្នោតគ្រប់រូបមានសិទ្ធិទទួលការការពារសន្តិសុខ និងសុវត្ថិភាព ដើម្បីឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។
- បេក្ខជន វាគ្មិន ឬឃោសនិក ភ្នាក់ងារ និងតំណាងនៃគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាព ក្នុងគ្រប់សកម្មភាពស្របច្បាប់ ។

## V. សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវនៃភ្នាក់ងារសន្តិសុខបោះឆ្នោត

### ក- ភ្នាក់ងារសន្តិសុខបោះឆ្នោត មានភារកិច្ច ៖

១. ត្រូវសហការ និងត្រៀមលក្ខណៈសហការជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីផ្តល់សុវត្ថិភាព ក្នុងដំណើរការបោះឆ្នោត ។

២. ត្រូវរក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ក្នុងពេលបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ បញ្ជីបេក្ខជន ពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត ។

៣. ត្រូវធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយពាក់ព័ន្ធទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពនៅក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត។

៤. ត្រូវចូលរួមចំណែកការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ដែលជាបរិវេណរដ្ឋបាល និងសន្តិសុខ ។

៥. នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួន ៣(បី)នាក់ ដើម្បីការពារបរិវេណសន្តិសុខ នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវមានឯកសណ្ឋានត្រឹមត្រូវ និងមានពាក់ប៉ាន ដែសន្តិសុខរបស់ គ.ជ.ប ។

៦. ត្រូវយាម និងត្រួតពិនិត្យគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត យ៉ាងតឹងរ៉ឹងបំផុត ក្នុងគោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧. មិនត្រូវអនុញ្ញាតឱ្យជនណាម្នាក់ដែលប្រដាប់អាវុធ ឬមានលាក់អាវុធនៅក្នុងខ្លួនចូល ឬឈរក្បែរ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត លើកលែងតែជាសមាជិកនៃកងយោធពល ខេមរភូមិន្ទ កងរាជអាវុធហត្ថ ឬកងនគរបាលជាតិ ដែលមានភារកិច្ច និងត្រូវបានស្នើសុំ ដោយប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ដើម្បីដោះស្រាយបាតុភាព ដែលអាចនឹងកើតមាន ។

៨. ត្រូវស្ថិតនៅជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដើម្បីត្រៀមបំពេញភារកិច្ច ក្នុង ករណីមានសំណូមពរពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុង គោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយា ល័យណាមួយនោះ ។

៩. ត្រូវបានស្នើឱ្យជួយការពារការដឹកជញ្ជូនសម្ភារៈបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយ តាម ការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

១០. មេបញ្ជាការ ឬតំណាងនៃកងយោធពលខេមរភូមិន្ទ កងរាជអាធវុហត្ថ និងកងនគរបាលជាតិ ត្រូវចូលរួមប្រជុំជាមួយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បី ចាត់វិធានការការពារសន្តិសុខ និងសុវត្ថិភាព ក្នុងដំណើរការបោះឆ្នោតទាំងមូល ។

១១. មេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវចេញ សេចក្តីណែនាំ ឬបទបញ្ជាទៅដល់មន្ត្រីនៅក្រោមឱវាទ ដើម្បីពិនិត្យមើលសកម្មភាពរបស់ មន្ត្រី នៃអង្គភាពរៀងៗខ្លួនពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រគណបក្សនយោ បាយ និងប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងការការពារនូវសិទ្ធិសេរីភាពជាមូលដ្ឋាន ដូចមានចែង ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ខ- សមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវអនុវត្តបម្រាម ដូចតទៅនេះ ៖**

១. សមាជិកនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ មិនត្រូវ ចូលរួមសកម្មក្នុងគ្រប់សកម្មភាពឃោសនាបោះឆ្នោត របស់គណបក្សនយោបាយណាមួយ ឡើយ ។ ការចូលរួមសកម្មត្រូវបានកំណត់ ដូចតទៅ ៖

១.១ ការធ្វើជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ វាគ្មិន ឬក្រុមអ្នកឃោសនាបោះឆ្នោតនៃគណបក្សនយោបាយ ។

១.២ ការចូលរួមក្នុងក្បួនដង្ហែ ការជួបជុំ និងក្បួនព្យុហយាត្រាដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៣ ការដាក់តាំងរូបភាពផ្សាយ ឬឯកសារផ្សេងៗដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់នៅតាមយានជំនិះផ្ទាល់របស់ខ្លួន ឬ/និងរបស់អង្គភាព ។

១.៤ ការស្ទង់មតិសម្រាប់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៥ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៦ ការធ្វើសកម្មភាពចែកចាយសម្ភារៈដល់អ្នកបោះឆ្នោត ក្នុងគោលដៅគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៧ ការចេញសេចក្តីថ្លែងការណ៍ជាសាធារណៈក្នុងការគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

១.៨ ការលេងភ្លេងគាំទ្រគណបក្សនយោបាយ ឬ/និងការច្រៀងចម្រៀង ឬ/និងការផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសម្លេងនានា ដើម្បីគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

២. មិនត្រូវចូលរួមក្នុងសកម្មភាពឃោសនាជាសាធារណៈណាមួយ ក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ ។

៣. មិនត្រូវចូលរួមក្នុងសកម្មភាពឃោសនាណាមួយ ក្នុងពេលបំពេញភារកិច្ច ។

៤. មិនត្រូវដើរ ឬឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៥. មិនត្រូវជ្រៀតជ្រែកក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ។

៦. មិនត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ ឬ/និងយកអាវុធ សារជាតិផ្ទុះ ឬឧបករណ៍ប្រកបដោយគ្រោះថ្នាក់តាមខ្លួនចូលក្នុងបរិវេណខាងក្រៅ និងខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៧. មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលនេះឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀត ។ ការគំរាមកំហែង ការបំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ៖

៧.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញនិង ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ។

៧.២ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថា នឹងធ្វើទារុណកម្ម ។

៧.៣ ការវាយតប់បង្កិចបង្ខូច ឬធ្វើទុក្ខបុកម្នេញលើបុគ្គលណាម្នាក់ ។

៧.៤ ការរំលោភដោយពាក្យសម្តីថា នឹងធ្វើទុក្ខទោសដល់រាងកាយ ។

៧.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ ។

៧.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរដែលយោងទៅលើព្រឹត្តិការណ៍ ពីអតីតកាល ដូចជា : ឃាតកម្ម ការវាយដំ ឬការបង្ករបួសស្នាម ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។

៧.៧ ការបាញ់កាំភ្លើងបង្អើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

៧.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខ ផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬ ដល់បងប្អូនគ្រួសាររបស់ខ្លួន ។

៧.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើ ឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬ សុវត្ថិភាពគ្រួសាររបស់ខ្លួន ។

៧.១០ ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង ។

៧.១១ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង និងផលប្រយោជន៍ផ្សេងទៀត ។

៨. មិនត្រូវចូលក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត លើកលែងតែមានករណីចាំបាច់ និងមានការស្នើសុំពីប្រធាន គ.ជ.ប ប្រធាន គធ/ខប ប្រធាន គឃ/សប ឬពីប្រធាន ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

## VI ការរៀបចំយន្តការ និងសហប្រតិបត្តិការផ្នែកសន្តិសុខ

ដើម្បីការពារសន្តិសុខ ស្ថិរភាព សុវត្ថិភាព សម្រាប់ការបោះឆ្នោតទាំងនៅថ្នាក់ជាតិ_ថ្នាក់ក្រោមជាតិ កងយោធពលខេមរភូមិន្ទ ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងកម្លាំងនគរបាលជាតិ ត្រូវចាត់ឱ្យបំពេញភារកិច្ចជា ភ្នាក់ងារសន្តិសុខបោះឆ្នោត ។ ជាគោលការណ៍យន្តការរចនាសម្ព័ន្ធចាត់តាំង និងកិច្ចសហប្រតិបត្តិការផ្នែក សន្តិសុខ មានការរៀបចំដូចតទៅ ៖

**១_ អំពីយន្តការផ្នែកសន្តិសុខរវាង គ.ជ.ប និងរាជរដ្ឋាភិបាល**

**ក- រចនាសម្ព័ន្ធសន្តិសុខរបស់ គ.ជ.ប**

- គ.ជ.ប
- អគ្គលេខាធិការដ្ឋាន
- លធ/ខប ឬ គធ/ខប
- គឃ/សប
- គណៈកម្មការការិយាល័យបោះឆ្នោត (គកប)
- កបឃ/ស (នៅពេលចុះឈ្មោះបោះឆ្នោត)

**ខ- រចនាសម្ព័ន្ធសន្តិសុខរបស់រាជរដ្ឋាភិបាល**

- គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ (គ.ស.អ)
- លេខាធិការដ្ឋាននៃ គ.ស.អ
- គណៈអភិបាល ឬគណៈបញ្ជាការឯកភាពរាជធានី ខេត្ត
- គណៈអភិបាល ឬគណៈបញ្ជាការឯកភាព ក្រុង ស្រុក ខណ្ឌ
- មន្ត្រីអនុវត្តច្បាប់ រួមមាន កងយោធពលខេមរភូមិន្ទ ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងនគរបាលជាតិ ត្រូវបានរៀបចំចាត់តាំងជាភ្នាក់ងារសន្តិសុខបោះឆ្នោត ។

**២_ កិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខបោះឆ្នោតរវាង គ.ជ.ប និង គ.ស.អ**



# ផ្នែកទី ២

# មុខសញ្ញានិងគោលដៅ ប្រព័ន្ធការពារសន្តិសុខការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត និងយន្តការការពារសន្តិសុខបោះឆ្នោត

**I. មុខសញ្ញា និងគោលដៅដែលត្រូវការពារជាអាទិភាព**

ចំពោះកិច្ចការពារមុខសញ្ញា និងគោលដៅសំខាន់ៗ ត្រូវរៀបចំជាផែនការដោយតម្រូវឱ្យមានការការពារជាលក្ខណៈប្រយោល ។

មុខសញ្ញា និងគោលដៅជាអាទិភាពដែលត្រូវការពារ រួមមាន ៖

**១_ មុខសញ្ញាដែលត្រូវការពារ**

- ប្រធាន អនុប្រធាន និងសមាជិក សមាជិកា គ.ជ.ប
- មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- បេក្ខជនឈរឈ្មោះបោះឆ្នោត
- ឃោសនិក ឬវាគ្មិន និងក្រុមឃោសនាបោះឆ្នោត របស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត
- តំណាង ឬភ្នាក់ងាររបស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត
- អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ
- ប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត
- អ្នកបោះឆ្នោត ។

**២_ គោលដៅដែលត្រូវការពារ**

- ទីស្តីការរបស់ គ.ជ.ប
- ទីកន្លែងស្នាក់នៅនៃបេក្ខជនឈរឈ្មោះបោះឆ្នោត ឃោសនិក ឬវាគ្មិន ឬក្រុមឃោសនាបោះឆ្នោត និងតំណាងនៃគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត
- ទីស្នាក់ការរបស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត
- ទីកន្លែងស្នាក់នៅរបស់អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ
- ទីស្នាក់ការរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត
- ការិយាល័យពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

- ការដឹកជញ្ជូនសម្ភារៈបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយតាមការកំណត់របស់ គ.ជ.ប ឬ,និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

## II. ប្រព័ន្ធការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

គ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត មានបរិវេណខាងក្នុងជាវ័ណ្ឌមណ្ឌលមួយដែលមានកាំប្រវែងយ៉ាងតិច ១៥ម៉ែត្រ និងមានបរិវេណខាងក្រៅដែលជាតំបន់នៅជុំវិញការិយាល័យទាំងនោះមានកាំប្រវែង ១០០ម៉ែត្រ ឬមានទម្រង់ផ្សេងៗ ឬមានកាំតូចជាងស្របទៅតាមស្ថានភាពភូមិសាស្ត្រជាក់ស្ដែងនៃបរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗនោះ ។




**ចំនួសទំហំនៃបរិវេណខាងក្នុង និងបរិវេណខាងក្រៅ នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**




**ចំនួសប្រព័ន្ធការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

- ពណ៌សមានវ័ណ្ឌមណ្ឌលកាំប្រវែង ១៥ម៉ែត្រ គឺជាបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- ពណ៌ខៀវមានវ័ណ្ឌមណ្ឌលកាំប្រវែង ១០០ម៉ែត្រ គឺជាបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងឯកសណ្ឋានត្រឹមត្រូវ និងពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប ។

**សេចក្ដីបញ្ជាក់៖**

❈ ភ្នាក់ងារសន្តិសុខបោះឆ្នោត ចំនួន ០៣ (បី)នាក់ ស្លៀកពាក់ឯកសណ្ឋាន និងមានពាក់ប៉ាន់ដៃសន្តិសុខរបស់ គ.ជ.ប ការពារនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ៖

- ភ្នាក់ងារសន្តិសុខ ០១(មួយ)នាក់ ត្រូវចល័តការពារជុំវិញការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬចល័តការពារនៅក្នុងបរិវេណខាងក្រៅ នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយត្រូវស្ថិតនៅក្នុងចម្ងាយពី ១៥_១០០ម៉ែត្រ គ្មានសិទ្ធិប្រើអាវុធឡើយ ។
- ភ្នាក់ងារសន្តិសុខ ០២(ពីរ)នាក់ទៀតត្រូវចល័តការពារជុំវិញបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយត្រូវស្ថិតនៅក្នុងចម្ងាយពី ១០០_១៥០ម៉ែត្រ មានសិទ្ធិប្រើប្រាស់នូវអាវុធវែង ០១ដើម បង់ ០១ និងមានគ្រាប់យ៉ាងច្រើនចំនួន ៣០គ្រាប់ ។

❈ ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវប្រមូលផ្តុំកម្លាំងយាមទីកន្លែងរក្សាទុក ឬ/និងការពារការដឹកជញ្ជូនសម្ភារៈបោះឆ្នោត និងឯកសារបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយ តាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

## III. គោលការណ៍ និងយន្តការការពារសន្តិសុខបោះឆ្នោត

ភ្នាក់ងារសន្តិសុខបោះឆ្នោតដែលបំពេញភារកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ដំណើរការរៀបចំការបោះឆ្នោតទាំងនៅថ្នាក់ជាតិ_ថ្នាក់ក្រោមជាតិ ត្រូវគោរពអនុវត្តតាមគោលការណ៍សំខាន់ៗ ដូចតទៅ ៖

### ១_ គោលការណ៍ទូទៅ

- រក្សាបរិយាកាសនយោបាយអព្យាក្រឹត និងគោរពវិន័យយ៉ាងម៉ឺងម៉ាត់ដើម្បីឱ្យការបោះឆ្នោតមានដំណើរការទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សា ។
- ត្រូវផ្អែកលើច្បាប់ និងបទបញ្ជា និងនីតិវិធី គ.ជ.ប ធ្វើជាមូលដ្ឋានក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។
- ពង្រឹងការពារសន្តិសុខសម្រាប់សង្គមជាតិទាំងមូល ។
- ត្រូវមានអព្យាក្រឹតក្នុងមុខនាទី ក្នុងសកម្មភាពការងារ និងក្នុងនាមជាកងកម្លាំងរបស់ជាតិ ។
- ហាមឃាត់ការប្រើមុខងារ ការបំពេញភារកិច្ច និងការប្រើប្រាស់មធ្យោបាយ សម្ភារៈរបស់រដ្ឋ ដើម្បីបំរើឱ្យសកម្មភាព និងផលប្រយោជន៍របស់គណបក្សនយោបាយណាមួយ ។

### ២_ ការរៀបចំយន្តការការពារសន្តិសុខសម្រាប់ការបោះឆ្នោត

- ចាត់តាំងកម្លាំងការពារគ្រប់ទីតាំងបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ។
- ចាត់តាំងកម្លាំងការពារសកម្មភាពឃោសនាបោះឆ្នោត របស់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត ។

- ការពារការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការពារការដឹកជញ្ជូនសម្ភារៈ ឯកសារបោះឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត ដោយត្រូវធ្វើកិច្ចសហប្រតិបត្តិការជាមួយ គ.ជ.ប លធ/ខប ឬ គធ/ខប និងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- បន្តរក្សាសន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

**បញ្ជាក់ ៈ**

- នៅថ្ងៃបោះឆ្នោតភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ០៣(បី)នាក់ ស្លៀកពាក់ឯកសណ្ឋានត្រឹមត្រូវ និងមានពាក់ប៉ាន់ដៃសន្តិសុខរបស់ គ.ជ.ប ត្រូវការពារនៅតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត រហូតដល់ចប់ភារកិច្ច ។
- ប្រធានការិយាល័យបោះឆ្នោត ប្រកាសបើកការបោះឆ្នោតនៅម៉ោង ៧:០០ និងប្រកាសបិទការបោះឆ្នោតនៅម៉ោង ១៥:០០ នៅថ្ងៃដដែល ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ហើយចាត់វិធានការរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត ឱ្យបានតឹងរឹងបំផុត ។
- ក្នុងករណីមានសំណូមពរពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងគោលបំណងស្នើសុំឱ្យជួយថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវបានបំពាក់អាវុធសមស្រប ឬ/និងភ្នាក់ងារសង្គ្រោះ អាចចូលធ្វើអន្តរាគមន៍ នៅក្នុងការិយាល័យបាន ។
- ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវប្រមូលផ្តុំកម្លាំងចូលរួមការពារការរក្សាទុក និង/ឬការដឹកជញ្ជូនសម្ភារៈបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតពីគោលដៅមួយទៅកាន់គោលដៅមួយ តាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

# ផ្នែកទី ៣
# តួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់អាជ្ញាធរដែលទទួលខុសត្រូវលើ ការងារសន្តិសុខ និងអំពីទោសប្បញ្ញត្តិដែលកំណត់ដោយច្បាប់

សមាជិក នៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងនគរបាលជាតិ ត្រូវយល់និងចងចាំនូវមាត្រាមួយចំនួន នៃច្បាប់ស្តីពីការបោះឆ្នោតគ្រប់ប្រភេទ សេចក្តីណែនាំ និងបទបញ្ជាផ្សេងៗ ដែលកំណត់អំពីតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់គ្រប់អាជ្ញាធរដែលទទួលខុសត្រូវលើការងារសន្តិសុខ នៃរាជរដ្ឋាភិបាល និងអំពីទោសប្បញ្ញត្តិ ៖

**១. អំពីតួនាទី ភារកិច្ច និងកាតព្វកិច្ចរបស់អាជ្ញាធរ :**

**មាត្រា ១៦_ថ្មី** (សម្រង់ចំណុចទី ៥) នៃ ច.ប.ត.រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិអំណាច និងភារកិច្ច ៖ "លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត"។

**មាត្រា ២៩_ថ្មី** នៃ ច.ប.ត.រ

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតតាមសំណើរបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

**មាត្រា ៧៦_ថ្មី** នៃ ច.ប.ត.រ

ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គណបក្សនយោបាយនិងបេក្ខជនទាំងអស់មិនត្រូវប្រើអំពើហិង្សា អំពើរំលោភ សំដីប្រមាថមើលងាយ មិនត្រូវសាបព្រោះឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់ បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

**មាត្រា ១០០_** នៃ ច.ប.ត.រ

ហាមដាច់ខាតមិនឱ្យយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងហាមមិនឱ្យស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពិសេសពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ទីធ្លាការិយាល័យបោះឆ្នោតត្រូវមានទំហំប្រមាណ ២០០០ ម៉ែត្រការ៉េ ហើយរង្វង់ការពារសន្តិសុខត្រូវស្ថិតនៅចម្ងាយប្រមាណ ២០០ ម៉ែត្រជុំវិញការិយាល័យបោះឆ្នោត លើកលែងតែមានការសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**២. អំពីទោសប្បញ្ញត្តិ :**

**មាត្រា ១២៤_ថ្មី** នៃ ច.ប.ត.រ

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា និងគណបក្សនយោបាយណាដែលបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម :

- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យមិនឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។
- ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។
- ធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសម្បថឱ្យគេបោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត ។
- ប្រើកម្លាំង ឬអំពើហិង្សាដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។
- រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់ ។
- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យ ប្រើពាក្យសម្តីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាចការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកទុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន ។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន ។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។
- ទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬដោយប្រាក់កាស ។

**មាត្រា ១២៥_ថ្មី** នៃ ច.ប.ត.រ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ,និងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ(៥)ឆ្នាំ ចំពោះសមាជិកគណៈកម្មាធិការជាតិ សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិច ដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

**មាត្រា ១២៦_ថ្មី** នៃ ច.ប.ត.រ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ដល់ហាសិបលាន (៥០.០០០.០០០) រៀល និងត្រូវបញ្ឈប់ពីការងារបោះឆ្នោតជារៀងរហូត ចំពោះភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មាធិការជាតិ ឬភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតណា ដែលប្រព្រឹត្តល្មើសនឹងវាក្យខ័ណ្ឌទី ២ មាត្រា ១២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ១២៧_ថ្មី** នៃច្បាប់ ច.ប.ត.រ

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥៥ថ្មី ឬមាត្រា ១០០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ក្នុងករណីដែលមិនព្រមអនុវត្តតាមការព្រមាននេះ ត្រូវឃាត់ខ្លួន និងដកហូតអាវុធសម្រាប់រយៈពេលសែសិបប្រាំបី(៤៨)ម៉ោង ដោយភ្នាក់ងារមានសមត្ថកិច្ច និងផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ដល់ហាសិបលាន (៥០.០០០.០០០)រៀល ។

ប្រសិនបើជនល្មើសនោះជាមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ នគរបាលជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

_ ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន ដើម្បីឱ្យដាក់ពិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែង យោលទៅតាមកម្រិតនៃបទល្មើស ។

_ លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាសមាជិក ឬជាបុគ្គលិករបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារភ្លាម និងមិនឱ្យចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់(១០)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខណ្ឌទី១ នៃមាត្រានេះ ។

**មាត្រា ១២៨_ថ្មី** នៃច្បាប់ ច.ប.ត.រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាលចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែង ចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៩ថ្មី នៃច្បាប់នេះ ។

**មាត្រា ១២៩_ថ្មី** នៃ ច.ប.ត.រ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលបង្ខាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនប្រព្រឹត្តល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៣០_ថ្មី នៃ ច.ប.ត.រ**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និងត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលមានចេតនាធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនល្មើសនោះជាបេក្ខជនវិញ ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៣១_ថ្មី នៃ ច.ប.ត.រ**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬនិងត្រូវលប់ឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណា ឬគណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៣ថ្មី ឬមាត្រា ៧៦ នៃច្បាប់នេះ ។

**មាត្រា ១៣៣_ថ្មី នៃ ច.ប.ត.រ**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនិងមាត្រា ៧២នៃច្បាប់នេះ ។ ក្នុងករណីដែលនៅពុំព្រមអនុវត្តតាម ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ(៥)ឆ្នាំ លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល ។

# ឧបសម្ព័ន្ធទី ៦
## គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

### I- គោលបំណង

- ដើម្បីធានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ច.ប.ក) និងស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ។
- ដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយ ។
- ដើម្បីអនុវត្តនូវមាត្រា ៧៤ មាត្រា ៧៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជន មានភាពអព្យាក្រឹត ក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កំណត់នូវគោលការណ៍មួយចំនួន សម្រាប់ប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជន ដូចខាងក្រោម ។

### II-គោលការណ៍ទូទៅ

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងដែលអាចទទួលយកបាននូវលទ្ធផលនៃការបោះឆ្នោត អ្នកយកព័ត៌មានជាតិ ( រដ្ឋ និងឯកជន ) និងអន្តរជាតិ មានតួនាទីសំខាន់ក្នុងការប្រមូលព័ត៌មាន និងរាយការណ៍អំពីដំណើរការបោះឆ្នោតទូទាំងប្រទេស ។

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា មានលក្ខណៈប្រជាធិបតេយ្យ និងតម្លាភាព គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញគោលការណ៍សំរាប់គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងចូលរួមយកព័ត៌មាន ក្នុងដំណាក់កាលនីមួយៗនៃការបោះឆ្នោត ដូចខាងក្រោម ៖

១- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ មិនលំអៀង និងដោយមានការថ្លឹងថ្លែងអោយមានតុល្យភាព ។

២- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលផ្តល់ព័ត៌មានអំពីការបោះឆ្នោត ត្រូវតែផ្ទៀងផ្ទាត់អំពីប្រភពព័ត៌មានភាពសុក្រឹត និងភាពច្បាស់លាស់នៃហេតុការណ៍ និងព្រឹត្តិការណ៍ដែលខ្លួនត្រូវរាយការណ៍ ។

៣- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវតែផ្តល់ព័ត៌មាន និងការអប់រំអំពីការបោះឆ្នោតដែលងាយយល់សម្រាប់អ្នកបោះឆ្នោត ។

៤_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវជៀសវាងការប្រើប្រាស់ភាសាញុះញង់ ឬវាយប្រហារ ដែលអាចបង្កភាពគ្មានសណ្តាប់ធ្នាប់ ឬអាចឱ្យមានអំពើហិង្សា និងត្រូវថ្លឹងថ្លែងជាមុន មុននឹងធ្វើការផ្សព្វផ្សាយ ។

៥_ ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកគ្រប់គ្រងត្រូវខិតខំប្រឹងប្រែងឱ្យអស់សមត្ថភាព ចូលរួមធ្វើឱ្យការបោះឆ្នោតមានលក្ខណៈសេរី និងយុត្តិធម៌ តាមរយៈការផ្តល់ព័ត៌មានអំពីការបោះឆ្នោត និងចាត់ទុកព័ត៌មានអំពីការបោះឆ្នោតជាព័ត៌មានអាទិភាព ។

៦_ អ្នកសារព័ត៌មានមិនត្រូវបោះបង់គោលជំហរ ឬក្រមសីលធម៌របស់ខ្លួន ដោយសារតែអំណោយផលប្រយោជន៍ ឬចំណង់ចំណូលចិត្តពិសេសទេ ។

៧_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវមានភារកិច្ច និងការទទួលខុសត្រូវ ក្នុងការស៊ើបអង្កេត និងរាយការណ៍នូវបញ្ហាដែលទាក់ទងដល់ការបោះឆ្នោតឱ្យបានត្រឹមត្រូវ ដើម្បីរក្សាស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ។

៨_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវស្វែងរក និងត្រូវផ្សព្វផ្សាយព័ត៌មាន អំពីទស្សនៈ និងគំនិតផ្សេងៗគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបោះឆ្នោត ។

៩_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ ត្រូវគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប នៅក្នុងដំណើរការបោះឆ្នោត ។

១០_ គ.ជ.ប លើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងលក្ខណៈជាដៃគូ ជាមួយ គ.ជ.ប និងសង្គមស៊ីវិល ដើម្បីធ្វើការផ្តល់ព័ត៌មាន និងអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត ។

១១_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវតែជៀសវាងការផ្តល់ព័ត៌មាន ដែលពាក់ព័ន្ធនឹងការរើសអើងដល់ស្ត្រីភេទ និងជនពិការ ។

១២_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្សព្វផ្សាយព័ត៌មាន អំពីសារៈសំខាន់ នៃការចូលរួមរបស់ស្ត្រី និងជនពិការក្នុងជីវភាពសង្គម និងនយោបាយដើម្បីបង្កើនការយល់ដឹងជាសាធារណៈ ។

១៣_ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និងឯកជន ត្រូវតែធ្វើការបែងចែកឱ្យបានច្បាស់ ក្នុងការផ្សព្វផ្សាយព័ត៌មាន អំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោតដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

១៤_ អ្នកយកព័ត៌មាន អ្នករាយការណ៍ និងអ្នកធ្វើអត្ថាធិប្បាយ ត្រូវជៀសវាងសំដែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថតាមរយៈការលើកដាក់សំឡេង ឬឥរិយាបថជាក់ស្តែងផ្សេងទៀត ។

១៥_ ការផ្សព្វផ្សាយដែលមានលក្ខណៈបរិហារកេរ្តិ៍គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយនោះ មានសិទ្ធិប្តឹងពីបទបរិហារកេរ្តិ៍ ឬការ

ប្រមាថមើលងាយ ឬ/និងសុំឱ្យអ្នកផ្សព្វផ្សាយ ឬជនដែលបានបរិហារកេរ្តិ៍នោះ ធ្វើការកែតម្រូវ ឬបញ្ឈប់ការផ្សព្វផ្សាយនូវព័ត៌មានទាំងនោះ ។ ក្នុងករណីនេះ អ្នកផ្សព្វផ្សាយ ឬជនដែលបាន បរិហារកេរ្តិ៍ ត្រូវធ្វើការឆ្លើយតបទៅនឹងគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយនោះ ឬក៏ធ្វើការកែតំរូវលើការផ្សព្វផ្សាយព័ត៌មានឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ។ ការផ្សព្វផ្សាយ ព័ត៌មានឡើងវិញ អំពីខ្លឹមសារកែតំរូវ ត្រូវផ្សព្វផ្សាយក្នុងរយៈពេលប្រហែលគ្នានឹងរយៈពេល ដែលបានផ្សព្វផ្សាយបរិហារកេរ្តិ៍ ។

១៦- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ត្រូវបង្ហាញនូវកំរិតគុណភាពខ្ពស់ នៃវិជ្ជាជីវសារព័ត៌មាន និងត្រូវផ្តល់ព័ត៌មាន និងហេតុការណ៍ថ្មីៗ ឱ្យបានសមរម្យ ពិតប្រាកដ និងឥតលំអៀង ដើម្បីធានានូវយុត្តិធម៌ និងតុល្យភាពព័ត៌មានសម្រាប់គណបក្សនយោបាយ ដែលចូលរួមក្នុង ការបោះឆ្នោតទាំងអស់ ។

# ឧបសម្ព័ន្ធទី ៧

## សម្ភារ ឯកសារ ដែលត្រូវប្រគល់ជូន គជ/ខប
## សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល

១. បណ្ណសំគាល់សមាសភាព គកប/គករ ចំនួនប្រាំ (៥) សន្លឹក សម្រាប់ មួយ (១) ការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ (ត្រូវបញ្ជូនមុន) ។

២. បណ្ណសំគាល់តំណាងគណបក្សនយោបាយ ចំនួនម្ភៃ(២០) សន្លឹក សម្រាប់ មួយ (១) ការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ (ត្រូវបញ្ជូនមុន) ។

៣. ទម្រង់បែបបទលេខ ១០០២ សម្រាប់បំពេញកិច្ចសន្យាបម្រើការងាររបស់សមាសភាពនៃ គកប ចំនួនដប់ (១០) សន្លឹក សម្រាប់ មួយ (១) ការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ (ត្រូវបញ្ជូនមុន) ។

៤. ទម្រង់បែបបទ ១០០៤ សម្រាប់បំពេញបញ្ជីវត្តមាន និងប្រាក់កំរៃសមាសភាព នៃ គកប ចំនួនបី(៣)ច្បាប់ (ត្រូវបញ្ជូនមុន) ។

៥. តាំប៉ុងក្រហម ចំនួនមួយ(១)ប្រអប់ និងទឹកតាំប៉ុងពណ៌ក្រហម ចំនួនមួយ (១)ដប (ត្រូវបញ្ជូនមុន) ។

៦. បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌបី (៣) ច្បាប់ (ត្រូវបញ្ជូនមុន) ។

៧. បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងក្រុង ស្រុក ខណ្ឌពីរ (២) ច្បាប់ សម្រាប់បិទផ្សាយមួយ (១) ច្បាប់ និងរក្សាទុកមួយ (១) ច្បាប់ ។

៨. ទម្រង់បែបបទលេខ ១១១១ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទនីមួយៗ ចំនួនដប់ (១០) ច្បាប់ ។

៩. ទម្រង់បែបបទលេខ ១១០៦ ចំនួនប្រាំមួយ (៦) ច្បាប់សម្រាប់កត់ត្រា ការត្រួតពិនិត្យការបែងចែកសន្លឹកឆ្នោត ។

១០. ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារបោះឆ្នោត ចំនួនដប់ពីរ (១២) ច្បាប់ សម្រាប់មួយ (១) ការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ។

១១. ទម្រង់បែបបទលេខ ១១១៦តពស សម្រាប់បំពេញតារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចំនួនប្រាំ (៥) ច្បាប់

និងទម្រង់បែបបទលេខ ១១១៦តពខ សម្រាប់បំពេញតារាងត្រួតពិនិត្យបញ្ជាក់និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ចំនួនប្រាំ (៥) ច្បាប់ ។

១២. ទម្រង់បែបបទលេខ ១១១៣ សម្រាប់បំពេញការវាយតម្លៃសមាសភាព នៃ គកប ចំនួនដប់ (១០) ច្បាប់ សម្រាប់មួយ (១) ការិយាល័យបោះឆ្នោត ក្រុង ស្រុក ខណ្ឌ ។

១៣. ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្ដឹងតវ៉ា ឬប្ដឹងជំទាស់ ចំនួនបី (៣) ក្បាល ក្នុង១ក្បាល មានម្ភៃ(២០)ច្បាប់ ។

១៤. ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញសម្រង់សេចក្ដីសំរេចលើពាក្យបណ្ដឹងតវ៉ា ឬប្ដឹងជំទាស់ចំនួនប្រាំ(៥)ក្បាល ក្នុង១ក្បាលមានម្ភៃ(២០)ច្បាប់ ។

១៥. ស្រោមសំបុត្រធំពីរ (២) មធ្យមដប់ (១០) និងបន្ថែមស្រោមសំបុត្រមធ្យម ចំនួនគិតតាមសមាមាត្រនឹងស្បោង " ឃ " ដែលត្រូវប្រើនៅ គធ/ខប ។

១៦. ម៉ាស៊ីនគិតលេខមួយ(១)គ្រឿង ។

១៧. ប៊ិចហ្វឺតធំលុបលាងមិនជ្រះចំនួនពីរ(២)ដើម ។

១៨. ប៊ិចហ្វឺតធំពណ៌ខៀវសម្រាប់សរសេរលើក្ដារខៀនចំនួន ពីរ (២) ដើម ។

១៩. ប៊ិចខៀវចំនួនប្រាំ (៥) ដើម ។

២០. ស្បោង ឬកញ្ចប់សុវត្ថិភាព " ឃពិសេស " ចំនួនពីរ (២) ។

២១. ស្បោង ឬកញ្ចប់ " ឃ " ចំនួនគិតតាមសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ តិច ឬច្រើនក្នុងរាជធានី ខេត្ត ។

២២. សោឃ្លុំធំសម្រាប់ចាក់ឃ្លុំស្បោង ឬកញ្ចប់ " ឃ " ចំនួនស្មើនឹងស្បោង ឬកញ្ចប់ " ឃ " ។

២៣. ទម្រង់បែបបទលេខ ១១១៤ស ចំនួនប្រាំ (៥) ច្បាប់ សម្រាប់បំពេញលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងទម្រង់បែបបទលេខ ១១១៤ខ ចំនួនប្រាំ (៥) ច្បាប់ សម្រាប់បំពេញលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២៤. ទម្រង់បែបបទលេខ ១១១០ខ ចំនួនប្រាំ (៥) ច្បាប់ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ។

# ឧបសម្ព័ន្ធទី ៨

## សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឧបករណ៍ និងឯកសារផ្សេងទៀត ដែល គជ/ខប ត្រូវប្រគល់ជូន គកប នីមួយៗ

១. បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធចំនួនពីរ(២)ច្បាប់ ។

២. សន្លឹកឆ្នោតពីរ (២) កញ្ចប់ ដែលត្រូវបានវេចខ្ចប់ដោយឡែក និងអមដោយត្រា សម្ងាត់ពីរ (២) សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ដែលដាក់ក្នុងស្រោមសំបុត្រ បិទជិត ។

៣. ត្រាការិយាល័យបោះឆ្នោត ចំនួនមួយ (១) ។

៤. តាំប៉ុងពណ៌ក្រហមចំនួនពីរ (២) ប្រអប់ និងទឹកតាំប៉ុងពណ៌ក្រហមចំនួនមួយ (១) ដប ។

៥. ហិបឆ្នោតពីរ (២) ដែលមិនទាន់តម្លើង និងវេចខ្ចប់ដោយឡែក ។

៦. បន្ទប់សម្ងាត់ស័ង្កសីបីផ្នត់សម្រាប់គូសសន្លឹកឆ្នោតចំនួនពីរ (២) ដែលមិនទាន់តម្លើង និងវេចខ្ចប់ច្រកក្នុងការុងនីឡុងមួយដោយឡែក និងអមដោយស្កុតមួយ (១) ដុំ ។

៧. ទឹកខ្មៅលុបលាងមិនជ្រះចំនួនពីរ (២) ដប ។

៨. ផ្លាកសញ្ញា " ការិយាល័យបោះឆ្នោត" បោះពុម្ពលើកំណាត់ ផ្លាស្ទិកចំនួនមួយ(១) ។

៩. ប័ណ្ណប្រកាសហាមប្រើទូរស័ព្ទដៃនិងម៉ាស៊ីនថតចំនួនពីរ(២)សន្លឹក។

១០. ប៊ិចមានខ្សែសម្រាប់គូសសន្លឹកឆ្នោត និងប៊ិចធម្មតាសម្រាប់ គកប សរុបទាំងពីរមុខ ចំនួនប្រាំពីរ (៧) ដើម ។

១១. ប៊ិចហ្វឺតធំលុបមិនជ្រះ ចំនួនមួយ (១) ដើម ។

១២. ប៊ិចហ្វឺតធំចំនួន (១ មួយដើម ។

១៣. ជ័រការ៉ាវ ចំនួនមួយ (១) ដប ។

១៤. បន្ទាត់ជ័រមួយ (១) ដើម ។

១៥. ស្កុតថ្លាធំមួយ (១) ដុំ ។

១៦. ប្រដាប់ចោះសន្លឹកឆ្នោតមួយ (១) ។

១៧. កៅស៊ូកងមួយចំនួនសម្រាប់ចងសន្លឹកឆ្នោតតាមគណបក្សនយោបាយ ។

១៨. ស្រោមសំបុត្រធំចំនួនពីរ (២) មធ្យមចំនួនដប់ប្រាំបី (១៨) និងតូចចំនួនបួន (៤) ។

១៩. ក្រដាសស្ដើងសម្រាប់បិទពាសសន្ទះបិទប្រឡោះស៊កសន្លឹកឆ្នោត ចំនួនដប់ពីរ (១២) សន្លឹក ។

២០. ក្រដាសរ៉ាមសម្រាប់សរសេរសំគាល់លេខការិយាល័យបោះឆ្នោត បិទលើហិបឆ្នោត និងសម្រាប់ប្រើប្រាស់ការងារផ្សេងៗ ចំនួនម្ភៃ (២០) សន្លឹក ។

២១. ផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ចំនួនពីរ(២)ផ្ទាំង ។

២២. ផ្ទាំងក្រដាសធំសម្រាប់កត់ត្រាសំឡេងឆ្នោតពីរ (២) សន្លឹក ។

២៣. ទម្រង់បែបបទលេខ ១១០១ស ចំនួនប្រាំមួយ (៦) ច្បាប់ ទម្រង់បែបបទលេខ ១១០១ខ ចំនួនប្រាំមួយ (៦) ច្បាប់សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត ។

២៤. ទម្រង់បែបបទលេខ ១១០២ស ចំនួនប្រាំមួយ (៦) ច្បាប់ ទម្រង់បែបបទលេខ ១១០២ខ ចំនួនប្រាំមួយ (៦) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

២៥. ទម្រង់បែបបទលេខ ១១០៤ស និងទម្រង់បែបបទលេខ ១១០៤ខ សម្រាប់ចម្លងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតចំនួនម្ភៃ (២០) សន្លឹក ។

២៦. ទម្រង់បែបបទលេខ ១១០៧ ចំនួនប្រាំមួយ (៦) ច្បាប់ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត ។

២៧. ទម្រង់បែបបទលេខ ១១០៨ស ចំនួនបួន (៤) ច្បាប់ និងទម្រង់បែបបទលេខ ១១០៨ខ ចំនួនបួន (៤) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោត ។

២៨. ទម្រង់បែបបទលេខ ១១១២ ចំនួនបួន (៤) ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យសម្ភារឯកសារបោះឆ្នោត ដែល គកប បានទទួល ។

២៩. ទម្រង់បែបបទលេខ ១១១៥ ចំនួនពីរ (២) ច្បាប់ សម្រាប់ស្រង់វត្តមានតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងអំឡុងពេលនៃការរាប់សន្លឹកឆ្នោត ។

៣០. ទម្រង់បែបបទលេខ ១២០២ ចំនួនពីរ (២) ក្បាល ក្នុង១ក្បាលមានម្ភៃ (២០) ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។

៣១. ស្បោងផ្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតដែលមិនបានប្រើ និងគល់សន្លឹកឆ្នោតដែលប្រើហើយ ចំនួនពីរ (២) ។

៣២. ស្បោងផ្លាស្ទិកដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការចំនួនពីរ (២) ។

៣៣. ស្បោង ឬកញ្ចប់សុវត្ថិភាព " ក " សម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត និងសម្ភារឯកសារបោះឆ្នោតចំនួនពីរ (២) ។

៣៤. ស្បោង ឬកញ្ចប់ " ខ " សម្រាប់ដាក់កញ្ចប់សុវត្ថិភាព " ក " និងសម្ភារឯកសារបោះឆ្នោតចំនួនពីរ (២) ។

៣៥. សោឃ្លុំជ័រមានលេខសម្រាប់បិទគំរបខាងក្នុង និងខាងក្រៅនៃហិបឆ្នោតចំនួនប្រាំមួយ (៦) ។

៣៦. សោឃ្លុំជ័រសម្រាប់ឃ្លុំបិទមាត់កញ្ចប់ " ខ " ចំនួនពីរ (២) ។

# ឧបសម្ព័ន្ធទី ៩

## បទល្មើស និងទណ្ឌកម្មដែលជាកម្មវត្ថុនៃការផ្តន្ទាទោស ក្នុងជំពូកទី ៤ នៃ ច.ប.ក និងតាមនីតិវិធី ជំពូកទី ១១ នៃ ច.ប.ត.រ

**ជំពូកទី ៤ នៃ ច.ប.ក**

**មាត្រា ៨៤.-**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤៩ នៃច្បាប់នេះ ។ ក្នុងករណីដែលនៅពុំព្រមអនុវត្តតាម ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (០៥) ឆ្នាំ លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ និង/ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ដល់ដប់លាន (១០.០០០.០០០) រៀល ។

**មាត្រា ៨៥.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត និង/ឬលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (០៥) ឆ្នាំ ចំពោះសមាជិកគណៈកម្មាធិការជាតិ សមាជិកគណៈកម្មការរាជធានី សមាជិកគណៈកម្មការខេត្ត សមាជិកគណៈកម្មការក្រុង ស្រុក ខណ្ឌរៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬ ប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

**មាត្រា ៨៦.-**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១០០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ក្នុងករណីដែលមិនព្រមអនុវត្តតាមការព្រមាននេះ ត្រូវឃាត់ខ្លួន និងដកហូតអាវុធសម្រាប់រយៈពេលសែសិបប្រាំបី (៤៨) ម៉ោង ដោយភ្នាក់ងារមានសមត្ថកិច្ច និងផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ដល់ហាសិបលាន (៥០.០០០.០០០) រៀល ។

ប្រសិនបើជនល្មើសនោះ ជាមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ នគរបាលជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន ដើម្បីដាក់វិន័យរដ្ឋបាលចាប់ពីការដាក់ឱ្យនៅទំនេរ ដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែងយោលទៅតាមកម្រិតនៃបទល្មើស
- លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាសមាជិក ឬជាបុគ្គលិករបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ គណៈកម្មការរាជធានី ឬ គណៈកម្មការខេត្ត ឬគណៈកម្មការក្រុង ស្រុក ខណ្ឌរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារភ្លាម និងមិនឱ្យចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ សម្រាប់រយៈពេលដប់ (១០)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ៨៧.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត និង/ឬត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំពោះជនណា ឬគណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៨៥ នៃច្បាប់នេះ ឬមាត្រា ៧៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ៨៨.-**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៧ និងបទប្បញ្ញត្តិនៃមាត្រា ៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ក្នុងករណីដែលនៅតែពុំព្រមអនុវត្តតាម ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (០៥)ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាលចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់បណ្តេញចេញពីមុខតំណែង និង/ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀលដល់ពីរលាន (២.០០០.០០០) រៀល ។

**ជំពូកទី ១១ នៃ ច.ប.ត.រ**

**មាត្រា ១២៤.-ថ្មី**

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឬ/និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា និងគណបក្សនយោបាយណាដែលបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម ៖

- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យមិនឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។
- ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។
- ធ្វើការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំធ្វើសម្បថឱ្យគេបោះឆ្នោតឱ្យគណបក្សនយោបាយរបស់ខ្លួន ឬគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត ។
- ប្រើកម្លាំង ឬអំពើហិង្សាដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ។
- រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់ ។
- ប្រើកម្លាំង ឬអំពើហិង្សា ឬបំភិតបំភ័យ ប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន ។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន ។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស ។

**មាត្រា ១២៦._ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ដល់ហាសិបលាន (៥០.០០០.០០០) រៀល និងត្រូវបញ្ឈប់ពីការងារបោះឆ្នោតជារៀងរហូត ចំពោះភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មាធិការជាតិ ឬភ្នាក់ងារ ឬសមាជិក ឬបុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតណាដែលប្រព្រឹត្តល្មើសនឹងវាក្យខ័ណ្ឌទី ២ មាត្រា ១២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ១២៨.‑ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែង ចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៩ថ្មី នៃច្បាប់នេះ ។

**មាត្រា ១២៩.‑ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ដល់ដប់លាន (១០.០០០.០០០)រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលបង្គាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបំរើការងារក្នុងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនប្រព្រឹត្តល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រានេះ ។

**មាត្រា ១៣០.‑ថ្មី**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ/និងត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណាដែលមានចេតនាធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបំរើការងារជាមួយគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេលដប់ (១០)ឆ្នាំ គិតចាប់ ពីសម័យបោះឆ្នោតនេះតទៅ ។

ប្រសិនបើជនល្មើសនោះជាបេក្ខជនវិញ ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោល បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

# ឧបសម្ព័ន្ធទី ១០

## បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយបណ្តឹង

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខ ក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ជនគ្រប់រូប ដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ ៖

១. ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ

២. ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ដូចជា ៖

- ការដើរឆ្លងកាត់ ឬដើរចេញ-ចូលរហោតរហូត ដោយគ្មានការអនុញ្ញាត
- ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ ។

៣. ហាមយកក្មេងអាយុក្រោម ១៨ ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ។

៤. ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ។

៥. ហាមថតរូប និងអាត់សំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៦. ហាមប្រើប្រាស់ទូរស័ព្ទដៃ វិទ្យុទាក់ទងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ។

៧. ក្នុងករណីជនណាម្នាក់ ឬច្រើននាក់បង្កភាពណាមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ យល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយនៃការប្រជុំផ្សះផ្សា ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ អាចបណ្តេញជននោះ ឬទាំងនោះចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

# ឧបសម្ព័ន្ធទី ១១

## ខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំធ្វើឡើងដោយលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិ នៅទីកន្លែងបើកអង្គប្រជុំផ្សះផ្សា ឬសវនាការ នីមួយៗ ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជានៅចំពោះមុខវត្ថុសក្តិសិទ្ធិ ដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មកលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម ។

ក្រោយពីធ្វើសម្បថរួច លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ បញ្ជាក់ថា បានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណាត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង ។

## ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្របាមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវីវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ត្បិតគូភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និង បានចាំ ដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យយកអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់ តាមពិត ។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និង បានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និង បារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំបីរយជាតិ ។

បើអ្នកណាឆ្លើយឱ្យការណ៍ ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិ សាលោហិត មិនសម គំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ ហូរហៀរ មានញាតិផៅគោរព ស្រឡាញ់រាប់អាន លុះអនាគតជាតិ បានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តីបំណងប្រាថ្នា កុំបីអាក់ខានឡើយ ។

# ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និង បានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និង បារមីដ៏សក្ដិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និង ស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្ដីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសន្ដាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៣

# ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី ២ ឆ្នាំ២០១៤

| ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោតមុនពេលចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ |
| ការចុះឈ្មោះបោះឆ្នោត ការបញ្ជាក់តាមឋានានុក្រម និងការបញ្ជូនមក គ.ជ.ប | ថ្ងៃទី ១៣ ខែ កុម្ភៈ - ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១៤ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង នៅតាមសាលាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត | ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៤ |
| ការប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូង និងការដោះស្រាយនៅ គធ/ខប | ថ្ងៃទី ២៦ ខែ មីនា - ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤ |
| ការប្តឹងតវ៉ា ឬជំទាស់លើបញ្ជីបោះឆ្នោតដំបូង និងការដោះស្រាយនៅ គ.ជ.ប | ថ្ងៃទី ០៣ - ១២ ខែ មេសា ឆ្នាំ ២០១៤ |
| ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត | ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៤ |
| ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះនៅ គធ/ខប | ថ្ងៃទី ២៧ ខែ កុម្ភៈ - ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ |
| ការប្តឹងតវ៉ាទៅនឹងការបដិសេធសុំចុះបញ្ជីគណបក្សទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ថ្ងៃ | ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងតវ៉ា ដោយ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ថ្ងៃ បន្ទាប់ពីទទួលបណ្តឹង | ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៤ ( ថ្ងៃចុងក្រោយ ) |
| ការបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ | ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៤ ( ថ្ងៃចុងក្រោយ ) |
| ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការនៅការិយាល័យបោះឆ្នោត និងតាមមណ្ឌល | ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៤ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោតនៅសាលាឃុំ សង្កាត់ និងតាមមណ្ឌល | |
| ការឃោសនាបោះឆ្នោត | ថ្ងៃទី ០២ - ១៦ ខែ ឧសភា ឆ្នាំ ២០១៤ |
| ការបោះឆ្នោតការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៅការិយាល័យបោះឆ្នោត | ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៤ |
| ការប្តឹងតវ៉ាពីការសម្រេចរបស់ប្រធានការិ.បោះ/រាប់សន្លឹកឆ្នោត ឬពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតទៅ គធ/ខប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេច ឬបិទផ្សាយ | ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយ គធ/ខប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីទទួលបណ្តឹង | ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ ( ថ្ងៃចុងក្រោយ ) |
| ការបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមមណ្ឌលនីមួយៗក្នុងរាជធានី ខេត្ត | ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ |
| ការប្តឹងតវ៉ាពីការសម្រេចរបស់ គធ/ខប ឬពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមមណ្ឌលនីមួយៗទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេច ឬបិទផ្សាយ | ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤ ( ថ្ងៃចុងក្រោយ ) |
| ការដោះស្រាយបណ្តឹងដោយ គ.ជ.ប រយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបណ្តឹង | ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤ ( ថ្ងៃចុងក្រោយ ) |
| ការបោះឆ្នោតសាជាថ្មី ក្នុងរយៈពេល ៨ថ្ងៃ ក្រោយការសម្រេចរបស់ គ.ជ.ប ( ប្រសិនបើមាន ) | ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៤ ( ថ្ងៃចុងក្រោយ ) |
| ការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត ( ករណីគ្មានការបោះឆ្នោតសាជាថ្មី ) | ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ( ថ្ងៃចុងក្រោយ ) |

បោះពុម្ពដោយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត